IFL

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
វិទ្យាស្ថានភាសាបរទេស

# អរិយធម៌ខ្មែរ



សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

ខែមីនា ឆ្នាំ២០១៣

www.elibraryofcambodia.org

www.elibraryofcambodia.org

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
វិទ្យាស្ថានភាសាបរទេស

# អរិយធម៌ខ្មែរ

## សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
15564/13
2/5
បណ្ណាល័យជាតិ

អ្នករៀបរៀង៖

លោក ងឹម ហួរ
លោក វ៉ាន់ ម៉ុន
លោក ហង់ ពៅ
អ្នកស្រី ជា ផល្លី
បណ្ឌិត វង្ស មេង
អ្នកស្រី សំរិត សុទ្ធា
លោក យៀង វីរបុត្រ
លោក ងាវ ស៊ីជា

ខែមីនា ឆ្នាំ២០១៣

www.elibraryofcambodia.org
National Library of Cambodia
00030241

www.elibraryofcambodia.org

# មាតិកា


| ចំណងជើង | ទំព័រ |
|---|---|
| ជំពូក ១៖ សេចក្ដីផ្ដើម | ១ |
| ១- បញ្ហាអរិយធម៌ និង វប្បធម៌ | ១ |
| ១.១- អរិយធម៌ | ១ |
| ១.២- វប្បធម៌ | ៥ |
| ២- លក្ខណៈរបស់វប្បធម៌ | ៥ |
| ២.១- វប្បធម៌មានលក្ខណៈជានិមិត្តសញ្ញា | ៦ |
| ២.២- វប្បធម៌មានលក្ខណៈជាការរៀនសូត្រ | ៧ |
| ២.៣- វប្បធម៌មានលក្ខណៈជាការប្រើប្រាស់រួមគ្នា | ៨ |
| ២.៤- វប្បធម៌មានលក្ខណៈជាការសម្រប | ៩ |
| ៣- ប្រភេទនៃវប្បធម៌ | ៩ |
| ៤- ការរីកចម្រើននិងការធ្លាក់ចុះនៃអរិយធម៌ | ១០ |
| ៥- ការរីកចម្រើននិងការធ្លាក់ចុះនៃអរិយធម៌ខ្មែរ | ១១ |
| ៥.១- បុព្វហេតុនៃការរីកចម្រើននៃអរិយធម៌អង្គរ | ១១ |
| ៥.២- បុព្វហេតុនៃការធ្លាក់ចុះនៃអរិយធម៌អង្គរ | ១៣ |
| ៦- ទំនាក់ទំនងនៃអរិយធម៌ខ្មែរជាមួយបរទេស | ១៤ |
| ៧- មូលធម៌ខ្មែរ-មន | ១៥ |
| ៨- ដើមកំណើតជាតិខ្មែរ | ១៥ |
| ជំពូក ២៖ សាសនា | ១៧ |
| និយមន័យ "សាសនា" | ១៧ |
| ជំនឿរបស់ជនជាតិខ្មែរមុនសាសនាឥណ្ឌាហូរចូល | ១៨ |
| ១- និយមន័យ "អ្នកតា" | ១៨ |


www.elibraryofcambodia.org

២- ជំនឿលើអ្នកតា ........................................ ១៩

លទ្ធិសាសនាព្រាហ្មណ៍ក្នុងសង្គមខ្មែរ ........................................ ២២
១- ប្រភពនិងវត្តមានសាសនាព្រាហ្មណ៍ក្នុងសង្គមខ្មែរ ........................................ ២២
២- ដំណាក់កាលវិវឌ្ឍនន៍នៃព្រហ្មញ្ញសាសនា ........................................ ២៥
២.១- អំពីវេទនិយម ........................................ ២៥
២.២- ព្រាហ្មណ៍និយម ........................................ ២៨
២.៣- ហិណ្ឌូនិយម ........................................ ៤៥
៣- ឥទ្ធិពលសាសនាព្រាហ្មណ៍ក្នុងសង្គមខ្មែរ ........................................ ៤៧
៣.១- ផ្នែកជំនឿ ........................................ ៤៨
៣.២- ផ្នែកសិល្បៈ ........................................ ៤៩
៣.៣- ផ្នែកអក្សរសិល្ប៍ ........................................ ៤៩
៣.៤- ផ្នែកទំនៀមទម្លាប់ប្រពៃណី ........................................ ៤៩

លទ្ធិព្រះពុទ្ធសាសនា ........................................ ៥១
១- សេចក្តីផ្តើម ........................................ ៥១
២- ពុទ្ធប្រវត្តិសង្ខេប ........................................ ៥២
៣- គម្ពីរព្រះត្រៃបិដក ........................................ ៥៥
៣.១- វិនយបិដក ........................................ ៥៦
៣.២- សុត្តន្តបិដក ........................................ ៥៦
៣.៣- អភិធម្មបិដក ........................................ ៥៧
៤- អរិយសច្ចៈ ........................................ ៥៨
៤.១- ទុក្ខអរិយសច្ចៈ ........................................ ៥៨
៤.២- សមុទយអរិយសច្ចៈ ........................................ ៦០
៤.៣- និរោធអរិយសច្ចៈ ........................................ ៦០
៤.៤- មគ្គអរិយសច្ចៈ ........................................ ៦១



www.elibraryofcambodia.org

៥- ការបែងចែកនៃព្រះពុទ្ធសាសនា ............ ៦៣
៥.១- និកាយនៃពុទ្ធសាសនានៅកម្ពុជា ............ ៦៣
៥.២- ភាពខុសគ្នានៃនិកាយហីនយាន និង និកាយមហាយាន ............ ៦៦
៦- វិវឌ្ឍន៍ និង ឥទ្ធិពលព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា ............ ៦៩
៦.១- សម័យបុរេប្រវត្តិ ............ ៦៩
៦.២- សម័យនគរភ្នំ ............ ៦៩
៦.៣- សម័យចេនឡា ............ ៧០
៦.៤- សម័យអង្គរ ............ ៧០
៦.៥- សម័យក្រោយអង្គររហូតដល់សព្វថ្ងៃ ............ ៧៣

ជំពូក ៣៖ សិល្បៈ ............ ៧៦
សិល្បៈស្ថាបត្យកម្មខ្មែរបុរាណសម័យមុនអង្គរ និង អង្គរ ............ ៧៦
១- និយមន័យ ............ ៧៦
២- វិវឌ្ឍន៍នៃសិល្បៈស្ថាបត្យកម្មខ្មែរ ............ ៧៦
២.១- សិល្បៈស្ថាបត្យកម្មខ្មែរសម័យមុនអង្គរ ............ ៧៧
២.២- សិល្បៈស្ថាបត្យកម្មខ្មែរសម័យអង្គរ ............ ៨៦
៣- រចនាសម្ព័ន្ធ និង សំណង់ប្រាសាទខ្មែរ ............ ១០៤
៣.១- រចនាសម្ព័ន្ធ ............ ១០៤
៣.២- ប្រភេទប្រាសាទខ្មែរ ............ ១០៦
៣.៣- មុខងារនៃប្រាសាទខ្មែរ ............ ១០៧
៣.៤- តម្លៃនៃស្ថាបត្យកម្មខ្មែរ ............ ១០៧

សិល្បៈចម្លាក់ខ្មែរ ............ ១២៨
១- មុខងារនៃចម្លាក់ ............ ១២៨
២- ប្រភេទចម្លាក់ ............ ១២៨
២.១- ចម្លាក់លើប ............ ១២៨


www.elibraryofcambodia.org

២.២- ចម្លាក់លៀន ............ ១២៨
២.៣- ចម្លាក់លោត ............ ១២៨
៣- ប្រធាននៃចម្លាក់ ............ ១២៩
៣.១- ពុទ្ធប្បដិមា ............ ១២៩
៣.២- ព្រះស្តូប-ព្រះចេតិយ ............ ១៣១
៣.៣- ព្រះពោធិសត្វ ............ ១៣១
៣.៤- សិវលិង្គ ............ ១៣២
៣.៥- ព្រះនារាយណ៍ ............ ១៣៣
៣.៦- ព្រះហរិហរៈ ............ ១៣៣
៣.៧- អប្សរា ............ ១៣៣
៣.៨- សត្វ ............ ១៣៣
សិល្បៈតន្ត្រីខ្មែរ ............ ១៣៩
១- ភ្លេងពិណពាទ្យ ............ ១៣៩
២- ភ្លេងខ្មែរ ............ ១៤១
៣- ភ្លេងអារក្ស ............ ១៤២
៤- ភ្លេងស្គរឈ្នះឬស្គរយោន ឬក៏ ភ្លេងក្លងខែកឬក្លងឆ្នះ ............ ១៤៣
៥- ភ្លេងទាំមីង ឬ ធម្មមីង ឬក៏ ត្រៃលក្ខណ៍ ............ ១៤៤
៦- ភ្លេងឆៃយ៉ាំ ............ ១៤៥
៧- របាំមហោរី ............ ១៤៦
សិល្បៈរបាំ ............ ១៤៨
១- របាំក្បាច់បុរាណខ្មែរ ............ ១៤៨
២- របាំប្រពៃណីខ្មែរ ............ ១៤៨
២.១- របាំត្រុដិ ............ ១៥០
២.២- របាំស្នែងទន្សោង ............ ១៥៦



www.elibraryofcambodia.org

២.៣- របាំគោះអង្រែ ..................... ១៥៨
២.៤- របាំក្ងោកប៉ៃលិន ..................... ១៥៩
របាំប្រជាប្រិយខ្មែរ ..................... ១៦២
ជំពូក ៤៖ ជំនឿ ទំនៀមទម្លាប់ និង ប្រពៃណីខ្មែរ ..................... ១៦៨
ជំនឿ ..................... ១៦៨
១- ជំនឿលើព្រលឹង ..................... ១៦៩
១.១- ជំនឿលើព្រលឹងម្ដាយឪពុក ..................... ១៦៩
១.២- ជំនឿលើព្រលឹងមេបា ..................... ១៦៩
១.៣- ជំនឿលើដូនជំបូរ (ឬឈ្មួរ) ..................... ១៧០
១.៤- ជំនឿលើគ្រូបាធ្យាយ ឬគ្រូកំណើត ..................... ១៧០
១.៥- ជំនឿលើអ្នកដូនអ្នកតា ..................... ១៧១
២- ជំនឿលើព្រះ ..................... ១៧២
៣- ជំនឿលើទេវតា ..................... ១៧២
៤- ជំនឿលើព្រះភូមិ និង ជំនាងផ្ទះ ..................... ១៧៣
៥- ជំនឿលើបារមី ..................... ១៧៣
៦- ជំនឿលើរបៀន (ឬមន្តអាគមគាថា) ..................... ១៧៤
៧- ជំនឿលើការរំលឹកគុណគ្រូ និង គ្រាប់តាមដំបូន្មានគ្រូ ..................... ១៧៤
៨- ជំនឿលើគ្រូទាយ ..................... ១៧៤
៩- ជំនឿលើសិរីសួស្ដី ..................... ១៧៥
១០- ជំនឿលើវត្ថុស័ក្ដិសិទ្ធិ ..................... ១៧៦
១១- ជំនឿលើថ្នាំស័ក្ដិសិទ្ធិ ..................... ១៧៦
១២- ជំនឿលើសត្វ ..................... ១៧៧
១៣- ជំនឿលើសកម្មភាពផ្សេងៗរបស់សត្វ ..................... ១៧៧
១៤- ជំនឿលើខ្លែង ..................... ១៧៨
១៥- ជំនឿលើទីងមោង ..................... ១៧៨



www.elibraryofcambodia.org

ប្រពៃណីកោរជុក ........................................ ១៨០
១- ប្រវត្តិនៃពិធីកោរជុក ........................................ ១៨០
២- លក្ខខណ្ឌនៃពិធីកោរជុក ........................................ ១៨២
៣- គោលបំណងនៃពិធីកោរជុក ........................................ ១៨២
៤- ការប្រព្រឹត្តទៅនៃពិធីកោរជុក ........................................ ១៨២

ប្រពៃណីចូលម្លប់ ........................................ ១៨៥

ប្រពៃណីបំបួសនាគ ........................................ ១៨៨
១- ប្រវត្តិនៃពិធីបំបួសនាគ ........................................ ១៨៨
២- គោលបំណងនៃពិធីបំបួសនាគ ........................................ ១៨៩
៣- ការប្រព្រឹត្តទៅនៃពិធីបំបួសនាគ ........................................ ១៨៩

ប្រពៃណីទាក់ទងនឹងកំណើត ........................................ ១៩២
១- មុនពេលសម្រាល ........................................ ១៩៣
២- ពេលសម្រាល ........................................ ១៩៤
៣- ក្រោយពេលសម្រាល ........................................ ១៩៥

ប្រពៃណីរៀបអាពាហ៍ពិពាហ៍ខ្មែរ ........................................ ១៩៨
១- ប្រភព និង ប្រវត្តិពិធីផ្សេងៗនៃអាពាហ៍ពិពាហ៍ខ្មែរ ........................................ ១៩៨
២- ទម្រង់ផ្សេងៗនៃអាពាហ៍ពិពាហ៍ខ្មែរ ........................................ ២០១
២.១- អាពាហ៍ពិពាហ៍បែបបុរាណ ........................................ ២០២
២.២- អាពាហ៍ពិពាហ៍បែបទំនើប ........................................ ២១១
២.៣- អាពាហ៍ពិពាហ៍បែបលើកត្រៃ........................................ ២១២
២.៤- អាពាហ៍ពិពាហ៍បែបកំព្រាគូ ........................................ ២១៣
២.៥- អាពាហ៍ពិពាហ៍បែបសែន ........................................ ២១៤
២.៦- អាពាហ៍ពិពាហ៍បែបផ្តាច់ការ ឬ សមូហភាព ........................................ ២១៤


www.elibraryofcambodia.org

ប្រពៃណីពេលមានមនុស្សស្លាប់ ........ ២១៨
១- ពេលឈឺធ្ងន់ ........ ២១៩
២- ពេលស្លាប់ ........ ២១៩
៣- ពេលហែសពទៅបូជា ........ ២២០
៤- ពេលបូជាសព ........ ២២២
៥- ទក្ខិណានុប្បទានកម្ម ........ ២២៣
៥.១- បុណ្យ ៧ ថ្ងៃ ........ ២២៣
៥.២- បុណ្យ ១០០ ថ្ងៃ ........ ២២៣
៥.៣- បុណ្យខួប ........ ២២៤
៦- អត្ថន័យខ្លះៗនៃកិច្ចក្នុងពិធីបុណ្យសពខ្មែរ ........ ២២៤
៦.១- ពិធីសណ្តោងស្បូវភ្លាំង ........ ២២៤
៦.២- ពិធីប្រាយលាជ ........ ២២៤
៦.៣- ពិធីកៀសចិញ្ចៀនត្បូង ........ ២២៤
៦.៤- ពិធីបួសមុខភ្លើង ........ ២២៥
៦.៥- ពិធីប្រែរូប ........ ២២៥
ប្រពៃណីបុណ្យមាឃបូជា ........ ២២៥
ប្រពៃណីបុណ្យចូលឆ្នាំខ្មែរ ........ ២២៨
ប្រពៃណីបុណ្យពិសាខបូជា ........ ២៣៣
ព្រះរាជពិធីច្រត់ព្រះនង្គ័ល ........ ២៣៤
១- អត្ថន័យ ........ ២៣៤
២- កំណើតនៃព្រះរាជពិធីនេះ ........ ២៣៤
៣- ទីកន្លែងប្រារព្ធព្រះរាជពិធីច្រត់ព្រះនង្គ័ល ........ ២៣៥
៤- ពេលវេលាច្រត់ព្រះនង្គ័ល ........ ២៣៥
៥- គ្រឿងប្រដាប់ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល ........ ២៣៥



www.elibraryofcambodia.org

៦- ព្រះគោដែលប្រើក្នុងពិធី ........ ២៣៦
៧- អ្នកតំណាងព្រះមហាក្សត្រពេលច្រត់ព្រះនង្គ័ល ........ ២៣៦
៨- ការតែងខ្លួនសម្រាប់អ្នកតំណាងព្រះរាជា ........ ២៣៧
៩- ក្បួនហែច្រត់ព្រះនង្គ័ល ........ ២៣៨
១០- ការផ្សងគោឧសភរាជ ........ ២៣៨

ប្រពៃណីបុណ្យចូលព្រះវស្សា ........ ២៤០

ប្រពៃណីបុណ្យកាន់បិណ្ឌ និង ភ្ជុំបិណ្ឌ ........ ២៤២

ប្រពៃណីបុណ្យចេញវស្សា ........ ២៤៦

ប្រពៃណីបុណ្យកឋិន ........ ២៤៨
១- ប្រភពនៃកឋិនទាន ........ ២៤៨
២- បុគ្គលទទួលផលពីកឋិនទាន ........ ២៤៩
៣- កឋិនទានជាទានពិសេស ........ ២៤៩
៤- កិច្ចធ្វើសំពត់កឋិន ........ ២៥០
៥- កិច្ចសុំវត្តធ្វើកឋិន ........ ២៥១
៦- កិច្ចផ្សាយដំណឹងបុណ្យកឋិន ........ ២៥១
៧- កិច្ចសូត្រមន្តកឋិន ........ ២៥១
៨- កិច្ចសូត្រសុន្ទរកថា ........ ២៥៣
៩- កិច្ចវេរសំពត់កឋិន ........ ២៥៤
១០- កិច្ចឧទ្ទិសផល ........ ២៥៥

ប្រពៃណីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និង សំពះព្រះខែ ........ ២៥៦
១- ប្រពៃណីបុណ្យអុំទូក ........ ២៥៦
២- ប្រពៃណីបុណ្យបណ្តែតប្រទីប ........ ២៥៨
៣- ប្រពៃណីបុណ្យអកអំបុក-សំពះព្រះខែ ........ ២៥៩

គន្ថនិទ្ទេស ........ ២៦១



www.elibraryofcambodia.org

# អារម្ភកថា

អរិយធម៌ជាមុខវិជ្ជាមួយយ៉ាងសំខាន់សម្រាប់អ្នកសិក្សា ពីព្រោះអរិយធម៌គឺជាការសិក្សាអំពី សង្គមមួយនៅក្នុងអតីតកាលនិងបច្ចុប្បន្នមួយចំនួន ដោយមានភាពខុសប្លែកគ្នាខាងប្រវត្តិសាស្ត្រ និង ខាងវប្បធម៌ ។ នៅក្នុងទិដ្ឋភាពនេះ ប្រវត្តិវិទូប្រើប្រាស់បច្ចេកសព្ទ "អរិយធម៌" ជាជាងពាក្យថា "ប្រទេស" ដោយសារពាក្យ *អរិយធម៌* ជាឯកតាសំខាន់នៃប្រភពដើមថ្មីៗដែលមានការទាក់ទងគ្នា ។

ការសិក្សាអរិយធម៌នៅទីនេះនឹងរំលេចអំពីបញ្ហាពាក្យ "វប្បធម៌" និង "អរិយធម៌" លក្ខណៈនៃវប្បធម៌ ប្រភេទវប្បធម៌ បុព្វហេតុនៃការរីកចម្រើន និងការធ្លាក់ចុះនៃអរិយធម៌មួយ បុព្វហេតុនៃការរីកចម្រើននិងធ្លាក់ចុះដុនដាបមកវិញនៃអរិយធម៌អង្គរ វប្បធម៌ខ្មែរ-មន ដើមកំណើតជាតិខ្មែរ ព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា ស្ថាបត្យកម្ម ចម្លាក់ តន្ត្រី ជំនឿ ទំនៀមទម្លាប់-ប្រពៃណី ។

ការសិក្សាអំពីអរិយធម៌ក៏អាចផ្តល់ផលប្រយោជន៍ផងដែរដល់អ្នកសិក្សា ពោលគឺឲ្យអ្នកសិក្សាស្គាល់អត្តសញ្ញាណខ្លួន ដើម្បីកុំឲ្យមានភាន់ច្រឡំ ព្រមទាំងដើម្បីផ្សព្វ-ផ្សាយអរិយធម៌របស់ខ្លួន ឲ្យពិភពលោកបានស្គាល់ថាខ្មែរមានអរិយធម៌មួយជាជាតិរបស់ខ្លួន។ ការសិក្សាអរិយធម៌ក៏ជាការបើកចិត្តទូលាយទៅរកបរិបទសង្គមថ្មីមួយនៃពិភពលោក សម្រាប់ខ្លួនយើងនិងសម្រាប់សង្គមជាតិទាំងមូល។ ទន្ទឹមគ្នានេះ យើងក៏ត្រូវចេះច្នៃប្រឌិតអ្វីៗជាបរទេសឲ្យមកជាខ្មែរ ដើម្បីសម្របខ្លួនទៅតាមវប្បធម៌និងបរិបទសង្គមខ្មែរ។



www.elibraryofcambodia.org

www.elibraryofcambodia.org

# ជំពូកទីមួយ
# សេចក្ដីផ្ដើមអំពីវប្បធម៌-អរិយធម៌

ការសិក្សាអរិយធម៌មានវិសាលភាពទូលំទូលាយណាស់។ នៅក្នុងបរិបទបស្ចិម-ប្រទេស ការសិក្សាអរិយធម៌គឺជាមុខវិជ្ជាមួយនៃការសិក្សាវប្បធម៌ ពីព្រោះថា ការសិក្សាវប្បធម៌គឺទំហំនៃការសិក្សាមុខវិជ្ជានរវិទ្យា ចំណែកឯពាក្យអរិយធម៌ជំនួសដោយការ-សិក្សាវប្បធម៌ទៅវិញ នៅក្នុងមុខវិជ្ជាសង្គមវិទ្យា ដូចលោក វ៉ាន់នី កាអុន អះអាងថា៖ «***សង្គមវិទូសម័យថ្មីប្រើពាក្យវប្បធម៌នេះ ជំនួសពាក្យអារ្យធម៌តែម្ដង។***»[1] នៅក្នុងបរិបទប្រទេសកម្ពុជា ការសិក្សាអរិយធម៌ច្រើនតែផ្អែកលើទ្រឹស្ដីរបស់លោក កេង វ៉ាន់សាក់ ដែលបានបែងចែកអរិយធម៌ជាពីរគឺ វប្បធម៌ និង សង្គមធម៌ ។

ដោយឈរលើការវិវឌ្ឍថ្មីៗផ្នែកទ្រឹស្ដីផងនិងការអនុវត្តជាក់ស្ដែង នៅក្នុងបរិបទសាកលលោកនិងកម្ពុជាផងនោះ ការសិក្សានៅទីនេះត្រូវបម្រើទាំងទ្រឹស្ដីនិងបទ-ពិសោធន៍ ដើម្បីឲ្យអ្នកសិក្សាយល់ដឹងនិងពិចារណាឲ្យទាន់សាកលលោក ហើយ យើងក៏មិនបដិសេធគំនិតរៀមច្បងចាស់ៗរបស់យើងដែរ ដោយគ្រាន់តែវិភាគនិងធ្វើការ-ពិចារណាដោយតក្កភាពតែប៉ុណ្ណោះ។

## ១- បញ្ហា«អរិយធម៌»និង«វប្បធម៌»

### ១.១- អរិយធម៌

ទស្សនៈរួមរបស់លោកស្រី ត្រឹង ងា បានពន្យល់ថា៖ «*អរិយធម៌សម្គាល់នូវការរស់នៅ ការរៀបចំជីវភាពនៃសង្គមមនុស្សឲ្យបានប្រកបទៅដោយសេចក្ដីសុខចម្រើនលូតលាស់ តាមវិធីផ្លូវចិត្តនិងផ្លូវកាយ។ ដូចនេះ គោលដៅនៃអរិយធម៌គឺ សុខៈ ដំណើរទៅកាន់សុខៈគឺសេចក្ដីចម្រើនលូតលាស់ ឯវិធីសម្រេចសុខៈ គឺផ្លូវចិត្តផង ផ្លូវកាយផង*

---

[1] វ៉ាន់នី កាអុន៖ ***បញ្ហាវប្បធម៌និងអារ្យធម៌*** ការផ្សាយរបស់អ្នកនិពន្ធ ១៩៧៣ ទំព័រ២១។



www.elibraryofcambodia.org

*ពោលគឺវប្បធម៌និងសង្គមធម៌នេះឯង*[2] ។ នៅក្នុងន័យនេះ លោកស្រីមានបំណងចង់បង្ហាញថា អរិយធម៌មានមែកធាងសំខាន់ពីរគឺ វប្បធម៌និងសង្គមធម៌។ តាមការណ៍ពិតទៅ គំនិតដែលបង្កើតឡើងនេះជាទស្សនៈរបស់សាស្ត្រាចារ្យ កេង វ៉ាន់សាក់ នៅក្នុងការសិក្សាអារ្យធម៌។ លោកបានសរសេរថា៖ «*ការសិក្សាអំពី អារ្យធម៌ បានបង្ហាញនូវមែកធាងពីរផ្នែកដ៏សំខាន់គឺ វប្បធម៌ នេះមួយ ហើយនិង ធម៌ទាំងឡាយដែលធ្វើឲ្យមនុស្សរស់នៅបានក្នុងសេចក្តីសុខសប្បាយនិងចម្រើនរុងរឿងនេះមួយទៀត។ តើ ធម៌ បែបទី ២ នេះមានឈ្មោះជាអ្វី។ អ្នកនិពន្ធអត្ថបទនេះបានបង្កើត ចំនួនជាង ៥ ឆ្នាំហើយ នូវពាក្យ «សង្គមធម៌» ដើម្បីសំគាល់មែកធាងទី២ នៃអារ្យធម៌ ហើយដែលជាគូគ្នានឹងវប្បធម៌។*»[3] លោកបានគូសបញ្ជាក់បន្ថែមទៀតថា៖«... *នៅក្នុងភាសាបារាំងវិញ យើងពុំអាចរកពាក្យណាមួយមកបកប្រែពាក្យ «សង្គមធម៌» បានឡើយ ពីព្រោះ «សង្គមធម៌» ជាពាក្យមួយដែលសំគាល់នូវកម្រិតនៃការសិក្សាជាភាសាខ្មែរដែលពុំមាននៅក្នុងការសិក្សាជាភាសាបារាំងទេ។*»[4]

តាមន័យនេះ ការសិក្សាអរិយធម៌ត្រូវផ្អែកលើមែកធាងពីរ គឺ វប្បធម៌ និង សង្គមធម៌។

---

[2]ត្រឹង ងា ***អរិយធម៌ខ្មែរ*** ការផ្សាយរបស់អ្នកនិពន្ធ បោះពុម្ពលើកទី៣ ១៩៧៤ ទំព័រ១០។

[3]កេង វ៉ាន់សាក់ ***មូលភាពនៃការបង្កើតពាក្យថ្មី (វេយ្យាករណ៍ អក្សរសិល្ប៍ ទស្សនវិជ្ជា)*** ភ្នំពេញ៖ រោងពុម្ពទេព បណ្ណាគារស្មើកម្ពុជា ១៩៦៤ ទំព័រ២១។

[4]ដដែល ទំព័រ២២។



www.elibraryofcambodia.org

- អរិយធម៌
  - វប្បធម៌
    - ចំណេះដឹង
      - ជំនឿ
      - សាសនា
      - សីលធម៌
      - ទស្សនវិជ្ជា
      - វិទ្យាសាស្ត្រ
    - ការផ្សាយ
      - អក្សរសិល្ប៍
      - សិល្បៈ
      - ព័ត៌មានឧបករណ៍
      - អក្សរ ភាសា សញ្ញា
      - អក្សរសាស្ត្រ
    - អនុវត្តន៍
      - ប្រពៃណី ទំនៀមទម្លាប់
      - ការសិក្សា អប់រំ
      - កីឡា ល្បែង
      - ច្បាប់ផ្សេងៗ
  - សង្គមធម៌
    - សង្គមសម្ភារៈ
      - ប្រដាប់ប្រដាប្រើប្រាស់
      - បច្ចេកទេស
      - វិជ្ជាជីវៈឬបរកស៊ី
    - សង្គមវិធី
      - សេដ្ឋកិច្ច
      - សង្គមកិច្ច
      - នយោបាយ
      - នីតិសាស្ត្រ
    - សង្គមនិម្មាណ
      - ក្រុមញាតិ
      - ជាតិ រដ្ឋ ប្រជាជាតិ
      - ស្ថាប័ន



www.elibraryofcambodia.org

តារាងមែកធាងអរិយធម៌នេះគឺជាការសិក្សាបែបខ្មែរដោយយោងតាមទស្សនៈរបស់សាស្ត្រាចារ្យ កេង វ៉ាន់សាក់ ។

ប្រវត្តិវិទូមានការលំបាកនៅក្នុងការកំណត់ព្រំដែនសង្គមមួយជាពិសេស និងកំណត់បច្ចេកសព្ទ «អរិយធម៌»ឲ្យបានត្រឹមត្រូវ។ ពួកគេបានប្រើបច្ចេកសព្ទ***«អរិយធម៌» គឺចង់សំដៅទៅលើសង្គមមួយនៅក្នុងអតីតកាលនិងបច្ចុប្បន្នមួយចំនួន ដោយមានភាពខុសប្លែកគ្នាខាងប្រវត្តិសាស្ត្រនិងខាងវប្បធម៌។***[5] នៅក្នុងទិដ្ឋភាពបែបនេះ ប្រវត្តិវិទូប្រើប្រាស់បច្ចេកសព្ទ«អរិយធម៌»ជាជាងពាក្យថា«ប្រទេស» ដោយសារថា ពាក្យ *អរិយធម៌* ជាឯកតាសំខាន់នៃប្រភពដើមថ្មីៗដែលមានការទាក់ទងគ្នា។

សព្វវចនាធិប្បាយ វើលប៊ុក បានបង្ហាញថា «អរិយធម៌ (Civilization)» ជាពាក្យដែលក្លាយមកអំពីឡាតាំង (Civis) ដែលមានន័យថា «ប្រជាពលរដ្ឋនៃទីក្រុង (Citizen of the city) ហើយ សព្វវចនាធិប្បាយនេះក៏បានផ្តល់និយមន័យ *អរិយធម៌* ថា៖ «***អរិយធម៌គឺជារបៀបរបបរស់នៅដែលបានកើតឡើងបន្ទាប់ពីមនុស្សដែលបានចាប់ផ្តើមឡើងរស់នៅក្នុងទីក្រុងឬនៅក្នុងសង្គម ដោយមានការរៀបចំជារដ្ឋ»***។[6] នៅក្នុងន័យនេះ ***អរិយធម៌រួមមាន សិល្បៈ ប្រពៃណី បច្ចេកទេស ទម្រង់រដ្ឋាភិបាល និងអ្វីៗផ្សេងៗទៀតដែលបង្កើតរបៀបរបបរស់នៅនៅក្នុងសង្គម***។ នៅក្នុងទិដ្ឋភាពបែបនេះ «អរិយធម៌»គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងពាក្យ«វប្បធម៌»។ ពាក្យ«វប្បធម៌»គឺចង់សំដៅទៅលើរបៀបរបបរស់នៅ ដែលរាប់បញ្ចូលទាំងរបៀបរបបធម្មតានិងរបៀបរបបចម្រុះ នៅខណៈពេលដែល «អរិយធម៌»និយាយយោងត្រឹមតែទៅលើរបៀបរបបរស់នៅដែលមានធាតុសំខាន់ដូចជា ប្រព័ន្ធសេដ្ឋកិច្ចចម្រុះ ប្រព័ន្ធរដ្ឋាភិបាល និងប្រព័ន្ធសង្គម។ ហេតុដូច្នេះ មនុស្សគ្រប់គ្នារស់នៅក្នុងវប្បធម៌ ហើយ មិនមែនមនុស្សម្នាក់ៗរស់នៅក្នុង

---

[5] "Civilization." Microsoft® Student 2008 [DVD]. Redmond, WA: Microsoft Corporation, 2007. <<*Historians have found difficulties in delimiting a particular society and correctly labeling it a civilization; they use the term civilization to refer to a number of past and present societies that manifest distinctive cultural and historical patterns.*>>

[6] "Civilization." World Book 1999. Brian M. Fagan, <<*Civilization is a way of life that arose after people began to live in cities or in societies organized as states.*>>



www.elibraryofcambodia.org

អរិយធម៌នោះទេ។

### ១.២- វប្បធម៌

បញ្ញត្តិនៃពាក្យ«វប្បធម៌»ជាពាក្យមូលដ្ឋានយូរយារណាស់មកហើយ នៅក្នុងការសិក្សានរវិទ្យា។ ជាច្រើនសតវត្សកន្លងមកហើយ សៀវភៅរបស់គាត់មានចំណងជើងថា៖ «វប្បធម៌ដើម (*Primitive Culture*)»ដែលជារបស់លោក អិដវើត ថៃល័រ (Edward Tylor) បានលើកឡើងថា វប្បធម៌ ប្រព័ន្ធឥរិយាបថរបស់មនុស្សនិងគំនិតការគោរពច្បាប់ធម្មជាតិ បានត្រូវគេសិក្សាជាលក្ខណៈវិទ្យាសាស្ត្រ។ និយមន័យរបស់លោក ថៃល័រ នៅតែជាការផ្តល់គោលគំនិតនៃប្រធានបទចំពោះការសិក្សានរវិទ្យា ហើយគំនិតនេះត្រូវគេយកទៅសិក្សាយ៉ាងទូលំទូលាយ។

«វប្បធម៌...***គឺជាការទាក់ទងគ្នាទាំងមូលដែលមាន ចំណេះដឹង ជំនឿ សិល្បៈ សីលធម៌ ច្បាប់ទំនៀមទម្លាប់ សមត្ថភាពដទៃផ្សេងទៀត ព្រមទាំងទម្លាប់ ដោយបានមកពីមនុស្សដែលជាសមាជិកនៃសង្គម។***»[7] គំនិតនេះគឺជាទស្សនៈដែលមានយូរយារណាស់មកហើយ ហើយ ការសិក្សាបច្ចុប្បន្នក៏មានការប្លែកគ្នាពីទស្សនៈខាងលើផងដែរ តែគំនិតខាងលើត្រូវគេយកមកសិក្សាជាហូរហែកន្លងមក។ ពាក្យ«វប្បធម៌» នៅក្នុងមុខវិជ្ជានរវិទ្យាគឺចង់សំដៅទៅលើទម្រង់នៃឥរិយាបថនិងការគិតដែលមនុស្សរស់នៅ តាមរយៈការសិក្សារៀនសូត្រ ការច្នៃប្រឌិត និងការចែករំលែកគ្នាទៅវិញទៅមក។[8]

## ២- លក្ខណៈនៃវប្បធម៌

វប្បធម៌បង្កើតឡើងដោយសារមនុស្ស និង ជួយការរស់នៅរបស់មនុស្ស ។ សត្វពុំមានវប្បធម៌ទេ ព្រោះលក្ខណៈរបស់វប្បធម៌បានបង្ហាញថា សត្វពុំអាចបង្កើតវប្បធម៌បានទេ ។

---

[7] Conrad Phillip Kottak, ***Anthropology: The Exploration of Human Diversity***, McGraw-Hill Companies, Inc., 2000, p.62.

[8] Bodley, John H. "Culture." Microsoft® Student 2008 [DVD]. Redmond, WA: Microsoft Corporation, 2007. *<<**Culture**, in anthropology, the patterns of behavior and thinking that people living in social groups learn, create, and share. >>*



www.elibraryofcambodia.org

## ២.១- វប្បធម៌មានលក្ខណៈជានិមិត្តសញ្ញា

និមិត្តសញ្ញាជាវប្បធម៌បឋមរបស់មនុស្ស ពីព្រោះមនុស្សអាចទាក់ទងគ្នា បាន ដោយការប្រើប្រាស់និមិត្តសញ្ញា ។ និមិត្តសញ្ញាដែលជាវប្បធម៌របស់មនុស្សមានដូចជា ភាសា អក្សរ សញ្ញាតន្ត្រី សញ្ញាគណិតវិទ្យា សញ្ញាចរាចរណ៍ សញ្ញាហោរាសាស្ត្រ។ល។

មនុស្សមានសរីរៈបញ្ចេញសម្លេងដែលសត្វគ្មាន។ ដោយសារសរីរៈនេះ មនុស្ស បង្កើតបានជាភាសាដែលអាចឱ្យគេទាក់ទងគ្នាយ៉ាងស្មុគស្មាញ។ ការបញ្ចេញសម្លេង ស្រែកយំរបស់មនុស្សឬសត្វ ការសើចរបស់មនុស្ស និង ការបញ្ចេញសម្លេងទាក់ទងគ្នា របស់សត្វ (ទោះបី តាមប្រពៃណី គេហៅថា *ភាសាសត្វ* ក៏ដោយ ក៏គេមិនអាចចាត់ទុក ថាសត្វមានភាសាទេ ឯពាក្យ *ភាសា* នៅក្នុង *ភាសាសត្វ* សំដៅន័យថា *មធ្យោបាយ ទាក់ទងគ្នា* មិនមែនក្នុងន័យដូច *ភាសា* មនុស្សឡើយ) មិនមែនជាវប្បធម៌ ទេ ពីព្រោះ វាជាសញ្ញាធម្មតា ឬជាសញ្ញាបង្កើតដោយសភាវគតិ ។ ព្រោះហេតុនេះ សត្វស្វាឬសត្វ សេកមួយ ដែលគេខំបង្រៀនឱ្យនិយាយពាក្យពេចន៍ជាច្រើននៃភាសាមនុស្ស នៅតែពុំ អាចយកពាក្យទាំងនោះមកផ្សំផ្គុំគ្នាបង្កើតជាឃ្លាល្បះ ដោយខ្លួនវាឡើយ។ នេះដោយ សារតែភាសាជាវប្បធម៌ ឬ ជាសញ្ញា (សញ្ញាកើតក្នុងខួរក្បាលមនុស្ស) ដ៏ស្មុគស្មាញ។ ក្រៅពីភាសា មនុស្សគអាចប្រើកាយវិការ (និមិត្ត សញ្ញា) សម្រាប់ទាក់ទងគ្នា ។

អក្សរ គឺជានិមិត្តសញ្ញាសម្រាប់សម្តែងភាសា ហើយវាក៏ជាផ្នែកមួយនៃវប្បធម៌។

និមិត្តសញ្ញាក៏អាចឱ្យមនុស្សបង្កើតជាគំនិតដ៏ស្មុគស្មាញថែមទៀត ។ ឧទា- ហរណ៍ វិស្វករអាចសាងសង់អាគារប្រកបដោយរចនាបថណាមួយបានដោយចាប់ ផ្តើមពីការគូសវាស និងប្រើនិមិត្តសញ្ញាពិសេសដែលអ្នកដទៃមិនអាចយល់បាន ។

ពេលខ្លះទៀត អត្ថន័យនៃនិមិត្តសញ្ញាមិនមានជាប់ទាក់ទងនឹងសញ្ញាវាទាល់តែ សោះ។ ឧទាហរណ៍ ខ្មែរប្រើពណ៌បីក្នុងការតាក់តែងទង់ជាតិរបស់ខ្លួន ហើយពណ៌ នីមួយៗមានន័យតំណាងរបស់វា ។

និមិត្តសញ្ញាដែលមានរៀបរាប់ខាងលើនេះសុទ្ធតែជាវប្បធម៌ ពោលគឺវាអាចធ្វើឱ្យ មនុស្សសម្តែងគំនិតរបស់ខ្លួន ក្នុងការប្រស្រ័យទាក់ទងគ្នាបាន ហើយនិមិត្តសញ្ញា



www.elibraryofcambodia.org

ទាំងនេះកើតពីមនុស្ស ។

## ២.២- វប្បធម៌មានលក្ខណៈជាការរៀនសូត្រ

មនុស្សម្នាក់ទទួលវប្បធម៌ដោយការរៀនសូត្រ ។ គេថា មនុស្សម្នាក់មិនមែនកើតមក ដោយយកវប្បធម៌មកជាមួយទេ ផ្ទុយទៅវិញ គេកើតមកនៅក្នុងសង្គមមួយដែលមានវប្បធម៌ ហើយ ដើម្បី ទទួលបានឬចេះវប្បធម៌នោះ គេត្រូវតែរៀន។ ឧទាហរណ៍ កូនម្នាក់ដែលកើតក្នុងគ្រួសារដែលមានឪពុកជាជាងឈើ អាចចេះជំនាញជាជាងឈើដូចឪពុកវាបាន ទាល់តែវារៀនពីឪពុកវា។ ការរៀនសូត្រ អាចជាការរៀនដោយផ្ទាល់ ឬ ដោយប្រយោល ពោលគឺវាអាចចេះជំនាញនោះបាន ទាល់តែឪពុកវាបង្រៀនវា ឬ ដោយសារវាសង្កេតមើលជំនាងនោះពីឪពុករបស់វា ។ ឧទាហរណ៍ម្យ៉ាងទៀត មនុស្សម្នាក់ ដែលកើតនៅក្នុងសង្គមណាមួយ នឹងចេះនិយាយភាសារបស់សង្គមនោះ មិនមែនភាសារបស់សង្គមផ្សេងទេ។

វប្បធម៌ផ្ទុយពីសភាវគតិដែលជាចំណេះមិនត្រូវការការរៀនសូត្រ។ សត្វពីងពាងកើតមក នឹងចេះធ្វើសំបុកដោយខ្លួនឯង ដោយមិនចាំបាច់រៀនទេ។ ការណ៍នេះហៅថា *សភាវគតិ* មិនមែនវប្បធម៌ទេ។

ការរៀនសូត្រដែលជាលក្ខណៈរបស់វប្បធម៌មិនមែនជំរុញដោយធម្មជាតិទេ ។ សត្វខ្លះមានការបង្ហាត់បង្រៀនគ្នាដែរ ឧទាហរណ៍សត្វចាបអាចនឹងបង្រៀនកូនវា ឱ្យចេះហើរ ឯសត្វខ្លាអាចនឹងបង្រៀនកូនវាឱ្យចេះចាប់ចំណី តែការរៀនសូត្របែបនេះជំរុញដោយធម្មជាតិពោលគឺសភាវគតិ ដែល មិនខុសពីការណ៍ដែលមនុស្សបង្រៀនកូនឱ្យចេះដើរនោះឡើយ ។ ធម្មជាតិរបស់សត្វស្លាបគឺការចេះហើរ ធម្មជាតិរបស់សត្វខ្លាគឺការស៊ីសាច់ជាអាហារ ឯធម្មជាតិរបស់មនុស្សគឺការចេះដើរជើងពីរ (ដែលជាសភាវគតិ) ទោះបីមនុស្សឬសត្វទាំងនេះមិនរៀនក៏ដោយ ។ ការរៀនរបស់សត្វទាំងនេះគឺជាការរៀនដែលជំរុញដោយធម្មជាតិ ឯការរៀនដើរ របស់មនុស្សក៏ជំរុញដោយធម្មជាតិ ឬ ដោយសារមនុស្សចង់ឱ្យកូនរបស់ខ្លួនចេះដើរមុន ធម្មជាតិតម្រូវឱ្យកូននោះចេះដើរ។


www.elibraryofcambodia.org

## ២.៣- វប្បធម៌មានលក្ខណៈជាការប្រើប្រាស់រួមគ្នា

វប្បធម៌របស់សង្គមមួយត្រូវបានបង្កើត រក្សា ផ្ទេរបន្ត និង កែសម្រួលដោយសមាជិកទាំងអស់នៅក្នុងសង្គមនោះ ហើយ វាក៏អាចឱ្យគេយល់បានថា មនុស្សម្នាក់មកពីសង្គមណា ។ ឧទាហរណ៍ គេអាចយល់បានភ្លាម នៅពេលដែលគេឃើញមនុស្សម្នាក់ដែលមិនបរិភោគសាច់ជ្រូក ហើយបរិភោគម្ហូប ហាឡាល់ ថា មនុស្សម្នាក់នោះមកពីសង្គមដែលកាន់សាសនាឥស្លាម។

វប្បធម៌ខ្លះក្លាយជាវប្បធម៌អន្តរជាតិដោយសារជាតិសាសន៍ជាច្រើននៅលើពិភពលោក ជាជាងជាតិសាសន៍ដែលបង្កើតវប្បធម៌នោះ អនុវត្តវា ។ ឧទាហរណ៍ សាសនាឥស្លាម សាសនាព្រះពុទ្ធ សាសនាគ្រិស្ត និង ការប្រើគ្រិស្តសករាជ ជាដើម ត្រូវបានគោរព និង ប្រតិបត្តិ ដោយប្រជាជាតិ ជាច្រើនលើពិភពលោក ។

វប្បធម៌តែងតែប្រែប្រួលឥតឈប់ឈរ ព្រោះវាត្រូវការបំពេញសេចក្តីត្រូវការរបស់មនុស្ស ឬ បំពេញការខ្វះចន្លោះរបស់វា ប៉ុន្តែ ការប្រែប្រួលរបស់វប្បធម៌មួយអាចកើតឡើងបាន លុះត្រាតែមនុស្សនៅក្នុងសង្គមនោះទទួលយកទាំងអស់គ្នា (លើកលែងតែក្នុងករណីមានការបង្ខំដោយអ្នកមានអំណាច ដូចក្នុងសម័យប៉ុលពត ដែលវប្បធម៌ខ្មែរប្រែប្រួលទាំងស្រុង) ។ ឧទាហរណ៍ កាលពីបោះពុម្ពគ្រា ទី ៤ វចនានុក្រមខ្មែរដែលរៀបរៀងដោយក្រុមជំនុំ ក្រោមការដឹកនាំរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** បានណែនាំឱ្យសាធារណជនប្រើប្រាស់ សញ្ញាអឌ្ឍចន្ទដាក់នៅលើអក្សរកំព្រាក្នុងពាក្យដូចជា *ទូកង កុកសក ជាដើម* ជា *ទូកង៌ កុកសក៌* ដើម្បីជៀសភាពពាំត្រណោត ។ ប៉ុន្តែដោយសារសាធារណជន មិនព្រមប្រើតាម វចនានុក្រមនេះក៏កែសម្រួល លែងប្រើសញ្ញានេះវិញ នៅពេលបោះពុម្ពគ្រាទី ៥ ។ នេះហើយជាលក្ខណៈរបស់វប្បធម៌ព្រោះវប្បធម៌ជារបស់រួមរបស់សង្គមមួយ ។

ប៉ុន្តែ ទន្ទឹមនឹងការកំណត់ថា វប្បធម៌មួយជារបស់សង្គមណាមួយ គេក៏ត្រូវចងចាំថា គេត្រូវគោរពវប្បធម៌របស់សង្គមដទៃ ពុំនោះសោតវានឹងនាំឱ្យកើតមានការប្រល័យពូជសាសន៍ ឬ ប្រល័យវប្បធម៌។


www.elibraryofcambodia.org

## ២.៤- វប្បធម៌មានលក្ខណៈជាការសម្រប

លក្ខណៈសម្របនៃវប្បធម៌បានធ្វើឱ្យមនុស្សក្លាយជាប្រភេទតែមួយគត់ដែលមានភាពជោគ-ជ័យនៅលើភពផែនដីនេះ ។ នៅពេលដែលអាកាសធាតុប្រែប្រួល មនុស្សក៏អាចសម្របទៅតាមអាកាសធាតុនោះបាន ដោយការបង្កើតបច្ចេកវិទ្យាផ្សេងៗ ដែលផ្ទុយពីសត្វដែលត្រូវការផ្លាស់លំនៅ ។ ទោះជាយ៉ាងណា បច្ចេកវិទ្យាទាំងនេះអាចនឹងផ្តល់ផលដល់មនុស្សសម្រាប់រយៈពេលខ្លី ប៉ុន្តែនឹងអាចនាំមកនូវផលអាក្រក់សម្រាប់មនុស្សរយៈពេលវែង ។

## ៣- ប្រភេទនៃវប្បធម៌

នរវិទូបានពិពណ៌នាប្រភេទផ្សេងគ្នាមួយចំនួននៃវប្បធម៌។ អ្នកទាំងនោះរួមមាននរវិទូអង់គ្លេស អេតវើត ថាយលើ (Edward B. Tylor) ដែលជាអ្នកផ្តល់និយមន័យដំបូងគេនិងពេញលេញស្តីអំពីពាក្យថា «វប្បធម៌» នៅក្នុងស្នាដៃរបស់លោកស្តីអំពី «វប្បធម៌បុរាណ» នៅឆ្នាំ១៨៧១[៩]។ និយមន័យគាត់បញ្ជាក់ថា *វប្បធម៌ជាការរាប់បញ្ចូលចំណេះដឹងដែលទទួលបានពីសង្គម ជំនឿ សិល្បៈ ច្បាប់ សីលធម៌ ប្រពៃណី និងទំនៀមទម្លាប់។* នៅឆ្នាំ១៩៣០ នរវិទូអាមេរិក ឈ្មោះ ចច មើដក់ (George P. Murdoc)បានចូលទៅជ្រៅជាងនេះបន្តិច ដោយគាត់បានរាយបញ្ជីមែកធាងសំខាន់ៗអំពីវប្បធម៌ចំនួន ៦៣៧។ ស្នាដៃរបស់លោក មើដក់បានពិពណ៌នាយ៉ាងលម្អិតអំពីប្រព័ន្ធក្បួនច្បាប់ដែលគេស្គាល់នោះគឺ «សំណុំរឿងតំបន់ទំនាក់ទំនងមនុស្ស (Human Relation Area Files)»។ ក្រោយមក នរវិទូបានបែងចែកប្រភេទវប្បធម៌ជាបីប្រភេទគឺ វប្បធម៌សម្ភារៈ វប្បធម៌សង្គម វប្បធម៌មនោគមវិជ្ជា និងចុងក្រោយទីបួនគឺ សិល្បៈ។

***វប្បធម៌សម្ភារៈជាផលិតផលខាងឧស្សាហកម្មរបស់មនុស្ស ដូចជាបច្ចេកវិទ្យា សម្លៀកបំពាក់ ផ្ទះសម្បែង ជាដើម។ វប្បធម៌សង្គមទាក់ទងទៅនឹងទម្រង់នៃការរៀបចំសង្គមរបស់មនុស្ស មានដូចជា សាច់សាលោហិតនិងគ្រួសារ ជីវិតការងារ និងភាពជាអ្នក***

---

[៩] Bodley, John H. "Culture." Microsoft® Student 2008 [DVD]. Redmond, WA: Microsoft Corporation, 2007.



www.elibraryofcambodia.org

*ដឹកនាំនិងអំណាចនយោបាយ។ វប្បធម៌មនោគមវិជ្ជាទាក់ទងទៅនឹងអ្វីដែលមនុស្សគិត មនុស្សឲ្យតម្លៃ មនុស្សជឿ និងឧត្តមគតិ។ វប្បធម៌មនោគមវិជ្ជាទាក់ទងទៅនឹងសាសនា និងអាណាចក្រនិយម។*

### ៤- ការរីកចម្រើននិងធ្លាក់ចុះនៃអរិយធម៌

ទស្សនវិទូ ប្រវត្តិវិទូ និងបុរាណវិទូបានផ្តល់ហេតុផលជាច្រើនស្តីអំពីការរីកចម្រើន និងការធ្លាក់ចុះនៃអរិយធម៌។ លោក ចច ហេហ្គេល (Georg W.F. Hegel) ទស្សនវិទូអាឡឺម៉ង់នៅដើមឆ្នាំ១៨០០បានប្រៀបធៀបសង្គមទៅនឹងបុគ្គលដែលបានឆ្លងកាត់ប្រភពនៃគោលការណ៍អរិយធម៌ពីមនុស្សម្នាក់ទៅម្នាក់ទៀត។ នៅក្នុងកំឡុងពេលនៃដំណើរការនេះ យោងទៅតាមលោក ហេហ្គេល អរិយធម៌បានវិវឌ្ឍទៅតាមបីដំណាក់កាលៈ ទីមួយ ការដឹកនាំដោយមនុស្សតែម្នាក់គឺមេដឹកនាំផ្តាច់ការ ទីពីរ ការដឹកនាំដោយក្រុមមនុស្សនៅក្នុងសង្គម និងទីបី ការដឹកនាំដោយប្រជាពលរដ្ឋទាំងអស់គ្នា។ លោក ហេហ្គេលមានជំនឿថាដំណើរការបានផ្តល់លទ្ធផលជាយថាហេតុតាមរយៈសេរីភាពសម្រាប់មនុស្សទាំងអស់។[10]

ទស្សនវិទូអាឡឺម៉ង់ លោក អូស្វល ស្ពែងល័រ (Oswald Spengler)គិតថាអរិយធម៌គឺប្រៀបប្រដូចទៅនឹងជីវិតរបស់មនុស្សយ៉ាងដូច្នោះដែរ ពោលគឺ ការចាប់កំណើត ធំធាត់ និងស្លាប់ទៅវិញ។ នៅក្នុងស្នាដៃស្តីអំពី«ការដួលរលំបស្ចិមប្រទេស (១៩១៨-១៩២២)» គាត់បានសរសេរថា "អរិយធម៌បស្ចិមប្រទេសកំពុងតែស្លាប់ហើយ វានឹងជំនួសដោយអរិយធម៌អាស៊ីសម័យថ្មី។"

ប្រវត្តិវិទូអង់គ្លេស លោក អាណុល ថនប៊ី (Arnold Toynbee) បានស្នើជាទ្រឹស្តីរបស់គាត់មួយឡើង គឺទ្រឹស្តីនៃការប្រឈមនិងការឆ្លើយតប នៅក្នុងការសិក្សាប្រវត្តិសាស្ត្រ (១៩៣៤-១៩៦១)។ លោក ថនប៊ីមានជំនឿថាអរិយធម៌រីកចម្រើនត្រឹមតែកន្លែងដែលបរិស្ថានឆ្លើយតបទៅនឹងប្រជាជន ហើយពេលដែលមនុស្សមានលក្ខណៈ

---

[10]Brian M. Fagan, "Civilization" in Encyclopedia, 1999, pp.635-636.


www.elibraryofcambodia.org

ត្រឹមត្រូវ ដើម្បីឆ្លើយតបទៅនឹងការប្រឈម។ ឧទាហរណ៍ អាកាសធាតុក្តៅធ្វើឲ្យដីមិនអាចដាំដុះបាន ហើយអាកាសធាតុបែបនោះអាចឆ្លើយតបទៅនឹងមនុស្សដែលរស់នៅទីនោះ។ មនុស្សអាចធ្វើសកម្មភាពចំពោះបញ្ហាប្រឈមទាំងឡាយ ដោយកសាងប្រព័ន្ធធារាសាស្ត្រ ដើម្បីកែលម្អដី។ លោក ថនប៊ី បានស្នើជាយោបល់ថាអរិយធម៌ដួលរលំនៅពេលដែលមនុស្សបាត់បង់ការបង្កើតឬការច្នៃប្រឌិតរបស់គេ។

បុរាណវិទូភាគច្រើនបានកំណត់ថាអរិយធម៌រីកចម្រើន ដោយសារបុព្វហេតុមួយចំនួនដូចជា ជីវិតសង្គម ជីវិតនយោបាយ មធ្យោបាយដែលមនុស្សសម្របសម្រួលទៅនឹងបរិស្ថាន និងការប្រែប្រួលខាងប្រជាសាស្ត្រ។ ករណីភាគច្រើនអរិយធម៌អាចលេចឡើង ពីព្រោះមេដឹកនាំអាចពង្រឹងអំណាចនយោបាយបានដោយឯករាជ្យ។

## ៥- ការរីកចម្រើននិងការធ្លាក់ចុះនៃអរិយធម៌អង្គរ[11]

### ៥.១- ការរីកចម្រើននៃអរិយធម៌អង្គរ

ចក្រភពអង្គររីកចម្រើនដោយសារកត្តាជាច្រើនដូចជា៖

#### ៥.១.១- គ្រឹះនយោបាយនិងគ្រឹះសង្គម

– នយោបាយក្រៅប្រទេសចាប់ផ្តើមរឹងមាំ ដោយសារ ការធ្លាក់ចុះទន់ខ្សោយនៃសន្តតិវង្សសៃលេន្ទ្រនៅកោះជ្វា ជនជាតិថៃនៅជាកុលសម្ព័ន្ធនៅឡើយហើយមិនទាន់បានឯករាជ្យនោះផងទេ យួនទៀតសោតក៏មិនទាន់រួចផុតពីអាណានិគមចិននោះផងដែរទេ។

– នយោបាយក្នុងប្រទេសមានការរួបរួមគ្នាចាប់ពីព្រះបាទជ័យវរ្ម័នទី២ ចំណែកឯសាមគ្គីភាព និងឯកភាពជាតិបានសម្រេចពេញលេញ នៅក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័នទី១ បន្ទាប់ពីនោះ មក សង្គមកាន់តែរឹងមាំឡើងៗ ក្រោយៗមកទៀត។ ក្រៅពីនេះយើងឃើញ មាន គុណសម្បត្តិយោធា យុទ្ធោបករណ៍ រដ្ឋបាលកណ្តាលរឹងមាំដោយ

[11]សូមអាន ថាច់ វ៉ាន់ផាតនិងកែវ សុគុន *អាទិទេពក្រុងអង្គរ៖ សាកល្បងសិក្សាពីបុព្វហេតុដែលនាំឲ្យអរិយធម៌អង្គររីកចម្រើនដល់កំពូលរួចធ្លាក់ចុះជាបមកវិញ* ១៩៧៣ ១១២ទំព័រ។



www.elibraryofcambodia.org

មានខែត្រពី ៩០ ដល់ ១០១ ខែត្រ។

- ស្ថាប័នតុលាការស្ថិតនៅលើព្រះមហាក្សត្រ ។

### ៥.១.២- គ្រឹះសេដ្ឋកិច្ច

- ស្ថានភាពភូមិសាស្ត្រគាប់ប្រសើរ រាជធានីអង្គរជាបេះដូងនៃសេដ្ឋកិច្ចទាំងផ្លូវគោក ផ្លូវទឹក ដែលមានបឹងទន្លេសាបជាផ្លូវទឹកសំខាន់

- កត្តាមនុស្សនិងមរតកពីអតីតកាលពិសេសពីសម័យហ្វូណន

- ឧស្សាហកម្មនិងសិប្បកម្ម៖ ឧស្សាហកម្មគ្រឿងសំណង់ កំបោរលាយខ្សាច់ ស្ករត្នោត បិទស្រា ចម្លាក់ថ្ម ការត្បាញសម្លៀកបំពាក់ ជាងទងផលិតគ្រឿងអលង្ការ

- សម្បត្តិជាតិបានមកពីសួយសារអាករនឹងការរឹបអូសក្នុងចម្បាំង

- សង្គមកិច្ចនិងនគរូបនីយកម្ម៖ ការឈឺឆ្អាលរបស់ព្រះមហាក្សត្រមានភស្តុតាងមួយអំពី ព្រះបាទជ័យវរ្ម័នទី៧ សិលាចារឹកមួយនៅសាយហ្វុង ត្រង់គាថា ទី១៣ បានចែងថា ព្រះបាទជ័យវរ្ម័នទី៧« *មានកង្វល់ណាស់ចំពោះសុខភាពប្រជារាស្ត្រ ព្រោះជំងឺរបស់រាស្ត្រនេះ ហើយដែលធ្វើឲ្យទ្រង់មានការឈឺចាប់ជាជាងជំងឺរបស់ព្រះអង្គ។*»

### ៥.១.៣- មុខងារព្រះមហាក្សត្រនៅក្នុងការចម្រើនលូតលាស់នៃអរិយធម៌ខ្មែរ

- លទ្ធិទេវរាជឬកម្រតេជគតរាជចាប់តាំងពីរជ្យព្រះបាទជ័យវរ្ម័នទី២

- ក្រោយមកជាពុទ្ធរាជ នៅសម័យជ័យវរ្ម័នទី៧

### ៥.១.៤- គ្រឹះសាសនានិងវប្បធម៌

- ជំនឿនិងសាសនាមានលទ្ធិទេវរាជ

- ព្រះពុទ្ធសាសនាមហាយាន

- ព្រះពុទ្ធសាសនាហីនយាន

- សិល្បករនិងភាពរុងរឿងនៃសិល្បៈខ្មែរ ។



www.elibraryofcambodia.org

## ៥.២- មូលហេតុនៃការធ្លាក់ចុះដុនដាបនៃអរិយធម៌អង្គរ

### ៥.២.១- ឥទ្ធិពលនយោបាយក្រៅប្រទេស

- ការរាតត្បាតនៃម៉ុងហ្គោលធ្វើឲ្យថៃផ្សេងៗនៅភាគខាងត្បូងប្រទេសចិនធ្វើដំណើរមកកាន់ ទន្លេមេគង្គ ផ្នែកខាងលើទន្លេមេណាម និងប្រទេសភូមា
- ការគំរាមកំហែងនៃជនជាតិថៃពីសតវត្សទី១១មកលើអាណាចក្រអង្គរ
- ទំនាក់ទំនងនៃជនជាតិអណ្ណាម ។

### ៥.២.២- ឥទ្ធិពលនយោបាយក្នុងប្រទេស

- ការបោះបោរផ្សេងៗមុនសតវត្សទី១៣
- ជម្លោះផ្សេងៗក្រោយរាជព្រះបាទជ័យវរ្ម័នទី៧
- បដិវត្តន៍ត្រសក់ផ្អែម
- សង្គ្រាមជាមួយពួក មន ចាម យួន

### ៥.២.៣- ការធ្លាក់ចុះផ្នែកសេដ្ឋកិច្ច

- ការខូចខាតសង្វារណបរិក្ខារសេដ្ឋកិច្ច
- ដោយសារធម្មជាតិ
- ការធ្លាក់ចុះនៃផលិតផលកសិកម្ម
- តំហយប្រជាជន
- ការធ្លាក់ចុះនៃពាណិជ្ជកម្មក្រៅប្រទេស

### ៥.២.៤- សេចក្តីស្លាប់ខាងផ្លូវចិត្តៈ ការដួលរលំនៃគ្រឹះវប្បធម៌

- ការផ្លាស់ប្តូរខាងផ្នែកជំនឿសាសនាៈ អវសាននៃលិទ្ធិទេវរាជនិងលទ្ធិបុគ្គលនិយមបន្ទាប់ពីជ័យវរ្ម័នទី៧
- ការបាក់ទឹកចិត្ត ដោយបាត់អំណួត ។

លោក ឡូរិន ប៉ាមើ ប្រិត (Lawrence Palmer Briggs)បានអះអាងថាចក្រភព


www.elibraryofcambodia.org

អង្គរធ្លាក់ចុះដោយសារកត្តាមួយចំនួនដូចជា[12]៖

- ការស្លាបនាហួសហេតុលើស្ថាបត្យកម្ម
- ការបាត់បង់ចំណូលនិងផលទុនផ្សេង
- ការបាត់បង់កម្លាំងពលកម្ម
- ការផ្លាស់ប្តូរសាសនាទៅជាហីនយាន
- ការបំផ្លិចបំផ្លាញទីក្រុងរបស់ពួកសៀម

## ៦- ទំនាក់ទំនងអរិយធម៌ខ្មែរជាមួយបរទេស

ទំនាក់ទំនងមុនសតវត្សទី ៨ មាន ចាម្ប៉ា អាណ្ណាម តុងកឹង ទៀបកោះម៉ាឡាកា ឈេទូ ឬសៀម ឥណ្ឌានិងចិន៖

- ក្នុងអំឡុងពេលប្រហែលជា៥០០ឆ្នាំដំបូងនៃគ.ស. ឥណ្ឌាបានឲ្យខ្មែរនូវៈទស្សនៈអំពី ចក្រពត្រាធិរាជ សាសនា ភាសាសំស្ក្រឹត អក្សរ អក្សរសិល្ប៍ ទំនៀមទម្លាប់ច្បាប់ របៀបរបបថ្មីនៅក្នុងការដឹកនាំនយោបាយ សង្គមវិទ្យា ស្ថាបត្យកម្ម បដិមាសាស្ត្រ តារាសាស្ត្រ និង សោភណវិទ្យា។[13]

- ឥទ្ធិពលចិន សតវត្សទី ៣ មាន៖ ជំនួញ ឈ្មួយជាតិសាសន៍ ល្ខោន ប្រពៃណី ភាសា ជាដើម ។

- ឥទ្ធិពលចាម-ជ្វាសតវត្សទី ៥ ៖ ស្ថាបត្យកម្មនិងក្បាច់លំអ ដូចយ៉ាងក្បាច់លំអរាហ៊ូជាដើម។

- ឥទ្ធិពលសៀម យួន សតវត្សទី ១៣ ៖ ពាក្យពេចន៍មួយចំនួន ។

- ឥទ្ធិពលអឺរ៉ុបសតវត្សទី១៦៖ វិទ្យាសាស្ត្រ បច្ចេកទេស ទម្លាប់ចាប់ដៃ ការស្លៀកពាក់ លទ្ធិប្រជាធិបតេយ្យ កិច្ចការរដ្ឋបាល។ល។

- ឥទ្ធិពលជប៉ុន-កូរ៉េ៖ បទចម្រៀង ភាសា ម្ហូបអាហារ ។

---

[12]Lawrence Palmer Briggs, ***The Ancient Khmer Empire***, American Philosophy Society, 1951, pp.258-261.

[13]ដេវិឌ ឆាណ្ឌល័រ ***ប្រវត្តិសាស្ត្រខ្មែរ*** មជ្ឈមណ្ឌលខេមរសិក្សា ២០០៥ ទំព័រ២០។



www.elibraryofcambodia.org

### ៧- មូលធម៌ខ្មែរ-មន

ទោះបីជាខ្មែរមានឥទ្ធិពលពីបរទេសក៏ដោយ ក៏ខ្មែរមានគ្រឹះរបស់ខ្លួន។ គ្រឹះវប្បធម៌នោះ យើងហៅថា "មូលធម៌ខ្មែរ-មន" ដែលរួមមាន៖

- ជឿព្រលឹង អារក្ស អ្នកតា
- មាតាធិបតេយ្យ
- បាចទឹកបញ្ចូលស្រែ
- ផ្សាំងសត្វ
- កប់ខ្មោចក្រោមថ្មដុលឬក្នុងក្រឡ
- ភាសាមានអន្តេបទឬផ្នត់ដែក ជាដើម ។

### ៨- ដើមកំណើតជាតិខ្មែរ[14]

ពុំមាននរណាដឹងច្បាស់ទេថាតើនៅលើទឹកដីប្រទេសកម្ពុជាបច្ចុប្បន្ននេះ មានមនុស្សរស់នៅតាំងពីពេលណាមកនិងមកពីណា ហើយ ពួកគេនិយាយភាសាអ្វីនោះទេ មុនគេចេះសរសេរអក្សរដែលមកពីឥណ្ឌា នៅប្រហែលសតវត្សទី៣។ ប៉ុន្តែ តាមការប្រើប្រាស់បច្ចេកទេសកាបូន ១៤ ដែលជាវិធីមួយប្រើវិទ្យុសកម្ម ដើម្បីកំណត់អាយុកាលនៅរូងភ្នំល្អាងស្ពានដែលជាស្ថានីយបុរេប្រវត្តិ ក្នុងភាគពាយ័ព្យនៃប្រទេសកម្ពុជា គេដឹងថា មានមនុស្សដែលចេះធ្វើក្អមឆ្នាំង បានមករស់នៅក្នុងរូងភ្នំនេះតាំងពី៤២០០ឆ្នាំមុនគ្រិស្តសករាជមកម្ល៉េះ។ ចំណែករូងភ្នំមួយទៀតដែលស្ថិតនៅជិតមាត់សមុទ្រមានមនុស្សរស់នៅ ប្រហែលជា១០០០ឆ្នាំក្រោយមកទៀត។ គេគិតស្មានថាប្រជាជនដំបូងៗបានមករស់នៅលើទឹកដីនេះ តាំងពីពេលយូរជាងកាលបរិច្ឆេទខាងលើនេះទៅទៀត ពីព្រោះគេបានប្រទះឃើញភស្តុតាងជាច្រើន នៃការតាំងលំនៅមុនគេបង្អស់ តាំងពីសម័យយុគថ្ម នៅភាគខាងកើតនៃប្រទេសខ្មែរ។ នៅសំរោងសែន កន្លែងនេះមានមនុស្សមករស់នៅតាំងពីជិត១៥០០ឆ្នាំមុនគ្រិស្តសករាជ គេបានជីកដីឃើញឆ្អឹងលលាដ៍ក្បាលនិងឆ្អឹងផ្នែកផ្សេងៗទៀតរបស់សាកសពមនុស្សដែលសបញ្ជាក់ឲ្យឃើញថា មនុស្សសម័យបុរេ-

---

[14]សូមមើល ដេវិឌ ឆាណ្ឌលើរ *ប្រវត្តិសាស្ត្រខ្មែរ* មជ្ឈមណ្ឌលខេមរសិក្សា ២០០៥ ទំព័រ១៨-៣៤។



www.elibraryofcambodia.org

ប្រវត្តិនោះ ស្រដៀងគ្នានឹងជនជាតិខ្មែរសម័យបច្ចុប្បន្ននេះ ទោះជាខ្មែរសព្វថ្ងៃ មានខ្លះកាត់ចិននិងខ្លះកាត់យួនក៏ដោយ។

អ្នកស្រាវជ្រាវទាំងឡាយនៅតែពិភាក្សា ដើម្បីដឹងថាតើក្រុមមនុស្សដំបូងគេទាំងនោះមានដើមកំណើតនៅប្រទេសចិន ឥណ្ឌា ឬក៏មកពីប្រជុំកោះនៃអាស៊ីអាគ្នេយ៍។ គេក៏នៅតែពិភាក្សាអំពីទ្រឹស្តីខ្លះដែលស្តីអំពី«រលក»ប្រជាជនដែលបានមកដល់បន្តបន្ទាប់គ្នា ហើយដែលបានធ្វើដំណើរឆ្លងកាត់ទឹកដីនេះ នៅសម័យបុរេប្រវត្តិ។ ប៉ុន្តែ តាមការឃើញនាពេលថ្មីនេះ អាស៊ីអាគ្នេយ៍ដីគោកធ្លាប់មានវប្បធម៌ជឿនលឿនល្អម្យ៉ាង តាំងពីយុគសម័យបុរេប្រវត្តិមកម្ល៉េះ។ អ្នកប្រាជ្ញខ្លះសន្មតថាការដាំស្រូវនិងការសិតរូបអំពីលង្ហិន បានកើតមានមុនគេ នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍។ ពិតក្តី មិនពិតក្តី អ្វីដែលប្រាកដនោះគឺថាចាប់ពីដើមគ្រិស្តសករាជមក អ្នកតាំងទីលំនៅនៅលើទឹកដីដែលសព្វថ្ងៃជាប្រទេសកម្ពុជា និយាយភាសាស្រដៀងគ្នានឹងភាសាខ្មែរ បច្ចុប្បន្ននេះដែរ។ ភាសានៃអម្បូរមន-ខ្មែរមានវិសាលភាពធំធេង ក្នុងអាស៊ីភាគអាគ្នេយ៍ដីគោក ក្នុងកោះនៃអាស៊ីអាគ្នេយ៍ខ្លះ និងក្នុងតំបន់ខ្លះនៃប្រទេសឥណ្ឌា។ ភាសាយួនទំនើបក៏ស្ថិតនៅក្នុងអម្បូរភាសាមន-ខ្មែរដែរ ថ្វីបើភាសានេះបានទទួលឥទ្ធិពលពីភាសាចិនយ៉ាងសម្បើមក៏ដោយ។ គេពុំអាចធ្វើការកំណត់អំពីយុគសម័យដែលភាសាទាំងនោះបានបែកចេញពីគ្នាបានឡើយ។ ភាសាវិទូខ្លះជឿថាការបែកចេញពីគ្នានេះបានកើតមានឡើងអស់រយៈពេលរាប់ពាន់ឆ្នាំកន្លងមកហើយ។ ផ្ទុយពីភាសាជនជាតិដទៃទៀតក្នុងអាស៊ីអាគ្នេយ៍ដីគោក ភាសាខ្មែរនិងភាសាយួនមិនមែនជាភាសាថ្មីទើបចូលមកភូមិភាគនេះឡើយ។ ក្នុងចំណោមនិរន្តភាពជាច្រើនទៀត និរន្តភាពនេះធ្វើឲ្យនិស្សិតសិក្សាអំពីអតីតកាល នៃប្រទេសកម្ពុជាមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ដូច្នេះ អ្វីដែលគួរឲ្យចាប់អារម្មណ៍នៅល្អាងស្ពានគឺថាមិនគ្រាន់តែការណ៍ដែលមនុស្សមករស់នៅជាបន្តបន្ទាប់គ្នារហូតមកសតវត្សទី៩ ប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែលសំខាន់នោះ គឺ វិធីសាស្ត្រផ្សេងៗនៃការផលិតនិងការតុបតែងលម្អ ក្អមឆ្នាំងដែលគ្មានការប្រែប្រួល តាំងពីពេលប្រហែល៦០០០ឆ្នាំមកម្ល៉េះ។



www.elibraryofcambodia.org

# ជំពូកទីពីរ

## សាសនា

## ១

## សេចក្តីផ្តើម

*សាសនា* គឺជាពាក្យក្លាយមកពី *សាសន* ដែលបានន័យថា ពាក្យបណ្តាំ ពាក្យផ្តាំផ្ញើ ពាក្យប្រៀនប្រដៅ ឬ ពាក្យបង្គាប់បញ្ជា។ *សាសនា* ក៏អាចពន្យល់ថា ជា ពាក្យបណ្តាំ ឬការទូន្មានប្រៀនប្រដៅរបស់គ្រូអាចារ្យណាមួយក្នុងលោក ដែលអប់រំឱ្យបរិស័ទធ្វើខ្លួនឱ្យក្លាយទៅជាមនុស្សល្អ ដើម្បីឱ្យសង្គមមានសន្តិភាព រីកចម្រើនរុងរឿងនាលោកិយ ។ អត្ថន័យនៃពាក្យសាសនា ឬលទ្ធិសាសនា ពុំមែនស្ថិតនៅត្រង់ជំនឿ ឬ បញ្ញត្តិសីលធម៌ និងការគោរពប្រណិប័តន៍ប៉ុណ្ណោះទេ គឺវាត្រូវមានអង្គការពិសេសមួយសម្រាប់ទ្រទ្រង់ថែរក្សាលទ្ធិសាសនាឱ្យមានស្ថិរភាពតាំងនៅជាស្ថាពរ វែងឆ្ងាយទៀតផង ។

ឯមុខងារនៃសាសនាទាំងអស់ ទោះបីមានលក្ខណៈទ្រឹស្តីនិងការប្រត្តិបត្តិផ្សេងៗ ឬ ក៏ស្របគ្នាក៏ដោយ ក៏តែងមានគោលការណ៍សំរាប់បំពេញដល់សេចក្តីត្រូវការនៃមនុស្សលោក ដូចខាងក្រោម៖

- សម្រាប់បម្រើសេចក្តីត្រូវការនៃមនុស្សម្នាក់ៗ ។
- សម្រាប់ធ្វើសម្ពន្ធភាពនៃមនុស្សម្នាក់ៗ ទៅនឹងអ្នកដទៃ ។
- សំម្រាប់ធ្វើសម្ពន្ធភាពនៃជនគ្រប់រូប ទៅនឹងទីបំផុតទុក្ខ នឹងព្រះអាទិទេព ឬវត្ថុស័ក្តិសិទ្ធិ ។

**សាសនាក្នុងលោកមានដូចជា៖**

- សាសនាព្រាហ្មណ៍ ឬព្រហ្មញ្ញសាសនា មានកំណើតនៅ ឥណ្ឌា ។
- សាសនាព្រះពុទ្ធ ឬព្រះពុទ្ធសាសនា មានកំណើតនៅប្រទេស ឥណ្ឌា ។
- សាសនាគ្រិស្តមានកំណើតនៅប្រទេសស៊ីរី ។
- សាសនាអ៊ីស្លាម មានកំណើតនៅប្រទេសអារ៉ាប់ ។



www.elibraryofcambodia.org

- សាសនាតៅ មានកំណើតនៅប្រទេសចិន ។
- សាសនាសិន្តូ មានកំណើតនៅប្រទេសជប៉ុន ។

## ២
## ជំនឿលើអ្នកតារបស់ជនជាតិខ្មែរមុនសាសនាឥណ្ឌាហូរចូល

### ១- និយមន័យ "អ្នកតា"

ឯកសារមួយចំនួនបានបញ្ជាក់យ៉ាងច្បាស់ថា មុនការចូលមកដល់នូវវប្បធម៌របស់ឥណ្ឌា ខ្មែរមិនទាន់មានសាសនាផ្ទាល់ខ្លួននៅឡើយទេ។ កាលដើមឡើយ ខ្មែរយើងនិយមគោរពកម្លាំងធម្មជាតិដោយគេយល់ថា ធម្មជាតិទាំងឡាយសុទ្ធតែមានព្រលឹង និងមានកម្លាំងស័ក្តិសិទ្ធ ដែលគេមើលមិនឃើញ។ ព្រោះហេតុនេះ ទើបគេយកដុំថ្មតំណាងឱ្យធម្មជាតិមកគោរពហើយនាំគ្នាហៅដុំថ្មនោះថា "អ្នកតា" ឬ "អ្នកដូន ឬយាយ" ដូចជាអ្នកតាទឹក អ្នកតាភ្នំ យាយម៉ៅ និង យាយទេព ជាដើម។

ក្រៅពីគោរពអ្នកតាតាមបែបធម្មជាតិ ក្រោយមកគេក៏នាំគ្នាគោរពអ្នកតាម្យ៉ាងទៀតគឺអ្នកតាតំណាងឲ្យបុព្វការីជន ដែលអ្នកទាំងនោះនៅពេលដែលគាត់នៅរស់រានមានជីវិតគឺជាអ្នកថែរក្សាកូនចៅឬអ្នកស្រុកភូមិរបស់គាត់ អាស្រ័យហេតុនេះហើយទោះបីជាគាត់ស្លាប់បាត់ទៅហើយក៏ដោយ ក៏គេនៅមានជំនឿថាគាត់នៅតែតាមថែរក្សា និងផ្តល់សេចក្តីសុខដល់មនុស្សយើងទូទៅ។

ទោះបីមានការគោរពទៅលើអ្នកតាទាំងពីរខាងលើយ៉ាងណាក៏ដោយ ក៏គេពុំឃើញ មានការរីកចម្រើនលូតលាស់ទេ ព្រោះការគោរពតាមបែបតៗគ្នា គ្មានក្បួនខ្នាតកត់ត្រាចេញជាទស្សនៈ ទ្រឹស្តី ដូចសាសនាផ្សេងៗឯទៀត។ អាស្រ័យហេតុនេះហើយ បានជានៅដើមគ្រិស្តសករាជ ខ្មែរយើងចាប់ផ្តើមទទួលយកលទ្ធិសាសនា ជំនឿសំខាន់ៗពីររបស់ឥណ្ឌា គឺលិទ្ធិព្រហ្មញ្ញសាសនា និងលិទ្ធិព្រះពុទ្ធសាសនា។



www.elibraryofcambodia.org

## ២- ជំនឿលើអ្នកតា

តាមជំនឿរបស់ខ្មែរយើងពីបុរាណ (តាំងពីមុនគ្រិស្តសករាជ) គេចាត់ទុក**អ្នកតា** ជាព្រលឹងនៃ ជនដែលបានស្លាប់ទៅហើយ ប៉ុន្តែព្រលឹងនៅតាមថែរក្សាមើលសុខទុក្ខកូនចៅតទៅទៀត។ អ្នកតាតំណាងមនុស្សស្រី គេហៅថា "អ្នកជួន, ជួន ឬយាយៈ ។ ហេតុមកទល់សព្វថ្ងៃ ក៏ខ្មែរយើងនៅតែជឿ គោរពអ្នកតានៅឡើយ។ ភស្តុតាងជាក់ស្តែងគឺពេលធ្វើបុណ្យឡើងផ្ទះ ស្រោចទឹកលើករាសី រំដោះគ្រោះ ចាត់ចែងពិធីចូលម្លប់ រៀបអាពាហ៍ពិពាហ៍ ក៏គេតែងសែននឹករំលឹកដល់អរុក្ខអារក្ស អ្នកតាសុំសុខសប្បាយ។ ម្យ៉ាងទៀត កាលណាមានមនុស្សឈឺ គេក៏រៀបចំចាត់ចែងពិធីសែនព្រេន ដើម្បីអង្វរករលន់តួអ្នកតា ឱ្យលស់លាប្រណីឲ្យកូនចៅបានសះស្បើយពីជំងឺ។ នៅតាមទីស្ថាន នានា តាមភូមិ តាមវត្តអារាម តាមវាលស្រែចម្ការ ឬ នៅតាមព្រៃភ្នំក្រំថ្ម បឹងបួរ ទន្លេ សមុទ្រ គេតែងប្រទះឃើញខ្ទមអ្នកតាដែលជាធម្មតានៅក្រោមដើមឈើធំ។ ជួនកាលអ្នកតាក៏តាំងទីនៅលើដើមឈើធំណាមួយដោយពុំចាំបាច់មានខ្ទមផងដែរ។ នៅក្នុងខ្ទមអ្នកតា ជួនកាល មានរូបអ្នកតាតំណាងធ្វើអំពីថ្ម ឬឆ្លាក់អំពីឈើខ្លឹម។ គេអាចប្រទះឃើញលិង្គព្រះឥសូរជាតំណាងរូបអ្នកតាខ្លះៗដែរ។ ខ្ទមខ្លះទៀតពុំមានរូបតំណាងទេ។ អ្នកតាទាំងនោះសុទ្ធតែមានឈ្មោះ ឧទាហរណ៍ អ្នកតាក្រហមក យាយទេព ជួនតី ជំទាវម៉ៅ។ល។ ចាស់ៗតែងនិយាយតៗគ្នាថា អ្នកតានៅភូមិណាជាអ្នកតាទទួលបន្ទុក មើលការខុសត្រូវ ថែរក្សាភូមិនោះ ប៉ុន្តែបើមានមនុស្សប្រព្រឹត្តអំពើផ្តាំឆ្គងលើលោកតា មើលងាយ ចំអក គេនឹងទទួលទណ្ឌកម្មពីអ្នកតា ឈឺក្តៅចុកពោះជាដើម។

អ្នកតាខ្លះត្រូវគេឱ្យឈ្មោះយ៉ាងសាមញ្ញថា **"ចាស់ស្រុក"** ដូចជាអ្នកតាឃ្លាំងមឿងជាដើម។ ក៏ប៉ុន្តែ មានអ្នកតាជាច្រើនមានឈ្មោះជាវត្ថុជាទីគោរពសក្ការៈតាមបែបព្រហ្មញ្ញសាសនា ហើយ ប្រហែលជាគេដឹងថា ទីដែលអ្នកតាស្ថិតនៅនោះធ្លាប់មានប្រាសាទបុរាណដែលគេបានសាងសង់ ដើម្បីឧទ្ទិសបុគ្គល ឬ វត្ថុជាទីគោរពសក្ការៈទាំងនោះជាញឹកញាប់បំផុត។ នៅកន្លែងមួយចំនួន គេឃើញ នៅក្នុងខ្ទមអ្នកតា មាន


www.elibraryofcambodia.org

បំណែកនៃរូបចម្លាក់ចាស់ៗ ដែលជាភ័ស្តុតាងបញ្ជាក់ថាមានប្រាសាទ ដែលបច្ចុប្បន្ននេះ បានរលាយបាត់ទៅហើយ។

អ្នកតាគ្រាន់តែព្រមានប្រដៅកូនចៅខ្លះៗ ដើម្បីឱ្យរាងចាល និង កែប្រែកំហុស។ ចំណែកឯអ្នកតាដែលនៅតាមវាលស្រែចំការវិញនោះ ក៏ខ្មែរយើងជឿថា ជាព្រលឹងដូនតា ដែលនៅចាំជួយថែរក្សាផលដំណាំ និង គ្រប់គ្រងទឹកដីនៃតំបន់នោះផងដែរ។ នៅតាមដើមឈើធំខ្លះ នៅតាមដំបូកមុមស្រែ មានអ្នកតាដែលគេតែងឱ្យឈ្មោះថា "អ្នកតាព្រះភូមិ"។ មុនពេលដែលគេភ្ជួររាស់ស្រែនោះដើម្បីស្ទូង គេត្រូវធ្វើពិធីសែនព្រេនអ្នកតាព្រះភូមិនេះជាចាំបាច់។ ពេលរាស់ស្រែចប់សព្វគ្រប់ហើយគេចាត់តាំង ពិធីបំបោសនោស់ (ប្រណាំងនោស់)។ រួចហើយគេបរគោទាំងនោស់មកជុំគ្នាត្រង់មុមស្រែដែលមានដំបូក ឬ ដើមឈើធំ ដែលអ្នកតាព្រះភូមិស្នាក់នៅ។ កសិករដែលចូលរួមភ្ជួររាស់ទាំងប៉ុន្មានអង្គុយ លើកដៃប្រណម្យសែនព្រេន ដោយមានបាយសម្ល បង្អែម ចម្អាបដាក់ក្នុងច្រមមួយមុខបន្តិចៗ។ ទាំងអស់គ្នានិយាយថា "ឱថ្ងៃនេះថ្ងៃជាវេលាល្អ គុណព្រះតេជៈម្ចាស់ថ្លៃ យើងខ្ញុំសុំទឹក សុំដីធ្វើស្រែ ដាំព្រះពៃស្រពណ៍ (ស្រូវ) សូមលោកតាជួយថែរក្សាកុំឱ្យសត្វស៊ីបំផ្លាញ និង សូមឱ្យបានផលផ្លែផ្កា ដងដើមល្អ ព្រមទាំងសត្វពាហនៈ គោក្របីបានសុខប្រាសចាកជំងឺដង្កាត់នានា។" គេសែនព្រេនរបៀបនេះ ជាគម្រប់បីដង ទើបច្រូចស្រា ច្រូចទឹកជាកិច្ចបញ្ចប់។ ថ្ងៃនោះក៏ជាថ្ងៃរីករាយចំពោះកសិករដែលចូលរួមធ្វើស្រែនោះផងដែរ ព្រោះគេបរិភោគសាច់មាន់ស្ងោរ ឬ ក្បាលជ្រូក ផឹកស្រារួមគ្នា ក្នុងស្មារតី សាមគ្គីជាភាតរៈ។ អ្នកតាខ្លះទៀត ដែលមានទីតាំងនៅទួលធំនៅចុងឬដើមភូមិ គេតែងធ្វើបុណ្យ ថ្វាយជាកិត្តិយសមួយឆ្នាំម្តង ដើម្បីសុំសេចក្តីសុខសប្បាយ។ ជួនកាលនៅពេលកើតមានអសន្តិសុខ ចម្បាំងរាំងជល ជំងឺរាតត្បាតប្រកបដោយគ្រោះអាសន្នដូចជាជំងឺអុតធំ អាសន្នរោគ (អាហិវាតរោគ) រាំងភ្លៀងនោះ ក៏អ្នកស្រុកធ្វើបុណ្យបន់ស្រន់ឱ្យអ្នកតា សុំឱ្យអ្នកតាជួយការពារកូនចៅឱ្យរួចពីគ្រោះភ័យ និងជួយបណ្តេញកំចាត់បង់គ្រោះកាចចង្រៃឱ្យចេញឆ្ងាយពីភូមិស្រុកទៀតផង។


www.elibraryofcambodia.org

សូម្បីតែក្នុងព្រៃ នៅលើភ្នំ ក៏មានអ្នកតាប្រចាំការ ត្រួតត្រា មើលការខុសត្រូវដែរ។ ថ្មើរព្រៃទាំងឡាយ កាលបើដើរទៅកន្លែងអ្នកតាព្រៃភ្នំហើយ ក៏តែងតែកាច់ស្លឹកឈើថ្វាយលោកតា ដោយគេនាំគ្នាសន្មតថា "ថ្វាយធ័ត្រ" ។ ដូច្នេះ គេឃើញគំនរស្លឹកឈើជាច្រើននៅត្រង់ទីដែលអ្នកតាតាំងនៅ ប្រសិន បើគេបរិភោគបាយកញ្ចប់នៅទីនោះ គេក៏មិនភ្លេចបេះបាយមួយចំណីផ្សេងៗ សែនព្រេនអ្នកតា ដើម្បីសុំសេចក្តីសុខសប្បាយ ឬ សុំឱ្យការបរបាញ់សត្វ ដាក់អន្ទាក់ រកឈើព្រៃ ទទួលបានលាភជ័យ។ អ្នកតាខ្លះមានរូបតំណាងដូចជាអារក្សដែរ។ អ្នកតាប្រភេទនេះច្រើនតែជាអ្នកតាថ្នាក់ធំនៅទីរួមស្រុក ឬ ទីរួមខេត្ត។ ជួនកាលបើកន្លែងដែលអ្នកតាស្នាក់នៅនោះជាដើមឈើធំ ជាទីទួលដែលគេត្រូវការយក មកធ្វើជាប្រយោជន៍រួម ដូចជាកាប់ឈើនោះយកមកសង់ព្រះវិហារ កុដិ មន្ទីរពេទ្យ គេប្រារព្ធពិធីឧបកិច្ច សុំអ្នកតា អញ្ជើញអ្នកតា ផ្ទេរអ្នកតាឱ្យចេញទៅនៅទីណាមួយផ្សេងទៀតតាមរបៀបឧបកិច្ច។ ដូច្នេះ គេនាំគ្នាក្លែងធ្វើលិខិតមួយរៀបរាប់អំពីគោលបំណង និង ផលប្រយោជន៍ដែលអ្នកស្រុកនៅតំបន់នោះត្រូវការជាចាំបាច់។ វិធីមួយសំខាន់បន្ថែមពីលើនេះទៀត លោកមេឃុំ លោកចៅហ្វាយស្រុកបានធ្វើលិខិតបង្គាប់ការសុំផ្លាស់លោកតាទៅនៅកន្លែង ឬ ត្រង់ដើមនោះវិញ សឹងមានត្រា និង ហត្ថលេខា របស់លោកធំទាំងពីររូបនៅលើលិខិតនោះស្រាប់។ គេយកបញ្ជាបេសកកម្មនោះមកសូត្រ (អាន) នៅចំពោះមុខទីតាំងរបស់អ្នកតា ដោយមានចាស់ទុំ និង បណ្តាជនក្នុងស្រុកភូមិ ជាច្រើនចូលរួមផង។ ធ្វើពិធីនោះរួច គេបិទលិខិតនៅទីនោះ។ រួចហើយគេអាចកាប់ដើមឈើនោះ ឬ យកទីនោះមក ចាត់ចែងធ្វើអ្វីៗបានដោយពុំទទួលទុក្ខទោស ឬ គ្រោះភ័យអ្វីឡើយ។

ម្យ៉ាងវិញទៀត ប្រសិនបើគេចង់បណ្តេញកំចាត់លោកតាឱ្យចេញពីទីតាំងនោះ គេអាចប្រើមធ្យោបាយផ្សេងទៀតរបៀបហិង្សាជាងមុន តែក៏ពុំមានរងគ្រោះថ្នាក់ពីការសងសឹករបស់លោកតា ដែរ។ នោះគឺគេធ្វើកិច្ចកលយកអុស និង ចំបើងទៅផ្ទែកទៅគរលើគល់ឈើជាលំនៅរបស់អ្នកតា ដោយពោលពាក្យផ្អែមល្ហែមថា " ឱ! លោកតាអើយខ្ញុំសូមផ្ញើអុស និង ចំបើងនៅទីនេះ សូមលោកតា ជួយមើលឱ្យល្អឱ្យខ្ញុំផង! " ។


www.elibraryofcambodia.org

លុះថ្ងៃក្រោយមកទៀតគេធ្វើជាយកចំបើងទៅរាយបន្តពីគំនរនៅគល់ ឈើជាទីស្នាក់នៅរបស់អ្នកតាចេញឆ្ងាយពីទីនោះដោយយកគុម្ពោត ឬ ដំបូកណាមួយធ្វើជារបាំង។ នៅថ្ងៃកំណត់ដែលត្រូវអនុវត្តផែនការ គេយកភ្លើងទៅលួចដុតចំបើង ត្រង់ទីកំបាំងនោះឱ្យឆេះទ្រលោម ហើយគេក៏រត់បណ្តើរស្រែកបណ្តើរថា " លោកតាអើយប្រយ័ត្ន! ភ្លើងឆេះទៅហើយ សូមលោកតាជួយលត់ភ្លើងផង ឆេះអុសចំបើងខ្ញុំអស់ហើយ។ លោកតាអើយ! មើលទៅលោកតាមិនអាចលត់ភ្លើងបានទេ សូមលោកតាជញ្ជូនកូនចៅ និងរបស់របរចេញទៅឱ្យឆ្ងាយពីនេះទៅ កុំឱ្យមានគ្រោះថ្នាក់ ផ្ទះលោកតាត្រូវភ្លើងឆេះអស់ហើយ ហើយមិនអាចនៅទៀតបានឡើយ" ។ ធ្វើបែបនេះគេអាចកម្ចាត់លោកតាដោយស្របច្បាប់ ដោយពុំខ្លាចទទួលរងគ្រោះថ្នាក់ពីការសងសឹករបស់លោកតាឡើយ។

៣

## លទ្ធិសាសនាព្រាហ្មណ៍នៅក្នុងសង្គមខ្មែរ

### ១- ប្រភព និង វត្តមានសាសនាព្រាហ្មណ៍ក្នុងប្រទេសកម្ពុជា

ព្រហ្មញ្ញសាសនា ត្រូវបាននាំចូលប្រទេសឥណ្ឌាដោយពួក អារ្យៈ (Arya) ឬពួកអារ្យ៉ែន (Aryan) ។ ក្នុងស្នាដៃ *វប្បធម៌ខ្មែរសម្រាប់ថ្នាក់ទីបញ្ចប់* របស់អ្នកស្រី ត្រឹង ងា អ្នកស្រីបានបញ្ជាក់ថា៖ "ប្រមាណជា ១៥០០ ឆ្នាំ មុនគ្រិស្តសករាជ ពួកអារ្យនេះបានលុកលុយប្រទេសអ៊ឺរ៉ុបមួយផ្នែក និង មួយផ្នែកទៀតបានលុកលុយប្រទេសឥណ្ឌាភាគខាងជើង។ ក្រោយពីបានជ័យជំនះពីពួកដ្រាវីឌ ដែលជាឥណ្ឌាស្បែកខ្មៅមក ពួកនេះបានគ្រប់គ្រងលើពួកម្ចាស់ស្រុក ហើយក៏ចាប់ផ្តើមផ្សព្វផ្សាយឥទ្ធិពលលទ្ធិសាសនាព្រាហ្មណ៍ពីពេលនោះមក ។ ពួកព្រាហ្មណ៍ជាអ្នកមានភារៈថែរក្សាជំនឿ និង ផ្សព្វផ្សាយលទ្ធិសាសនាព្រាហ្មណ៍ ។ គេបានរៀបចំកែច្នៃផ្លាស់ប្តូរទស្សនៈនិងទ្រឹស្តីឱ្យកាន់តែ



www.elibraryofcambodia.org

ប្រសើរឡើងជាលំដាប់ ។"

ចំណែកឯអ្នកស្រី ហ្សីតូ (Madelene Giteau) វិញ គាត់បានបញ្ជាក់ក្នុងលទ្ធិនេះ របស់គាត់ថា៖ "មូលដ្ឋានគ្រឹះនៃអរិយធម៌ខ្មែរមានសាសនាពីរ ដែលបានទទួលឥទ្ធិពលពីឥណ្ឌាគឺ ព្រហ្មញ្ញសាសនា និង ព្រះពុទ្ធសាសនា ។ ឥទ្ធិពលនេះមានការអះអាងច្បាស់ និងត្រូវគេរកឃើញតាមរយៈអក្សរសាស្ត្រ ខ្មែរ សិល្បៈខ្មែរ និងក្នុងសង្គមខ្មែរ ។ មុនសម័យនគរភ្នំ គ្រប់ប្រទេសទាំងអស់នៅអាស៊ីអាគ្នេយ៍បាន ទទួលឥទ្ធិពលអរិយធម៌ឥណ្ឌា ។ ដល់សតវត្សទី ១ នៃគ្រិស្តសករាជ បាតុភូតនេះមានដំណើរការយឺតៗតែរីកចម្រើនទៅមុខ ។" អ្នកប្រវត្តិសាស្ត្របានរកឃើញថា លទ្ធិព្រហ្មញ្ញសាសនា ដែលបានផ្សព្វផ្សាយនៅប្រទេសកម្ពុជាមានចន្លោះយឺតរហូតដល់ចូលស៊ិបតែម្តងនេះ គឺវាតាមរយៈស្តេចឥណ្ឌា និង ឈ្មួញឥណ្ឌាដែលបានចេញចូលស្រុកខ្មែរ ។ មានរឿងមួយនិទានថា មានស្តេចឥណ្ឌាមួយអង្គ ព្រះនាម **កៅណ្ឌិន្យ** បានលើកទ័ពជើងទឹកមកច្បាំងដណ្តើមទឹកដីខ្មែរដែលមានស្តេចស្រីមួយព្រះអង្គ ព្រះនាម **សោមា** សោយរាជ្យនៅនគរគោកធ្លក។ ដោយធ្វើសង្គ្រាមចាញ់ ព្រះនាង សោមា ត្រូវរៀបអភិសេកជាមួយព្រះបាទកៅណ្ឌិន្យ ហើយគ្រប់គ្រងនគរគោកធ្លក តរៀងមក ។ តាមស្រឡាយខ្មែរ ព្រះបាទកៅណ្ឌិន្យ បានដាក់ឈ្មោះជា ហ៊ុន ទៀន វិញ ទើបគេសន្និដ្ឋានថា ប្រទេសខ្មែរទទួលយកឥទ្ធិពលលទ្ធិព្រហ្មញ្ញសាសនា តាមរយៈក្សត្រអង្គនេះ ។

អំណះអំណាងមួយទៀតបានរកឃើញថា ពួកឈ្មួញឥណ្ឌាតែងតែធ្វើដំណើរតាមសំពៅ មកទាក់ទងរកស៊ីជួញដូរជាមួយអ្នកស្រុក ហើយបានរៀបការជាមួយស្ត្រីខ្មែរទៀតផង ។ ពួកនេះបានបង្កជាពូជពង្សកូនចៅនៅក្នុងស្រុកខ្មែររហូតមក ។ ហេតុនេះហើយ បានជាទំនៀមទម្លាប់ប្រពៃណីឥណ្ឌាបានបន្សល់ទុកពីពេលនោះមក ។ មានការអះអាងច្រើនទៀតនិងប្លែកៗ តែខ្លឹមសារបានបញ្ជាក់ ឯកភាពគ្នាថា ព្រហ្មញ្ញ-សាសនាបានទទួលឥទ្ធិពលពីប្រទេសឥណ្ឌាមែន ។ ឥទ្ធិពលបានចាក់ឫសយ៉ាងមាំ ក្នុងចិត្ត ក្នុងសង្គមខ្មែរ ក៏ដូចជា ជំនឿ ប្រពៃណី ភាសា អក្សរ ជាពិសេសសិល្បៈស្ថាបត្យកម្មខ្មែរបុរាណ។



www.elibraryofcambodia.org

គេរកឃើញថា ក្នុងរជ្យព្រះបាទភវវរ្ម័ន និងរជ្យព្រះបាទឥសានវរ្ម័ន មានការ-គោរពព្រះហរិហរៈ ដែលមានទ្រង់ទ្រាយព្រះឥសូរនិងព្រះវិស្ណុលាយចូលគ្នា។ ព្រះព្រហ្ម ក៏ត្រូវបានរកឃើញថា មានការគោរពខ្លះដែរ តែព្រហ្មញ្ញសាសនានៅមានឥទ្ធិពលខ្សោយនៅឡើយ ។ ក្រោយរជ្ជកាលរបស់ព្រះអង្គ ជាច្រើនជំនាន់មក គេសង្កេតឃើញ ថា អ្នកស្រុកនៅតែប្រកាន់យកលទ្ធិព្រហ្មញ្ញសាសនាដដែល ។ នៅក្នុងរជ្យជ័យវរ្ម័នទី២ ព្រហ្មញ្ញសាសនាកាន់តែលូតលាស់ឡើងព្រោះមានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ក្សត្រខ្មែរ និង នាម៉ឺនមន្ត្រីក្នុងរាជវាំង ។ ព្រហ្មញ្ញសាសនានាពេលនោះ គេគោរពព្រះឥសូរជាធំ ។ រហូតដល់គេបានចាត់ទុកថា ព្រហ្មញ្ញសាសនាជាទឹកបន្សាបវាំងរដ្ឋពីរដែលបែកបាក់ មកជារដ្ឋមួយមានឯកភាពទូទាំងប្រទេស ។ នៅពេលនោះ គេបានយកកំពូលភ្នំគូលែនធ្វើជា កន្លែង រៀបចំពិធី ដែលគេហៅថា *ព្រះរាជ្យចក្រវាល* ។

សតវត្សទី១២ នៃរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ ព្រះអង្គប្រកាន់យកលទ្ធិព្រហ្មញ្ញសាសនា តែគោរពព្រះវិស្ណុជាធំ។ ការអះអាងនេះបញ្ជាក់តាមរយៈក្បាច់រចនា និង ចម្លាក់ជាច្រើន ដែលគេសាងឡើងតាមប្រាសាទនានាដូចជា រូបអវតារព្រះវិស្ណុ ឬរឿងព្រេងដែលឆ្លាក់តាមរយៈជញ្ជាំងប្រាសាទ ដូចជារឿងរាមាយណៈឥណ្ឌា រឿងមហាភារតយុទ្ធជាដើម ។

នៅសតវត្សទី ១៣ ថ្វីបើព្រហ្មញ្ញសាសនាត្រូវប្រជាជនអស់ជំនឿទៅហើយក្តី តែគេអាចនិយាយបានថា ព្រហ្មញ្ញសាសនាមិនលោយសាបសូន្យឡើយ ព្រោះព្រះបាទជ័យវរ្ម័នទី៧ ដែលមានជំនឿទៅលើព្រះពុទ្ធសាសនាមហាយាន បានបង្កលក្ខណៈឲ្យព្រហ្មញ្ញសាសនា មានជីវិតរស់នៅ ពុំបាត់បង់ឡើយ ។

លទ្ធិព្រហ្មញ្ញសាសនាត្រូវបានបន្តគោរពវិញ តាមបែបការគោរពព្រះឥសូរជាធំគឺក្នុងឱកាស នោះហើយដែលអ្នកប្រវត្តិសាស្ត្រទទួលស្គាល់ថា មានប្រតិកម្មសាសនាបានន័យថា អ្នកដែលងប់ងល់ នឹងជំនឿព្រហ្មញ្ញសាសនាបានវាយបំបាក់ធ្វើឱ្យខូចខ្ទីរទាំងពុទ្ធរូប ទាំងបដិមា និង ព្រាហ្មណាស្រមនៃលទ្ធិព្រហ្មញ្ញសាសនាដែរ ដូចជាការគាស់រំលើង ឬវាយបំបាក់ និង នាំយកទៅទម្លាក់ ចោលនៅបាតស្រះស្រង់ ឬ បឹង អូរ



www.elibraryofcambodia.org

ទន្លេជាដើម ។

លុះដល់សតវត្សទី ១៤ ព្រហ្មសាសនាអស់ឥទ្ធិពល តែជំនឿផ្សេងៗនៃលទ្ធិនេះ បានបន្សល់រហូតរៀងមក ។ សព្វថ្ងៃ គេឃើញមានសល់ដូចជា ពិធីអភិសេកមហាក្សត្រ ពិធីបន់ស្រន់សុំទឹកភ្លៀង សុំសេចក្ដីសុខពីអ្នកតាម្ចាស់ភូមិករ ព្រះធរណី អារក្ស ពិធីជំឡើងគ្រូតូច គ្រូធំ ពិធីសែនព្រេន ពិធីបង្វិលពពិល ស្រោចទឹកមន្ត ប្រើយ័ន្ត អាបធ្មប់ ។ល។

នេះហើយជាប្រភព ដែលចេញពីវត្តមានរបស់លទ្ធិព្រហ្មញ្ញសាសនាអនុវត្តនៅប្រទេសខ្មែរយើងកន្លងមក ។

## ២- ដំណាក់កាលវិវឌ្ឍន៍នៃព្រហ្មញ្ញសាសនា

ព្រាហ្មណ៍សាសនានេះចែកចេញជា ៣ សម័យធំៗគឺៈ

-សម័យវេទនិយម (១៥០០ ឆ្នាំដល់ ៥៥០ ឆ្នាំមុនគ.ស.)

-សម័យព្រាហ្មណ៍និយម (៥៥០ ឆ្នាំមុនគ.ស. ដល់ ស.វទី១០ នៃគ.ស.)

-សម័យហិណ្ឌូនិយម (ស.វ. ទី ១០ រហូតមក)

## ២.១- អំពីវេទនិយម

### ២.១.១- គម្ពីរវេទ

អត្ថបទទាំងអស់ស្ដីពីសាសនាដែលជនជាតិអារ្យ៉ននាំចូលមកក្នុងប្រទេសឥណ្ឌា គេឱ្យឈ្មោះ ថា *វេទ* ដែលប្រែថា «ចំណេះដឹង»។ អត្ថបទទាំងអស់នោះច្រើនតែជាមន្តសម្រាប់សូត្រចំពោះទេវៈ ក្នុងឱកាសធ្វើពិធីបូជា ជាពិសេសក្នុងពិធីបូជាយញ្ញ។ គម្ពីរវេទដែលសរសេរជាអក្សរសំស្ក្រឹតគឺជាប្រភពនៃសាសនាឥណ្ឌូឬសាសនាព្រាហ្មណ៍ និង ជាមូលដ្ឋាននៃវិទ្យាសាស្ត្រឥណ្ឌាទាំងអស់ ។

វេទនិយម គឺជាចលនាវប្បធម៌ឥណ្ឌា ដែលនិយមអោយតម្លៃទៅលើគម្ពីរវេទ ។ វេទនិយមសិក្សា អនុវត្តតាមទស្សនៈ ទ្រឹស្ដី ដែលមានរៀបរាប់នៅក្នុងគម្ពីរវេទ ពោលគឺជាចលនាវប្បធម៌ ដែលមានគម្ពីរវេទជាមូលដ្ឋាន ។ ចំណេះវិជ្ជាគ្រប់បែបយ៉ាង របៀប



www.elibraryofcambodia.org

រស់នៅ ទំនៀមទម្លាប់ គោលការណ៍អប់រំ ការគ្រប់គ្រងស្រុកទេស ការរៀបចំសង្គមមនុស្ស ក៏មានអធិប្បាយនៅក្នុងគម្ពីរវេទនេះដែរ ។

គម្ពីរវេទមាន ៤ **ចំណែក**គឺ៖

**ក- ឫគវេទ** ៖ មន្តបទសម្រាប់សូត្រអង្វរ បន់ស្រន់ បួងសួង និងសរសើរអាទិទេព ដូចជា ព្រះឥន្ទ្រ ព្រះវាយុ ព្រះអគ្និ ព្រះធរណី និង ព្រះចន្ទ្រជាដើម ដើម្បីធ្វើឱ្យអាទិទេពទាំងអស់នេះពេញចិត្ត ហើយជួយឱ្យបានសម្រេចបំណងផ្សេងៗ ។ ក៏ប៉ុន្តែ ឫគវេទពុំមែនមានតែបទគាថាសម្រាប់បួងសួង សរសើរប៉ុណ្ណោះទេ គឺវាមានបទគាថាផ្សេងៗទៀតដូចជា៖

. បទគាថា សំរាប់សូត្រធ្វើវិតី (សូត្រក្នុងពិធីបុណ្យនៃសាសនាព្រាហ្មណ៍)

. បទគាថា សំរាប់សូត្រក្នុងពិធីបូជាយញ្ញ

. បទគាថា អធិប្បាយពីទស្សនវិជ្ជា ។

(ឫគវេទជាអត្ថបទបរមបុរាណ ហើយសំខាន់ជាងគេក្នុងចំណោមគម្ពីរទាំង៤។)

**ខ- សាមវេទ៖** ជាកម្រងបទឆន្ទៈសម្រាប់សូត្រក្នុងពិធីគង្វាយចំពោះទេវៈ (ព្រះឥន្ទ, ព្រះអគ្និ, ព្រះវាយុ, ជាដើម) ។ សាមវេទ មានអត្ថបទចម្រៀងផ្សេងៗដូចជា៖

- ចម្រៀងដែលគេទុកច្រៀងនៅក្នុងស្រុកភូមិ ពីព្រោះនាំឱ្យកើតជ័យមង្គលសិរីសួស្តី ក្នុងនោះ ក៏មានចម្រៀងសម្រាប់ទុកតែច្រៀងក្នុងព្រៃដែរ ។

- ក្រៅពីនេះ អត្ថបទសាមវេទជាសេចក្តីពន្យល់ឱ្យចេះធ្វើបទ ឱ្យចេះផ្លាស់ប្តូរក្នុងពេលសូត្រ ឱ្យជាវែង ជាខ្លី ឬជាដដែលៗ។ អត្ថបទខ្លះទៀតនិយាយពីហេតុអស្ចារ្យផ្សេងៗ និយាយពីរឿងព្រេង របស់ជនដែលមានឥទ្ធិពលមកលើពួកអារ្យ៉ន ជាដើម។

**គ- យជុរវេទ** ៖ យជុរវេទមកពីពាក្យ *យជុស* ប្រែថា ការបូជា ។ ដូចនេះ យជុរវេទជាកម្រង គាថាស្តីពីបូជាយញ្ញ និង បួងសួងទេវៈ ។ យជុរវេទ ចែកជា ២ ផ្នែកគឺ៖

*យជុរវេទ-ស* ជាអត្ថបទដើមមានបែបផែនល្អ រៀបចំត្រឹមត្រូវ ជាការប្រាប់បង្ហាញ



www.elibraryofcambodia.org

របស់ អាទិទេព។ បទគាថានេះសំរាប់សូត្រក្នុងពិធីបូជាយញ្ញ ។

*យជុរវេទខ្មៅ* ជាអត្ថបទរៀបចំពុំបានត្រឹមត្រូវ ជាអត្ថបទពាក្យរាយបន្ថែមក្រោយ សម្រាប់ពន្យល់ឱ្យចេះធ្វើពិធី ។ អត្ថបទនេះក៏មានបន្ថែមការនិយាយអំពីការបូជាសំខាន់ៗដូចជា៖

- ការបូជាដែលក្សត្រ ឬ ព្រាហ្មណ៍ធ្វើ ដើម្បីបូជាទេវតាសោម (ទេវតាសោយទឹកសោម គឺទឹកស្រាសោម ផ្សំដោយដើមឈើឈ្មោះសោម។)

- ការបូជាដែលក្សត្រធ្វើក្នុងពិធីរាជាអភិសេក

- ការបូជាដែលក្សត្រធ្វើពង្រីកទឹកដី ពង្រីកកិត្យានុភាពឱ្យទៅជាស្តេចចក្រពត្តិជាដើម ។

**ឃ- អថវវេទ** ៖ អថវ៌/អថព្វ គឺជាឈ្មោះព្រាហ្មណ៍ម្នាក់ ដែលបានបង្កើតគម្ពីរនេះឡើង។ អថវវេទពុំមែនជាវេទអធិប្បាយពីការបួងសួង ឬសូត្រសរសើរដូចវេទទាំងបីខាងលើទេ ។ ផ្ទុយទៅវិញ វេទនេះនិយាយអំពីមន្រ្ត:/មន្ត, អាគម, អាគមគាថា ដែលជាពាក្យស័ក្តិសិទ្ធ ចងក្រងជាវគ្គ ឃ្លា រៀបតាមខ្យល់ អក្សរ សម្រាប់ សូត្រ ស្តោះផ្លុំ ។ អាគមក្នុងវេទមានច្រើនយ៉ាង៖

. មន្តសម្រាប់សូត្រអោយសះស្បើយជំងឺ

. មន្តសម្រាប់សូត្រឱ្យអាយុវែង

. អាគមលើករាសី

. មន្តសម្រាប់សូត្រឱ្យអាយុវែង, ឱ្យអ្នកធំចូលចិត្ត

. អាគមហៅពស់

. មន្តសម្រាប់សូត្ររំដោះគ្រោះ ឱ្យផុតឧបទ្រពចង្រៃ បណ្តេញខ្មោចបិសាច

. មន្តសំរាប់សូត្រឱ្យបានចម្រើន មានសេរីសួស្តី ជាដើម ។

ក្រៅពីនេះ មានវិជ្ជាផ្សេងៗជាច្រើនទៀតដែលពួកព្រាហ្មណ៍បានរៀបចំ ហើយបញ្ចូលទៅក្នុងគម្ពីរវេទ ៖ វិជ្ជាយុទ្ធសាស្រ្ត វិជ្ជាសង់ផ្ទះ/ប្រាសាទ វិជ្ជាភ្លេង របាំ វិជ្ជាធ្វើគ្រឿងឈើ ជាដើម ។



www.elibraryofcambodia.org

### ២.១.២- វណ្ណៈ

*វណ្ណៈ* ជាពាក្យកម្ចីមកពីពាក្យបាលី *វណ្ណ* ដែលមានន័យដូចគ្នានឹងពាក្យសំស្ក្រឹត *វណ៌* ដែល មានន័យដើមថា *ពណ៌ , សម្បុរ, ពន្លឺ, រស្មី, ភេទ ថ្នាក់វង្ស, ពូជ* ។ ប៉ុន្តែ ក្នុងភាសាខ្មែរ ពាក្យ វណ្ណៈ ត្រូវបានគេប្រើប្រាស់សម្គាល់ន័យថា ថ្នាក់វង្ស ឬ ឋានៈសង្គម ឯពាក្យ *វណ៌* ប្រើក្លាយជា *ពណ៌* មានន័យថា សម្បុរ ។

វណ្ណៈក្នុងសាសនាព្រាហ្មណ៍មាន ៤ ហើយវណ្ណៈទាំង ៤ នេះត្រូវស្លៀកសំពត់ដណ្តប់ដែលមាន *ពណ៌* ខុសៗគ្នា ។ ការចែកវណ្ណៈនេះគឺចែកដោយពណ៌សំពត់នេះឯង ។ វណ្ណៈទាំង ៤ ក្នុង សាសនា ព្រាហ្មណ៍មាន ៖

. *វណ្ណៈព្រាហ្មណ៍* ប្រើពណ៌ស កើតពីព្រះឱស្ឋព្រហ្ម ជាម្ចាស់សាសនា មានមុខការ ជាអ្នកបង្រៀនវេទ ឬ មន្តវិជ្ជាផ្សេងៗ ។

. *វណ្ណៈក្សត្រ* ប្រើពណ៌ក្រហម កើតពីព្រះពាហា (កំភួនដៃ) ព្រហ្ម មានមុខការជាអ្នកចំបាំងអ្នកគ្រប់គ្រងនគរ ។

. *វណ្ណៈវៃស្យៈ* ប្រើពណ៌លឿង កើតពីឧរុ (ភ្លៅ) ព្រហ្ម មានមុខការខ្ពង់ខ្ពស់ចុះរងពីវណ្ណៈក្សត្រមក ឬកិច្ចការធម្មតា ។

. *វណ្ណៈសូទ្រៈ* ប្រើពណ៌ខ្មៅ កើតពីព្រះបាទព្រហ្ម មានមុខការខាងស៊ីឈ្នួល ឬការងារថយថោកផ្សេងៗ (គឺអ្នកបម្រើ ឬ វណ្ណៈខ្ញុំគេ) ។

### ២.១.៣- លំនៅរបស់អាទិទេព

អាទិទេពមានលំនៅនៅស្ថានសួគ៌, ស្ថានមនុស្ស, ក្នុងខ្លួនមនុស្ស (អាទិទេពមានរូបស្ថិតនៅជាមួយមនុស្ស ជួយមនុស្សឱ្យបានឃើញជាក់ស្តែងនឹងភ្នែកគួរគោរព), ដាច់ពីស្ថានមនុស្ស ឬ លើអាកាស (ក្នុងសង្គមមនុស្ស) ។

### ២.២- ព្រាហ្មណ៍និយម

ពួកព្រាហ្មណ៍គឺអ្នកកាន់ អ្នកផ្សាយព្រហ្មញ្ញសាសនា ។ លទ្ធិរបស់ពួកព្រាហ្មណ៍មានឈ្មោះថា ព្រាហ្មណ៍និយម។ ព្រាហ្មណ៍និយមគឺជាទ្រឹស្តីតាមបែបពួកព្រាហ្មណ៍ ។



www.elibraryofcambodia.org

ពួកព្រាហ្មណ៍ជាអ្នកគោរពបូជាអាទិទេព។ គេជឿថា បញ្ហាអាទិទេពពុំមែនជាបញ្ហាអស្ដិរូបនិយមទេ វាគឺជាបញ្ហាដែលគេចាត់បញ្ចូលក្នុងទស្សនវិជ្ជារូបនិយម។ អាស្រ័យហេតុនេះហើយ បានជាគេធ្វើឱ្យព្រះអាទិទេពរបស់គេជាតួអង្គមានរូបរាង មានគ្រួសារ មានបញ្ហាដូចមនុស្សដែរ ។

**ព្រះអាទិទេពសំខាន់មាន ៣ អង្គគឺ៖**

- ព្រះព្រហ្ម ( Brahma )
- ព្រះសិវៈ ( Shiva )
- ព្រះវិស្ណុ ( Vishnu )។

**ឯព្រះអាទិទេពរាយរងមាន៖**

-ព្រះអាទិត្យ - ព្រះចន្ទ - ព្រះធរណី

- ព្រះគង្គា - ព្រះពាយ - ព្រះភិរុណ ជាដើម។

**ក- ព្រះព្រហ្ម**

ព្រះព្រហ្មមានលក្ខណៈពិសេស សម្រាប់សម្គាល់ដូចតទៅ៖



- មុខ ៤
- ដៃ ៤ កាន់គម្ពីវេទទាំង៤
- កាយសម្បុរផ្កាឈូក
- សម្លៀកបំពាក់ពណ៌ស
- កេតនភ័ណ្ឌ ថូ, ផ្គាំ, ស្លាបព្រា, ចាស
- ជួនកាល ព្រះព្រហ្មឈរ ស្មៀម ជួនកាលទៀតអង្គុយនៅលើផ្កាឈូកដែលដុះចេញពី ផ្ចិតរបស់ព្រះវិស្ណុ។
- មានសត្វហង្សជាជំនិះ
- មានមហេសី១អង្គនាមនាងសរស្វតី (ទេពធីតាបង្កើតចំណេះវិជ្ជានិងភាសា)

មានបុត្រ ៣ អង្គ គឺព្រះទក្សៈ, ព្រះភូគុ, និង ព្រះនាងសំធ្យា ឬ សន្ធិយា ។


www.elibraryofcambodia.org

សង្កេត៖

- គម្ពីរវេទបានចែងថា ព្រះព្រហ្មជាព្រះអាទិទេពច្បងគេ ជាព្រះអាទិទេពបង្កើតលោកនិងភាវៈ ព្រមទាំងជាអ្នកបង្កើតគម្ពីរវេទទាំង ៤ ទៀតផង (ព្រះព្រហ្មពុំមានសកម្មភាពអ្វីសំខាន់ទេ ក្នុងសាសនាហិណ្ឌូ) ។
- ព្រះព្រហ្ម កាលបានបង្កើតលោក ភាវៈ និងគម្ពីរវេទរួចហើយ ក៏គង់នៅស្ងៀមលែងមានចលនាអ្វីទាំងអស់ ។
- នៅប្រទេសកម្ពុជា គេឃើញមានរូបចម្លាក់ព្រះព្រហ្មបន្តិចបន្តួច ។

## ខ- ព្រះសិវៈ

ព្រះសិវៈមានលក្ខណៈពិសេសសម្រាប់សំគាល់ដូចតទៅ៖

- មានមុខមួយប៉ុន្តែអាចបែងភាគបានមុខ ៥ ដៃ ១០
- មានកពណ៌ខៀវ
- កាយសម្បុរ ស
- ព្រះនេត ៣ ដោយព្រះនេត្រ ២ ដូចមនុស្សធម្មតតា និង ១ ទៀត ដែលហៅថាអគ្គីនេត្រ នៅចំកណ្តាលថ្ងាស ហើយបិទជានិច្ច និងអាចក្រឡេកឆេះ
- សម្លៀកបំពាក់ស្បែកខ្លាឬស្បែកដំរី
- រូបដូចឥសីមាន ផ្នួងសក់ធំ ហើយមានខ្សែផ្គាំនៅក ឬនៅដៃ
- រូបដូចគ្រូរបាំ
- កេតនភណ្ឌមាន៖ ត្រីសូល៍/ច្បូកផ្លែ ៣ (ច្បូក=ប្រដាប់នេសាទធ្វើដោយដែកមានចម្ពាមបី មានដង មានងៀង) ខ្សែផ្គាំ ស្គរ ដំបង លលាដ៏ក្បាល ខ្សែ ១ ចង្វាយ។ល។
- មានពាក់កម្រងឆ្អឹងលលាដ៏ក្បាលជាគ្រឿងសំគាល់រាប់យុគ
- មាននាគសង្វារជាគ្រឿងសម្គាល់រាប់ឆ្នាំ
- ពាក់មួកមានព្រះចន្ទ្រមួយចំណិតរាងកណ្តៀវជាគ្រឿងសម្គាល់រាប់ខែ
- យានជំនិះគឺគោនន្ទិ


www.elibraryofcambodia.org

- មានមហេសី ៩ អង្គ ដូចជា៖

១- នាងទុគ៌ា (*ស្ត្រីចេះធ្វើមិនដឹងមិនឮ*)

២. នាងឧមា (*ស្ត្រីជាទីពេញចិត្ត*)

៣. នាងគោរី (*ស្ត្រីសម្បុរទង់ដែង*)

៤. នាងកាលី (*ស្ត្រីសម្បុរខ្មៅ*)

៥. នាងចន្ទី (*ស្ត្រីកំណាច*)

៦. នាងបវ៌តី (*បុត្រីម្ចាស់ភ្នំ*)

៧. នាងកុមារី(*ស្ត្រីក្រមុំបរិសុទ្ធ*)

៨. នាងទេវី( *ទេពកញ្ញា*)

៩. នាងមហាទេវី( *ទេពកញ្ញាដ៏ប្រសើរ*)។



- មានបុត្រ ២ អង្គ ជាមួយនាងទុគ៌ា គឺ ស្កន្ទ (ទេវៈតំណាងចម្បាំង មានយានជំនិះជាសត្វក្ងោក) និង គណេស (ទេវៈខាងបញ្ញា មានដៃ ២ ឬ ៤ ពោះកំប៉ោង ក្បាលជាដំរី មានតែភ្លុកឆ្វេង ភ្លុកខាងស្តាំបាក់ដោយសារប្រយុទ្ធជាមួយ បរសុរាមៈ ដែលជាអវតារព្រះវិស្ណុនិងដែលមានយានជំនិះជាសត្វកណ្តុរ)។



ព្រះសិវៈមានឈ្មោះច្រើន៖

១-ព្រះមហាទេព Maha Deva

២-ព្រះហរៈ Hara

៣-ព្រះមហេស្វរៈ Mahesvara

៤-ព្រះរុទ្រៈ Rudra

៥-ព្រះឥស្វរៈ Ishvara

៦- ព្រះឧគ្រៈ Ugra

៧- ព្រះអឃោរ Aghora

៨- ព្រះភៃរវៈ Bhaivara

៩- ព្រះឥសូរ ( បែបខ្មែរ )



www.elibraryofcambodia.org

ព្រះសិវៈជាអ្នកបង្កើតលោកផង និងបំផ្លាញលោកឱ្យវិនាសទៅវិញផង។ ព្រះសិវៈជាអាទិទេពរបស់ជនជាតិឥណ្ឌាភាគខាងជើង (ពួកអារ្យាង) ហើយព្រះ សិវៈតំណាងសភាវៈកាចឃោរឃៅ ចូលចិត្តកាប់ចាក់ ស៊ីសាច់ហុតឈាម ហើយពេលខឹងម្ដងៗ ព្រះសិវៈតែងតែរាំដើម្បីបំផ្លាញលោក ។ ព្រោះហេតុនេះ ទើបជនជាតិឥណ្ឌា មានជំនឿថា ព្រះសិវៈចូលចិត្តសោយឈាម ។



ក្រៅពីនេះ មានការសាងរូបសិវៈឬឥសូរ ជាលិង្គតំកល់ឱ្យនៅជាមួយយោនីនាងឧមា ជានិមិត្តរូបនៃការបង្កើតលោក ។ នៅប្រទេសឥណ្ឌា ស.វ. ទី១២ មាននិកាយមួយឈ្មោះ វរសិវៈបាននិយមគោរពសិវៈដោយចាត់ទុកព្រះសិវៈជាអាទិទេពតែមួយ ធំជាង គេបានកសាងលិង្គជាតំណាង ហើយយកលិង្គនេះមកពាក់ជាប់ជាមួយខ្លួនទៀតផង ។ អ្នកគោរពសិវៈតែងនិយមធ្វើបុណ្យក្នុង មួយឆ្នាំម្ដង ដោយធ្វើនៅវេលាយប់ ហើយឱ្យឈ្មោះពិធីនោះថា "សិវរាត្រី" ។ ពិធីនេះ គេប្រារព្ធក្នុងទន្លេគង្គា (មុជទឹកលាងបាប ហើយដង ទឹកយកទៅស្រោចលើលិង្គឥសូរ បង្ហូរទៅលើយោនីនាងឧមា) ។ អ្នកនៅឆ្ងាយពីទន្លេគង្គាអាចយកទឹកដូងមកជំនួសក៏បាន ឯនៅប្រទេសកម្ពុជា សម័យគោរពព្រះឥសូរ គេបានសាង សង់លិង្គព្រះឥសូរ និង យោនីនាងឧមាតម្កល់សឹងគ្រប់ប្រាសាទនិងតាមទីប្រជុំជននានាទុកគោរពបូជា។

ខ្មែរពីបុរាណហៅថ្មដែលគេបានសាងជារូបសិវលិង្គ កាត់ខ្លីថា *អង្គ* គឺអង្គជាត ឬអង្គកំណើត ហៅថ្មតំណាងយោនីនាងឧមាថា បំពង់ខ្ទី ។ ដូច្នេះ ទឹកស្រោចលើថ្ម ដែលជានិមិត្តរូបនៃសិវៈនិងឧមាដើម្បីសុំសេចក្ដីសុខសេរីសួស្ដី មានឈ្មោះថា *ទឹកអង្គបំពង់ខ្ទី* (ឈ្មោះទីគោរពបូជាទាំងនេះមានដល់សព្វថ្ងៃ ដូចជា អង្គតាសោម អង្គស្នួលជាដើម )។



www.elibraryofcambodia.org



ក្រោយមក គេសាងរូបសិវៈ ជាតួមនុស្សមានក្បាល៥ ដៃ១០ ជួនជាឥសី ឬ ជាតាបស ដែលជាម្ចាស់នៃពួកយោគិនឬអ្នកធ្វើពិធីយោគៈ មានសក់បួង មានពុកមាត់ស្រួច មានផ្កាំកាន់ នៅដៃ ហើយពេលខ្លះទៀត សិវៈមានរូបរាងជាមនុស្សក្មេងពាក់មួករាងមូល មានលម្អដោយរូបចំណិតលោកខែដូចផ្លែកណ្ដៀវ នៅពីមុខ មានភ្នែកទី ៣ នៅលើ ថ្ងាស ជួនកាល គេសាងរូបឥសូរជាក្សត្រគ្រងលើបល្ល័ង្ក ជារូបឥសូររាំ ឬ ជារូបឥសូរជិះគោនន្ទិជាមួយនាងឧមា។

## គ- ព្រះវិស្ណុ

ព្រះអាទិទេពជាអ្នកថែរក្សាលោកឲ្យបានគង់វង្សសុខសាន្ត និងមានរបៀបរៀបរយ ។ ព្រះវិស្ណុមានឈ្មោះច្រើនទៀតដូចជា ព្រះនរាយណ៍ (និយមហៅនៅស្រុកខ្មែរ) ភគវន្ត, ហរិ, ឬ អនន្ត ។ គម្ពីរខ្លះនិយាយថា ព្រះវិស្ណុមានកំណើតពីតំណក់ញើសថ្ងាសរបស់ព្រះព្រហ្មក្នុងពេលព្រះអង្គបំពេញតបៈ ។

**លក្ខណៈពិសេសសម្គាល់ព្រះវិស្ណុ**



- មានព្រះកេស១
- មានដៃ២ ឬ ៤ ឬ ៨ (ចម្លាក់ព្រះវិស្ណុ ដៃ ៨ នៅស្រុកខ្មែរមាននៅសតវត្សទី ៨)
- ទ្រង់ឈរ
- សម្លៀកបំពាក់លឿង
- កេតនភណ្ឌមានដូចជា កងចក្រ ដំបង ផ្កាឈូក ខ្យងស័ង្ខ ធ្នូ ដាវ ម្កុដមូលវែង
- យានជំនិះគឺសត្វគ្រុឌ និង ពស់សេសៈ
- វិមាននៅស្ថានវៃកុណ្ឋ ។



www.elibraryofcambodia.org

ព្រះវិស្ណុមានអវតារ១០យ៉ាងគឺ៖

១- មត្ស្យ (Matasyavataram)



មត្ស្យគឺជាអវតារព្រះវិស្ណុ មានរាងជាសត្វត្រី ដែលបានជួយជីវិតមនុស្សឱ្យរួចផុតពីទឹកជំនន់ ដែលបង្កដោយយក្សឈ្មោះ ហយគ្រីវៈ (មានក្បាលជាសេះ) ។ យក្សហយគ្រីវៈ បានចាប់យកព្រះសិវៈទៅ ហើយបានបាត់ខ្លួននៅមហាសមុទ្រ ។ បើគ្មានព្រះសិវៈ ព្រះព្រហ្ម មិនអាចបន្តតួនាទីជាអ្នកបង្កើតលោកបានទេ។ នៅពេលនោះ ព្រះវិស្ណុបានធ្វើខ្លួនឱ្យក្លាយជាត្រី ដើម្បីជួយព្រះសិវៈ ។ យក្សហយគ្រីវៈ បានបង្កើតឱ្យមានទឹកជំនន់ឡើង ពេលនោះ ព្រះវិស្ណុ ដែលស្ថិតនៅរូបរាងជាត្រីបានប្រើកន្ទុយរបស់ខ្លួនចង ភ្ជាប់ជាមួយសត្វពស់ឈ្មោះវ៉ាសុគី (Vaasuki) ដោយយកពស់វ៉ាសុគីធ្វើជាខ្សែ ចងភ្ជាប់នឹងទូក ហើយបានបញ្ចៀសទូកឱ្យគេចផុតពីទឹកជំនន់។ ពេលនោះ ទឹកជំនន់ក៏បានស្ងប់ទៅវិញ ។ នៅពេលដែលព្រះព្រហ្មបានភ្ញាក់ដឹងខ្លួនឡើង ហើយដឹងថា ព្រះសិវៈត្រូវបានយក្សហយគ្រីវៈ ចាប់ខ្លួនទៅ ព្រះព្រហ្មក៏បានសុំបួងសួងឱ្យព្រះវិស្ណុជួយ ។ ពេលនោះ ព្រះវិស្ណុស្ថិតនៅរូបរាងជាសត្វត្រីនៅឡើយ បានស្វែងរកនិងច្បាំងជាមួយយក្សហយគ្រីវៈ ហើយក៏បានជួយព្រះសិវៈដើម្បីឱ្យបន្តការបង្កើតលោក។

២- កូម៌ (Kurmavataram)

កូម៌គឺជាអវតារទីពីររបស់ព្រះវិស្ណុមានរូបរាងជាសត្វអណ្តើក ដើម្បីជួយពួកទេវៈក្នុងការដណ្តើមទឹកអម្រឹត (ដែលអាចធ្វើឱ្យពួកគេមានជីវិតអមតៈ) ក្នុងសង្គ្រាមដណ្តើមទឹកអម្រឹតជាមួយនឹងពួកអសុរា នៅក្នុងរឿងកូរសមុទ្រទឹកដោះ ។ ដោយខ្លាចទឹកអម្រឹតបានទៅពួកអសុរា ពួកទេវៈក៏បានបួងសួងសុំឱ្យព្រះវិស្ណុជួយ ។ ពួកគេបានយកភ្នំមន្ទរៈធ្វើជាស្នូល និងនាគវ៉ាសុគីធ្វើជាខ្សែដើម្បីកូរយកទឹកអម្រឹត។ ពេលនោះ



www.elibraryofcambodia.org

ព្រះវិស្ណុនិងពួកទេវៈនៅខាងកន្ទុយ ហើយពួកអសុរានៅខាងក្បាល ។ នៅពេលពួកអាសុរានិងពួកទេវៈកំពុងកូរសមុទ្រទឹកដោះនោះ ភ្នំមន្ទរៈបានស្រុតចុះ។ រំពេចនោះ ព្រះវិស្ណុក៏បានកាឡាខ្លួនជាសត្វអណ្តើកដើម្បីកល់ និងទប់ភ្នំមិនឱ្យស្រុត ហើយពួកអសុរា និង ទេវៈក៏បន្តការកូរ តទៅទៀត។ នៅពេលការកូរចេះតែបន្តកាន់តែយូរ នាគវាសុគីអស់កម្លាំង និងបានព្រួសពិសមកក្រៅ ដែលធ្វើឱ្យពួកយក្ស ដែលនៅខាងក្បាល ត្រូវពិសយ៉ាងខ្លាំងនិងមានការឈឺចាប់ជាពន់ពេក ហើយក៏រត់បាត់ទៅ។ ពួក



ទេវៈបានសុំឱ្យព្រះសិវៈជួយ។ សង្គ្រាមដណ្តើមទឹកអម្រឹត បានចាប់ផ្តើមម្តងទៀត ហើយនៅពេលដែលពួកយក្សនិងទេវៈកំពុងធ្វើការកូរ ស្រាប់តែមានវត្ថុមានតម្លៃមួយចំនួនបានផុសចេញពីក្រោមសមុទ្រមក ។ អប្សរាបានលេចចេញឡើង ហើយទេពីលក្ស្មី ក៏បានលេចឡើង ប្រកបដោយសម្រស់ដ៏ស្រស់ត្រកាលដែលធ្វើឱ្យពួកយក្ស និង ទេវៈកើតក្តីស្រឡាំងកាំង ។ បន្ទាប់មកទៀត ទន្វន្ត្រីភគវៈ (Danvantri Bhagava) ក៏បានលេចឡើងពីក្រោយ ដោយមានកាន់ថូពណ៌មាសដែលពេញទៅដោយទឹកអម្រឹត។ ពេលនោះ មោហិនិ (Mohini) បានចាប់ផ្តើមចែកឱ្យពួកទេវៈមុន ហើយពួកអាសុរារង់ចាំដោយឥតប្រយោជន៍ ។

**៣- វរាហៈ** (Varahavataram)

វរាហៈគឺជាព្រះវិស្ណុដែលបានកាឡាខ្លួនធ្វើជាជ្រូកព្រៃដើម្បីចាប់យក្សហិរណៈដែលមានបំណងចង់រំលាយលោកឲ្យក្លាយទៅជាទឹកសមុទ្រ។ នៅពេលដែលព្រះព្រហ្មបានប្លែងខ្លួនជាពីរ ជាស្វយម្ភូ (Swayambu) និង សថរូពៃ (Satharoobai) ក្នុងបំណងការពារជីវិតនៅលើលោកយើងនេះ នៅពេលលោកយើងបានលេចលង់ក្នុងទឹកសមុទ្រដោយសារទឹកជំនន់ ដែលបង្កឡើងដោយយក្សហិរណៈ ។ ពេលនោះ ព្រះព្រហ្មក៏បាន



www.elibraryofcambodia.org

សុំឱ្យព្រះវិស្ណុជួយស្រោចស្រង់ផែនដីដែលបាន លេចនៅបាតសមុទ្រនោះ ។ នៅពេល ព្រះព្រហ្មកំពុងតែធ្វើការតាំងសមាធិ ព្រះវិស្ណុបាន កាឡាខ្លួនធ្វើជាសត្វជ្រូកព្រៃឈ្មោះ វរាហៈ ដែល ធំធាត់យ៉ាងលឿន និង មានទំហំធំជាងសត្វដទៃ ទៅទៀត។ វរាហៈបានធ្វើដំណើរទៅបាតសមុទ្រ ហើយនៅទីនោះ វរាហៈ បានស្វែងរកឃើញផែន-ដី និងបានលើកវាឡើងពីមហាសមុទ្រ ដោយ ចង្កូមខាងមុខដ៏វែងទាំងពីរ តែពេលនោះ យក្ស ហិរណ្យៈ បានព្យាយាមរាំងព្រះវិស្ណុនិងបានសើច ចំអកឱ្យព្រះវិស្ណុ នៅពេលព្រះវិស្ណុមានរូបរាងជា ជ្រូកព្រៃ។ ចម្បាំងដ៏ធំរវាងយក្សហិរណ្យៈ និង



វរាហៈ បានផ្ទុះឡើង ហើយពេលនោះ វរាហៈបានប្រើដំបងធំ និង កងចក្រដើម្បីសម្លាប់ យក្សហិរណ្យៈ។ យក្សហិរណ្យៈត្រូវព្រះវិស្ណុវាយចំត្រចៀកហើយក៏ស្លាប់បាត់ទៅ ហើយ ព្រះវិស្ណុក៏បានលើកផែនដីឡើង ឱ្យផុតពីមហាសមុទ្រ ។

**៤- នរសិង្ហ** (Narasimhavataram)

នរសិង្ហគឺជាព្រះវិស្ណុដែលបានកាឡាខ្លួន ធ្វើជាមនុស្សសិង្ហ (ដងខ្លួនជាមនុស្ស និងក្បាល ជាសិង្ហ) ដើម្បីសម្លាប់យក្ស ហិរណ្យកសិបុ។ ហិរណ្យៈ និង ហិរណ្យកសិបុ គឺជាបងប្អូនបង្កើត នឹងគ្នា ។ ក្រោយការស្លាប់របស់ហិរណ្យយក្ស ដែលត្រូវអវតារវរាហៈសម្លាប់ ហិរណ្យកសិបុ បានសច្ចាថានឹងសងសឹក។ ហិរណ្យកសិបុ បាន



សុំពរពីព្រះព្រហ្មថា កុំឱ្យនរណាសម្លាប់វាបានឡើយ ទោះបីជានៅពេលយប់ឬពេល ថ្ងៃក្តី ទោះបីជាមនុស្សទូទៅក្តីឬអាទិទេពក្តី ទោះបីជា នៅលើដីក្តីឬលើអាកាសក្តី និង



www.elibraryofcambodia.org

ដោយអាវុធណាក្តី។ យក្សហិរណកសិបុ មានកូនប្រុសម្នាក់ឈ្មោះ *ប្រហាលធៈ* (Prahaladha) ដែលជាអ្នកគោរពព្រះវិស្ណុយ៉ាងខ្លាំង។ ហិរណកសិបុបានព្យាយាមបញ្ចុះបញ្ចូលកូនប្រុសឱ្យឈប់ជឿ និងមិនគោរពប្រណិប័តន៍ព្រះវិស្ណុតទៅទៀត តែទោះបីជាហិរណកសិបុ ខំប្រឹងព្យាយាមយ៉ាងណាក៏ដោយ ក៏នៅតែពុំបានសម្រេចបំណងដែរ។ ដើម្បីបង្ហាញឱ្យឃើញពីការគុំគួន ក្នុងភាពជាសត្រូវនឹងព្រះវិស្ណុ ហិរណកសិបុ បានតាំងចិត្តថា នឹងសម្លាប់កូនប្រុសបង្កើតជាទីស្រលាញ់របស់ខ្លួន។ ហិរណកសិបុបានរិះរកគ្រប់វិធី ដោយយកកូនទៅទម្លាក់ក្នុងមហាសមុទ្រ និងដាក់ថ្នាំបំពុល ក្នុងអាហារជាដើម ប៉ុន្តែ រាល់លើក វាសុទ្ធតែបរាជ័យ ដោយមានការជួយពីព្រះវិស្ណុ។ ហិរណកសិបុ កើតចិត្តក្តៅក្រហាយយ៉ាងខ្លាំង ហើយបានសួរកូនថា តើខ្លួនអាចជួបនឹងព្រះវិស្ណុបាននៅកន្លែងណា? ប្រហាលធៈ ឆ្លើយថា ព្រះវិស្ណុអាចលេចចេញពីសសរនៃព្រះរាជវាំងនេះ។ ឲ្យដូច្នោះ ហិរណកសិបុបានវាយបំបែកសសរផ្អែកជាពីរ ស្រាប់តែពេលនោះ ហិរណកសិបុ បានឃើញព្រះវិស្ណុមានរូបរាងជាមនុស្សពាក់កណ្តាល និងសិង្ហពាក់កណ្តាល អង្គុយនៅក្នុងសសរនោះ ។ ក្នុងរូបរាងជានរសិង្ហ ព្រះវិស្ណុ ដែលមិនមែនជាមនុស្សហើយ ក៏មិនមែនជាអទិទេពនោះបានសម្លាប់យក្ស ហិរណកសិបុ ដោយប្រើក្រចកដៃ ដែលមិនមែនជាអាវុធ និង សម្លាប់វានៅវេលាល្ងាច ដែលមិនមែន ជាពេលយប់និងពេលថ្ងៃ ។




**៥- វាមនៈ** (Vamanavataram)

វាមនៈជាមនុស្សតឿ ដែលព្រះវិស្ណុកាឡាខ្លួនបោកបញ្ឆោតយក្សពលិ។ ពលិ គឺជាចៅរបស់ហិរណកសិបុហើយមានមហិទ្ធិរិទ្ធខ្លាំងក្លា និង បានគ្រប់គ្រងភពទាំងបី ។ ទោះបីពលិជាយក្សក៏ដោយ ក៏ពលិគ្រប់គ្រងផែនដីនិង មនុស្សប្រកបដោយ យុត្តិធម៌ និងគុណសម្បត្តិ។ តែដោយហេតុថា លោកទាំងបីមិនអាចឱ្យយក្សជាអ្នកគ្រប់គ្រងទេ ពេលនោះ និងដោយសារព្រះវិស្ណុក៏ពុំអាចច្បាំងជាមួយពលិបាន



www.elibraryofcambodia.org

ទើបព្រះវិស្ណុកាឡាខ្លួនធ្វើជាព្រាហ្មណ៍តឿ។ ពលិកំពុងធ្វើការតាំងសីល និង ដើម្បីតាំងសីលបានសម្រេច ពលិត្រូវផ្តល់អ្វីៗគ្រប់យ៉ាងដែលព្រាហ្មណ៍សុំ។ ព្រះវិស្ណុ ដែលបានកាឡាខ្លួនជាមនុស្សតឿ សុំ ពលិ តែដីបីជំហានប៉ុណ្ណោះ។ ពលិគិតថាការសុំបែបនេះគឺជារឿងគួរឱ្យអស់សំណើច ដោយគិតថា ដីបីជំហានរបស់ វាមនៈ គឺមានទំហំតូច ។ ពលិបានស្នើសុំឱ្យព្រាហ្មណ៍តឿសុំអ្វីដែលមានតម្លៃជាងនេះ តែវាមនៈទទូចសុំតែដីបីជំហានតែប៉ុណ្ណោះ ។ ដោយសារការទទូចរបស់វាមនៈ ពលិយក្សក៏យល់ព្រមផ្តល់ដីបីជំហានដល់ព្រាហណ៍តឿ ។ បានការយល់ព្រមពីយក្សភ្លាម ព្រាហ្មណ៍តឿបានពង្រីកខ្លួនយ៉ាងធំ ហើយឈានជំហានទីមួយជាន់បានដីទាំងមូល និងជំហានទីពីរជាន់បាន ចក្រវាលទាំងមូល។ ពេលនោះពលិដឹងថាគ្មានដីឱ្យទៅព្រាហ្មណ៍តឿទៀតទេ ក៏បានឱនចុះចំពោះមុខវាមនៈ និងបានសុំឱ្យវាមនៈជាន់ក្បាលជាថ្នូរនឹងជំហានទីបី ។ ជំហានទីបីព្រះវិស្ណុបានជាន់យក្សពលិឱ្យទៅ គ្រប់គ្រង នៅកន្លែងទាបជាងគេ ។



**៦-បរសុរាម**( Parashuramavataram )

បរសុរាមជាអវតាររបស់ព្រះវិស្ណុកាន់ពូថៅដៃ ដែលជាអំណោយរបស់ព្រះសិវៈប្រទានឱ្យ ដើម្បីរំដោះមនុស្សឱ្យចេញពីការសង្កត់សង្កិនរបស់ស្តេច មានស្តេច *កាតិវិរយៈ* ជាដើម និង ដើម្បីលុបបំបាត់ចោលវណ្ណៈក្សត្រ។ បរសុរាមបានព្យាយាមសម្លាប់ស្តេច ២១ ដង។ នៅក្នុងសារមន្ទីរជាតិ យើងឃើញ មានបដិមាបរសុរាម ដែលធ្វើអពីថ្មភក់ នៅស.វ.ទី ៦-៧ នៅភ្នំដា ស្រុកអង្គរបុរី ខេត្តតាកែវ។ មើលទៅតាម ក្បាច់ក្បូរ សម្លៀកបំពាក់បដិមានេះ វាទំនងជាស្ថិតក្នុងរចនាបថភ្នំដា ។



www.elibraryofcambodia.org

**៧- រាមា** (Ramavataram)

រាមាជាតួអង្គក្នុងរឿងរាមយណៈរបស់ឥណ្ឌា ដែលខ្មែរស្គាល់ថាជាតួអង្គព្រះរាម



នៅក្នុងរឿងរាមកេរ្តិ៍របស់ខ្មែរ។ រាមា មានមុខងារសម្លាប់ក្រុងរាពណ៍ ដែលជាយក្សឃោរឃៅ ដើរគំរាមគំហែងមនុស្សលោក និង ទេវលោក។ ជម្លោះរវាង ក្រុងរាពណ៍ និង រាមា កើតឡើងនៅពេលដែលក្រុងរាពណ៍បានចាប់យកនាងសីតាដែលជាមហេសីរបស់រាម ពេលដែលទ្រង់គង់នៅក្នុងព្រៃ។ នាងសីតាជានាងលក្ស្មីទេពីជាមហេសីរបស់ព្រះវិស្ណុ។ ចម្បាំងដ៏ខ្លាំងក្លារបស់រាមា និង ក្រុងរាពណ៍ កើតឡើងនៅក្រុងលង្កា ហើយចម្បាំងនេះបានធ្វើឱ្យប្អូននិងកូនរបស់ក្រុងរាពណ៍ស្លាប់ទៀតផង។

**៨- គ្រឹស្នៈ** (Krishnavataram)



គ្រឹស្នៈជាអវតារទី ៨ របស់ព្រះវិស្ណុ ដែលមានតួនាទីអប់រំមនុស្សឱ្យផ្ដាច់ខ្លួនចេញពីវដ្តសង្សារ ពិសេសគឺផ្ដាច់ខ្លួនចេញ ពីយក្សកំណាចឈ្មោះ *កម្ស:* (Kamsan)។ គ្រឹស្នៈគឺជាកូនទី ៨ របស់នាង ទេវាគី (Devaki) និង វាសុទេវារៈ (Vasudevar)។ ពេលកំពុងជិះរទេះសេះជាមួយនាងទេវាគី និង វាសុទេវារៈ យក្សកម្សៈ ដែលជាបងប្រុសរបស់នាង ក៏ស្រាបប់តែឮសម្លេងបន្លឺឡើងថា យក្សកម្សៈនឹងត្រូវស្លាប់ នៅក្នុងដៃកូនទី ៨ របស់នាងទេវាគី និង វសុទេវារៈ។ ពេលនោះយក្សកម្សៈក្រេវក្រោធជាខ្លាំង និងចង់



www.elibraryofcambodia.org

សម្លាប់នាង ទេវកី តែត្រូវខកខានទៅវិញដោយហេតុថា បញ្ហានឹងកើតឡើងនៅពេលដែលពួកគេមានកូនទី ៨ ។ ពួកគេបានយល់ព្រមប្រគល់កូនដែលកើតមក ឱ្យទៅយក្សកម្សៈ ទាំងអស់ ។ យក្សកម្សៈ បានយក ទេវកី និង វាសុទេវៈ និង ឧគ្រសេនៈ ដែលជាឪពុករបស់ទេវកីទៅឃុំឃាំង។ យក្សកម្សៈ បានសម្លាប់កូនទាំង ៦ របស់ទេវកីដោយគ្មានត្រាប្រណី ។ ក្រោយទៀត នាងទេវកីក៏ចាប់មានផ្ទៃពោះកូនទី៧ ដែលជាអទិសេស (Adisesha'samsam)។ ព្រះវិស្ណុបានដឹងរឿងនេះក៏បានបង្វែរឱ្យកូនទី ៧ របស់នាងទេវកី ទៅចាប់កំណើតក្នុងផ្ទៃពោះរបស់នាង រោហិនី (Rohini) ដែលជាភរិយាម្នាក់ទៀតរបស់វាសុទេវៈ។ យក្សកម្សៈស្មានថា កូនទី ៧ របស់នាង ទេវកី បានស្លាប់បាត់។ រោហិនី បានប្រសូតបុត្រមួយដ៏ស្អាតនិងមាន ឫទ្ធានុភាពខ្លាំងក្លាទៀតផង។ នាង ទេវកី បានបង្កើតកូនទី ៨ ហើយ វាសុទេវៈ បានយកកូនទី ៨ នោះចេញពីគុក ហើយយកកូនផ្សេងមកជំនួសវិញ ។ នៅតាមផ្លូវ អាទិសេស ដែលជាកូនទី ៧ របស់នាង ទេវកី និងដែលមានកំណើតនៅក្នុងផ្ទៃពោះរបស់នាង រោហិនី បានជួយការពារគ្រឹស្នៈពីគ្រោះធម្មជាតិ។ យក្សកម្សៈ ពេលដឹងថាគ្រឹស្នៈបានចាប់កំណើត ក៏ប្រញាប់ទៅក្នុងគុកចាប់យកក្មេងនោះ បម្រុងសម្លាប់ចោល។ ស្រាប់តែ ពេលនោះ ក្មេងនោះក៏ហោះឡើង ហើយចំអកដាក់យក្សកម្សៈថា សត្រូវរបស់ខ្លួននៅរស់រានមានជីវិត រួចក៏បានបាត់ខ្លួនមួយរំពេច ។ យក្សកម្សៈ បានបញ្ជូនយក្សឱ្យស្វែងរកគ្រឹស្នៈ ។ គ្រឹស្នៈ រស់នៅ ធំធាត់ និងបានទទួលការស្រលាញ់រាប់អានពីមនុស្សគ្រប់គ្នា ។ ទោះបីជាគ្រឹស្នៈជាក្មេងក៏ដោយ ក៏គេបានសម្លាប់យក្សជាច្រើនរាប់មិនអស់រួចមកហើយ ។ គ្រឹស្នៈបានប្រាប់ យសោធៈ (Yasodha) ដែលជាអ្នកចិញ្ចឹមបីបាច់ និង ចាត់ទុក ជាម្តាយថា ចក្រវាលទាំងមូលនៅក្នុងមាត់របស់គេ សូម្បីតែពស់កោលិង្គ (Koalinga) ដ៏ខ្លាំងពូកែក៏ត្រូវគ្រឹស្នៈបង្ក្រាបបាននិងអាចបញ្ចាពស់នោះបានទៀតផង ។

យក្សកម្សៈក៏ត្រូវគ្រឹស្នៈសម្លាប់ នៅ ពេលនោះដែរ។ រូបចម្លាក់គ្រឹស្នៈកំពុងទ្រភ្នំ គោវធ៌ន ដែលធ្វើអំពីថ្មភក់នៅដើមស.វ. ទី ៦ រកឃើញ នៅវត្តកោះ ព្រៃកប្បាស ស្រុកអង្គរបុរី ខេត្តតាកែវ មាននៅក្នុងសារមន្ទីរជាតិ ។



www.elibraryofcambodia.org



គ្រឹស្នៈសម្លាប់នាគកៅលិង្គ



គ្រឹស្នៈសម្លាប់កម្សៈ

**៩- ពុទ្ធ:** (Budha)

សាសនាហិណ្ឌូបានបញ្ចូលតួអង្គព្រះពុទ្ធជាតួអង្គអវតារទី ៩ របស់ព្រះវិស្ណុ ក្នុងនាមជាអ្នកមកអប់រំ ផ្សះផ្សារពួកបព្វជិត និង មនុស្សផងទាំងពួងឱ្យផុតពីទុក្ខ ។ ព្រះពុទ្ធបានបង្រៀនពីទុក្ខដែលជាមែកធាងរបស់ការជាប់ជំពាក់ចិត្ត នឹងងកាមកិលេសតណ្ហាទាំងពួង ព្រមទាំងបានផ្សព្វផ្សាយនូវមាគ៌ារលត់ទុក្ខទាំង ៨ ទៀតផង ។ តាមការណ៍ពិតព្រះពុទ្ធគឺជាព្រះសមណគោតម ដែលជាព្រះបរមគ្រូដ៏ល្បីល្បាញ និង ជាអ្នកបង្កើតព្រះពុទ្ធសាសនា ។ ពេលដែលព្រះពុទ្ធសាសនាបានកំពុងរីកចម្រើនយ៉ាងខ្លាំងក្លា ពួកព្រាហ្មណ៍និយមនៃប្រទេសឥណ្ឌា នាសម័យនោះមានការភ័យខ្លាច ក្រែងព្រះពុទ្ធសាសនាមានការរីកចម្រើនជាងព្រហ្មញ្ញសាសនា ពួកគេក៏បានបង្កើតទស្សនៈថា ព្រះពុទ្ធជាអវតាររបស់ព្រះវិស្ណុដែលចុះមកចាប់កំណើតលើផែនដី ជាព្រះសមណគោតមមានតួនាទីជួយដាស់តឿនមនុស្សឱ្យស្គាល់ល្អស្គាល់អាក្រក់ ជឿទៅលើការធ្វើបុណ្យ និងជៀសវាងនូវអំពើបាប។ ការបញ្ចូលតួអង្គព្រះពុទ្ធជាអវតាររបស់ព្រះវិស្ណុក៏ជា មធ្យោបាយមួយ ដើម្បីទាក់ទាញឱ្យក្រុមពុទ្ធសាសនិកមានជំនឿតាមបែបការគោរពបូជាព្រហ្មញ្ញសាសនាវិញ ។



www.elibraryofcambodia.org

១០- កល្កិន (Kalkiavataram)



កល្កិនជាអវតារទី ១០ របស់ព្រះវិស្ណុដែលមិនទាន់បានចាប់បដិសន្ធិនៅលើលោកយើងនេះទេ ។ ការមកដល់នៃអវតារនេះ ហាក់ដូចជាវាជាចុងបញ្ចប់នៃផែនដី។ កល្កិនជាមនុស្សមានក្បាលជាសេះ មានមុខងារជាអ្នក-កាត់ទោសពួកសភាវៈអាក្រក់ ដោយដាក់ទណ្ឌកម្ម និងឱ្យរង្វាន់ពួកសភាវៈល្អដើម្បីរៀបចំយុគមាស។ មិនតែប៉ុណ្ណោះ កល្កិនបញ្ជាក់ស្មារតីមនុស្សឱ្យសាងអំពើកុសលរស់ក្នុងពិភពលោកដែលប្រកបដោយគុណធម៌ សច្ចធម៌ និង អនុវត្តខ្លួនឱ្យសមក្នុងភាពជាមនុស្ស ។ យើងឃើញរូបកល្កិនអវតារ មាននៅក្នុងសារមន្ទីរជាតិ ដែលរូបនោះធ្វើអំពីភក់ក្នុង ស.វ. ទី ៧ រចនាបថសម្បូរ។

**សង្កេត៖** គាថាតូចមួយរបស់មនុ (Manu) បានចែងថា៖

- ព្រះសិវៈជាព្រះអាទិទេពនៃវណ្ណៈព្រាហ្មណ៍
- ព្រះវិស្ណុ ជាព្រះអាទិទេពនៃវណ្ណៈក្សត្រ
- ព្រះព្រហ្ម ជាព្រះអាទិទេព នៃវណ្ណៈវេស្សៈ
- ព្រះគណេស ជាព្រះអាទិទេព នៃវណ្ណៈសូទ្រៈ ។

ឃ- ព្រះហរិហរៈ

ដើម្បីរៀតចំណងងជនជាតិខ្មែរនិងនគរខ្មែរ កុំឱ្យបែកបាក់ និង ដើម្បីការពារជាតិពូជពង្សវង្សត្រកូលខ្មែរជាអមតៈ ព្រះរាជាខ្មែរនាសម័យនគរភ្នំ ស.វ. ទី១ ដល់ស.វ. ទី៦ បានអនុវត្តមនោគមសាសនាសំយោគមួយគឺការបញ្ចូលទេវៈពីរព្រះអង្គ (ព្រះសិវៈ និង ព្រះវិស្ណុ) ឱ្យទៅជាអង្គតែមួយ គឺ ព្រះហរិហរៈ (*ហរិ* គឺ វិស្ណុ ឯ *ហរៈ* គឺសិវៈ) ។

គម្ពីរវេទខ្លះបានបង្ហាញពីការបែងចែកព្រះហរិហរៈ ដែលជាអាទិទេពផ្សំជាពីរផ្នែក គឺ នៅចំហៀងខាងឆ្វេងគឺហរិឬវិស្ណុ និងចំហៀងខាងស្តាំគឺហរៈ ឬ សិវៈ ។



www.elibraryofcambodia.org

គេបានរកឃើញកំណើតព្រះហរិហរៈនៅប្រទេសឥណ្ឌានៅស.វ.ទី១០។ ជំនឿលើហរិហរៈបានផ្សាយឥទ្ធិពលខ្លាំងនៅឥណ្ឌាប៉ែកខាងត្បូងនៅស.វ. ទី១៤ ប៉ុន្តែគេបានរកឃើញថា បដិមាហរិហរៈនៅក្នុងប្រទេសខ្មែរត្រូវបានឆ្លាក់តាំងពីស.វ.ទី ៦ មកម្ល៉េះ ។

ជំនឿលើហរិហរៈជាជំនឿដែលកើតឡើងនៅពេលមានវិបត្តិរវាងនិកាយព្រះសិវៈនិង និកាយព្រះវិស្ណុ ។ ដើម្បីដោះស្រាយការបាក់បែកគ្នានេះ គេបានបង្រួបបង្រួមព្រះអាទិទេពទាំងពីរអង្គនេះឱ្យទៅជាអាទិទេពតែ១អង្គវិញ ។ អ្នកគោរពព្រះវិស្ណុក្តី អ្នកគោរពព្រះសិវៈក្តី អាចគោរពបូជាព្រះហរិហរៈ បានទាំងអស់គ្នា ។

## ហេតុដូចម្តេចបានជាគេគោរពទេវៈ?

ដើមឡើយ ជនជាតិឥណ្ឌាមិនគោរពទេវៈទេ ពួកគេជឿលើកម្លាំងធម្មជាតិដូចបុព្វបុរសយើងដែរ។ តែចាប់ពីពេលពួកអារ្យ៉ាងចូល ហើយបានផ្សព្វផ្សាយសាសនាដល់ជនជាតិដើមឥណ្ឌាមក ជនជាតិឥណ្ឌាក៏គោរពទេវៈរហូតមក ។

ទេវៈនីមួយៗមានទីលំនៅខុសៗគ្នា៖ លើស្ថានទេវលោក លើអាកាស លើកំពូលភ្នំ ក្នុងទឹក លើផែនដី។ល។ អាស្រ័យលើមុខងារតួនាទីខ្ពស់ឬទាប និងលក្ខណៈល្អ ឬអាក្រក់របស់ទេវៈទាំងនោះ ។

## ទេវៈសំខាន់ៗ និង មុខងារ



- *ព្រះឥន្ទ* ឬ *ឥន្ទ្រ*៖ នៅដើមសម័យវេទ ពួកអារ្យ៉ាងចាត់ទុកព្រះឥន្ទជាអាទិទេពធំជាងគេ មានឋានៈនិងអំណាចខ្ពស់បំផុត។ ព្រះឥន្ទមានយានជំនិះជាដំរីក្បាលបី ដែលមានឈ្មោះថា *ឰរាវ័ណ* ។ ព្រះឥន្ទបញ្ជាផ្គរនិងរន្ទះ ។ ឧទាហរណ៍, ដោយខឹងនឹងកសិករលែងគោរពខ្លួនតាមការបញ្ចុះបញ្ចូលរបស់គ្រឹស្នៈ ព្រះឥន្ទ្រក៏បញ្ជារន្ទះបាញ់កសិករទាំងនោះ តែកសិករទាំងនោះក៏ត្រូវគ្រឹស្នៈជួយការពារ ដោយលើកភ្នំគោវធ៌នបាំង ។



www.elibraryofcambodia.org

- *ព្រះអគ្និ* ឬ *អគ្គិ* ៖ ជាទេវៈតំណាងភ្លើង ជាសាក្សីនៃអំពើល្អ/អាក្រក់របស់មនុស្ស។ ឧទាហរណ៍, ដើម្បីបង្ហាញភាពស្អាតស្អំរបស់ខ្លួនចំពោះព្រះរាម នាងសិតាក៏ដើរកាត់ភ្លើង ។
- *ព្រះភិរុណ*៖ ជាទេវៈបង្កើតភ្លៀងនិងទឹក និង ជាអ្នកតាមដានអំពើល្អ/អាក្រក់របស់មនុស្ស។ ឧទាហរណ៍, ពេលរាំង គ្មានភ្លៀង គេបន់ស្រន់សុំទឹកភ្លៀងព្រះភិរុណឱ្យផ្តល់ទឹកភ្លៀង ។ ព្រះភិរុណមានយានជំនិះជាសត្វហង្ស ។
- *ព្រះសូរ្យ* ឬ *ព្រះអាទិត្យ*៖ ជាទេវៈបង្កើតកម្តៅនិងពន្លឺ។ ក្នុងវប្បធម៌ខ្មែរ ព្រះសូរ្យត្រូវបានគេគូរជារូបទេវតាជិះរាជរថអូសដោយសេះ ៧ ឬ ដោយសិង្ហ។ ក្នុងរឿងរាមកេរ្តិ៍ ក្រោយពេលព្រះរាមសន្លប់ដោយសារត្រូវសររបស់ឥន្ទ្រជិត ហនុមានត្រូវទៅរកថ្នាំមកព្យាបាលព្រះរាមឱ្យទាន់មុនព្រះអាទិត្យលិច ពុំនោះ ព្រះរាមនឹងត្រូវស្លាប់។ ដើម្បីកុំឱ្យព្រះអាទិត្យលិច ហនុមានក៏វាយសេះរបស់ព្រះអាទិត្យឱ្យរត់បាត់ទៅ ម្ល៉ោះហើយព្រះអាទិត្យក៏ពុំអាចធ្វើដំណើរទៅមុខបានឡើយ ។
- *ព្រះចន្ទ្រ* ៖ ជាទេវៈតំណាងសោភណភាព ជាអ្នកថែរក្សារុក្ខជាតិ ។ ក្នុងវប្បធម៌ខ្មែរ គេគូររូបព្រះចន្ទ្រដោយមានរូបរាងប្រហាក់ប្រហែលនឹងព្រះអាទិត្យដែរ។
- *ព្រះយម* ៖ ជាទេវៈតំណាងសេចក្តីស្លាប់ ជាអ្នកធ្វើទោសមនុស្សអាក្រក់ នៅពេលស្លាប់ទៅ ។ ព្រះយមមានយានជំនិះជាសត្វក្របី។

ក្រៅពីនេះ មានទេវៈជាច្រើនទៀតដែលមានមុខងារផ្សេងៗគ្នាតែមិនសូវច្បាស់លាស់ ។ សម័យវេទ គេនិយមគោរពទេវៈច្រើនអង្គ។ ការគោរពទេវៈច្រើនបែបបនេះហៅថា «ពហុទេវនិយម »។

ឈានដល់សម័យព្រាហ្មណ៍និយម គេមានទំនោរគោរពទេវៈតែមួយអង្គវិញដោយគេបង្រួម ទេវៈទាំងនោះឱ្យនៅសល់តែមួយអង្គដែលគេចាត់ទុកជាអាទិទេពដើមបង្អស់ក្នុងការបង្កើតភាវៈក្នុងលោក។ ទេវៈឯទៀតនៅរក្សាទុកដដែល តែគ្មានតួនាទីសំខាន់ឡើយ ។ អាទិទេពដែលព្រាហ្មណ៍ចាត់ ទុកជាធំជាងគេនោះគឺព្រះព្រហ្ម ។



www.elibraryofcambodia.org

ទស្សនៈនេះហៅថា «ឯកទេវនិយម» ។

គួរកត់សម្គាល់ថា ឯកទេវនិយម ក្នុងសាសនាព្រាហ្មណ៍ គឺជាឯកភាពក្នុងពហុភាពដោយហេតុថា ពួកព្រាហ្មណ៍បានលើកតម្កើងសិវៈជាអាទិទេពធំជាងគេ ហើយបានបែងភាគជាទេវៈ ៣ អង្គ គឺ "ព្រហ្ម, វិស្ណុ និង សិវៈ" ដែលបានបង្កើតទស្សនៈថ្មីមួយទៀត គឺ *ត្រីមូតិ* ។

ទស្សនៈនេះត្រូវបានគេនិយមរាប់អានតាំងពីសម័យព្រាហ្មណ៍និយម ហើយខ្លាំងជាងគេនៅសម័យហិណ្ឌូនិយម ។

កាលដើមឡើយអាទិទេពទាំងនោះគ្មានរូបរាងទេ តែក្រោយមកទើបគេបង្កើតឱ្យមានរូបរាង តំណាងតួអង្គមនុស្ស មានប្រពន្ធ កូន មានតណ្ហា មានកេតនភណ្ឌ ។

## ២.៣- ហិណ្ឌូនិយម

សម័យហិណ្ឌូនិយមជាសម័យតពីសម័យព្រាហ្មណ៍និយមមក គឺពីសតវត្សទី១០-១១ រហូតមកទល់សព្វថ្ងៃនេះ ។

ហិណ្ឌូនិយមជាលិទ្ធិសំយោគរវាងវេទនិយម និងព្រាហ្មណ៍និយម ។ បានសេចក្តីថា ហិណ្ឌូនិយមពុំមែនជាលិទ្ធិថ្មីរបស់ពួកហិណ្ឌូទេ ។ ផ្ទុយទៅវិញ លទ្ធិនេះមានទស្សនៈទ្រឹស្តីនៃវេទនិយម និងព្រាហ្មណ៍និយមស្ទើរតែទាំងស្រុង ។ យ៉ាងណាមិញ បញ្ហាពុទ្ធិភាវៈ សុខៈ ពួកហិណ្ឌូបាន ដោះស្រាយស្របតាមទេវនិយមនិងព្រាហ្មណ៍និយមដែរពោលគឺ៖

ក- ឱ្យតម្លៃលើគម្ពីរវេទទាំង៤

ខ- គម្ពីរវេទនិយមជាកម្រងអត្ថបទសំខាន់ៗ ៤ ប្រភេទ (សំហិតាឬមន្ត្រៈ ព្រាហ្មណៈ អារណ្យកៈ និង ឧបនិស័ទ)

គ- អត្ថបទផ្សេងៗទៀតដែលជាអត្ថាធិប្បាយរបស់ពួកព្រាហ្មណ៍ ហើយដែលគេឱ្យឈ្មោះថាស្ម្រឹតិនៅតែមានតម្លៃដដែល មានជាអាទិ៍ គឺអត្ថបទធម្មសាស្ត្រ បុរាណសាស្ត្រ មហាភារតៈ រាមាយណៈ និងតន្ត្រៈ ។



www.elibraryofcambodia.org

ឃ- វិជ្ជាច្រើនបែបយ៉ាងដែលមានឈ្មោះថា ពហុស្សុតវិជ្ជា ត្រូវបានគេចាត់ទុក ជាវិជ្ជាសំខាន់ដូចសម័យមុន ហើយបានកែច្នៃឱ្យកាន់តែមានលក្ខណៈប្រសើរ ទៀតផង។ វិជ្ជាទាំងនោះគឺ៖

- វេយ្យាករណ៍វិទ្យា - វចនានុក្រមវិទ្យា - កាព្យវិទ្យា
- កាព្យអលង្ការវិទ្យា - នាដ្យវិទ្យា - អត្ថវិទ្យា
- កាមវិទ្យា

ង- កម្រង ទស្សនៈ៦យ៉ាងដែលជាមែកសំខាន់ៗ នៃលទ្ធិព្រាហ្មណ៍និយម នោះ នៅតែមានខ្លឹមសារដដែលក្នុងសម័យហិណ្ឌូនិយម ។ ទស្សនៈទាំងនោះគឺ៖

- មិមំសា - វេទន្តៈ - សំខ្យា
- យោគៈ - វៃសេសិកៈ - ន្យាយៈ

ច- វណ្ណៈទាំង ៤ គឺនៅមានគេគោរព ហើយចាត់ទុកជាការរៀបរាប់របស់ អាទិទេពអត់ប្រែប្រួល ដូចជា៖

- វណ្ណៈព្រាហ្មណ៍ - វណ្ណៈក្សត្រ
- វណ្ណៈវៃស្យៈ ឬ វេស្ស - វណ្ណៈសូទ្រៈ

ក៏ប៉ុន្តែ ដោយសារការវិវឌ្ឍនៃសង្គមមនុស្ស ការប្រកាន់វណ្ណៈរបស់ពួកហិណ្ឌូ សម័យបច្ចុប្បន្ន មានការកែសម្រួលឱ្យមានលក្ខណៈប្រជាធិបតេយ្យជាងសម័យវេទ-និយម និងសម័យព្រាហ្មណ៍និយមខ្លះៗ គឺមិនតឹងរ៉ឹងដូចពីដើមពេកទេ ដូចជាការលុប របបរាជានិយមចោល បន្ថយបុព្វសិទ្ធិនៃគ្រួសារស្តេច ហើយនិយមឱ្យតម្លៃមនុស្សទៅ លើគុណសម្បត្តិផ្សេងៗទៀតដូចជា ចេះ ល្ងង់ មាន ក្រ ។ល។

ឆ- ការនិយមចែកជីវិតជាអាស្រម ៤ ក៏ត្រូវបានពួកហិណ្ឌូអនុវត្តតមកទៀត ។ ក៏ប៉ុន្តែ គេពុំឱ្យឈ្មោះអាស្រមទាំងនោះថា ព្រហ្មចារ្យ គ្រហស្ថ វនប្រស្ថ ឬ សន្យាសៈ ដូចសម័យមុនទេ គេបានប្រើពាក្យផ្សេងៗជំនួសវិញគឺ៖

- កាមៈ - អថ៌ៈ - ធម៌ៈ - មោក្សៈ ។



www.elibraryofcambodia.org

ជ- ទស្សនៈចំពោះអាទិទេព និងលោកៈក៏ពុំមានការកែប្រែដែរ ពោលគឺឱ្យតម្លៃលើទស្សនៈឯកទេវនិយមផង ពហុទេវនិយមផង ដូចក្នុងសម័យវេទនិយម និង ព្រាហ្មណ៍និយមដែរ។ គេនៅតែមានជំនឿថា ព្រហ្មន៍ជាអាទិទេពធំ មានតែឈ្មោះ អត់មានរូប ពុំដូចអ្វីទាំងអស់ ជាគង់ភាពទាំងអស់ ជាគង់ភាពចុងក្រោយបង្អស់ ( Ultimerealite ) ដែលមិនប្រែប្រួលផ្លាស់ប្តូរ មិនវិនាសឬស្លាប់ លោកៈពុំមានអ្វីជា ការណ៍ពិត ជាទៀងទាត់ ពីព្រោះជាមាយាការ (illusion) ជាសភាវៈក្លែងក្លាយ ដែលអាទិទេពបង្កើតជាល្បែងលេង ជាគ្រឿងបន្លំមិនឱ្យមើលឃើញការណ៍ពិត។ អាទិទេពផ្សេងៗទៀតមានចំនួនច្រើន។ អាទិទេពសំខាន់ៗគឺ សិវៈ វិស្ណុ ព្រហ្ម សក្តិ សូរ្យៈ គណេស (មានក្បាលជាដំរី) ។ សិវៈ និង វិស្ណុ មានឈ្មោះ តាំងពីសម័យវេទមកម្ល៉េះ ។ ទេវៈនីមួយៗសុទ្ធតែបានការគោរពស្រលាញ់ផ្សេងៗគ្នា តាមទីកន្លែង និងតាមការចូលចិត្តរបស់ បណ្តាជន ។ អ្នកស្រលាញ់និងគោរពអាទិទេពណា តែងតែចាត់ទុកអាទិទេពនោះថា ធំជាចំគេ ឬ មានឫទ្ធានុភាពច្រើនជាងគេ ។

រួមសេចក្តីទៅ ទស្សនៈទាក់ទងទៅនឹងជំនឿ ប្រពៃណី ទំនៀមទម្លាប់ របៀបរស់នៅ នៅសម័យហិណ្ឌូនិយម ពុំប្លែកពីសម័យវេទនិយម និង ព្រាហ្មណ៍និយមឡើយ គ្រាន់តែសម័យហិណ្ឌូនិយម គេបានឱ្យតម្លៃលើភក្តីភាព គឺការគោរពអាទិទេព មានរូបរាងខ្លាំងជាងសម័យមុនៗ រហូតដល់រៀបចំតុបតែងធ្វើឱ្យអាទិទេពមានឈ្មោះច្រើន មានប្រពន្ធកូន មានគ្រឿងអលង្ការ។ល។ ចំណែកសិល្បៈ សូន-គូរ-ឆ្លាក់ រូបអាទិទេពសម្រាប់គោរពបូជាក៏ផុះដាលខ្លាំងឡើង ហើយឥទ្ធិពលនេះបានសាយភាយទៅគ្រប់ទិសទី ជាពិសេសគឺ ភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ ដូចជា ថៃ ម៉ាឡាយូ សៀម លាវ ខ្មែរ ជាដើម ។

### ៣- ឥទ្ធិពលសាសនាព្រាហ្មណ៍ក្នុងសង្គមខ្មែរ

សាសនាព្រាហ្មណ៍បានចាក់ឫសក្នុងសង្គមខ្មែរតាំងពីយូរណាស់មកហើយ និងមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើមនុស្សខ្មែរ ពិសេសសតិអារម្មណ៍ ទំនៀមទម្លាប់រហូតដល់



www.elibraryofcambodia.org

សព្វថ្ងៃនេះ ទោះបីជាកម្ពុជាបានឈានចូលក្នុងរបបថ្មីមួយដែលមានលក្ខណៈជឿន-លឿនក៏ដោយ ក៏ឥទ្ធិពលព្រហ្មញ្ញសាសនានៅតែបន្តអន្លាយជាប់នឹងសតិអារម្មណ៍ ទំនៀមទម្លាប់របស់ខ្មែរយើងដែរ។ ប៉ុន្តែ ប្រជាជនបានជម្រុះចោលបន្តិចម្តងៗ ជាបណ្តើរៗនូវជំនឿមិនសមហេតុផលមានលក្ខណៈវិទ្យាសាស្ត្រ ។ ទន្ទឹមនឹងនេះ គេបានរក្សាសម្បត្តិវប្បធម៌ សិល្បៈនេះជាគ្រឹះមួយដ៏រឹងមាំសម្រាប់ឱ្យយើងកសាងខឿនវប្បធម៌ថ្មីមួយដែលមានលក្ខណៈជឿនលឿន ព្រមទាំងជាមធ្យោបាយមួយសម្រាប់កសាងសេដ្ឋកិច្ច ។ ហើយគេមិនដែលឃើញមានអរិយធម៌ខ្ពង់ខ្ពស់ណាមួយនៅសម័យបុរាណដែលអាចកើតឡើងរួច ដោយមិនបានពឹងពាក់លើសាសនាទេ ។ នៅចំពោះមុខប្រាសាទ សិល្បៈទាំងឡាយនៅតំបន់អង្គរក្តី នៅតំបន់ណាទៀតក្តី គេពុំអាចបដិសេធ ឬនិយាយផ្ទុយបានឡើយ។ ប្រាសាទទាំងឡាយនោះ គេច្រើនកសាងឡើងដើម្បីបូជាដល់សាសនាទាំងពីរដោយឥតប្រកែកបាន ។

ដូច្នេះ ព្រហ្មសាសនា មានឥទ្ធិពលទៅលើផ្នែកធំៗបី គឺជំនឿ សិល្បៈ អក្សរសិល្ប៍ និង ទំនៀមទម្លាប់-ប្រពៃណី ។

## ៣.១- ផ្នែកជំនឿ

លើវិស័យជំនឿ ទំនៀមទម្លាប់ និង ជីវភាពរស់នៅ ព្រហ្មញ្ញសាសនាបានធ្វើឱ្យប្រជាជនយើង នាសម័យមុនមានជំនឿទៅលើអាទិទេព ទេវៈ ព្រាយ បិសាច ធ្មប់។ល។ គេបានរៀបចំពិធីផ្សេងៗ ដើម្បីគោរពអាទិទេព និងទេវៈ ។ ក្នុងពេលសង់ផ្ទះ គេធ្វើការ-ទស្សន៍ទាយលើដីកន្លែងសង់ គេរៀបចំបាយសី ស្លាធម៌ដូង...។ ពេលលើកផ្ទះ គេរៀបចំពិធីសែនព្រេនម្ចាស់ទឹក ម្ចាស់ដី មានព្រះធរណីជាដើម។ ក្នុងពេលមានជំងឺ គេរៀបចំពិធីផុតទៀនធូបអង្វរកបន់ស្រន់សុំឱ្យជាសះស្បើយ លៀងអារក្សសុំឱ្យខ្មោចជួយ រៀបចំហៅព្រលឹង។ គេបួងសួងនឹកគុណព្រះឥន្ទ ព្រះព្រហ្ម ដូនតា (ជំនឿដើម)។ ក្នុងពេលមានគ្រោះធម្មជាតិដូចជាខ្យល់ព្យុះ ទឹកជំនន់ គេបានអង្វរអាទិទេព មានព្រះព្រាយ ព្រះអង្គារជាដើម។ ក្នុងពេលដែលមានរាសីចុះ គេបានអញ្ជើញគ្រូអាចារ្យ ឬ ព្រះសង្ឃមកសូត្រមន្តអាគមលើករាសី។ ក្នុងពេលរៀបអាពាហ៍ពិពាហ៍ គេរើសពេលចូលរោង



www.elibraryofcambodia.org

ពេលធ្វើម ធ្វើកនទេវតា ឬ សែនក្រុងពាលី ព្រមទាំងធ្វើនំអន្សម និង នំគមតំណាងលិង្គព្រះឥសូរ និង យោនីនាងឧមា។

### ៣.២- ផ្នែកសិល្បៈ

ខាងវិស័យសិល្បៈ ខ្មែរយើងកសាងរូបចម្លាក់ បដិមានានា ដែលទាក់ទងនឹងលទ្ធិសាសនាព្រាហ្មណ៍ មានព្រះវិស្ណុ ព្រះសិវៈ លិង្គព្រះឥសូរ។ ហើយយើងឃើញមានរូបចម្លាក់ គំនូរដែលទាក់ទងនឹងព្រហ្មញ្ញសាសនា ដូចជារឿងរាមាយណៈ និង មហាភារតយុទ្ធ ជាដើម។ គេបានកសាងប្រាសាទជាច្រើន ជាពិសេសប្រាសាទភ្នំ សម្រាប់ឧទ្ទិសឱ្យព្រហ្មញ្ញសាសនា ។

**៣.៣- ផ្នែកអក្សរសិល្ប៍៖** លើវិស័យអក្សរសាស្ត្រ-អក្សរសិល្ប៍ខ្មែរ ខ្មែរយើងទទួលភាសាសំស្ក្រឹត អក្សរ និង អក្សរសិល្ប៍ដែលយើងហៅថាអក្សរសិល្ប៍ចលនាព្រាហ្មណ៍និយម ។ អក្សរសិល្ប៍ព្រហ្មនិយមគឺជាអក្សរសិល្ប៍ទាក់ទងនឹងព្រហ្មញ្ញ-សាសនា ដោយលើកយកព្រះឥន្ទ ព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ ទេវៈ វត្ថុអច្ឆរិយៈ មកបង្ហាញ ។ ម្យ៉ាងទៀត អក្សរសិល្ប៍ព្រហ្មនិយមបានលើកយកមន្ត អាគមគាថា ឧមអាម បែងភាគ ចេះជប ចេះប្រស់ ហោះហើរដើរលើអាកាស ជាដើម មកបង្ហាញក្នុងផ្ទៃរឿង ។ អក្សរសិល្ប៍ខ្មែរព្រហ្មនិយម គេសង្កេតឃើញមានរឿងរាមកេរ្តិ៍ មានភារតយុទ្ធ ។ល។

### ៣.៤- ផ្នែកទំនៀមទម្លាប់ប្រពៃណី

សង្គមខ្មែរមានទំនៀមទម្លាប់ប្រពៃណីជាច្រើនដែលមានទាក់ទងនឹងលទ្ធិព្រាហ្មណ៍និយម ដូចជា៖

- ពិធីបង្កក់ប្រសិទ្ធីទារក៖ មានជញ្ជាត់ព្រលឹង អន្ទងព្រលឹង។
- ពិធីកោរជុក៖ ប្រើមន្តគាថាប្រសិទ្ធី។
- ពិធីរៀបមង្គលការ៖ ធ្វើនំអន្សមតំណាងលិង្គព្រះឥសូរ ធ្វើនំគម តំណាងយោនីនាងឧមា។ ធ្វើពិធីបុកល័ក្ត បង្វិលពពិល បញ្ចុកចេក។ ក្រមុំកំលោះ



www.elibraryofcambodia.org

ស្រលាញ់គ្នា មានដាក់ស្នេហ៍ មន្តអាគម ។

❖ ពិធីសែនព្រេនៈ ឡើងផ្ទះថ្វាយស្រា ស្លាធម៌ បាយសី ។

❖ ក្នុងពិធីបុណ្យទានៈ មានធ្វើពោងទេវតា ៨ ទិស ធ្វើរទ្រូន មានស្លាធម៌ បាយសី ៧ រូត។

❖ ពិធីរលាយសពៈ មានធ្វើឧបកិច្ចផ្តុំរូបនោះពេលបូជាសពរួច លាងធាតុ ដោយទឹកដូង (លាងបាប)។

ក្រៅពីផ្នែកធំៗខាងលើ ជនជាតិខ្មែរយើងក៏បានទទួលឥទ្ធិពលវប្បធម៌ពីលទ្ធិសាសនាព្រាហ្មណ៍លើច្រើនវិស័យទៀតដូចជា៖

❖ លើវិស័យស្ថាបត្យកម្ម ខ្មែរយើងកសាងប្រាសាទភ្នំ ។

❖ លើស្មារតីទឹកចិត្ត ព្រាហ្មសាសនាបានធ្វើឱ្យខ្មែរយើងមានទឹកចិត្តអង់អាចក្លាហាន មិនចុះញ៉មនឹងខ្មាំងសត្រូវ តែសាសនានេះក៏ធ្វើឱ្យខ្មែរយើងចងគំនុំគំគួនគ្នា សងសឹក គ្មានទីបញ្ចប់ដែរ ។

❖ លើវិស័យនយោបាយ និងការគ្រប់គ្រងក្នុងសម័យអង្គរ ការគ្រប់គ្រងរបស់ព្រះរាជាបានអនុវត្តតាមលទ្ធិទេវរាជ ពោលគឺ ស្តេចមានតួនាទីស្មើនឹងអាទិទេព ស្តេចគឺអាទិទេព អាទិទេពគឺស្តេច។ ពាក្យសម្តីរបស់ស្តេចគឺសម្តីរបស់អាទិទេព ។ ក្នុងពេលសព្វថ្ងៃនេះ ពួកបារគូក៏នៅមានឥទ្ធិពលដល់ការលើករាសីប្រសិទ្ធពរដល់ព្រះរាជាផងដែរ ។

នៅពេលមានពិធីច្រើនទៀត ដែលទាក់ទងនឹងលទ្ធិព្រាហ្មណ៍និយម ប៉ុន្តែ ពិធីកិច្ចការទាំងនោះ មានខ្លះៗជារបស់ខ្មែរស្រេចទៅហើយ ។ ដូច្នេះ ខ្មែរយករបស់ឥណ្ឌាមកកាឡៃយ៉ាងណាឱ្យទៅជារបស់ខ្មែរ មានលក្ខណៈជាខ្មែរ។



www.elibraryofcambodia.org

# លទ្ធិព្រះពុទ្ធសាសនា

## ១- សេចក្តីផ្តើម

ប្រជាពលរដ្ឋខ្មែរដែលមានជំនឿទៅលើព្រះពុទ្ធសាសនានោះ បើពោលដោយសង្ខេប មានន័យថា ព្រះពុទ្ធសាសនាជាសាសនាប្រកបដោយហេតុផល ជាសាសនាប្រកបដោយសេចក្តីពិត ជាសាសនាប្រាប់ឱ្យលះបង់សេចក្តីអាក្រក់ ឲ្យធ្វើសេចក្តីល្អ ជាសាសនាដឹកនាំសត្តនិករឲ្យងាកចេញពីផ្លូវខុស ដើរទៅរកផ្លូវត្រូវ ជាសាសនាជួយសត្វលោកឲ្យស្គាល់មធ្យោបាយដោះខ្លួនអោយរួចផុតពីទុក្ខ ឲ្យបានសម្រេចដល់នូវសេចក្តីសុខក្សេមក្សាន្ត ។

ព្រះពុទ្ធសាសនាផ្សាយចូលមកប្រទេសកម្ពុជាមុនដំបូងតាមគម្ពីរពុទ្ធសាសនា **សមន្តបាសាទិកា អដ្ឋកថា វិនយបិដក** ជាភាសាបាលីបានប្រាប់ព័ត៌មានថា កាលក្រោយពេលដែលធ្វើតតិយសង្គាយនារួចហើយ នៅក្នុងជម្ពូទ្វីប គឺប្រទេសឥណ្ឌា ក្នុងពុទ្ធសតវត្សរ៍ទី ៣ ព្រះមហាថេរមួយអង្គ ព្រះនាម **មហាមោគ្គលិបុត្តតិស្ស** បានចាត់ចែងបញ្ជូនព្រះថេរៈពីរអង្គគឺព្រះ**សោណត្ថេរ** និង ព្រះ **ឧត្តរត្ថេរ** ឲ្យចេញពីជម្ពូទ្វីបឥណ្ឌា មកផ្សព្វផ្សាយព្រះពុទ្ធសាសនានៅសុវណ្ណភូមិ ក្នុងព្រះបរមរាជូបត្ថម្ភនៃ ព្រះមហាក្សត្រ ព្រះនាម **ធម្មាសោក** ។

សុវណ្ណភូមិនៅគឺប្រទេសខាងអាស៊ីអាគ្នេយ៍នេះឯង ដែលមានប្រទេសកម្ពុជា រួមនៅជាមួយផង។ ប្រទេសទាំងឡាយនៅក្នុងអាស៊ីអាគ្នេយ៍ នឹងសម្គាល់សុវណ្ណភូមិនោះជាប្រទេសរបស់ខ្លួនមួយៗ មិនសមទេ គួរប្រទេសទាំងអស់ជាសុវណ្ណភូមិទើបសម ហើយពិតជាត្រូវទៀតផង ព្រោះប្រទេសកម្ពុជាយើង បើពិនិត្យតាមសិលាចារឹកបុរាណខ្លះ តាមប្រវត្តិសាស្ត្រផ្សេងៗខ្លះដែលទាក់ទងដល់រឿងព្រះពុទ្ធសាសនា ឃើញថា ព្រះពុទ្ធសាសនាដែលបានមកប្រតិស្ឋាននៅប្រទេសកម្ពុជា មានតាំងពី ពុទ្ធសតវត្សរ៍ទី ៣ នោះមក ឬ អាចសន្និដ្ឋានបានថា ព្រះពុទ្ធសាសនាបានមកប្រតិស្ឋាននៅប្រទេស កម្ពុជា



www.elibraryofcambodia.org

នៅក្នុងពុទ្ធសតវត្សរ៍ទី ៣ ដោយព្រះសោណត្ថេរនាំមកផ្សាយតាមថេរបញ្ញានៃព្រះ**មហាមោគ្គលិបុត្តតិស្សត្ថេរ និងតាមព្រះបរមរាជបូជនីយកម្មនៃព្រះបាទព្រះនាម ធម្មាសោក** មហារាជ ។

ព្រះរាជាអង្គនេះប្រកបដោយឫទ្ធានុភាពច្រើន ផ្សាយតេជានុភាពទូទៅពេញប្រទេសឥណ្ឌា។ ទ្រង់បានចូលកាន់ពុទ្ធសាសនាហើយបានក្លាយជាព្រះសាសនូបត្ថម្ភកៈក្នុងការធ្វើតតិយសង្គាយនា ព.ស. ២៣៤ (សង្គាយនាទី១ឬបឋមសង្គាយនា ធ្វើក្រោយពុទ្ធបរិនិព្វានប្រមាណ ៣ ខែ ធ្វើរយៈពេលបីខែ, សង្គាយនាទី ២ ឬ ទុតិយ-សង្គាយនា កាលវេលាកន្លងទៅបាន ១០០ឆ្នាំ ធ្វើរយៈពេល ៨ ខែ, សង្គាយនាទី ៣ ឬ តតិយសង្គាយនា, សង្គាយនាទី៤ ឬ ចតុត្ថសង្គាយនាធ្វើរយៈពេល ១០ខែ នៅ ព.ស. ២៣៦ និងសង្គាយនាទី ៥ ឬ បញ្ចមសង្គាយនា ធ្វើរយៈពេល១ឆ្នាំ នាព.ស. ៥២០) ។

ការផ្សាយពុទ្ធសាសនា ចេញពីប្រទេសឥណ្ឌាទៅកាន់ប្រទេសនានា (ក្រៅប្រទេស) តែងតែធ្វើជាពីរផ្លូវ គឺផ្លូវគោក១ និង ផ្លូវទឹក១។ ផ្លូវគោក ពុទ្ធសាសនាផ្សាយទៅតាមពួកពាណិជ ក្បួនរទេះ ដែលធ្វើដំណើរទៅលក់ដូរតាមស្រុកតូចធំនិគមជនបទ ឯផ្លូវទឹក ពុទ្ធសាសនាផ្សាយទៅតាមពួកពាណិជសំពៅសមុទ្រដែលធ្វើដំណើរទៅលក់ដូរតាមកោះតូចធំ ។ តាមទំនៀមពុទ្ធសាសនិក ទោះជាពាណិជជើងគោកក្តី ពាណិជជើងទឹកក្តី ក្នុងពេលធ្វើដំណើរចេញទៅម្តងៗតែងតែនិមន្តភិក្ខុសង្ឃ ឬកសាងព្រះពុទ្ធរូបយកទៅតាមជាមួយ ដើម្បីការពារខ្លួនពីភយន្តរាយ តាមផ្លូវផង ដើម្បីធ្វើសក្ការបូជា យកចំណែកកុសលតាមផ្លូវផង (ការផ្សាយពុទ្ធសាសនាធ្វើនៅក្នុងរដូវវស្សា) ។



## ២- ពុទ្ធប្រវត្តិសង្ខេប

- ព្រះពុទ្ធប្រសូត្រនៅក្រុងកបិលពស្តុ ក្នុងសួនលុម្ពិនី នាថ្ងៃសុក្រ ១៥កើត ពេញបូរមី ខែពិសាខ ឆ្នាំច។ ទ្រង់មានព្រះនាមថា *ព្រះសិទ្ធត្ថ* ឬ *សិទ្ធាថ៌* ក្នុងវង្ស *គោតម* ។



www.elibraryofcambodia.org

- ព្រះបិតាព្រះនាម *សុទ្ធោទនៈ* ព្រះមាតាព្រះនាម *មាយាទេវី* (សិរិមហាមាយា) សោយរាជ្យនៅឥណ្ឌាប៉ែកខាងជើងឈ្មោះរង្គសក្យ (នេប៉ាល់ សព្វថ្ងៃនេះ) នាសតវត្សទី៦ មុនគ.ស ។

- កាលព្រះសិទ្ធត្ថរាជឱរសមានវ័យចម្រើនឡើងទ្រង់សិក្សាវិជ្ជាអក្សរសាស្ត្រនិងវិទ្យាសាស្ត្រ ក្នុង សំណាក់សាស្ត្រាចារ្យនាម "វិស្វាមិត្រ" ។

- បានរៀបអភិសេកជាមួយនាងពិម្ពាយសោធរា កាលព្រះជន្មាយុ ១៦ វស្សា ហើយបានរស់ នៅក្នុងជីវភាពដ៏ប្រសើរបំផុត ។

- បញ្ហាជីវិតបានធ្វើឱ្យទ្រង់យល់អំពីការឈឺចាប់របស់សត្វលោក ។

- កាលព្រះជន្មាយុ ២៩ វស្សា ក្រោយពេលបានព្រះរាជបុត្រមួយអង្គ ព្រះនាមរាហុលកុមារ ព្រះសិទ្ធត្ថកុមារបោះបង់ចោលរាជសម្បត្តិ ហើយបានចេញទៅសាងផ្នួស។

- ទ្រង់បានយាងទៅសិក្សានឹងភិក្ខុជាច្រើនអង្គ ប៉ុន្តែពុំបានសម្រេច ។

- លុះកាលព្រះជន្ម ៣៥ វស្សា នាល្ងាចមួយ ទ្រង់បានទៅសិក្សាក្រោមដើមពោធិ៍ នាក្រុងពិហារសព្វថ្ងៃទ្រង់បានសម្រេចព្រះសម្ពោធិញ្ញាណ ឬការចេះដឹងសព្វគ្រប់ នាថ្ងៃពុធ ១៥ កើត ពេញបូណ៌មី ខែពិសាខ ឆ្នាំរកា ។

- ព្រះអង្គយាងទៅប្រោសបញ្ចវគ្គិយ គឺភិក្ខុ៥អង្គ ជាសហការីចាស់នៅ ឥសិ-បតនមិគទាយពន ក្បែរក្រុងពារាណសី ។

- ទ្រង់យាងប្រោសសត្វទូទៅ ដោយមិនប្រកាន់វណ្ណៈ ព្រមទាំងប្រកាសផ្សាយការរំលាយវណ្ណៈទៀតផង ។

- ទ្រង់ចូលបរិនិព្វាន នៅព្រះជន្មាយុ ៨០ វស្សា នៅក្រុងកុសីនារា ដែលសព្វថ្ងៃហៅឧត្តរប្រទេស (Uttar Pradesh) (ថ្ងៃ ១៥ កើត ពេញបូណ៌មី ខែមាឃ ឆ្នាំម្សាញ់ ព្រះពុទ្ធទ្រង់ដាក់អាយុសង្ខាររបស់ព្រះអង្គដោយប្រាប់មារថា ព្រះអង្គនឹងចូលបរិនិព្វានក្នុងរវាង៣ខែទៀត) នៅថ្ងៃអង្គារ១៥ កើតពេញបូណ៌មី ខែពិសាខ ឆ្នាំម្សាញ់ (៥៤៣ ឆ្នាំ មុនគ.ស.) ។



www.elibraryofcambodia.org



ព្រះពុទ្ធប្រសូត្រ រហូតដល់ត្រាស់ដឹង



ព្រះពុទ្ធប្រោសបញ្ចវគ្គិយ



ព្រះពុទ្ធប្រោសអង្គុលីមាល៍



ព្រះពុទ្ធចូលបរិនិព្វាន

ប្រភព៖ http://phong.com/journal/wp-content



www.elibraryofcambodia.org

**សង្កេត៖** ពេលចេញទៅក្រសាលទាំង ៤លើកព្រះអង្គបានទតឃើញទេពនិម្មិត (ទេវតាចុះមកនិមិតខ្លួន) ៤យ៉ាងគឺ៖

- លើកទី១ ទតឃើញមនុស្សជរា
- លើកទី២ ទតឃើញមនុស្សឈឺ
- លើកទី៣ ទតឃើញមនុស្សស្លាប់
- លើកទី៤ ទតឃើញមនុស្សបួស ។

មនុស្សទាំង៤ប្រភេទនេះបានធ្វើឱ្យព្រះអង្គកើតក្តីសង្វេគហើយយល់ច្បាស់អំពីបញ្ហាជីវិតរបស់សត្វលោក។ មនុស្សប្រភេទទី៤ធ្វើឱ្យព្រះអង្គមានសោមនស្សចង់សាងផ្នួស។

ក្រោយត្រាស់ដឹង ព្រះអង្គតែងបំពេញពុទ្ធកិច្ច ៥ ប្រការជានិច្ច អស់រយៈពេល ៤៥ឆ្នាំ៖

- នៅពេលព្រឹក ទ្រង់និមន្តបិណ្ឌបាត្រ
- នៅពេលរសៀល ទ្រង់សំដែងធម្មទេសនាដល់សាធារណជន
- នៅពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ភិក្ខុសង្ឃ
- នៅពេលកណ្តាលអធ្រាត្រ ទ្រង់ដោះស្រាយប្រស្នានៃពួកទេវតា
- នៅពេលជិតភ្លឺ ទ្រង់ប្រមើលទតនូវសត្វលោកដែលមានភ័ព្វនិងឥតភ័ព្វ។

### ៣- គម្ពីរព្រះត្រៃបិដក

ទាំងទស្សនៈ ទាំងទ្រឹស្តីរបស់ព្រះពុទ្ធអង្គ ស្ថិតនៅក្នុងគម្ពីរព្រះត្រៃបិដក ។

**ព្រះត្រៃបិដកជាអ្វី?**

ព្រះត្រៃបិដក (តាមទស្សនៈព្រះពុទ្ធសាសនា) ជាឃ្លាំងផ្ទុកព្រះពុទ្ធវចនៈ គឺវចនៈនៃអង្គព្រះសម្មាសម្ពុទ្ធដែលទ្រង់ទេសនាទូន្មានរវាង ៤៥ វស្សា ចាប់តាំងពីទ្រង់បានត្រាស់ដឹងព្រះសម្ពោធិញ្ញាណ រហូតមកដល់ទ្រង់បរិនិព្វាន ។

វចនៈដែលទ្រង់សម្តែងនេះហៅថា ធម្មវិន័យ ។ ធម្មវិន័យនេះមាន ៣ ចំណែក គឺ វិន័យ សុត្តន្ត និង អភិធម្ម។ ទាំងបីចំណែកនេះ ព្រះថេរទាំងឡាយបានសង្គាយនា



www.elibraryofcambodia.org

(ផ្ទៀងផ្ទាត់) ចងក្រងហើយដាក់ ទុកមួយក្រុមៗ ហៅថា តិបិដក ឬ ត្រៃបិដក (កញ្ចើ បី) ។ ពាក្យថា «បិដក» នេះ បើប្រែថា «ទូបណ្ណាល័យ» ក៏សឹងតែបានដែរ ។

គម្ពីរព្រះត្រៃបិដក មាន៣ចំណែក គឺ វិន័យបិដក (ជាភាសាខ្មែរ មាន ១៣ ភាគ) សុត្តន្តបិដក (ជាភាសាខ្មែរ មាន ៦៤ ភាគ) និង អភិធម្មបិដក (ជាភាសាខ្មែរ មាន ៣៣ ភាគ) ។

### ៣.១- វិនយបិដក

វិនយបិដកហៅខ្លីថា ព្រះវិន័យ។ បិដកនេះគឺជាកម្រងធម៌វិន័យ ឬ ច្បាប់ទូន្មានរបស់ព្រះសម្មាសម្ពុទ្ធដល់ពួកពុទ្ធបរិស័ទ ពោលគឺជាសេចក្តីបង្គាប់ឱ្យធ្វើអ្វីដែលគួរធ្វើ និងជាការហាមឃាត់មិនឱ្យធ្វើអ្វីដែលមិនត្រូវធ្វើ ហើយដែលគេហៅសង្ខេបថា *បទ-ប្បញ្ញត្តិ* និង *សេចក្តីអនុញ្ញាត* របស់បរមគ្រូ។វិន័យបិដកនេះចែកចេញជាគម្ពីរតូចៗ ៥ តមកទៀតគឺ៖

១- អាទិកម្ម(ទោសធ្ងន់)
២- បាចិត្តយ (ទោសស្រាល) } **វិភង្គ**

៣- មហាវគ្គ (វគ្គធំ)
៤- ចុល្លវគ្គ (វគ្គតូច) } **ខន្ធក**

៥- បរិវារ (សេចក្តីរាយរង) ។

គម្ពីរទី១ និង ទី២ ឋិតនៅក្នុងផ្នែកមួយឈ្មោះ វិភង្គ ដែលអធិប្បាយពីទោសធ្ងន់ ទោសស្រាល របស់ព្រះសង្ឃ។ គម្ពីរទី៣ និង ទី៤ឋិតក្នុងផ្នែកមួយទៀតឈ្មោះ ខន្ធក ដែលនិយាយអំពីវិន័យទាក់ទង នឹងជីវភាពសង្ឃ (កិរិយា សម្លៀកបំពាក់ អនាម័យ បញ្ញត្តិពេលបួស ពេលបុណ្យ ពេលចូលវស្សា)។

### ៣.២- សុត្តន្តបិដក

សុត្តនបិដកហៅខ្លីថា ព្រះសូត្រ។ បិដកនេះគឺជាពាក្យពន្យល់របស់ព្រះពុទ្ធចំពោះពុទ្ធបរិស័ទឱ្យដឹងខុសត្រូវ គុណទោស ស្គាល់ល្អ អាក្រក់ បុណ្យបាប ពុំមែនជាសេចក្តី



www.elibraryofcambodia.org

បង្គាប់ឱ្យធ្វើ ឬពាក្យហាមឃាត់មិនឱ្យធ្វើទេ គ្រាន់តែបង្ហាញផ្លូវល្អ អាក្រក់និទានរឿងជាឧទាហរណ៍បញ្ជាក់ប៉ុណ្ណោះ។ ការជ្រើសរើសផ្លូវដើរស្រេចទៅលើឆន្ទៈរបស់ពុទ្ធបរិស័ទម្នាក់ៗ ។

សុត្តន្តបិដក ចែកជាគម្ពីរធំ៥ ៖

១- ទីឃនិកាយ (ធម៌មានសេចក្តីវែងពិស្តារ)
២- មជ្ឈិមនិកាយ (ធម៌មានសេចក្តីមធ្យម)
៣- សំយុត្តនិកាយ (ធម៌មានសេចក្តីប្រហែលគ្នា)
៤- អង្គុត្តរនិកាយ (ធម៌មានសេចក្តីជាក្រុម ជាពួក)
៥- ខុទ្ទកនិកាយ (ធម៌មានសេចក្តីខ្លីៗ)

គួរកត់សម្គាល់ថា គម្ពីរសុត្តន្តបិដកមានរឿងរ៉ាវជាច្រើនរបស់ពោធិសត្វ ។ រឿងរ៉ាវទាំងនេះហៅថា *ជាតក* ដែលអធិប្បាយពីការសាងបារមី ពីកម្មផល ពីជាតិកំណើត រាប់មិនអស់របស់ពោធិសត្វ ។

### ៣.៣- អភិធម្មបិដក

ហៅខ្លីថា ព្រះអភិធម្ម គឺជាគម្ពីរសំដែងធម៌ទេសនារបស់ព្រះពុទ្ធដែលជាធម៌ល្អក្រៃលែង មានខ្លឹមសារជ្រាលជ្រៅពិបាកយល់ពិបាកចាប់សេចក្តីបំផុត ហៅថា បរមត្ថវិជ្ជា គឺវិជ្ជានិយាយពីចិត្ត ចេតសិក (ភាវៈ កើតស្លាប់ជាមួយចិត្ត) ពីនាមរូប ការកើតស្លាប់ សំសារៈ និព្វាន ។ល។

អភិធម្មចែកជាផ្នែក ឬអត្ថបទសំខាន់ៗ មាន៧៖

១- ធម្មសង្គណីៈ ប្រភេទវិភាគនៃធម៌
២- វិភង្គៈ ការបែងចែកធម៌
៣- កថាវត្ថុៈ ធម៌មានសេចក្តីផ្ទុយគ្នា
៤- បុគ្គលបញ្ញត្តិៈ ការពណ៌នាអំពីបុគ្គល
៥- ធាតុកថាៈ អត្ថាធិប្បាយវែកញែកធាតុ



www.elibraryofcambodia.org

៦- យមកៈ ធម៌មកជាគូៗ

៧- បដ្ឋានៈ ធម៌ជាបច្ច័យទាក់ទងគ្នា ។

ផែកជាងនីមួយៗនៃព្រះត្រៃបិដកខាងលើនេះ ចែកចេញជាគម្ពីរតូចៗច្រើនត ទៅទៀត រួមទាំងអស់មាន ១១០ ក្បាល (ចំនួនសៀវភៅដែលប្រទេសខ្មែរយើងបាន បោះពុម្ពរួចហើយ) ។

ពុទ្ធិ ឬ វិជ្ជា ដែលព្រះពុទ្ធបានអធិប្បាយផ្សាយក្នុងគម្ពីរទាំងនេះមានមូលដ្ឋានឋិត នៅលើធម៌សំខាន់មួយឈ្មោះថា ចតុរារិយសច្ចៈ ឬ អរិយសច្ចៈ ៤។ ពុទ្ធិ ឬ វិជ្ជា មូលដ្ឋាននៃពុទ្ធនិយម អរិយសច្ចៈ ៤ ពុទ្ធិ ឬ វិជ្ជាក្នុងពុទ្ធនិយមមានមូលដ្ឋានឋិត លើទ្រឹស្តីពន្យល់អំពីទុក្ខ បុព្វហេតុនាំឱ្យមានទុក្ខ ការរលត់ទុក្ខ ផ្លូវឬមធ្យោបាយបំបាត់ ទុក្ខ ដែលបានចងក្រងក្នុងអត្ថបទអរិយសច្ចកថា ។ ទ្រឹស្តីពន្យល់ពីភាវៈ សុខៈ ត្រូវតែ មានវិជ្ជាអធិប្បាយពីអរិយសច្ចៈ ៤ ជាពន្លឺដ៏ចាំបាច់ដែរ ។ ដូច្នេះ យើងគប្បីលើកយក អរិយសច្ចៈ ៤ មករៀបរាប់ជាមុន ។

### ៤- អរិយសច្ចៈ

អរិយសច្ចៈមានន័យថា សច្ចៈ ឬ ការណ៍ពិតដ៏ខ្ពង់ខ្ពស់ គួរគោរព គួរជឿ គួរដឹង គួរចេះ ។ គម្ពីរពុទ្ធនិយមបានពន្យល់ថា អរិយសច្ចៈមាន៤យ៉ាងគឺ៖

១- ទុក្ខអរិយសច្ចៈ

២- សមុទយអរិយសច្ចៈ

៣- និរោធអរិយសច្ចៈ

៤- មគ្គអរិយសច្ចៈ

ខាងក្រោមនេះ យើងសិក្សាអំពីអរិយសច្ចៈ ដែលតាមគម្ពីរពុទ្ធនិយមមាន៤ គឺ៖

### ៤.១- ទុក្ខអរិយសច្ចៈ

តាមទ្រឹស្តីព្រះពុទ្ធ មនុស្សសត្វកើតមកតែងជួបប្រទះនឹងទុក្ខ ពិតប្រាកដ ជៀស ពុំផុតឡើយ ប្លែកតែត្រង់ ខ្លះមានទុក្ខតិច ខ្លះមានទុក្ខច្រើន ខ្លះមានទុក្ខមុន ខ្លះមានទុក្ខ ក្រោយ ។ ទុក្ខនោះចែកចេញជាប្រភេទជាច្រើនដូចតទៅនេះ៖



www.elibraryofcambodia.org

ក- *ជាតិទុក្ខ* គឺទុក្ខមានតាំងពីកំណើត តាំងពីនៅក្នុងផ្ទៃមាតា ដូច ខ្លះមានអវៈយវៈពុំគ្រប់គ្រាន់ ឈឺចាប់ដោយមាតាមានការប៉ះទង្គិចខ្លាំងឬមានគ្រោះថ្នាក់ មានការក្រហល់ក្រហាយឈឺផ្សា ដោយមាតាបរិភោគអាហារមិនល្អ ពេលកើតចេញមក ក៏មានទុក្ខដោយកើតពិបាក ដោយឆ្អបដុះលាងសំអាត ។ល។

ខ- *ជរាទុក្ខ* ពោលគឺទុក្ខកើតមានពេលចាស់ជរា។ មនុស្សសត្វមិនអាចចៀសផុតពីចាស់ជរា បានជាដាច់ខាត ។ ជរាភាពធ្វើឱ្យរូបកាយទ្រុឌទ្រោម គ្រាំគ្រាវិកលវិការធ្មេញបាក់ សក់ស្កូវ ថ្ពាល់ខួង ស្បែកជ្រីវជ្រួញ កម្លាំងថយ ភ្នែកងងឹត ត្រចៀកថ្លង់។ល។ សភាពបែបនេះប្រកបដោយទុក្ខពិត ប្រាកដ។

គ- *ព្យាធិទុក្ខ* គឺទុក្ខកើតពេលមានជំងឺ។ មនុស្សសត្វតែងជួបប្រទះជានិច្ចនូវធាតុក្ដៅ គ្រជាក់ គ្រុនរងារ ឈឺក្បាលវិលមុខ ចុកពោះ ឈឺទ្រូង អុតកញ្ជ្រិល ពិស បូសដួលកាល របេងរីងរៃ មហារីក គាំងបេះដូង ស្វាយប្រមេះ។ល។ ដូច្នេះ ពេលមានជំងឺមនុស្សសត្វ ពិតជាឈឺចុកចាប់ច្រើនបែបយ៉ាង ណាស់ ។

ឃ- *មរណទុក្ខ* គឺទុក្ខកើតមាននៅពេលស្លាប់ ។ មនុស្សសត្វជៀសមិនផុតពីសេចក្ដីស្លាប់ ។ រៀបនឹងស្លាប់ មនុស្សសត្វតែងមានសេចក្ដីតក់ស្លុត សោកស្ដាយជីវិត ។ ការភ័យ ការសោកស្ដាយនេះជាទុក្ខ ។ ពេលស្លាប់ មនុស្សសត្វកម្រជួបប្រទះនឹងភាពសុខស្រួលណាស់ ច្រើនតែអន្ទះអន្ទែង រសោប់រសល់ ធាតុក្ដៅត្រជាក់ឡើងចុះខ្លាំងធ្វើឱ្យវេទនាឈឺចាប់ឥតឧបមា ។ ខ្លះស្លាប់ ដោយគេវាយដំ ចាក់កាប់ ធ្វើទារុណកម្មឱ្យរងទុក្ខខ្លោចផ្សាកាន់តែខ្លាំងណាស់ទៅទៀត ។

ង- ក្រៅពីទុក្ខទាំង៤ខាងលើនេះនៅមានទុក្ខច្រើនយ៉ាងទៀត ដែលកើតមកពីការព្រាត់ ប្រាសមិត្តសម្លាញ់ ឪពុកម្ដាយ ទុក្ខកើតមកពីអ្នកដទៃធ្វើឱ្យខឹងក្ដៅក្រហាយតូចចិត្តមកពីខ្លួនឯង ប្រព្រឹត្តអំពើខុសឆ្គង មិនត្រូវចិត្តខ្លួនឯង ខ្លួនឯងលោភចង់បានមិនសម្រេចបំណង មកពីគ្រឿងវិញ្ញាណ ជួបប្រទះនឹងរូបារម្មណ៍មិនល្អ មិនគាប់ចិត្ត ។ល។



www.elibraryofcambodia.org

### ៤.២- សមុទយអរិយសច្ចៈ

សមុទយអរិយសច្ចៈអធិប្បាយអំពីហេតុដែលនាំឱ្យកើតទុក្ខ បានសេចក្តីថាទុក្ខកើតឡើងមកពីមានហេតុ មានឫសគល់ជាប្រាកដ ។ តាមលទ្ធិពុទ្ធនិយម ឫសគល់ធំនៃទុក្ខមាន ២ យ៉ាងគឺ *អវិជ្ជា* និង *តណ្ហា* ។

**អវិជ្ជា** និង **តណ្ហា** គឺសេចក្តីល្ងង់ខ្លៅ និងចិត្តជាប់ជំពាក់លោភចង់បាន ត្រេកត្រអាល ស្រេកឃ្លានចង់រស់នៅចង់សប្បាយក្នុងវដ្តសង្សារ ។ មានអវិជ្ជា មនុស្សមិនយល់ប្រយោជន៍លោកុត្តរ ឬប្រយោជន៍និព្វាន ហើយវានាំឱ្យមនុស្សមានតណ្ហា ដែលជាប្រភពនៃទុក្ខ។

តណ្ហាមាន ៣ ប្រភេទ៖

ក- កាមតណ្ហា

ខ- ភវតណ្ហា

គ- វិភវតណ្ហា

- **កាមតណ្ហា** គឺជាការជាប់ជំពាក់និងកាមគុណ ៥ (រូប សម្លេង ក្លិន រសសម្ផស្ស) ចង់បាន សម្បត្តិមនុស្ស ចង់បានសម្បត្តិទេវតា ។

- **ភវតណ្ហា** គឺការលោភចង់បានទៅកើតក្នុងឋានព្រហ្មដោយយល់ខុសថា ចាស់ជរា មរណៈ នៅក្នុងឋាននោះពុំមានឡើយ។ ភវតណ្ហាកើតមានដល់ពួកយោគាវចរដែលខំធ្វើឈានសមាបត្តិ ប្រាថ្នា ឱ្យបានកើតក្នុងឋាន ព្រហ្មនេះ។

- **វិភវតណ្ហា** គឺលោភចង់បានទៅកើតនៅឋានព្រហ្មដោយយល់ថាពុំវិលត្រឡប់មកកើតក្នុងឋានមនុស្សវិញទេ ហើយភាន់ច្រឡំថានឹងបាននិព្វាន រំលត់ខន្ធនៅក្នុងព្រហ្មលោកនេះ។

### ៤.៣- និរោធអរិយសច្ចៈ

**និរោធ** មានន័យថារលត់ ។ ព្រះពុទ្ធបានចែងថា បើចង់បំបាត់ទុក្ខ ត្រូវបំបាត់អវិជ្ជា លះបង់តណ្ហា រំលត់រំលាយតណ្ហាកុំឱ្យសេសសល់ ។ អវិជ្ជា និង តណ្ហា ជាឫសគល់នៃទុក្ខ ។ កាលបើអស់ អវិជ្ជា វិជ្ជាដែលជាពន្លឺយល់ច្បាស់នូវប្រយោជន៍និព្វាន



www.elibraryofcambodia.org

ក៏កើតមានឡើង តណ្ហា ការជាប់ជំពាក់នឹងប្រយោជន៍លោកិយ ប្រយោជន៍ក្នុងឋានសួគ៌ក៏ត្រូវលោយរលត់ថែមទៀត ទុក្ខទាំងពួងមាន ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ ជាដើមនឹងវិនាសជាប្រាកដ ប្រៀបដូចជាអ្នកធ្វើចំការដែលគាស់រំលើងឫសឈើ ឫសស្មៅសម្អាតដីដាំដំណាំ បើកាត់តែមែកឈើ ជម្រះតែស្មៅលើៗ រុក្ខជាតិទាំងនោះនឹងដុះឡើងវិញ ផលដំណាំនឹងស្វិត ឬ ក្រិនជាមិនខាន ។ ដូច្នេះ ទស្សនៈសមុទយអរិយសច្ចៈបញ្ជាក់ថា ទុក្ខ គេពិតជាអាចរំលត់រំលោយបានជាប្រាកដ ។

**៤.៤- មគ្គអរិយសច្ចៈ**

គឺផ្លូវសម្រាប់រំលត់ទុក្ខ ។ មគ្គអរិយសច្ចៈមានន័យថា ផ្លូវសម្រាប់ប្រតិបត្តិដើម្បីបំបាត់ទុក្ខមានពិតប្រាកដមែន។ មគ្គអរិយសច្ចៈ គឺជាសច្ចៈខ្ពង់ខ្ពស់មែន ។ ដើម្បីរំលត់ទុក្ខ ត្រូវតែដើរតាមផ្លូវនេះ ។

ពួកអរិយបុគ្គល មានព្រះពុទ្ធជាដើម ដែលអនុវត្តតាមផ្លូវនេះ បានរួចចាកទុក្ខដែលបណ្ដាល មកពីអវិជ្ជា កិលេស តណ្ហាគ្រប់យ៉ាង ហើយបានសម្រេចនិព្វាន លែងកើត ចាស់ ឈឺ ស្លាប់ ។ មគ្គ ឬ ផ្លូវរំលត់ទុក្ខមាន ៨ យ៉ាងដែលមានឈ្មោះថា **អដ្ឋង្គិកមគ្គ** មានជាអាទិ៍គឺ៖

**១- សម្មាទិដ្ឋិ** ៖ ការយល់ឃើញត្រូវ ដឹងច្បាស់នូវសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ មគ្គសច្ចៈ ពេញចិត្តនឹងងយកនិព្វានជាគោលដៅ ហើយយល់ព្រមប្រតិបត្តិតាមផ្លូវត្រូវ ៨ យ៉ាងនេះ ដើម្បីកំចាត់ ឱ្យអស់នូវ អវិជ្ជា និង តណ្ហា ។

**២- សម្មាសង្កប្បៈ** ៖ ការត្រិះរិះត្រូវ បានដល់ការត្រិះរិះគិតបំពេញសីលទានចម្រើនមេត្តាភាវនា រិះគិត កំចាត់ការចងពៀរព្យាបាទ កំចាត់គំនិតឈ្នានីស បៀតបៀនអ្នកដទៃ កំចាត់លោភៈ ទោសៈ មោហៈ និង ចិត្តគំនិតអាក្រក់ផ្សេងទៀតគ្រប់យ៉ាងទាំងអស់ ហើយរិះគន់សន្សំកសាងតែអំពើល្អ កុសលជានិច្ច ។

**៣- សម្មាវាចា** ៖ ពាក្យសម្ដីត្រូវ ហៅថា *វចីសុចរិត* ដែលមាន៤ យ៉ាងគឺ៖

- បៀសវាងពាក្យកុហក បោកបញ្ឆោតដែលធ្វើឱ្យគេខូចចិត្ត ខូចប្រយោជន៍ (មុសាវាទ)



www.elibraryofcambodia.org

- ចៀសវាងពាក្យស៊កសៀត ញុះញង់បំបែកបំបាក់ ដែលធ្វើឱ្យអ្នកដទៃខូចប្រយោជន៍ ខ្មាសអៀន ឈឺចាប់ ក្ដៅក្រហាយ (មេសុនាវាទ)

- ចៀសវាងពាក្យអាក្រក់ គំរោះគំរើយ ជេរប្រទេច ត្មះតិះដៀល (ផុរសវាទ)

- ចៀសវាងពាក្យក្រមាច់ កំប្លែង សើចលេងឥតប្រយោជន៍ (សម្ផប្បលាវាទ) ។

**៤- សម្មាកម្មន្ត ៖** ការងារត្រូវ ប្រព្រឹត្តត្រូវ មានការប្រព្រឹត្តល្អ ដោយផ្លូវកាយ ៣ យ៉ាងជាដើម ហៅថា *កាយសុចរិត* ៖

- មិនសម្លាប់សត្វ មានជីវិត (បាណាតិបា វេរមណី)

- មិនលួចទ្រព្យសម្បត្តិអ្នកដទៃ (អទិន្នាទានា វេរមណី)

- មិនសេពកាមខុសច្បាប់ គឺមិនលួចប្រពន្ធគេ កូនគេ (កាមេសុមិច្ឆាចារា វេរមណី) ។

**៥- សម្មាអាជីវៈ៖** ការចិញ្ចឹមជីវិតត្រូវ បានដល់ការចិញ្ចឹមជីវិតដោយគន្លងធម៌ ដូចជាមិនរកស៊ី លួចប្លន់ទ្រព្យសម្បត្តិឯកជន ឬ ទ្រព្យសម្បត្តិរដ្ឋ មិនប្រកបមុខរបរពុករលួយ ផ្ទុយនឹងច្បាប់រដ្ឋ មិនរត់ពន្ធ ចិញ្ចឹមស្រីពេស្យា ធ្វើជំនួញទុច្ចរិត លក់មនុស្ស លក់គ្រឿងអាវុធ លក់ថ្នាំពុល ។ល។

**៦- សម្មាវាយាម៖** ការព្យាយាមត្រូវ ដូចជាព្យាយាមប្រព្រឹត្តអំពើល្អ ជាប្រយោជន៍សាធារណៈ ព្យាយាមលះបង់ចិត្តលោភដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន ចិត្តជាប់ជំពាក់នឹងកាមតណ្ហា ព្យាយាមទប់ទល់ប្រឆាំងនឹងអំពើអកុសលគ្រប់យ៉ាង ព្យាយាមកសាងសន្សំកុសលធម៌ ដែលមិនទាន់មាន ព្យាយាមថែរក្សាបុណ្យកុសលដែលមានហើយកុំឱ្យបាត់ទៅវិញ ។ល។

**៧- សម្មាសតិ៖** ការភ្ញាក់រឭកនឹកឃើញត្រូវ បានដល់សតិនឹករឭក យករូបក្ខន្ធ វេទនាក្ខន្ធ វិញ្ញាណក្ខន្ធ សញ្ញាក្ខន្ធ សង្ខារក្ខន្ធជាអារម្មណ៍ ហើយពិចារណារូប វេទនា វិញ្ញាណ សញ្ញា ឱ្យឃើញថាជាអនិច្ចំ ទុក្ខំ អនត្តា ជាប់ជានិច្ច ។

**៨- សម្មាសមាធិ៖** ការធ្វើសមាធិត្រូវគឺនាំឱ្យចិត្តស្ងប់ស្ងាត់ ប្រាសចាកកិលេសកាម និង វត្ថុកាមហើយ ធ្វើចិត្តឱ្យបិតក្នុងឈាន៤៖



www.elibraryofcambodia.org

១- បឋមជ្ឈាន មានអង្គ៥ (វិតក្ក១ វិចារ ១ បីតិ១ សុខ១ ឯកគ្គតា១ គឺការធ្វើចិត្តឱ្យស្ពឹងក្នុង អារម្មណ៍តែមួយ) ។

២- ទុតិយជ្ឈាន មានអង្គ៣ (បីតិ សុខ ឯកគ្គតា)

៣- តតិយជ្ឈាន មានអង្គ២ (សុខ ឯកគ្គតា)

៤- ចតុត្ថជ្ឈាន មានអង្គ ២ (ឯកគ្គតា ឧបេក្ខា) ។

សមាធិនេះមានដំណើរអប់រំចិត្ត ឬប្រមូលអារម្មណ៍ឱ្យនឹង ឱ្យមូលបន្តិចម្តងៗ ហេតុដល់លែង រវើរវាយ រិលវល់ ហើយតាំងនៅស៊ប់ជានិច្ចក្នុងអារម្មណ៍តែមួយ ។

## ៥- ការបែងចែកនៃព្រះពុទ្ធសាសនា

### ៥.១- និកាយនៃពុទ្ធសាសនានៅកម្ពុជា

ការស្រាវជ្រាវអំពីវប្បធម៌អារ្យធម៌ខ្មែរបុរាណបានឱ្យដឹងថាលទ្ធិព្រះពុទ្ធសាសនា ដែលបានហូរចូលពីប្រទេសឥណ្ឌា មកនៅក្នុងប្រទេសកម្ពុជាបុរាណ ត្រូវបាន ចែកចេញជា ២ និកាយធំៗគឺ និកាយមហាយានឬវជ្រយាន និង និកាយហីនយាន ឬ ថេរវាទ។

#### ៥.១.១- និកាយមហាយាន ឬ វជ្រយាន

ក្នុងនិកាយមហាយាន ដែលមានការឃ្លាតចេញពីទ្រឹស្តីដំបូងនៃ ការប្រៀនប្រដៅបង្ហាត់បង្រៀនមូលដ្ឋានរបស់សម្មាសម្ពុទ្ធ គេឃើញជំនឿលើកត្តាដូចតទៅ៖

- ការរំដោះមនុស្សលោកដែលជាសភាវៈទាំងអស់ដោយព្រះពោធិសត្វ ការមានមេត្រី ឬមេត្តា ករុណាធម៌ចំពោះខ្លួនឯង ។
- ជំនឿលើប្រាជ្ញាឬបញ្ញា ដែលដោះលែងឱ្យមានសេរីភាពលើសូន្យឬភាពទទេ។ ក្នុងលទ្ធិមហាយាន មាននិកាយវជ្រយានដែលប្រកាន់នូវគោលគំនិតសំខាន់ គឺសេចក្តីប្រាជ្ញា សេចក្តីរីករាយតាមផ្លូវចិត្តឬតន្ត្រៈ និង តួនាទីសំខាន់របស់គ្រូបាធ្យាយក្នុងពេលរំដោះទុក្ខ។



www.elibraryofcambodia.org

លទ្ធិមហាយានគឺជាយានធំ ។ គេជឿថា យាននេះអាចផ្ទុកមនុស្សច្រើនជាងហីនយាន ដើម្បីឆ្ពោះទៅកាន់គោលដៅត្រឹមតែព្រះពោធិសត្វ មិនទាន់ដល់ព្រះនិព្វាននៅឡើយទេ។ មហាយានជាលទ្ធិថ្មីប្រកបដោយវិន័យ ឬ ធម៌ដែលធូរស្រាល មិនមែនតឹងតែងហ្មត់ចត់ដូចហីនយានឡើយ។ ក្នុងលទ្ធិនេះ គេគោរពប្រតិបត្តិតាមលទ្ធិអាចរិយវាទ គឺតាមគ្រូអាចារ្យរបស់ខ្លួនតៗគ្នា ដែលមាន ព្រះលោកេស្វរៈ ជាដើម ។

ទំព័រប្រវត្តិសាស្ត្របានចែងថា ទ្រឹស្តីព្រះពុទ្ធសាសនាមហាយាននេះបានរីកចម្រើនយ៉ាងខ្លាំងក្លា នៅទីក្រុងនាលន្ទា ដែលបានស្ថាបនាឡើងនៅពាក់កណ្តាល ស.វ. ទី ៥ នៃគ.ស. ដោយមានសង្ឃសំខាន់ៗដែលជាតំណាងដូចជាព្រះគ្រូ *ចន្ទ្រគោមិន* ដែលជាវេយ្យាករវិទូដ៏ចំណានមួយរូប ។

ប្រជាជនកម្ពុជាចាប់ផ្តើមគោរពពុទ្ធសាសនានិកាយមហាយាននាសតវត្សទី ៨ ហើយនិកាយ នេះមានការរីកចម្រើនខ្លាំងនាសម័យអង្គរក្នុងរាជស្តេចជ័យវរ្ម័នទី ៥, សូរ្យវរ្ម័នទី១ និង ជ័យវរ្ម័នទី៧។

## ៥.១.២- និកាយហីនយានឬថេរវាទ

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋនិងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងជីវិតប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ ។ ការស្រាវជ្រាវអំពីព្រះពុទ្ធសាសនានៅកម្ពុជាបានបង្ហាញនូវប្រភពឥណ្ឌានៃសាសនានេះ។ សាសនានេះបានចាក់ឫសកែវតាមទីកន្លែង តាមយុគសម័យ ឬ ដំណាក់កាលលូតលាស់ក្នុងសង្គមបុរាណ និង សិល្បៈជាដើម។ ប៉ុន្តែរហូតមកដល់សព្វថ្ងៃ គេពុំទាន់ឃើញមានការពិចារណាស៊ីជម្រៅណាមួយស្តីពីប្រវត្តិ ឬ ចំណាស់របស់លទ្ធិថេរវាទ ឬ ហីនយាននេះនៅកម្ពុជានៅឡើយ ។

**តើអ្វីទៅជាលទ្ធិព្រះពុទ្ធសាសនា? តើយើងអាចបង្ហាញនូវប្រភពសាសនានេះនៅប្រទេស ខ្មែរយើងបានដែរឬទេ ហើយតើយើងមានឯកសារដើម្បីអ្វីសំអាងមតិរបស់យើង?**



www.elibraryofcambodia.org

និកាយថេរវាទដែលមានន័យថានិកាយចាស់ទុំ មានបទប្បញ្ញត្តិតឹងរ៉ឹង ។ នៅប្រទេសឥណ្ឌា លទ្ធិនេះត្រូវបានគេគូសបញ្ជាក់តាមប្រវត្តិផែនដីគឺ ទីបវង្ស និង មហាវង្ស តែងដោយព្រះថេរមហានាម។ ក្រៅពីនេះ គេឃើញមានឯកសារមួយចំនួនដែលជាវិចារណកថានា ស.វ. ទី ៥ នៃគ.ស. របស់ ព្រះពុទ្ធឃោសៈ ព្រមទាំងកំណត់ហេតុរបស់អ្នកដំណើរចិនឈ្មោះថា ហ្វាហាន, សួន, សាង និង អ៊ី ឈីងជាដើម ។ វិស័យបុរាណវិទ្យា និងសិលាចារឹកសាស្ត្រក៏អាចបំពេញបន្ថែមលើទិន្នន័យខាងលើនេះដែរ ។ លទ្ធិហិនយាន ឬថេរវាទ បានចាប់ផ្តើមដុះដាលហើយចាក់គ្រឹះយ៉ាងរឹងមាំនៅរជ្ជកាលរបស់ព្រះបាទអសោកនៃរាជវង្សមោរ្យៈ (២៩២-២៣៦ មុនគ.ស) ។ ក្នុងសម័យនោះព្រះអង្គបានបញ្ជាមហាថេរមហិន្ទឱ្យនិមន្តទៅទេសនានៅលង្កាទ្វីប ។ ព្រឹត្តិការណ៍នេះត្រូវបានប្រព្រឹត្តឡើងនៅ ស.វ. ទី៣ មុនគ.ស. ហើយជាមូលហេតុនៃការជ្រួតជ្រាបផ្សព្វផ្សាយនៃលទ្ធិព្រះពុទ្ធសាសនា ក្នុងបណ្តាជននៃប្រទេសសិរីលង្កា ចាប់ពីពេលនោះមក ។

ដូច្នេះ វប្បធម៌ព្រះពុទ្ធសាសនាហីនយានឬថេរវាទបានហូរចូលក្នុងនរគរភ្នំនៅរជ្ជកាលរបស់ព្រះអង្គ ក្នុងស.វ. ទី ៣ មុនគ.ស. ក្រោយពីព្រះអង្គបានធ្វើសង្គាយនារួចមក ។ តាមប្រភពឯកសារប្រវត្តិសាស្ត្រ យើងដឹងថា គឺព្រះមោគ្គល្លិបុត្តតិស្សត្ថេរ ដែលជាមេព្រះសង្ឃ បានចាត់ព្រះថេរពីរព្រះអង្គគឺ សោណត្ថេរ និងឧត្តរត្ថេរ ដើម្បីឱ្យទៅផ្សព្វផ្សាយព្រះពុទ្ធសាសនានៅជ្រោយសុវណ្ណភូមិយើង នេះ ។ ដូច្នេះ ទឹកដីខ្មែរ កាលពីអតីតកាល មុនការបង្កើតរដ្ឋភ្នំនាដើមស.វ.ទី ១ នៃគ.ស. ពិតជាបានទទួលលទ្ធិព្រះពុទ្ធសាសនាហីនយានឬថេរវាទ គឺតំណាលនឹងប្រទេសភូមាដែលជាប់ភូមិបេងជាមួយនឹង ទឹកដីខ្មែរបុរាណ បន្ទាប់ពីសន្និបាតសង្ឃនោះមែន ពោលគឺមុនការបង្កើតរដ្ឋរបស់ថៃនៅស.វ. ទី១៣ នៃគ្រិស្តសករាជលើទឹកដីនៃប្រទេសកម្ពុជាបុរាណ ។ នេះជាភ័ស្តុតាងខាងប្រវត្តិសាស្ត្រដែលអាចបំភ្លឺយើងឱ្យឃើញថា លទ្ធិព្រះពុទ្ធសាសនាថេរវាទនេះប្រហែលជាត្រូវបានផ្សព្វផ្សាយក្នុងបង្គោលសីមានៃដែនដីខ្មែរតាំងតែពីស.វ. ទី ៣ មុនគ.ស.ដូចមតិរបស់ព្រះភិក្ខុប៉ាងខាត់ ក៏ប៉ុន្តែភាពរុងរឿងថ្កុំថ្កើងនៃព្រះពុទ្ធិសាសនា



www.elibraryofcambodia.org

ពោលគឺវឌ្ឍនភាពនៃសាសនានេះបានផ្ដើមឡើងត្រឹមតែនៅស.វ. ទី ២ ទៅ ស.វ. ទី ៤ នៃគ.ស.តែប៉ុណ្ណោះ ក្នុងពេលជាមួយគ្នានឹងលទ្ធិព្រហ្មញ្ញសាសនាដែលមានឥទ្ធិពលជាង។

## ៥.២- ភាពខុសគ្នារវាងនិកាយហីនយាន និង និកាយមហាយាន

និកាយមហាយាន

១- ជាយានធំ អាចដឹកនាំសត្វលោកបានច្រើនដល់ត្រឹមឋានសួគ៌។

២- អប់រំពុទ្ធបរិស័ទឱ្យជ្រះថ្លា ។

៣- គោរពតាមលទ្ធិអាចរិយវាទ ដែលតម្រូវឱ្យត្រេងត្រាប់ស្ដាប់គ្រូអាចារ្យរបស់គេតៗគ្នា និងពឹងផ្អែកលើគម្ពីរសាសនាដែលខុសផ្លែកពីគម្ពីរព្រះត្រៃបិដក។ គម្ពីរទាំងនោះមានដូចជាលទ្ធម្មបុណ្ឌរីកៈ លង្ការវតារសូត្រ សុវណប្រភាស្ស លង្កាតារ ជាដើម។ ចំពោះភាសាដែលប្រើក្នុងការកត់ត្រាគម្ពីរគឺ គេយកភាសាសំស្ក្រឹតជាចម្បង។

៤- គោរពពោធិសត្វដែលមិនទាន់ចូលនិព្វានដូចជា៖

- អវលោកិតេស្វរៈ ជាអ្នកសង្គ្រោះផ្ដល់សេចក្ដីសុខថែរក្សាលោក
- មញ្ចុស្រី ជាអ្នកត្រួតត្រាផ្លូវយុត្តិធម៌
- សមន្តភទ្រ ជាអ្នកថែរក្សាអ្នកកាន់សាសនា
- មៃត្រេយ នៅចាំថែរក្សាសាសនាដែលព្រះសមណគោតមបានផ្សាយ
- ក្សិតិគត៌ ជាពោធិសត្វស្រោចស្រង់មនុស្សពីឋាននរក
- វជ្របាណិ ជាពោធិសត្វការពារសាសនា
- ប្រាជ្ញាបារមិតា ជាពោធិសត្វតំណាងចំណេះដឹង ។

៥- ជឿថា ព្រះពុទ្ធជាអច្ឆរិយបុគ្គល បែងភាគស្ថិតនៅគ្រប់ទីកន្លែង អាស្រ័យដោយឈានដូចជា ព្រះពុទ្ធឈ្មោះ «អមិតាភអក្សោភ្យៈ» ដែលស្ថិតនៅទិសខាងលិចក្នុងឋានសួគ៌ឈ្មោះ «សុខាវតី»។



www.elibraryofcambodia.org

៦- ជឿថា ដើម្បីសម្រេចបរមសុខ បរិស័ទគ្រាន់តែមានចិត្តជ្រះថ្លាចំពោះព្រះពុទ្ធទៅបានហើយ។
៧- ពន្យល់ថា គោលបំណងធំបំផុតគឺទីពោធិសត្វដែលមានពោធិញ្ញាណ។
៨- ជឿថា កុសលល្អរបស់មនុស្សម្នាក់អាចជះឥទ្ធិពល រឺជួយស្រោចស្រង់អ្នកដទៃឲ្យរួចពីទុក្ខទោសបាន។
៩- ឱ្យព្រះសង្ឃស្លៀកខោ ពាក់អាវពណ៌លឿង ។
១០- អនុញ្ញាតឱ្យព្រះសង្ឃអាចរកស៊ីជួញដូរបាន ។
១១- បញ្ញត្តព្រះសង្ឃឱ្យឆាន់តែម្ហូបបួស មិនមានសាច់ឡើយ។

**និកាយហីនយាន**

១- ជាយានតូចដឹកសត្វលោកបានតិចទៅដល់និព្វាន។
២- អប់រំទូន្មាន កាយ វាចា ចិត្តឱ្យល្អ។
៣- គោរពពុទ្ធោវាទ តាមគម្ពីរព្រះត្រៃបិដកតែមួយគត់ដែលមានចំនួន ១១០ ក្បាល (ជាភាសាខ្មែរ) និង ៨៤០០០ ព្រះធម្មក្ខន្ធ ដែលចែកជា វិនយបិដក សុត្តន្តបិដក និង អភិធម្មបិដក។ ភាសាដែលប្រើជាភាសាបាលី ។
៤- ជឿថា មានតែព្រះពុទ្ធមួយគត់ដែលអាចជួយស្រោចស្រង់សត្វលោក។
៥- ជឿថា ព្រះពុទ្ធអាចសម្រេចឈានហោះហើរ តែពុំមែនបែងភាគទៅគ្រប់ទិសទីទេ។
៦- អប់រំឱ្យធ្វើទានភាវនា បើម្បីសម្រេចនិព្វាន។
៧- អប់រំឱ្យប្រាថ្នាយកអរហន្ត និងនិព្វានជាគោលដៅធំបំផុត។
៨- ពន្យល់ថា ដើម្បីរួចពីទុក្ខទោស បុគ្គលម្នាក់ៗត្រូវខិតខំសន្សំបុណ្យកុសលដោយខ្លួនឯង គឺមានតែខ្លួនគេផ្ទាល់ទេដែលអាចជួយខ្លួនគេបាន។
៩- ព្រះសង្ឃ ត្រូវគ្រងឃ្លុំស្បង់ចីវរ ពណ៌លឿង។
១០- បញ្ញត្តមិនឱ្យព្រះសង្ឃប្រកបរបររកស៊ីឡើយ។
១១- អនុញ្ញាតឱ្យព្រះសង្ឃឆាន់សាច់ (ម្ហូបមានសាច់) បាន។


www.elibraryofcambodia.org

និកាយហីនយានចែកចេញជាពីរទៀតគឺ គណៈមហានិកាយ និង គណៈធម្មយុត្តិកនិកាយ។ គេសង្កេតឃើញមានលក្ខណៈខុសគ្នាបន្តិចបន្តួចរវាង គណៈទាំងពីរ៖

- ផ្នែកធម៌
- ផ្នែកវិន័យ
- ទម្លាប់ពាក់ស្បែកជើងនិងកាន់បាត្រ
- ទម្លាប់ឆាន់គេសជ្ជៈបន្ទាប់ពីពេលថ្ងៃត្រង់ ។

ឯលក្ខណៈខុសគ្នាខ្លាំងនៃ គណៈធម្មយុត្តិ និង គណៈមហានិកាយមាន

**គណៈមហានិកាយ៖**

- ស្បង់ជីវរមានប្រវែង ១៥ហត្ថ
- សាមណេរគ្រងស្បង់ជីវរនិងដណ្តប់ស្មាខាងឆ្វេង ហើយទុកស្មាខាងស្តាំទំនេររាល់ពេល។
- កាសូត្រធម៌ត្រូវជូនគ្នាល្អទៅតាមរបៀប ហើយពេលសូត្រធម៌មិនឱ្យមានគេវខាន ដែលធ្វើ ឱ្យអាក់ខានដល់ការសូត្រធម៌។

**គណៈធម្មយុត្តិ**

- ស្បង់ជីវរមានប្រវែង១០ហត្ថ
- សាមណេរ និងភិក្ខុត្រូវបានអនុញ្ញាតឱ្យគ្រងស្បង់ជីវរលើស្មាទាំងសងខាង
- ការសូត្រធម៌ ឬ បាលីត្រូវសូត្រដោយបញ្ចេញសំឡេងខ្សឹបៗ ហើយត្រូវសង្កត់សំឡេងគ្រប់ ពាក្យដែលនៅខាងចុងឃ្លា។
- ការអនុវត្តនិងគោរពរបស់គណៈធម្មយុត្តិមានលក្ខណៈខិតទៅរកព្រះពុទ្ធច្រើនជាងមហានិកាយ ។

❖ គណៈមហានិកាយបានចែកជាពីរផ្នែកទៀត គឺ៖

- វត្តនិយមធម៌ចាស់ (ធម៌មិនប្រែភាសាបាលីមកជាភាសាខ្មែរ) វត្តបែបនេះគេហៅថាវត្តចាស់ ឬវត្តប្រកាន់វិធីបុរាណ ។



www.elibraryofcambodia.org

- វត្តនិយមធម៌ថ្មី (ធម៌ដែលប្រែពីភាសាបាលីមកជាភាសាខ្មែរដើម្បីឲ្យពុទ្ធសាសនិកងាយយល់)។ វត្តបែបនេះគេហៅថាវត្តថ្មី (មិនមែនវត្តសង់ថ្មីទេ) គឺវត្តប្រកាន់ធម៌សម័យ។

បច្ចុប្បន្នកាល ប្រទេសខ្មែរយើងនៅតែមានបញ្ញាធម៌បុរាណ និង ធម៌សម័យ រហូតមកទល់ពេលនេះ។

## ៦- វិវឌ្ឍន៍ និង ឥទ្ធិពលព្រះពុទ្ធសាសនានៅក្នុងប្រទេសកម្ពុជា

### ៦.១- សម័យបុរេប្រវត្តិសាស្ត្រ

នៅសម័យបុរេប្រវត្តិ មុនសតវត្សទី ១ នៃគ.ស. ព្រះពុទ្ធសាសនាបានចូលមកដល់ប្រទេសកម្ពុជាយើងហើយ តែវិវឌ្ឍន៍ និង ការរីកចម្រើនយ៉ាងណានោះ យើងពុំអាចដឹងបានច្បាស់លាស់ទេ ព្រោះយើងពុំអាចរកឃើញឯកសារ ឬ ការកំណត់ណាដែលយើងអាចវាយតំលៃ ឬ ធ្វើការសន្និដ្ឋាន បានឡើយ ។ តែទោះជាយ៉ាងណា ក៏យើងអាចយល់ថា ព្រះពុទ្ធសាសនា ក្រោយការចូលមកដល់ ក្នុងសម័យបុរេប្រវត្តិសាស្ត្រនោះ ជាពន្លកត្រួយទ្រទ្រង់ដល់វិវឌ្ឍន៍នៃសម័យក្រោយៗមកទៀត ។

នៅក្នុងសម័យបុរេប្រវត្តិសាស្ត្រ មុនសតវត្សទី ១ នេះ ជនជាតិខ្មែរយើងគោរពព្រះពុទ្ធ សាសនាបែបថេរវាទដូចពុទ្ធសាសនាដែលយើងគោរពនាពេលសព្វថ្ងៃនេះ ។

### ៦.២- សម័យនគរភ្នំ (ស.វ.ទី ១ ដល់ពាក់កណ្ដាលស.វ.ទី ៦)

នៅសម័យនគរភ្នំ ព្រះពុទ្ធសាសនាមានវិវឌ្ឍន៍ និង ការរីកចម្រើនយ៉ាងច្បាស់លាស់ តែព្រះពុទ្ធសាសនានៅក្នុងសម័យនោះ គឺព្រះពុទ្ធសាសនាហីនយាន និយមភាសាសំស្ក្រឹតដែលនាំចូលមក តាំងពីសតវត្សទី៣ ឬ ទី២ មុនគ.ស. ដោយភិក្ខុសោណត្ថេរ និង ឧត្តរត្ថេរ ។ រហូតដល់ពាក់កណ្ដាលសតវត្សទី៦ នៃការវាយលុករបស់ចេនឡាមកលើអាណាចក្រភ្នំ ពុទ្ធសាសនាហីនយាននេះនៅរុងរឿងនៅឡើយ ។ លុះចូលមកដល់សតវត្សទី៧ នៃសម័យចេនឡា ទើបចុះអានុភាពបន្តិច ម្ដងៗ។

ទន្ទឹមនឹងនេះ សាសនាព្រាហ្មណ៍ ដែលចូលមកក្នុងប្រទេសកម្ពុជាយើង នៅស.វ. ទី ១ នៃគ.ស. ក៏មានការរីកចម្រើនដែរ ។ សាសនានេះគឺ មកតាមរយៈព្រាហ្មណ៍



www.elibraryofcambodia.org

កៅណ្ឌិន្យ ។ តែក្រោយមក មានអធិរាជខ្លះមានព្រះបាទកៅណ្ឌិន្យជ័យវរ្ម័នជាដើមដែល ដើមឡើយព្រះអង្គគោរពសាសនាព្រះ ឥសូរនោះ ក៏ផ្លាស់មកកាន់ពុទ្ធសាសនាវិញ ។

ដូចច្នេះនៅសម័យនគរភ្នំ មានសាសនាច្រើនដែលត្រូវប្រជាពលរដ្ឋខ្មែរយើង គោរពបូជា គ្រាន់តែព្រះពុទ្ធសាសនារីកចម្រើនជាងគេប៉ុណ្ណោះ ។

## ៦.៣- សម័យចេនឡា (ពាក់កណ្ដាលស.វ.ទី ៦ ដល់ចុងស.វ. ទី៨)

នៅសម័យនេះ ព្រះពុទ្ធសាសនាហីនយានដែលបានរីកចម្រើនក្នុងសម័យនគរភ្នំ នោះបានចុះអានុភាពរបស់ខ្លួនបន្តិចម្ដងៗតែពុំសាបសូន្យភ្លាមទេ។ គេប្រទះឃើញ ព្រះពុទ្ធរូបនៅព្រៃកប្បាស ដែលបានកសាងឡើងនៅស.វ.ទី ៧ ព្រមទាំងមាន សិលា-ចារឹកជាច្រើនទៀត ។ លុះមកដល់ចុងស.វ. ទី៨ ព្រះពុទ្ធសាសនាមហាយាន ដែល និយមកាសាសំស្ក្រឹតបានចូលមកដល់ប្រទេសខ្មែរយើង រីកលូតលាស់មកដល់ ស.វ.ទី ១៣ នៃសម័យអង្គរ ។ គេបានរកឃើញសិលាចារឹកមួយផ្ទាំងទៀត ចុះកាល បរិច្ឆេទ ៧៩១ នៅប្រាសាទតាគៀមក្នុងខេត្តសៀមរាប ដែលអាចចាត់ទុកជាសក្ខីភាពមួយចាស់ ជាងគេនៃព្រះពុទ្ធសាសនាមហាយាននៅស្រុកខ្មែរយើង ព្រោះឯកសារនេះបាននិយាយ ពីការកសាងបដិមា ពោធិសត្វលោកិតេស្វរៈជាពោធិសត្វមួយព្រះអង្គ ដែលគេនិយម ជាងគេនៅស្រុកខ្មែរយើង។ ទោះបីជាពុទ្ធសាសនាមហាយាន ដែលជាសាសនាចំណូល ថ្មី មានការរីកចម្រើនក៏ដោយ ក៏គេនៅតែឃើញមន្ត្រី និងប្រជាពលរដ្ឋ ខ្មែរសម័យនោះ ខ្លះគោរពព្រះពុទ្ធសាសនាហីនយានដែរ ។

## ៦.៤- សម័យអង្គរ (គ.ស. ៨០៥-១៤៣១)

ក្នុងដំណាក់កាលដំបូងនៃសម័យអង្គរនេះ ព្រះពុទ្ធសាសនាហីនយានដែលចុះ អានុភាពតាំងពីចុងសតវត្សទី ៨ មកនោះ កាន់តែចុះអានុភាពខ្លាំងឡើងៗ តែពុំរលត់ រលាយបាត់ទាំងស្រុងឡើយ ។ ផ្ទុយទៅវិញ គេសង្កេតឃើញថា ព្រហ្មញ្ញសាសនា និង ពុទ្ធសាសនាមហាយានមានការរីកចម្រើន និងជះឥទ្ធិពលយ៉ាងខ្លាំងដល់ការកសាង ប្រទេសជាតិនាសម័យនោះ។ ប៉ុន្តែ ពេលខ្លះ សាសនាទាំងពីរមានទំនាស់នឹងគ្នាយ៉ាង


www.elibraryofcambodia.org

ខ្លាំងក្លា។

នៅស.វ. ទី១១ ព្រះពុទ្ធសាសនាមហាយានដែលនាំចូលតាំងពីសម័យចេនឡានាស.វ. ទី៨ ត្រូវបានព្រះបាទសូរ្យវរ្ម័នទី១ (១០០២-១០៥០) លើកតម្កើងជាសាសនាសម្រាប់រដ្ឋ។ តែក្រោយមក នៅស.វ.ទី១២ គណៈវិស្ណុនិយមត្រូវបានព្រះបាទសូរ្យវរ្ម័នទី ២ គោរពរាប់អានសម្បើមណាស់។ ក្រោមព្រះរាជឧបត្ថម្ភរបស់ព្រះបាទសូរ្យវរ្ម័នទី២ ប្រាសាទអង្គរវត្តដ៏ធំស្កឹមស្កៃបានកសាងឡើងដើម្បីតម្កល់ វិស្ណុបដិមាសម្រាប់ជាទីគោរពបូជា ។

បន្តមកទៀត ក្នុងរាជ្យក្រោយៗ ជាពិសេសក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ ព្រះពុទ្ធ-សាសនាត្រូវបានគោរពយ៉ាងមុតមាំវិញម្តង។ ព្រះអង្គទ្រង់បានចាត់តាំងឱ្យកសាងប្រាសាទបាយ័ន ដែលមានលក្ខណៈជាប្រាសាទភ្នំ សម្រាប់តម្កល់រូបតំណាងព្រះរាជាគឺពុទ្ធបដិមាជាភ័ស្តុតាង។ ពិធីទេវរាជដែល ព្រះរាជាមុនៗបានគោរពបូជាត្រូវជំនួសដោយពិធីពុទ្ធរាជ ។

ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ២ (៨០២-៨៥០) ដែលមានរាជធានីនៅភ្នំគូលែន ព្រះរាជាកាន់សាសនាព្រាហ្មណ៍ តែមាននាម៉ឺន និង ប្រជារាស្ត្រកាន់ព្រះពុទ្ធសាសនាមហាយានដែរ ។

ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៣ (គ.ស. ៨៥០-៨៧៧) ដែលមានរាជធានីនៅហរិហរាល័យ ក្នុងតំបន់រលួស ស្រុកសូត្រនិគម ខេត្តសៀមរាបសព្វថ្ងៃ ព្រះរាជាគោរពសាសនាព្រាហ្មណ៍ ឯនាម៉ឺន និង ប្រជារាស្ត្រកាន់ព្រះពុទ្ធសាសនា ។

ក្នុងរាជ្យព្រះបាទយសោវរ្ម័នទី ១ (គ.ស ៨៨៩-៩០០) ដែលមានរាជធានីនៅយសោធបុរៈ (អង្គរធំ) ពុទ្ធសាសនា និងសាសនាព្រាហ្មណ៍មានសិទ្ធិដូចគ្នា គឺ រាស្ត្រគោរពតាមការស្ម័គ្រចិត្តរបស់ខ្លួន។ ព្រះអង្គទ្រង់បានកសាងនៅលើច្រាំងខាងត្បូងនៃបារាយណ៍យសោធរតជាកន្លែងអាស្រមជាច្រើនសម្រាប់គណៈសាសនា ដូចជាព្រាហ្មណាស្រមសម្រាប់អ្នកកាន់សាសនាព្រះឥសូរ វៃស្ណវាស្រមសម្រាប់អ្នកកាន់សាសនាព្រះវិស្ណុ និង សៅគតាស្រម សម្រាប់អ្នកកាន់ពុទ្ធសាសនា ។



www.elibraryofcambodia.org

ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៤ (គ.ស. ៩២៨-៩៤១) ដែលមានរាជធានីនៅកោះកេរ ៧០ គ.ម. ទិសឦសានក្រុងអង្គរ ព្រះរាជាអង្គនេះកាន់សាសនាព្រាហ្មណ៍ឯនាម៉ឺន និង ប្រជារាស្ត្រភាគច្រើនកាន់និងគោរពព្រះពុទ្ធសាសនា ។

ក្នុងរាជ្យព្រះបាទរាជេន្ទ្រវរ្ម័នទី២ (គ.ស ៩៤៤-៩៦៧) ដែលមានរាជធានីនៅកោះកេរបានមួយឆ្នាំ រួចរើមកនៅអង្គរធំវិញ ព្រះរាជាអង្គនេះកាន់សាសនាព្រាហ្មណ៍តែទ្រង់បានប្រោសប្រទានចំពោះព្រះពុទ្ធសាសនាដែរ ។ ព្រះអង្គបានកសាងវត្តអារាមខាងព្រះពុទ្ធសាសនាកាន់តែប្រសើរឡើងមកជិតរាជធានី ។ ក្នុងរាជ្យព្រះមហាក្សត្រអង្គនេះ សេរីភាពខាងសាសនាបានបើកទូលំទូលាយណាស់។ ព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាមានការរាប់អានចូលគ្នាកាន់តែជិតស្និទ្ធថែមទៀត ។

ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៥ (គ.ស ៩៦៧-១០០១) ដែលមានរាជធានីនៅអង្គរធំ ព្រះរាជាអង្គនេះជាអ្នកកាន់សាសនាព្រះពុទ្ធដ៏មុតមាំ ដែលធ្វើឲ្យអ្នកដែលពុំធ្លាប់តែមានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ក៏ត្រឡប់ជាមានសទ្ធាជ្រះថ្លាតាមព្រះអង្គ។ ព្រះអង្គបានសាងពុទ្ធរូបមួយអង្គធំ នៅជិតប្រាសាទបាយ័ន គឺ ព្រះពុទ្ធរូបគោកធ្លក ។

ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ (គ.ស ១០០២-១០៥០) ដែលមានរាជធានីនៅអង្គរធំ ព្រះអង្គជាអ្នកកាន់ព្រះពុទ្ធសាសនាលទ្ធិមហាយាន តែព្រះអង្គគោរពព្រះពុទ្ធ-សាសនាថេរវាទ និង សាសនាព្រាហ្មណ៍ដែរ ដោយមិនឲ្យសាសនាទាំងនេះមានការថ្នាំងថ្នាក់គ្នាឡើយ ។

ក្នុងរជ្ជកាលព្រះបាទហស៌វរ្ម័ន (គ.ស ១០៦៦-១០៨០) ដែលមានរាជធានីនៅអង្គរធំ ព្រះរាជាអង្គនេះប្រកបដោយគតិបណ្ឌិត កាន់គ្រប់ព្រះរាជករណីយកិច្ចនៃសាសនា។ ព្រះអង្គគោរពកាន់គ្រប់សាសនាទាំងអស់ស្មើៗគ្នាតាមឋានៈព្រះអង្គជាព្រះមហាក្សត្រ ។

ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី ២ (គ.ស ១១១៣-១១៥០) ដែលមានរាជធានីនៅអង្គរធំ ព្រះរាជាអង្គនេះកាន់សាសនាព្រាហ្មណ៍ ឯនាម៉ឺននិងប្រជារាស្ត្រភាគច្រើនកាន់



www.elibraryofcambodia.org

ពុទ្ធសាសនា ។

**៦.៥- សម័យក្រោយអង្គរហូតដល់សព្វថ្ងៃ**

ចាប់ពីចំណាកចោលអង្គរ ១៤៣១ រហូតមកដល់សព្វថ្ងៃនេះ សង្គមកម្ពុជាមាននិន្នាការនយោបាយផ្សេងៗ ។

ពីចុងស.វ.ទី១៥ ដល់ ដើមស.វ.ទី១៧៖ សម័យលង្វែក

ពីដើមស.វទី១៧ ដល់ ១៨៦៣៖ សម័យឧត្តុង្គ

ពី១៨៦៣-១៩៥៣៖ សម័យអាណានិគមបារាំង

ពី១៩៥៣-១៩៧០៖ សម័យសង្គមរាស្ត្រនិយម

ពី១៩៧០-១៩៧៥៖ សម័យរបបសាធារណរដ្ឋខ្មែរ

ពី១៩៧៥-១៩៧៩៖ របបកម្ពុជាប្រជាធិបតេយ្យ

ពី១៩៧៩-១៩៩៣៖ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា និង រដ្ឋកម្ពុជា

ពី១៩៩៣ រហូតដល់របបរាជានិយមដែលប្រទេសយើងមានឈ្មោះថា «ព្រះរាជាណាចក្រ»។

- **នៅសម័យលង្វែកក៏ដូចជាសម័យឧត្តុង្គ** ព្រះពុទ្ធសាសនានិកាយហីនយានបានរីកចម្រើនយ៉ាងខ្លាំងក្លា ព្រមទាំងមានតួនាទីសំខាន់ក្នុងសង្គមខ្មែរយើង ។ ជាពិសេសនៅសម័យឧត្តុង្គ ព្រះពុទ្ធសាសនានិកាយហីនយានត្រូវបានលើកតម្កើង ដោយសារព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គជា ពុទ្ធសាសនូបត្ថម្ភក៏យ៉ាងជ្រាលជ្រៅជាទីបំផុត។ ព្រះហរិក្សរាមាឥស្សរាធិបតីព្រះអង្គឌួង (១៩៤០-១៨៥៩) ព្រះអង្គជាអ្នកធ្លាប់សិក្សារៀនសូត្រក្នុងសំណាក់ព្រះពុទ្ធសាសនា ព្រះអង្គសព្វព្រះហឫទ័យ ឲ្យភិក្ខុសាមណេរ ឧបាសក ឧបាសិកា យុវជនទៅសិក្សាវិជ្ជាគ្រប់បែបយ៉ាង មានអក្សរសាស្ត្រខ្មែរ កាព្យសាស្ត្រ និង ទស្សនវិជ្ជាពុទ្ធសាសនា ជាដើម។ នៅសម័យឧត្តុង្គ គ្រាន់តែឧត្តុង្គមួយមានវត្តរហូតដល់ទៅ ៥០០វត្ត ។



www.elibraryofcambodia.org

**- នៅសម័យអាណានិគមនិយមបារាំង** (១៨៦៣-១៩៥៣) ថ្វីបើពួកបារាំងមានបំណងលុបបំបាត់ចោលវប្បធម៌ អក្សរសាស្ត្រខ្មែរក៏ដោយ ក៏ព្រះពុទ្ធសាសនានិកាយហីនយាននៅតែរីកចម្រើន ព្រមទាំងមានតួនាទីរឹតតែខ្លាំងក្លាឡើងនៅក្នុងសង្គមខ្មែរ ។ ព្រះមហាក្សត្រខ្មែរ មានជាអាទិ៍ ព្រះបាទនរោត្តម ព្រះបាទស៊ីសុវត្ថិ ព្រះបាទស៊ីសុវត្ថិមុនីវង្ស សុទ្ធតែជាអ្នកគោរពព្រះពុទ្ធសាសនាយ៉ាងមុតមាំ ។ ក្នុងរជ្ជកាលព្រះបាទនរោត្តម (១៨៥៩-១៩០៤) ព្រះអង្គទ្រង់បានកសាងព្រះវិហារព្រះកែវមរតកនៅខាងត្បូងជាប់ព្រះបរមរាជវាំង ដើម្បីជាទីសក្ការៈបូជា និងឧទ្ទិសចំពោះព្រះពុទ្ធសាសនាហីនយាន។ ប៉ុន្តែ ក្នុងរជ្ជកាលរបស់ព្រះអង្គនេះ គេសង្កេតឃើញមានការចូលមកដល់នូវពុទ្ធសាសនានិកាយហីនយានមួយប្រភេទទៀត គឺពុទ្ធសាសនាហីនយានគណៈធម្មយុត្តិកនិកាយក្នុងប្រមាណឆ្នាំ ១៨៥៤។ ដូច្នេះ ចាប់ពីពេលនោះមកព្រះពុទ្ធសាសនាហីនយាននៅប្រទេសកម្ពុជាយើងមានពីរនិកាយគឺ មហានិកាយ និងធម្មយុត្តិកនិកាយ។ និកាយទាំងពីរនេះពុំមានទំនាស់រវាងគ្នានឹងគ្នាឡើយ។ ផ្ទុយទៅវិញនិកាយទាំងពីរនេះក្លាយទៅជាកម្លាំងមួយដ៏សំខាន់ ជះឥទ្ធិពលដល់ប្រជាពលរដ្ឋខ្មែរយើងឲ្យមានកម្លាំងសាមគ្គីភាព ឯកភាពជាតិ និង ការកសាងទឹកដីក្នុងរាជ្យនៃព្រះមហាក្សត្រក្រោយៗទៀត ព្រោះប្រជាពលរដ្ឋម្នាក់ៗមានសិទ្ធិសេរីភាពក្នុងជំនឿរបស់ខ្លួនដោយពុំមានការបង្ខិតបង្ខំ និងការប្រកាន់បក្សពួកឡើយ ។ ចូលមកដល់រាជ្យព្រះបាទស៊ីសុវត្ថិ(១៩០៤-១៩២៧) ព្រះរាជាជាពុទ្ធសាសនិកដ៏ឆ្នើម ហើយបានកសាងរាជបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ និង សាលាបាលីជាន់ខ្ពស់ ។ មកដល់រជ្ជកាលព្រះបាទស៊ីសុវត្ថិមុនីវង្ស(១៩២៧-១៩៤១) ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ចំពោះព្រះសង្ឃឱ្យមានសណ្ដាប់ធ្នាប់ត្រឹមត្រូវទៅតាមព្រះត្រៃបិដក ។ ព្រះអង្គជាពុទ្ធសាសនូបត្ថម្ភកៈនៃឧត្តមសង្ឃ័តិ បង្កើតឱ្យមានក្រុមជំនុំផ្ទៀងផ្ទាត់ព្រះត្រៃបិដកហើយប្រែពីភាសា បាលី មកភាសាជាតិ រយៈពេល១០ឆ្នាំ ពីឆ្នាំ ១៩២៩-១៩៣៩ រួចបោះពុម្ពសៀវភៅបន្តៗ តាំងពីពេលនោះរហូតដល់ឆ្នាំ១៩៦៩ ទើបចប់សព្វគ្រប់ដែលមានសៀវភៅខ្នាតធំៗចំនួន ១១០ ក្បាល ។



www.elibraryofcambodia.org

**សម័យសង្គមរាស្ត្រនិយម៖** នៅក្នុងរជ្ជកាលព្រះបាទនរោត្តមសីហនុ ព្រះពុទ្ធសាសនាមានការរីកចម្រើន ដោយសារ នៅសម័យនោះ ព្រះអង្គបានចែងក្នុងរដ្ឋធម្មនុញ្ញថា «ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ» ។ តាមស្ថិតិឆ្នាំ១៩៦១ ក្នុងប្រទេសកម្ពុជាមានវត្តអារាមចំនួន២៥៨០ ។ ចំណែកព្រះសង្ឃដែលអាស្រ័យនៅក្នុងវត្តទាំងនេះមានចំនួន ៥៣៥០៩ អង្គ ។ តែបើគិតនៅឆ្នាំ១៩៦៩ វត្ត អារាមមានចំនួន ៣៣៦៩ គឺ វត្តគណៈមហានិកាយមាន ៣២៣០ និងគណៈធម្មយុត្តិកនិកាយមាន ១៣៩ ។ ចំណែកព្រះសង្ឃវិញ មានព្រះសង្ឃចំនួន ៦៥០៦ អង្គ ក្នុងនោះខាងមហានិកាយ មាន ៦២៦៧៨ អង្គ និង ខាងធម្មយុត្តិកនិកាយមាន ២៣៨៤ អង្គ។

**សម័យសាធារណរដ្ឋ៖** នៅសម័យនេះ ព្រះពុទ្ធសាសនាដែលពីមុនមក មិនសាបសូន្យទេ តែក៏មិនរីកចម្រើនដែរ ។ វត្តអារាមត្រូវបានកងទ័ព លន់ ណុល ចូលបោះទីតាំងជាច្រើនកន្លែង ។ គម្ពីរទាំងឡាយរបស់សាសនាត្រូវបានបំផ្លិចបំផ្លាញ ព្រះសង្ឃត្រូវបានគេគំរាមកំហែង ។

**របបកម្ពុជាប្រជាធិបតេយ្យ៖** ព្រះពុទ្ធសាសនាត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង ។ ទីវត្តអារាម ត្រូវបានប្រើជាទីកន្លែងសម្រាប់ដាក់អាវុធ សម្ភារៈ ឬ ជាទីកន្លែងចិញ្ចឹមជ្រូក ជាដើម ។ ព្រះសង្ឃជា ច្រើនអង្គត្រូវពួក ប៉ុល ពត ធ្វើគតដោយគ្មានកំហុស គម្ពីរសាសនាត្រូវដុតបំផ្លាញ និង ទុកចោលដោយគ្មានការថែរក្សាត្រឹមត្រូវ ។

**ព្រះពុទ្ធសាសនានាពេលបច្ចុប្បន្ន៖** ព្រះពុទ្ធសាសនាត្រូវបានដាក់ជាសាសនារបស់រដ្ឋ ដោយយកលទ្ធិព្រះពុទ្ធសាសនាបែបហីនយាន ។ ប្រជាពលរដ្ឋដែលជាពុទ្ធសាសនិកមានចិត្តជ្រះថ្លា ជួយកសាង និង លើកតម្កើងព្រះពុទ្ធសាសនាតាមលទ្ធភាព ដូចជាការកសាងព្រះវិហារ ពុទ្ធប្បដិមាតូច ធំ និង ជួយទំនុកបម្រុងរាល់ ការខ្វះខាតរបស់ព្រះសង្ឃ។



www.elibraryofcambodia.org

# ជំពូកទីបី

# សិល្បៈ

## ១

## សិល្បៈស្ថាបត្យកម្មខ្មែរបុរាណសម័យមុនអង្គរ និង អង្គរ

### ១- និយមន័យ

**ស្ថាបត្យកម្ម** ឬ **និម្មាបនកម្ម** (Architecture) សំដៅយកសិល្បៈ និង វិជ្ជានៃការកសាងប្រកបដោយភាពប៉ិនប្រសប់ ឬការតុបតែងលម្អនូវវត្ថុផ្សេងៗឲ្យបានល្អឆើតឆាយទៅតាមបច្ចេកទេស។ ក្រៅពីនេះនៅមានន័យសំដៅទៅដល់អគារ ឬ សំណង់ផ្សេងៗដែលស្ថាបនិកបានកសាងឡើង។ ស្ថាបត្យកម្មក្នុងទីនេះសំដៅយកសំណង់ប្រាសាទនានារបស់ខ្មែរដែលបានកសាងឡើងតាំងពីសម័យ បុរាណ។

**សិល្បៈ** (Arts) សំដៅយកការងារផ្សេងៗ ជំនាញហត្ថកម្មនិងបញ្ញាពលកម្មគ្រប់បែបយ៉ាង ដែលមានសិល្ប៍ ពោលគឺធ្វើឲ្យមនុស្សចាប់ចិត្ត ចាប់អារម្មណ៍ ចង់មើល ចង់ឃើញ ចង់ស្តាប់។ សិល្បៈមានច្រើនប្រភេទណាស់ដូចជា សិល្បៈរបាំ ចម្រៀង ភ្លេង ល្ខោន គំនូរ សំណង់ សូនរូប។ល។

**រចនាបថ** (Style) សំដៅយកលក្ខណៈពិសេសនៃការសម្តែងចេញក្នុងកិច្ចការសិល្បៈ មានទាំងរបៀបនៃការរចនាប្រចាំសម័យកាលនីមួយៗ និងរបៀបនៃការរចនាទៅតាមក្រុម តាមបុគ្គល។

### ២- វិវឌ្ឍន៍នៃសិល្បៈស្ថាបត្យកម្មខ្មែរ

ប្រាសាទទាំងឡាយ ដែលជាសំណង់ស្ថាបត្យកម្មរបស់ខ្មែរបានចាប់ផ្តើមកសាងឡើងតាំងពីសម័យមុនអង្គរ រហូតមកដល់សម័យអង្គរ។ ស្នាដៃសិល្បៈស្ថាបត្យកម្មទាំងអស់បានរីកចម្រើន ផ្លាស់ប្តូរទៅតាមសម័យកាលនីមួយៗ ពិសេសទៅតាមព្រះរាជ-បញ្ញាញាណរបស់ព្រះមហាក្សត្រមួយអង្គៗ ដែលបានចេញព្រះរាជបញ្ជាឲ្យកសាង។ ចំណុចសម្គាល់សំខាន់ដែលធ្វើឲ្យគេមើលឃើញពីវិវឌ្ឍន៍ គឺស្ថិតនៅត្រង់មូលដ្ឋាន


www.elibraryofcambodia.org

សម្ភារៈសំណង់ រចនាបថនៃសិល្បៈស្ថាបត្យកម្ម និងក្បូរក្បាច់ រចនានៃសិល្បៈចម្លាក់។

ការសិក្សាកំណត់អំពីការបែងចែកវិវឌ្ឍន៍នៃសិល្បៈស្ថាបត្យកម្មខ្មែរ ដូចដែលគេធ្លាប់បានកំណត់កន្លងមក បានពឹងផ្អែកលើឯកសារមូលដ្ឋានសំខាន់ពីរបែប គឺ ទីមួយ ឯកសារ«សិលាចារឹក» ដែលបានចារឹកទុកនូវព័ត៌មាន និងចុះកាលបរិច្ឆេទនៃព្រឹត្តិការណ៍ដែលបានកើតឡើងទាក់ទងនឹងពេលវេលានៃការកសាងស្ថាបត្យកម្មនានា និង ទីពីរ ឯកសារ «ប្រវត្តិសិល្បៈខ្មែរ» របស់អ្នកនិពន្ធជនជាតិ បារាំងពីររូបគឺ លោក **ហ្វីលីប ស្ទែន** (Philipp Stern 1665) និងលោកស្រី **ហ្ស៊ីលប៊ឺត ដឺកូរ៉ាល់រ៉េមុស្សាត** (Gilberte de Coral Remusat 1951: 32-74) ដែលបានសិក្សាអំពីសិល្បៈខ្មែរយ៉ាងល្អិតល្អន់។ ឯកសារទាំងពីរបានកំណត់និងបែងចែកវិវឌ្ឍន៍នៃសិល្បៈស្ថាបត្យកម្មខ្មែរចេញជាពីរសម័យកាល និង ១៣ រចនាបថ ដូចតទៅ៖

### ២.១- សិល្បៈស្ថាបត្យកម្មខ្មែរសម័យមុនអង្គរ (សតវត្សទី១ ដល់សតវត្សទី៨)

សិល្បៈស្ថាបត្យកម្មក្នុងតំណាក់កាលនេះចាប់រាប់ពីសម័យហ្វូណន រហូតដល់សម័យចេនឡា មុនការកសាងរាជធានីអង្គរ។ អ្នកសិក្សាខ្លះបានហៅសិល្បៈក្នុងតំណាក់កាលនេះថា សិល្បៈបុរេអង្គរ។ សិល្បៈស្ថាបត្យកម្មខ្មែរសម័យមុនអង្គរចែកចេញជា ៤ រចនាបថ៖

#### ២.១.១- រចនាបថភ្នំដា (សតវត្សទី១ដល់សតវត្សទី៦)

នៅខាងដើមនៃរចនាបថភ្នំដា ចាប់ពីសតវត្សទី ១ មក គេពិបាកក្នុងការស្វែងរកព័ត៌មានទាក់ទងនឹងសិល្បៈស្ថាបត្យកម្មខ្លាំងណាស់ សូម្បីតែសិលាចារឹក ដែលជាប្រភពឯកសារកំណត់ត្រាដ៏សំខាន់ ក៏ពុំមានកត់ត្រាអ្វីទាំងអស់។ គេអាចដឹងព័ត៌មានទាំងអស់នេះបាន តាមរយៈប្រភពឯកសារចិនតែប៉ុណ្ណោះ។ នៅសម័យហ្វូណន ប្រទេសខ្មែរមានទំនាក់ទំនង និងទទួលឥទ្ធិពលពីឥណ្ឌាយ៉ាងច្រើន ទាំងខាងវិស័យសាសនា និងស្ថាបត្យកម្ម។ សំណង់ប្រាសាទ បដិមា ក្បូរក្បាច់ចម្លាក់ ដែលស្ថិតនៅក្នុងរចនាបថនេះមានចំនួនតិចតួចប៉ុណ្ណោះ។


www.elibraryofcambodia.org

លទ្ធផលនៃកំណាយបុរាណវិទ្យា ដែលបានធ្វើឡើងនៅ អូកែវ(កម្ពុជាក្រោម) បាភ្នំ(ព្រៃវែង) និង អង្គរបុរី(តាកែវ) បានបង្ហាញឲ្យឃើញថា សិល្បៈស្ថិតនៅក្នុងសម័យហ៊្វូណនត្រូវបានគេចាត់ បញ្ចូលទៅក្នុងរចនាបថភ្នំដាដោយយកឈ្មោះទីតាំងប្រាសាទភ្នំដាធ្វើជាមូលដ្ឋាននៃឈ្មោះរចនាបថ។

នៅអូកែវ បុរាណវិទូជនជាតិបារាំងឈ្មោះ **ល្វីម៉ាល់ឡឺរ៉េ** (Loui Malleret) បានធ្វើកំណាយបុរាណវិទ្យាក្នុងឆ្នាំ១៩៤២ និងបានរកឃើញបុរាណវត្ថុជាច្រើន មានឧបករណ៍ប្រើប្រាស់ គ្រឿងអលង្ការ បដិមា គ្រឹះប្រាសាទជាដើម។

នៅបាភ្នំ ខេត្តព្រៃវែង ដែលជាអតីតរាជធានីពីបុរាណមានឈ្មោះថា«វ្យាធបុរៈ» គេបានរកឃើញសំណល់ជាកំពែងទីក្រុង គូទឹក ទួល ថ្មនិងឥដ្ឋរបស់ប្រាសាទ បដិមា កុលាលភាជន៍ អង្កាំ និង គ្រឿងអលង្ការជាដើម។

ចំណែកនៅអង្គរបុរីវិញ លទ្ធផលកំណាយបានបង្ហាញឲ្យឃើញថាមានស្លាកស្នាមទីក្រុងបុរាណ ដែលមានកំពែងព័ទ្ធជុំវិញគ្រឹះប្រាសាទ បដិមា អង្កាំ គ្រឿងអលង្ការ កុលាលភាជន៍ សិលាចារឹកជាដើម។ ចំពោះសំណង់ប្រាសាទវិញ គេឃើញមានប្រាសាទពីរបែបដែលបានបន្សល់ទុករហូតមកដល់សព្វថ្ងៃ ហើយវាតំណាងឲ្យរចនាបថភ្នំដា គឺប្រាសាទចោះភ្នំ និងប្រាសាទអាស្រមមហាឫសី។

ប្រាសាទចោះភ្នំមានទីតាំងនៅលើភ្នំដា ដែលជាកូនភ្នំតូចមួយ(រូបទី១)។ នៅតាមចង្កេះភ្នំ គេសង្កេតឃើញមានចោះលុងភ្នំជារូងធ្វើប្រាសាទដោយមានការរៀបចំតុបតែងលម្អជាកំពែង ភ្លោងទ្វារ តាមមាត់រូងប្រាសាទ និងមានដាក់តម្កល់បដិមាខាងលទ្ធិព្រហ្មញ្ញសាសនា សម្រាប់គោរពបូជាទៀតផង។ បដិមាទាំងនេះ សព្វថ្ងៃ គេបានប្រមូលយកមករក្សាទុកនៅសារមន្ទីរជាតិទីក្រុងភ្នំពេញ។ គេពុំឃើញ មានផ្តែរសសរពេជ្រ និងក្បូរក្បាច់ចម្លាក់អ្វីគួរឲ្យកត់សម្គាល់ទេ។ របៀបនៃការចោះភ្នំធ្វើប្រាសាទបែបនេះមានលក្ខណៈដូចគ្នាទៅនឹងប្រាសាទនៅប្រទេសឥណ្ឌា។

ប្រាសាទអាស្រមមហាឫសីសង់នៅលើភ្នំមួយជាប់នឹងភ្នំដា មានចម្ងាយប្រមាណជា ៣០០ ម៉ែត្រ នៅប៉ែកនិរតីនៃប្រាសាទភ្នំដា(រូបទី២)។ ប្រាសាទនេះបន្សល់ទុក



www.elibraryofcambodia.org

ទ្រង់ទ្រាយល្អបរិបូរ អាចឲ្យគេសិក្សាវិភាគបាន។ តាមលក្ខណៈស្ថាបត្យកម្ម ប្រាសាទអាស្រមមហាឫសីសាងសង់នៅលើភ្នំមានប្លង់ជាការ៉េ ។ ថ្មដែលយកមកសាងសង់ប្រាសាទជាប្រភេទថ្មរឹងមួយប្រភេទហៅថា «ថ្មបាសាល់»។ ប្រភេទថ្មនេះ គេឃើញមានច្រើននៅខេត្តកំពង់ចាម។ ប្រាសាទអាស្រមមហាឫសីមានទ្វារចូលតែមួយគត់ គ្មានទ្វារបញ្ឆោតទេ។ នៅអមសងខាងទ្វារចូល មានសសរពេជ្ររាងមូលលម្អដោយក្បាច់រំយោល និងក្បាច់ពងត្រី។ ពីខាងលើទ្វារចូល មានផ្តែរតូចមួយទ្រដោយសសរពេជ្រលម្អដោយក្បាច់រំយោលប្រទាក់គ្នាដូចជាទឹករលក។ ហោជាងគ្មានក្បាច់ចម្លាក់អ្វីទេ វាមានប្រហោងរាងបួនជ្រុងតូចមួយដូចជាប្រហោងខ្យល់នៅចំកណ្តាល។ តាមជញ្ជាំងពីខាងមុខនិងពីចំហៀងទាំងសងខាង មានបង្អួចចំហដែលតុបតែងលម្អដោយក្របពីខាងក្រៅ តែគ្មានចម្រឹងទេ។ ខាងក្នុងប្រាសាទ មានបន្ទប់នៅចំកណ្តាល ហើយមានផ្លាព័ទ្ធជុំវិញខាងក្រៅបន្ទប់ ។ ជារួម ប្រាសាទអាស្រមមហាឫសី គ្មានក្បូរក្បាច់ចម្លាក់អ្វីនៅតាមជញ្ជាំងទេ ប៉ុន្តែប្រការដែលគួរឲ្យចាប់អារម្មណ៍គឺប្រាសាទនេះ មានរូបរាងដូចគ្នាទៅនឹងប្រាសាទនៅប្រទេសឥណ្ឌាខ្លាំងណាស់។

ចំពោះរូបបដិមាក្នុងរចនាបថភ្នំដា គេឃើញមានទាំងបដិមាខាងលទ្ធិព្រហ្មញ្ញ-សាសនា និង ព្រះពុទ្ធសាសនា។ បដិមាទាំងនោះសាងឡើងពីថ្ម លោហៈ និងឈើ ។ ជាទូទៅ លក្ខណៈបដិមាក្នុងរចនាបថភ្នំដាមានរាងកាច់ចង្កេះ មានស្លៀកសំពត់ ឯរូបខ្លះឈរត្រង់ ។ លក្ខណៈបែបនេះបានចម្លងតាមគំរូសិល្បៈ ឬ ទទួលឥទ្ធិពលពីសិល្បៈឥណ្ឌា។ ក្នុងរចនាបថភ្នំដា សិល្បករមានបច្ចេកទេសទប់លំនឹងបដិមាទោល ដោយប្រើជន្ទល់។ ដូចជាធ្លាក់ជន្ទល់មានរាងកោងដូចដែកក្រចកសេះនៅជាប់នឹងដងខ្លួនបដិមាពីខាងក្រោយខ្នង ធ្លាក់ជាយសំពត់ឲ្យធ្លាក់ដល់ក្រោមដើម្បីទប់លំនឹង ធ្លាក់ដំបងដែលកាន់ក្នុងដៃទាំងពីរពីខាងមុខឲ្យជំសម្រាប់ទ្រដងខ្លួន។ អ្នកសិក្សាអំពីប្រវត្តិសិល្បៈខ្មែរបានបែងចែកបដិមាក្នុងរចនាបថភ្នំដាជាពីរក្រុមគឺ រចនាបថភ្នំដា«A» និងរចនាបថភ្នំដា«B»។ រចនាបថទាំងពីរនេះ មានលក្ខណៈខុសប្លែកពីគ្នាបន្តិចបន្តួចប៉ុណ្ណោះ។



www.elibraryofcambodia.org

បដិមាក្នុងរចនាបថភ្នំដា«A» បានសាងឡើងក្នុងរវាងឆ្នាំ ៥១៤ រហូតដល់ឆ្នាំ ៥៣៩ នៃគ្រិស្តសករាជ ស្ថិតក្នុងរជ្ជកាលរបស់ព្រះបាទរុទ្រវរ្ម័ន។ បដិមាដែលស្ថិតនៅក្នុងរចនាបថនេះមាន ព្រះគ្រឹស្នៈទ្រភ្នំគោវធ៌ន (រូបទី៣) មានប្រភពពីវត្តកោះ ព្រះវិស្ណុដៃប្រាំបី(រូបទី៤) ព្រះពលរាម(រូបទី៥) ព្រះបរសុរាម (រូបទី៦) មានប្រភពពីភ្នំដា ព្រះពុទ្ធរូប(រូបទី៧) មានប្រភពពីវត្តរំលេក និងព្រះពុទ្ធ អវលោកិតេស្វរសំរិទ្ធ(រូបទី៨) មានប្រភពពីវត្តកំពង់លួង។ សព្វថ្ងៃ នេះបដិមាទាំងអស់បានយកមក រក្សាទុក ដាក់តាំងបង្ហាញនៅសារមន្ទីរជាតិទីក្រុងភ្នំពេញ។ បដិមាក្នុងរចនាបថភ្នំដា «A» សាងឡើងពីថ្មភក់ មានរបៀបតុបតែងលម្អប្រហាក់ប្រហែលគ្នា(រូបទី៩) វង្វង់មុខរាងមូលទ្រវែង ភ្នែកក្រឡោត ត្របកភ្នែករាងកោងស្រួច ចង្ការាងខ្លី ស្លឹកត្រចៀកវែង សក់រួញរមួលដូចគូទខ្យង ពាក់មកុដរាងបំពង់ (ចំពោះតែបដិមាព្រះវិស្ណុប៉ុណ្ណោះ) ចង្កេះរាងរៀវ ស្មាបើកធំ ស្លៀកសំពត់ខ្លី ខ្លះជាសំពត់ចងក្បិន សារបាប់ (ឬចរបាប់) ចាប់ក្លីចេញពីប្រភពតែមួយ ក្បាលក្លីរបស់សំពត់មូលញាត់ចូលក្នុងខ្សែក្រវាត់ តូចឆ្មារ មានក្បាលរាងកំប៉ោងបន្តិច ពីខាងមុខ មានជាយផ្នត់ធ្លាក់សំយ៉ុងចុះ ។ បដិមាខ្លះទៀតស្លៀក សំពត់លាតគ្មានចាប់ក្លី ឯពុទ្ធប្បដិមាវិញ គ្រងចីវរលាតស្តើង ធម្មតាមិនមានពាក់មកុដ មិនមានប្រើចន្ទល់ទប់ដងខ្លួនបដិមាទេ ។

បដិមាក្នុងរចនាបថភ្នំដា «B» បានកសាងឡើងក្នុងរវាងឆ្នាំ៥៤០ រហូតដល់ឆ្នាំ ៦០០ នៃគ្រិស្តសករាជ ស្ថិតក្នុងរជ្ជកាលរបស់ព្រះបាទភវវរ្ម័នទី១។ បដិមាសំខាន់ៗដែលបានរកឃើញ មានព្រះវិស្ណុដែលមានប្រភពពីកំពង់ចាមដាក់តាំងនៅសារមន្ទីរជាតិទីក្រុងភ្នំពេញ ព្រះហរិហរៈ (រូបទី១០) ដែលមានប្រភព ពីអាស្រមមហាឫសី ដាក់តាំងនៅសារមន្ទីរហ្គីមេនៃប្រទេសបារាំង។ បដិមាក្នុងរចនាបថភ្នំដា «B» កសាងឡើងពីថ្មភក់ មានរបៀបតុបតែងលម្អប្រហាក់ប្រហែលគ្នានឹងរចនាបថភ្នំដា «A» ដែរ តែច្រើនតែមានមាឌធំ រាងមាំ ទឹកមុខញញឹម ច្រមុះរាងកោង វង្វង់មុខមូលទូលាយ ចង្កាខ្លី ភ្នែកបើកធំក្រឡោត ត្របកភ្នែកកោង ត្រចៀកវែង ពាក់មកុដរាងបំពង់ សក់រួញរមួលដូចគូទខ្យង តែរាងធំបន្តិច។ ចន្ទល់ដែលប្រើសម្រាប់ទប់បដិមា រាងដូចដែកក្រចកសេះនៅខាង



www.elibraryofcambodia.org

ក្រោយខ្នង ជាប់នឹងដងខ្លួន តាំងពីព្រះកេសរហូតមកដល់ខាងក្រោម ឥឡូវត្រូវរុញនៅសល់ ចាប់ពីត្រឹមព្រះកេស មកដល់ត្រឹម ព្រះហស្តខាងលើប៉ុណ្ណោះ។

សរុបមក រាល់ប្រាសាទនិងបដិមា ដែលស្ថិតនៅក្នុងរចនាបថភ្នំដា សុទ្ធតែបានទទួលឥទ្ធិពលពីចរន្តវប្បធម៌នៃសិល្បៈឥណ្ឌា។ សិល្បករមានភាពប៉ិនប្រសប់ក្នុងការកែច្នៃ និងបញ្ចេញរូបរាង រចនាបថបានច្រើនបែបច្រើនយ៉ាង ក្នុងការកសាងប្រាសាទ និងបដិមា ដើម្បីបម្រើឲ្យវិស័យសាសនា និងការគោរពបូជា។

### ២.១.២- រចនាបថសម្បូណ៌ (គ.ស.៦១៥ ដល់ គ.ស.៦៥០ ពាក់កណ្ដាលទី១ នៃសតវត្ស ទី៧)

រចនាបថសម្បូណ៌ ចាប់ផ្ដើមកសាងឡើងក្នុងរវាងឆ្នាំ៦១៦ រហូតដល់ឆ្នាំ ៦៣៥ នៃគ្រិស្តសករាជ ស្ថិតក្នុងរជ្ជកាលរបស់ព្រះបាទឥសានវរ្ម័នទី១។ អ្នកស្រាវជ្រាវពីប្រវត្តិសិល្បៈខ្មែរ បានរាប់បញ្ចូលប្រាសាទនានាដែលស្ថិតនៅក្នុងរចនាបថសម្បូណ៌ ដែលមានដូចជា៖

- ប្រាសាទសម្បូណ៌ព្រៃគុហ៍ (ខេត្តកំពង់ធំ)
- ប្រាសាទភ្នំហាន់ជ័យ (ខេត្តកំពង់ចាម)
- ប្រាសាទភ្នំបាយ៉ង់ តួប៉មកណ្ដាល (ខេត្តតាកែវ)
- ប្រាសាទភ្នំធំ (ខេត្តបាត់ដំបង)
- ប្រាសាទដំបងដែក (ខេត្ត?) ។

ក្រុមប្រាសាទនៅសម្បូណ៌ព្រៃគុហ៍ជាមូលដ្ឋានរចនាបថគំរូតំណាងឲ្យរចនាបថសម្បូណ៌ ។ ប្រាសាទទាំងនោះមាន ក្រុមប្រាសាទខាងជើង និង ក្រុមប្រាសាទខាងត្បូង លើកលែងតែប្រាសាទតោ(នៃក្រុមប្រាសាទកណ្ដាល)មួយចេញ ដែលបានសាងឡើងក្នុងសម័យអង្គរដោយជ័យវរ្ម័នទី២ ។ សម្បូណ៌ព្រៃគុហ៍ជាអតីតរាជធានីពីសម័យបុរាណដែលមានឈ្មោះថា «ឥសានបុរៈ»។ កាលសម័យនោះ វាជាមជ្ឈមណ្ឌលខាងលទ្ធិព្រហ្មញ្ញសាសនា។ ប្រាសាទនេះមានទីតាំងស្ថិតក្នុងភូមិ សម្បូណ៌ ឃុំសម្បូណ៌ ស្រុកប្រាសាទសម្បូណ៌ ខេត្តកំពង់ធំ មានចម្ងាយប្រមាណជា ៣០ គីឡូម៉ែត្រ ពីទីរួមខេត្ត។



www.elibraryofcambodia.org

តាមការស្រាវជ្រាវខាងសំណង់សិល្បៈស្ថាបត្យកម្ម និង បដិមាសាស្ត្រក្នុងរចនាបថសម្បូណ៌ គេបានកត់សម្គាល់ឃើញថា៖

- **ផ្នែកស្ថាបត្យកម្ម៖** ប្រាសាទច្រើនកសាងឡើងជាសំណង់ទោល ឬជាក្រុមមានកំពែងព័ទ្ធជុំវិញ ប្រាសាទខ្លះកសាងនៅលើដីរាបស្មើ ខ្លះនៅលើភ្នំ។ តួប្រាសាទច្រើនកសាងពីឥដ្ឋ ចំណែកផ្តែរ ស៊ុមទ្វារ សសរពេជ្រ បដិមា ជណ្តើរ និង ផ្នែកសំខាន់ៗផ្សេងទៀតកសាងពីថ្មភក់។ នៅតាមជញ្ជាំងប្រាសាទខ្លះមានចម្លាក់បង្អួចបញ្ឆោតលៀនមកក្រៅ លម្អដោយក្បូរក្បាច់រចនាច្រើនបែបយ៉ាង លាយឡំជាមួយនឹងរូបមនុស្ស រូបទេវៈនិងទេវិនី ជារបៀប ប្រាសាទអណ្តែតឬវិមានអណ្តែត(រូបទី១១) និង មានទ្វារបញ្ឆោត។ ការតុបតែងលម្អមួយបែបទៀត គេបូកបាយអកំបោរលាយស្ករត្នោតនៅលើតួប្រាសាទ កន្លែងខ្លះមានក្បូរក្បាច់ចាក់ពុម្ពដោយបាយអកំបោរបិទពីលើ។ ប្លង់ប្រាសាទជាទូទៅ រាងជាការ៉េ តែមួយចំនួនមានរាងជាចតុកោណកែង(រូបទី១២) និង អដ្ឋកោណ (រាង ៨ ជ្រុង មានតែនៅក្នុងក្រុម ប្រាសាទសម្បូណ៌ព្រៃគុហ៍ប៉ុណ្ណោះ (រូបទី១៣) ហើយច្រើនបែរមុខទៅទិសខាងកើត។
- **ផ្តែរ(lintel)** លក្ខណៈសម្គាល់ផ្តែរក្នុងរចនាបថសម្បូណ៌ ជាទូទៅ នៅត្រង់ផ្នែកកណ្តាល មានក្បាច់រាងកោងដូចដងធ្នូ ជាបន្ទះសំប៉ែត លម្អដោយក្បាច់ផ្កាច័ន និងក្បាច់ពងត្រី ។ លើដងធ្នូ មានក្បាច់វង្វង់ចំនួនបី លម្អដោយក្បាច់ផ្កាក្ញីនៅជុំវិញ ត្រង់កណ្តាលក្បាច់វង្វង់ មានឆ្លាក់ចម្លាក់លៀនជារូបមនុស្សជួនកាលជិះសេះ ជួនកាលជារូបទេវៈ។ នៅចុងសងខាងដងធ្នូ មានចម្លាក់រូបសត្វមករហាមាត់ពាំឬខ្ជាក់ដងធ្នូ បែរមុខទល់គ្នា។ នៅក្រោមដងធ្នូ មានការ-លម្អដោយក្បាច់រំយោល និងក្បាច់កម្រងផ្កា ហើយនៅចន្លោះក្បាច់នីមួយៗមានឆ្លាស់គ្នា រំលេចដោយក្បាច់សន្លឹកតូចៗបន្ថែមទៀត(រូបទី១៤)។ ផ្តែរខ្លះទៀតមានរូបមនុស្សនៅខាងក្រោមដងធ្នូ។ ផ្តែរបែបនេះហៅថាផ្តែររឿង។ ផ្តែរទាំងឡាយដែលស្ថិតនៅក្នុងរចនាបថសម្បូណ៌ ច្រើនមានការតុបតែងលម្អជា



www.elibraryofcambodia.org

របៀបជាងទង។

- **សសរពេជ្រ (Colonnette)** ជាទូទៅ រាងមូលដូចបំពង់មានទំហំតូចល្មម។ នៅលើតួសសរ ពុំមានក្បាច់លម្អច្រើនស្មុកស្មាញទេ ចំកណ្តាលសសរមានចង្កៀងវណ្ណធំមួយ ។ ត្រង់ក្បាលសសរ មានវណ្ណរាងដូចចិញ្ចៀន លម្អដោយក្បាច់ចម្លាក់។ ពីក្រោមក្បាលសសរ គេឃើញ មានក្បាច់រំយោល និងកម្រងផ្កា (រូបទី១៥)។
- **ហោជាង (Fronton)** មានរាងដូចដែកក្រចកសេះឬរាងដូចអក្សរអ៊ិយផ្កាប់។ លើផ្ទៃហោជាង គេឃើញមានក្បាច់លម្អជារូបកូនប្រាសាទអណ្តែតនៅចំកណ្តាល (រូបទី១៦)។
- **បដិមា (statue)** បដិមាទោលដែលគេបានរកឃើញមានចំនួនតិចតួចណាស់ មានដូចជា ព្រះហរិហរៈ(រូបទី១៧) ព្រះនាងទុគ៌ា(រូបទី១៨)មកពីសម្បូណ៌ព្រៃគុហ៍ ព្រះនាងលក្ស្មី (រូបទី១៩) មកពីកោះត្រៀង ខេត្តក្រចេះ។ សព្វថ្ងៃបដិមាទាំងនេះបានដាក់តាំងបង្ហាញនៅសារមន្ទីរជាតិទីក្រុងភ្នំពេញ។ បដិមាក្នុងរចនាបថសម្បូណ៌បានចម្លងតាមរចនាបថភ្នំដា។ គេសង្កេតឃើញថាទេវរូបភេទស្រីមានមានឧតូច ខ្លះរាងកាច់ចង្កេះ ត្រគាកសាយ ខ្លះទៀតឈរត្រង់ធម្មតា ហើយក្រងសក់បួងឡើងលើខ្ពស់រាងដូចមកុដ ស្លៀកសំពត់លាតធម្មតា មានផ្នត់នៅចំកណ្តាល ក្រវាត់ខ្សែក្រវាត់ដែលលម្អដោយក្បូរក្បាច់រចនានៅត្រង់ក្បាលខ្សែក្រវាត់ ឯទេវរូបភេទប្រុសមានរាងធំហើយមាំ ប្រើចន្ទល់ដើម្បីទប់បដិមាដូច រចនាបថភ្នំដាដែរ។

### ២.១.៣- រចនាបថព្រៃក្មេង (គ.ស.៦៣៥ ដល់គ.ស.៧០០ ពាក់កណ្តាលទី ២ នៃសតវត្សទី៧)

រចនាបថព្រៃក្មេងចាប់ផ្តើមកសាងឡើងក្នុងរវាងឆ្នាំ ៦៥៥ ដល់ឆ្នាំ៦៨១ នៃគ្រិស្តសករាជ ស្ថិតក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី១ មានរាជធានីនៅអង្គរបុរី ប្រាសាទសំខាន់ៗ ដែលរាប់បញ្ចូល ក្នុងរចនាបថព្រៃក្មេង មានដូចជា៖



www.elibraryofcambodia.org

- ប្រាសាទព្រៃក្មេង(ខេត្តសៀមរាប)
- ប្រាសាទស្វាយព្រាម ផ្នែកដែលបុរាណជាងគេ(ខេត្តសៀមរាប)
- ប្រាសាទភ្នំបាសិទ្ធ ផ្នែកទ្វារខាងកើត(ខេត្តកណ្តាល)
- ប្រាសាទព្រៃប្រាសាទ ផ្នែកតួប៉មខាងត្បូង(ខេត្តសៀមរាប)
- ប្រាសាទអណ្តែត(ខេត្តកំពង់ធំ) ។

- **ស្ថាបត្យកម្ម៖** ក្នុងដំណាក់កាលនេះ គេកសាងជារបៀបប្រាសាទទោល ធ្វើពីឥដ្ឋ មានលំនាំប្រហាក់ប្រហែលគ្នានឹងរចនាបថសម្បូណ៌ព្រៃគុហ៍ដែរ។ លើជញ្ជាំងនៅតែលម្អដោយ បង្អួចបញ្ឆោត ជារបៀបប្រាសាទអណ្តែតដដែល។
- **ផ្តែរ៖** ក្បាច់រចនាបថលម្អក្នុងផ្តែរមានការរីកចម្រើន ហើយកាន់តែសម្បូណ៌ដោយក្បាច់ភ្ញីទេស(ក្បាច់ស្លឹកឈើ)ពោលគឺក្បាច់វង្វង់ចំនួន៣ នៅលើដងធ្នូដែលលម្អ ដោយរូបមនុស្សបានផ្លាស់ប្តូរ ទៅជាក្បាច់ផ្កាឈូកបន្ទុំ ឯសត្វមករនៅចុងសងខាងដងធ្នូ ក៏ពុំឃើញមានទៀតដែរ ត្រូវជំនួសដោយក្បាច់សន្លឹក ឬ ក្បាច់ខ្យងហៀនទៅវិញ។ ចំណែកដងធ្នូវិញ វាមានរាងត្រង់ លម្អដោយក្បាច់ផ្កាច័ន និងក្បាច់ពងត្រីនៅជុំវិញ។ ពីក្រោមដងធ្នូ មានការលម្អដោយក្បាច់រំយោល និងក្បាច់កម្រងផ្កា ឯក្បាច់សន្លឹកបន្ទះធំៗស្ថិត នៅចន្លោះក្បាច់ទាំងពីរនេះ (រូបទី២១)។
- **សសរពេជ្រ** នៅតែមានរាងមូលដូចបំពង់ដដែល ហើយបានរចនា តុបតែងលម្អកាន់តែ វិសេសឡើងថែមទៀត (រូបទី២២)។
- **បដិមា៖** លក្ខណៈបដិមាបានយកលំនាំតាមរចនាបថសម្បូណ៌ មានទំហំតូចពុំសូវកាច់ចង្កេះដូចសម័យមុនទេ ពេលខ្លះមានជំហរត្រង់។ សម្លៀកបំពាក់ទេវរូបភេទប្រុសមានពីរបែប មួយបែបជាសំពត់សារបាប់រុំជុំវិញចង្កេះ ដែលទម្លាក់ជាយធ្លាក់សំយាកមកខាង មួយបែបទៀតស្លៀកសំពត់សារបាប់ដែលមានផ្នត់វែងធ្លាក់ចុះមកក្រោម ។ ឯទេវរូបភេទស្រីស្លៀកសំពត់សារបាប់ឡើងហួសចង្កេះ ទម្លាក់ផ្នត់សំពត់មកក្រៅ ចំពីខាងមុខ រាងដូចផ្លែត្រប់សណ្តាយ



www.elibraryofcambodia.org

ហើយរឹតដោយឈ្នួតឬខ្សែក្រវាត់ រាងសំប៉ែតលើចង្កេះសំពត់ (រូបទី២៣)។

ទេវរូបដែលធ្វើឲ្យគេចាប់អារម្មណ៍និងកោតសរសើរជាងគេនោះគឺ ទេវរូបហរិហរៈ មកពីប្រាសាទអណ្តែត ខេត្តកំពង់ធំ (រូបទី២៤)។ បដិមានេះបានឆ្លុះបញ្ចាំងឲ្យឃើញពីភាពប៉ិនប្រសប់ និង បច្ចេកទេសខ្ពស់របស់សិល្បករក្នុងការឆ្លាក់បដិមាឲ្យមានរាងរៅសមសួនល្អឥតខ្ចោះ។

## ២.១.៤- រចនាបថកំពង់ព្រះ (គ.ស.៧០៧ ដល់គ.ស. ៨០០ នៃសតវត្សទី៨)

ដំណាក់កាលនៃរចនាបថកំពង់ព្រះ ស្ថិតក្នុងសម័យចេនឡាដែលមានការបែកបាក់គ្នាជាពីរ។ ប្រាសាទដែលរាប់បញ្ចូលក្នុងរចនាបថកំពង់ព្រះមាន៖

- ប្រាសាទកំពង់ព្រះ(ខេត្តកំពង់ឆ្នាំង)
- ប្រាសាទអកយំ ផ្នែកដែលបុរាណជាងគេ(ខេត្តសៀមរាប)
- ប្រាសាទត្រពាំងផុង ផ្នែកដែលបុរាណជាងគេ(ខេត្តសៀមរាប)
- ប្រាសាទភ្នំបាសិទ្ធ ទ្វារខាងលិច(ខេត្តកណ្តាល)
- ប្រាសាទភូមិប្រាសាទ(ខេត្តកំពង់ធំ) ។

- **ស្ថាបត្យកម្ម៖** ប្រាសាទនេះមានលក្ខណៈជាសំណង់ទោល កសាងពីឥដ្ឋ បែរមុខទៅទិសខាងកើត លើដីរាបស្មើ លើកលែងតែប្រាសាទអកយំមួយប៉ុណ្ណោះដែលសង់នៅលើខឿនច្រើនជាន់។ ប្រាសាទគំរូដែលតំណាងឲ្យរចនាបថនេះគឺប្រាសាទកំពង់ព្រះ ដែលស្ថិតនៅក្នុងបរិវេណវត្តកំពង់ព្រះ ឃុំធ្នុកទ្រូ ស្រុកបរិបូរ ខេត្តកំពង់ឆ្នាំង (រូបទី២៥) ។
- **ផ្តែរ៖** នៅលើផ្តែរនៃរចនាបថកំពង់ព្រះ ដងធ្នូដែលគេឃើញនៅក្នុងរចនាបថព្រៃក្មេងបានបំបែកទៅជាមែកជាងនៃក្បាច់សន្លឹកភ្ញីទេសឬកម្រងស្លឹកឈើ ។ ចុងទាំងសងខាងដងធ្នូមានរាងកោងពត់-ង ឡើងទៅលើ។ ក្បាច់ផ្កាវល្លិយោល



www.elibraryofcambodia.org

និងក្បាច់កម្រងផ្កាក៏បានបំបែកទៅជាក្បាច់សន្លឹកបែបខ្យងហៀនដូចទម្លក់ (រូបទី២៦)។

- **សសរពេជ្រ** ភាគច្រើនមានរាងមូល ហើយតុបតែងលម្អដោយក្បាច់ត្របកផ្កា និង ក្បាច់សន្លឹកឈើលាតថែមទៀតផង។ នៅចុងរចនាបថនេះ គេឃើញមានសសរពេជ្ររាង ៨ ជ្រុង បានលេចឡើងខ្លះហើយ ដោយមានការតុបតែងលម្អផងដែរ។
- **បដិមា** ក្នុងរចនាបថនេះ មានខ្លះស្អាត ខ្លះមិនសូវស្អាត។ សិល្បករបានចាប់ផ្ដើមធ្វើឲ្យមានវិវឌ្ឍន៍មួយជំហានទៀត ដោយសាកល្បងបំបាត់ចោលនូវចន្ទល់ និងទម្របដិមាមួយចំនួន។ សម្លៀកបំពាក់បដិមាទេវរូបភេទប្រុសមានលក្ខណៈពីរបែប បែបទីមួយមានលក្ខណៈដូចគ្នានឹងរចនាបថព្រៃក្មេងពិសេស បដិមានៅប្រាសាទអណ្ដែត។ បែបទីពីរគ្មាន ផ្នត់ជារាងហោប៉ៅទេ គ្រាន់តែមានផ្នត់រាងជាកន្ទុយត្រីធ្លាក់ចុះសំយាកនៅលើភ្លៅខាងឆ្វេង។ ចំពោះទេវរូបភេទស្រីវិញ សំពត់មានលក្ខណៈដូចគ្នាទៅនឹងរចនាបថព្រៃក្មេងដដែល។

### ២.២- សិល្បៈស្ថាបត្យកម្មខ្មែរសម័យអង្គរ (សតវត្សទី ៩ ដល់ សតវត្សទី១៣)

អ្នកស្រាវជ្រាវពីប្រវត្តិសិល្បៈខ្មែរបានបែងចែកស្ថាបត្យកម្មនិងបដិមាកម្ម ក្នុងសម័យនេះជា ៩ រចនាបថ៖

#### ២.២.១- រចនាបថគូលែន (គ.ស.៨០២ ដល់គ.ស.៨៥០ ពាក់កណ្ដាលទី១នៃសតវត្សទី៩)

ដំណាក់កាលនៃរចនាបថគូលែន ស្ថិតក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ២ (គ.ស. ៨០២ ដល់ គ.ស. ៨៥០)។ ភ្នំគូលែនជាអតីតរាជធានីដែលព្រះអង្គបានកសាងឡើង ហើយមានបូជនីយដ្ឋាន ប្រាសាទជាច្រើនកន្លែង។ ក្រុមប្រាសាទដែលស្ថិតនៅក្នុងរចនាបថនេះមាន៖



www.elibraryofcambodia.org

- ប្រាសាទបន្ទាយព្រៃនគរ(ខេត្តកំពង់ចាម)
- ប្រាសាទអកយំ(ខេត្តសៀមរាប)
- ប្រាសាទព្រៃប្រាសាទ(ខេត្តសៀមរាប)
- ប្រាសាទគោនៅសម្បូណ៌ព្រៃគុក ក្រុមកណ្ដាល(C1) (ខេត្តកំពង់ធំ) ។
- ក្រុមប្រាសាទនៅភ្នំគូលែនមាន ប្រាសាទដំរីក្រាប ប្រាសាទអូរផ្អុង ប្រាសាទខ្ទឹងស្លាប់ ប្រាសាទរូបអារក្ស ប្រាសាទអ្នកតា(រូបលេខ ២៧) ប្រាសាទអូរថ្មដាប់ ប្រាសាទគគីរ ប្រាសាទអារាមរោងចិន និង ប្រាសាទក្រហម ។

- **ស្ថាបត្យកម្ម៖** ដូចនៅក្នុងសម័យមុនៗដែរ ប្រាសាទនៅក្នុងរចនាបថគូលែននៅតែកសាងឡើងអំពីឥដ្ឋដដែល ទំហំប្រាសាទក៏ប្រហាក់ប្រហែលនឹងតួប៉មនៃប្រាសាទសម្បូណ៌ព្រៃគុហ៍បែរមុខទៅទិសខាងកើត មានទ្វារបញ្ឆោត។ ទាក់ទងនឹងវិវឌ្ឍន៍ផ្នែកស្ថាបត្យកម្ម គេឃើញមានបច្ចេកទេសថ្មីមួយ គឺការ-កសាងប្រាសាទនៅលើភ្នំ ដើម្បីតម្រូវទៅតាម ទស្សនលទ្ធិ *ទេវរាជ* ដែលបានរៀបចំឡើង ដោយព្រះបាទជ័យវរ្ម័នទី២។ ព្រះអង្គបាន ប្រមែប្រមូលស្ថាបនិកជំនាញទាំងអស់ ដើម្បីកសាងនូវស្នាដៃមួយថ្មី ដែលកើតចេញពីការផ្សំរវាងបច្ចេកទេសពីសម័យមុនខ្លះ ការស្រាវជ្រាវរកឃើញថ្មីខ្លះ និង ការទទួលឥទ្ធិពលពីជ្វាខ្លះ ។ ជាក់ស្តែងប្រាសាទអកយំ ដែលចាត់ទុកថាជារាជធានី *អមរេន្ទ្របុរៈ* បានកសាងនៅលើខឿនឥដ្ឋដីផុតពីរថ្នាក់ មានប្រាង្គចំនួន ៥ កសាងពីឥដ្ឋដីផុតដូចគ្នា ជារបៀបប្រាសាទភ្នំដាក់តម្កល់សិវលិង្គ។ ប្រាសាទអារាមរោងចិនកសាងនៅលើភ្នំគូលែនមានខឿនច្រើនជាន់ ហើយប្រហែលជានៅទីនេះហើយដែលព្រះបាទជ័យវរ្ម័នទី ២ បានរៀបចំពិធី *ទេវរាជ* ។ ប្រាសាទដំរីក្រាបមានប្រាង្គចំនួន ៣ នៅលើខឿនតែមួយ កសាងនៅលើភ្នំគូលែន។
- **ផ្តែរ** មានលក្ខណៈសម្គាល់ប្លែកៗគ្នាច្រើនខុសពីរចនាបថកំពង់ព្រះប៉ុន្តែបែរជាមានការចម្លង យកមកវិញខ្លះពីរចនាបថសម្បូណ៌។ នៅចុងដងធ្នូទាំងសង


www.elibraryofcambodia.org

ខាង បែរជាមានរូបសត្វមករពាំកម្រងផ្កា ពេលខ្លះបែរមុខចេញក្រៅ ពេលខ្លះទៀត បែរមុខចូលក្នុង។ នៅលើដងធ្នូ មានការលម្អដោយក្បាច់ស្លឹកឈើ (រូបលេខ ២៨) មានរូបមនុស្សផុសចេញពីស្លឹកឈើនិងវល្លិយោលផ្កា ជួនកាលជាក្បាច់ខ្សែហៀន ជួនកាល ក្បាច់ទាំងពីរនេះនៅលាយឡំជាមួយគ្នា។ នៅចំកណ្ដាលដងធ្នូ មានរូប *កាលៈ* ឬ *រាហុ* ដែលជាឥទ្ធិពល*សិល្បៈជ្វា*។

- **សសរពេជ្រ** ចាប់ផ្ដើមឃើញមានរាង៤ជ្រុង និង៨ជ្រុង។ នៅចំកណ្ដាលសសរមានកងធំមួយ រួចមានកងវណ្ណមួយភាគបួន និងមួយភាគប្រាំបី នៅតាមចន្លោះនោះទៀតតម្រៀបគ្នាជាកង់ៗពីលើដល់ក្រោម ហើយសុទ្ធសឹងតែមានការតុបតែងលម្អ។ នៅលើជ្រុងនីមួយៗ នៃ *សសរ ៨ ជ្រុង* តែងមានលម្អដោយក្បាច់ស្លឹកឈើមួយសន្លឹក អមសងខាងកង (រូប លេខ ២៩)។
- **ហោជាង** មានដងក្ដាររាងដូចស្នាមជើងធ្មារឬក្បាច់កញ្ចុំជើងធ្មា កើតពីខ្លួននាគពត់ពែន គន្លិគន្លាក់ចុះឡើង។ នៅផ្ទៃកកណ្ដាលហោងជាង ជួនកាល ឆ្លាក់ជាទេវរូប ជួនកាលទៀត មានរូបទេពប្រណម្យ នៅអមសងខាង(រូបទី៣០)។
- **បដិមា** ក្នុងរចនាបថគូលែន គេរកពុំឃើញមានទេវរូបភេទស្រីទេ មានច្រើនតែទេវរូបភេទប្រុស។ ការតុបតែងលម្អបានវិលត្រឡប់ទៅរករចនាបថនៅសតវត្សទី ៨ វិញ។ ដូចជា ព្រះវិស្ណុមកពីប្រាសាទរូបអារក្ស បានប្រើជន្ទល់និង ដំបងដដែល(រូបទី៣១) មានពាក់មួករាងបំពង់ តែនៅចុងសម័យនេះបែរជាលម្អដោយ *មកុដ* ហើយតុបតែងដោយក្បូរក្បាច់ អលង្ការខាងលើកំពូលមកុដរាងដូចសាជី (រូបលេខ ៣២)។ ដងខ្លួនបដិមាខ្លះរាងបន្ទន់ចង្កេះបន្តិច ខ្លះរាងត្រង់ធម្មតា មានទម្រង់មុខធំ ញញឹមស្ញប់ ចិញ្ចើមជាប់ចេញពីគ្នា មានពុកមាត់ ស្លៀកសំពត់សារបាប់ខ្លីបែត្រឹមភ្លៅ មានជាយសំពត់ធ្លាក់សំយាកលើភ្លៅខាងឆ្វេង និងមានរំកាយផ្នត់ពីរជាន់រាងដូចកន្ទុយត្រីធ្លាក់សំយុងនៅពីខាងមុខ ជួនកាល គ្មានរំកាយនេះទេ ។ ចង្កេះសំពត់រឹតដោយខ្សែក្រវាត់បន្ទះធំ (រូបទី៣៣)។


www.elibraryofcambodia.org

### ២.២.២- រចនាបថព្រះគោ (គ.ស.៨៥០ ដល់គ.ស.៨៨៩ ភាគ៤ ចុងក្រោយសតវត្សទី៩)

ជំណាក់កាលនៃរចនាបថព្រះគោ ស្ថិតក្នុងរជ្ជកាលរបស់ព្រះមហាក្សត្រពីរព្រះអង្គគឺ ព្រះបាទឥន្ទ្រវរ្ម័នទី១(គ.ស. ៨៧៧ ដល់គ.ស. ៨៨៩) និងព្រះបាទយសោវរ្ម័នទី ១ (គ.ស.៨៨៩ ដល់គ.ស. ៩០០) ដែលដំបូងឡើយគង់នៅរាជធានីហរិហរាល័យ គឺនៅរលួសខេត្តសៀមរាប ។ ប្រាសាទ សំខាន់ៗដែលស្ថិតនៅក្នុងរចនាបថនេះមាន៖

- ប្រាសាទព្រះគោ (ខេត្តសៀមរាប)
- ប្រាសាទបាគង (ខេត្តសៀមរាប)
- ប្រាសាទលលៃ (ខេត្តសៀមរាប) ។

- **ស្ថាបត្យកម្ម៖** ប្រាសាទនៅក្នុងរចនាបថព្រះគោនៅតែបន្តប្រើប្រាស់ឥដ្ឋដីដុតសម្រាប់កសាងប្រាសាទ និងបាយអកំបោរបូកនៅលើជញ្ជាំង ឬចាក់ពុម្ពក្បាច់បិទភ្ជាប់លើជញ្ជាំងប្រាសាទ។ គេចូលចិត្តកសាងប្រាសាទជាច្រើន នៅលើខឿនតែមួយដែល មានច្រើនថ្នាក់ សម្រាប់តម្កល់បដិមាទេវរូប ឬ សិវលិង្គឧទ្ទិសចំពោះបុព្វការីជន មាន មាតាបិតាជាដើម។

*ប្រាសាទព្រះគោ* ( រូបទី៣៤) កសាងឡើងដោយព្រះបាទឥន្ទ្រវរ្ម័នទី១ ហើយបានធ្វើបុណ្យឆ្លងនៅក្នុងឆ្នាំ គ.ស. ៨៧៩ ។ ប្រាសាទនេះកសាងអំពីឥដ្ឋដីដុត មានប្រាង្គចំនួន ៦ សង់តម្រៀបគ្នាជាពីរជួរ នៅលើខឿនតែមួយបែរមុខទៅទិសខាងកើត។ ប្រាង្គ ៣ នៅជួរខាងមុខមានទំហំធំ ដាក់តម្កល់បដិមាឧទ្ទិសដល់ទេវៈនិងបុព្វការីជនភេទប្រុស ពិសេស តួប៉មកណ្តាលឧទ្ទិសដល់ព្រះបាទ *ជ័យវរ្ម័នទី ២* ។ ឯប្រាង្គ ៣ ទៀត នៅជួរក្រោយ មានរាងតូចបន្តិច ឧទ្ទិសដល់ទេវៈ និង បុព្វការីជនភេទស្រីរបស់ព្រះអង្គ ។

*ប្រាសាទបាគង* (រូបទី៣៥) ក៏បានកសាងឡើងដោយព្រះបាទឥន្ទ្រវរ្ម័នទី ១ ដែរ។ ព្រះអង្គបានធ្វើបុណ្យឆ្លងនៅក្នុងគ្រិស្តសករាជ ៨៨១ ។ សំណង់



www.elibraryofcambodia.org

ប្រាសាទដែលសង់នៅលើខឿនច្រើនជាន់ ឡើងខ្ពស់លេចធ្លោ ហើយធំស្កឹមស្កៃលើកទី ១ បែបនេះ អ្នកស្រាវជ្រាវបានឲ្យឈ្មោះថា *ប្រាសាទភ្នំ* ។

*ប្រាសាទលលៃ* កសាងឡើងនៅក្នុងរជ្ជកាលរបស់ព្រះបាទយសោវរ្ម័នទី ១ នៅកណ្ដាលបារាយណ៍ឥន្ទ្រតដាក ដើម្បីឧទ្ទិសថ្វាយដល់បុព្វការីជនរបស់ព្រះអង្គ ដោយបានធ្វើបុណ្យឆ្លងនៅក្នុងឆ្នាំ ៨៩៣ ។ ប្រាសាទនេះកសាងអំពីឥដ្ឋ នៅលើខឿនតែមួយ មានប្រាង្គ ចំនួន ៤ បែរមុខទៅទិសខាងកើត។

- **ផ្ដែរ** នៅក្នុងរចនាបថនេះ បានបន្តក្បូរក្បាច់រចនាពីរចនាបថគូលែនដែលមានទឹកដៃល្អស្រស់បំព្រង ព្រមទាំងមានភាពទន់ភ្លន់។ លើដងធ្នូបានផ្លាស់ប្ដូរមកជាកម្រងមែកឈើផ្ដេក មានរូបមនុស្សជិះសេះផុសចេញពីលើមែកឈើនេះ។ ភាគកណ្ដាលដងធ្នូ ជួនកាល មាន ក្បាច់ក្បាលរាហូគ្រុឌ និង ក្បាលដំរីជាដើម។ ចុងដងធ្នូលម្អដោយចម្លាក់ក្បាលនាគ-ងឡើងលើ ជួនកាល ជារូបរាជសីហ៍ ជួនកាលរូបមករជាដើម ។ ផ្នែកខាងក្រោមដងធ្នូ មាន ក្បាច់សន្លឹកនិង វល្លិយោលផ្កា (រូបទី ៣៦)។
- **សសរពេជ្រ** រាងមូលនៅមានបន្តប្រើខ្លះដែរ សម្រាប់តែប្រាង្គណាដែលពុំសូវសំខាន់ តែ ភាគច្រើន ជាសសររាង ៨ ជ្រុង ។ តាមជ្រុងនីមួយៗ នៅតែមានក្បាច់សន្លឹកលាតធំមួយដដែល។ លុះមកដល់ខាងចុងរចនាបថនេះ នៅប្រាសាទលលៃ គេឃើញមានរំលេចនូវ កូនសន្លឹកតូចមួយបន្ថែមទៀត នៅតាមសសរពេជ្រ (រូបទី ៣៧)។ សសរបញ្ឈោត គេលម្អ ដោយក្បាច់ភ្ញីល្ងើ ក្បាច់ត្របកឈូក និងក្បាច់ ថ្នាំងអំពៅដ៏ល្អវិចិត្រ។ នៅលើជញ្ជាំង មានចម្លាក់រូបទេវតា ឬទ្វារបាលឈរក្នុងស៊ុមអម ទ្វារប្រាង្គ ។
- **ហោជាង** មានដងក្ដាររាងដូចស្នាមជើងឆ្មា ខាងលើដងក្ដារ គេរចនាក្បាច់ស្រួចៗដូចធ្មេញរណារ ឯខាងចុងដងក្ដារ គេឆ្លាក់ជាហ្វាជារូបក្បាលមករ បែរ



www.elibraryofcambodia.org

មុខចេញក្រៅ ។ លើផ្ទៃហោជាង មានចម្លាក់ទេវរូបធំមួយអមដោយរូប *ទេពប្រណម្យ* ពីរទៀត (រូបទី ៣៨)។

- **បដិមា** មានរាងមាំ មិនកាច់ចង្កេះដូចសម័យមុន ។ សំពត់សារបាប់ដីបជាផ្នត់នៅខាងមុខ។ នៅត្រង់ពោះ ដោយសំពត់បត់ទម្លាក់មកក្រោម គ្របលើខ្សែក្រវាត់។ ចំណែកឯម្កុដវិញ គេរចនាដោយក្បូរក្បាច់ជាច្រើន ។ ដងខ្លួន ដៃ និងក សឹងប្រដាប់ដោយគ្រឿងអលង្ការ។ ចិញ្ចើមមានរាងត្រង់ជាប់គ្នា។ ទេវរូបភេទប្រុសមានពុកចង្កា(រូបទី ៣៩ និង ៤០)។

## ២.២.៣- រចនាបថបាខែង (គ.ស.៨៨៩ ដល់គ.ស.៩១២ ភាគ៤ ចុងសតវត្សទី ៩ និងដើមសតវត្សទី ១០)

ដំណាក់កាលនៃរចនាបថបាខែង បានកសាងឡើងនៅក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី១ (គ.ស. ៨៨៩ ដល់ គ.ស.៩០០)។ ប្រាសាទភ្នំបាខែងជាស្នូលនៃអតីតរាជធានីយសោធរបុរៈ ឬ ភ្នំកណ្ដាល។ អ្នកស្រាវជ្រាវពីប្រវត្តិសិល្បៈខ្មែរបានចាត់ទុកសំណង់ ប្រាសាទសំខាន់ៗ ដែលរាប់បញ្ចូលក្នុងរចនាបថនេះមាន៖

- ប្រាសាទភ្នំបាខែង
- ប្រាសាទភ្នំក្រោម
- ប្រាសាទភ្នំបូក ។

គេអាចរាប់បញ្ចូលប្រាសាទពីរទៀត ដែលស្ថិតនៅក្នុងរចនាបថនេះផងដែរ គឺ *ប្រាសាទក្រវ៉ាន់* និង *ប្រាសាទបក្សីចាំក្រុង* ។

- **ស្ថាបត្យកម្ម៖** គេសង្កេតឃើញថា វិស័យស្ថាបត្យកម្មក្នុងសម័យនេះមានវិវឌ្ឍន៍យ៉ាងខ្លាំងខាងបច្ចេកទេសសំណង់ ព្រោះស្ថាបត្យករបានជ្រើសរើសយកសម្ភារៈ សំណង់ជាប្រភេទ ថ្មភក់មកកសាងប្រាសាទធំៗ មានច្រើនជាន់នៅលើខឿនខ្ពស់ ជាពិសេស គេនិយម កសាងប្រាសាទនៅលើភ្នំតែម្ដង (រូបទី ៤១) ។



www.elibraryofcambodia.org

- **ផ្តែរ** ក្បាច់ផ្តែរនៅក្នុងរចនាបថនេះ បានរក្សាទុកនូវក្បូរក្បាច់លម្អផ្នែកខ្លះនៃរចនាបថព្រះគោ។ នៅចំកណ្តាលជងធ្នូលម្អដោយរូបរាហ៊ូ ឬ ក្បាលដំរីមានរូបទេវៈជិះពីលើដូចរចនាបថព្រះគោ។ ចំណែកឯជងធ្នូវិញ គេលម្អដោយកម្រងមែកឈើមានរាងកោងស្រុតចុះបន្តិច។ រូបមនុស្សនៅលើជងធ្នូលែងមានទៀតហើយ(រូបទី៤២)។ នៅចុងជងធ្នូ មានផ្តែរខ្លះលម្អដោយរូបក្បាលសឹង្ហខ្លះទៀតជារូបនាគ ។
- **ហោជាង** នៅលើជងក្ដារមានរូបដូចស្នាមជើងឆ្មា ហើយនៅខាងចុងជងក្ដារមានការរចនាជារូបក្បាលមករ ។ ក្នុងផ្ទៃហោជាង ច្រើនមានាការលម្អដោយក្បាច់ស្លឹកឈើលាយឡំ ជាមួយនឹងរូបមនុស្ស។
- **បដិមា** ក្នុងរចនាបថនេះ មានរាងមាំ មាឌធំ ឈរត្រង់ មានទឹកមុខស្ងួតចិញ្ចើមទាំងពីរត្រង់ហើយជាប់គ្នា ភ្នែកនិងបបូរមាត់មានរាងជាវង្វង់ពីរផ្នត់យ៉ាងច្បាស់ (រូបលេខ ៤៣)។ ចំណែកពុកចង្កានិងជើងសក់ជាប់គ្នាតែម្តង។ ទេវរូបភេទប្រុសស្លៀកពាក់សំពត់សារបាប់ខ្លីជីបជាផ្នត់ធំៗរឹបត្រង់ភ្លៅ មានជាយធ្លាក់សំយាកនៅលើភ្លៅខាងឆ្វេង និង មានជាយរាងដូចកន្ទុយត្រីពីរជាន់ទម្លាក់ចុះក្រោមចំពីខាងមុខដែលជាយខាងក្រៅវែងជាងជាយខាងក្នុង មានខ្សែក្រវាត់រឹបពីលើចង្កេះសំពត់មួយជាន់ទៀត។ ទេវរូបភេទស្រីស្លៀកសំពត់សារបាប់វែងមានផ្នត់ញឹកជាយខាងលើធ្លាក់រំភាយចំពីមុខ ។

### ២.២.៤- រចនាបថកោះកេរ (គ.ស. ៩២១ ដល់ គ.ស. ៩៤១ មួយភាគបួន ទី ២ នៃសតវត្សទី១០)

ដំណាក់កាលនៃរចនាបថកោះកេរ បានកសាងឡើងនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ (គ.ស. ៩២៧ ដល់ គ.ស.៩៤១)។ កោះកេរជាអតីតរាជធានីពីបុរាណដែលស្ថិតនៅចម្ងាយប្រមាណ ៧២ គីឡូម៉ែត្រ ភាគឥសាននៃទីក្រុងអង្គរ។ ប្រាសាទសំខាន់ៗដែលស្ថិតនៅក្នុងរចនាបថកោះកេរមាន៖


www.elibraryofcambodia.org

- ប្រាសាទកោះកេរ (ខេត្តព្រះវិហារ) មាន៖ ប្រាសាទនាងខ្មៅ ប្រាសាទធំ ប្រាសាទក្រហម ប្រាសាទដំរីចែងកណ្តឹង ប្រាសាទលិង្គ ប្រាសាទប្រាប... ។ល។
- ប្រាសាទនាងខ្មៅ (ខេត្តតាកែវ និង ខេត្តព្រះវិហារ) ។

- **ស្ថាបត្យកម្ម៖** ការប្រើប្រាស់ឥដ្ឋក្នុងការកសាងប្រាសាទនៅតែមានបន្តទៀត។ ប្រាសាទទាំងឡាយមានទំហំធំៗ ជារបៀបប្រាសាទភ្នំ សង់នៅលើខឿនច្រើនជាន់ ដូចជាប្រាសាទ*កោះកេរ* សង់នៅលើខឿនថ្មបាយក្រៀម មាន ៧ ថ្នាក់ កម្ពស់ ៣៥ ម៉ែត្រ បែរមុខទៅទិសខាងកើត សម្រាប់ដាក់តម្កល់សិវលិង្គដែលមានកម្ពស់ប្រមាណ ៣ ម៉ែត្រ (រូបទី៤៤)។
- **ផ្តែរ** ក្បាច់ដងធ្នូមានលម្អដោយក្បាច់ស្លឹកឈើ មានរាងកោងខ្លាំង ត្រេចចុះក្រោមបន្តិចត្រង់ផ្នែកកណ្តាល។ នៅចំកណ្តាលផ្តែរ មានផ្តែរខ្លះលម្អដោយរឿងទេវកថា ឬ រូបទេពនិករណាមួយ។ គេសង្កេតឃើញ មានផ្តែរមួយទៀតរាងត្រីកោណបានលេចឡើងនៅក្នុងរចនាបថ នេះ។
- **សសរពេជ្រ** មានរាង ៨ ជ្រុងដដែល ជ្រុងនីមួយៗលម្អដោយក្បាច់ស្លឹកឈើមួយសន្លឹកអមដោយស្លឹកជ្រៀកពាក់កណ្តាលចំនួន ២ ។ នៅលើតួសសរ គេបន្ថែមវណ្ណៃច្រើន ហើយមានទំហំធំ មើលទៅញឹកដូចថ្នាំងអំពៅ(រូបទី៤៥)។
- **ហោជាង** មានរាងដូចស្នាមជើងធ្មា។ លើផ្ទៃហោជាង មានការលម្អដោយក្បាច់ភ្ញីទេសព័ទ្ធពេនចុះឡើងជុំវិញរូបមនុស្ស ជួនកាល ឆ្លាក់ជាក្បាច់ស្លឹកឈើអមរូបមនុស្ស និង មានលេចឡើងនូវហោជាងរាងត្រីកោណ (រូបលេខ ៤៦)។

- **បដិមា** លក្ខណៈបដិមានៅក្នុងរចនាបថនេះមានសភាពប្រហាក់ប្រហែលនឹងចនាបថបាខែងដែរ គឺមានមាឌធំមាំ ប៉ុន្តែគេបានបន្ថែមនូវគំនិតក្នុងការឆ្លាក់បដិមាឲ្យមានចលនាជាបែបផ្សេងៗដូចជា រូបដើរ រូបរាំ(សិវៈរាំ) រូបប្រយុទ្ធគ្នា (សុគ្រីពប្រយុទ្ធជាមួយនឹងពាលី)(រូបទី៤៧) និងរូបគ្រុឌហោះ(នៅសារមន្ទីរជាតិទីក្រុងភ្នំពេញ) (រូបទី ៤៨)។ ទេវរូបភេទប្រុសស្លៀកសំពត់សារបាប់ខ្លី


www.elibraryofcambodia.org

ដឹបជាផ្គត់ធំៗ រឹបត្រង់ភ្លៅ ហើយមានជាយទម្លាក់ចុះពីខាងមុខដូចកន្ទុយត្រី ត្រួតគ្នាពីរជាន់ប្រហាក់ប្រហែលនឹងរចនាបថបាខែងដែរ។ នៅពីលើជាយទាំងពីរ មានជាយធំមួយទៀតទម្លាក់មកបាំងពីខាងលើខ្សែក្រវាត់ខាងមុខ (រូបទី៤៩)។ ឯទេវរូបភេទស្រីស្លៀកសំពត់សារបាប់វែង ធ្លាក់ដល់ក្រោម ចាប់ភ្លីញីកល្អិត ជាយខាងលើធ្លាក់កែាយចំពីមុខ(រូបទី៥០)។

## ២.២.៥- រចនាបថបន្ទាយស្រី (គ.ស. ៩៦៨ ដល់គ.ស. ១០០១ ពាក់កណ្តាលទី២ នៃសតវត្សទី១០)

ដំណាក់កាលនៃរចនាបថបន្ទាយស្រីបានកសាងឡើង ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័នទី២ (គ.ស.៩៤៤ ដល់គ.ស.៩៦៨)។ ព្រះអង្គបានឡើងសោយរាជ្យសម្បត្តិនៅរាជធានីអង្គរ។ ប្រាសាទសំខាន់ៗដែលស្ថិតនៅក្នុងរចនាបថបន្ទាយស្រីមាន៖

- ប្រាសាទមេបុណ្យខាងកើត(គ.ស.៩៥២)
- ប្រាសាទប្រែរូប(គ.ស.៩៦១)
- ប្រាសាទបន្ទាយស្រី(គ.ស.៩៦៧)
- ប្រាសាទស្រឡៅ(ខាងលិចអង្គរធំ) និងប្រាសាទមួយទៀតនៅក្រោយប្រាសាទឃ្លាំងខាងជើង។

ទឹកដៃនៃសិល្បៈស្ថាបត្យកម្មក្នុងរចនាបថនេះគឺមានលក្ខណៈកាន់តែជឿនលឿនស្មុគស្មាញ និង ច្រើនបែបយ៉ាងណាស់ប្រកបដោយទេពកោសល្យសិល្បៈខ្ពស់ខុស ពីសម័យមុនៗ។

- **ស្ថាបត្យកម្ម៖** ជាក់ស្តែងគេបានសង្កេតឃើញថាប្រាសាទមេបុណ្យខាងកើត និង ប្រាសាទប្រែរូប ទោះបីកសាងឡើងអំពីឥដ្ឋដីដុតក៏ដោយ ក៏សិល្បករខ្មែរសម័យនោះបានអភិវឌ្ឍមួយកម្រិតថែមទៀត ចំពោះសំណង់ស្ថាបត្យកម្មដោយគេមានបច្ចេកទេសបន្ថែមនូវរោងថែវ ដែលមានបន្ទប់វែងៗ ដាច់ពីគ្នាព័ទ្ធជុំវិញប្រាសាទនៅលើខឿនជាន់ទីមួយ។


www.elibraryofcambodia.org

ប្រាសាទបន្ទាយស្រីកសាងឡើងដោយស្ថាបត្យករព្រាហ្មណ៍មួយរូប ដែលមានព្រះនាមថា **យជ្ញវរាហៈ** ដែលមានភាពប៉ិនប្រសប់ក្នុងការកសាង។ ប្រាសាទនេះពុំមែនជាប្រាសាទកសាងនៅលើភ្នំ តែជាប្រាសាទសាងសង់នៅលើដីរាបស្មើ កសាងអំពីថ្មភក់ពណ៌កុលាប មានប្រាង្គតូចច្រឡឹងចំនួនបីទន្ទឹមគ្នា ស្ថិតនៅលើខឿនតែមួយដែលមានកម្ពស់ ១ ម៉ែត្រ មានក្បូរក្បាច់ចម្លាក់រស់រវើក នៅគង់វង្សល្អឯកគ្មានផ្ទឹម ជាស្នាដៃសិល្បៈខ្មែរនាសម័យអង្គរ។ លើជញ្ជាំងប្រាសាទសុទ្ធតែឆ្លាក់ដោយក្បូរក្បាច់ចម្លាក់ជ្រៅៗយ៉ាងរស់រវើក គ្មានសល់ចន្លោះទំនេរ(រូបទី៥១)។

- **ផ្តែរ** គេសង្កេតឃើញថា បានចម្លងគំរូចេញពីផ្តែរក្នុងរចនាបថព្រះគោ។ នៅកណ្តាលផ្តែរ គេនិយមឆ្លាក់ជារឿងទេវកថានានា។ ត្រង់កន្លែងមួយភាគបួននៃដងធ្នូ ច្រើនមានការឆ្លាក់ជារូបក្បាលសត្វឬក្បូរក្បាច់ផ្សេងៗ ។
- **សសរពេជ្រ** គេបែរមកប្រើប្រាស់សសររាងមូលមួយចំនួនឡើងវិញខ្លះ និងបន្តប្រើប្រាស់សសររាង ៨ ជ្រុងផងដែរ ប៉ុន្តែបានកាត់បន្ថយចំនួនក្បាច់វណ្ណឲ្យនៅតិច ធ្វើឲ្យផ្ទៃសសររាងស្រឡះ មិនញឹកដូចថ្នាំងអំពៅ។ ជ្រុងនីមួយៗនៃសសរ ៨ ជ្រុង នៅតែមានក្បាច់សន្លឹកលាតតូចៗពីរជំដែល(រូបទី៥២)។
- **ហោជាង** រាងត្រីកោណក៏មានខ្លះដែរ តែភាគច្រើនមានរាងជាស្នាមជើងឆ្មា។ ហោជាងរាងស្នាមជើងឆ្មា មានដងក្តារត្រួតគ្នាជាថ្នាក់ៗនៅខាងចុងសងខាងនៃហោជាងខ្លះ មានក្បាលមករពាំរំយោលផ្កា ខ្លះទៀតមានចម្លាក់ក្បាលមករខាំខ្នាក់នាគ។ កណ្តាលហោជាង ច្រើនរចនាជាក្បាច់រឿងទេវកថាផ្សេងៗ (រូបទី ៥៣)។
- បដិមាច្រើនមានរាងតូចៗប៉ុន្តែឆ្លាក់យ៉ាងផ្ចិតផ្ចង់ ទឹកមុខញញឹមស្រស់ មានរបៀបតុបតែងសក់ថ្មីដោយពុំមានប្រើមកុដ។ បដិមាខ្លះស្លៀកសំពត់សារបាប់ជីបជាផ្នត់ ខ្លះទៀតស្លៀកសំពត់សារបាប់លាតរលីងធម្មតា ។


www.elibraryofcambodia.org

## ២.២.៦- រចនាបថឃ្លាំង (គ.ស.៩៦៥ ដល់ គ.ស. ១០៥០ ចុង សតវត្ស ទី១០ និង ពាក់កណ្តាលទី១នៃសតវត្សទី១១)

ដំណាក់កាលនៃរចនាបថឃ្លាំង បានកសាងឡើងនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ (គ.ស.៩៨៦ ដល់គ.ស.១០០១) និង ព្រះបាទសូរ្យវរ្ម័នទី១ (គ.ស. ១០០២ ដល់គ.ស.១០៥០) ដែលបានគ្រងរាជសម្បត្តិនៅរាជធានីអង្គរ ។ ប្រាសាទសំខាន់ៗដែលស្ថិតនៅក្នុងរចនាបថឃ្លាំងមាន៖

- ប្រាសាទតាកែវ
- ប្រាសាទភិមានអាកាស
- ក្លោងទ្វារប្រាសាទភិមានអាកាស
- ប្រាសាទព្រះវិហារ
- ប្រាសាទឃ្លាំងខាងជើង
- ប្រាសាទឃ្លាំងខាងត្បូង
- ប្រាសាទភ្នំជីសូរ
- ប្រាសាទចៅស្រីវិបុល ។

- **ស្ថាបត្យកម្ម៖** ប្រការដែលគួរឲ្យកត់សម្គាល់ចំពោះប្រាសាទនៅក្នុងរចនាបថឃ្លាំងគឺការកសាងប្រាសាទដោយប្រើថ្មភក់សុទ្ធ គេឈប់ប្រើប្រាស់ឥដ្ឋដីដុតទៀតហើយ។ គេកសាងថែវព័ទ្ធជុំវិញត្លប្រាង្គខាងលើ ដែលមានលក្ខណៈជាបន្ទប់រាងទ្រវែង ជាក់ស្តែង ដូចជា ប្រាសាទតាកែវជាប្រាសាទភ្នំកសាងនៅលើខឿនខ្ពស់ ៥ ថ្នាក់ ដែលមានប្រាង្គ ៥ ហើយមានបន្ទប់ថែវព័ទ្ធជុំវិញ។ ខឿន ប្រាង្គ និង ថែវរបស់ប្រាសាទតាកែវសុទ្ធតែកសាង អំពីថ្មភក់ (រូបទី៥៥)។ ចំណែកឯប្រាសាទភិមានអាកាសវិញ គេចាប់ផ្តើមកសាងថែវព័ទ្ធជុំវិញដោយមានដំបូលរាងកោងសាងអំពីថ្មភក់។
- **ផ្តែរ** មានវិវឌ្ឍន៍ឈានមួយកម្រិតទៀត នៅចំកណ្តាលនៃដងធ្នូ គេច្រើនឆ្លាក់ជារូបក្បាលរាហ៊ូលៀនអណ្តាតចេញក្រៅជារាងស្លឹកឈើ។ ត្រង់មួយភាគបួននៃដងធ្នូ គេខណ្ឌដោយក្បាច់រំយោលផ្កា។ ចំពោះក្បាច់ស្លឹកឈើ និងក្បាច់ទម្លាក់ មានលក្ខណៈច្បាស់លាស់ (រូបទី៥៦)។
- **សសរពេជ្រ** មានការតុបតែងលម្អបន្តិចបន្តួច។ នៅតាមជ្រុងនីមួយៗនៃសសរពេជ្រ គេឆ្លាក់ក្បាច់ស្លឹកឈើល្អិតៗញឹកដូចធ្មេញរណារ។



www.elibraryofcambodia.org

- **ហោជាង៖** ជងក្ដាររបស់ហោជាងលម្អដោយក្បាច់ស្លឹកឈើ ចុងសងខាងរបស់ជងក្ដារមានរូបក្បាលរាហ៊ូខ្ទាក់នាគ ហើយនាគខ្ទាក់ផ្កាវិយោល។ លុះមកដល់ចុងរចនាបថនេះ គេឃើញមានតែក្បាលនាគប៉ុណ្ណោះ។ លើផ្ទៃហោជាង គេនិយមឆ្លាក់លម្អដោយក្បាច់ភ្ញីទេសច្រើនជាងឆ្លាក់ក្បាច់រឿងទេវកថា (រូបទី ៥៧)។

- **បដិមា** មានលក្ខណៈទន់ភ្លន់ ទឹកមុខស្រទន់ដូចជាមានវិញ្ញាណ ស្លៀកសំពត់សារបាប់ជីបជាផ្នត់ល្អិតៗ។ ការស្លៀកសំពត់ គេសង្កេតឃើញ មានលក្ខណៈប្លែកពីសម័យមុន គឺផ្នែកខាងក្រោយចង្កេះសំពត់ឡើងរហូតដល់ខ្នង ឯខាងមុខធ្លាក់សំយេះ មកក្រោម បញ្ចេញក្បាលពោះកណ្ដាលវាល។

### ២.២.៧- រចនាបថបាពួន (ពាក់កណ្ដាលទី២នៃសតវត្សទី១១)

ដំណាក់កាលនៃរចនាបថបាពួន បានកសាងឡើងនៅក្នុងរជ្ជកាលព្រះបាទឧទយាទិត្យវរ្ម័នទី ២ (គ.ស.១០៤០ ដល់ គ.ស.១០៦៦) និង ព្រះបាទហស៌វរ្ម័នទី ៣ (គ.ស.១០៦៦ ដល់ គ.ស. ១០៨០)។ ព្រះមហាក្សត្រទាំងពីរអង្គនេះគ្រងរាជ្យសម្បត្តិនៅរាជធានីអង្គរ ។ ប្រាសាទ សំខាន់ៗ ដែលស្ថិតនៅក្នុងរចនាបថបាពួន មាន៖

- ប្រាសាទបាពួន
- ប្រាសាទមេបុណ្យខាងលិច
- ប្រាសាទវត្តខ្នារ ។

- **ស្ថាបត្យកម្ម៖**

ការកសាងប្រាសាទភ្នំនៅក្នុងសម័យនេះកាន់តែមានភាពជឿនលឿន ប្រកបដោយបច្ចេកទេសខ្ពស់ និង មានទំហំធំ។ ជាក់ស្ដែងប្រាសាទ*បាពួន* កសាងឡើងនៅក្នុងរាជ្យរបស់ព្រះបាទឧទ្យាទិត្យវរ្ម័នទី ២ ជាប្រភេទប្រាសាទភ្នំដែលមានទំហំធំ សាងសង់អំពីថ្មភក់(រូបទី៥៨)។ ប្រាសាទនេះមានថែវព័ទ្ធជុំវិញប្រក់ដោយដំបូលថ្មភក់រាងកោង មានមណ្ឌបនៅតាមរោងថែវទាំង ៤ ទិស។



www.elibraryofcambodia.org

នៅតាមជញ្ជាំងប្រាសាទ មានរូបចម្លាក់ជាផ្ទាំងតូចៗដែលរៀបរាប់ពីរឿងរ៉ាវទាក់ទងនឹងរឿងទេវកថានានា។ ផ្លូវចូលទៅកាន់ប្រាសាទ គេធ្វើជាស្ពានពីថ្មភក់ ។

- **ផ្តែរ៖** ដូចសម័យមុនៗដែរ ផ្តែរក្នុងរចនាបថបាពួន ក្បាច់ដងធ្នូដែលលម្អដោយក្បាច់ស្លឹកឈើ មានសភាពកោងចុះក្រោមខ្លាំងដល់បាត។ ចំណែកឯក្បាលរាហ៊ូវិញ វាមានមាត់ធំ លែងឃើញមានអណ្តាតលៀនទៀត ហើយខ្ទង់ច្រមុះខើចខ្ពស់ឡើងលើច្បាស់ បញ្ចេញចង្កូមតាមមាត់មកក្រៅ (រូបទី៥៩)។ ផ្ទៃផ្តែរច្រើនឆ្លាក់ជាក្បាច់រឿងទេវកថានានា។
- **សសរពេជ្រ៖** សសរពេជ្រមានកងវណ្ណលម្អដោយក្បាច់ស្លឹកឈើដូចសម័យមុនៗដែរ។
- **ហោជាង** ដងក្តារមានរាងប៉ោងជាខ្លួននាគ មានក្បាលបើកពពារចេញក្រៅនៅចុងខាងក្រោម ហើយលម្អដោយក្បាច់សន្លឹកសុទ្ធសាធ។ ផ្ទៃហោជាង គេច្រើនលម្អដោយក្បាច់ភ្ញីទេស។
- **បដិមា** មានមាឌតូចតែរាងសង្ហា មានទឹកមុខស្រទន់ដូចរចនាបថបន្ទាយស្រីដែរ។ ទេវរូបភេទប្រុសមានពុកចង្កា និងពុកមាត់ ដែលឆ្លាក់ជាស្នាមបន្តិចៗប៉ុណ្ណោះ។ លក្ខណៈសម្គាល់នៃបដិមាក្នុងរចនាបថនេះ គឺមានចិញ្ចើមនិងបបូរមាត់ខាងលើរាងដូចទឹករលក។ ឯទេវរូបភេទស្រីស្លៀកសំពត់វែងរឹបខាងក្រោយខ្នងឡើងខ្ពស់ហួសពីចង្កេះ ឯផ្នែកខាងមុខវិញ ច្រើនទុកចំហបញ្ចេញក្បាលពោះ និងផ្ចិត។ ជាយសំពត់ខាងមុខធ្លាក់សំយាកចុះក្រោម (រូបទី ៦០)។

### ២.២.៨- រចនាបថអង្គរវត្ត (គ.ស.១១១២ ដល់ គ.ស.១១៥២ ពាក់កណ្តាលទី ១ នៃសតវត្សទី១២)

ដំណាក់កាលនៃរចនាបថអង្គរ បានកសាងឡើងនៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ២ (គ.ស. ១១១៣ ដល់ គ.ស.១១៤៥) ដែលបានគ្រងរាជ្យសម្បត្តិនៅ


www.elibraryofcambodia.org

រាជធានីអង្គរ ។ ប្រាសាទសំខាន់ៗដែល ស្ថិតនៅក្នុងរចនាបថនេះមាន៖

- ប្រាសាទបឹងមាលា
- ប្រាសាទព្រះបាលិលេយ្យ
- ប្រាង្គកណ្ដាលនៃប្រាសាទបាគង
- ប្រាសាទភិមាយ
- ប្រាសាទព្រះពិធូរ
- ប្រាសាទចៅសាយទេវតា
- ប្រាសាទធម្មានន្ទ
- ប្រាសាទបន្ទាយសំរែ
- ប្រាសាទអង្គរវត្ត
- ប្រាសាទវត្តអធ្វា
- ប្រាសាទព្រះខ័ន(កំពង់ស្វាយ ខេត្តកំពង់ធំ) ។

- **ស្ថាបត្យកម្ម៖** នៅក្នុងដំណាក់កាលនេះ ស្ថាបត្យករខ្មែរបានពង្រីកនូវសមត្ថភាពបច្ចេកទេសខ្ពង់ខ្ពស់ដល់កំពូលក្នុងកសាងប្រាសាទ និង ក្នុងការ-រៀបចំគម្រោងប្លង់បច្ចេកទេស ចម្លាក់និងក្បូរក្បាច់រចនា។ គេសង្កេតឃើញថាប្រាសាទច្រើនមានទំហំធំ ស្កុកស្កម្ភ កម្ពស់ ខ្ពស់ស្កឹមស្កៃ សម្ភារៈធំៗ ធ្ងន់ៗ។ ពង្រីករបៀងថែវឲ្យកាន់តែវែង និង ភ្ជាប់ទៅដោយរូបចម្លាក់ស្អែកស្កះរាប់សិបម៉ែត្រ។ ដាក់ស្តែងប្រាសាទអង្គរវត្ត ដែលកសាងឡើងដោយព្រះបាទសូរ្យវរ្ម័នទី ២ ក្នុងសតវត្សទី១២ ជាប្រាសាទភ្នំ សាងសង់នៅលើផ្ទៃដី ២០០ ហិចតា រាងជាចតុកោណកែង មានគូទឹកព័ទ្ធជុំវិញដែលមានទទឹង ២០០ ម៉ែត្រ និង មានកំពែងថ្មបាយក្រៀមប្រវែងប្រហែល ៥.៥ គីឡូម៉ែត្រ។ ផ្លូវចូលធ្វើអំពីថ្មភក់ប្រវែង ២៥០ម៉ែត្រ និងទទឹង ១២ ម៉ែត្រ ។ នៅតាមផ្លូវចូល មានថែវជើងក្អែកភ្ជាប់ថែវជាន់ទី ១ ទៅនឹងថែវជាន់ទី២ ហើយមានថែវជើងក្អែកមួយទៀតភ្ជាប់ប្រាង្គស្ពានបាកាណទៅនឹងថែវជាន់ទី៣។ នៅតាមជញ្ជាំងថែវមានឆ្លាក់ដោយក្បាច់រឿងផ្សេងៗ ប្រក់ដោយដំបូលថ្មភក់ដែលមានរាងកោងទ្រដោយសសរស្តម្ភធំៗ។ នៅថ្នាក់លើបង្អស់ មានប្រាង្គចំនួន៥ សង់ខ្វែងគ្នា ហើយប្រាង្គទាំងអស់តភ្ជាប់គ្នា ដោយថែវដែលមានដំបូល។ តួប្រាសាទទាំងមូលសាងពីថ្មភក់ទាំងអស់ (រូបទី៦១)។ អ្នកស្រាវជ្រាវបុរាណវិទ្យាបាន


www.elibraryofcambodia.org

សន្និដ្ឋានថា មុននឹងកសាងប្រាសាទអង្គរវត្ត ស្ថាបត្យករខ្មែរបានសាកល្បងកសាងប្រាសាទ *បឹងមាលា* ជាមុន ព្រោះប្រាសាទនេះមានប្លង់ដូចប្រាសាទ *អង្គរវត្ត* ប៉ុន្តែគេកសាងវានៅលើដីរាបស្មើ។ ប្រាសាទ*អង្គរវត្ត* បើគេមើលពីលើអាកាសនោះ គេនឹងបានឃើញថា ប្រាសាទនេះមានកម្រិតសិល្បៈសកលស័ក្តិសមទាំងកម្ពស់ និង ទំហំ(រូបទី៦១)។

- **ផ្តែរ** បានយកលំនាំតាមគំរូផ្តែរនៃរចនាបថបាពួន ដងធ្នូដែលលម្អដោយក្បាច់ស្លឹកឈើ មានរាងកោងកាច់ចុះយ៉ាងខ្លាំងនៅចំកណ្តាល និងនៅសងខាង។ ផ្តែរខ្លះលែងមានក្បាច់ដងធ្នូ ហើយជំនួសមកវិញដោយក្បាច់ទម្លាក់តម្រៀបស្របៗគ្នា។ រូបរាហ៊ូបញ្ចេញធ្មេញ និងចង្កូម(រូបទី៦២)។
- **សសរពេជ្រ** លម្អដោយក្បាច់ស្លេកស្លុះ។ ក្បាច់សន្លឹកលាតមានទំហំតូចៗល្អិតដូចធ្មេញរណារ ។ សសរពេជ្រខ្លះមានរាង ១៦ ជ្រុង មើលឃើញហាក់ដូចជារាងមូល (រូបទី៦៣)។
- **ហោជាង៖** ដងក្តាររបស់ហោជាងមានរាងប៉ោង លម្អដោយក្បាច់ដេរដាសពាសពេញ។ ខាងចុងសងខាងរបស់ដងក្តារ មានការរចនាជាក្បាច់សត្វមករខ្ជាក់នាគ ដូចនៅក្នុងរចនាបថមុនៗដែរ។ ផ្ទៃហោជាងច្រើនមានចម្លាក់ជាក្បាច់រឿងទេវកថាផ្សេងៗញឹកស្លេកស្លុះពាសពេញ (រូបទី៦៤)។
- **បដិមា** ច្រើនមានមាឌធំមាំ ទឹកមុខទន់ភ្លន់។ ទេវរូបភេទប្រុស ស្លៀកសំពត់សារបាប់ខ្លីដូចរចនាបថមុនៗតែមានការរចនាលម្អខ្លាំងជាងមុន។ ជូនកាលមានជាយផ្នត់ធ្លាក់ពីចង្កេះខាងស្តាំមកសន្ធឹងលើភ្លៅខាងឆ្វេង។ នៅចំពីមុខ ក៏មានជាយរាងដូចកន្ទុយត្រីពីរជាន់។ ទេវរូបភេទស្រីស្លៀកសំពត់សារបាប់ជីប ៣ ផ្នត់ ល្អិតៗញឹក ទម្លាក់ដល់ក្រោម មានផ្នត់ ពីខាងមុខទម្លាក់ដល់ក្រោមរាងដូចកន្ទុយត្រី(រូបទី៦៥)។ គេសង្កេតឃើញថា បដិមានៅតាមជញ្ជាំងគេសង្កេតឃើញថា ជាប្រភេទចម្លាក់លៀនមានដូចជា៖


www.elibraryofcambodia.org

- ចម្លាក់លើជញ្ជាំងថែវជាន់ទី១មានជាក្បាច់រឿងចែកចេញជា ៨ ផ្ទាំង ហើយរៀងៗ៖

១- ជញ្ជាំងខាងលិចឆៀងខាងត្បូង ជាចម្បាំងរវាងពួកបាណ្ឌវៈ និង ពួកកៅរវៈ នៅគុរុក្សេត្រក្នុងរឿងមហាភារតៈ។

២- ជញ្ជាំងខាងត្បូងឆៀងខាងលិច ព្យុហយាត្រាកងទ័ពរបស់ព្រះបាទសូរ្យវរ្ម័នទី២។

៣- ជញ្ជាំងខាងត្បូងឆៀងខាងកើត រឿងឋានសួគ៌ ឋានកណ្តាលនិងឋាននរក។

៤- ជញ្ជាំងខាងកើតឆៀងខាងត្បូង រឿងកូរសមុទ្រទឹកដោះយកទឹកអម្រឹត។

៥- ជញ្ជាំងខាងកើតឆៀងខាងជើង រឿងជ័យជំនះរបស់ព្រះវិស្ណុលើពួកអសុរៈ។

៦- ជញ្ជាំងខាងជើងឆៀងខាងកើត រឿងចម្បាំងរវាងព្រះក្រឹស្ណៈ និងសុរវាណៈ ដកស្រង់ពីគម្ពីរហរិវង្ស។

៧- ជញ្ជាំងខាងជើងឆៀងខាងលិច រឿងចម្បាំងរវាងពួកទេវៈ និង អសុរៈ ក្នុងព្រហ្មញ្ញសាសនា។

៨- ជញ្ជាំងខាងលិចឆៀងខាងជើង រឿងចម្បាំងរវាងព្រះរាម និងក្រុង រាពណ៍ក្នុងរឿងរាមកេរ្តិ៍។

- រូបទេពអប្សរ នៅតាមជញ្ជាំងប្រាសាទដែលមានកាយវិការផ្សេងៗគ្នា ខ្លះឈរអោបពត់ពែន ខ្លះឈរធម្មតា ខ្លះពាក់ម្កុដកំពូលបីខ្ពស់ៗ និងស្លៀកសំពត់ផ្កាស្តើងៗ គ្មានផ្ទត់ដោយទម្លាក់ជាយសងខាង ម្ខាងធំ ម្ខាងតូច។ ទេពអប្សរខ្លះទៀតឥតមានពាក់ម្កុដទេ តែមានក្រងសក់ ជាច្រើនបែបយ៉ាង ។

### ២.២.៩- រចនាបថបាយ័ន (គ.ស.១១៨១ -១២២០ ពាក់កណ្តាលទី២ នៃសតវត្សទី១២ និងដើមសតវត្សទី១៣)

ដំណាក់កាលនៃរចនាបថបាយ័ន បានកសាងឡើងនៅក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧ (គ.ស.១១៨១ -១២១៨) ដែលបានគ្រងរាជ្យសម្បត្តិនៅរាជធានីអង្គរ។ ប្រាសាទសំខាន់ដែលស្ថិតនៅក្នុងរចនាបថនេះមាន៖



www.elibraryofcambodia.org

- ប្រាសាទតាព្រហ្ម
- ប្រាសាទបន្ទាយក្តី
- ប្រាសាទព្រះខ័ន
- ប្រាសាទនាគព័ន្ធ
- ប្រាសាទតាសោម
- ប្រាសាទតាណី
- ប្រាសាទនៅតាមជ្រុងនៃកំពែងអង្គរធំ
- ប្រាសាទបន្ទាយឆ្មារ
- ប្រាសាទបាយ័ន
- ប្រាសាទក្រោលគោ
- ព្រះលានជល់ដំរី
- ប្រាសាទតាព្រហ្មទន្លេបាទី និង
- ប្រាសាទវត្តនគរ(កំពង់ចាម) ។

- **ស្ថាបត្យកម្ម៖** ការកសាងប្រាសាទនៅក្នុងដំណាក់កាលនៃរចនាបថនេះ ហាក់ដូចជាមានការចុះថយបន្តិច បើប្រៀបធៀបនឹងដំណាក់កាលនៃរចនាបថមុន។ ស្ថាបត្យករបានកសាងប្រាសាទដោយលក្ខណៈប្រញាប់ប្រញាល់ ហើយថ្មដែលជ្រើសរើសយកមកកសាងសង់ក៏ពុំសូវមានគុណភាពល្អ និងច្រើនមានទំហំតូច។ ចំណែកប្លង់ប្រាសាទមានលក្ខណៈស្មុគស្មាញ មានការរុះរើកែតម្រូវឡើងវិញជាច្រើនលើកច្រើនសា ។ ប្រាសាទនៅក្នុងរចនាបថនេះ ច្រើនកសាងនៅលើដីរាបស្មើ លើកលែងតែប្រាសាទបាយ័នមួយប៉ុណ្ណោះ ដែលកសាងនៅលើខឿនច្រើនជាន់ជារបៀបប្រាសាទភ្នំ ហើយនៅលើប្រាង្គ មានរូបព្រះភ័ក្រ្តមុខបួន បែរមុខទៅគ្រប់ទិសទាំងបួន នៅស្ទើរគ្រប់ប្រាង្គទាំងអស់ (រូបទី ៦៦)។ ខាងក្រៅកំពែង ត្រង់ក្លោងទ្វារចូលទៅកាន់ទីក្រុងអង្គរធំ ស្ថាបត្យករបានកសាងស្ពានឆ្លងកាត់គូទឹក ដែលលម្អដោយបង្កាន់ដៃនាគ ក្បាលនាគបើកពពារបែងភាគចេញជាក្បាលប្រាំពីរ ដងខ្លួននាគត្រូវឱបរឹតទាញដោយពួកទេវតាម្ខាង ហើយម្ខាងទៀតដោយពួកអសុរៈ ដើម្បីកូរសមុទ្រទឹកដោះយកទឹកអម្រឹត ។
- **ផ្តែរ៖** មានផ្តែរខ្លះបានយកលំនាំតាមរចនាបថអង្គរ។ ក្បាច់ដងធ្នូដែលលម្អដោយក្បាច់ស្លឹកឈើមានរាងកោងកាច់ធ្លាក់ចុះក្រោមខ្លាំង។ ផ្តែរខ្លះទៀតមិន


www.elibraryofcambodia.org

មានក្បាច់ស្លឹកឈើទេ តែមានរាងជាក្បាច់ចង្វាយឬស្លឹកឈើដូចទម្ពក់ស្របគ្នា (រូបទី៦៧)។

- **សសរពេជ្រ** មានលម្អដោយក្បាច់ស្លឹកឈើលាតតូចញឹកល្អិតដូចធ្មេញរណារ។ ក្បាច់វល្លិមានច្រើនចាប់ពីក្រោមរហូតដល់លើ មានលក្ខណៈស្រដៀងគ្នា ហើយឆ្លាក់ជាក្បាច់ត្របកឈូកតូចៗសាំញ៉ាំ។
- **ហោជាង** តុបតែងលម្អស្ទើរតែដូចគ្នាទៅនឹងហោជាងនៃរចនាបថអង្គរវត្តដែរមានរាងដូចស្នាមជើងឆ្មា គ្រាន់តែមិនសូវមានក្បាច់លម្អស្មុគស្មាញដូចរចនាបថអង្គរ។ នៅខាងចុង សងខាងជង្គ្រារ គេច្រើនឆ្លាក់ជារូបរាហ៊ូ ឬ រូបមករ។ ផ្ទៃហោជាងច្រើនមានចម្លាក់ក្បាច់ រឿងទាក់ទងនឹងពុទ្ធប្រវត្តិ (រូបទី៦៨)។
- **បដិមាសាស្ត្រ៖** បដិមានៅក្នុងសិល្បៈបាយ័នច្រើនតែជារូបព្រះពុទ្ធ ព្រះអវលោកិតេស្វរ ព្រះភៃសជ្ជគុរុ និង ប្រាជ្ញាបារមិតាជាដើម ។ សិល្បករបានផ្តល់សារៈសំខាន់ និងយកចិត្តទុកដាក់លើទម្រង់មុខ មើលទៅរាងម៉ឺងម៉ាត់ញញឹមប្រកបដោយអាថ៌កំបាំង ឯភ្នែកភាគច្រើនសម្លឹងចុះក្រោម ឬ ស្ទើរតែបិទក្នុងឥរិយាបថធ្វើសមាធិ ឬ ឈាន។ រាងកាយ របស់បដិមាពុំមានការតុបតែងលម្អឲ្យបានផ្ចិតផ្ចង់ឡើយ។ សម្លៀកបំពាក់បដិមាបុរសគឺស្លៀកសំពត់សារបាប់ខ្លី រឹតចងដោយខ្សែក្រវាត់ សំពត់មានផ្នត់ទម្លាក់ចុះក្រោមពីខាងមុខ និង ខាងក្រោយរាងកន្ទុយត្រី។ ចំណែកបដិមាទ្វារបាល គេបានបន្តឆ្លាក់តាមរចនាបថអង្គរ។ ឯសម្លៀកបំពាក់បដិមាស្ត្រីពុំមានប្រើសំពត់ចាប់ក្បិនទេ គេនិយមលម្អដោយក្បាច់ផ្កាតូចៗដូចនៅក្នុងរចនាបថអង្គរវត្តដែរ ហើយជាយសំពត់ខាងមុខមានទម្លាក់ផ្នត់បត់ជារាងកន្ទុយត្រីឆ្លាម(រូបទី៦៩)។ នៅលើជញ្ជាំងថែវខាងក្រៅនៃប្រាសាទបាយ័ននិងប្រាសាទបន្ទាយឆ្មារ គេសង្កេតឃើញមានក្បាច់រឿងដែលទាក់ទងទៅនឹងប្រវត្តិសម័យព្រះបាទជ័យវរ្ម័នទី ៧ ដូចជាចម្បាំងរវាងខ្មែរនិងចាម និង បដិសណ្ឋារកិច្ច ចំពោះគណៈប្រតិភូបរទេសជាដើម ។ ម្យ៉ាងទៀត ក្បាច់រឿងនេះមានបង្ហាញសកម្មភាពផ្សេងៗ



www.elibraryofcambodia.org

នៃប្រជាពលរដ្ឋ ដូចជា នេសាទ កីឡា ល្បែងប្រជល់មាន់ជាដើម។ សម្លៀកបំពាក់ និងកាយវិការនៃរូបចម្លាក់ទាំងអស់មិនសូវខុសពីខ្មែរយើងសម័យបច្ចុប្បន្ននេះប៉ុន្មានទេ។ រីឯជញ្ជាំងថែវខាងក្នុងនៃប្រាសាទបាយ័នវិញ ក្បាច់រឿងច្រើនតែទាក់ទងនឹងសាសនា ដូចគ្នានឹងសម័យអង្គរវត្តដែរ។ ខឿននៃព្រះលានក៏មានចម្លាក់រឿងដែរ (ប៉ែកខាងត្បូងមានរូបដំរី កណ្ដាលមានរូបគ្រុឌ និង ប៉ែកខាងជើងមានរូបមនុស្សធំៗ)។ នៅលើជញ្ជាំងប្រាសាទ គេរចនារូបទេវតា ឬ ទេពអប្សរនៅក្នុងស៊ុមឡើងវិញ។ ទេវរូបទាំងនោះមានទឹកមុខស្រស់ប្រិមប្រិយល្អណាស់ ស្លៀកសំពត់ផ្កាគ្មានជីបជាផ្នត់ ដូចរចនាបថអង្គរវត្តដែរ ខុសតែត្រង់ឥតទម្លាក់ជាយសងខាង ព្រោះគេចូលចិត្តឲ្យមានជាយមួយផ្ទាំងធំនៅពីខាងមុខវិញ។ មកុដមានកំពូលច្រើនដែរ តែមានរបៀបរៀបរយជាងសម័យអង្គរវត្ត ដោយគេរៀបចំកំពូលឲ្យកើតជារាងត្រីកោណយ៉ាងច្បាស់លាស់ ដែលនាំឲ្យឃើញកំពូលទាបនៅខាង កម្ពស់ខ្ពស់នៅកណ្ដាល។ ក្នុងសម័យនេះ ការរចនារូបបដិមាមានការរីចម្រើនលូតលាស់ខ្លាំង។ គេមិនសូវគិតពីរាងរៅទេ គេខំផ្ចិតផ្ចង់តែទឹកមុខ។ បដិមាជាព្រះពុទ្ធរូបខ្លះជាព្រះពោធិសត្វលោកិតេស្វរៈ និង ខ្លះទៀតជាព្រះបរមរូបនៃព្រះបាទជ័យវរ្ម័នទី ៧ ។ បដិមាទាំងនេះមានភ្នែកសម្លឹងមកក្រោម ឬធ្មេចតែម្ដង មាត់ញញឹម មុខមានសភាពទន់ភ្លន់ បង្ហាញឲ្យឃើញថា មានការរីករាយពេញចិត្តឥតឧបមា គឺទឹកមុខញញឹមដោយស្រគត់ស្រគំ ។ បែបនេះហើយដែលធ្វើឲ្យសិល្បៈខ្មែរមានឈ្មោះល្បីខ្ចរខ្ចាក្នុងលោក ហើយអ្នកផងតែងឲ្យឈ្មោះទឹកមុខបែបនេះថា «**ញញឹមបែបបាយ័ន**»។

## ៣- រចនាសម្ព័ន្ធនិងសំណង់ប្រាសាទ

### ៣.១- រចនាសម្ព័ន្ធ

សំណង់ប្រាសាទទាំងឡាយជាទូទៅសុទ្ធសឹងប្រកបដោយរចនាសម្ព័ន្ធដូចខាងក្រោម៖



www.elibraryofcambodia.org

- **ជញ្ជាំង៖** ជញ្ជាំងធ្វើអំពីថ្មភក់ ឬថ្មបាយក្រៀម។ ថ្មបាយក្រៀម ដែលជារ៉ែមានជាតិដែក មានណ្ដានគ្រាប់ៗជាប់គ្នាដូចបាយក្រៀម មានពណ៌ក្រហម ខ្មៅស្វាយ ។ ថ្មបាយក្រៀមធន់នឹងអាកាសធាតុគ្រប់បែបយ៉ាង។ គេមិនឆ្លាក់លើថ្មប្រភេទនេះទេ តែគេប្រើសម្រាប់សាងសង់កំពែង ជណ្ដើរបុះ ទៅក្នុងស្រះខឿនប្រាសាទ និង ជញ្ជាំងប្រាសាទខ្លះដែរ។
- **វ្ទត៖** គេយកឥដ្ឋ ឬថ្មរៀបធ្វើដំបូលប្រាសាទឱ្យមានរាងជ្រលមដូចផ្កាឈូកដែលគេហៅថា *វ្ទត* ។ នៅស្រុកខ្មែរគេធ្វើវ្ទតដោយរៀបផ្ទាំងថ្ម ឬឥដ្ឋឲ្យលៀនចេញពីគ្នាបន្តិចម្ដងៗ រហូត ជួបគ្នា ដល់ដំបូលលើបង្អស់ ។
- **ទ្វារ បង្អួច៖** គេធ្វើក្របទ្វារ ប្រាសាទអំពីថ្មភក់។ ឯទ្វារបង្អួច គេច្រើនធ្វើទ្វារបង្អួចបិទជិត ភាគច្រើនធ្វើអំពីថ្មបាយក្រៀម ជួនកាលគេធ្វើចម្រឹងអំពីថ្មភក់ដាក់បញ្ឈរតាមបង្អួច។ នៅតាមជញ្ជាំងប្រាសាទខ្លះសិល្បករបានឆ្លាក់ទ្វារនិង បង្អួចបញ្ឆោត។
- **ផ្ដែរ៖** ច្រើនមានទំហំធំ និងទម្ងន់ធ្ងន់ដែលទ្រដោយសសរពេជ្រ (colonnette) ពីរ។ ធម្មតា គេធ្វើផ្ដែរពីរជាន់ ផ្ដែរទី១ជាផ្ទាំងថ្មធម្មតា(ផ្ដែរសម្រាប់ទ្រ) ឯផ្ដែរទី២ ជាផ្ទាំងថ្មដែលគេរចនាដោយក្បាច់ក្បូរឬ រូបផ្សេងៗហើយដែលដាក់បិទពីមុខផ្ដែរទី១ (ផ្ដែរសម្រាប់លម្អ)។ គេបានសង្កេតឃើញថា ក្បាច់លម្អនៅលើផ្ដែរ និងលើសសរពេជ្រ មានការវិវឌ្ឍហូរហែពី រចនាបថមួយទៅរចនាបថមួយទៀត។

គេតែងចាត់ទុកថាប្រាសាទជាលំនៅរបស់អាទិទេព។ ប្រាង្គប្រាសាទដែលជាលំនៅរបស់អាទិទេពមានទំហំតូច។ អ្នកដែលអាចចូលទៅក្នុងប្រាសាទនេះបាន មានតែពួកព្រាហ្មណ៍បុរោហិត និង ពួកថែរក្សាប្រាសាទ។ គេច្រើននិយមធ្វើប្រាង្គអាទិទេពនោះរាងសាជី ហើយចាត់ទុកជាតំណាងភ្នំព្រះសុមេរុ ដែលជាទេវស្ថានរបស់អាទិទេពក្នុងសាសនាព្រាហ្មណ៍។ ប្រាង្គនេះស្ថិតនៅចំអ័ក្សនៃប្រាសាទនិងនៅចំកណ្ដាលប្រាង្គ


www.elibraryofcambodia.org

ឯទៀតៗដែលជាលំនៅរបស់ទេវៈរាយរង និងជាលំនៅរបស់យានជំនិះនៃអាទិទេព (ត្រឹង ងា ១៩៧៤ ទំព័រ ១២៣)។

ប្រាសាទខ្លះទៀត គេសន្និដ្ឋានថាជាបណ្ណាល័យ តែអ្នកខ្លះបានអះអាងថា ជាកន្លែងទុកដាក់សម្ភារៈផ្សេងៗសម្រាប់ពិធីទៅវិញ ។ម្យ៉ាងទៀត គេបានសង្កេតឃើញថា នៅក្បែរប្រាសាទ មានស្រះទឹកមួយជានិច្ច។ នៅមាត់ជណ្ដើរឡើងទៅកំពែងនីមួយៗ មានគោបុរៈដែលជាទ្វារដែលមានដំបូលរាងដូចប្រាង្គកណ្ដាល តែមានរាងតូចជាង ។ នៅពីមុខប្រាង្គកណ្ដាលមានថែវម្យ៉ាងដែលភ្ជាប់ទៅនឹងប្រាង្គនោះ គេនិយមហៅថា «មណ្ឌប» ។

## ៣.២- ប្រភេទនៃប្រាសាទ

សំណង់នៃប្រាសាទមានច្រើនប្រភេទមានដូចជា៖

- *ប្រាសាទដែលមានប្រាង្គតែមួយ ហើយសង់ដាច់តែឯង* មាន ប្រាសាទបាយ័ង្គ ប្រាសាទភ្នំបាសិទ្ធ ប្រាសាទភូមិប្រាសាទជាដើម ។
- *ប្រាសាទដែលមានប្រាង្គច្រើន នៅលើខឿនតែមួយជាន់* មាន ប្រាសាទព្រះគោ ប្រាសាទ លលៃជាដើម ។
- *ប្រាសាទដែលសង់លើដីរាបស្មើគ្មានខឿនទេ* (សង់ផ្ទាល់ដីរាបស្មើ) មាន ប្រាសាទភូមិប្រាសាទ ប្រាសាទព្រះខាន់ជាដើម។
- *ប្រាសាទភ្នំ* មានប្រាសាទបាគង ប្រាសាទបាខែង ប្រាសាទកោះកេរ ប្រាសាទប្រែរូប ប្រាសាទតាកែវ ប្រាសាទបាពួន និងប្រាសាទអង្គរវត្តជាដើម ដែលសង់នៅលើខឿនច្រើនជាន់ មានជណ្ដើរគ្រប់ទិសទាំងបួន កំពែងច្រើនជាន់ និងគូទឹកព័ទ្ធជុំវិញជានិមិត្តរូបនៃភ្នំព្រះសុមេរុ ដែលជាលំនៅរបស់អាទិទេពក្នុងសាសនាព្រាហ្មណ៍។ គេសាងប្រាសាទភ្នំ សម្រាប់ធ្វើពិធីទេវរាជលើកតម្កើងមហាក្សត្រជាតំណាងអាទិទេព ដោយយកសិវលិង្គទៅតម្កល់នៅក្នុង


www.elibraryofcambodia.org

ប្រាសាទទាំងនោះទុកជាគោលនៃការគោរព នមស្សការ។ គូទឹកព័ទ្ធជុំវិញជានិមិត្តរូបនៃមហាសមុទ្រ។

**៣.៣- មុខងារនៃប្រាសាទ**

ប្រាសាទបុរាណរបស់ខ្មែរយើងមានមុខងារសម្រាប់៖

- ឧទ្ទិសថ្វាយអាទិទេព ឬទេវៈផ្សេងៗក្នុងសាសនាព្រាហ្មណ៍
- ឧទ្ទិសថ្វាយព្រះពោធិសត្វក្នុងសាសនាព្រះពុទ្ធ
- ឧទ្ទិសថ្វាយទេវរាជ(តម្កល់សិវលិង្គតំណាងព្រះរាជា)
- ឧទ្ទិសថ្វាយបុព្វបុរស ព្រះរាជាមានមាតា ព្រះបិតា និងវីរជនស្នេហាជាតិ។

**៣.៤- តម្លៃនៃស្ថាបត្យកម្មខ្មែរ**

ការអធិប្បាយកន្លងមកបង្ហាញឲ្យឃើញថា ស្ថាបត្យកម្មខ្មែរមានការវិវឌ្ឍឥតឈប់ឈរ ពីសម័យមួយទៅសម័យមួយហើយកាន់តែល្អតលាស់ជាលំដាប់ផង។ ត្រង់នេះបង្ហាញឲ្យឃើញថាស្ថាបត្យករខ្មែរមានទេពកោសល្យខ្ពង់ខ្ពស់ណាស់។ ក្រៅពីការផ្សំផ្គុំធ្វើសំយោគសិល្បៈបរទេស និងសិល្បៈខ្មែរ បង្កើតឲ្យបានសិល្បៈថ្មីមួយទៀត ស្ថាបត្យករខ្មែរនៅមានទេពកោសល្យពិសេសម្យ៉ាងទៀត គឺការបង្កើតសិល្បៈខ្មែរស្របតាមទស្សនៈខ្មែរថែមទៀត។

ឧទាហរណ៍៖ នៅសម័យភ្នំដា ខ្មែរបានលុងភ្នំធ្វើប្រាសាទតាមឥណ្ឌាដែរ តែដល់ក្រោយមកទៀត ស្ថាបត្យករខ្មែរបានច្នៃប្រឌិតជំនឿគោរពទីខ្ពស់ដោយកសាងប្រាសាទភ្នំ។ ទស្សនៈគោរពទីខ្ពស់នេះ ខ្មែរមានរួចមកហើយតាំងពីបុរេប្រវត្តិម្ល៉េះ លុះឥណ្ឌាចូលមក ទស្សនៈទាំងពីរស្របគ្នាតែម្តង។

ឯបង្កាន់ដៃរូបនាគអមសងខាងផ្លូវទៅកាន់ប្រាសាទនីមួយៗ និងគូទឹកព័ទ្ធជុំវិញដែលជានិមិត្តរូប នៃការកូរសមុទ្រទឹកដោះក្នុងទស្សនៈឥណ្ឌាសម័យដើម ក៏បានក្លាយមកជានិមិត្តរូបនៃនយោបាយទឹករបស់ខ្មែរសម័យអង្គរ។ ចំណុចនេះបញ្ជាក់ឲ្យឃើញថាសិល្បៈស្ថាបត្យកម្មខ្មែរមិនគ្រាន់តែជានិមិត្តរូបផ្នែកសាសនាប៉ុណ្ណោះទេ វាក៏បម្រើឲ្យផលប្រយោជន៍មនុស្សដែរ។


www.elibraryofcambodia.org





១- ប្រាសាទចោះភ្នំនៅលើភ្នំដា

២-ប្រាសាទអាស្រមមហាឫសី







៣-ព្រះក្រឹស្ណគោវធ៌ន (វត្តកោះ) ៤-ព្រះវិស្ណុដៃប្រាំបី (ភ្នំដា) ៥-ព្រះពលរាម (ភ្នំដា)



www.elibraryofcambodia.org



៦- ព្រះបរាសុរាម (ភ្នំដា)



៧-ព្រះពុទ្ធរូប(វត្តរំលក)



៨-ព្រះពោធិសត្វអវលោកិ-តេស្វរៈសំរិទ្ធ(វត្តកំពង់លួង)



៩-សម្លៀកបំពាក់បដិមាភេទប្រុស



១០-ព្រះហរិហរៈរចនាបថភ្នំដា



១១-បង្អួចបញ្ឆោតមាន ចម្លាក់របៀបជាប្រាសាទអណ្តែត



www.elibraryofcambodia.org





១២- ប្លង់ប្រាសាទសម្បូណ៌ព្រៃគុហ៍ រាងចតុកោណកែង (ប្រាង្គ S1) និងប្លង់





១៣- ប្រាសាទសម្បូណ៌ព្រៃគុហ៍ រាងអដ្ឋកោណ (ប្រាសាទ S11) និង ប្លង់



www.elibraryofcambodia.org



១៤- ផ្តែរនៃប្រាសាទសម្បូណ៌ព្រៃគុហ៍ S7



១៥-សសរពេជ្រ ប្រាសាទសម្បូណ៌ព្រៃគុហ៍ S1



១៦-ហោជាងប្រាសាទ សម្បូណ៌ព្រៃគុហ៍ N1



១៧- ព្រះហរិហរៈ ( ប្រាសាទ សម្បូណ៌ព្រៃគុហ៍ )



www.elibraryofcambodia.org







២០-ប្រាសាទអណ្តែត ខេត្តកំពង់ធំ

១៨- ព្រះនាងទុគ៌ា
(ប្រាសាទសម្បូណ៌
ព្រៃគុហ៍)

១៩-ព្រះនាងលក្ស្មី
កោះក្រៀង
ខេត្តក្រចេះ



២១-ផ្តែរចនាបថព្រៃក្មេងសារមន្ទីរជាតិភ្នំពេញ



www.elibraryofcambodia.org



២២-សសរពេជ្រ
ប្រាសាទ
ព្រៃប្រាសាទ
រចនាបថ
ព្រៃក្មេង



២៣-ព្រះនាង
ទុគ៌ា
ទួលកំណប់
ខេត្តព្រៃវែង



២៤-ព្រះ
ហរិហរៈ
ប្រាសាទ
អណ្តែត



២៥- ប្រាសាទកំពង់ព្រះ ខេត្តកំពង់ឆ្នាំង



www.elibraryofcambodia.org



២៦- ផ្តែរនៃប្រាសាទភូមិប្រាសាទ ខេត្តកំពង់ធំ



២៧- ប្រាសាទអ្នកតា រចនាបថគូលែន

២៩-
សសរ
ពេជ្រ
រចនា
បថ
គូលែន



២៨- ផ្តែររចនាបថគូលែន



www.elibraryofcambodia.org



៣០- ហោជាងរចនាបថគូលែន



៣១- ព្រះវិស្ណុរចនាបថគូលែន



៣២- ការតុបតែងព្រះកេស រចនាបថគូលែន



៣៣- សម្លៀកបំពាក់
រចនាបថគូលែន



www.elibraryofcambodia.org



៣៤- ប្រាសាទព្រះគោ
ខេត្តសៀមរាប



៣៥- ប្រាសាទបាគង
ខេត្តសៀមរាប



៣៦- ផ្តែររចនាបថព្រះគោ ខេត្តសៀមរាប



www.elibraryofcambodia.org





៣៨- ហោជាងរចនាបថព្រះគោ



៣៧- សសរពេជ្រ
រចនាបថព្រះគោ

៣៩- ព្រះវិស្ណុ
រចនាបថព្រះគោ



៤០- ព្រះសិវៈ រចនាបថ
ព្រះគោ



៤១- ប្រាសាទភ្នំបាខែង ខេត្តសៀមរាប



www.elibraryofcambodia.org



៤២- ផ្តែររចនាបថបាខែង



៤៣- ព្រះសិរ:
រចនាបថបាខែង



៤៥- សសរពេជ្រ
រចនាបថកោះកេរ



៤៤- ប្រាសាទកោះកេរ ខេត្តព្រះវិហារ



www.elibraryofcambodia.org



៤៦- ហោជាងរចនាបថកោះកេរ



៤៧- បដិមាសុគ្រីពប្រយុទ្ធ
នឹងពាលី ( កោះកេរ )



៤៨- បដិមាគ្រុឌ រចនាបថកោះកេរ



៤៩-សម្លៀកបំពាក់ ទេវរូបភេទប្រុស
កោះកេរ


www.elibraryofcambodia.org





៥០-សម្លៀកបំពាក់
ទេវរូបភេទស្រី
កោះកេរ



៥២-
សសរ
ពេជ្រ
រចនាបថ
បន្ទាយស្រី



៥១- ប្រាសាទបន្ទាយស្រី ខេត្តសៀមរាប



៥៣- ហោជាង មួយបែបទៀត
របស់រចនាបថបន្ទាយស្រី



www.elibraryofcambodia.org



៥៤- ចម្លាក់ព្រះសិវៈ
និងនាងឧមា
រចនាបថបន្ទាយស្រី



៥៥- ប្រាសាទតាកែវ
រចនាបថឃ្លាំង



៥៦- ផ្តែររចនាបថឃ្លាំង



www.elibraryofcambodia.org



៥៧- ហោជាង
រចនាបថឃ្លាំង



៥៨- ប្រាសាទបាពួន ខេត្តសៀមរាប



៥៩- ផ្តែរចនាបថ បាពួន


www.elibraryofcambodia.org



៦០- ការតុបតែងព្រះកេស និង សម្លៀកបំពាក់ ទេវរូបភេទស្រីនិងភេទប្រុស
រចនាបថបាពួន



៦១- ប្រាសាទអង្គរវត្ត ខេត្តសៀមរាប



www.elibraryofcambodia.org



៦២- ផ្តែរ រចនាបថអង្គរវត្ត





៦៤- ហោជាង រចនាបថអង្គរវត្ត

៦៣- សសរពេជ្រ
រចនាបថអង្គរវត្ត



www.elibraryofcambodia.org



៦៥- សម្លៀកបំពាក់ទេវរូបភេទប្រុស និង ភេទស្រី រចនាបថអង្គរវត្ត



៦៦- ប្រាសាទបាយ័ន



www.elibraryofcambodia.org



៦៧- ផ្តែររចនាបថបាយ័ន



៦៨- ហោជាង រចនាបថបាយ័ន



www.elibraryofcambodia.org



៦៩- សម្លៀកបំពាក់
ទេវរូបភេទប្រុស
និងភេទស្រី
របនាបថបាយ័ន



www.elibraryofcambodia.org

# ២
# សិល្បៈចម្លាក់បុរាណខ្មែរ

## ១- មុខងារនៃចម្លាក់

ក្នុងសិល្បៈចម្លាក់ខ្មែរបុរាណ រូបចម្លាក់មានមុខងារសំខាន់ពីរយ៉ាងគឺ៖

- ចម្លាក់សម្រាប់បូជា៖ ដូចជាបដិមាព្រះពុទ្ធ ព្រះពោធិសត្វ ព្រះសិវៈ និងព្រះវិស្ណុ ជាដើម ។

- ចម្លាក់សម្រាប់លម្អ៖ ដូចជាចម្លាក់ក្បាច់ក្បូរផ្សេងៗ ចម្លាក់ភ្ញីផ្កាជាដើម ។

## ២- ប្រភេទចម្លាក់

ចម្លាក់បុរាណខ្មែរមានបីយ៉ាងគឺ ចម្លាក់លឹប/ចម្លាក់ចាក់/ចម្លាក់ក្រលោតទាប ចម្លាក់លៀន/ចម្លាក់ជ្រៅ/ចម្លាក់ក្រលោតខ្ពស់ និងចម្លាក់លោត/បដិមា ។

### ២.១- ចម្លាក់លឹប

*ចម្លាក់លឹប* ជាក្បាច់ដែលគេឆ្លាក់រាក់ៗនៅលើផ្ទាំងថ្ម លឹបចូលទៅក្នុងផ្ទាំងថ្ម មើលទៅមិនសូវឃើញខ្ពស់ឬផុសចេញពីផ្ទាំងថ្មខ្លាំងពេកទេ ។ ឧទាហរណ៍, ក្បាច់រឿង នៅតាមថែវជាន់ទី ១ នៃប្រាសាទអង្គរ (គេច្រើនឆ្លាក់នៅលើជញ្ជាំងប្រាសាទ) ។

### ២.២- ចម្លាក់លៀន

*ចម្លាក់លៀន* គឺជាក្បាច់ចម្លាក់ដែលបានមកដោយការដាប់សាច់ថ្មឲ្យជ្រៅ ដើម្បីឲ្យរូបនោះ មើលទៅ ដូចជាផុសខ្ពស់ចេញពីផ្ទៃថ្ម (លៀនហួសផ្ទៃថ្ម) ។ គេច្រើនឆ្លាក់ ចម្លាក់ប្រភេទនេះនៅលើផ្ដែរ លើសសរពេជ្រ លើជញ្ជាំងប្រាសាទ។ ឧទាហរណ៍, រូបទេពអប្សរ ទ្វារបាល ជាដើម ។

### ២.៣- ចម្លាក់លោត

*ចម្លាក់លោត* ជាចម្លាក់ពេញលេញដាច់ពីជញ្ជាំង ពោលគឺមិនមានផ្ទៃថ្មពីក្រោយ។ គេឆ្លាក់ចម្លាក់ប្រភេទនេះជារូបសត្វ ឬ មនុស្ស ដោយដាក់តាំងនៅមុខ ឬ កណ្ដាលប្រាសាទសម្រាប់គោរពបូជា ។ នៅដំណាក់កាលដំបូងៗ គេផ្អែកចម្លាក់នេះ



www.elibraryofcambodia.org

ទៅជាប់នឹងជញ្ជាំងប្រាសាទដោយទម្រ (ព្រោះខ្លាចដួលរលំ) ក្រោយមកទៀត គេក៏ឆ្លាក់រូបបដិមាដាច់តែឯងពុំមានទម្រដូចមុនទៀតឡើយ ។

## ៣- ប្រធាននៃចម្លាក់

ប្រធានចម្លាក់គឺរូបដែលគេត្រូវឆ្លាក់ ។ រូបចម្លាក់បុរាណមានច្រើនបែបយ៉ាងណាស់ តែពេលនេះយើងលើកយករូបចម្លាក់ (បដិមានិងសត្វ) ដែលទាក់ទងនឹងសាសនាដែលមាននៅជាប់ជាមួយប្រាសាទបុរាណខ្មែរ ។

### ៣.១- ពុទ្ធប្បដិមា

គេបានរកឃើញថា ព្រះពុទ្ធប្បដិមាខ្មែរមានតាំងពីសម័យនគរភ្នំមកម្ល៉េះ។ ក្នុងសិល្បៈខ្មែរ ព្រះពុទ្ធរូបគ្មានគ្រឿងអលង្ការទេ ប៉ុន្តែគេអាចសម្គាល់ពុទ្ធប្បដិមាបានដោយលក្ខណៈ និង កាយវិការ (មុទ្រៈ) ដូចជា៖

- គ្រងស្បង់ និង គ្រងចីវរដោយលែងស្នាស្តាំ ។ ពេលខ្លះ គេឆ្លាក់ស្បង់ចីវរស្តើងមើលទៅ ឃើញដូចជាជាប់នឹងសាច់ព្រះកាយព្រះពុទ្ធ ដើម្បីបង្ហាញថា ក្រោយត្រាស់ដឹងព្រះពុទ្ធបានជម្រះអស់ នូវអវិជ្ជា ហើយមានតែពន្លឺនៃវិជ្ជាដែលចាំងចេញពីព្រះកាយព្រះអង្គ ។ (រូបលេខ ៧ នៃមេរៀនសិល្បៈ ស្ថាបត្យកម្ម)



- មានសញ្ញាមួយនៅចន្លោះភ្នែក
- មានពកឬបន្តុបនៅតាលព្រះកេស
- មានសក់ច្រើនរួញ ហើយក្ងចគ្របាញ់ជុំៗ
- មានមុខមូលពងក្រពើ
- មានត្រចៀកធំៗហើយវែងធ្លាក់ទៅក្រោម
- មានទឹកមុខញញឹម
- មានកងចក្រនៅបាតព្រះហស្ត ។

- **ឈានមុទ្រៈ** (សមាធិមុទ្រៈ) គឺកាយវិការធ្វើសមាធិ ដោយព្រះអង្គទ្រង់ភ្នែនផ្កាព្រះហស្តទាំងពីរដាក់លើភ្លៅ។



www.elibraryofcambodia.org

- **ភូមិស្បស់មុទ្រ**:គឺកាយវិការយកព្រះធរណីជាសាក្សី។ ព្រះអង្គយកព្រះហស្ត ឆ្វេងដាក់លើភ្លៅ ហើយដាក់ព្រះហស្តស្តាំលើជង្គង់សំយុងចង្អុលទៅដី។ កាយវិការនេះ កើតមានកាលដែលមារមកករាំងកុំឲ្យព្រះអង្គត្រាស់ដឹងបាន។ មារបានដេញព្រះអង្គ ឲ្យចុះពីបល្ល័ង្កគេន៍(ផ្កាឈូក) ដោយអាងរេហ៍ពលថា បល្ល័ង្កនោះជារបស់ខ្លួន ។ កាលនោះ ព្រះអង្គបានប្រកាសនិងធ្វើកាយវិការយកព្រះធរណី (នាង គង្ហីង) ជាសាក្សី វេលានោះ នាងគង្ហីងបង្ហាញខ្លួន និង ច្បូតសក់បង្កើតជាទឹកជំនន់ដែលបណ្តាលឲ្យ ទ័ពមារលិចលង់ និង ត្រូវក្រពើខាំស្លាប់អស់ទៅ ។

- **អភយមុទ្រ**:គឺកាយវិការប្រាប់ថាកុំឲ្យភ័យ។ នេះគឺកាយវិការដែលព្រះអង្គលា ព្រះហស្តទៅមុខ និង ចង្អុលលើកទៅលើ។

- **ធម្មចក្រមុទ្រ**:គឺកាយវិការសម្តែងធម៌ ។ នេះគឺកាយវិការដែលព្រះអង្គទ្រង់ សម្តែងដោយធ្វើព្រះហស្តទាំងពីរដូចជាបង្វិលកងចក្រ ។

- **វរមុទ្រ**:គឺកាយវិការឲ្យពរឬ សម្តែងសប្បុរសធម៌ឬទាន។ នេះគឺកាយវិការដែល ព្រះអង្គទ្រង់ លាព្រះហស្តបែរទៅខាងមុខ ដាក់សម្រាកទៅក្រោមស្របនឹងព្រះបាទ ។

- **វិតក្កមុទ្រ**:គឺកាយវិការត្រិះរិះពិចារណាឬមានន័យថា កុសលដែលធ្វើហើយ ចូរធ្វើថែមទៀតឲ្យបានរឹតតែមាំឡើង។ នេះគឺជាកាយវិការដែលព្រះអង្គយកម្រាម ចង្អុលមកប៉ះនឹងមេដៃ ។

- **ទុក្ករកិរិយាមុទ្រ**:គឺកាយវិការនៃអំពើធ្វើបានដោយកម្រ ។ នេះគឺកាយវិការ ដែលព្រះអង្គមានព្រះកាយស្គមស្គាំង មានតែស្បែកនិងឆ្អឹង ។ ព្រះអង្គជ្រើសរើសយក ការបង្អត់អាហារ (តាមលទ្ធិព្រាហ្មណ៍) ដើម្បីតាំងចិត្ត ធ្វើភាវនា ស្វែងរកធម៌អាថ៌កំបាំង រហូតដល់ព្រះអង្គមានព្រះកាយស្គមស្គាំង មានតែស្បែកនិងឆ្អឹងដូច្នេះ ។

- **នាគមុទ្រ**: ឬព្រះពុទ្ធប្រក់នាគគឺកាយវិការដែលព្រះពុទ្ធទ្រង់គង់សមាធិលើ ក្អែននាគមុច្ចលិន ដែលបើកពពារការពារពីលើព្រះកេសព្រះអង្គ។ ពុទ្ធប្បដិមាប្រក់នាគ ជាព្រះពុទ្ធរូបបែបខ្មែរសុទ្ធសាធ ព្រោះមាននៅក្នុងរចនាបថខ្មែរមុនរចនាបថឯទៀត។

- **បាត្រាទានមុទ្រ**:គឺកាយវិការឱបបាត្រ ។ តាមប្រពៃណីពុទ្ធសាសនា ព្រះពុទ្ធក្តី



www.elibraryofcambodia.org

ព្រះសង្ឃក្តី ចេញនិមន្តបិណ្ឌបាត ។

- **សយនមុទ្រៈ** គឺកាយវិការព្រះពុទ្ធផ្ទំ (ឬចូលនិព្វាន) ផ្អៀងព្រះកាយទៅខាងស្តាំ ព្រះបាទ ឆ្វេងដាក់លើព្រះបាទស្តាំ ដោយយកបាតនៃព្រះហស្តស្តាំមកប៉ះព្រះកេស ហើយដាក់ព្រះហស្តឆ្វេង សណ្តូកលើព្រះកាយ។

### ៣.២- ព្រះស្តូប-ព្រះចេតិយ

**ស្តូបច្រើនកសាងឡើងជាតំណាងចេតិយ ពោលគឺសម្រាប់រំឭកវិញ្ញាណក្ខន្ធបុគ្គល ដែលស្លាប់ទៅហើយ ប៉ុន្តែពុំមានកន្លែងសម្រាប់ដាក់ធាតុទេ ។** ព្រះស្តូបមានរាងមូល (ដូចបាត្រផ្កាប់) ឬជាចេតិយតូចរាបដែលមានរាងស្រដៀងនឹងសណ្ឋានអកកំបោរ ឬ សណ្ឋានចេតិយខ្សាច់។

ឯព្រះចេតិយមានរាងដូចអកកំបោរមានក្បាច់រចនាជាទីសម្រាប់តម្កល់ធាតុ ឬ ព្រះសិរីរិកធាតុ អរហន្តធាតុ ។ ព្រះចេតិយមានបួនបែបគឺៈ

- **ធាតុចេតិយ** សម្រាប់ដាក់ធាតុ
- **បរិភោគចេតិយ** សម្រាប់ដាក់គ្រឿងប្រើប្រាស់ មានបាត្រចីវរ របស់ព្រះពុទ្ធ
- **ធម្មចេតិយ** សម្រាប់តម្កល់ក្បួនខ្នាតគម្ពីរដីកាដូចជាធម្មមន្ទីរហោត្រ័យជាដើម
- **ឧទ្ទេសិកចេតិយ** ទីដែលសម្រាប់ឧទ្ទិសថ្វាយព្រះពុទ្ធ ឬបុព្វបុរសផ្សេងៗ ។

### ៣.៣- ព្រះពោធិសត្វ (ព្រះពុទ្ធសាសនានិកាយមហាយាន)

- លោកិតេស្វរៈជាពោធិសត្វជួយសង្គ្រោះនិងឲ្យសុខដល់សត្វលោក។ គេឆ្លាក់រូបពោធិសត្វ លោកិតេស្វរៈគង់លើផ្កាឈូក មានព្រះហស្តច្រើនទ្រង់កេតនភណ្ឌផ្សេងៗ មានគម្ពីរ ខ្សែផ្កាំ ដបឬថុផ្កាឈូកជាដើម មានគ្រឿងអលង្ការ ៨ មានផ្នួងសក់ធំ ហើយនៅលើផ្នួងសក់មានព្រះពុទ្ធរូបមួយឈ្មោះអមិតាភៈ(Amitabha) ។ (រូបលេខ ៨ នៃមេរៀនសិល្បៈស្ថាបត្យកម្ម)

- មញ្ជុស្រី ជាព្រះពោធិសត្វតុលាការ។ គេធ្វើរូបមនុស្សកាន់សៀវភៅមួយ និងព្រះខ័នមួយគង់លើសត្វតោ។

- សមន្តភទ្រៈជាពោធិសត្វគ្រប់គ្រងសាសនិក ។ គេធ្វើរូបមនុស្សគង់លើសត្វ



www.elibraryofcambodia.org

ជំរី។

- មៃត្រេយ ជាពោធិសត្វដែលនឹងបានត្រាស់ជាព្រះពុទ្ធបន្ទាប់ពីព្រះពុទ្ធសមណៈគោតម ។

- ក្សិតិគភ៌ ជាពោធិសត្វស្រង់មនុស្សពីនរក ។

- វជ្របាណិ ជាពោធិសត្វការពារសាសនា ។ គេធ្វើរូបមនុស្សកាន់រន្ទះ ។

- ប្រាជ្ញាបារមីតា ជាពោធិសត្វស្រី ជានិមិត្តរូបនៃប្រាជ្ញា ។

### ៣.៤- សិវលិង្គ

គេតែងឆ្លាក់សិវលិង្គតម្កល់លើយោនីនាងឧមា ដាក់កណ្ដាលបំមប្រាសាទ ទុកគោរពបូជា ។ ជញ្ជាំងប្រាសាទខ្លះ ដែលមានតម្កល់លិង្គព្រះឥសូរនិងយោនីនាងឧមានេះ គេចោះដាក់មាត់យោនីបដិមាឲ្យលេចចេញក្រៅ ដើម្បីបង្ហូរទឹកដែលគេចាក់លើលិង្គព្រះឥសូរ ហើយបង្ហូរមកវិញតាមយោនីនាងឧមានោះ។ លិង្គនិងយោនីនេះជានិមិត្តរូបនៃការកំណើត ។

មានរឿងដំណាលថា មានឥសីមួយក្រុមបានផ្អាកការតាំងសីល ហើយចូលទៅសុំជួបប្រណិប័តន៍ព្រះឥសូរ តែត្រូវឆ្មាំទ្វារហាមឃាត់ដោយសារតែព្រះឥសូរកំពុងផ្ទំជាមួយនាងឧមា ។ ចាំយូរពេក ដោយខឹងនឹងអ្នកយាមផង ឥសីក៏ដាក់បណ្ដាសាឲ្យព្រះឥសូរមានរូបរាងត្រឹមតែលិង្គ (ខ្មាសបុរស) ឯនាងឧមាមានរូបរាងត្រឹមតែយោនី (ខ្មាសស្ត្រី) ចាប់ពីពេលនោះមក ។ ដោយបណ្ដាសានេះ ទើបព្រះឥសូរនិងនាងឧមាមានរូបរាងជាលិង្គនិងយោនីរហូតមក។



នាសម័យអង្គរ គេឃើញ មានចម្លាក់រូបលិង្គព្រះឥសូរ ដែលគេឆ្លាក់អំពីថ្មពណ៌ប្រផេះ តំណាងលទ្ធិត្រីមូ៌តិ (ការគោរពអាទិទេពធំបី)។



www.elibraryofcambodia.org

សិវលិង្គបែបនេះមានបីថ្នាក់៖

- ផ្នែកលើមានរាងមូលវែងដូចសសរ
- ផ្នែកកណ្តាលមានរាង ៨ ជ្រុងស្មើទម្រ ដែរ
- ផ្នែកក្រោយមានរាង ៤ ជ្រុងស្មើជាទម្រដែរ ។

នៅលើរូបលិង្គខ្លះ គេឆ្លាក់មុខមនុស្ស លិង្គបែបនេះគេហៅថា *មុខលិង្គ* ។

**៣.៥- ព្រះនារាយណ៍**

គេឆ្លាក់រូបមនុស្សដែលច្រើនតែមានដៃ ៤ មានកេតនកណ្តាផ្សេងៗមាន ជាស ខ្យងស័ង្ខ មោង ដុំមូល(ផែនដី) ឬផ្កាឈូក ម្កុដមូលវែង ។ នៅជញ្ជាំងប្រាសាទអង្គរវត្ត គេប្រទះឃើញព្រះនារាយណ៍ជិះគ្រុឌឬព្រះនារាយណ៍ផ្ទំលើពស់ឈ្មោះសេសៈ នៅកណ្តាលសមុទ្រមានដើមឈូកដុះចេញពីផ្ចិតហើយនៅលើផ្កាឈូកមានរូបព្រះព្រហ្ម ។

**៣.៦- ព្រះហរិហរៈ**

គេរកឃើញថា បដិមាព្រះហរិហរៈនៅប្រទេសខ្មែរមានកំណើតតាំងពីស.វ.ទី ៦ នៃគ.ស. ម្ល៉េះ ឯប្រទេសឥណ្ឌាវិញ បដិមាព្រះហរិហរៈមានកំណើតនៅស.វ.ទី ២០ នៃគ.ស.។ គេបានសាងរូបបដិមា ហរិហរៈ ជារូបអាទិទេពឥសូរនៅចំហៀងខាងស្តាំ និងអាទិទេពវិស្ណុនៅចំហៀងខាងឆ្វេង ហើយបដិមានេះរាងសមសួនល្អណាស់។ (សូមមើលរូបលេខ ១០, ២១ និង ២៦ នៃមេរៀនសិល្បៈស្ថាបត្យកម្ម)។ ពេលខ្លះទៀត គេសង្កេតឃើញ រូបព្រះហរិហរៈជារូបមនុស្សដៃបួន កាន់កេតន-កណ្តាព្រះវិស្ណុផង ព្រះសិវៈផង ។

**៣.៧- អប្សរា**

*អប្សរា* គឺជាទេវតាពួករបាំ ដែលតាមជំនឿព្រហ្មញ្ញសាសនា កើតពីការកូរសមុទ្រទឹកដោះ។ គេសង្កេតឃើញ អប្សរាមានសម្លៀកបំពាក់ និង គ្រឿងអលង្ការខុសៗគ្នា អាស្រ័យទៅតាមសម័យកាល និង តួនាទីរបស់អប្សរានោះនៅក្នុងរបាំ (ឧ. ជាតួឯង តួរង ។ល។) នៅ ប្រាសាទអង្គរវត្ត គេច្រើនឆ្លាក់អប្សរាគូៗឬច្រើន។

**៣.៨- សត្វ**

ក្រៅពីឆ្លាក់អាទិទេព សិល្បករខ្មែរក៏មានឆ្លាក់រូបសត្វដែលពាក់ព័ន្ធនឹងសាសនា



www.elibraryofcambodia.org

និង ជីវភាព រស់នៅរបស់ខ្មែរ ដែរ ។ សត្វទាំងនោះមានដូចជា *មករ នាគ គោ គ្រុឌ គោ សេះ ក្របី មាន់* ជាដើម ។

*មករ* ៖ មករជាសត្វកើត ពីការស្រមើស្រមៃរបស់មនុស្សសម័យបុរាណ។ គេជឿថា វាជាត្រីសមុទ្រមួយប្រភេទ ដែលមានខ្លួនធំក្បាលខ្លីក្រមុប ធ្មេញ និងចង្កូមស្វាញគួរស្ញើម។ *មករ* មានឆ្លាក់លើផ្តែរប្រាសាទ សម្បូណ៌ព្រៃគុហ៍ ជារូបពាំងដងធ្នូឬផ្កា មានកន្ទុយដូចក្រពើ មាត់ធំវែង និង មានប្រមោយដូចដំរី ។ នៅសម័យអង្គរ គេឆ្លាក់សត្វមករខ្ជាក់ឬព្រួសនាគ ឬ ជារូបទូកក្បាលមករ ។

គេនិយមឆ្លាក់សត្វមករ ព្រោះវាតំណាងឲ្យទឹកដែលផ្តល់ភាពត្រជាក់ត្រជំដល់ប្រាសាទ ។

*នាគ* ៖ នាគជាសត្វមាននៅក្នុងទេវកថាសាសនា។ គេជឿថា វាជាប្រភេទសត្វពស់ ។ សិល្បករខ្មែរចូលចិត្តឆ្លាក់ សត្វនាគដែលមានក្បាលច្រើន ។ ចំនួនក្បាលនាគច្រើនតែជាចំនួនសេស ដោយសារគេជឿថា ចំនួនសេស (គឺសេសសល់) (១, ៣, ៥, ៧, ឬ ៩) របស់ក្បាលនាគតំណាងភាពអមតៈ ឯចំនួនគូជាចំនួននៃសេចក្តីស្លាប់ ។ ក្នុងទេវកថាហិណ្ឌូ ព្រះវិស្ណុមានយានជំនិះជាសត្វគ្រុឌមួយនិងនាគមួយឈ្មោះ *អនន្តសេសៈ* ដែលមានន័យថាគ្មានទីបញ្ចប់ ។ ក្នុងវប្បធម៌ខ្មែរ គេជឿថា សត្វនាគនាំមកនូវភាពត្រជាក់ត្រជំដល់ស្រុកទេស ។ ហើយនាគដែលគេឆ្លាក់ នៅតាមប្រាសាទអាចនិយាយបានថាតំណាងឲ្យ៖

- ទឹក (ក្រៅពីរស់នៅក្នុងទឹក នាគក៏ជាយានជំនិះរបស់ព្រះភិរុណដែលជាឆ្មាំហានសួគ៌ទិសបស្ចឹម និងជាអ្នកកាន់កាប់ទឹកភ្លៀង) និង នយោបាយទឹក
- ឆ្មាំមរតក/ប្រាសាទ (ប្រៀបដូចនាគមុច្ចលិនដែលបើកពពារការពារព្រះពុទ្ធនៅយាមដែលព្រះពុទ្ធត្រាស់ដឹង ហើយភ្លៀងក៏បង្អុរធ្លាក់មកអបអរសាទរដូច្នោះដែរ)
- ភាពអមតៈ ។

ក្រៅពីចម្លាក់លម្អតាមប្រាសាទនានា បច្ចុប្បន្ន គេក៏ឆ្លាក់រូបនាគនៅតាមវត្តអារាម



www.elibraryofcambodia.org

ឬ របស់ ប្រើប្រាស់ផ្សេងៗដូចជា រទេះគោ នង្គ័ល ជាដើម ។



ចម្លាក់អប្សរ ឬ អប្សរា







ចម្លាក់មករនៅលើផ្តែរប្រាសាទសម្បូណ៌ព្រៃគុហ៍



www.elibraryofcambodia.org

*គោ* ៖ គេតែងឆ្លាក់សត្វគោនៅមុខប្រាសាទឬខ្លោងទ្វារចូលប្រាសាទ។ សត្វគោមានឫកពាមាំមួន ខ្លាំងក្លា និង អង់អាច ។ បដិមាគោដែលគេឆ្លាក់នៅមុខប្រាសាទបែបនេះតំណាងទ្វារបាល គឺអ្នកការពារប្រាសាទ។ ខ្មែរបុរាណជឿអបិយជំនឿខ្លាំងក្លាណាស់ ថ្វីដ្បិតតែវាមិនមែនជាគោពិតប្រាកដ តែវាធ្វើឲ្យគេខ្លាចរអានៅក្នុងអារម្មណ៍ ហើយម្យ៉ាងទៀត ប្រាសាទនីមួយៗតែងមានសិលាចារឹកដែលប្រាប់ប្រវត្តិនៃការសាងសង់ប្រាសាទ និង ដាក់បណ្តាសាដល់ជនដែលបំផ្លាញប្រាសាទ។ ព្រោះហេតុនេះ គេអាចនិយាយបានថា គោតំណាង៖

- ដី (ជាស្តេចសត្វនៅលើដី)
- ភាពអង់អាចក្លាហាន ឬ ជាឆ្មាំមរតក(ប្រាសាទ) និង
- ភាពយុត្តិធម៌ឃ្លាំមើលមនុស្សចូលប្រាសាទ (ដ្បិតវាជាយានជំនិះរបស់ពោធិសត្វមញ្ជុស្រី ខាងពុទ្ធសាសនាមហាយានដែលកាន់ការខាងតុលាការ)។

*គ្រុឌ* ៖ គ្រុឌជាបក្សីម្យ៉ាងដែលមនុស្សបុរាណប្រឌិតបង្កើតឡើង ។ គ្រុឌជាស្តេចបក្សី។ ក្នុងព្រហ្មញ្ញសាសនា គ្រុឌក៏ជាជំនិះមួយទៀតរបស់ព្រះវិស្ណុដែរ។ នៅក្នុងទេវកថាព្រាហ្មណ៍សាសនា គ្រុឌជាសត្រូវស៊ីសាច់ហុតឈាមជាមួយនាគ។ ដោយសារកម្លាំងដ៏ខ្លាំងក្លារបស់គ្រុឌ គ្រុឌត្រូវបានគេយកមកធ្វើជាទម្រដំបូលព្រះវិហារ ឬសំណង់ស្ថាបត្យកម្មនានាជាលម្អ។ ហេតុនេះ គ្រុឌតំណាងឲ្យ *អាកាស* និងជា *ឆ្មាំមរតក*។

*គោ* ៖ គោត្រូវបានឆ្លាក់ ដាក់ខាងមុខប្រាសាទខ្មែរ ដូចជាប្រាសាទ*ព្រះគោ* ជាដើម។ ដូចនៅប្រទេសឥណ្ឌាដែរ សត្វគោត្រូវបានគេគោរពបូជា ព្រោះវាជា





www.elibraryofcambodia.org

យានជំនិះរបស់ *ព្រះសិវៈ* ។ ព្រោះហេតុនេះ គោតំណាងឲ្យព្រះសិវៈ ហើយប្រាសាទដែលមានចម្លាក់គោ គឺត្រូវបានគេសាងសង់ដើម្បីឧទ្ទិសដល់ព្រះសិវៈ។ ខ្មែរសម័យលង្វែកគោរពគោ (ដែលជាយានជំនិះព្រះឥសូរ) ថាជាព្រះ (ព្រះគោ) ដែលរក្សាគម្ពីរក្បួនខ្នាត ផ្សេងៗ (ត្រៃវេទ ?) សម្រាប់នគរខ្មែរ។



*សេះ* ៖ សេះ *ពលហៈ* ត្រូវបានគេឆ្លាក់ដាក់នៅប្រាសាទនាគព័ន្ធ។ ចម្លាក់សេះនេះកំពុងតែ ហែលទៅទិសខាងកើត ដោយមានរូបមនុស្ស (ក្បាលនិងផ្នែកខ្លះៗនៃរូបមនុស្សនេះបានបាត់បង់ទៅហើយ) តោងវាទាំងសងខាងផង។ តាមទេវកថាពុទ្ធសាសនានិកាយមហាយាន សេះនេះជាការកាឡាខ្លួនរបស់ពោធិសត្វ អវលោកិតេស្វរៈ ដើម្បីជួយសង្គ្រោះពាណិជម្នាក់ឈ្មោះ *សិម្ហាលៈ* និង អ្នកធ្វើដំណើរក្នុងសំពៅរបស់គាត់ឲ្យរួចពីគ្រោះកាច ដោយសារការលិចសំពៅនៅកោះមួយនៃប្រទេសសិរីលង្កា និងត្រូវយក្សស្រីចាប់ស៊ី។ ពួកគេខំតោងខ្លួន និងកន្ទុយសេះដើម្បីឲ្យបានឆ្លងទៅដល់ដីគោកដោយសុវត្ថិភាព ។

*ដំរី* ៖ ដំរីត្រូវបានគេប្រើ ប្រាស់ក្នុងចម្បាំង និងការងារធ្ងន់ៗ មានការសាងសង់ប្រាសាទជាដើម នៅក្នុងសម័យបុរាណ។ មិនតែប៉ុណ្ណោះ ដំរីត្រូវបានចាត់ទុកជាសត្វនាំមកនូវភាពត្រជាក់ត្រជុំ និង ជាសត្វមានឫទ្ធអំណាចអស្ចារ្យ ព្រោះវាជាយានជំនិះរបស់អាទិទេព ។ គេតែងសង្កេត ឃើញចម្លាក់ដំរី និង ជាពិសេស ដំរីក្បាលបីឈ្មោះ *ឰរាវ័ណ* ដែលជាយានជំនិះរបស់ ព្រះឥន្ទ្រ នៅតាមប្រាសាទ ឬ រាជធានីខ្មែរសម័យបុរាណ ។



www.elibraryofcambodia.org

ក្រៅពីសត្វទាំងប៉ុន្មានខាងលើ គេក៏ឃើញមានចម្លាក់ប្រជល់មាន់ និងសត្វផ្សេងៗ ដែលជាសត្វ ស្រុក ដែលបង្ហាញអំពីជីវភាពរស់នៅរបស់ប្រជារាស្ត្រនាសម័យនោះ តាមជញ្ជាំងប្រាសាទនានាដែរ ។



ដំរីឰរាវ័ណ



មាន់ដែលគេ
យកមក
ប្រជល់



www.elibraryofcambodia.org

# ៣
# សិល្បៈតន្ត្រីខ្មែរ

## ១- ភ្លេងពិណពាទ្យ



ចម្លាក់នៅលើផ្ទៃរ៖ តន្ត្រីករខ្មែរដេញពិណ និង សាដៀវ

"ពិណ" គឺជាឧបករណ៍ភ្លេងប្រើខ្សែម្យ៉ាង ឯ "ពាទ្យ" មានន័យថា គ្រឿងភ្លេងប្រគំ។ *ពិណពាទ្យ* ជាឈ្មោះវង់ភ្លេងខ្មែរដែលមានឧបករណ៍៦ យ៉ាងគឺ សម្ភោរ១ ស្គរធំ១គូ ស្រឡៃ១ រនាត(១ ឬ ៣) គងវង់(ធំ និង/ឬតូច) និង ពិណ (ដែលជាអ្នកនាំមុខ)។ សម័យបច្ចុប្បន្ន គេពុំមានប្រើពិណ(ចាប៉ី)ទេ។ ទោះជាយ៉ាងនោះក៏ដោយ ក៏ភ្លេងនេះនៅតែមានឈ្មោះថា *ពិណពាទ្យ* ដដែល ។

មានអ្នកខ្លះយល់ច្រឡំនិងហៅភ្លេងនេះថា "ភ្លេងសៀម" ឬអ្នកខ្លះហៅតាមសំនៀងសៀមថា "ប៉ី(ស្រឡៃ)ផាត(ពាទ្យ)"។ នេះដោយសារ ខ្មែរយើងធ្លាប់ធ្លាក់ក្នុងភ្លើងសង្គ្រាមជាច្រើនឆ្នាំ ហើយម្យ៉ាងសៀមដែលធ្លាប់ទទួលឥទ្ធិពលវប្បធម៌ខ្មែរទៅ បានថែរក្សាវាយ៉ាងល្អ លុះក្រោយសង្គ្រាម ខ្មែរក៏ទទួលយកវប្បធម៌នោះមកវិញ ។ ដោយហេតុមិនដឹង ខ្មែរក៏នាំគ្នាហៅវប្បធម៌ទាំងនោះតាមភាសាសៀម និង បញ្ជាក់កំណើតវាថាមកពីសៀម ។ តាមការណ៍ពិត វង់ភ្លេងនេះមានកំណើតពីទឹកដីខ្មែរ យ៉ាងពិតប្រាកដដូចមានចម្លាក់នៅលើផ្ទៃរប្រាសាទសម្បូណ៌ព្រៃគុហ៍ (មុនកំណើតក្រុងឰយុធ្យាទៅទៀត) និង ប្រាសាទមួយចំនួនទៀត នៅសម័យអង្គរ ។



www.elibraryofcambodia.org

លោកឧកញ៉ា **ឈឹម ក្រសេម** បានសរសេរទុកថា «គ្រឿងតូ្យតន្ត្រីរបស់ខ្មែរយើងដែលលេង សព្វថ្ងៃនេះបែបបានមកពីប្រទេសឥណ្ឌា» តាំងពីសម័យព្រេងនាយលុះមកដល់សម័យក្រោយ វិជ្ជាតូ្យតន្ត្រី និងបែបគ្រឿងតូ្យតន្ត្រីរបស់ខ្មែរបានផ្សាយចេញពីប្រទេសសៀមក្នុងសម័យក្រុងស្រីអយុធ្យា (រវាងព.ស.១៨៩៣-២៣១០)។ លោកបានបន្ថែមទៀតថា "គម្រានាដសាស្ត្ររបស់ឥណ្ឌាមួយនិយាយថា ភ្លេងពិណពាទ្យក្នុងសម័យដើមមានតែត្រឹមបួនគ្រឿងប៉ុណ្ណោះ គឺ ខ្លុយ ពិណ សម្ភោរ និងឈិង" ។

គម្រានាដសាស្ត្របានបង្ហាញថា « សម័យមួយព្រះឥសូរទ្រង់គង់កណ្ដាលទេវសភាដែលស្ថិតនៅលើកំពូលភ្នំកៃលាស មានបំណងនឹងសម្ដែងពិធីរាំឲ្យជាបែបច្បាប់សម្រាប់លោកទើបស្ដេចត្រាស់បង្គាប់ឲ្យព្រះនាងឧមាទេវីគង់លើបល្ល័ង្កសុវណ្ណ ឲ្យនាងសរស្វតីជាទេពីព្រះព្រហ្មដិញពិណ ឲ្យព្រះឥន្ទផ្លុំខ្លុយ ឲ្យព្រះព្រហ្មគោះឈិង ឲ្យព្រះលក្ស្មីជាទេពីព្រះនារាយណ៍ច្រៀង ឲ្យព្រះនារាយណ៍វាយថូ ឯព្រះឥសូរព្រះអង្គឯងទ្រង់រាំដើម្បីឲ្យទេវតា គន្ធព្វ យក្សទាំងឡាយដែលឡើងទៅគាល់ព្រះអង្គ មើលគ្រប់គ្នា» ។

លុះមកដល់សម័យក្រោយៗ ខ្មែរយើងក៏បានកែប្រែផ្លាស់ប្ដូរនិងថែមថយគ្រឿងភ្លេងឲ្យក្លាយទៅជាភ្លេងរបស់ខ្មែរ។ សព្វថ្ងៃនេះ គេរៀបចំភ្លេងពិណពាទ្យពីរវង់គឺ ពិណពាទ្យ វង់តូច និងពិណពាទ្យវង់ធំ ។

ពិណពាទ្យវង់តូច មានឧបករណ៍ភ្លេងដូចខាងក្រោម៖

- រនាតឯក ១ ( ជាអ្នកដើរបទ )
- ស្គរធំ ២
- គង់វង់តូច ១
- សម្ភោរ ១ និង
- ស្រឡៃ ១



www.elibraryofcambodia.org

ពិណពាទ្យវង់ធំមានឧបករណ៍ភ្លេងដូចខាងក្រោម៖

- រនាតឯក ១,

  រនាតធុង ១ និង

  រនាតដែក ១

- សម្ភោរ ១

- ស្គរធំ ២ (១ គូ)

- ស្រឡៃ ១

- ឈិង ១គូ

- គងវង់ធំ ១ និងគងវង់តូច ១ ។


ប្រភព៖ កែវ ណារុំ (ទំ. ៥១)

ក្នុងចំណោមវង់ភ្លេងខ្មែរទាំងអស់ មានតែភ្លេងពិណពាទ្យមួយទេដែលមានរបៀបរៀបចំគ្រឿងភ្លេងក្នុងទីដ៏សមសួននៅពេលលេងម្តងៗ ឯភ្លេងដទៃទៀតគ្រាន់តែអង្គុយឈមមុខរកគ្នាហើយ ប្រគំលេងទៅ ពុំមានកំណត់កន្លែងច្បាស់លាស់ឡើយ ។ ឯវង់ភ្លេងពិណពាទ្យ ទោះបីតាមទម្លាប់របស់គ្រូម្នាក់ៗក៏ដោយ ក៏ស្គរធំនិងសម្ភោរត្រូវនៅមុខគ្រឿងឯទៀតជាដរាប ។

ខ្មែរប្រើវង់ភ្លេងពិណពាទ្យក្នុងការកំដររបាំនិងល្ខោនបុរាណ (ស្រមោលស្បែកតូច ស្បែកធំ ល្ខោនខោលជាដើម) ក្នុងពិធីបួងសួង (បន់ស្រន់ និង លាបំណន់) ក្នុងពិធីសាសនា (បុណ្យផ្កា កឋិន បំបួសនាគ ពុទ្ធាភិសេក ជាដើម) និង ក្នុងពិធីតម្កល់សព។

## ២- ភ្លេងខ្មែរ

ភ្លេងខ្មែរមានប៉ីអ (ខ្លះគេប្រើខ្លុយជំនួសវិញ) ទ្រខ្មែរ ចាប៉ីដងវែង និងស្គរដៃ។ អ្នកវាយស្គរ និងអ្នកកូតទ្រត្រូវច្រៀងផង ។ សូមបញ្ជាក់ថា លេងភ្លេងនេះ តាមប្រពៃណីបុរាណ គេមិនយកអ្នកភ្លេងស្រីលេងភ្លេងទេ ពោលគឺអ្នកលេងសុទ្ធតែប្រុសៗពេញវ័យពុំត្រូវក្រមាច់កំប្លែងសើចផ្តេសផ្តាស ព្រោះភ្លេងខ្មែរនេះ គេចាត់ទុកជាភ្លេងមង្គល គេត្រូវលេងតែក្នុងមង្គលតាមប្រពៃណីខ្មែរដូចជា ពិធីមង្គលការ ពិធីបញ្ចាញម្លប់ជាដើម ។

ក្នុងពិធីរៀបមង្គលការ អ្នកកាន់ទំនៀមទម្លាប់បុរាណ គេរើសអ្នកភ្លេងនេះឲ្យ


www.elibraryofcambodia.org

មានរូបរាងពេញលេញ គឺមិនឲ្យពិការភ្នែក ឬអវយវៈណាមួយឡើយ ហើយអ្នកភ្លេងមានសម្លៀកបំពាក់គួរសម ព្រមទាំងមានវ័យចាស់បន្តិចផង។ ឯចំណែកបទដែលលេងក៏ប្លែកខុសអំពីបទភ្លេងពិណពាទ្យដែរ ។

បទភ្លេងខ្មែរមានទំនាក់ទំនងទៅនឹងរឿងព្រេងខ្មែរ ។ បទខ្នងភ្នំ របងមាស បន្ទាយប្រាសាទ ជ្រងស្រងាត់ ។ល។ ដែលប្រើលេងនៅពេលលៀងភោជនាហារថ្ងៃត្រង់ (ក្រោយពេលស៊ីស្លាកំណត់) មានកំណើតឡើងដោយយកតម្រាប់តាម **តាជុង** និង **យាយជ័យ** ដែលបានឲ្យអ្នកភ្លេងលេងបទទាំង នោះថ្វាយអ្នកតាព្រៃ ដើម្បីលាមាត់ លាក គាត់កាលដែលបានបន់ស្រន់នៅពេលធ្វើដំណើរកាត់ព្រៃទៅ រៀបការកូនស្រីឈ្មោះនាង **ត្រចើលដោះក្រាល** និង **ចៅប្រមាញ់វិញស៊ីង**។ កូនស្រីនេះគាត់បានធ្វើនឹងនាងទេន ជាប្អូនហើយវង្វេងផ្លូវ ។

ចំណែកបទព្រះថោង និងបទនាងនាគដែលប្រើលេងនៅពេលសំពះផ្ទឹមនោះមានកំណើតឡើងក្នុងរជ្ជកាល ព្រះថោង ឬ ហ៊ុន ទៀន។ ព្រះអង្គបានរៀបអភិសេកជាមួយនាងទាវតី (លីវ យី) បុត្រីស្តេចកុជង្គនាគ។ លុះរៀបមង្គលការនៅស្ថានមនុស្សរួចហើយ ស្តេចកុជង្គនាគបាននាំព្រះថោងទៅជប់លៀងម្តងទៀតនៅស្ថានបាតាល ។ ដោយសារព្រះថោងពុំចេះវិជ្ជាខាងជ្រែកទឹក ទ្រង់ក៏តោងកន្ទុយនាងនាគចុះទៅ ។ អាស្រ័យដោយមានរឿងខាងលើនេះហើយ ទើបគេសន្មតឈ្មោះ បទភ្លេងថា "បទព្រះថោង និង នាងនាគ" ដែលខ្មែរយើងយកប្រើតាំងពីដើមហូតដល់បច្ចុប្បន្ន ព្រមទាំងមានទំនៀមឲ្យកូនប្រុសតោងជាយស្បៃកូនស្រីចូលក្នុងបន្ទប់ទៀតផង ។

### ៣- ភ្លេងអារក្ស

ភ្លេងមួយបែបទៀតដែលមានគ្រឿងលេងប្រហែលគ្នានឹងភ្លេងខ្មែរដែរ តែគេប្រើលេងតែនៅពេលប្រគំបញ្ចូលខ្មោច ឡើងរោង និងឡើងអ្នកតា គេហៅថា *ភ្លេងអារក្ស* ។ ភ្លេងនេះមានស្គរដីពីរ ទ្រខ្មែរ(ខ្សែ៣)១ ប៉ីពក១ ចាប៉ី១ ។ ក្រុមភ្លេងនេះច្រើនតែប្រើប៉ី មិនប្រើខ្លុយទេ ។

តាមការស្រាវជ្រាវរបស់លោក ជឹម ឈុំ សមាជិកនៃក្រុមទំនៀមទម្លាប់ ភ្លេង


www.elibraryofcambodia.org

អារក្សនេះមានកំណើតឡើងអំពីរឿងកូនក្មេងលេង "បាយឡុកបាយឡ" ។ គេតែងនិយាយរឿងនេះតៗគ្នាមកថា កាលនោះ នៅក្នុងភូមិមួយ មានក្មេងស្រីប្រុសជាច្រើនប្រជុំគ្នាលេង ខ្លះធ្វើភ្ញៀវ ខ្លះធ្វើម្ចាស់ផ្ទះ ខ្លះធ្វើប្ដី ខ្លះធ្វើប្រពន្ធ ខ្លះទៀតធ្វើកូន ហើយនាំគ្នាលេងជប់លៀងស៊ីផឹកស្រវឹងដួលដេក សើចហ៊ោកញ្ជ្រៀវយ៉ាងសប្បាយរាល់ៗថ្ងៃរៀងមក។ ដំបូងលេងតែពេលថ្ងៃៗទេ លុះយូរៗទៅក៏វក់លេងទាំងថ្ងៃ ទាំងយប់ រហូតដល់ភ្លេចបាយ ភ្លេចទឹក ភ្លេចដេកពួន។ ឪពុកម្ដាយហាមឃាត់យ៉ាងណាក៏ពុំស្ដាប់ ។ ឃើញហេតុខុសពីធម្មតាបែបនេះ ចាស់ៗក៏នឹកថាប្រហែលជាមានព្រាយបិសាចណាមួយមកពង្វក់ចិត្តក្មេងទាំងនោះហើយ ទើបពួកគាត់នាំគ្នាបន់ស្រន់ឡើង ។ ឯពួកបិសាច កាលបើគេនឹកនា ហៅរកខ្លួន ក៏ឆ្លៀតឱកាសនេះចូលទៅសណ្ឋិតក្នុងរូបក្មេងម្នាក់ភ្លាម ហើយក៏និយាយបញ្ជាឲ្យចាស់ៗ ទាំងនោះរៀបសំណែនដោយមានលេងភ្លេងថ្វាយពួកគេផង ទើបពួកគេជួយរក្សាឲ្យបានសុខសប្បាយតរៀងទៅ ។ បន្ទាប់មកបិសាចក៏នាំក្មេងឲ្យធ្វើបទភ្លេងដោយមាត់តាមចិត្តវា។ ក្រោយពីបានស៊ីសំណែនឆ្អែតស្កប់ស្កល់ហើយ ពួកបិសាចក៏ចាកចេញទៅ។ ឯពួកក្មេងៗក៏ឈប់លេងដូចមុនទៀត ហើយរស់នៅជាសុខសាន្តរហូតមក ។

ចាប់តាំងពីពេលនោះមក អ្នកស្រុកក៏ប្រកាន់ជឿខ្មោចអារក្ស ព្រាយ បិសាច ព្រមទាំងយកជា ទីគោរពទីពឹងក្នុងគ្រាមានទុក្ខភ័យអាសន្នម្ដងៗ ។

## ៤- ភ្លេងស្គរឈ្នះឬស្គរយោន ឬក៏ ភ្លេងក្លងខែកឬក្លងឆ្នះ

ភ្លេងក្លងខែកជាភ្លេងខ្មែរមួយបែប ដែលប្រើ លេងក្នុងពិធីតម្កល់សព ហែសព ឬបូជាសព ដើម្បីឲ្យមានបរិយាកាសស្រងេះស្រងោចលន្លង់លន្លោច និងដើម្បីកំដរកីឡាប្រដាល់សេរីនិងល្បុកតោ។ ភ្លេងនេះ ខ្មែរច្រើនហៅតាមភាសាសៀមថា *ក្លងខែក* ។ "ក្លង" មានន័យថា *ស្គរ* ឯ "ខែក" មាន ន័យថា *ឥណ្ឌា* ។ ហេតុនេះ ក្លងខែកមានន័យថា "**ស្គរឥណ្ឌា**" គឺស្គរដែលមានមុខពីរ ហើយដែលអ្នកភ្លេងលើកខ្សែវា ពាក់នឹង-ក ដើម្បីលេង។ អ្នកខ្លះហៅស្គរនេះថា *ស្គរយោន* ។ ពាក្យ *យោន* ក្លាយមកពីពាក្យ *យួន* ដែលមានន័យថា "បោះ ឬ ពួយ" ហើយដែលជាឈ្មោះបទភ្លេងគេលេងនៅកំដរកីឡា



www.elibraryofcambodia.org

ប្រដាល់។[15] ស្គរយោន នេះមាន ពីរបែប គឺស្គរយោនវាយដោយអន្លូង និង វាយដោយដៃ។ ខ្មែរខ្លះក៏ហៅស្គរនេះថា "ស្គរឈ្នះ" ដោយហេតុថា នៅសម័យបុរាណ គេប្រើវាលេងលើខ្នងដំរីក្នុងចម្បាំង សម្រាប់ធ្វើឲ្យដំរីដើរស្រុះគ្នា និងដើម្បីឲ្យកងទ័ពច្បាំងដោយក្លាហានឲ្យបានជោគ-ជ័យ ឬ ដោយសារគេលេងកំដរអ្នកប្រដាល់ ដោយជូនកាល លេងឲ្យរន្ថើនដើម្បីឲ្យកីឡាករវាយដោយក្លាហាន។ ឯអ្នកខ្លះហៅវាថា *ស្គរឆ្នះ* ដែលប្រហែលហៅក្លាយមកពីពាក្យសៀមថា *ឆៈនៈ* ដែលមានន័យថា *ឈ្នះ*។



ប្រភព៖ កែវ ណារុំ (ទំ. ៦៦)

វង់ភ្លេងនេះមានឧបករណ៍តែបីមុខទេ គឺស្រឡៃ ១ (ជាអ្នកដើរសាច់បទ) ស្គរយោនវាយដោយដៃ១ និងស្គរយោនវាយដោយអន្លូង២ (អាចមានច្រើនជាងនេះអាស្រ័យលើឋានៈសព)។

## ៥- ភ្លេងទាំមីង ឬ ទម្មីង ឬក៏ ត្រៃលក្ខណ៍

នេះជាឈ្មោះ បទភ្លេងដែលគេលេង កំដរសពនិងលើកខ្មោច និង ដែលមានន័យផ្លូវធម៌គួរឲ្យសង្វេគ អនិច្ចា។ អ្នកស្រុក ពោធិ៍សាត់និយមហៅ ភ្លេងនេះថា *ទាំមីង* ដោយសារគេឮសម្លេង ស្គរខ្ញុំលាន់ *មូងៗ* និង គងលាន់ *ទាំៗ* បែប នេះ។ គេហៅវាថា *ត្រៃលក្ខណ៍* ព្រោះវារំឭកមនុស្សឲ្យយល់ពីលក្ខណៈបីយ៉ាងនៃរូប គឺ អនិច្ចំ ទុក្ខំ អនត្តា ហើយអ្នកភ្លេងមានតែបីនាក់ដែរ ដែលតំណាងលក្ខណៈទាំងបីនេះ។ ដើម្បីជានិមិត្តរូបនៃការបែកធ្លាយរាងកាយ ក្នុងពេលលេង អ្នកភ្លេងត្រូវអង្គុយបែរខ្នងដាក់គ្នា ។

---

[15] កែវ ណារុំ៖ *មរតកតន្ត្រីខ្មែរ* បោះពុម្ពលើកទី ១, រៃយំ, ភ្នំពេញ៖ ២០០៥, ទំ. ៦៦។



www.elibraryofcambodia.org

តាមការស្រាវជ្រាវរបស់សមាជិកក្រុមជំនុំទំនៀមទម្លាប់ ភ្លេងគងស្គរមានកំណើតឡើង ក្នុងរជ្ជកាលព្រះបាទត្រសក់ផ្អែម។ កាលព្រះអង្គបានឡើងសោយរាជ្យសម្បត្តិ ព្រះអង្គតែងនឹកស្រណោះសម្លេងគ្រប់បែបយ៉ាងលាយឡំនឹងស្គរខ្យល់ ភ្លៀង ផ្គររន្ទះ


ប្រភព៖ កែវ ណារុំ (ទំ. ៧១)

ដែលព្រះអង្គធ្លាប់បានស្គាល់ ទាំងយប់ទាំងថ្ងៃ អ្នកប្រាជ្ញរាជបណ្ឌិតក៏បង្កើតក្រុមភ្លេងស្គរនេះឡើងថ្វាយព្រះអង្គទៅ ។

ភ្លេងនេះមានឧបករណ៍ ៖

- គងវង់ចំណិតលោកខែ ១ (តំណាងភ្លៀង)
- ស្រឡៃត្រៃលក្ខណ៍ ១ (តំណាងខ្យល់)
- ស្គរធំ១ និង គងញីឈ្មោលពីរព្យួរទន្ទឹមគ្នា លេងដោយមនុស្សម្នាក់ (តំណាងផ្គររន្ទះ) ។

បច្ចុប្បន្ន វង់ភ្លេងនេះលែងឃើញលេងទៀតហើយ ។ កាលដើមទសវត្សនៃឆ្នាំ ១៩៩០ គេឃើញមានលេងនៅខេត្តសៀមរាប និង មានការចាក់ខ្សែអាត់នៅក្នុងខេត្តសៀមរាប ឧត្តរមានជ័យ បន្ទាយមានជ័យ និង ស្រុកខ្លះក្នុងខេត្តបាត់ដំបង។[16]

### ៦- ភ្លេងឆៃយ៉ាំ

គ្រឿងភ្លេងឆៃយ៉ាំ មានស្គរវែងៗ ៤ ធ្វើដោយ ឈើ គងម៉ង់ ១ ឈិង ១ គូ ឆាប ១

[16] កែវ ណារុំ៖ *មរតកតន្ត្រីខ្មែរ* បោះពុម្ពលើកទី ១, រៃយំ, ភ្នំពេញ៖ ២០០៥, ទំ.៦៩។



www.elibraryofcambodia.org

គូ។ ភ្លេងនេះ គេលេងតែក្នុងពិធីបុណ្យជាទីរីករាយ មានបុណ្យកឋិន បុណ្យផ្កា បំបួសនាគជាដើម ព្រោះភ្លេងមួយបែបដ៏ប្លែកនេះមានសម្មស្សបទរស់រវើក ដែលធ្វើឲ្យគេរំភើបចិត្ត។



ភ្លេងឆៃយ៉ាំនេះពុំមានប្រភពណាបញ្ជាក់ពីដើមកំណើតនៃភ្លេងនេះឲ្យបានច្បាស់លាស់ទេ គ្រាន់តែអ្នកខ្លះយល់ថា ភ្លេងឆៃយ៉ាំទំនងជាមានកំណើតចេញពីមនុស្សជំនាន់ដើមដែលតែងមានសភាពភ្ញាក់ផ្អើលខ្លាចរអើលប្រៀបបានទៅនឹងសត្វព្រៃដែលភ្ញាក់ផ្អើលនៅពេលឃើញមនុស្ស ។ អ្នកខ្លះទៀតយល់ថា នៅពេលមនុស្សបានទទួលជោគជ័យក្នុងកិច្ចការរបស់ខ្លួន មនុស្សតែងតែត្រេកអរសប្បាយរីករាយយ៉ាងខ្លាំង ហើយក៏បង្កើតភ្លេងឆៃយ៉ាំនេះឡើងដើម្បីរំលឹកនូវជ័យជំនះនោះ ។

**៧- ភ្លេងមហោរី**

ពាក្យ "មហោរី" សម្គាល់ឈ្មោះភ្លេងផង និង សម្គាល់សភាពនៃវង់ភ្លេងផង។ បទភ្លេងមហោរីមានលក្ខណៈប្រជាប្រិយ ហើយស្រាលជាងភ្លេងពិណពាទ្យ ។ វង់ភ្លេងមហោរី គេមិននិយមលេងក្នុងពិធីបុណ្យទានផ្ទាល់ទេ ប៉ុន្តែអាចប្រើកំដរបរិយាកាសបានដែរ ។ ជាទូទៅ គេលេងភ្លេងមហោរីកំដរ ល្ខោនមហោរី ។

ឯវង់ភ្លេងមួយវង់ទៀតដែលសម្តែងក្នុងព្រះបរមរាជវាំង ដែលមានគ្រឿងចម្រុះច្រើនយ៉ាង ហៅថា «ក្រុមមហោរីព្រះរាជទ្រព្យ»។ ប្រដាប់ក្រុមភ្លេងនេះមានដល់ទៅ ១៦ គ្រឿង គឺ ៖

- រនាតឯក - ទ្រខ្សែ៣ - ស្គរជ្វេចស្គរអារក្ស - តាខេធុង
- រនាតធុង - ទ្រអ៊ូខ្សែ២ - ចាប៉ីវែងខ្សែ ៤ - ក្រាប់



www.elibraryofcambodia.org

- គងវង់តូច - ទ្រខ្មែរឬទ្រឯកខ្សែ២ - តាខេឯកខ្សែ៣ - ឈិង
- គងវង់ធំ - ខ្លុយរន្ធ ៨ - ស្គរថូននិងស្គររមនា

ភ្លេងទាំងប៉ុន្មានខាងលើនេះ ជាភ្លេងដែលគេរកឃើញមានលេងក្នុងប្រទេសកម្ពុជាជាយូរណាស់មកហើយ ។



ប្រភព៖ កែវ ណារុំ, ទំ. ៥១



www.elibraryofcambodia.org

## ៤
## សិល្បៈរបាំ

ព្រះរាជាណាចក្រកម្ពុជាជាប្រទេសមួយ ដែលសម្បូរទៅដោយរបាំច្រើនប្រភេទខុសៗគ្នា ។ គេនិយមចែករបាំជា ៣ ក្រុមគឺ ៖

- របាំក្បាច់បុរាណខ្មែរ(របាំព្រះរាជទ្រព្យ)
- របាំប្រពៃណីខ្មែរ
- របាំប្រជាប្រិយខ្មែរ ។

### ១- របាំក្បាច់បុរាណខ្មែរ

កាលពីសម័យមុនគេហៅរបាំតន្ត្រីនេះថាជារបាំព្រះរាជទ្រព្យ ព្រោះជារបាំរបស់ព្រះមហាក្សត្រ ហើយ គេនិយមលេងតែក្នុងវាំងស្តេច ដូចជាលេងនៅពេលបួងសួងលេងថ្វាយព្រះអាទិទេព និង ថ្វាយវិញ្ញាណក្ខន្ធព្រះមហាក្សត្រដែលបានចូលទិវង្គតទៅហើយ។ របាំនេះមានកំណើតយូរយារណាស់មកហើយ ។ លុះមកដល់សម័យអង្គរ គេបានឆ្លាក់រូបទេពអប្សរដែលជាស្ត្រីរបាំចុះពីឋានសួគ៌មករាំ នៅតាមជញ្ជាំងប្រាសាទ។ របាំនេះពុំទទួលឥទ្ធិពលពីខាងក្រៅទេ ព្រោះមានភារៈជារបាំតង្វាយនៅក្នុងរាជវាំង។ ផ្នែកខ្លះនៃរបាំនេះដកស្រង់ចេញពីរឿងរាមកេរ្តិ៍ រឿងមហាភារតៈ និង រឿងព្រេងខ្មែរ។ ក្រៅពីរបាំដែលទាក់ទងនឹងរឿងរ៉ាវទាំងនេះ នៅមានរបាំថ្វាយព្រះពរ របាំទេពមនោរម្យ របាំអប្សរា (ទេពអប្សរ) របាំមណីមេខឡា របាំសុវណ្ណមច្ឆា របាំរាមលក្ស្មណ៍-ជបលក្ស្មណ៍ របាំមេអំបៅ របាំស្វា និង របាំដាវជាដើម ។

នាសម័យបច្ចុប្បន្ន របាំក្បាច់បុរាណនេះត្រូវបាននាំទៅលេងនៅឯបរទេសជាញឹកញាប់ ហើយ បានទទួលជោគជ័យលើឆាកអន្តរជាតិ ។

### ២- របាំប្រពៃណីខ្មែរ

របាំប្រពៃណី ជាប្រភេទរបាំទាំងឡាយណាដែលស្ថិតជាប់នឹងពិធីប្រពៃណី ឬពិធីតំណាត្រកូលយូរលង់ណាស់មកហើយ ។



www.elibraryofcambodia.org

របាំប្រពៃណីមួយចំនួននៅតាមខេត្ត-ខណ្ឌក្នុងព្រះរាជណាចក្រកម្ពុជាមាន៖

- ខេត្តសៀមរាប ៖ របាំត្រុដិ របាំត្រុដិនាងម៉េវ របាំចាក់អង្រ្គង
- ខេត្តពោធិសាត់៖ របាំបេះក្រវាញ របាំសែនភ្លយ របាំក្ងោកពោធិ៍សាត់
- ខេត្តកំពង់ស្ពឺ ៖ របាំដាល់អំបុក របាំស្គរ របាំគងសួយ របាំភ្លយសួយ
- ខេត្តកំពង់ឆ្នាំង៖ របាំក្អម របាំបរគោ របាំអារក្ខចាម
- ខេត្តស្ទឹងត្រែង ៖ របាំគែន របាំវាយគួយ
- ខេត្តកំពង់ធំ៖ របាំចាក់គ្រើល របាំត្បាល់កាប់(ត្បាល់ក្បឿង)
- ខេត្តកណ្ដាល ៖ របាំអន្ទង់ហែន
- ខេត្តតាកែវ ៖ របាំច្រម
- ខេត្តស្វាយរៀង៖ របាំគោះត្រឡោក(កណ្ដូបសេះ)
- ខេត្តកោះកុង ៖ របាំព័ទ្ធរ៉ុង
- ខេត្តបាត់ដំបង៖ របាំបក់ស្រូវ
- ក្រុងប៉ៃលិន ៖ របាំក្ងោកប៉ៃលិន
- ខេត្តក្រចេះ ៖ របាំគងស្នៀង
- ខេត្តរតនគិរី ៖ របាំរាំវង់ភូមិថ្មី (រាំវង់ស្រុកហ៊ានទើម)
- ខេត្តរតនគិរី-មណ្ឌលគិរី៖ របាំកាប់ក្របីផឹកស្រា របាំត្បូងណៃទីន
- ខេត្តកណ្ដាល-តាកែវ ៖ របាំវាយក្រាប់
- ខេត្តកំពង់ស្ពឺ-កំពង់ធំ ៖ របាំកន្ដេរ៉ែ
- ខេត្តពោធិសាត់-កំពង់ឆ្នាំង ៖ របាំស្នែងទន្សោង
- ខេត្តកណ្ដាល-កំពង់ចាម-សៀមរាប៖ របាំគោះអង្រែ

របាំផ្សេងទៀតដែលពុំទាន់ដឹងប្រភពច្បាស់លាស់មាន៖ របាំកន្សែងស្នេហ៍ របាំច្រូតស្រូវ របាំឆៃយ៉ាំ របាំនេសាទ របាំស្គរត្នោត របាំកង្កែប របាំស្វា របាំអាពាហ៍-ពិពាហ៍ របាំបក្សី របាំបុកល័ខ...។



www.elibraryofcambodia.org

តទៅ យើងសូមលើកយកប្រភេទរបាំប្រពៃណីខ្មែរខ្លះៗមកបង្ហាញដូចតទៅៈ

## ២.១- របាំត្រុដិ

របាំត្រុដិ ជារបាំប្រជាប្រិយមួយបែប ដែលពីសម័យមុនគេឃើញមានតែនៅក្នុងខេត្តសៀមរាបហើយជួនកាលគេឃើញនៅខេត្តបាត់ដំបងខ្លះដែរត្រង់ភូមិភាគណាដែលនៅជាប់នឹងខេត្តសៀមរាបនោះឯង ។ តែ បច្ចុប្បន្ន របាំត្រុដិត្រូវគេនិយមរាប់អានស្ទើរតែទូទាំងប្រទេស ពិសេសនៅរាជធានីភ្នំពេញ ។

របាំនេះគេលេងតែនៅពេលបុណ្យចូលឆ្នាំខ្មែរតែប៉ុណ្ណោះដែលគេចាំបាច់ព្រោះរបាំនេះគេលេងឡើងដើម្បីប្រសិទ្ធិនូវសព្ទសាធុការពរជូនដល់អ្នកស្រុកក្នុងឱកាសឆ្នាំថ្មី ។ ពាក្យ "ត្រុដិ" ដែលជាពាក្យដើមមកពីភាសាសំស្ក្រឹត ប្រែថា *ផ្តាច់* ឬ *កាត់ផ្តាច់* គឺសំដៅដល់ការដាច់ឆ្នាំ ឬ ការកាត់ផ្តាច់ឆ្នាំចាស់ចូលទៅក្នុងឆ្នាំថ្មី ហើយដែលមានជាប់ឈ្មោះព្រះរាជពិធីមួយហៅថា "ត្រស្តិសង្ក្រាន្ត" ជាប់រហូតដល់សព្វថ្ងៃ (ពាក្យ *ត្រស្តិ* ក្លាយមកពីពាក្យត្រុដិ) ។ ដូច្នេះ យើងឃើញថា តាមរយៈឈ្មោះវា របាំនេះគឺសម្រាប់សម្តែងឡើងនៅពេលដំណាច់ឆ្នាំនីមួយៗ ។ តែតាមទម្លាប់របស់អ្នកស្រុក ជួនកាល គេមានលេងរបាំនេះនៅពេលប្រារព្ធពិធីសុំទឹកភ្លៀងនៅគ្រា ដែលស្រុកទេសមានភាពរាំងឬសជាច្រើនខែ ។ ព័ត៌មានខ្លះបញ្ជាក់ថា របាំនេះបានសេសសល់ពីមនុស្សជំនាន់ដើមមួយពួកដែលរស់នៅលើទឹកដីសុវណ្ណភូមិ តាំងពីដែនដីនេះពុំទាន់បានទទួលអារ្យធម៌ពីប្រទេសឥណ្ឌានៅឡើយនោះ គឺមនុស្សមួយពួកនៅប្រទេសយើង ដែលអ្នកស្រុកហៅថា "សម្រែ" ហើយដែលសព្វថ្ងៃច្រើនរស់នៅក្នុងភូមិភាគខាងជើងទន្លេសាបនេះឯង ។ កាលជំនាន់ដើម វង់ត្រុដិរបស់ជនជាតិសម្រែនេះបាននាំគ្នាទៅលេងថ្វាយព្រះរាជានៅរាល់បុណ្យចូលឆ្នាំ ដើម្បីថ្វាយព្រះពរសួស្តីសិរីមង្គល ។

តាមធម្មតា របាំវង់នេះមានក្រុមតូច ក្រុមធំ ទៅតាមការនិយមរបស់អ្នកស្រុក និងតាមការនិយមរបស់មនុស្សដែលស្ម័គ្រចិត្តចូលលេង ។ ឯប្រដាប់ប្រដានិងរបៀបលេងយ៉ាងណាៗនោះ យើងនឹងអធិប្បាយជូនខាងក្រោម។



www.elibraryofcambodia.org

## ២.១.១- គ្រឿងភ្លេង

- កញ្ចាគឺជាដងធ្វើពីពីងពង់ប្រវែង ២ ម៉ែត្រ មានបន្ទះរនាបតូចផ្ចារភ្ជាប់នៅចុង ហើយខ្វែង គ្នាទន្ទាំ មានសណ្ឋានដូចស្នែង ៤ ។ នៅចុងបន្ទះរនាប មានខ្សែចងខ្វែងពីចុងមួយ ទៅចុងមួយ ហើយត្រង់កណ្ដាលខ្វែងនេះ មានបន្ទោងផ្លែអង្គញ់ដែលចោះយកគ្រាប់ចេញអស់ ហើយដាក់គ្រាប់គ្រួស ឬ កម្ទេចដែកទៅក្នុង ប្រយោជន៍ឲ្យឮសូរ កាលណាគេអុកដងវានឹងដី តាមចង្វាក់ស្គរ ។
- ចង្រ្កង់ដំបែរគឺជាចង្រ្កង់ចងបន្តោងនឹងខ្សែទាមគោ ហើយចងភ្ជាប់នឹងដងឫស្សីដែរ។ កាលណាគេបុកវានឹងដី វាមានសូរប្រាវៗតាមចង្វាក់ ។
- ចង្រ្កង់វ៉ែងជាចង្រ្កង់ដែលគេចងព្យួរជាប់នឹងចង្កេះមនុស្សតែម្ដង ដោយចងគួបគ្នាជាចង្កោមផង។
- ស្គរអារក្ស គឺស្គរដែលធ្វើពីដីដុត ពាសស្បែកថ្លាន់ ។
- ប៉ីពក មានតែមួយប៉ុណ្ណោះ ។
- ទ្រអ៊ូ-ទ្រសោ
- សន្ទូចគឺដងពីងពង់វែង មានសណ្ឋានដូចសន្ទូច ចងចុង ដូចចន្ទោលរទេះ ដោយមានព្យួរថង់នៅចុងសម្រាប់ទទួលវត្ថុជាទាន ។ គ្រឿងតែងមានមុខត្លុកមកុដ ស្នែងប្រើស ស្នែងទន្សោង កន្ទុយក្ងោក ក្រចក ។

## ២.១.២- ប្រភពរបាំតាមរៀបរឿងនិទាន

**រឿងទី ១** ៖ មានសេចក្ដីដំណាលថា ជាយូរលង់មកហើយ មានត្រកូលអ្នកនេសាទម្នាក់ ប្ដីឈ្មោះ ប៊ុន ប្រពន្ធឈ្មោះ នាងឧមា ដែលមានលំនៅនៅជិតស្រុកសារ័ត្ន និស្ស័យជាមនុស្សកាចរបឹង រឹងរូស។ ពួកគាត់កម្សត់ទាល់ក្រ តែតែងតែដើរបាញ់សត្វម្រឹគ បក្សី និង នេសាទត្រី យកមកចិញ្ចឹម ជីវិតរៀងដរាបមក ។ នៅវេលាថ្ងៃមួយ ប្ដីរៀបប្រដាប់ប្រដាធ្នូ ស្នា ព្រួញ ជ័រធក់ កាំបិតស្នៀត និងវត្ថុអ្វីៗទៀតតាមទម្លាប់ព្រាន។ នាងភរិយាចាត់ចែងម្ហូបចំណី បារីស្លាប្រគល់ឲ្យប្ដី ។ ព្រានក៏ចេញដំណើរ ត្រាច់វង្កត់កាត់ព្រៃ ឆ្លងស្ទឹងឆ្ងាយទៅៗ ពុំមានប្រទះម្រឹគណាមួយសោះ ដែលជាហេតុនាំឲ្យព្រាន



www.elibraryofcambodia.org

នឹកថា ប្រហែលជាអស់លោកទេពារក្សបំបិទបំបាំង បង្វែរដានមិនឲ្យឃើញសត្វហើយ។ គិតដូច្នេះហើយ ព្រានក៏ចាត់ចែងធ្វើជារានទេព្ដា ៣ ថ្នាក់ នូវប្រដាប់ប្រដាពលិការ សុំលាភ សុំជ័យឲ្យបានជួបម្រឹគ ។ បន្ទាប់ពីបួងសួងរួចហើយ ព្រានធ្វើដំណើរតទៅមុខទៀត ហើយព្រាន ប៊ុន ក៏ប្រទះប្រើសមាសភ្លឺ ផ្អិនផ្អៅ គឺរោមសុទ្ធតែសរសៃមាស ស្នែងជាកែវភ្លឺច្រាលរន្ទាល ។ ព្រានត្រេកអរផុតឧបមា ក៏ពួនលបបំបាំងអាត្មា បាញ់បានប្រើសនោះដូចប្រាថ្នា ព្រានក៏មីម្នាយកកំបិតទៅកាត់យកស្នែង ពន្លះស្បែក មូរចងជាមួយដុំ អារសាច់ដោតចងប្រមូលរែកដោយសេចក្ដីត្រេកអរ ហើយវិលត្រលប់មកផ្ទះវិញ។ មកដល់ហើយ ដោយឃើញថា ប្រើសនេះល្អណាស់ ក៏នាំយកស្បែកនឹងស្នែងទៅថ្វាយស្ដេច។ ព្របាទព្រហ្មទត្តទ្រង់យល់ ក៏ទ្រង់សព្វព្រះរាជហឫទ័យ ទើបប្រទានយសដល់នាយព្រានជាចៅហ្វាយខេត្ត។ ក្រោយពេល ព្រាន ប៊ុន ឡើងយសជា ចៅហ្វាយខេត្ត ឯនាង ឧមា ជាជំទាវមក ពួកគាត់ ក៏បង្កឲ្យមានក្រុមរបាំមួយដែលនិទានពីព្រានដើរបរបាញ់ម្រឹគ ដូចមានការរៀបចំក្នុងវង់ត្រុដិសព្វថ្ងៃនេះ ។

**រឿងទី២** ៖ មានសេចក្ដីដំណាលមួយទៀតថា របាំត្រុដិនេះកើតឡើងតាមហេតុភេទដែលមានឡើងនៅសម័យដែលព្រះសម្មាសម្ពុទ្ធ នៅជាពោធិសត្វ មុនត្រាស់ដឹង ព្រះអង្គទ្រង់ចេញសាងបព្វជ្ជា ។ ពេលនោះ មារាធិរាជបានតំណែងក្លែងខ្លួនជាសត្វប្រើសមករារាំង ស្ទាក់ផ្លូវព្រះអង្គ កុំឲ្យព្រះអង្គយាងទៅមុខបាន ។ ព្រះពោធិសត្វ ទ្រង់តាំងអធិដ្ឋានឡើង ហើយការណ៍នោះក៏នាំឲ្យក្ដៅដល់ទេវលោកមួយរំពេច ព្រះព្រហ្មព្រះឥន្ទ និង ទេវតាទាំងឡាយក៏ចុះមកតំណែងភេទជាដោះ លបបាញ់ ប្រើសដែលជារាមាធិរាជក្លែងភេទនោះស្លាប់បង់ទៅ ។ រួចហើយ ពពួកទេវតាទាំងអស់នោះក៏នាំគ្នាដើរដង្ហែព្រះអង្គឆ្លងស្ទឹងអនោមា ទៅសាងព្រះផ្នួសសម្រេចតាមបំណងទៅដោយមានភ្លេងមហោស្រព រងំតាមដងផ្លូវផង ។ ដើម្បីរឭកដល់គ្រានោះ គេបានយករឿងនោះមកសាងជារបាំត្រុដិកើតឡើង គឺដងកញ្ចារតំណាងឆ័ត្រ ឬ ជាភ្លស់បើកបាំងព្រះពោធិសត្វពួកភ្លេងតំណាងទេវតា នាងរាំតំណាង ទេពអប្សរហែហម ប្រើសទន្សោងតំណាងមារ និងព្រានមនុស្សព្រៃតំណាងដោះទេវតាកាឡា ។



www.elibraryofcambodia.org

### ២.១.៣- ប្រភពតាមបែបជំនឿអ្នកស្រុក

លោក ឡុង សាន់ នៅបាត់ដំបងបានឲ្យការណ៍ថា គេលេងរបាំនេះដោយមានជំនឿថា នៅតាមស្រុកជិតឆ្ងាយ យូរៗម្តង រមែងមានសត្វព្រៃចូលមកក្នុងភូមិអ្នកស្រុក។ បើប្រសិនណា មានសត្វព្រៃ ចូលស្រុកហើយ ស្រុកភូមិនឹងកើតឧបទ្រព្យចង្រៃបែបណាមួយជាមិនខាន។ ហេតុនេះបាននាំឲ្យមានទម្លាប់ថា បើឃើញសត្វព្រៃចូលស្រុកកាលណា គេនាំគ្នាប្រោះព្រំប្រេងម្សៅឲ្យសត្វនោះ ហើយ សុំពរជ័យពីសត្វទាំងនោះវិញកលនោះ។ ដើម្បីរកឱកាសបង្កក់ប្រសិទ្ធីចំពោះសត្វព្រៃឲ្យស្រេចក្នុងមួយឆ្នាំៗ អ្នកស្រុកដែលមានជំនឿដូច្នេះក៏បង្កើតរបាំត្រុដិនេះឡើង ។ ហេតុនេះហើយ ទើបវង់ត្រុដិត្រូវមានប្រើស ទន្សោង ,ក្ងោក សុទ្ធសឹងជាសត្វព្រៃ មកបង្ហាញខ្លួន ឱ្យអ្នកស្រុកអ្នកភូមិប្រោះព្រំប្រេងម្សៅ ចងដៃអំបោះកម្រង ឱ្យទានជាលុយកាក់ទៅធ្វើបុណ្យរំដោះគ្រោះឱ្យស្រេចហើយតែម្តងទៅ ដោយមានជំនឿថា ប្រសិនជាមានសត្វព្រៃចូលមកក្នុងស្រុកទៅថ្ងៃមុខទៀត ដោយសារគេបានប្រារព្ធពិធីនេះ រួចជាស្រេចទៅហើយ គេជឿថាគ្មានចង្រៃឧបទ្រពអ្វីអាចកើតមានឡើងទៀតទេ ។

### ២.១.៤- ប្រភពតាមការស្រាវជ្រាវ

ក្នុងឯកសារស្រាវជ្រាវរបស់ក្រុមជំនុំទំនៀមទម្លាប់ មានឯកសារមួយជារបស់លោក **មាស ហាំ** កាលធ្វើជាចៅហ្វាយស្រុក នៅស្រុកសូត្រនិគម បានឱ្យការណ៍ថា កាលលោកធ្វើជាចៅហ្វាយស្រុក នោះ លោកបានស៊ើបសួររកកំណើតនៃត្រុដិនេះដែរ ប៉ុន្តែលោកពុំមានទទួលបានរឿងរ៉ាវច្បាស់លាស់ សោះ ។ ប៉ុន្តែ គ្រូត្រុដិម្នាក់និយាយថា ត្រុដិជារបាំរបស់សាសន៍សម្រែដែលជាជនជាតិដើមមួយរស់ នៅលើទឹកដីយើងពីបុរាណមក។ ជាតិសម្រែធ្លាប់នាំគ្នាលេង(ត្រុដិ)ថ្វាយព្រះរាជាខ្មែរយើង កាលគ្រាព្រះអង្គគង់នៅអង្គរវត្ត ។ ព្រោះហេតុនេះហើយ បានជារបៀបរាំត្រុដិនេះនៅសល់តែក្នុងខេត្តសៀមរាប ដើលនៅជិតរាជធានីចាស់របស់យើង ។

ដូចយើងបានជម្រាបរួចម្តងនៅខាងលើថា របាំនេះជាសិល្បៈកេរតំណែលសេសសល់ពីមនុស្សដើមពិតមែន ដូចលោក **ហ ម៉ាកហ្សាល** (H.Machal) ដៅបង្ហាញក្នុង



www.elibraryofcambodia.org

អត្ថបទមួយថា កាលពីរវាង ១០ ឆ្នាំមុន (ពេលលោកសរសេរអត្ថបទនោះគឺរវាងឆ្នាំ ១៩២០) លោកបានឃើញពួកអ្នកលេងត្រុដិមកពីភូមិភាគភ្នំគូលែនសុទ្ធសឹងជាជនជាតិសម្រែ ។ លោក ម៉ាកហ្សាល់ បញ្ជាក់ទៀតថា សព្វថ្ងៃ ជនជាតិ សម្រែទាំងនោះបានរលាយចូលក្នុងជាជាតិខ្មែរដែលរស់នៅជិតខាងអង្គរវត្តអស់ទៅហើយ ។

លោក **រ. បារាដាត់** (R.Baradat) ជាតិបារាំងសេសបានធ្វើការអង្កេតយ៉ាងល្អិតល្អន់អំពីជនជាតិសម្រែ/ជាតិព័រ ព្រោះលោកបានទៅរស់នៅជាមួយពួកនេះអស់រយៈពេលយ៉ាងយូរ លុះត្រាតែ ចេះពាក្យសម្រែយកមកធ្វើជាសន្ទានុក្រមពាក្យសម្រែ ប្រែជាបារាំងបាន ។ លោកសរសេរបញ្ជាក់ត្រង់វគ្គនិយាយពីចម្រៀង និងរបាំជនជាតិសម្រែថា «មានរបាំមួយដែលក្លាយមកជាត្រុដិសព្វថ្ងៃ តែរបាំនេះ ជំនាន់ដើមនោះ ពុំមានស្ត្រីៗចូលរាំជាមួយផងទេ គឺសុទ្ធតែប្រុសៗទាំងអស់ សឹងមានសេសសល់របៀបនេះនៅនឹងពួកខ្មែរនៅឯស្រុកសុរិន្ទ (ប្រទេសសៀមសព្វថ្ងៃ) និយមរហូតមកដល់សព្វថ្ងៃនេះ»។

### ២.១.៥- របៀបសម្តែង

របាំនេះមានវង់តូច វង់ធំ យោលទៅតាមការនិយមរបស់អ្នកស្រុក និងចំនួនអ្នកស្ម័គ្រចិត្តលេង។ ជាមធ្យម គេបបួលគ្នា ២៥ នាក់លេងរបាំនេះ ។ ដំបូង គេដើរដង្ហែជាក្បួនទៅមុខ ប្រៀបដូចអ្នកហែទាំងអស់នោះជិះរទេះ ព្រោះគេមានដងសន្ទូចជានិមិត្តរូបនៃចន្ទោលរទេះ ។ វង់ត្រុដិនីមួយៗ តែងមានអាចារ្យជាអ្នកនាំមុខ ។ មុននឹងចាប់សម្តែង តួទាំងអស់ត្រូវបន្ទន់កាយរំលឹកគុណគ្រូ ។ បន្ទាប់មក តួព្រានស្លៀកស្លឹកចេកព្រៀកព័ន្ធចង្កេះលាបខ្លួនខ្មៅ ចេញមកមានកិរិយាមិននឹង ដើងរត់ ឆ្វេឆ្វា ច្រើនរត់ទៅមុខគេ ជួនកាល រត់ចេញក្រៅវង់ ដងខ្លួនងេកងោកយោលតាមចង្វាក់ភ្លេង ដៃគ្រាន់តែពត់បន្តិចមិនពេញជារាំទេ ។

អ្នកពាក់ស្នែងប្រើស និងទន្សោងរត់ឆ្វេឆ្វាក្នុងក្រុមរបាំ គេចពីពួកព្រានព្រៃម្នាក់ដែលកាន់ស្នា និងបំពង់ព្រួញតាមតម្រង់រកបាញ់ប្រើស។ តួឯកពីរនាក់ ស្លៀកចងក្បិនពណ៌ ពាក់អាវពណ៌ ពាក់មកុដ ដៃកាន់កន្ទុយក្ងោក ។ តួនាងពីរនាក់ទៀត ស្លៀកសំពត់សំឡុយ គ្មានសង្វារ ក្បាលពាក់របៃ ហើយ បង់-ក កន្សែងសំយុង។ គូរាំទាំងពីរគូនេះ



www.elibraryofcambodia.org

មានក្បាច់ទន់ភ្លន់ជាងគេ មានឫកពាជាស្រីក្រមុំអែនអន។ ពេលទៅដល់មុខផ្ទះណាមួយដែលត្រូវសម្តែង តួទាំងពីរគូនេះ ត្រូវលុតជង្គង់ ឱនក្បាលលើកដៃ ប្រណម្យយោលខ្លួនបន្តិចតាមចង្វាក់ស្គរ រួចទើបក្រោកឈរបន្ទន់ជើងស្តាំទៅមុខ ដៃឆ្វេងច្រត់ចង្កេះ ដៃស្តាំលាទៅមុខ ទំនងជាសុំនូវសប្បុរសទានពីម្ចាស់ផ្ទះ។ ក្នុងពេលនោះ អ្នកដទៃទៀតក្នុងវង់ត្រុដិ ត្រូវយោលខ្លួនតាមចង្វាក់ស្គរ ប្លែកៗគ្នាតាមចរិតតួកំប្លែង ឬនឹងធឹង ។

អ្នកពាក់ក្រចក ជួយក្នុងការច្រៀងផង និងការឲ្យចង្វាក់ជាមួយស្គរផង ដោយផ្ទាត់ក្រចករបស់ខ្លួនឱ្យឮសូរផស់ៗ ហើយងេកងោកខ្លួនតាមចង្វាក់ ។

អ្នកកាន់ផងសន្ទូចជាស្រីរាំស្អាតបាតម្នាក់ (ជួនកាលគេឲ្យតួនាង ឬតួឯកកាន់) រេរាំតាម ចង្វាក់ភ្លេង ដៃម្ខាងកាន់ផងដោយយកគល់មកទល់ចង្កេះ ហើយដាក់ខាងចុងដែលមានព្យួរថង់ តម្រង់ទៅម្ចាស់ផ្ទះរបៀបជាការរង់ចាំទទួលសប្បុរសទាន ។

ពួកអ្នកភ្លេង មានអ្នកវាយស្គរ ផ្លុំប៉ី អ្នកបុកកញ្ចានិងចង្រ្កង់ដំបែរ ពុំមានតាក់តែងអ្វីឲ្យប្លែកធម្មតាឡើយ ។ អ្នកកាន់ផងកញ្ចា និងចង្រ្កង់ដំបែរត្រូវមានគ្នាយ៉ាងតិច ២ នាក់។ គេកាន់ផងកញ្ចា ឬ ចង្រ្កង់ដំបែរ ដៃម្ខាងបុកទៅនឹងដីដើម្បីឱ្យឮសូរឆោៗ រ៉ាវៗ ស្របជាមួយនឹងសំលេងស្គរ ដៃម្ខាងទៀត យោលតាមចង្វាក់នោះជាមួយនឹងផងខ្លួនផង។ ឯចង្រ្កង់រ៉ូងចងភ្ជាប់នឹងចង្កេះអ្នកលោតរាំ មានអ្នក ពាក់ក្រចកជាដើម ។

នៅពេលព្រានព្រៃដេញតាមបាញ់ប្រើស មានតួអង្គអ្នកកាន់ស្លាបក្ងោក ព្រាយក្រចកវែង តួយក្ស តួព្រាយ តួទន្សោង មកជួយស្ទាក់ប្រើសឱ្យចូលគន្លងព្រាន ដើម្បីឱ្យតួព្រានបាញ់សម្លាប់ប្រើស បាន ។ ត្រង់នេះមានចម្ងល់មួយថា ខ្មែរយើងច្រើននិយមថា តួយក្ស និង ព្រាយតំណាងសភាវៈអាក្រក់ ប៉ុន្តែក្នុងឱកាសនេះ ហេតុអ្វីបានជាស្រុះស្រួលគ្នាជួយកម្ចាត់ប្រើស ។ ចម្លើយគឺថា មកពី មុនចេញបរបាញ់ ព្រានព្រៃតែងរៀបចំសែនព្រេននិយាយលួងលោមពួកគេ (ព្រាយបិសាច ខ្មោច អារក្ស) ជានិច្ច។ ដូច្នេះពេលនេះ គេត្រូវតែចូលរួមជួយព្រាន ដើម្បីកម្ចាត់ឧបទ្រពចង្រៃ និងដើម្បីកុំឱ្យមានគ្រោះថ្នាក់ដល់ពួកគេដែរ ។ ឯក្ងោកតំណាងឱ្យសោណភាព ក៏ដូចជាតំណាងឱ្យ សភាវៈល្អ ក្នុងការជួយ ជ្រោមជ្រែងព្រានដើម្បីសម្លាប់ប្រើសក៏ដូចជាកម្ចាត់ឧបចង្រៃដែរ ។


www.elibraryofcambodia.org

ពេលសំដែងជិតចប់ ក្រុមរបាំច្រៀងរាំ ជម្រាបលាម្ចាស់ផ្ទះ ដើម្បីធ្វើដំណើរទៅមុខទៀត ។ អ្នកដែលឈរទស្សនាតែងមានសទ្ធាដាក់ប្រាក់ទៅក្នុងថង់ដែលព្យួរខាងចុងដងដោយនោះ ព្រោះគេ យល់ថាគ្រោះចង្រៃនឹងឃ្លាតចាកដោយការកសាងកុសល។ ថង់លុយនេះនឹងក្តោបយកឧបទ្រពចង្រៃ ពីខ្លួនគេ និងគ្រួសារគេ ។

## ២.២- របាំស្ទេចទន្សោង

### ២.២.១- ប្រវត្តិ

បើនិយាយអំពីដើមកំណើតនៃរបាំនេះ មានប្រភពលេចចេញឡើងច្រើនទាក់ទងទៅខាងរឿងនិទាន ដូចជាអ្នកភូមិអញ្ចាញរូង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង បាននិទានថា កាលនោះ មានព្រានព្រៃម្នាក់ ឈ្មោះព្រាន "ពរ" ទទួលព្រះរាជបញ្ជា ហើយក៏ចេញទៅរកបាញ់ទន្សោង ។ ព្រាន ទៅយូរណាស់ ទើបត្រឡប់ចូលគាល់ព្រះរាជាវិញ ដោយដៃទទេ គ្មានទន្សោងឡើយ ។ ស្តេចក៏ត្រាស់ សួរថា៖ "ហេតុអ្វីក៏ពុំបានទន្សោងមួយសោះដូច្នេះ?" ព្រាន ពរ ក្រាបបង្គំទូលថា៖ "ទូលព្រះបង្គំបាន ទៅដល់ព្រៃដែលសម្បូរទៅដោយសត្វទន្សោងនឹងម្រឹគដទៃៗ ប៉ុន្តែដោយទូលព្រះបង្គំរវល់តែមើលទស្សនីយភាពមួយយ៉ាងចម្លែកអស្ចារ្យណាស់ គឺសត្វទន្សោងមួយគូញីឈ្មោលចេះរាំយ៉ាងល្អ ជាហេតុនាំឱ្យទូលព្រះបង្គំជក់មើល មិនអាចបាញ់វាកើតឡើយ ។ ដំបូង ទូលព្រះបង្គំគងស្នាលើស្មា លបៗចូលទៅប្រុងតែនឹងបាញ់ដែរ តែដោយសោភណភាពនៃក្បាច់ចង្វាក់រាំរបស់សត្វនេះស្រស់ស្អាតពេក ក៏ខកខានរកតែតម្រោះព្រួញឱ្យរត់ទៅមុខមិនកើត ។ មិនតែប៉ុណ្ណោះ មានខ្លាធំមួយដែល លបមកប្រុងនឹងចាប់ទន្សោងដែរនោះក៏ចាប់មិនកើត បែរជាជួយគោះជើងជាចង្វាក់ឱ្យសត្វនេះទៅវិញ។ ឯកន្លង់មួយវ៉ូងហើរស្របទក្សិណជុំវិញទន្សោងទាំងពីរជួយធ្វើជាសូរសំនៀងពីរោះល្វើយល្វែងណាស់។

ព្រះរាជាទ្រង់ព្រះសណ្តាប់ដូច្នេះហើយ ក៏ត្រាស់បង្គាប់ឱ្យព្រានពរធ្វើត្រាប់តាមទស្សនីយភាព នោះថ្វាយព្រះអង្គទត ។ ព្រាន ពរ ក៏ខំធ្វើត្រាប់ឱ្យបានគ្រប់កាយវិការ និងសូរសៀងសត្វ ថ្វាយ ព្រះរាជាទ្រង់ទត និងទ្រង់ព្រះសណ្តាប់គ្មានសល់ចន្លោះអ្វី ។

ការសម្តែងកាយវិការរបស់ព្រាន ពរ នេះហើយ ដែលកើតបានជាវង់របាំនេះ


www.elibraryofcambodia.org

ឡើងដោយ៖

- អ្នកពាក់ស្នែងពីនោក់ជាតំណាងទន្សោងញី-ឈ្មោល
- សម្លេងស្គរតំណាងសន្ទឹកខ្លាធំ
- សម្លេងឱ្លយជាតំណាងសូរសត្វកន្លង់ ។

វង់ភ្លេងនៃរបាំនេះគេហៅឈ្មោះថា "ភ្លេងមហោរព" គឺគេសម្គាល់តាមឈ្មោះព្រានពរដែលជា អ្នកបង្កើតវាឡើង ។

ប៉ុន្តែ បើយើងដេញដោលរិះរេ គិតស្រាវជ្រាវតាមការសិក្សាតាមបែបជាតិពិន្ទុសាស្ត្រ (Etudes ethnographiques) វិញ យើងយល់បានម្យ៉ាងទៀតថា ក្នុងចំណោមជនជាតិដើមភាគតិច (Autocatone) នៅក្នុងប្រទេសកម្ពុជាយើង មានជនជាតិមួយហៅថា "ព័រ" ដែលច្រើនរស់នៅតាមជួរ ភ្នំក្រវាញ ត្រង់ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់, ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ, ស្រុកទឹកផុស ខេត្តកំពង់ ឆ្នាំង, និងស្រុកកំពង់សោម ខេត្តកោះកុង ។ របាំនេះសោតក៏មានតែត្រង់ភូមិភាគទាំងនេះដែរ។ ការណ៍នេះនាំឱ្យគេសន្និដ្ឋានបានថា ព្រាន *ពរ* នេះគឺព្រានសាសន៍ *ព័រ* ។ ដូច្នេះ របាំប្រជាប្រិយនេះកកើតឡើងពីជនជាតិព័រដែលមានសូរសៀងអានពាក្យនេះក្លាយបន្តិចមក ។ ព្រោះហេតុនេះ យើងសរុបបានថា របាំទន្សោងជាកេរតំណែលមកពីពួកព័រសម្រាប់លេងនៅពេលប្រកបពិធីអ្វីមួយ យកលំនាំ តាមរបរគ្នាគេជាអ្នកប្រមាញ់ ។

តាមសេចក្តីអធិប្បាយយ៉ាងវែងរបស់លោក រ.បាពជាត់ ក្នុងព្រឹត្តិបត្រសាលាបារាំងនៅចុងបូព៌ាប្រទេស របាំពាក់ស្នែងទន្សោងនេះប្រាកដជាកើតឡើងពីពួកជាតិព័រមែន ដោយលោកបានទៅធ្វើសេចក្តីសង្កេតដល់ទីកន្លែង រស់នៅជាមួយពួកព័រនេះអស់ពេលយ៉ាងយូរ។ លោកបានអះអាងទៀតថា លោកធ្លាប់ឃើញពួកព័រលេងរបាំនេះផ្ទាល់ភ្នែក ហើយលោកមានទាំងថតរូប ចុះផ្សាយជាមួយអត្ថបទលោកផង ។ ដូច្នេះ យើងអាចសរុបសេចក្តីបានថា បណ្តាជនដែលរស់នៅលើទឹកដីយើងពីបុរាណ មានសាសន៍ ព័រជាអាទិ៍ សុទ្ធតែបានបង្កើតរបាំលំហែចិត្តដោយប្រឌិតយកតាមលំនាំនៃការប្រកបរបរចិញ្ចឹមជីវិត គឺកាលនោះគេរស់នៅក្នុងព្រៃមានតែម្រឹគជាញាតិមិត្ត ឬជាចំណីអាហារ


www.elibraryofcambodia.org

ប្រចាំថ្ងៃ ម្ល៉ោះហើយការប្រឌិតក្បាច់រាំរែក និងប្រដាប់តាក់តែងកាយដោយផ្តេកផ្តួលទៅរករូបភាព និងកាយវិការ ម្រឹគទាំងនោះដែរ ។

ឯកសារលោក រ.បារាដាត់ (R.Baradat) បញ្ជាក់ទៀតថា របាំនេះលេងនៅក្នុងភូមិដែលសំខាន់ៗ ប៉ុន្តែខ្មែរយើងខ្លះចាំថា គេលេងនៅក្នុងវាំងសម្រាប់តែក្នុងព្រះរាជពិធីបុណ្យចូលឆ្នាំ ។

### ២.២.២- គ្រឿងភ្លេង និង អ្នកសម្តែង

- គ្រឿងភ្លេងមាន ស្គរ ២ ពួយ ១ និង កញ្ជា ១ ។

- អ្នកលេងរបាំនេះមានចំនួន ១២នាក់ មានប្រុសស្រី៖ អ្នកកាន់គ្រឿងភ្លេង ៣នាក់ អ្នកពាក់ ស្នែងទន្សោង ២នាក់ ពាក់ក្បាលសេះ ២នាក់ ពាក់កន្ទុយក្ងោក ២នាក់ អ្នកច្រៀង ២នាក់ និង អ្នកអុក កញ្ជាម្នាក់ដែលគេហៅថា "មេជាគ្រូ" ។

### ២.៣- របាំគោះអង្រែ

កាលពីសម័យដើម ប្រជាពលរដ្ឋខ្មែរយើងនិយមលេងរបាំគោះអង្រែសឹងតែគ្រប់ភូមិស្រុក ។ សព្វថ្ងៃនេះ របាំគោះអង្រែនៅសេសសល់បន្តិចបន្តួច តែកន្លែងណាដែលមានអ្នកចង់ថែរក្សានូវប្រពៃណីនេះ ឬ ក៏កន្លែងខ្លះទៀតដែលនៅឆ្ងាយពីទំនាក់ទំនងជាមួយអរិយធម៌បរទេសឬអរិយធម៌ បរទេសមិនទាន់ទៅដល់តំបន់ទាំងនោះតែប៉ុណ្ណោះ។

### ២.៣.១- ឧបករណ៍ សម្លៀកបំពាក់ និង គ្រឿងភ្លេង

- ឧបករណ៍ ៖ អង្រែពីរមានប្រវែងប្រមាណជាជាង ២ ម៉ែត្រ និងទំហំប៉ុនកំភួនដៃ ។ មានអង្រែ ២ សម្រាប់កល់ចុងសងខាង ។

- សម្លៀកបំពាក់ ៖ តាមការនិយមរបស់អ្នកចូលចិត្តរបាំនេះ គេស្លៀកខោ ទាំងប្រុស ទាំងស្រី ឯអាវ គេពាក់អាវធម្មតា។ ខោនោះជួនពណ៌ ជួនខ្មៅតាមគេស្ម័គ្រ ហើយក្រវាត់ចង្កេះយ៉ាងតឹងដោយ ក្រមាពណ៌។ មានស្រុកខ្លះទៀតគេស្លៀកខោតែប្រុសៗទេ ឯស្រីៗគេស្លៀកសំពត់ចងក្បិនឱ្យខើច បន្តិចហើយមានក្រវាត់ចង្កេះដូចគ្នា។



www.elibraryofcambodia.org

- គ្រឿងភ្លេង៖ ខ្សែជៀរ ១ និងអង្គួច ១ សម្រាប់លេងកំដរបទច្រៀងតាមចង្វាក់អង្រែដែលគេគោះទង្គិចគ្នា ។ វង់ខ្លះទៀត គេបន្ថែមស្គរអារក្ស និងក្រាប់១គូទៀត ព្រមទាំងមានអ្នកទះដៃបន្ទរ ថែមទៀត ។

**២.៣.២- របៀបសម្តែង**

អ្នកសម្តែងត្រូវមានការរហ័សរហួនខ្លាំងណាស់ ព្រោះបើភាន់ជើងតែបន្តិចនឹងមានគ្រោះថ្នាក់ ។ មនុស្ស ២ នាក់អង្គុយកាន់ចុងអង្រែម្ខាងម្នាក់ គឺកាន់ដៃទាំងសងខាងម្ខាងមួយ រួចហើយ គេទាញ អង្រែនេះ ទង្គិចគ្នាជាចង្វាក់ ព្រមទាំងគោះទង្គិចទៅនឹងកំណល់ទៀត ។

**២.៣.៣- ប្រភព**

ឯកសាររបស់លោក កុយ ហួត នៅស្រុកសូត្រនិគមខេត្តសៀមរាបបានឱ្យដឹងថា អ្នកស្រុក សូត្រនិគមហៅរបាំគោះអង្រែថា "របាំគួយ ឬ រាំគួយ" ។ បើតាមព័ត៌មាននេះ ឃើញថា ជាប់ឈ្មោះ កុលសម្ព័ន្ធខ្មែរដើមមួយដែលគេហៅថា "គួយ" ។ ព័ត៌មានមួយទៀតបានឱ្យដឹងថា របាំគោះអង្រែនេះចម្លងមកពីប្រទេសហ្វីលីពីនកាលពីជំនាន់ជ្រកាលព្រះបាទសម្តេចព្រះនរោត្តម កាលព្រះអង្គទ្រង់យាងទៅក្រុងម៉ានីល ហើយពពួកបរិពារព្រះអង្គបានរៀនចេះរបាំនេះ យកមកលេងនៅប្រទេសយើង។ លោក ដឹម ឈុំ នៅស្រុកសណ្តាន់បានបញ្ជាក់ថា របាំនេះរាលដាលទៅតាមភូមិក្រៅៗ ដោយសារមោនទាហានហ្លួង ដែលចេញទៅធ្វើសង្គ្រាមតាមនិគមជនបទនានា បាននាំយករបាំនេះទៅឱ្យអ្នកស្រុក ហាត់លេង តាមដំណើរដែលកងទ័ពលើកទៅដល់ ។

មតិមួយទៀតបង្ហាញឲ្យឃើញថា ជនជាតិគួយក្តី ហ្វីលីពីនក្តី សុទ្ធតែជាអ្នកមានកំណើតដើមបង្កើតអរិយធម៌អូស្ត្រូអាស៊ីដូចគ្នា ។ ដូច្នេះ របាំនេះមានដើមកំណើតមកពីមនុស្សជាន់ដើមទាំងនោះ មិនប្រាកដជារបស់ជនជាតិណាតែម្នាក់ឯងឡើយ ។

**២.៤- របាំត្រោកប៉ៃលិន**

របាំត្រោក គេប្រទះឃើញជាពិសេសនៅតំបន់ប៉ៃលិន។ របាំនេះមានប្រភព



www.elibraryofcambodia.org

កំណើតពីជនជាតិ *កុឡា* ដែលរស់នៅតែតំបន់នេះតាំងពីយូរលង់មកហើយ ដ្បិតទំនុកចម្រៀងមិនទាន់មានលាយបញ្ចូលនូវពាក្យខ្មែរសុទ្ធនៅឡើយ ពោលគឺគេច្រៀងជាភាសាកុឡា ដែលមានន័យជាការបួងសួងសុំឲ្យសេចក្តីសុខចម្រើនកើតមានដល់អ្នកស្រុក ។ របាំក្ងោកនៅប៉ៃលិន គេលេងនៅតែក្នុងពេលបុណ្យចូលឆ្នាំ ដើម្បីជួយលើកតម្កើងឱកាសនេះឲ្យសប្បាយរីករាយឱឡារិកឡើង ឬមួយ លេងនៅឱកាសពិសេសៗណាមួយដែលគេឃើញថាជាការគួរ។ រាល់ពេលមានការសម្តែងរបាំនេះម្តងៗ អ្នកស្រុកតែងទុកដាក់វេលានោះដូចជា បុណ្យទានអ្វីមួយអ៊ឹកអធឹកណាស់ សឹងលះបង់ការងារមួយពេលមួយគ្រានោះ មកប្រមូលប្រជុំចោមរោម ជួយលើកទឹកចិត្តវង់របាំ និង សប្បាយរីករាយជាមួយផង។

### ២.៤.១- គ្រឿងភ្លេង និង អ្នកសម្តែង

ប្រដាប់ភ្លេងសម្រាប់លេងរបាំនេះមាន ស្គរវែង(សណ្ឋានដូចស្គរឆៃយ៉ាំ) ស្រឡៃ ស្គរខ្លី (មាន សណ្ឋានដូចស្គរដៃ) ឆាប ឈិង និង គងម៉ង់ ។ ឯអ្នកសម្តែងរបាំនេះមានអ្នកធ្វើក្ងោក (ស្រី១ ប្រុស១) ដែលមានអលង្ការសម្រាប់តុបតែងខ្លួនឲ្យមានរូបរាងដូចក្ងោកមែនទែន ។ អ្នកឯទៀតស្លៀក ពាក់ធម្មតាបែបជនជាតិកុឡា (ស្រីមានបាំងតាំងយូ ផង) ។

### ២.៤.២- ប្រភពនៃរឿងនិទាន

អ្នកស្រុកប៉ៃលិនបានបរិយាយអំពីកំណើតរបាំនេះតាមរឿងនិទានដែលដំណាលថា កាលពីយូរលង់មកហើយ នៅរាត្រីមួយ បុត្រីក្សត្រមួយព្រះអង្គដែលមានព្រះឆោមស្រស់ស្អាតដាច់គេ បានសុបិនឃើញ មានក្ងោកឈ្មោលមួយពង់យ៉ាងល្អ ចេះចម្រើនមន្តអាគម និង ទេសនាយ៉ាងពីរោះក្បោះក្បាយ ថ្វាយព្រះនាងសណ្តាប់ ។ ចាប់ពីថ្ងៃនោះមក ព្រះនាងតែងរំពឹងក្នុងព្រះចិន្តាថា មិនដឹងធ្វើយ៉ាងណា នឹងបានក្ងោកនោះមកទេសនាថ្វាយព្រះនាងសណ្តាប់។ មានព្រះទ័យបែបនេះយូរទៅ ព្រះនាងក៏ចេះតែមានព្រះភក្រ្តស្រពោន ហើយបណ្តាលឲ្យស្តេចជាបិតាកត់សម្គាល់ និងមានព្រះរាជតម្រាស់សួរដឹងការណ៍។ ស្តេចក៏បានបញ្ជាឲ្យព្រានម្នាក់ទៅតាមរកក្ងោកនោះ នៅឯព្រៃជ្រៅ ។



www.elibraryofcambodia.org

ព្រានចូលទៅរកក្ងោកតាមព្រះរាជបញ្ជា ។ ព្រានចេះតាមរកក្ងោកគ្រប់ច្រកល្ហក លុះព្រឹកមួយ គាត់បានឃើញក្ងោកឈ្មោលមួយដ៏ស្រស់ឆើតឆាយឈរភាវនាធម៌លើមែកឈើ បែរមុខទៅទិសខាង កើត ។ ភាវនាធម៌រួចហើយ ក្ងោកនោះក៏លោតចុះមកដីរាំហាក់ដូចជាសប្បាយរីករាយខ្លាំងណាស់។ ព្រាននោះអរពន់ពេកណាស់ ក៏លើកស្នាផ្គងបាញ់ ប៉ុន្តែបាញ់ជាច្រើនលើក បាញ់មិនត្រូវសោះ ។ ព្រាននោះក៏គិតថា ប្រហែលក្ងោកចេះមន្តអាគមហើយ ទើបខ្លួនបាញ់មិនត្រូវ ។ មួយថ្ងៃពីរថ្ងៃក្រោយមក ទើបព្រានដឹងថា ក្ងោកនោះតែងតែភ្ញាក់ពីព្រលឹម តាំងសីលសែកមន្តគាថា ប្រណម្យឆ្ពោះទៅព្រះអាទិត្យឯទិសខាងកើត លុះល្ងាចឡើង មុនចូលទ្រនំ ក៏ភាវនាបែរមុខទៅទិសខាងលិច។ ព្រានក៏នឹកឃើញមធ្យោបាយធ្វើឲ្យក្ងោកភ្លេចភាវនាធម៌ដើម្បីឲ្យខ្លួនបាញ់បានដោយចាប់យកក្ងោកញីមួយ ដ៏ស្រស់ប្រិមប្រិយមកបញ្ឆោតក្ងោកឈ្មោល។ ព្រឹកឡើងបម្រុងនឹងទទះស្លាបភាវនាធម៌កម្មហើយ គ្រាន់តែក្រឡេកឃើញក្ងោកញីភ្លាម ក្ងោកឈ្មោលក៏លោតចុះមករកនាងមយូរីដ៏ស្រស់នោះ។ ព្រានក៏ចាប់ក្ងោកនោះបាន ។ ក្ងោកសួរថា៖

- ព្រានអើយ! ព្រានប្រាថ្នាខ្ញុំយកទៅធ្វើអ្វី? ខ្ញុំនេះខំលះបង់ព្រៃរៀងអាយមកនៅព្រៃជ្រៅ ប្រាថ្នាឲ្យផុតពីការសៅហ្មង និង របរប្រមាញ់នេសាទគ្រប់យ៉ាង ហេតុអ្វីក៏ព្រានតាមមកធ្វើ បាបខ្ញុំទៀត?
- ក្ងោកអើយ! ខ្ញុំមិនមែនយកអ្នកទៅសម្លាប់ទេ បុត្រីព្រះរាជាទ្រង់សុបិនឃើញក្ងោកចេះទេសនា ទេសនាថ្វាយព្រះនាងសណ្តាប់ ទើបព្រះរាជាបញ្ជាខ្ញុំឲ្យមករក ខ្ញុំឃើញអ្នកចេះភាវនាធម៌ ទើបខ្ញុំយកអ្នកទៅថ្វាយព្រះនាងតែប៉ុណ្ណោះ ។
- (ក្ងោកសើច) បើដូច្នោះ សូមអ្នកកុំព្រួយ ខ្ញុំនឹងទៅសម្តែងធម៌ថ្វាយព្រះនាងសណ្តាប់ជា រៀងរាល់ថ្ងៃសីល ចាប់ពីសីលនេះតទៅ។

ចាប់ពីពេលនោះ ក្ងោកតែងតែហិចហើរមកថ្វាយធម្មទេសនាថ្វាយព្រះរាជបុត្រីជានិច្ច។ អាស្រ័យហេតុនេះ ទើបខ្មែរកុឡានៅប៉ៃលិនតែងតែលេងរបាំនេះនៅថ្ងៃសីល ។



www.elibraryofcambodia.org

### ៣- របាំប្រជាប្រិយខ្មែរ

របាំប្រជាប្រិយខ្មែ ជាប្រភេទរបាំដែលប្រជាជននិយមចូលចិត្តយកមកបង្ហាញ ឬរាំលេងកម្សាន្ត ក្នុងពេលជួបជុំនៃពិធីអ្វីមួយដែលសប្បាយដូចជា ពិធីបុណ្យចូលឆ្នាំជាដើម ។ របាំប្រជាប្រិយខ្មែរមាន របាំរាំវង់ រាំក្បាច់ ជាដើម ។

### ប្រវត្តិសង្ខេបនៃរបាំ *រាំវង់- រាំក្បាច់* ប្រជាប្រិយខ្មែរ

រាំវង់-រាំក្បាច់ មិនខុសពីល្បែងប្រជាប្រិយបោះឈូង លាក់កូនខ្លែង បោះអង្គុញ ស្តេចចង់ ឬ ល្បែងឯទៀតដែលខ្មែរនិយមនាំគ្នាលេងកម្សាន្តក្នុងពិធីបុណ្យប្រពៃណីនានា ពិសេសគឺបុណ្យចូលឆ្នាំនោះឡើយ ។ របាំប្រជាប្រិយ រាំវង់-រាំក្បាច់ គឺជាប្រភេទរបាំដែលមានការនិយមជាទូទៅនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ទោះនៅទីក្រុង ក៏ដូចជាជនបទ នៅតំបន់ភ្នំក៏ដូចជានៅវាលទំនាប ឬតំបន់មាត់សមុទ្រ ។ របាំប្រជាប្រិយខ្មែរនេះជាប្រភេទរបាំដែលងាយចាំ ងាយចេះ ហើយងាយក្នុងការរៀបចំ សម្តែងទៀតផង។ អាស្រ័យហេតុនេះ ទើបគេសង្កេតឃើញជនជាតិខ្មែរ តាំងពី នាម៉ឺនសព្វមុខមន្ត្រី រហូតដល់ប្រជារាស្ត្រ ទាំងក្មេងទាំងចាស់ ប្រុសស្រីចេះរាំរបាំនេះគ្រប់ៗគ្នា ។

ពាក្យថា រាំវង់ គឺជាលក្ខណៈពិសេសមួយសម្រាប់សម្គាល់រូបភាពនៃរបាំនេះ ពោលគឺពេលរាំ គេនាំគ្នារាំបន្តគ្នាជារង្វង់មួយ ។ ហើយជារបាំសម្រាប់រាំលេងកម្សាន្ត ឬក៏រាំដើម្បីបំបាត់ការនឿយហត់ ក្រោយពីការបំពេញពលកម្មនានារួច ។

ចំពោះប្រវត្តិកំណើតនៃរបាំរាំវង់នេះវិញ

បើយើងពឹងផ្អែកលើឯកសារសរសេរដែលមានបន្តិច បន្តួចនិងពឹងផ្អែកលើសភាពជាក់ស្តែង ក្នុងជីវិតដែលមានប្រព្រឹត្តដល់សព្វថ្ងៃនេះ យើងជឿថា សិល្បៈ រាំវង់នេះមានអាយុច្រើនសតវត្សណាស់មកហើយ នៅលើទឹកដីនៃមាតុភូមិកម្ពុជានេះ ។ ព្រោះតាំងពីបុរាណដ៏យូរលង់ ទាំងជនជាតិខ្មែរ និង ជនជាតិឯទៀត ដែលស្ថិតក្នុងអម្បូរជាមួយគ្នា ដូចជា ព្នង គ្រឹង ទំពួន ព្រៅ... មានទំនាក់ទំនងរាំជាវង់ ឬ ជារង្វង់មូលនេះជាច្រើន។

បងប្អូនជាជាតិខ្មែរលើនៅភូមិភាគឦសាននៃប្រទេស និង តំបន់ព្រៃដទៃទៀតនិយមរាំលេងកម្សាន្តនៅជុំវិញភ្នក់ភ្លើងនាពេលរាត្រី ។ ទម្លាប់រាំវង់ជុំវិញភ្នក់ភ្លើងនេះ



www.elibraryofcambodia.org

មានច្រើនពាន់ឆ្នាំមកហើយ ហើយមានសេសសល់រហូតដល់សព្វថ្ងៃនេះ ។

ក្នុងពិធីលៀងអារក្ស ឡើងអ្នកតា (ជំនឿខ្មែរដើមដែលមានតាំងពីយូរលង់ មុនសម័យដែលព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាហូរចូលមកសុវណ្ណភូមិ គឺតាំងពីមុន ៣០៩ ឆ្នាំមុនគ.ស. ជនជាតិខ្មែរតែងតែនាំគ្នាសង់រោងតូចមួយដោយធ្វើរាជវត្តព័ទ្ធជុំវិញ ហើយរូបមេមត់ (អ្នកចូលរូប) តែងតែរាំជារង្វង់មូលនៅជុំវិញរោងនោះ ក្នុងពេលប្រារព្ធពិធីលៀងអារក្សនេះ ។

ឯពិធីកាប់ក្របីថ្វាយអ្នកតារបស់បងប្អូនជនជាតិ ពួង គ្រឹង ទំពួន ដែលមានអាយុតាំងពីច្រើនពាន់ឆ្នាំមកហើយ ព្រមទាំងមានរូបចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន ហើយដែលបងប្អូនជនជាតិ ទាំងនេះថែរក្សាឱ្យនៅគង់វង្សរហូតដល់សព្វថ្ងៃនេះ ក៏គេមានទម្លាប់រាំជារង្វង់មូលដែរ ។

លើសពីនេះទៅទៀត បងប្អូនជនជាតិ ព្រៅ ពួង គ្រឹង ទំពួន នៅប្រកាន់ខ្ជាប់ទំនៀម «រាំវង់ភូមិថ្មី» ដែលជាភាសាជនជាតិនិយាយថា «រាំវង់ស្រុកហាន់ទើម» ។ របាំរាំវង់ភូមិថ្មី គេមានទម្លាប់ធ្វើនៅពេលប្តូរភូមិពីភូមិចាស់ទៅរស់នៅក្នុងភូមិថ្មី ។ តាមធម្មតា ក្នុងរយៈពេលពីបីទៅប្រាំពីរឆ្នាំ មុននឹងប្តូរភូមិ ឬចាកចេញពីភូមិចាស់ មេកន្ទ្រាញ និង ចាស់ទុំក្នុងភូមិ តែងនាំគ្នាធ្វើពិធីផ្សងទៅតាម ជំនឿរបស់ខ្លួន ដើម្បីរកកន្លែងដីថ្មី ដែលមានលក្ខណៈភូមិសាស្ត្រល្អ មានទឹកគ្រប់គ្រាន់ និងជាកន្លែងដែលអាចការពារសន្តិសុខជូនញាតិមិត្តក្នុងស្រុកភូមិបានល្អ ។ ពេលផ្សងរើសដីថ្មីបានហើយ ទើបគេនាំគ្នាធ្វើពិធីកំណត់ឆ្នាំសម្រាប់រស់នៅ គឺធ្វើឱ្យដឹងថា តើពួកគេអាចរស់នៅបានប៉ុន្មានឆ្នាំនៅនឹងភូមិថ្មីនោះ ។ ពិធីកំណត់ឆ្នាំសម្រាប់រស់នៅនេះ ប្រព្រឹត្តទៅ ដោយមេកន្ទ្រាញ និង ចាស់ទុំក្នុងភូមិយក ប្រទាលមកចិតទម្លាក់មកលើដីចំនួនប្រាំពីរចំណិត។ បើប្រទាលនេះក្រឡាប់ប៉ុន្មានចំណិតនោះ គេជឿថាគេអាចរស់នៅក្នុងភូមិថ្មីនោះបានប៉ុណ្ណឹងឆ្នាំដែរ គឺតាមចំនួនចំណិតប្រទាលដែលក្រឡាប់នោះ ។ ដូចជា បើប្រទាលក្រឡាប់បី ឬប្រាំចំណិតនោះ គេអាចរស់នៅទីនោះបានបី ឬប្រាំឆ្នាំដែរ ។ ជំនឿនេះ មានរហូតតាំងពីបុរាណកាលយូរលង់ណាស់មកហើយ។ ពេលធ្វើពិធីផ្សងរកដីថ្មីបានហើយ



www.elibraryofcambodia.org

មេកន្ទ្រាញក៏ប្រកាសឱ្យអ្នកស្រុកអ្នកភូមិរុះរើពីភូមិចាស់ទៅរៀបចំផ្ទះសម្បែងនៅភូមិថ្មី។ ពេលនាំគ្នាចូលទៅភូមិថ្មី ជាដំបូងគេនាំគ្នាប្រារព្ធពិធីសម្តែងរបាំរាំវង់ភូមិថ្មីនេះមុនគេបង្អស់ ។ អ្នកស្រុក អ្នកភូមិ មានស្រី មានប្រុសនាំគ្នារាំជាគូ (តាមប្រពៃណីពីដូនតាតៗគ្នារហូតដល់បច្ចុប្បន្ននេះ ដែលមានជំនឿថា នឹងនាំឱ្យគេគ្រប់ៗគ្នា បានសេចក្តីសុខចម្រើន) ។

ការរៀបរាប់ខាងលើនេះ របាំរាំវង់នៅប្រទេសកម្ពុជានេះ មានតាំងពីយូរយារណាស់មកហើយ ជារបាំដែលជាប់នឹងពិធីប្រពៃណី តែលុះចំណេរកាលក្រោយមក ទើបក្លាយទៅជារបាំប្រជាប្រិយ ដែលមានការនិយមចូលចិត្តពីគ្រប់មជ្ឈដ្ឋានក្នុងសង្គមជាតិកម្ពុជាទាំងមូល ។ ហើយក្រោយមកទៀត ក្នុងពេលដែលប្រទេសជិតខាងមាន សៀម និង លាវ បានចាប់កំណើតឡើង របាំរាំវង់ នេះ ក៏ដូចជាទម្រង់សិល្បៈឯទៀតដែរ បានហូរចុះហូរឡើងឬក៏ជះឥទ្ធិពលឆ្លងគ្នាទៅវិញទៅមករវាងខ្មែរ និង លាវ ខ្មែរ និង សៀម ពិសេសនៅគ្រប់តំបន់ជាយដែន និង តំបន់ដែលមានប្រជាជនខ្មែរលាវ ឬខ្មែរសៀមរស់នៅលាយឡំគ្នាច្រើននោះ ។

បើតាមឯកសារខ្លះៗដែលនៅសល់ និង តាមព័ត៌មានដែលយើងទទួលបានពីចាស់ទុំជាច្រើន នៅប្រទេសកម្ពុជា របាំប្រជាប្រិយរាំវង់ រាំក្បាច់នេះបានរីកចម្រើនយ៉ាងខ្លាំងនៅក្នុងសតវត្សទី ២០ នេះ ពិសេសគឺតាំងពីពេលដែលចលនាខ្មែរឥស្សរៈកើតមាននៅគ្រប់តំបន់ក្នុងប្រទេស និង កងជីវពលនារីក្លាហានក្រោកឡើងបណ្តេញអាណានិគមនិយមបារាំងដើម្បីទាមទារឯករាជ្យជូនជាតិមាតុភូមិនោះមក ហើយដែលគេអាចឃើញមានសល់នូវបទចម្រៀងរាំវង់មួយចំនួនដែលជាតឹកតាង ឬជាអនុស្សាវរីយ៍នៃសម័យកាលនោះផង ។ ហើយក៏ប្រហែលនៅក្នុងពេលនោះដែរ ដែលឥទ្ធិពលនៃពាក្យបរទេស ដូចជាពាក្យថា រាំ «ឡាំថូន» ឬ ឡក «ឡាំថូន» (ថូន គឺស្គរ) ត្រូវខ្មែរយកមកប្រើ ព្រោះពេលនោះ កងទ័ពខ្មែរឥស្សរៈដែលបោះទីតាំងក្នុងព្រៃជ្រៅៗនៃតំបន់ភ្នំដងរែក តំបន់ឱរ៉ាល់ ក្រវាញ តំបន់ភាគ ឦសាននៃប្រទេស (ដែលអាចចងសម្ព័ន្ធជាមួយឥស្សរៈលាវ) ឬតំបន់មាត់សមុទ្រក្តី ច្រើននាំគ្នាលេងរាំវង់ ដោយប្រើតែស្គរដៃ



www.elibraryofcambodia.org

មួយប៉ុណ្ណោះ និងចម្រៀងដែលមានលក្ខណៈងាយស្រួលក្នុងការកម្សាន្ត ទៅតាមកាលៈទេសៈនៃការតស៊ូនិងការរស់នៅដោយយកព្រៃជ្រៅជាមូលដ្ឋានបង្អែក។ សូមបញ្ជាក់ថា ស្គរដៃនេះជាស្គរនៃវង់ភ្លេងអារក្ខ ឬវង់ភ្លេងប្រជាប្រិយ ឬក៏ភ្លេងការរបស់ជនជាតិខ្មែរ ដែលមានកំណើតរាប់ពាន់ឆ្នាំមកហើយ ។ តាំងពីពេលស្រុកខ្មែរបានឯករាជ្យក្រោមព្រះរាជកិច្ចដឹកនាំនៃព្រះករុណា ព្រះបាទនរោត្តម សីហនុវរ្ម័ន ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ មក ប្រទេសជាតិ និង ប្រជារាស្ត្រមាន សេរីភាពគ្រប់គ្រាន់ របាំប្រជាប្រិយ រាំវង់ រាំក្បាច់ក៏បានរីកចម្រើនយ៉ាងខ្លាំងក្លា ពោលគឺនៅកន្លែងខ្លះ គេរាំជាមួយស្គរដៃ ពេលខ្លះគេរាំជាមួយវង់ភ្លេងខ្មែរដែលមានឧបករណ៍ ស្គរ ទ្រ រនាត និងឧបករណ៍ ច្រើនផ្សេងៗទៀតរហូតដល់វង់តន្ត្រីសម័យយ៉ាងទំនើប ដែលយើងឃើញតរហូតដល់សព្វថ្ងៃនេះផង ។

**របៀបសម្តែង**

ដូចបានជម្រាបខាងលើមកហើយថា រាំវង់ រាំក្បាច់ ជារបាំប្រជាប្រិយខ្មែរដែលមានលក្ខណៈ ងាយស្រួល ងាយចេះ ទាំងក្បាច់ក្បូរ ប្រើដៃ ជើង ក ចង្កេះ ទៀតសោតក៏សាមញ្ញណាស់ដែរ ។ ឯចង្វាក់វិញមិនយឺតពេក ហើយក៏មិនញាប់ពេកដែរ គឺបើស្តាប់សម្លេងស្គរដៃឮ «ប៉ាក់ ពើង ប៉ាក់(ៗ)» យ៉ាងនេះ ។ ក្នុងពេលរាំទាំងស្រីទាំងប្រុសត្រូវបោះជំហាន ឆ្វេងស្តាំទៅមុខ ដោយស្រីរាំនៅខាងមុខ ប្រុសរាំនៅពីក្រោយបន្តគ្នា ឬពេលខ្លះ រាំកៀងគ្នា ឬជម្រុញឱ្យប្តូរគូក៏មាន ។ ឯដៃត្រូវ «ដឹប» ពីក្រោម ហើយលើកចំពីមុខទៅ «លា» ខាងលើ ឆ្លាស់គ្នា ឆ្វេងម្តង ស្តាំម្តង ហើយលៃដៃនិងជើងនោះឱ្យឆ្លាស់គ្នា ផងដែរ គឺបើឈានជើងស្តាំទៅមុខត្រូវលើកដៃឆ្វេង ហើយបើឈានជើងឆ្វេងទៅមុខវិញ ត្រូវលើកដៃស្តាំ ។ល។ ជួនកាល គេរាំធ្វើដំណើរទៅមុខបីជំហាន រួចគោះជើងមកខាងក្រោយ «មួយ» ក៏មាន ហើយចេះតែបន្តយ៉ាងនេះជារង្វង់មូលរហូតទៅ ។

ឯចង្វាក់ភ្លេងរាំវង់វិញ ជាទូទៅពេលចាប់ផ្តើមច្រើនតែស្ថិតនៅក្នុងចង្វាក់នឹង ឬស្មើធម្មតា លុះជិតចាប់បទនីមួយៗក្រុមតន្ត្រីច្រើនតែប្រគំរន្ថើនឡើងៗ «ញាប់ឡើងៗ» រហូតដល់ចប់។



www.elibraryofcambodia.org

ចំណែកខាងរាំក្បាច់វិញក៏មានលំនាំប្រហាក់ប្រហែលគ្នា និងក្បាច់រាំវង់ដែរ គឺដៃត្រូវ «ជីប» ពីក្រោម ហើយវាសលើកឡើងខ្ពស់រួចទៅ"លា"នៅខាងលើ ខាងឆ្វេងម្តងខាងស្តាំម្តងវេនគ្នា ដោយលៃ ឱ្យឆ្លាស់គ្នា និងជើងដែលបោះខ្វែងគ្នាឈានទៅមុខនោះផង ពោលគឺបើបោះជើងស្តាំឈានទៅមុខ ខ្វែងជើងឆ្វេងដែលទ្រទម្ងន់ដងខ្លួន ដៃឆ្វេងដែល"ជីប"ពីក្រោមត្រូវវាសលើកឡើងខ្ពស់ឡើងលើត្រឹមចុងចិញ្ចើមហើយ "លា" ទៅខាងឆ្វេង ។ លុះដល់ឈានជើងឆ្វេងទៅមុខខ្វែងនឹងជើងស្តាំ ដែលទ្រទម្ងន់ដងខ្លួនវិញនោះ ដៃស្តាំដែល «ជីប» នៅខាងក្រោមត្រូវលើកឡើងខ្ពស់រួច «លា» ខាងស្តាំវិញម្តង ធ្វើចលនាយ៉ាងនេះក្នុងដំណើររាំឈានទៅមុខជារង្វង់មូលដូចរាំវង់ដែរ ខុសតែចង្វាក់នោះយឺតជាង គឺបើស្តាប់ជើងស្គរឃើញ «តាក់ៗ ទីងៗ» ឬ «ប៉ាកៗ តើងៗ» យ៉ាងនេះ។ ឯការតុបតែងលំអទី សម្រាប់រាំវិញ វាមានលក្ខណៈសាមញ្ញាបំផុត គឺមានតែទីលានស្អាត និង តុដាក់ផ្កាមួយដែលគេចាត់ ទុកជាស្នូលកណ្តាលប៉ុណ្ណោះ ។ ប៉ុន្តែនៅសម័យថ្មីនេះឃើញគេមានតុបតែងលំអភ្លើង ឬអ្វីផ្សេងៗទៀត ទៅតាមភាពសម្បូរបែបរបស់កន្លែងនីមួយៗទៀតផង ។

នៅក្នុងប្រភេទសិល្បៈរបាំប្រជាប្រិយ នៅប្រទេសកម្ពុជាយើងនេះ ក្រៅពីរាំវង់ និងរាំក្បាច់ ដែល ជារបាំមូលដ្ឋានរបស់ជនជាតិខ្មែរនោះ នៅមាន «ឡាំលាវ» និង «សារ៉ាវ៉ាន់» ថែមទៀត ដែលមាន ប្រជាប្រិយភាពធំធេង ហើយមានការនិយមរាំគ្នាជាមួយរាំវង់និងរាំក្បាច់ជានិច្ចនោះផង ។ ចំពោះរបាំ ឡាំលាវ ដែលមានចង្វាក់ញាប់រន្ថើន និង របាំសារ៉ាវ៉ាន់នេះ យើងត្រូវតែទទួលស្គាល់ថា នេះគឺពិតជា ឥទ្ធិពលរបស់សិល្បៈលាវ ដែលបានហូរចូលមកប្រទេសកម្ពុជាក្នុងឋានៈ ជាមិត្តភក្តិ និងជាបងប្អូន និងជាអ្នកភូមិផងរបងជាមួយ ហើយត្រូវបានជនជាតិកម្ពុជានិយមរាប់អានយ៉ាងក្រៃលែង ។ ដូច្នេះ "ខ្មែររាំឡាំលាវ" គឺបានសេចក្តីថា "ខ្មែររាំបែបលាវ ឬ ចម្លងរបៀបរាំតាមជនជាតិលាវ" ថ្វីដ្បិតតែមិនបានចម្លងឱ្យដូចគ្នាបេះបិទឬក៏ដូចលាវសុទ្ធសាធក្តី។ ឯសារ៉ាវ៉ាន់វិញ វាគឺជាឈ្មោះខេត្តមួយរបស់ ប្រទេសលាវជាប់គ្នា នឹងខេត្តអាត់តៈពើ ហើយដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីខេត្តស្ទឹងត្រែងរបស់ ប្រទេសកម្ពុជាយើងនេះ



www.elibraryofcambodia.org

ឡើយ ។ ដូច្នេះ ក្បាច់សារ៉ាវ៉ាន់នោះក៏ជាភស្តុតាងគួសបញ្ជាក់ថា វាមានប្រភពដើម ចេញមកពីខេត្តសារ៉ាវ៉ាន់នេះឯងពិតប្រាកដ ។

ខ្មែររាំវង់កម្សាន្តក្នុងពិធីអាពាហ៍ពិពាហ៍មង្គលការកូនប្រុសស្រី ពិធីជប់លៀង ពិធីបុណ្យ តាមគ្រួសារ ឬក៏រាំកែកម្សាន្តពេលជួបជុំញាតិមិត្តជិតឆ្ងាយ ឬរាំដើម្បីបំបាត់ការនឿយហត់ ក្រោយពេល ធ្វើពលកម្មនានាថែមទៀតផង ។ រហូតមកដល់សព្វថ្ងៃនេះ គេសង្កេតឃើញរបាំប្រជាប្រិយ រាំវង់ រាំក្បាច់ ឡាំលាវ សារ៉ាវ៉ាន់ ត្រូវបានគេនិយមរាំលេង នៅតាមរង្គសាលនានាលាយចម្រុះនឹងក្បាច់រាំ បរទេសនានាជារៀងរាល់រាត្រីផងដែរ ។

ចំពោះការប្រើកាយវិការ និង ក្បាច់ដៃ«ជីប» ពីក្រោមហើយលើកឡើង «លា» នោះវិញ មាន មតិភាគច្រើនយល់ថា នោះគឺជាការបង្កើតសាមគ្គីភាពរវាងគ្នានិងគ្នាផង ការបង្ហាញពីសុភមង្គលក្នុង ជីវិតខ្មែរផង និងជាតំណាងវដ្តនៃជីវិត ដែលត្រូវតែមាន ពលកម្មដាំដុះផលដំណាំសាចុះសាឡើង បន្ត ជានិច្ចនិរន្តរ៍មិនចេះចប់ ដើម្បីទ្រទ្រង់ជីវិត និងការចាំបាច់នៃការបន្តពូជពង្សវង្ស ត្រកូល (បន្តវេន) នៃជម្មជាតិនិងមនុស្ស ពិសេស គឺ ពូជពង្សវង្សត្រកូលខ្មែរនេះតែម្តង ។


www.elibraryofcambodia.org

# ជំពូក ៤
# ជំនឿ ទំនៀមទម្លាប់ និង ប្រពៃណីខ្មែរ
## ១
## ជំនឿ

វចនានុក្រមខ្មែរ បោះពុម្ពដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៅឆ្នាំ១៩៦៨ បានពន្យល់ ពាក្យនេះ នៅត្រង់ទំព័រទី២៧៤ ថា ជំនឿ គឺជាសេចក្តីដែលគួរជឿ ឬ ដំណើរជឿ។ ចំណែកអ្នកស្រាវជ្រាវខ្លះទៀតបានពន្យល់ពាក្យនេះថា ជំនឿគឺជាការជឿចិត្តស៊ប់ ដោយយល់ថាពិត ឬការយកចិត្តទុកដាក់ថាជា ការណ៍មែន[17]។

ជំនឿកើតឡើងស្របពេល ដែលមនុស្សលោក បានជួបនឹងភយន្តរាយ ឬ បញ្ហាណាមួយ ហើយគេពុំអាចដោះស្រាយដោយកម្លាំងកាយ និងកម្លាំងប្រាជ្ញា របស់ខ្លួនបាន គេក៏ចាប់ផ្តើមពឹងពាក់ និងជឿលើកម្លាំងក្រៅខ្លួន។ គេជឿថា កម្លាំងក្រៅខ្លួនទាំងនោះ អាចធ្វើឱ្យមនុស្សបានសេចក្តីសុខ ឬជួបនឹងមហន្តរាយបាន។ ហេតុនេះពួកគេក៏គោរពជឿលើកម្លាំងក្រៅខ្លួនទាំងនោះ និងបានធ្វើពិធីបូជាបន់ស្រន់អង្វរតាមរបៀបផ្សេងៗ ដើម្បីសុំសេចក្តីសុខ។

មនុស្សគ្រប់ជាតិសាសន៍នៅលើពិភពលោក សុទ្ធតែមានជំនឿប្រចាំជាតិរៀងៗខ្លួនតាំងពីយូរណាស់មកហើយ។ យ៉ាងណាមិញ ខ្មែរក៏ជាជាតិសាសន៍មួយ ដែលមានជំនឿប្រចាំជាតិខ្លួនរួចទៅហើយ មុនការមកដល់នៃឥណ្ឌានីយកម្មនាដើមគ្រិស្តសតវត្សមកម្ល៉េះ។ អ្នកស្រាវជ្រាវនិយមហៅជំនឿដើមនៃជនជាតិខ្មែរថា «ជំនឿជីវចល» ឬ «លទ្ធិព្រលឹង» ដែលជាជំនឿទៅលើអភិធម្មជាតិ។ រហូតមកដល់សព្វថ្ងៃនេះ ខ្មែរមានជំនឿជាច្រើនផ្សេងទៀត ដែលគួរឱ្យកត់សម្គាល់។ ជំនឿ សំខាន់ៗរបស់ជនជាតិខ្មែរ មានដូចជា៖

---

[17] សុង ស៊ី, ***ជំនឿចាស់ មនុស្សថ្មី*** បោះពុម្ពលើកទី១ ឆ្នាំ១៩៩៦ ទំព័រ១។


www.elibraryofcambodia.org

### ១- ជំនឿលើព្រលឹង

ជំនឿលើព្រលឹង គឺជាជំនឿដើមរបស់ជនជាតិខ្មែរតាំងពីបុរមបុរាណកាលមក ហើយបានក្លាយជាជំនឿចាក់ឫសក្នុងផ្នត់គំនិតខ្មែរ។ គេជឿថា ព្រលឹងបុព្វបុរស ដែលបានស្លាប់ទៅ មិនទៅណាឆ្ងាយឡើយ ហើយព្រលឹងនោះទៀតសោត ក៏តែងតាមមើលថែរក្សាមនុស្សជំនាន់ក្រោយជានិច្ច។ ជំនឿលើព្រលឹងរបស់ជនជាតិខ្មែរនេះ រួមមាន៖

### ១.១- ជំនឿលើព្រលឹងម្ដាយឪពុក

ដោយសារតែកាលពីនៅរស់ ម្ដាយឪពុកគឺជាអ្នកមានគុណដ៏ធ្ងន់ចំពោះកូនៗ ហេតុនេះហើយ បានជានៅពេលគេជួបបញ្ហា ទុក្ខលំបាកឬគ្រោះថ្នាក់ដោយប្រការណាមួយ គេរមែងរំលឹក និងបន់ស្រន់ សុំជំនួយពីព្រលឹងរបស់លោកទាំងពីរ។ ជាក់ស្ដែង រហូតដល់សព្វថ្ងៃនេះ មានប្រជាជនខ្មែរមួយចំនួន ចូលចិត្តតាំងរូបថតម្ដាយឪពុក ដែលបានទទួលអនិច្ចកម្មទៅហើយនោះ ដើម្បីគោរពបូជានៅក្នុងផ្ទះសម្បែង។ នៅរៀងរាល់ថ្ងៃសីល ឬនៅក្នុងពិធីបុណ្យធំៗដូចជា បុណ្យចូលឆ្នាំខ្មែរ និងបុណ្យភ្ជុំបិណ្ឌ ជាដើម ជនជាតិខ្មែរនិយមរៀបចំថ្វាយផ្លែឈើ និងផ្កា សែនព្រេន និងបង្សុកូលឧទ្ទិសកុសលជូនព្រលឹងអ្នកមានគុណ និងសុំសេចក្ដីសុខចម្រុងចម្រើន។ ម្យ៉ាងទៀត យើងសង្កេតឃើញថា ដោយសារតែមាន ជំនឿលើព្រលឹងម្ដាយឪពុក ទើបមានកូនៗខ្លះចូលចិត្តសុំផ្ទេញម្ដាយឪពុកមកស្រោបមាស ឬឆ្លាក់ជា រូបព្រះ ពាក់នៅនឹងខ្សែក ដើម្បីរំលឹកគុណជាប្រចាំទៀតផង។

### ១.២- ជំនឿលើព្រលឹងមេបា

គេតែងជឿថា នៅពេលកូនចៅប្រព្រឹត្តខុសឆ្គងនឹងព្រលឹងមេបា (មានព្រលឹងជូនតា ម្ដាយឪពុក ព្រមទាំងញាតកា ដែលបានចែកឋានទៅហើយ) ព្រលឹងទាំងនោះនឹងដាក់ទណ្ឌកម្ម សមាជិកគ្រួសារណាម្នាក់ឱ្យមានជំងឺតម្កាត់ផ្សេងៗ ដែលខ្មែរនិយមហៅថា *មេបាកាច់* ហើយដើម្បីឱ្យបានជាសះស្បើយវិញ គេត្រូវទៅបួល និងសែនព្រេនសូមអង្វរមេបាឱ្យលែងប្រកាន់ទៀត។



www.elibraryofcambodia.org

ការខុសមេបាននេះ មានបីបែបសំខាន់ៗដូចជា[18]៖

- ខុសមេបាចាស់ទុំ (នៅពេលមានការឈ្លោះទាស់ទែងគ្នារវាងបងប្អូនញាតិទាំង ៧សន្តាន)

- ខុសមេបាក្រមុំកំលោះ (នៅពេលដែលក្រមុំកំលោះលួចលាក់ប្រព្រឹត្តផ្រូលផ្រួស ហួសប្រពៃណី)

- ខុសមេបាផ្កាប់មុខ ឬបិទមុខ (នៅពេលស្ត្រីជាភរិយាផិតក្បត់នឹងស្វាមី ទៅលួចលាក់មានសហាយស្មន់)។

## ១.៣- ជំនឿលើជូរជំបូរ (ឬឈ្នួរ)

ជំនឿលើជូរជំបូរនេះ គេនិយមហៅថា ជំនឿលើ «អារក្ស» ឬ «ឈ្នួរ»។ ខ្មែរតែង ជឿថា វង្សត្រកូលនីមួយៗ មានជូរជំបូរ២យ៉ាង៖

- ឈ្នួរខាងម្ដាយ ឬល្បាក់សាខាងម្ដាយ (ឬអារក្សខាងម្ដាយ)

-ឈ្នួរខាងឪពុក ឬល្បាក់សាខាងឪពុក (ឬអារក្សខាងឪពុក)

កាលណាសមាជិកគ្រួសារណាម្នាក់ ឈឺរកមុខពុំឃើញ គេក៏ទៅរកគ្រូបូល ឬ ទាយ ដើម្បីរកឈ្នួរខាងម្ដាយ ឬខាងឪពុកថា កូនចៅមានខុសឆ្គងអ្វី ឬឈ្នួរចង់បានអ្វី។ ពេលរកឃើញហើយ ទើបគេចាត់តាំងពិធីប្រគំខ្មោច ឬពិធីលៀងអារក្ស ដើម្បីលួងលោម ខ្មោចជូរជំបូរឱ្យឈប់ខឹងនឹងកូនចៅតទៅទៀត ដោយមានសែនព្រេនផងដែរ (នៅ តំបន់ខ្លះមានត្រឹមតែការសែនព្រេនប៉ុណ្ណោះ គឺមិនមានពិធីលៀងអារក្សទេ)។

## ១.៤- ជំនឿលើគ្រូបាធ្យាយ ឬគ្រូកំណើត

គ្រូបាធ្យាយ សំដៅដល់គ្រូ ដែលធ្លាប់បង្ហាត់បង្រៀនដល់សិស្សគណ មានដូចជា គ្រូសំដោះ គ្រូបង្រៀនមើលជំងឺ គ្រូបង្រៀនមន្តអាគម គ្រូបង្រៀនរបាំ តន្ត្រី គុនប្រដាល់ ជាដើម។ គ្រូបាធ្យាយ ក៏ជាអ្នកមានគុណមិនចាញ់ឪពុកម្ដាយ ដែរ ព្រោះហេតុនេះ

[18] ងួន ញ៉ិល *ព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ* បោះពុម្ពដោយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ឆ្នាំ២០០០ ទំព័រ៣៩-៤១។


www.elibraryofcambodia.org

ទើបនៅក្រោយពេលលោកធ្វើមរណកាលទៅ សិស្សគណ រមែងធ្វើវត្ថុតំណាង ដោយរៀបចំអុជធូប សែនព្រេន ថ្វាយផ្កា និងផ្លែឈើនានា ដើម្បីសុំសេចក្ដីសុខ និងជោគជ័យ។ ឧទាហរណ៍ បើគ្រូទាយថា អ្នកជំងឺត្រូវខ្មោចគ្រូបាធ្យាយ ពិសេសគ្រូសំដោះប្រកាន់ធ្វើឱ្យឈឺ គេត្រូវលៀងគ្រូ ឬលៀងដី ឬលៀងចំណី ដើម្បីឱ្យលោកផ្ដុំដកពិសពរ ចេញពីអ្នកជំងឺ នោះវិញ។



## ១.៥- ជំនឿលើអ្នកដូនអ្នកតា

អ្នកតា គឺជាព្រលឹងនៃបុព្វជន ចាស់ស្រុក មេកន្ទ្រាញ ឬមេទ័ពខ្លាំងពូកែជាដើម ដែលបានស្លាប់ទៅ ហើយព្រលឹងនោះនៅតែតាមថែរក្សាអ្នកជំនាន់ក្រោយៗទៀត។ តាមពិតទៅ អ្នកតា ពុំមានតែអ្នកតាប្រុសនោះទេ ហើយអ្នកតា ដែលតំណាង ឱ្យមនុស្សស្រី គេហៅថា «អ្នកដូន - ដូន ឬយាយ» តែគេនិយមហៅដោយខ្លីរួមថា អ្នកតាៗ។

គេជឿថា អ្នកតាមាននៅគ្រប់ច្រកល្ហកទាំងអស់ ដូចជានៅតាមភូមិ វត្តអារាម វាលស្រែចម្ការ ព្រៃភ្នំក្រំថ្ម ទន្លេ ស្ទឹង បឹងបួ សមុទ្ទ ដើមឈើធំៗ ទីទួលខ្ពស់ៗជាដើម។ ចំណុចនេះ មានន័យថាអ្នកតាមានទាំងនៅក្នុងស្រុកភូមិ និងនៅក្នុងព្រៃផងដែរ។ ភាគច្រើនលំនៅរបស់អ្នកតា មាននៅក្រោមដើមឈើធំៗ ឬនៅលើដើមឈើ ហើយគេនិយមសង់ខ្ទមតូចៗ ដោយមានដាក់ថ្ម តំណាងរូបអ្នកតាទៀតផង។

អ្នកតា ដែលប្រជាជនខ្មែរធ្លាប់ស្គាល់ច្រើនជាងគេនោះមានដូចជា អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក អ្នកតាមេ-ស អ្នកតាដំបងដែក យាយទេព ដូនតី និងជំទាវម៉ៅ (យាយម៉ៅ)ជាដើម។ ដោយសារតែប្រជាជនខ្មែរ មានជំនឿលើអ្នកតា ទើបបានជារៀងរាល់ឆ្នាំ នៅតាមនិគមជនបទស្រុកស្រែចម្ការ គេតែងរៀបចំពិធីឡើងអ្នកតា ដើម្បីសុំទឹកភ្លៀង និងសេចក្ដីសុខ។ (សូមមើល ជំពូក ២) ។


www.elibraryofcambodia.org

## ២- ជំនឿលើព្រះ

ទឹក ដី ភ្លើង និងខ្យល់ គឺជាធាតុពិសិដ្ឋ៤យ៉ាងដ៏សំខាន់សម្រាប់ជីវិតមនុស្សខ្មែរ។ ហេតុនេះហើយ ទើបគេនិយមចាត់ទុកទឹក ដី ភ្លើង និងខ្យល់ថាជាព្រះ ដូចដែលគេតែងហៅរៀងគ្នាថា ព្រះគង្គាព្រះធរណី ព្រះភ្លើង ឬព្រះអគ្គី និងព្រះពាយ ឬព្រះវាយោ។

ក្រៅពីព្រះទាំង៤នេះ គេនៅមានជំនឿលើព្រះជាច្រើនទៀតដូចជា ព្រះចន្ទ ព្រះអាទិត្យព្រះគោ និងព្រះពៃស្រពណ៍(មនុស្សសម័យបុរាណចាត់ទុកថាជាទេវតាម្ចាស់ទ្រព្យ)។

## ៣- ជំនឿលើទេវតា

ប្រជាជនខ្មែរ បានគោរពជឿលើទេវតាតាំងពីយូរណាស់មកហើយ ជាពិសេសនៅពេលព្រះពុទ្ធសាសនាបានហូរចូលមកដល់ស្រុកខ្មែរ។ គេជឿថា ទេវតា ឬទេព្តា ជាតំណាងនៃសេចក្តីល្អបរិសុទ្ធ ឬជាអតីតបុគ្គល ដែលបានប្រព្រឹត្តល្អ នៅជាតិមុន ហើយបានទៅកើតនៅឋានសួគ៌។ ដោយសារគេយល់ថា ទេវតាជាអ្នកមានបុណ្យបារមី និងឫទ្ធិអាចសម្រេចបំណងឱ្យមនុស្សលោកបាន ទើបខ្មែរនិយមគោរពបូជាចំពោះ ពពួកទេវតា។



ជាតួយ៉ាង ប្រជាជនខ្មែរតែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរជារៀងរាល់ឆ្នាំ ដើម្បីទទួលទេវតាឆ្នាំថ្មី ដែលមកទទួលតំណែងជំនួសទេវតានៅឆ្នាំចាស់។ ពេលនោះ នៅតាមផ្ទះនីមួយៗ សុទ្ធតែមានរៀបចំគ្រឿងរណ្តាប់ផ្សេងៗនៅតាមរានទេវតា ដើម្បីទទួលពរជ័យពីទេវតាឆ្នាំថ្មី។



www.elibraryofcambodia.org

### ៤- ជំនឿលើព្រះភូមិ និងជំនាងផ្ទះ

ព្រះភូមិ (ឬភុម្មទេវតា)[19] ជាទេវតា ដែលអាស្រ័យផ្ទាល់លើផែនដី។ ខ្មែរតែងតែហៅទេវតា ឬបិសាច ដែលអាស្រ័យនៅទីស្រែចម្ការ ឬដីភូមិថា *ព្រះភូមិ*។ ចំណែកឯជំនាងផ្ទះ (ឬជីនាងផ្ទះ) វិញ គឺជាទេវតា ឬខ្មោច ដែលមើលថែរក្សានៅខាងក្នុងផ្ទះ សម្បែងឱ្យបានជួបនឹងសេចក្ដីសុខ។ ដោយសារការមានជំនឿទៅលើព្រះភូមិ និងជំនាងផ្ទះបែបនេះហើយ ទើបបានជាប្រជាជនខ្មែរ និយមចូលចិត្តសង់ អាសនៈ (លំនៅ) របស់ព្រះភូមខាងក្រៅផ្ទះក្នុងបរិវេណដីភូមិរបស់ខ្លួន និងសង់កន្លែងសម្រាប់ជំនាងផ្ទះនៅក្នុងផ្ទះនីមួយៗ។ ម្យ៉ាងទៀត គេតែងតែអុជធូបបន់ស្រន់សុំសេចក្ដីសុខចម្រើន និងសែនព្រេនជារឿយៗ ជាពិសេសគឺនៅថ្ងៃសីល។

### ៥- ជំនឿលើបារមី

កាលណាគេជួបទុក្ខលំបាកអ្វីមួយ ដែលពុំអាចដោះស្រាយបាន ខ្មែរនិយមទៅរកកន្លែង ដែលគេជឿថា មានបារមី ដើម្បីបន់ស្រន់សុំឱ្យជួយរំដោះទុក្ខទាំងនោះ។ នៅពេលណាគេបានសម្រេចតាមបំណងហើយ គេក៏ទៅថ្វាយគ្រឿងសក្ការៈផ្សេងៗ ឬថ្វាយភ្លេងពិណពាទ្យតាមទម្លាប់ដើម្បីលាបំណន់វិញ។

ជាទូទៅ ពាក្យ «បារមី» នេះ ចង់សំដៅដល់ទីសក្ការៈណា ដែលមានបារមីព្រះពុទ្ធ ជាពិសេសកន្លែងដែលមានពុទ្ធបដិមាធំៗ មានពុទ្ធបដិមាច្រើនអង្គ ឬមានដើមពោធិ៍ជាដើម តែពេលខ្លះក៏សំដៅដល់កន្លែងផ្សេងៗ ដែលគេចាត់ទុកថា មានមហិទ្ធិឫទ្ធិ ដូចជានៅលើទីទួលខ្ពស់ ឬភ្នំដែលមានអាយុកាលច្រើនជាដើម។ បារមីល្បីៗនៅស្រុកខ្មែរ ដែលប្រជាជនតែងតែស្គាល់ នោះមានដូចជា បារមីព្រះអង្គដងកើ (នៅមុខព្រះបរមរាជវាំង) បារមីព្រះអង្គចេកព្រះអង្គចម (នៅខេត្តសៀមរាប) បារមីព្រះអង្គវិហារសួគ៌ (នៅខេត្តកណ្ដាល) បារមីព្រះអង្គភ្នំសន្ទុក (នៅខេត្តកំពង់ធំ) បារមីប្រាសាទព្រះវិហារ(នៅខេត្តព្រះវិហារ) ជាដើម។

---

[19] វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ *វចនានុក្រមខ្មែរ ភាគ១-២* បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៨ ទំព័រ៨២៣-៨២៤។



www.elibraryofcambodia.org

## ៦- ជំនឿលើរបៀន (ឬមន្តអាគមគាថា)

របៀន ឬមន្តអាគមគាថា គឺជាពាក្យ ឬបាលីសក្តិសិទ្ធិ ដែលគេរៀនតៗគ្នាមកសម្រាប់សែក ស្តោះ ផ្លុំឱ្យកើតសេចក្តីសុខ ជាសះស្បើយពីជំងឺ និងដើម្បីឱ្យមានមហិទ្ធិឫទ្ធិ។ មន្តអាគមគាថាបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីជំនឿក្នុងព្រះពុទ្ធសាសនា និង ព្រហ្មញ្ញសាសនា ព្រោះមន្តអាគមទាំងនេះ រមែងមានលាយឡំដោយ បាលីគាថានានា។ របៀនទាំងនេះទៀតសោត ក៏មានច្រើនបែបយ៉ាងដូចជា គាថាសម្រាប់ការពារខ្លួន គាថាសម្រាប់សូត្រស្តោះផ្លុំនិងស្រោចទឹក គាថាបង្ការ (បង្ការកុំឱ្យពស់ចឹក ឬខ្មោចលង...) គាថាមន្តស្នេហ៍ និងគាថាចារយ័ន្តផ្សេងៗ ។ល។ ម្យ៉ាងទៀត គេជឿថា មន្តអាគមគាថាទាំងនោះ អាចពូកែសក្តិសិទ្ធិទៅបាន លុះត្រាតែអ្នកទទួលគាថា មានសីលធម៌ខ្ពស់ ចេះដឹងគុណអ្នកមានគុណ និងគ្រូជានិច្ច ដោយពុំមានសេចក្តីប្រមាទឡើយ។

## ៧- ជំនឿលើការរំលឹកគុណគ្រូ និងគ្រាប់តាមដំបូន្មានគ្រូ

ការរំលឹកគុណគ្រូ ជាករណីយកិច្ចដ៏សំខាន់របស់សិស្សគណចំពោះគ្រូរបស់ខ្លួនជាក់ ស្តែងគេតែងតែឃើញមានការរំលឹកគុណគ្រូ នៅមុនការប្រកួតប្រដាល់ខ្មែរបុរាណដែលគេនិយម ហៅថា «ការថ្វាយបង្គំគ្រូ» ដោយមានភ្លេងកំដរទៀតផង។ ក្បាច់រំលឹកគុណគ្រូមានចើនបែបយ៉ាង ណាស់ដូចជា ក្បាច់នាគលេងទឹក គ្រុឌចក់នាគ ខ្លាក្រាប ក្រពើហា ព្រះរាមព័ទ្ធសីមា ព្រះរាមផ្លែងសរ និងក្បាច់ល្បុក្កតោជាដើម។

## ៨- ជំនឿលើគ្រូទាយ

គ្រូទាយ ឬហោរា ឬហៅតាមសម្តីសាមញ្ញរបស់អ្នកស្រុកថា ហោរ ត្រូវបានគេចាត់ទុកថាជាទីប្រឹក្សាដ៏សំខាន់របស់ប្រជាជនខ្មែរនៅតាមស្រុកភូមិនីមួយៗ ព្រោះគ្រូទាយជាបុគ្គលដែលអាចទស្សន៍ទាយអំពីបញ្ហាអ្វីមួយនៅពេលមនុស្សខ្មែរមានអាសន្ន មានបុណ្យទាន ឬពេល ធ្វើ ពិធីតាមទំនៀមទម្លាប់ប្រពៃណីផ្សេងៗដូចជា ពេលបាត់របស់របរ គោក្របី ពេលណាគ្រួសារមិនសូវសុខសប្បាយ ពេលគេចង់ដឹងពីជោគជតា



www.elibraryofcambodia.org

រាសី ពេលគេចង់ដឹងពីអនាគត ពេលរកគូព្រេង និង ពេលរៀបការ (ទាយរកថ្ងៃវេលាល្អ) ។ល។

### ៩- ជំនឿលើសិរីសួស្តីជ័យមង្គល

ខ្មែរតែងមានជំនឿថា សិរីសួស្តីអាចមានទៅបានដោយសារមូលហេតុមួយចំនួនដូចខាង ក្រោម៖

**ក- ការប្រព្រឹត្តតាមពេលវេលា**

- ពេលព្រឹក សិរីសួស្តីនៅត្រង់មុខ
- ពេលថ្ងៃត្រង់ សិរីសួស្តីនៅត្រង់ទ្រូង
- ពេលយប់ សិរីសួស្តីនៅត្រង់ជើង។

**ខ- ការប្រើពណ៌ទៅតាមថ្ងៃនីមួយៗ**

*- អាទិត្យក្រហមខ្ចី ឬចាស់ ចន្ទផ្ទាស់លឿងទុំ ស្វាយអង្គារ*
*ថ្ងៃពុធស៊ីលៀបសមសោភា ព្រហស្បត្តិ៍ប្រែជាបៃតង់ត្រួយខ្ចី។*
*- ពណ៌ខៀវក្រនៀវប្រើថ្ងៃសុក្រ ពណ៌និលព្រិលទុកសៅរ៍សិរី*
*តែងខ្លួនតាមក្បួនលោកស្រដី ចម្រើនសួស្តីជោគជ័យអើយៗ*

**គ- ការគោរពតាមដង្ហើមរស់ប្រចាំថ្ងៃ**

នៅក្នុងជំនឿខ្មែរ ការគោរពតាមដង្ហើមរស់នេះ គេច្រើនអនុវត្តក្នុងពិធីជូនពៃការធ្វើដំណើរទៅឆ្ងាយ ការទាក់ទងការងារ ឬការរកស៊ីផ្លូវឆ្ងាយជាដើម។ គេជឿថាដង្ហើមរស់នេះ មានតាមថ្ងៃនីមួយៗ ឧទាហរណ៍ ថ្ងៃអាទិត្យ នៅទិសឧត្តរ ថ្ងៃចន្ទនៅទិសនិរតី ថ្ងៃអង្គារនៅទិសឦសាន ជាដើម។

**ឃ- ឫក្សនៃថ្ងៃនិងខែប្រចាំឆ្នាំតាមមហាសង្រ្កាន្ត**

នៅក្នុងពិធីបុណ្យទានផ្សេងៗ ដូចជាពិធីសូត្រមន្ត ពិធីលើកផ្ទះ ដីករណ្ដៅគ្រឹះផ្ទះ បញ្ចុះធាតុ ជាដើម គេជៀសវាងវេលាមិនល្អ រួមមានថ្ងៃឧត្បាត ថ្ងៃឃ្លុប ខែឧត្បាត


www.elibraryofcambodia.org

និងខែឃ្មុប ដែលមានចែងក្នុងមហាសង្ក្រាន្តប្រចាំឆ្នាំនីមួយៗ។

**ង- ការដើរព័ទ្ធជុំវិញ**

នៅក្នុងការដើរព័ទ្ធជុំវិញវត្ថុអ្វីមួយក្នុងពិធីបុណ្យមួយចំនួន ដើម្បីឱ្យមានសិរីសួស្តី គេនិយមដូចជា៖

- ប្រទក្សិណ (ទក្ខិណាព័ត៌ ឬទក្ខិណាវដ្ត) ជាដំណើរព័ទ្ធជុំវិញដោយទុកឱ្យវត្ថុនៅខាងស្តាំ ឧទាហរណ៍ ការប្រទក្សិណជុំវិញព្រះ វិហារ៣ជុំ។ ដំណើរប្រទក្សិណអាចប្រៀបធៀបទៅនឹងដំណើរទ្រនិចនាឡិកា ។

- ឧត្តរាព័ត៌ (ឧត្តរាវដ្ត) ជាដំណើរព័ទ្ធជុំវិញដោយទុកឱ្យវត្ថុនៅខាងឆ្វេង ឧទាហរណ៍ ការហែសពជុំវិញជើងថ្ករជាដើម។ ដំណើរឧត្តរាព័ត៌អាច ប្រៀងថាជាដំណើរផ្ទុយនឹងដំណើរទ្រនិចនាឡិកា។

## ១០- ជំនឿលើវត្ថុស័ក្តិសិទ្ធិ

វត្ថុសក្តិសិទ្ធិ ជារបស់ស័ក្តិសិទ្ធិ ឬជារបស់មានឫទ្ធិខ្លាំងពូកែ ដែលអាចជួយអ្នកថែរក្សារបស់ទាំងនោះ ឱ្យបានគ្រជាក់គ្រជុំ និងរួចផុតពីភយន្តរាយផងទាំងឡាយ។ វត្ថុស័ក្តិសិទ្ធិ ដែលខ្មែរស្គាល់ជាទូទៅមាន យ័ន្ត ចែកាច់ នាងពួន កណ្តាញ់ ឬសក់ជាញ់ កូនក្រក ព្រះសំរិទ្ធិ នប់ប្រើស និង ខ្នាយតាន់ ជាដើម។ វត្ថុស័ក្តិសិទ្ធិទាំងអស់នោះ អាចមានភាពស័ក្តិសិទ្ធិទៅបាន លុះត្រាតែអ្នកថែរក្សាប្រកាន់អំពើល្អ ឬគោរពតាមត្រណមផ្សេងៗបាន។

## ១១- ជំនឿលើថ្នាំស័ក្តិសិទ្ធិ

ប្រជាជនខ្មែរ តែងមានជំនឿថា មានថ្នាំស័ក្តិសិទ្ធិ ដែលអាចធ្វើឱ្យមនុស្សមានសាច់គង់ ឬមានសាច់ស្វិតកាប់មិនមុតជាដើម។ គេតែងហៅថ្នាំប្រភេទនេះថា «ថ្នាំគង់» ហើយថ្នាំប្រភេទនេះរមែងមានវិធីផ្សែផ្សំទៅតាមអ្នកដែលជឿ និងចេះចាំតៗគ្នា។ម្យ៉ាងវិញទៀត ដើម្បីរក្សាខ្លួនឱ្យពូកែ ជាមនុស្សគង់ ដែលបានផឹកថ្នាំនោះរួចហើយ គេត្រូវប្រព្រឹត្តតាមតំណមគ្រូ ធ្វើតែអំពើល្អ ហើយត្រូវរំលឹកដល់គុណគ្រូ និងអ្នកមានគុណជានិច្ច។



www.elibraryofcambodia.org

### ១២- ជំនឿលើសត្វ

កាលពីដើមខ្មែរយើងមានជំនឿថា ដើមកំណើតខ្សែស្រឡាយរបស់ខ្លួន គឺសត្វពស់ ឬនាគ (តាមរឿងព្រេងព្រះថោងនាងនាគ)។ ក្រៅពីសត្វនេះ គេនៅមានជំនឿលើសត្វដទៃទៀតដូចជាសត្វ គោ មាន់ បង្គួយ ក្របី ដំរីជាដើម។ កាលបើគេជឿលើសត្វទាំងនេះហើយ គេតែងគោរពបូជាដល់សត្វទាំងនោះដើម្បីបានសេចក្ដីសុខ។ បើនរណាម្នាក់សម្លាប់សត្វប្រភេទនោះ ឧបទ្រព្យចង្រៃ ក៏នឹងកើតមានដែរ ហើយដើម្បីរំដោះគ្រោះ គេត្រូវធ្វើពិធីសែនព្រេនចំពោះសត្វនោះ។ ទោះបីជាខ្មែរមានជំនឿលើសត្វជាច្រើនក៏ដោយ ក៏គេនិយមគោរពជឿជាពិសេសលើសត្វនាគ និងសត្វដំរី។

### ១៣- ជំនឿលើសកម្មភាពផ្សេងៗរបស់សត្វ

#### ក- សំឡេងសត្វ

ខ្មែរយើងជឿថា សត្វខ្លែងស្រាក មៀម លលកខ្មោច និងសត្វឱឡជាដើម គឺជាអ្នកនាំសារ របស់ខ្មោចព្រាយបិសាច។ ហេតុនេះពេលសត្វទាំងនេះ យំនៅទីណា ឬលើដំបូលផ្ទះណាហើយ គេជឿថានឹងមានមនុស្សឈឺធ្ងន់ ឬក៏ស្លាប់មិនខាន។ ក្រៅពីជឿលើសំឡេងនៃសត្វទាំងអម្បាលនេះ ខ្មែរក៏មានជំនឿលើសំឡេងសត្វជាច្រើនទៀត ដូចជាសំឡេងឆ្កែលូ សំឡេងតុកកែ ។ល។

#### ខ- សកម្មភាពសត្វទាក់ទងនឹងផ្ទះ ឬភូមិ

គេរមែងជឿថា ពេលសត្វព្រួត ឃ្មុំ ពស់វែ្រ ពស់ថ្លាន់ អំពិលអំពែក ឆ្កែ ឆ្មា ឬព្រាបទាំងហ្វូង មកអាស្រ័យនៅនឹងផ្ទះណាហើយនោះ ពពួកសត្វទាំងនេះក៏នឹងនាំមកនូវសេចក្ដីសុខក្សេម ក្សាន្ត ឬលាភសំណាងជាពុំខាន។ តែផ្ទុយទៅវិញ ប្រសិនបើមាន កុក-ស ឬកុកសាប់មកទំលើដំបូលផ្ទះ ឬមានឈ្លូសរត់ចូលភូមិ នោះនឹងកើតមាននូវឧបទ្រព្យចង្រៃសម្រាប់ម្ចាស់ផ្ទះ ឬមនុស្សក្នុងភូមិជាមិនខានឡើយ។

#### គ- សម្បុរសត្វ

សម្បុររបស់សត្វ ក៏ជាគ្រឿងសម្គាល់ដ៏សំខាន់មួយ ដែលមនុស្សខ្មែរបុរាណតែងតែជឿតៗគ្នា។ ជាក់ស្ដែងណាស់ ចាស់ៗជំនាន់មុននិយមជឿថា បើហ្វូងក្របីខ្មៅ



www.elibraryofcambodia.org

ដេកក្នុងក្រោលតែមួយ ហើយបើមានក្របីខ្មៅណាមួយកើតកូនមកជាក្របីឈ្មៀច គេជឿថា នឹងមានក្របីស្លាប់រង្គាលពុំខាន។ ក្រៅពីនេះ គេក៏មានជំនឿលើសម្បុរសត្វដទៃទៀតដែរ ដូចជាគេជឿថា ជើងរបស់សត្វចតុបាទទាំងអស់ តែងមានសម្បុរដូចគ្នាជាធម្មតា តែបើមានសត្វចតុបាទណា មានជើងមួយសម្បុរខុសពីជើងដទៃទៀត គេចាត់ទុកសត្វនោះថាជាសត្វជើងបីដែលជាសត្វចង្រៃ គឺគេពុំគួរយកមកចិញ្ចឹមឡើយ។

### ១៤- ជំនឿលើខ្លែង

ចាស់ៗខ្មែរជឿថា ការបង្ហោះខ្លែង គឺជាការគោរពដឹងគុណចំពោះព្រះពាយដែលបានផ្តល់ដង្ហើមរស់នៅឱ្យមនុស្សលោក ហើយក៏ជាការគោរពបូជាចំពោះព្រះចូឡាមណីចេតិយ (តម្កល់ព្រះកេសា)របស់ព្រះសម្មាសម្ពុទ្ធ នៅឯស្ថាន ត្រៃត្រឹង្ស។ តែទោះជាយ៉ាងនេះក្តី នៅពេលដែលខ្លែងឯក (ខ្លែងធំៗ) ធ្លាក់លើដំបូលផ្ទះរបស់អ្នកណាម្នាក់ គេជឿថានឹងមានគ្រោះឧបទ្រព្យចង្រៃ កើតមានដល់ម្ចាស់ផ្ទះជាមិនខាន។ ហេតុនេះ ម្ចាស់ផ្ទះ តែងតែទាមទារឱ្យម្ចាស់ខ្លែង ធ្វើពិធីបង្កក់ប្រសិទ្ធិលើករាសី ដើម្បីឱ្យបានសេចក្តីសុខចម្រើនវិញ។

### ១៥- ជំនឿលើទីងមោង

ការជឿទៅលើទីងមោងនេះ ពុំមែនមានន័យថា ខ្មែរយើងទៅគោរពបន់ស្រន់ចំពោះទីងមោងនោះទេ តែគេមានជំនឿថា ទីងមោងជាវត្ថុ ដែលអាចជួយបន្លាចឬជួយបណ្តេញនូវឧបទ្រពចង្រៃនានា។ ជាក់ស្តែង ក្រៅពីការប្រើប្រាស់ទីមោងសម្រាប់បន្លាចសត្វក្នុងស្រែ ខ្មែរយើងក៏មាន ទំនៀមមួយទៀត គឺធ្វើរូបទីងមោង (នៅកន្លែងខ្លះគេនិយមគូររូបផ្សេងៗដាក់តាមពាង ឬក្អម)ដាក់នៅតាមផ្ទះ នៅពេលគេឮថាមានឧបទ្រពចង្រៃ ឬជំងឺរាតត្បាតកើតមានឡើង។ ពេលខ្លះទៀត គេធ្វើ «យក្សជាល» ដែលអ្នកស្រុកនិយមហៅថាទីងមោង[20] ដោយយកទៅដង្ហែរ តាមផ្លូវក្នុងគោលបំណងបន្លាច ឬបណ្តេញនូវហេតុអពមង្គលនានានៅក្នុងភូមិ។

---

[20] សូមមើល កម្រងអត្ថបទក្នុងបណ្ណាញព័ត៌មានវប្បធម៌ខ្មែរ លេខ១ ខែធ្នូ ២០០៥- ខែធ្នូ ២០០៦ ទំព័រ ៣៤។



www.elibraryofcambodia.org







រូបទី១និងទី២: ជារូបទីងមោង(គេដាក់នៅមុខផ្ទះ)      រូបទី៣: រូបយក្សជាល

ប្រភព៖ អាំង ជូនលាន, ព្រាប ចាន់ម៉ារ៉ា, និង ស៊ីយ៉ុន សុភារិទ្ធិ៖ *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ* លេខ១ ខែធ្នូ ២០០៥- ខែធ្នូ ២០០៦ ទំ. ៣២, ៣៤

ជារួមមក យើងឃើញថា ខ្មែរយើងមានជំនឿច្រើនបែបយ៉ាងណាស់ ហើយជំនឿនៅខាងលើនេះ គ្រាន់តែជាគោលជំនឿមួយចំនួនប៉ុណ្ណោះ។ ខ្មែរនៅមានជំនឿច្រើនទៀតដូចជា ជំនឿលើតម្រា (មានតម្រាហង្ស តម្រាចេកមាស តម្រាឆត្រ៣ជាន់) ជំនឿលើយាម (យាមបញ្ញ យាមអដ្ឋកាល យាមត្រីនេត្រ) ជំនឿផ្កាយ(ផ្កាយដុះកន្ទុយ) ជាដើម។



www.elibraryofcambodia.org

## ២
## ប្រពៃណីកោរជុក



ពិធីកោរជុក គឺជាពិធីដ៏សំខាន់មួយសម្រាប់ក្មេង ដែលរៀបនឹងពេញវ័យ។ «ពិធីកោរជុក» ជាឈ្មោះផ្លូវការ តែតាមសម្ដីសាមញ្ញរបស់អ្នកស្រុក គេហៅថា «កោរសក់» ឬ «កោរកំប៉ោយ» ដែលក្មេងប្រុសស្រីទុកលើក្បាលចាប់តាំងពីអាយុ៣ឆ្នាំរហូតដល់ធំ ទើបកាត់ផ្ដាច់ក្នុងពិធីកោរជុកនេះ។

### ១- ប្រវត្តិនៃពិធីកោរជុក

ពិធីកោរជុក ជាទំនៀមទម្លាប់ខ្មែរដ៏សំខាន់មួយ ដែលមានតាំងពីយូរណាស់មកហើយ។ ទំនៀមទម្លាប់នេះមានឫសគល់តាំងពីសម័យដែលខ្មែរកាន់ ព្រហ្មញ្ញសាសនាមកម្ល៉េះ។ សូម្បីតែរូបគំនូរក៏មាននិយាយពីពិធីនេះដែរ ជាតួយ៉ាង នៅព្រះវិហារវត្តបូព៌ គេឃើញមានរូបគំនូររឿងរាមកេរ្តិ៍ ដែលក្នុងនោះ ពាលីបានពអង្គទទៅឱ្យតាបសឬសីកោរជុកនៅក្នុងពិធីមួយ។ នៅសម័យមុន ទំនៀមទម្លាប់កោរជុកក្នុងព្រះញាតិវង្សប្រហែលជា មានទូទៅពុំអាក់ខានឡើយ។ ជាក់ស្ដែង នៅដើមសតវត្ស





www.elibraryofcambodia.org

ទី២០ បុណ្យកោរជុកនៃព្រះអង្គម្ចាស់ ចន្ទលេខា(ព្រះរាជបុត្រនៃព្រះបាទនរោត្តម) មានសភាពឱឡារិកជាពន់ពេកណាស់ ពោលគឺមានរយៈពេលដល់ទៅ៧ថ្ងៃឯណោះ។ ទោះជាយ៉ាងនេះក្តី ក៏នាពេលបច្ចុប្បន្ន ពិធីកោរជុក ស្ទើរតែវិនាសបាត់បង់ទៅហើយ ព្រោះគេឃើញមានរៀបចំម្តងម្កាលនៅតាមនិគមជនបទខ្លះៗប៉ុណ្ណោះ ដូចជានៅតាមភូមិខ្លះនៃតំបន់អង្គរក្នុងខេត្តសៀមរាប និង នៅភាគខាងជើង ឬ ភាគពាយព្យនៃប្រទេស។[21]



ព្រះបាទនរោត្តម និង ព្រះអង្គម្ចាស់ ចន្ទលេខា

[21] អាំង ជូលាន, ព្រាន ចាន់ម៉ារ៉ា និង ស៊ីយ៉ុនសុភារិទ្ធិ *កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ* លេខ១ ខែធ្នូ ២០០៥-ធ្នូ ២០០៦ ទំព័រ៤១-៤២។



www.elibraryofcambodia.org

## ២- លក្ខខណ្ឌនៃពិធីកោរជុក

កោរជុក ជាពិធីទំនៀមមួយ ដែលគេប្រារព្ធឡើងសម្រាប់ក្មេងតូច ឬធំទង់ (មានទាំងប្រុស និងស្រី) ដែលពុំទាន់ពេញវ័យនៅឡើយ ពោលគឺគេត្រូវធ្វើពិធីនេះនៅមុនពេលដែលក្មេងនោះ ពេញវ័យជាដាច់ខាត។ម្យ៉ាងទៀត គេនិយមធ្វើពិធីនេះទៅតាមខ្សែស្រឡាយ គ្រួសារ ដែលមានទម្លាប់

ទុកសក់ជុករហូតតកូនតចៅ។

គួរកត់សម្គាល់ថា គេអាចកោរជុកសម្រាប់តែក្មេងម្នាក់ក៏បាន ប៉ុន្តែដោយសារពិធីនេះតែងមានភាពឱឡារិក ហើយត្រូវចំណាយធនធានច្រើនផងនោះ គេក៏និយមធ្វើចូលគ្នា។ បើធ្វើចូលគ្នា បែបនេះ ចំនួនក្មេងត្រូវជាចំនួនសេស ហើយបើចំនួនជាលេខគត់វិញ គេត្រូវរកក្មេងណាម្នាក់ ផ្សេងទៀត មកអង្គុយឧបកិច្ចជាមួយគ្នានៅមុនពេលកោរផ្ដាច់ជុក។ ក្មេងដែលត្រូវ កោរជុករួមគ្នានេះ ជាមធ្យមគេឃើញមានប្រមាណ៥នាក់។ រីឯអាយុក្មេងក៏មិនខុសពីចំនួនក្មេងដែរ ពោលគឺត្រូវជាចំនួនសេសដូចគ្នា។ សូមបញ្ជាក់ដែរថា ប្រសិនបើទុកជុក(កំប៉ោយ)មួយ គេអាចនិមន្តព្រះសង្ឃពីវត្តមួយ ឬ៣វត្ត ប៉ុន្តែបើសិនជាទុកជុក៣វិញ គេត្រូវនិមន្តព្រះសង្ឃចំនួន៧វត្ត មកចូលរួមក្នុងពិធីនេះ។

## ៣- គោលបំណងនៃពិធីកោរជុក

គោលបំណងសំខាន់នៃពីធីនេះ គឺដើម្បីប្រសិទ្ធីក្មេង និង សម្ដែងការតបស្នងសងគុណដល់អ្នកម្ដាយ ដែលមានសេចក្ដីលំបាកនៅពេលឆ្លងទន្លេ ឬក៏ម្ដាយបានធ្វើការបន់ស្រន់សូមឱ្យការឆ្លងទន្លេបានទទួលនូវសុខសុវត្ថិភាព ដោយសន្យាថ្វាយសក់ដើម្បីលាបំណន់ ឬ គេអាចចាត់ទុកពិធីនេះថា ជាពិធីបង្កក់ឆ្អបផងដែរ។

## ៤- ការប្រព្រឹត្តទៅនៃពិធីកោរជុក

ទោះបីជាការពិត អាចារ្យ ឬ ឪពុកម្ដាយគឺជាអ្នកកោរជុកឱ្យក្មេងៗក៏ដោយ ក៏គេឃើញថា ព្រះសង្ឃជាអ្នកឧបកិច្ចធ្វើជាកោរឱ្យក្មេងៗ។ ហេតុនេះ គេចាំបាច់និមន្តព្រះសង្ឃ មកចូលរួមនៅក្នុងពិធីនេះ។



www.elibraryofcambodia.org

ជាទូទៅ ប្រជាជនខ្មែរ និយមធ្វើពិធីនេះ នៅក្នុងខែមាឃ ផល្គុន និងខែពិសាខ។ ពិធីនេះ មានរយៈពេល១ល្ងាច ហើយឆ្លងដល់១ព្រឹកទៀត ក៏ប៉ុន្តែរយៈពេលនៃពិធីនេះ អាចពោលថា ៣ថ្ងៃក៏បាន ប្រសិនបើរាប់បញ្ចូលទាំងការរៀបចំប្រដាប់ប្រដាផ្សេងៗ និងការធ្វើនំនែកជាដើម ព្រោះអ្នកភូមិត្រូវរវល់ទាំង៣ថ្ងៃ។ រីឯរណ្តាប់សំខាន់ៗ មានដូចបាយសី(តំណាងសាមីកោរជុក) បាយព្រលឹង ស្រូវកញ្ចើ គ្រឿងអង្ករាប (មានបង្កប់ដោយសម្ភារៈផ្សេងៗដូចជាដូងនាឡិ ដូងតក់ ស្បូវភ្លាំង ត្រល់ចងជាមួយ ចិញ្ចៀនជាដើម) ពពិល ប្រដាប់ហៅព្រលឹង ប្រដាប់កោរសក់ ព្រះខ័ន(ធ្វើពីស្លឹកត្នោត) គ្រឿងតុបតែងខ្លួន ជមផ្សេងៗ និងមានផ្លែឈើនានាទៅតាមលទ្ធភាពធនធាន របស់គ្រួសារនីមួយៗ។

គេចាប់ផ្តើមពិធីនេះនៅចុងរសៀល ដោយរៀបចំពិធីក្រុងពាលី និងមានកិច្ចជាបន្តបន្ទាប់ផ្សេងៗទៀតដូចជាបួងសួងនៅខាងមុខអាសនៈ (ដែលគេនិយមហៅថា *បញ្ញា*) អមទៅដោយភ្លេងពិណពាទ្យ។ ក្រោយពីបួងសួងរួច នៅក្បាលព្រលប់ គេក៏ចាប់ផ្តើមនិមន្តព្រះសង្ឃ(៥ ឬ ៧ អង្គ)សូត្រមន្តនិងមានការសែនព្រេនរំលឹកដល់ព្រលឹងដូនតា សាច់សាលោហិតទៀតផង។

ជាកិច្ចបន្ទាប់ សាមីកោរជុកត្រូវចូលពិធីមួយទៀត ហៅថាដេកអង្ករាប ដែលសាមីកោរជុកត្រូវដេកលើអង្ករ១តៅ តម្កល់ចាន៣ ពីលើសំពត់៣ហត្ថ តាមការរៀបចំរបស់អាចារ្យ ហើយក្រោយមកទៀត គេក៏ធ្វើកិច្ចមួយទៀត គឺពិធីហៅព្រលឹងសក់។ ក្រោយមក គេក៏រៀបចំពិធីបង្វិលពពិល និងបញ្ចុកទឹកដូង ដែលមានរសជាតិជូ ប្រៃ ភ្លាវ ដើម្បីទូន្មានដល់សាមីកោរជុក។ ក្រោយមកអាចារ្យ ក៏ឱ្យសាមីខ្លួនទន្ទេញធម៌សុគតោហេតុដល់ដេកលក់លើអង្ករាបនោះ។ នៅពេលទៀបភ្លឺ ពេលដែលសាមីខ្លួនដឹងខ្លួនហើយរាវរកត្រល់ ដែលចងភ្ជាប់នឹងចិញ្ចៀនត្បូងរួចហើយ ព្រះសង្ឃក៏ចាប់ផ្តើមសូត្រធម៌ជយន្តោចំនួន១០០ចប់។ ពិធីធ្វើធ្មេញ ជាកិច្ចសំខាន់មួយទៀតសម្រាប់រំដោះឧបទ្រព្យចង្រៃឱ្យចេញពីសាមីកោរជុក នៅមុនពិធីសំពះព្រះអាទិត្យ។


www.elibraryofcambodia.org

នៅព្រឹកជាកិច្ចបង្ហើយបុណ្យ គេចាប់ធ្វើពិធីកោរផ្កាច់ជុកដល់សាមីខ្លួន ដោយមានព្រះសង្ឃមួយអង្គគង់នៅលើអាសនៈ(បញ្ញា) ជាអ្នកកោរផ្កាច់ជុក និងមានព្រះសង្ឃច្រើនអង្គទៀត សូត្រធម៌ជយន្តោ និងស្រោចទឹកឱ្យសាមីកោរជុក ជាបន្តបន្ទាប់។ បន្ទាប់មក គេយកសាមីខ្លួនទៅបង្វិលពពិលម្តងទៀត និងជាចុងក្រោយ នៅប្រហែលជាម៉ោង១០ព្រឹក គេក៏រាប់បាត្រ[22] និងវេរចង្ហាន់ប្រគេនព្រះសង្ឃ ជាកិច្ចបង្ហើយ។ ក្នុងពិធីនេះដែរ ប្រជាជនខ្លះពុំទាន់បញ្ចប់ពិធីត្រឹមនេះទេ ពោលគឺគេបន្តដោយមានចងដៃដល់សាមីខ្លួន និងមានរៀបចំពិធីជប់លៀងជូនញាតិមិត្ត ដែលបានអញ្ជើញចូលរួមទៀតផង។[23]





រូបទី១៖ព្រះសង្ឃគង់លើបញ្ញាដើម្បីកោរផ្កាច់ជុក រូបទី២: ក្មេងដែលគេយកមកឧបកិច្ច

[22] ការរាប់បាត្រនេះ ពុំទាក់ទងនឹងពិធីឆ្លងវ័យឡើយ តែគេតែងធ្វើនៅរាល់បុណ្យសំខាន់ណាមួយ។
[23] ហង់ ពៅ ឯកសារទំនៀមទម្លាប់កោរជុក (សិក្ខាសាលានៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន ឆ្នាំ២០០៨) ទំព័រ១-២។


www.elibraryofcambodia.org

## ៣

# ប្រពៃណីចូលម្លប់

ក្នុងខណៈដែលកូនប្រុសមានឱកាសចូលបួសរៀនក្នុងសំណាក់ព្រះពុទ្ធសាសនា ពិធីចូលម្លប់ គឺជាពិធីប្រពៃណីទំនៀមទម្លាប់មួយ ដែលខ្មែរបានប្រារព្ធធ្វើឡើងដើម្បីបំពេញលក្ខណ៍ឱ្យកូនស្រីនៅពេលពេញវ័យ។ ពិធីនេះមានតាំងពីយូរណាស់មកហើយ ក៏ប៉ុន្តែជាប្រការគួរឱ្យសោកស្តាយ ដែលគេមិនអាចដឹងបានថា ពិធីនេះបានចាប់ផ្តើមតាំងពីពេលណាមកនោះទេ។ តាមអ្នកស្រាវជ្រាវបានឱ្យដឹងថា ពិធីឆ្លងវ័យមួយនេះត្រូវបានប្រជាជនខ្មែរនិយមប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនរហូតមកដល់ចុងរជ្ជកាលរបស់ព្រះបាទស៊ីសុវត្ថិមុនីវង្ស គឺប្រហែលជានៅរវាងឆ្នាំ១៩៣០-១៩៤០[24] ទើបគេពុំសូវប្រទះឃើញមានការប្រារព្ធធ្វើនៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជាដូចកាលពីពេលមុនទៀត។

គេធ្វើពិធីនេះឡើងនៅពេល ដែលយុវតីខ្មែរចាប់ផ្តើមពេញវ័យ (វ័យក្រមុំ)គឺរាប់ចាប់តាំងពីពេលនាងមានរដូវជាលើកដំបូង ដោយពុំមានដេញរកវេលាល្អអាក្រក់ដូចពិធីកោរជុក ពិធីអាពាហ៍ពិពាហ៍ ពិធីឡើងផ្ទះ ឬពិធីមួយចំនួនទៀតឡើយ។ ឪពុកម្តាយត្រូវរៀបចំពិធីចូលម្លប់ឱ្យកូនស្រីរបស់ខ្លួន យ៉ាងហោចណាស់ក៏ត្រូវធ្វើឱ្យកូនស្រីច្បងនៃគ្រួសារដែរ។ ការធ្វើពិធីឆ្លងវ័យនេះទៀតសោត មានគោលបំណងសំខាន់ៗមួយចំនួនដូចជា៖

- ប្រកាសភាពពេញក្រមុំឱ្យកូនស្រី
- បន្ទុំសម្បុរ និងអប់រំរូបរាងកាយឱ្យកូនស្រី
- បំពេញលក្ខណៈចរិយាសម្បត្តិ វិជ្ជាមេផ្ទះ និងវិជ្ជាជីវៈឱ្យកូនស្រី (ច្បាប់ស្រី ដេរប៉ាក់ ត្បាញរវៃ...)
- ទាក់ទាញអារម្មណ៍ញាតិមិត្តតាមរយៈរូបរាង ចរិយា និងវិជ្ជា។

---

[24] សូមមើល មៀច ប៉ុណ្ណ ***ក្រមុំចូលម្លប់*** បោះពុម្ពដោយបណ្ណាគារអង្គរ ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ៥ ។



www.elibraryofcambodia.org

ជាទូទៅ ការស្ថិតនៅក្នុងម្លប់មានរយៈពេលកំណត់ពី ៣ ខែ ទៅ ៦ខែ ឬអាច លើសពីនេះ ទៅតាមលទ្ធភាពរបស់គ្រួសារនីមួយៗ។ យុវតីដែលនៅក្នុងម្លប់ត្រូវ ហាត់រៀន និងអនុវត្តការកិច្ចជាច្រើនតាមទំនៀមដែលមានកំណត់ទុកតៗគ្នា ហើយត្រូវ ប្រកាន់ត្រណមួយចំនួន ជាពិសេសគឺត្រូវរក្សាខ្លួនឱ្យនៅក្នុងម្លប់ ដោយមិនប្រាស្រ័យ ទាក់ទងជាបុរសទាំងក្នុងផ្ទះ និងក្រៅផ្ទះទោះជាឪពុក ឬបងប្អូនបង្កើតក៏ដោយ។ម្យ៉ាងទៀត ពិធីឆ្លងវ័យមួយនេះមានពីរដំណាក់កាលសំខាន់ៗគឺការចូលម្លប់ និង ការចេញពីម្លប់ ដែលជាពិធីធំចុងក្រោយធ្វើឡើងយ៉ាងឱឡារិកអធិកអធមដើម្បីប្រកាស ដំណឹងឱ្យញាតិមិត្តជិតខាងបានដឹងឮ និងទទួលស្គាល់នារី ដែលបានឆ្លងកាត់ពិធីនេះ។

តាមទំនៀមទម្លាប់ខ្មែរ ពិធីចេញពីម្លប់ មានរយៈពេល២ថ្ងៃ និងមួយយប់ ពោល គឺថ្ងៃចូល ពិធី និងថ្ងៃឆ្លងពិធីឬថ្ងៃបង្ហើយ។ នៅក្នុងពិធីចេញពីម្លប់នេះគេមានប្រារព្ធ ពិធីតូចៗសំខាន់ៗមួយចំនួនទៀតដូចជា៖

- ពិធីកាត់ស្លឹក
- ពិធីបុកល័ខ
- ពិធីធ្វើធ្មេញបំពេញលក្ខណ៍
- ពិធីដឹកខ្សែ
- ពិធីចូលខ្មោចដំរីសារ។

នៅពេលសព្វថ្ងៃនេះ ទោះបីជាគេពុំសូវប្រទះឃើញនូវការប្រារព្ធពិធីនេះក្តី ក៏នៅ តាមតំបន់ខ្លះក្នុងស្រុក និគមជនបទនៃប្រទេសខ្មែរ នៅតែមានធ្វើពិធីនេះនៅឡើយ តែពិធីនេះស្ទើរតែលុបបាត់បង់ពីប្រពៃណីជាតិខ្មែរទៅហើយ។ អ្នកស្រាវជ្រាវមួយចំនួន បានគូសបញ្ជាក់ឱ្យដឹងទៀតថា មានតំបន់មួយចំនួននៅអនុវត្តពិធីនេះនៅឡើយ ហើយតំបន់ទាំងនោះរួមមានភូមិមួយចំនួននៅស្រុកស្រែអំបិល(ខេត្តកោះកុង) ភូមិ មួយចំនួនទៀតនៅស្រុកបាធាយ(ខេត្តកំពង់ចាម) និងមានភូមិខ្លះទៀតនៅស្រុក


www.elibraryofcambodia.org

សូទ្រនិគម(ខេត្តសៀមរាប)[25]។ ចំណែកនៅទីដទៃទៀត បើទោះជាមានធ្វើពិធីប្រពៃណីនេះក៏ជាករណីដែលមានដោយកម្រដែរ។



ប្រភព៖ អាំងជូលាន, ព្រាប ចាន់ម៉ារ៉ា និង ស៊ុន ចាន់ដឹប ទំ. ៣៥, ៣៧ ។

[25]សូមមើល អាំង ជូលាន ព្រាប ចាន់ម៉ារ៉ា និងស៊ុន ចាន់ដឹប *ដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យ* ការផ្សាយរបស់ហនុមានទេសចរណ៍ បោះពុម្ពលើកទី១ ភ្នំពេញ ឆ្នាំ២០០៧ ទំព័រ២៣។



www.elibraryofcambodia.org

# ៤

# ប្រពៃណីបំបួសនាគ

*នាគ* មានន័យថា ប្រសើរ ចម្បង ឬបរិសុទ្ធ ហើយកុលបុត្រដែលមានចិត្តជ្រះថ្លាចូលទៅបួសក្នុងសំណាក់ព្រះពុទ្ធសាសនាក៏ហៅថា *នាគ* ដែរ ព្រោះអ្នកនោះមានគំនិតបម្រុងនឹងប្រព្រឹត្តព្រហ្មចរិយាធម៌សម្រាប់បព្វជិត។

ពិធីបំបួសនាគ គឺជាពិធីឆ្លងវ័យដ៏សំខាន់មួយសម្រាប់ឆ្លងវ័យក្មេងប្រុស។ ពិធីនេះអាចឆ្លុះបញ្ចាំងថា ប្រុសដែលចូលក្នុងវ័យកំលោះ គេតែងញែកចេញឱ្យដាច់ពីស្រីដែលឈានចូលដល់វ័យក្រមុំ។ ជាក់ស្ដែងនៅសម័យមុន ក្នុងពេលដែលយុវតី ចូលម្លប់ យុវជនប្រុសៗជាទូទៅត្រូវចូលបួសរៀនក្នុងសំណាក់ព្រះពុទ្ធសាសនា។ កត្តានេះហើយ ទើបខ្មែរយើងនិយមនិយាយថា «បួសរៀន» ហើយនៅស្រុកស្រែចម្ការ ចាស់ៗភាគច្រើនចូលចិត្តរាប់អានអន្ទិត[26] ព្រោះគេយល់ថាជាអ្នកដែលបានបួសរៀនចេះដឹង និងមានកិរិយាមារយាទល្អប្រពៃ។



## ១- ប្រវត្តិនៃពិធីបំបួសនាគ

ការបួសរៀនក្នុងព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា មានប្រវត្តិតាំងពីយូរមកហើយ។ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរបានបញ្ជាក់ថា ប្រជាជនខ្មែរទាំងរាស្ដ្រ និងស្ដេចរមែងនិយមការបួសរៀនតាំងពីសម័យ ដែលព្រះពុទ្ធសាសនា បានផ្សាយចូលមកដល់ប្រទេសកម្ពុជាម្ល៉េះ ដោយគេចង់ជម្រះខ្លួនឱ្យបរិសុទ្ធ និងដើម្បីជាញាតិក្នុង

[26] ពាក្យ «អន្ទិត»នេះ ក្លាយមកពីពាក្យថា «បណ្ឌិត» ដែលខ្មែរប្រើយូរៗទៅក្លាយសូរជា «អន្ទិត» នេះឯង។



www.elibraryofcambodia.org

ព្រះពុទ្ធសាសនា។ អ្នកស្រាវជ្រាវអាចរកតឹកតាងពី សម័យបុរាណបានខ្លះដែរ ដូចយ៉ាងសិលាចារឹកនៅសសរប្រាសាទអង្គរវត្ត ត្រង់ថ្នាក់កណ្តាលពីខាងមុខបាននិយាយដល់រឿងព្រះរាជាទ្រង់បំបួសព្រះរាជបុត្រ។[27]

តាមទំនៀមបុរាណ គេនិយមបំបួសនាគជារាស្ត្រ ក្នុងរវាងពាក់កណ្តាលខែជេស្ឋ និង បំបួសនាគជាព្រះរាជវង្សានុវង្ស នៅរវាងពាក់កណ្តាលខែអាសាឍ។ លុះមកទល់នឹងរាជ្យព្រះបាទនរោត្តម ពិធីនេះក៏ត្រូវបង្រួមមកធ្វើនៅក្នុងខែអាសាឍទាំងអស់វិញ តែគេបំបួសនាគរាស្ត្រ និងនាគរាជវង្សានុវង្ស ក្នុងថ្ងៃផ្សេងគ្នាដដែល។ ក្នុងរជ្ជកាលក្រោយៗមកទៀត គេនិយមធ្វើពេល ជាមួយគ្នា ពោលគឺ ក្នុងថ្ងៃ ១៤ កើត និង ១៥ កើតវិញម្តង។ នៅពេលសព្វថ្ងៃនេះ យើងសង្កេតឃើញថា ពិធីបំបួសនាគនៅតែបន្តអត្ថិភាពរបស់ខ្លួនដដែល ក៏ប៉ុន្តែយើងហាក់ពុំប្រទះឃើញពិធីបំបួសនាគព្រះរាជវង្សានុវង្ស ធ្វើជាទូទៅ និងជាឱឡារិកដូចសម័យមុនទៀតឡើយ។

## ២- គោលបំណងនៃពិធីបំបួសនាគ

ដូចយើងដឹងត្រួសៗខ្លះហើយនៅចំណុចខាងលើថា គេធ្វើពិធីនេះឡើងដើម្បីញែកវ័យកំលោះ ឱ្យដាច់ពីវ័យក្រមុំ និង ជាពិសេស ដើម្បីភ្ជាប់និស្ស័យជាមួយព្រះពុទ្ធសាសនា។ គោលបំណងសំខាន់ ផ្សេងទៀតនោះគឺ គេបួសរៀនដើម្បីក្រេបយកចំណេះដឹងផ្សេងៗផង និងដើម្បីសងគុណមាតាបិតាផង។ ខ្មែរយល់ថា ការបួសជាសាមណេរ ពីអាយុ ១៣-២០ ឆ្នាំ គឺដើម្បីសងគុណម្តាយ ហើយការបួសជាភិក្ខុ ពីអាយុ ២០ ឆ្នាំឡើងទៅ គឺដើម្បីនឹងសងគុណឪពុក។

## ៣- ការប្រព្រឹត្តទៅនៃពិធីបំបួសនាគ

គួរកត់សម្គាល់ដែរថា ពិធីបំបួសនាគនេះ ខ្មែរជារឿយៗ តែង ធ្វើចូលគ្នាយ៉ាងឱឡារិកជួនកាលមាននាគ ចំនួនក្រោម១០ នាក់ ហើយជួនកាលទៀត អាចឈានដល់ទៅរាប់សិបនាក់ក៏មានដែរ។

---

[27] ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ *ព្រះរាជពិធីទ្វាទសមាស* ភាគទី៣ ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦០ ទំព័រ២៥-៣៣។



www.elibraryofcambodia.org

ដំណើរប្រព្រឹត្តទៅនៃពិធីនេះ មានសេចក្តីសង្ខេបត្រួសៗដូចតទៅនេះ។ ជាដំបូង គេរៀបចំតុបតែងនាគ ដោយសម្លៀកបំពាក់ស្អាត និងគ្រឿងអលង្ការផ្សេងៗ ប្រៀបដូចជាព្រះសិទ្ធត្ថ ដែលរស់នៅក្នុង វាំងប្រកបដោយរាជសម្បត្តិគ្រប់យ៉ាង មុននឹងយាងទៅសាងផ្នួសដែរ។ បន្ទាប់ពីកិច្ចនេះចប់ ទើបគេចាប់ផ្ដើមហែនាគចេញពីភូមិរៀងៗខ្លួន រហូតជួបគ្នាកើតជាក្រុមកាន់តែធំឡើងៗ។ ជាទូទៅ នាគតែងតែជិះសេះ តែបើពុំមានសេះទេនោះ គេឱ្យនាគជិះកង់ដោយមានអ្នកជីកបណ្ដើរ ហើយ តំបន់ខ្លះដែលសម្បូរដំរី (ឧ. ខេត្តសុរិន្ទ្រ) គេឱ្យនាគជិះដំរីទៀតផង។ ក្រៅអំពីនាគ មនុស្សដែលតាម ហែហមនាគនោះ សុទ្ធតែនាំគ្នាដើរទាំងអស់។ ទន្ទឹមនឹងនេះដែរ គេក៏មានលេងភ្លេងកំដរ ដូចជា ភ្លេងពិណពាទ្យ និងឆៃយ៉ាំជាដើម រហូតចូលដល់វត្ត ដែលមានមនុស្សម្នាច្រើនកុះករ។







ប្រភព៖ អាំង ជូលាន, ព្រាបចាន់ម៉ារ៉ា និង ស៊ុន ចាន់ដឹប, ទំព័រ ៤៧ ។



www.elibraryofcambodia.org

បើនិយាយដោយសង្ខេប កិច្ចសំខាន់ក្នុងពេលយប់ គឺពិធីហៅព្រលឹងនាគ ហើយពិធីនេះនឹងបញ្ចប់ទៅដោយកិច្ចជញ្ជាត់ព្រលឹងនាពេលទៀបភ្លឺ។ ក្នុងពេលធ្វើពិធីហៅព្រលឹងនេះ គេក៏មានភ្ជាប់ដោយការបង្វិលពពិលឱ្យនាគផងដែរ ហើយនៅកន្លែងខ្លះដែលកាន់ប្រពៃណីខ្លាំង គេឱ្យនាគដេកលើអង្ករាបទៀតផង។ ពេលព្រឹកព្រលឹមគេរៀបពិធីសំខាន់មួយទៀត គឺពិធីធ្វើធ្មេញ ដោយមានភ្ជាប់ជាមួយនូវកិច្ចផ្សេងៗទៀត។ ពិធីសំខាន់ចុងក្រោយ ដែលធ្វើឱ្យនាគនឹងក្លាយជាបព្វជិតនោះ គឺកិច្ចបំបួស ដែលត្រូវធ្វើនៅក្នុងព្រះវិហារនៅពេលរសៀល ហើយកិច្ចនេះមាន បែបបទហ្មត់ចត់ណាស់។ កាយវិការចុងក្រោយបង្អស់ ដែលនាគលះបង់ភាពជានាគមកជា បព្វជិតនោះ គឺត្រង់ពេលដែលឧបជ្ឈាយ៍ «ទាក់ក» នាគ ហើយនាគត្រូវដោះសំពត់ហូល សាវស្បៃ និងអលង្ការ នានាចេញពីខ្លួន ដោយមកស្លៀកស្បង់ គ្រងចីវរពេញលេញជាអ្នកបួសពិតប្រាកដ។



ប្រភព៖ អាំង ជូលាន, ព្រាបចាន់ម៉ារ៉ា និង ស៊ុន ចាន់ដឹប, ទំព័រ ៤៩, ៥០ ។

បើប្រៀបធៀបទៅនឹងចូលម្លប់ ពិធីបំបួសនាគនេះដូចជា «ចូល» ដែរ ដ្បិតបន្ទាប់មក អ្នកបួសថ្មីៗត្រូវស្ថិតក្នុងបរិបទខុសពីគ្រហស្ថ ព្រោះត្រូវនៅក្នុងវត្តជាពិសេសក្នុងវស្សា ពុំខុសពីកូនស្រីនៅក្នុងម្លប់ឡើយ។ តាមពិតទៅ ការបួសនេះ មានបីដំណាក់កាលដូចពិធីចូលម្លប់ដែរ គឺការបួស ការស្ថិតនៅជាបព្វជិតក្នុង រយៈពេលខ្លីឬវែង និងការលាចាកផ្នួស(សឹក)។ ទោះជាយ៉ាង នេះក្តី ពិធីសម្រាប់ស្រីប្រុស ផ្ទុយគ្នា


www.elibraryofcambodia.org

ត្រង់បួសមានភាពឱឡារិកខ្លាំងណាស់ ពុំដូចចូលម្លប់ ដែលមានត្រឹមតែសែនព្រេន ជូនតាបន្តិចបន្តួច តែលុះដល់ពេលសឹកវិញ គឺគេធ្វើឡើងស្ងាត់ៗពុំមាននរណាដឹងឮប៉ុន្មានឡើយ រីឯការចេញពីម្លប់របស់កូនស្រីវិញ មានភាពអធិកអធមក្រៃលេង។

ជាទំនៀមតៗមក អ្នកដែលបានបួសរៀនយូរ តែងតែទទួលបាននូវការឱ្យតម្លៃ ការគោរព និងការរាប់អានពីសំណាក់សង្គមខ្មែរ ដ្បិតប្រជាជនខ្មែរ យល់ឃើញថា អ្នកទាំងនោះសុទ្ធសឹងជា មនុស្សមានចំណេះដឹងច្រើន និងមានកិរិយាមារយាទល្អប្រសើរ។

## ៥
## ប្រពៃណីទាក់ទងនឹងកំណើត

ស្ត្រីមានគភ៌ តែងតែមានអាការៈខុសប្រក្រតីមួយចំនួនដូចជា បាត់រដូវ ក្អួតចង្អោរ ដោយគ្មានហេតុផល និងចូលចិត្តម្ជូរជាដើម។ ៣ខែបន្ទាប់ពីដឹងថា ខ្លួនមានផ្ទៃពោះហើយ ស្ត្រីនោះតែងត្រូវបានគេហាមមិនឱ្យធ្វើការធ្ងន់ ធ្វើដំណើរឆ្ងាយៗ ឬមិនឱ្យទទួលទានអាហារផ្តេសផ្តាសជាដើម។ លុះដល់ខែទី៤ ឬទី៥ នារីក៏ចាប់មានអាការៈប្រសើរជាងមុន ខណៈពេលដែលផ្ទៃពោះក៏ចាប់ផ្តើមធំឡើងជាងមុនបន្តិចម្តងៗ។ នៅក្នុងសង្គមខ្មែរ ជាពិសេសកាលពីសម័យមុន ដែលវិទ្យាសាស្ត្រពុំទាន់មានការរីកចម្រើននៅឡើយ ការសម្រាលកូនជាកិច្ចការប្រកបដោយគ្រោះថ្នាក់ ដូចការធ្វើដំណើរឆ្លងទន្លេដែរ ទើបគេនិយមហៅថា «ឆ្លងទន្លេ»។ ហេតុនេះ គេក៏ត្រៀមខ្លួនរួចជាស្រេចដើម្បីសម្រាលកូន ដោយមានវិធីនិងគ្រឿងណាមផ្សេងៗតាមទម្លាប់តៗគ្នារៀងមកទាំងមុនពេលសម្រាល ក្នុងពេលសម្រាល និង ក្រោយពេលឆ្លងទន្លេរួច។


www.elibraryofcambodia.org

## ១- មុនពេលសម្រាល

**+ ពិធីមុនពេលប្រសូតបុត្រ**



រូបភាព: ផ្លែសំពោង

ក្នុងស្នាដៃ "តន្ត្រីនិងជីវិតខ្មែរ" របស់អ្នកស្រី កែវ ណារុំ អ្នកស្រីបញ្ជាក់ថា នៅប្រទេសកម្ពុជា កាលណាស្ត្រីដឹងច្បាស់ថា ខ្លួនមានគភ៌៣ខែហើយនោះ គេក៏រៀបចំពិធីមួយហៅថា "ពិធីចងសំពោង[28]"។ ពិធីនេះ បុព្វបុរសខ្មែរធ្វើឡើងដើម្បីបួងសួងសូមឱ្យកូនមានលក្ខណៈគ្រប់ជាមនុស្ស គ្រប់វិញ្ញាណ និងសូមឱ្យកូននៅក្នុងផ្ទៃ ជាប់នៅជាមួយម្ដាយរហូតដល់ថ្ងៃ ប្រសូត ព្រមទាំងឱ្យទារក និងម្ដាយមាននិស្ស័យបិតនៅជិតគ្នា ជានិច្ច គឺមិនខុសពីចំណងដ៏រឹងមាំនៃផ្លែសំពោងនិងទងរបស់វានោះឡើយ។

នៅសម័យបច្ចុប្បន្ននេះ គេលែងធ្វើពិធីនេះហើយ សូម្បីតែក្នុងសម័យបុរាណក៏គេពុំសូវ ធ្វើធំដុំដែរ។ យើងសង្កេតឃើញជាទូទៅថា ពេលដែលមនុស្សមានផ្ទៃពោះហើយ គេតែងតែមាន ការរំភើបចិត្ត និងមានការបួងសួងសុំសុខុមាលភាពចំពោះមាតានិងទារក ទាំងក្នុងពេលមានផ្ទៃពោះ និង ថ្ងៃប្រសូត។

**+ គ្រណាមផ្សេងៗ**

នៅសម័យមុន ស្ត្រីខ្មែរជាម្ដាយ តែងដើរតាមគន្លងប្រពៃណីបុរាណមួយចំនួនដើម្បីរក្សាគភ៌ឱ្យបានគង់វង្ស និង ឆ្លងទន្លេបានរហ័ស៖

- កុំបរិភោគអាហារមានជាតិហឹរ នាំឱ្យក្រហល់ក្រហាយដល់កូនក្នុងផ្ទៃ។

---

[28] សំពោង ជាប្រភេទរុក្ខជាតិមានទង និងស្លឹកច្រើន ដែលបង្ខាំងជាប់គ្នានឹងទងធំមួយ ហើយពុំងាយនឹងបេះដោយដៃមនុស្ស ឬ កម្លាំងខ្យល់ព្យុះឡើយ។ ហេតុនេះ ទើបខ្មែររើសយករុក្ខជាតិនេះមកធ្វើពិធីបួងសួង។



www.elibraryofcambodia.org

- កុំឈោងយករបស់ ដែលនៅខ្ពស់ផុតពីដៃ នាំឱ្យរបួតទងសុកពីមាត់កូន។
- កុំស្លៀកពាក់រឹតតឹងពេក នាំឱ្យចង្អៀតចង្អល់ដល់កូន។
- កុំបរិភោគបបរ នាំឱ្យកូនកើតមកមិនស្អាត(មិនជ្រះ)។
- បើមានសូរ្យគ្រាស ឬ ចន្ទគ្រាស ត្រូវយកអកកំបោរមកដាក់លើពោះ ដើម្បីជួយសង្កត់ទារកនៅក្នុងផ្ទៃកុំឱ្យភ័យ ឬ ភ្ញាក់ផ្អើលនឹងមហិទ្ធិឫទ្ធិរាហូ បើមិនបានធ្វើបែបនេះទេ កូនកើតមកនឹងទៅជាល្ងីល្ងើមិនគ្រប់ដប់ (អ្នកខ្លះហៅថា កូនរាហ៍កន្លង)។
- កុំដេកថ្ងៃ កុំងូតទឹកយប់ នាំឱ្យកូនថ្លោសពិបាកកើត។
- កុំទៅសួរសុខទុក្ខអ្នកដែលកើតកូនពិបាក។
- កុំដេកដំអក់ ត្រូវហ៊ើសរហួនក្រោកមុនប្ដី នាំឱ្យកើតកូនបានស្រួល។ល។

ក្រៅពីត្រណមទាំងនេះ ស្ត្រីខ្មែរដែលមានគភ៌ហើយ តែងតែផឹកថ្នាំបុរាណ (ថ្នាំរក្សាគភ៌ និងថ្នាំកូនងាយ) ដែលអាចជួយថែរក្សាគភ៌ ក៏ដូចជាជួយសម្រួលដល់ម្ដាយក្នុងពេលឆ្លងទន្លេ។

នៅក្នុងបណ្ដាត្រណមទាំងនេះ មានត្រណមខ្លះមានលក្ខណៈស្របតាមវិទ្យាសាស្ត្រ ឬ វិជ្ជាពេទ្យដែរ ឧទាហរណ៍ "កុំស្លៀកពាក់រឹតតឹងពេក" មានលក្ខណៈសមហេតុសមផល ព្រោះនឹងមិនធ្វើឱ្យប៉ះពាល់ដល់ទារកក្នុងផ្ទៃ តែទន្ទឹមនឹងនេះ ក៏មានត្រណមខ្លះពុំមានលក្ខណៈសមស្របផងដែរ។ បើពិនិត្យឱ្យស៊ីជម្រៅ យើងនឹងឃើញថា ត្រណមខ្លះមានលក្ខណៈសមហេតុផលដែរ ប៉ុន្តែមូលហេតុរបស់វាភាគច្រើនពុំមានលក្ខណៈវិទ្យាសាស្ត្រឡើយ។

**ខ- ពេលសម្រាល**

ក្នុងស្នាដៃ "អរិយធម៌ ខ្មែរ" របស់គាត់ អ្នកស្រី ត្រឹង ងា បានគូសបញ្ជាក់ ថា "នៅពេលឈឺពោះដំបូង បុរសជាប្ដីជាឪពុក ឬ ជា បងប្អូនត្រូវរត់ទៅតាមយាយម៉បដែលនៅក្នុងភូមិ ឬនៅភូមិជិតខាងឱ្យមក ជួយសម្រាលកូន។ សូម បញ្ជាក់ថា ឆ្មបនៅសម័យមុន ពុំបានរៀនសូត្រខាងវិជ្ជាឆ្មប ដូចសម័យនេះទេ គឺគ្រាន់តែចេះដឹងតៗ គ្នាតាម



www.elibraryofcambodia.org

របៀបអ្នកស្រុក។ ព្រោះ ហេតុនេះ យើងសង្កេតឃើញថា ការជួយបង្កើតកូនរបស់ឆ្មប (ឬយាយម៉ប) នៅសម័យនោះ មានសារៈសំខាន់ណាស់ ព្រោះ ពេលនោះពុំទាន់មាន បច្ចេកទេស និងចំណេះដឹងនៃការបង្កើតកូនតាម បែបវេជ្ជសាស្ត្រនៅឡើយ។ ឯកសារជដែលក៏បានបញ្ជាក់ទៀតថា នៅតំបន់ខ្លះក្នុងពេលកំពុងឈឺពោះ គេរៀបពិធីបន់ស្រន់ដល់វត្ថុ ស័ក្តិសិទ្ធិ ឬព្រលឹងដូនតា ដើម្បីសុំឱ្យការឆ្លងទន្លេបានប្រកបដោយសុវត្ថិភាពនិងសុខុមាលភាពទៀតផង។



រូបភាព៖ ទិដ្ឋភាពសម្រាលកូនដោយមានឆ្មប (នៅប្រាសាទបាយ័ន)

**គ- ក្រោយពេលសម្រាល**

**+ ទំនៀមទម្លាប់ក្រោយពេលសម្រាលកូនរួចភ្លាមៗ**

នៅពេលឆ្លងទន្លេរួចហើយ គេតែងប្រព្រឹត្តតាមទំនៀមមួយចំនួនទៀត ដើម្បីធ្វើឱ្យម្តាយនិងកូន បានចៀសផុតពីការបៀតបៀនរបស់ខ្មោចព្រាយបិសាច ដូចជា៖

- ស្ត្រីជាម្តាយនិយមអាំងភ្លើង៣ថ្ងៃ ឬ មួយអាទិត្យ(បើកូនដំបូង)
- អាចារ្យសូត្រមន្តព័ទ្ធសីមាជុំវិញ និងគូសខ្វែងលើសសេរដោយកំបោរស ឬបិទខ្វែង ដោយក្រមួនសុទ្ធ និងជួនកាលគេយកកាំបិត ឬ កន្ត្រៃទៅដាក់នៅក្បាលដំណេកកូនខ្ចីនោះថែមទៀតផង



www.elibraryofcambodia.org

- គេហាមមិនឱ្យអ្នកអាំងភ្លើងនិយាយឆ្លើយឆ្លងជាមួយញាតិមិត្ត ដែលមកសួរសុខទុក្ខ។
- មានពិធីមួយទៀត ដែលគេធ្វើឡើងនៅពេលទម្លាក់ចង្ក្រាន (ពេលឈប់អាំងភ្លើង) ដោយគេបន់ស្រន់ព្រះធរណីនិងមេបា ដើម្បីសុំឱ្យជួយការពារម្ដាយនិងកូនខ្ចីនោះ។[29]

តាមទម្លាប់គ្រួសារខ្មែរ បន្ទាប់ពីស្ត្រីសម្រាលកូនរួចមិនយូរប៉ុន្មាន បុរសជាប្ដីត្រូវយកសុកទៅកប់ ឬ យកទៅដុតដោយជ្រើសរើសទិសណាដែលល្អទៀតផង។ ក្រៅពីនេះ ស្ត្រីមានកូនខ្ចី ជាទូទៅតែងតែផឹកថ្នាំខ្មែរ(ថ្នាំសរសៃ) ដើម្បីកុំឱ្យទាស់សរសៃខ្ចី និងកុំឱ្យមានជំងឺផ្សេងៗ ហើយស្ត្រីជាម្ដាយភាគច្រើន ជាពិសេសនៅតាមជនបទ និយមអនុវត្តតាមទម្លាប់មួយទៀត នោះគឺ"ការផ្តុង" ដើម្បីរក្សាសម្រស់របស់ខ្លួន និង ដើម្បីឱ្យឆាប់ជាសះស្បើយមាត់ស្បូនរបស់ខ្លួនផង។

**+ ពិធីផ្សេងៗ (ពិធីកាត់សក់បង្កក់ឆ្មប)**

នៅពេលដែលទារក កើតបាន៧ថ្ងៃ ឬ ១៥ថ្ងៃ ឬក៏១ខែ គឺទៅតាមការសន្មតរបស់គ្រួសារខ្មែរ គេរៀបចំពិធីទំនៀមមួយទៀត ហៅថា "ពិធីកាត់សក់បង្កក់ឆ្មប"។ នេះគឺជាពិធីមង្គលទី១ក្នុង ជីវិតរបស់ទារក ហើយក៏ជាពេលដែលគេដាក់ឈ្មោះឱ្យទារកនោះដែរ។

នៅក្នុងពិធីនេះ គេពុំឃើញមានវត្តមានរបស់អាចារ្យទេ គឺគ្រាន់តែអញ្ជើញញាតិមិត្ត បងប្អូន ម្ដាយឪពុករបស់ទារក និងឆ្មបមកចូលរួមតែប៉ុណ្ណោះ។ ឪពុកទារកក៏រៀបចំរណ្ដាប់សគុណ ដល់ឆ្មប ដែលបានខិតខំជួយបង្កើតកូន។ រីឯម្ដាយទារកក៏ត្រូវថ្លែងអំណរគុណ និងសុំខមាទោស ចំពោះឆ្មបផងដែរ។

កាលណាគេរៀបរណ្ដាប់ហើយ គេយកទារកមកដេកលើម៉ក់(ពូកតូចៗសម្រាប់ទារក) នៅចំកណ្ដាលផ្ទះបែរក្បាលទៅទិសខាងកើត ហើយនៅចុងជើង គេក៏រៀបចាសម្លូប និងបង្អែម ព្រមទាំងសម្លៀកបំពាក់និងអលង្ការនានាផងដែរ។ បន្ទាប់មក

---

[29] ត្រឹង ងា ***អរិយធម៌ខ្មែរ*** បោះពុម្ពលើកទី៣ ឆ្នាំ១៩៧៥ ទំព័រ១១២-១១៤។



www.elibraryofcambodia.org

ធ្មប់ក៏ចាប់ផ្ដើមអុជទៀនធូប ដើម្បីអញ្ជើញព្រលឹងគ្រូដែលថែរក្សាគាត់ ក្នុងខណៈពេលឪពុកទារក អុជទៀនធូប អញ្ជើញគ្រូបាធ្យាយនិងម្ដាយដើមដែលត្រូវតាមមកបង្ហាត់បង្រៀននិងថែរក្សាទារក ព្រមទាំងអញ្ជើញវត្ថុ ស័ក្ដិសិទ្ធិទាំងឡាយមកសេពសោយអាហារ។ នៅបន្ទាប់ពីនោះ មានកិច្ចជាច្រើនទៀតដូចជា ពិធីបើកភ្នែក ពិធីកាត់សក់ ពិធីជញ្ជាត់ព្រលឹងឬហៅព្រលឹងទារក(គេជឿថាមានព្រលឹង១៩) និងពិធីបង្វិលពពិល។ ក្រោយពីបានធ្វើកិច្ចទាំងនេះហើយ គេក៏បិទពន្លៃត្រង់បង្ហើយរបស់ទារក (គេតែងដូរពន្លៃដែលបិទនោះ ជារៀងរាល់ថ្ងៃ រហូតដល់ទារកមានអាយុ៧ ឬ ៨ ខែ ទើបគេឈប់បិទ)។ នៅទីបញ្ចប់ ធ្មប់ដែលជាអ្នកដឹកនាំពិធីនេះ ក៏អុជទៀនធូបដោតលើជង្ហាយផ្សេងៗ ដើម្បីអញ្ជើញជូនតាមកទទួលជង្ហាយ និងប្រសិទ្ធពរជ័យដល់កូនចៅ។ ឪពុកម្ដាយ បងប្អូន ញាតិមិត្ត នាំគ្នាចូលទៅប្រោះព្រំឱ្យពរជ័យម្នាក់ម្ដងៗដល់ទារក ហើយគេក៏នាំគ្នាចងដៃទារកតាមធនធានដែលមានរៀងៗខ្លួន។

ការខិតខំទ្រាំទ្រពពោះ ការថែរក្សាគភ៌ និងការឆ្លងទន្លេ គឺជាភារកិច្ចដ៏ចាំបាច់ និងជាកិច្ចការដ៏លំបាកក្រៃលែងសម្រាប់ស្ត្រីខ្មែរ ក៏ដូចជាស្ត្រីនៅក្នុងពិភពលោកដែរ។ ហេតុនេះហើយ ខ្មែរយើងសម័យបុរាណ បានស្វះស្វែងរកវិធីការពារ និងមានជំនឿផ្សេងៗសម្រាប់ជួយធ្វើឱ្យម្ដាយ និងគភ៌មានសុវត្ថិភាពទាំងមុនពេលសម្រាល ពេលសម្រាល និងក្រោយពេលសម្រាល។ បើទោះបីជាទំនៀមទាំងនោះមានលក្ខណៈបុរាណទៅហើយក្ដី តែវាគឺជាកត្តាមួយ ឆ្លុះបញ្ចាំងពី ប្រពៃណីដ៏សម្បូរបែប និង ការយកចិត្តទុកដាក់ចំពោះម្ដាយនិងទារក។ គួរកត់សម្គាល់ដែរថា ជំនឿ និងពិធីផ្សេងៗទាក់ទងនឹងស្ត្រីមានគភ៌នេះ គេពុំសូវយកមកអនុវត្តប៉ុន្មានទេក្នុងសម័យទំនើបនេះ ក៏ប៉ុន្តែប្រជាជនខ្មែរនៅតាមស្រុកស្រែចម្ការខ្លះៗ នៅតែ រក្សាជំនឿនិងទំនៀមទម្លាប់បុរាណនេះនៅឡើយ។


www.elibraryofcambodia.org

## ៦
## ប្រពៃណីរៀបអាពាហ៍ពិពាហ៍ខ្មែរ

**អាពាហ៍ពិពាហ៍ជាអ្វី ?**

យើងមិនទាន់ដឹងច្បាស់ថា សង្គមយើងចាប់រៀបអាពាហ៍ពិពាហ៍នៅក្នុងសម័យណាឡើយ។ តើអាពាហ៍ពិពាហ៍ខ្មែរមានត្រឹមសម័យព្រះថោង នាងនាគ ឬ មានមុនសម័យនេះ? នេះជាចម្ងល់របស់យើង ។ ប៉ុន្តែ អាពាហ៍ពិពាហ៍មានអត្ថន័យសំខាន់ណាស់ក្នុងជីវិតសង្គមខ្មែរ ។

ពាក្យ «អាពាហ៍ពិពាហ៍» ឬ «អាវាហ៍វិវាហ៍» ក្លាយមកពីពាក្យបាលីសំស្ក្រឹតថា *អាវាហៈវិវាហៈ* ដែលមានន័យដូចតទៅ ៖

- «អាវាហៈ»មានន័យថា៖ការនាំកូនស្រីមកផ្ទះខាងប្រុស ។

-«វិវាហៈ»មានន័យថា៖ ការនាំកូនប្រុសមកផ្ទះខាងស្រីវិញ។

-«អាវាហ៍វិវាហ៍»មានន័យថា៖ មង្គលការកូនប្រុសស្រីដែលនាំមក ហើយត្រឡប់ទៅវិញ (ពីរលើក) ។

តាមប្រពៃណីខ្មែរ គេនាំកូនប្រុសមកខាងលំនៅស្ថានកូនស្រីមុន(វិវាហៈ) ទើបនាំកូនស្រីមកផ្ទះខាងកូនប្រុសក្រោយ (អាវាហៈ) ។ ការណ៍នេះប្រហែលជាពីដើមមកខ្មែរគោរពរបបមាតាធិបតេយ្យ ។ ដូច្នេះ យើងអាចឲ្យនិយមន័យថា៖«អាពាហ៍ពិពាហ៍គឺជាពិធីមួយធ្វើឡើងសម្រាប់ផ្សំផ្គុំ បុរស នារីពីរនាក់ឲ្យទៅជាប្ដីប្រពន្ធ តាមទំនៀមទម្លាប់ និងតាមច្បាប់របស់ប្រទេស »

**១- ប្រភព និងប្រវត្តិពិធីផ្សេងៗនៃអាពាហ៍ពិពាហ៍ខ្មែរ[30]**

នៅកម្ពុជា ក្បួនឬទម្រង់អាពាហ៍ពិពាហ៍ ដែលត្រូវបានអនុវត្តមកទល់សព្វថ្ងៃនេះ

[30] មៀច ប៉ុណ្ណៈឯកសារស្រាវជ្រាវប្រពៃណីទំនៀមទម្លាប់ខ្មែរពាក់ពន្ធ័នឹង នរវិទ្យា និងជាតិពន្ធុវិទ្យា ២០០៣ ទំព័រ៣


www.elibraryofcambodia.org

ច្រើនធ្វើតាម លំអានរឿងរ៉ាវក្នុងគម្ពីរជាតក និងរឿងព្រេងផ្សេងៗដូចការពណ៌នាខាងក្រោមនេះ ៖

- កាលព្រះវេស្សន្តរ និងព្រះនាងមទ្រី រៀបអភិសេកបុត្រាបុត្រីគឺ ជាលី និង ក្រឹស្នា ឲ្យបានទៅ ជាគូស្វាមីភរិយា(ព្រះវេស្សន្តរជាតក)។
- កាលព្រះបាទទសរថ និងឥសីមិថិលា រៀបអភិសេកព្រះរាមនិងនាងសីតា (រឿងរាមកេរ្តិ៍)។
- កាលសេដ្ឋីបុណ្ណវឌ្ឍន រៀបការជាមួយនាងវិសាខាអស់រយៈពេល ៣ ខែ (គម្ពីរធម្មបទ)។
- កាលព្រះបាទមហាចក្រនៅនគរនិគ្រោធគ្រាមារៀបអាពាហ៍ពិពាហ៍ព្រះរាជបុត្រីរយៈពេល ៧ ថ្ងៃ ៧យប់ (សាស្ត្រាស្លឹករឹតៈ គម្ពីរក្បួនទម្រង់ការ ចារដោយភិក្ខុចន្ទ ថេរអ្នង)។
- កាលព្រះថោងរៀបអភិសេកជាមួយនាងនាគបានបន្សល់ទុកពិធីក្នុងអាពាហ៍-ពិពាហ៍ខ្មែរ ដូចជា ការតម្រូវឱ្យកូនប្រុសតោងជាយស្បៃកូនស្រីចូលក្នុងបន្ទប់ និងការមានបទព្រះថោង នាង នាគ បទនាគព័ន្ធ ជាដើម ។

ខាងក្រោមនេះជាប្រវត្តិនៃពិធីខ្លះៗ ដែលត្រូវបានបញ្ចូលមកក្នុងអាពាហ៍ពិពាហ៍ខ្មែរ ជាប់ជាទំនៀមមក។

### ក- រឿងបុរសឃ្វាលគោនិងបុរសឃ្វាលក្របី (ទាក់ទងនឹងពិធីស៊ីស្លាជក់ស្លាកន្សែង)

មានហេតុដំណាលថាកាលដើមឡើយមានបុរសពីរនាក់ទៅឃ្វាលគោនិងឃ្វាលក្របីជួបគ្នា ហើយសុំគ្នាធ្វើជាភ្លើ ។ពួកគាត់សាកសួរគ្នាពីបញ្ហាទាក់ទងនឹងគ្រួសារ ពីប្រពន្ធ និងកូន ។ ភ្លើម្នាក់ថា មានកូនស្រី ឯភ្លើម្នាក់ទៀតថាមានកូនប្រុស ។ ដូច្នេះ ក៏និយាយផ្សំផ្គុំកូននិងកូនឲ្យជាគូសម្ពន្ធ័នឹងគ្នា ។ បុរសមានកូនស្រីយល់ព្រម ទើបបុរសមានកូនប្រុសស្រាយយកស្លាចងវេចថ្នក់ ដក់នឹងកន្សែងមកឲ្យ បុរសមានកូនស្រីនោះធី



www.elibraryofcambodia.org

ហើយថាជ្បិតនៅក្នុងព្រៃខ្លួនគ្មានអ្វីជាគ្រឿងបញ្ចាំចិត្តទេ សុំឲ្យសម្លាញ់ធីស្លា ជាប់នឹងកន្សែងនេះមួយម៉ាត់ចុះ ដើម្បីជាកិច្ចសញ្ញាដល់គ្នានឹងគ្នាតទៅ ។ បុរសដែលមានកូនស្រីក៏ព្រមទទួលតាម ។

ព្រោះហេតុដូច្នេះហើយ ទើបមានកិច្ចពិធីពិសាស្លាកន្សែងនៅក្នុងអាពាហ៍ពិពាហ៍ខ្មែរហូតដល់សព្វថ្ងៃ ។ កិច្ចនេះជាសក្ខីភាពបញ្ជាក់ថាមាតាបិតាកូនប្រុស កូនស្រី យល់ព្រមធ្វើជាជន្លងផ្សារសាច់ ផ្សារឈាមនឹងគ្នា ។

**ខ- រឿងទាក់ទងនឹងពិធីសែនក្រុងពាលី**

មានការជំណាលខុសគ្នារវាងសៀវភៅប្រជុំរឿងព្រេងខ្មែរ ភាគ៩ និងការចេះចាំរបស់លោក អាចារ្យមួយចំនួនអំពីរឿងព្រេងទាក់ទងនឹងកិច្ចពិធីសែនក្រុងពាលីនេះ។

តាមដំណើររឿងក្នុងប្រជុំរឿងព្រេងខ្មែរ ការប្រារព្ធពិធីក្រុងពាលីក្នុងមង្គលការគ្រាន់តែជាការឧទ្ទិសកុសលជូនស្តេចក្រុងពាលីឲ្យរួចចាកជាតិជោកទាប។

តាមការជំណាលរបស់លោកអាចារ្យ សួន សុន ការធ្វើពិធីសែនក្រុងពាលី គឺដើម្បីសុំសេចក្តីសុខចម្រើន មានជោគជ័យសិរីសួស្តី សុភមង្គលដល់ម្ចាស់ពិធី។ ដោយហេតុនេះហើយ ទើបក្នុងពិធីកិច្ចផ្សេងៗរបស់ខ្មែរ គេតែងតែធ្វើកិច្ចពិធីសែនក្រុងពាលីនេះដោយការនិយាយពាក្យសុំទឹកដី សុំទីកន្លែងដើម្បីសុំសេចក្តីសុខសប្បាយ សិរីសួស្តី ។

**គ- រឿងទាក់ទងនឹងពិធីបុកលក្ត**

ពិធីបុកលក្ត ធ្វើធ្មេញមានដំណើររឿងនៅក្នុងសៀវភៅប្រជុំរឿងព្រេងខ្មែរ ភាគ៩ ដែលជា ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ។ បើយោលតាមការបំភ្លឺរបស់លោកអាចារ្យ សួន សុន កិច្ចពិធី បុកលក្តធ្វើធ្មេញធ្វើនៅពេលកូនស្រីចូលម្លប់ ពោលគឺនៅពេលកូនស្រីមានវ័យពេញក្រមុំ និងគ្រប់ការ។ គេធ្វើពិធីនេះឡើងដើម្បីជម្រុះឧបទ្រពចង្រៃ និងភាពសៅហ្មងទាំងពួង ។

**ឃ- រឿងព្រះឥសូរ និងព្រះជ័យសុរិយារាជកុមារ ( ទាក់ទងនឹងពិធីបង្វិលពពិល )**

ព្រះឥសូរស្ថិតនៅភ្នំកៃលាស មានរិទ្ធិខ្លាំងពូកែសូម្បីតែអង្គជាតិ( លិង្គ )ព្រះអង្គ និង យោនីនាងឧមាភោគវតីជាមហេសីក៏ខ្លាំងពូកែសក្តិសិទ្ធិណាស់ ។ ថ្ងៃមួយ ព្រះឥសូរ



www.elibraryofcambodia.org

ប្រោសមេត្តាព្រមទទួល បង្រៀនព្រះជ័យសុរិយារាជកុមារនៅឯនគរកែកេតជម្ពូ ជម្ពូទ្វីប ។ ព្រះអង្គទ្រង់ស្តោះទឹកព្រះឱស្ឋ (ទឹកមាត់)ដាក់ព្រះឱស្ឋរបស់ព្រះរាជកុមារ ឲ្យមានកម្លាំងដូចដំរីសារ។ បន្ទាប់រៀនចេះសព្វគ្រប់ហើយ ព្រះរាជកុមារបានក្រាបបង្គំ សុំពរជ័យមង្គលសម្រាប់អាពាហ៍ពិពាហ៍មនុស្សជាតិឲ្យមានសិរីសួស្តី សម្បូរ សប្បាយ។ ព្រះឥសូរបានប្រសិទ្ធីដីខ្សាច់ពេជ្រពីភ្នំចក្រវាលឡជាស្លឹកពោធិ៍មាស (តំណាងយោនីនាងឧមា) និងប្រសិទ្ធីថ្មពេជ្រពីភ្នំហិមាល័យជាទៀនមាស( តំណាងអង្គជាតិព្រះអង្គ ) ហើយសន្មតឈ្មោះ ថា «ពពីររតន៍» ប្រទានដល់ព្រះរាជកុមារយកទៅសម្រាប់មនុស្សជាតិបង្វិលជុំវិញគូស្វាមីភរិយាថ្មី ហើយបក់ផ្សែងចូលក្នុងមាត់ដើម្បីឲ្យមាន កម្លាំងខ្លាំងក្លា ហើយបុត្រធីតាកើតមកមានបញ្ញាឆ្លាតវៃ ។ តំណមក គេហៅថាពពិលៗ ។ ដោយអស់ទៀនមង្គលនេះ អ្នកស្រុកបានយកប្រាក់ សំរឹទ្ធ ទង់ដែង ស្ពាន់ ឬ ដែកធ្វើជាស្លឹកពោធិ៍ ហើយយកក្រមួនលញ់ធ្វើជាទៀន។ តពីនោះមក ក៏មានពិធីបង្វិលពពិល ក្នុងអាពាហ៍ពិពាហ៍ខ្មែរជាប់ជាប្រពៃណីរហូតដល់សព្វថ្ងៃនេះ ។[31]

ការរៀបរាប់ខាងលើបង្ហាញថាពិធីសិរីសួស្តីក្នុងអាពាហ៍ពិពាហ៍ខ្មែរសុទ្ធសឹងតែជាប់ទាក់ទងនឹងរឿងព្រេងនិទាន។ វាបង្ហាញពីមូលដ្ឋាន និងបុព្វហេតុពីបុរាណ នៃដំណើរការរៀបអាពាហ៍ពិពាហ៍ខ្មែរ មិនមែនធ្វើដោយគ្មានន័យខ្លឹមសារនោះទេ ។

## ២- ទម្រង់ផ្សេងៗនៃអាពាហ៍ពិពាហ៍ខ្មែរ

តាំងពីសម័យលង្វែកមកទល់សម័យបច្ចុប្បន្ន ទម្រង់អាពាហ៍ពិពាហ៍ខ្មែរបានវិវត្តប្រែប្រួល ទៅតាមទំនោរសង្គមវប្បធម៌ សង្គម-សេដ្ឋកិច្ច និងសង្គមប្រវត្តិសាស្ត្រ ។ មកទល់ពេលនេះ សង្គមខ្មែរបានឆ្លងកាត់ទម្រង់អាពាហ៍ពិពាហ៍ ៦ ប្រភេទគឺៈ[32]

---

[31] ចាប ពិន ( ឧត្តមប្រឹជា )៖ ក្បួនទម្រង់អាពាហ៍ពិពាហ៍ បណ្ណាគារសេង ងួនហួត ភ្នំពេញ ព.ស២៥០៨ គ.ស ១៩៦៥ ទំព័រ៦៣

[32] មៀច ប៉ុណ្ណ៖ ឯកសារស្រាវជ្រាវប្រពៃណីទំនៀមទម្លាប់ខ្មែរពាក់ពន្ធ័នឹង នរវិទ្យា និងជាតិពិន្ទុវិទ្យា ២០០៣ ទំព័រ៤៥



www.elibraryofcambodia.org

- អាពាហ៍ពិពាហ៍បែបបុរាណ
- អាពាហ៍ពិពាហ៍បែបលើកគ្រែ
- អាពាហ៍ពិពាហ៍ផ្តាច់ការ សមូហភាព
- អាពាហ៍ពិពាហ៍ទំនើប
- អាពាហ៍ពិពាហ៍បែបកំព្រាគូ
- អាពាហ៍ពិពាហ៍បែបសែន

គួរកត់សម្គាល់ថា ដំណើរវិវឌ្ឍប្រភេទអាពាហ៍ពិពាហ៍នីមួយៗតែងតែប្រែប្រួលកែទម្រង់ពី រយៈពេលវែងមករយៈពេលខ្លី ពីពិធីច្រើនមកពិធីតិច...។ មានប្រភេទអាពាហ៍ពិពាហ៍ខ្លះត្រូវគេបោះបង់ចោលទាំងស្រុង ហើយខ្លះទៀតរលុបរលាយសូន្យសុងបាត់បង់រូបភាពអស់ទៅអាស្រ័យ មូលហេតុ ផ្សេងៗ ។

### ២.១- អាពាហ៍ពិពាហ៍បែបបុរាណ

### វគ្គទី១

### ក- ពិធីចែចូវ

ឪពុកម្តាយឬអាណាព្យាបាលខាងកូនប្រុសត្រូវជ្រើសរើសរកស្រីណាម្នាក់ ដែលមានគូស្រករ ត្រឹមត្រូវតាមប្រពៃណី(មិនអភ័ព្វគូ) ជាស្រីមានចរិយាសម្បត្តិល្អ បើនិយាយទៅរកអ្នកណា គេស្តាប់ គេគោរពកោតខ្លាច ជាស្រីមានជីវភាពធូរធារសមរម្យឲ្យចូលទៅចែចូវ ។

ការចូលទៅជួបម្តាយកូនស្រីនេះមិនមែនតែម្តងទេ ជួនកាល ទៅលើកទី១ លើកទី២ លើកទី៣ ឬ លើកទី៤ ទើបទទួលបានលទ្ធផល។ ឪពុកម្តាយកូនប្រុសយកថ្ងៃ ខែ ឆ្នាំកូនស្រីទៅរកគ្រូហោរ ដើម្បីមើល សម្ពង្សឆ្នាំ សម្ពង្សធាតុ សម្ពង្សនាគ និងក្បួនមហាសម្ភារភ្លឹកជាដើម តាមប្រពៃណីខ្មែរ ។



www.elibraryofcambodia.org

## ខ- ពិធីស្ដីដណ្ដឹង

ឪពុកម្ដាយកូនប្រុសត្រូវរកឈ្នាយ[33] អញ្ជើញញាតិ និងរៀបចំជំនូនដើម្បីធ្វើដំណើរទៅផ្ទះខាងស្រី ។ ការធ្វើពិធីស្ដីដណ្ដឹងនេះមាន ៣ លើកគឺ ៖

- លើកទី១: លោកមេបាគ្រាន់តែអនុញ្ញាតឲ្យផ្លូវដើរ ដណ្ដើរចុះ សម្រាប់ទាក់ទងកិច្ចការផ្សេងៗតែប៉ុណ្ណោះ ។

- លើកទី២: លោកមេបាគ្រាន់តែអនុញ្ញាតឲ្យពឹងពាក់ពំនាក់អាស្រ័យគ្នាទៅវិញទៅមកបាន ។

- លើកទី៣: លោកមេបាបានអនុញ្ញាតឲ្យនាងឈ្នាយនាំកូនប្រុសមកជាមួយមាតាបិតា ញាតិសន្ដាន ដើម្បីនឹងបង្ហាញរូបសម្បត្តិកូនប្រុសដល់លោកមេបា និង ញាតិខាងកូនស្រី។ ក្រោយពីពិនិត្យ ទៅឃើញថាកូនប្រុសនោះមានចរិយាមារយាទសមរម្យល្អហើយ ទើបឲ្យមាតាបិតាកូនប្រុសរៀបចំធ្វើ ពិធីស៊ីស្លាកំជាប់ពាក្យ ។

## គ- ពិធីស៊ីស្លាកំជាប់ពាក្យ

មាតាបិតាកូនប្រុសត្រូវរៀបភស្ដុភារបណ្ណាការយ៉ាងច្រើន (៣៦ មុខ មួយមុខ ១ គូ) ព្រមទាំងរបស់បញ្ចាំចិត្ត (គ្រឿងមាសពេជ្រ) តាមកម្លាំងធនធាន ។ អ្នកផ្លូវចៅមហាជម្រាបមេបាជាមុនថា៖ «សូមទាន សូមជម្រាបអស់លោកមេបាតូចធំ ត្រកូលរៀមច្បង! ដ្បិតដើងមុនមហាខ្ញុំបាទបានមក ប្រណិប័តន៍លោកមេបា សូមស្ដីដណ្ដឹងកូនស្រីលោកមេបាៗក៏អនុញ្ញាតព្រមឲ្យ ឥឡូវអ្នកសាមីដើម ការឲ្យមហា ខ្ញុំបាទ មកជម្រាបលោកមេបា សូមលើកភស្ដុភារបណ្ណាការ និងរបស់បញ្ចាំចិត្ត ព្រមទាំង សូមស៊ីស្លាម្លូភ្ជាប់ពាក្យផង សូមលោកមេបាមេត្តាអនុញ្ញាតតាមការគួរ។» មេបាត្រូវតែឆ្លើយអនុញ្ញាតទៅតាមពាក្យដែលអ្នកមហាបានសុំ ។

---

[33] ឈ្នាយក្ដី លោកមហាក្ដី ពេលចូលទៅគាល់លោកមេបាម្ដងៗត្រូវមានបីនាក់គឺ បើឈ្នាយមាន ៖ នាងពេជ្រ នាងមាស នាងប្រាក់ កន្លែងខ្លះថា នាងកែវ នាងកង នាងពិទូរ្យស្សុរ្យកាន្ត ។ លោកមហាវិញ ក៏មានបីនាក់ដែរគឺ មហាទេព មហាមន្ត្រី មហាភក្ដី ។



www.elibraryofcambodia.org

ឃ- ពិធីជូនពេលាចេកមាស

បន្ទាប់ពីស៊ីស្លាភ្ជាប់ពាក្យរួចហើយ ត្រូវរៀបកំណត់ពេលាចេកមាសជូនលោកមេបា ។ ពេលាចេកមាសគឺជាពេលា ឬថ្ងៃ ខែ ឆ្នាំកំណត់រៀបមង្គលការកូនប្រុសស្រី ដែលគេសរសេរសេចក្តីលើផែនក្រដាសក្រហម ដាក់ក្នុងស្រោមក្រហមយកទៅតម្កល់លើពានមួយជាន់ឬពីរជាន់ ។

**វគ្គទី ២ ៖ ថ្ងៃរៀបមង្គលការ**

តាមទំនៀមរៀបមង្គលការរបស់ខ្មែរយើង តាំងពីបុរាណកាលមក លោកបានកំណត់ទុកជា ៣ ថ្ងៃគឺ ៖

. *ថ្ងៃទី១ ហៅថា ថ្ងៃចូលរោង*

. *ថ្ងៃទី២ ហៅថា ថ្ងៃស៊ីកំណត់*

. *ថ្ងៃទី៣ ហៅថា ថ្ងៃសំពះ*

**ថ្ងៃទី១៖ ថ្ងៃចូលរោង**

កំណត់ថ្ងៃនាំកូនប្រុសចូលរោងផ្កាស្លា។ មាតាបិតាខាងកូនប្រុសត្រូវរៀបគ្រឿងភ័ស្តុភារបណ្ណាការ ។ សម័យបុរាណគេកំណត់បណ្ណាការភេស្ជ័ភារដែលសំខាន់មិនអាចខ្វះបានមានប្រាំពីរមុខគឺ ចង់រង ស្លាដក់ ស្លាកន្សែង ស្លាព្រះពរ នំអន្សម នំគម និងប្រាក់ស្ពាប់ទឹកដោះ ។

**ថ្ងៃទី២៖ ថ្ងៃស៊ីកំណត់**

នៅពេលព្រឹកបើកិច្ចពិធីទាំងឡាយក្នុងវគ្គទី១ ដូចជា ពិធីបែចូវ ពិធីស្ដីដណ្ដឹង ដែលមិនទាន់បានធ្វើពីមុនមក ត្រូវធ្វើរួមគ្នាក្នុងវេលាព្រឹកនេះតែម្ដង ។

នៅពេលរសៀល គេរៀបចំ៖

**ក- ពិធីកាត់សក់**

ពីសម័យដើមគេកាត់សក់បែកអំពីគ្នា គឺកូនប្រុសកាត់នៅក្នុងរោងផ្កាស្លា រីឯកូនស្រីកាត់នៅលើ ផ្ទះ ។ សព្វថ្ងៃគេនិយមកាត់រួមគ្នា(លើផ្ទះ ឬ រោងផ្កាស្លា)។ ពិធីកាត់



www.elibraryofcambodia.org

សក់នេះ គេលេងភ្លេងបទ សារិកាកែវ ត្រពាំងពាយ ផាត់ជាយ ជាដើម ។[34]

រណ្តាប់ និង របៀបកាត់សក់៖

(១).អាចារ្យ (១១).កញ្ចក់ឆ្លុះមុខមានជើង

(២).អ្នកមហា (១២).រណ្តាប់ព្រះពិស្ណុការ

(៣).អ្នកផ្លូវ (១៣).សាមីខ្លួនកូនស្រី

(៤.៥).មេបា ចាស់ទុំ (១៤). សាមីខ្លួនកូនប្រុស

(៦.៧).ថង់រង១គូ (១៥).អ្នកកំដរកូនស្រី៤នាក់

(៨).ផ្តិលទឹកសំបួរ (១៦). អ្នកកំដរកូនប្រុស៤នាក់

(៩).គ្រឿងសម្អាងកាយ១ប្រដាប់ (១៧). ញាតិមិត្ត និងភ្ញៀវ

(១០).ពានក្រាស់ កន្ត្រៃ កាំបិតកោរ (១៨). អ្នករាំ ច្រៀង

**ខ- ពិធីសែនក្រុងពាលី**

បន្ទាប់មក ចៅមហាត្រូវប្តឹងមេបា សុំរៀបសែនក្រុងពាលី ដើម្បីប្រកាសប្រាប់ដល់ម្ចាស់ទឹក ម្ចាស់ដី ស្តីអំពីការរៀបមង្គលការនេះដោយមានការប្រគំភ្លេងបទកងសោយ ជូនដូនតាស្តាប់ចំនួន បីលើកផង ។

**គ- ពិធីព្រះសង្ឃចម្រើនពុទ្ធមន្ត**

ប្រហែលម៉ោង៦ល្ងាចគេត្រូវនិមន្តព្រះសង្ឃមកចម្រើនព្រះបរិត្ត ប្រសិទ្ធពរជ័យដល់កូនស្រី កូនប្រុស ។ ព្រះសង្ឃ ដែលគេត្រូវនិមន្តចម្រើនព្រះបរិត្តក្នុងពេលរៀបអាពាហ៍ពិពាហ៍ មានចំនួនយ៉ាងតិចក៏ ៤ ព្រះអង្គដែរ ។

រណ្តាប់ និង របៀបព្រះសង្ឃចម្រើនពុទ្ធមន្ត៖

(១).អាសនៈព្រះពុទ្ធរូប (១០.១១).កូនស្រី កូនប្រុស

(២).ស្លាធម៌កន្ទយប្រើស (១២).អាចារ្យ

---

[34] ធីង ផាន់សុផុនៈ បុណ្យទំនៀមខ្មែរ បុណ្យទំនៀមទម្លាប់ខ្មែរ ផ្សាយចេញពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ ភ្នំពេញ ឆ្នាំ២០០០ ទំព័រ ៦៦២



www.elibraryofcambodia.org

(៣).ព្រះសង្ឃ៥អង្គ (១៣).អ្នកមហា

(៤).ផ្តិលទឹកសំបួរ (១៤). អ្នកផ្លូវ

(៥).ផ្កាស្លាខ្ពរ (១៥).អ្នកកំដរកូនប្រុស៤នាក់

(៦).ផ្តិលអង្ករជ័យជោគពពិល៣ (១៦). អ្នកកំដរកូនស្រី៤នាក់

(៩).ថាសដាក់ទៀនពពិល ម្លូស្លា (១៧). មេបា ចាស់ទុំ

(១០).ជង់រង១គូ (១៨). ញាតិមិត្រ និងភ្ញៀវ

**ឃ- ពិធីសែនចងដៃ**

អាចារ្យរៀបចំពិធីសែនប្តឹងជូនតានិងញាតិការពសន្តាន ឲ្យដឹងឮព្រមទាំងជូនពរកូនប្រុសស្រី តាមជំនឿព្រហ្មញ្ញសាសនា ។ ភ្លេងលេងកំដរបទកងសោយ។

វណ្ណាប់ និង របៀបសែនចងដៃ

(១).ផ្តិលទឹកឆ្វេង ពានស្លាម្លូស្តាំ (១១).ផ្តិលទឹក អំបោះចងដៃ

(២).បង្អែមឆ្វេង ស្តាំ (១២). អាចារ្យ

(៣). ចំអាបឆ្វេង ស្តាំ (១៣).អ្នកមហា

(៤).មាន់ស្ងោរ ឆ្វេងស្តាំ (១៤).អ្នកផ្លូវ

(៥). ចានបាយឆ្វេងស្តាំ (១៥). សាមីខ្លួនកូនស្រី

(៦).ក្បាលជ្រូកស្ងោរ ឆ្វេង ស្តាំ រៀបដាក់ពីខាងមុខ (១៦). សាមីខ្លួនកូនប្រុស

(១៧).អ្នកកំដរកូនស្រី ប្រុស

(៧.៨).ជង់រង១គូ (១៨).ញាតិជុំវិញសាមីខ្លួន

(៩.១០).តៀប១គូ

**ង- ពិធីបុកល័ខ ធ្វើធ្មេញ**

ពិធីនេះ គេហៅឈ្មោះបានច្រើនបែបច្រើនយ៉ាងណាស់ ទៅតាមស្រុក តាមបុគ្គល និងតាមការចូលចិត្ត ។ ដូចជា ស្រុកខ្លះហៅ «ពិធីធ្វើធ្មេញបំពេញលក្ខណ៍» «ពិធីលេងសេះ » «ពិធីលេងសេះ ធ្វើធ្មេញបំពេញលក្ខណ៍ » និង «ពិធីកោសធ្មេញ » ជាដើម ។



www.elibraryofcambodia.org

នៅសម័យបុរាណ ពិធីធ្វើធ្មេញបំពេញលក្ខណ៍នេះនៅក្នុងសង្គមខ្មែរទាំងមូល គេនិយមចូលចិត្តធ្វើណាស់ពីព្រោះគេយល់ថាបន្ទាប់ពីធ្វើធ្មេញរួច កូនស្រីក្តី កូនប្រុសក្តីនឹងមានឋានៈនារីគ្រប់លក្ខណ៍ ប្រុសគ្រប់លក្ខណ៍ មានចរិយាល្អ ស្គាល់ខុស ស្គាល់ត្រូវ ។

**ច- ពិធីជាវខាន់ស្លា**

លុះម៉ោង២ឬ៣រំលងអាធ្រាត្រ អ្នកមហាត្រូវឡើងទៅជម្រាបមេបាសុំជាវខាន់ស្លា ឬ កាត់ខាន់ស្លា។ មេបាត្រូវកាត់ថ្លៃខាន់ស្លាតាមកូនច្បង កូនកណ្តាល កូនពៅ។ កូនច្បង និងកូនពៅ គេកាត់ថ្លៃខាន់ស្លាដូចគ្នា គឺប្រាក់៣០តម្លឹង ១បាទ ២ស្លឹង ។ ត្រូវឲ្យលោកមហាសុំបំពេញបន្ថែម ៦តម្លឹង ៣បាទ ២ស្លឹងទៀត បង្គ្រប់ជា ១ណែន(ទម្ងន់ ១៦រៀលជាសាច់ប្រាក់សុទ្ធ) ។ រីឯកូនកណ្តាល ត្រូវថយចុះពីកូនច្បងឬកូនពៅ ២តម្លឹង ដែលត្រូវមហាបំពេញឲ្យគ្រប់ ១ណែនដូចគ្នា។ ការណ៍ដែល អ្នកមហាធ្វើយ៉ាងនេះគឺដើម្បីចម្រើនសិរីសួស្តីដល់កូនស្រីលោកមេបា ។ នៅសម័យឥឡូវ តម្លៃកាត់ខាន់ស្លាច្រើនឬតិច សម្រេចទៅលើកិច្ចព្រមព្រៀងរវាងមាតាទាំងសងខាង ។ ភ្លេងលេងកំដរបទជ្រង។

វណ្តាប់ និងការរៀបចំជាវខាន់ស្លា

(១).កញ្ចក់ឆ្លុះមុខមានជើង
(២).គ្រឿងសម្អាងកាយ១ប្រដាប់
(៣).ពានតម្កល់ក្រាស់សិតសក់១
(៤).ថង់រង១
(៥).ពានចេកមាស១
(៦).នំ២ថាស
(៧).ដូងខ្ចីឡៅ១ និងកូនស្លាបព្រា១
(៨). ផ្តិលទឹក១
(៩). ពានតម្កល់ធាត្រ័១
(១០.១១).ឪពុក និងម្តាយ
(១២). សាមីខ្លួនកូនស្រី
(១៣). អ្នកមហា
(១៤). អ្នកផ្លូវ
(១៥). វង់ភ្លេង

**ឆ- ពិធីផ្ទុំពេលា**

នៅម៉ោង ៤ ជិតភ្លឺ មហាត្រូវឡើងទៅជម្រាបមេបាសុំពេលា ។ លោកមហាត្រូវបន្លឺឡើង៖ «សូមជម្រាបអស់លោកមេបា តូចធំត្រកូលរៀមច្បង សូមទានជ្រាប! ដ្បិត



www.elibraryofcambodia.org

អ្នកសាមីដើមការរកអាចារ្យ ឲ្យគន់គូរមើលពេលាចេកមាសកូនប្រុសស្រីថា ពេលាចេកមាសល្អ តើនឹងបើកបាននៅពេលម៉ោង ប៉ុន្មាន ?»

មេបាឆ្លើយតបថា៖ « ឯពេលាចេកមាសនេះស្រេចតែលើកូនប្រុស បើមហាយល់ថាពេលាណាល្អ យើងជាមេបាក៏នឹងតាមមិនយល់ទាស់ទេឲ្យតែប្រាកដជាមង្គលសួស្តីមែន។ បើមហាថាល្អ តើមាន អ្វីជាកសិណាឲ្យឃើញចាក់ស្តែង ល្មមយើងជាមេបា អាចជឿបានប្រាកដផង?» មហាត្រូវលើកចេក នំ ជំណាប់ជូនមេបាថា៖ «ចេកនេះ ហើយដែលផ្លែចេញមកមានមាសបង្កើតឡើងជាប់ជាមួយ ទាំង ជីវជាតិដីក៏មានរសផ្អែមល្អ ខ្ញុំបាទនាំយកមកទុកជាជ័យមង្គល សូមលោកមេបាមេត្តាពិនិត្យ រួចពិសា មើលចុះ »។

**ជ- ពិធីដោតផ្កាស្លា**

ពិធីជុំវេលារួច អាចារ្យត្រូវរៀបដោតផ្កាស្លាជា ៣ចំណែកគឺ ៖

. ផ្កាស្លាច្បងត្រូវដោតម្លូ២១សន្លឹក និងស្លា២១ផ្លែ( យកតាមគុណឪពុក )

. ផ្កាស្លាកណ្តាលត្រូវដោតម្លូ១២សន្លឹក និងស្លា១២ផ្លែ( យកតាមគុណម្តាយ )

. ផ្កាស្លាពៅត្រូវដោតម្លូ៦សន្លឹក និងស្លា៦ផ្លែ( យកតាមគុណបងប្អូនញាតិ )។

ក្បួនខ្លះដោតផ្កាស្លាច្បង ម្លូ៩ស្លា៩ ផ្កាស្លាកណ្តាល ម្លូ៧ស្លា៧ និងផ្កាស្លាពៅ ម្លូ៥ស្លា៥។ ដោតយ៉ាងនេះគឺគេរាប់តាមសក្តិហៅថា «អំបូរឧត្តមសក្តិ អំបូរមជ្ឈមសក្តិ អំបូរសាធារណសក្តិ» ។

**ថ្ងៃទី៣៖ ថ្ងៃសំពះផ្ទឹម**

ពេលព្រឹកអាចារ្យនាំកូនកម្លោះទៅអង្គុយនៅមុខរានទេវតា បែរមុខទៅរកទិសខាងកើត ដើម្បីចាំយកពេលា ។ លុះព្រះអាទិត្យរះពេញពន្លឺហើយ អាចារ្យគិតថាជាពេលាល្អក៏វាយឃ្មោះ ៣ ដង ជាសញ្ញាឲ្យដឹងថាអាចារ្យចាប់បើកពេលាហើយ ។

**ក- ពិធីហែកូនប្រុសឡើងទៅសំពះផ្ទឹម**

ពេលហែកូនប្រុសដល់មាត់ជណ្តើរ អ្នកកាន់ឃ្មោះវាយឃ្មោះ ៣ ដង ជាសញ្ញាដល់ខាងស្រី ។ កូនប្រុសឡើងកាន់ជណ្តើរ ឬឈរមាត់ទ្វារ ត្រូវធ្វើពិធីលាងជើងមុននឹងចូលផ្ទះកូនស្រីដើម្បីរៀបពិធី សំពះផ្ទឹម ។


www.elibraryofcambodia.org

## ខ- ពិធីបង្វិលពពិល

មុននឹងធ្វើពិធីបង្វិលពពិល កូនប្រុសត្រូវធ្វើពិធីសំពះផ្កាស្លាគម្រប់ ៣ លើក បន្ទាប់មក អ្នកភ្លេងច្រៀងរាំបើកវាំងនន អញ្ជើញកូនស្រីចូលរួមពិធីបង្វិលពពិល។ តាមលទ្ធិព្រហ្មញ្ញសាសនា សន្លឹកពពិលធ្វើឡើងអំពីដែកស្ពាន់ ប្រាក់ ឬ មាស មានឆ្លាក់រូបនាងឧមាភគវតីជាប្រពន្ធព្រះឥសូរ (ព្រះសិវៈ) ។ នាងជាអ្នកបង្កើតមនុស្សទាំងអស់នៅក្នុងឋានកណ្តាលយើងនេះ ។

សន្លឹកពពិលមានរូប១ សម្រាប់មនុស្សសាមញ្ញប្រើក្នុងពេលរៀបមង្គលការកូនចៅ។ គេប្រើ ពពិលនេះ ៣ សន្លឹក ។

សន្លឹកពពិលមានរូប២ សម្រាប់បង្វិលថ្វាយជាមង្គលដល់បុត្រាបុត្រីនៃព្រះរាជា ។ គេប្រើពពិល ៥ សន្លឹក គឺរូប១ បួនសន្លឹក និងរូប២ មួយសន្លឹក ។

សន្លឹកពពិលមានរូប៣ សម្រាប់បង្វិលថ្វាយជាមង្គលដល់ព្រះមហាក្សត្រអភិសេក ។ គេប្រើ ពពិល ៩ សន្លឹក គឺរូប១ ប្រាំបីសន្លឹក រូប២ មួយសន្លឹក និងរូប៣ មួយសន្លឹក។

អាចារ្យប្រកាសសុំមនុស្ស ៩ នាក់ គឺប្រុស ៥ នាក់(រួមទាំងអ្នកកាន់ផ្កាស្លា ៣ ផង) និងស្រី ៤ នាក់ រួមទាំងអ្នកផ្លូវ១ អ្នកមហា១ និងអាចារ្យ ១ នាក់ផង ត្រូវជា ១២ នាក់(ដែលជាតំណាងគុណ ម្តាយ) ដោយរើសយកសុទ្ធតែអ្នកមានគូស្រករ មិនដែលអក័ព្វគូ មកអង្គុយជំកង់ជុំវិញសាមីខ្លួនទាំងពីរ ដើម្បីបង្វិល ពពិលដែលបិទក្រមួនសុទ្ធពីលើ ជាទក្ខិណាព័ត៌១៩ជុំ (លេងភ្លេងជុំគ្រែ) ។

វេណ្តាប់ និងរបៀបបង្វិលពពិល

| | |
|---|---|
| (១.២).ថង់រង១គូ | (១២).អ្នកផ្លូវ |
| (៣.៤)តៀប១គូ | (១៣).អ្នកមហា |
| (៥).ផ្តិលអង្ករជ័យដោតពពិល៣ | (១៤).ផ្កាស្លាច្បង |
| (៦).ផ្តិលទឹកចំណងដៃ ទៀនពេលា | (១៥). ផ្កាស្លាកណ្តាល |
| (៧).ខ្នើយសំពះ | (១៦). ផ្កាស្លាពៅ |



www.elibraryofcambodia.org

(៨).កម្រាលព្រំ

(៩).សាមីខ្លួនកូនស្រី

(១០). សាមីខ្លួនកូនប្រុស

(១១).អាចារ្យ

(១៧).អ្នកកំដរកូនស្រី ប្រុស

(១៨).អ្នកបង្វិលពពិល

(១៩).មេបា ចាស់ទុំ

(២០).ញាតិ និងភ្ញៀវ

## គ- ពិធីហែរាំបើកគៀបបាយស្រី

រណ្តាប់គស្ទុភារដែលដាក់នៅក្នុងគៀបទាំងពីរគឺ៖ មាន់ស្ងោរ ឬសាច់ជ្រូក១ដុំធំ ល្មម នំអន្សម នំគម នំបត់ជាដើម ។ អ្នកភ្លេងម្នាក់ដែលចេះរាំច្រៀងចូលមករាំបើកគម្របបាយស្រីជាបទផាត់ជាយថា៖

*«ស្បែនេះស្បែពីណា ស្បែនេះស្បែពីណា*

*ស្បែលោកមេបា ឲ្យគ្រវាត់បើកបាយស្រី*

*ដាវអើយដាវដែក ដាវអើយដាវដែក*

*ដាវនេះចម្លែក បានមកពីកំពង់ស្វាយ*

*ផ្លែពីឪពុក ស្រោមពីអ្នកម្តាយ*

*ដាវដែកកំពង់ស្វាយ ឈ្នះមារសត្រូវ ។»*

ក្រោយពីរាំច្រៀងហើយអ្នករាំច្រៀងស្រែកថា៖

. ជ័យហោង! (អ្នកទាំងពួងឆ្លើយព្រមគ្នាថា) ជ័យ !

. សួស្តីហោង ! (អ្នកទាំងពួងឆ្លើយព្រមគ្នាថា) សួស្តី !

. សុខហោង ! (អ្នកទាំងពួងឆ្លើយព្រមគ្នាថា) សុខ !

## ឃ- ពិធីបង្វិលចងដៃ

រាំបើកបាយស្រីចប់ហើយ អាចារ្យក៏សូត្រឲ្យពរផ្កាស្លា និងចងដៃមុន។ បន្តមកទើបមាតាបិតា និងញាតិសន្តានទាំងសងខាងចងដៃកូនប្រុសស្រី ដោយប្រើអំបោះឆៅ



www.elibraryofcambodia.org

ពណ៌សនិងឲ្យសព្ទសាធុការពរ តាមចិត្តរៀងៗខ្លួន ។ អ្នកភ្លេងប្រគំបទបាយខុនចងដៃ កំដរពិធីនេះ។ បន្ទាប់មកទៀត អាចារ្យស្រាយ ផ្កាស្លាកណ្ដាលនិងផ្កាស្លាពៅចែកដល់ញាតិមិត្រ និងភ្ញៀវ ដើម្បីបាចសាចឲ្យពរសព្ទសាធុការដល់ កូនប្រុសស្រីរកស៊ីមានបានត្រជាក់ត្រជុំ មានកូនពូនជាចៅសុខសប្បាយជារៀងរហូតទៅ។ អ្នកភ្លេងប្រគំបទ «ចំបក់ពោយ» ដើម្បីកំដរក្នុងឱកាសបាចផ្កាស្លា។ រីឯផ្កាស្លាច្បងត្រូវតម្កល់ទុក ៣ ថ្ងៃ ទើបឲ្យស្វាមីភរិយាថ្មីនាំយកទៅប្រគេនព្រះសង្ឃ ឬគ្រូឧបជ្ឈាយ៍នៅឯវត្តបាចជូនពរឲ្យ។ ពិធីសំពះផ្ទឹមចងដៃ រួចរាល់ហើយនៅតំបន់ខ្លះគេធ្វើពិធីរាំសាកន្ទេល ដោយឲ្យអ្នករាំលីកន្ទេលបណ្ដើរ ច្រៀងបណ្ដើរ ស្រែក ពពាយនាយលក់កន្ទេល។ សាមីខ្លួនទាំងពីរអង្គុយទន្ទឹមគ្នាចាំទទួលទិញកន្ទេល ។ គុណសម្បត្តិរបស់កន្ទេលនេះ បើអ្នកទើបរៀបមង្គលការហើយថ្មីៗទិញយកទៅក្រាលដេក នឹងកើតមាស កើតប្រាក់ ។

ពេលរាត្រីឪពុកម្ដាយកូនស្រីត្រូវពឹងស្ត្រីវ័យចំណាស់២នាក់ ឲ្យមកជួយរៀបចំពិធីផ្សំដំណេក របស់កូនប្រុសស្រី។រណ្ដាប់ក្នុងពិធីនេះមានបង្អែម១ចាសចំអាប១ចាស បាយសី១ ដូងខ្ចី១ ។ ដំបូងគេ អុជទៀនធូបសែនជូនតា ។ បន្ទាប់មកចាក់ទឹកដូង និងបកចេកបញ្ចុកគ្នាទៅវិញទៅមក ដើម្បីទុកជា និមិត្តរូបនៃការចេះស្រឡាញ់គ្នារហូតអស់មួយជីវិត ។ ចុងក្រោយបង្អស់ គាត់ចាប់ក្បាលកូនប្រុស និង កូនស្រីទង្គិចគ្នា ហើយប្រាប់ថា៖ « ចូរអ្នកទាំងពីរបានគ្នាជាគូស្វាមី ភរិយាចុះ» និងបង្គាប់ឲ្យកូនប្រុស ដេកមុន (ខាងស្ដាំ) ឲ្យកូនស្រីដេកក្រោយ(ខាងឆ្វេង) ។

## ២.២- អាពាហ៍ពិពាហ៍បែបទំនើប

អាពាហ៍ពិពាហ៍បែបទំនើបនេះមិនមែនជាទម្រង់អាពាហ៍ពិពាហ៍មួយថ្មីសន្លាងទើបនឹងឧប្បត្តិ កចេញមកនោះឡើយ។ ប៉ុន្តែ វាគឺជាប្រភេទអាពាហ៍ពិពាហ៍ច្នៃ ដោយយកអាពាហ៍ពិពាហ៍បែបបុរាណមកកែសម្រួល បង្រួម កាត់បន្ថយពេល កាត់បន្ថយពិធីមួយចំនួនធំ ហើយរក្សាទុកតែពិធីណា ដែលគេ យល់ថាមានលក្ខណៈសំខាន់ ចាំបាច់បំផុត ដូចជា ពិធីហែកំណត់ ពិធីកាត់សក់ ពិធីបង្វិលពពិល និង ពិធីសំពះផ្ទឹមចងដៃ រីឯពិធីកាត់នំ ពិធីដើរកម្សាន្តតាមសួនឧទ្យានជាពិធីថ្មី (មិនធ្លាប់មានកាលពីមុន) ។



www.elibraryofcambodia.org

លក្ខណៈពិសេសមួយទៀតដែលគួរឲ្យកត់សម្គាល់នោះគឺទាំងសម្លៀកបំពាក់កូនប្រុសស្រីពុំ មែនជាសម្លៀកបំពាក់បែបប្រពៃណីឡើយ ( ខោបារាំង អាវធំ រ៉ូប... ) ។

## ២.៣- អាពាហ៍ពិពាហ៍បែបលើកត្រៃ[35]

ពុទ្ធសាសនិកខ្មែរខ្លះ ដែលបានបដិបត្តិពុទ្ធសាសនារបស់ព្រះបរមគ្រូនៃយើងបានត្រឹមត្រូវ ហ្មត់ចត់នោះ យល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍ឲ្យកូនប្រុសស្រីគឺតែងតែមានកិច្ចផ្សេងៗ ប្រកបដោយ «មង្គល»[36]ទើបគេឲ្យឈ្មោះថា *មង្គលការ* ដែលនឹងនាំមកនូវសុខសិរីសួស្ដី។ អំពើដែលប្រកបដោយមង្គលនេះទាល់តែប្រាសចាកនូវបញ្ចវេរាទាំងប្រាំមានកូតករ លួចប្លន់ សម្លាប់ជីវិតគេ ផឹកគ្រឿងស្រវឹង លួចកូន ប្រពន្ធ ឬប្ដីគេជាដើម។ ផ្ដើមចេញពីទស្សនៈនេះ បុព្វបុរសខ្មែរបានបង្កើតទម្រង់អាពាហ៍ពិពាហ៍មួយដែលមានឈ្មោះថាៈ «អាពាហ៍ពិពាហ៍លើកត្រៃ» ។ កិច្ចផ្សេងៗនៃអាពាហ៍ពិពាហ៍នេះមានលក្ខណៈខុសប្លែកច្រើនពីអាពាហ៍ពិពាហ៍ឯទៀតៗ ព្រោះអាពាហ៍ពិពាហ៍នេះគេធ្វើតែកិច្ចជា មង្គល (ពិធីចម្រើនព្រះបរិត្ត ពុទ្ធជ័យមង្គល សម្ដែងធម៌ទេសនា រាប់បាត្រ ប្រគេនត្រៃចីវរ វេរ ភត្តាហារ ថ្វាយព្រះសង្ឃ ) ។

បច្ចុប្បន្ននេះគេកម្រឃើញប្រជាជនទាំងនៅទីក្រុង ទាំងនៅជនបទ រៀបចំចាត់ចែងធ្វើពិធី អាពាហ៍ពិពាហ៍ប្រភេទនេះណាស់ មកពីនៅក្នុងអាពាហ៍ពិពាហ៍នេះ ពុំមានការសប្បាយ ស៊ីផឹក រាំច្រៀងគគ្រឹកគគ្រេងឡើយ ។ ផ្ទុយទៅវិញ អាពាហ៍ពិពាហ៍នេះ

---

[35] ពិមានឈ្មោះដូច្នេះ ព្រោះអាពាហ៍ពិពាហ៍ប្រភេទនេះស្ទើរតែដូចគ្នានឹងពិធីបុណ្យមួយទៅហើយ អាចហៅថា បុណ្យផ្សំផ្គុំកូនប្រុសស្រីក៏បាន តែមហាជនទូទៅឲ្យឈ្មោះថា អាពាហ៍ពិពាហ៍លើកត្រៃនេះ ដោយហេតុថា ក្នុងពិធីនេះគេបានប្រគេនត្រៃចីវរចំពោះព្រះសង្ឃចំនួន ១ត្រៃ ។

[36] ក្នុងស្នាដៃ «ដំណើរវិវត្តនៃអាពាហ៍ពិពាហ៍ខ្មែរ» របស់ពួកគាត់ ក្រុមស្រាវជ្រាវដឹកនាំដោយសាស្ត្រាចារ្យ ឆយ យីហ៊ាង បានបញ្ជាក់ថា កិច្ចមង្គលក្នុងអាពាហ៍ពិពាហ៍រួមមាន ស្លាធម៌ប្ដឹងចាស់ស្រុក បាយព្រលឹង ផ្កាស្លា៣ ស្លកសំណែន ៤ បាយសី ៥ ថ្នាក់ អ្នកមហាអ្នកផ្លូវ ៦នាក់ អ្នកភ្លេង ៧ នាក់ និងប៉ីមានរន្ធ ៧ មានល្វែងផ្ទះ ៨ រៀបរៀងផ្លែឈើ មានប្រុស ៤នាក់ និង ស្រី ៥នាក់ ជាអ្នកបង្វិលពពិល។



www.elibraryofcambodia.org

មានតែព្រះសង្ឃឲ្យសីល សូត្រមន្ត ចម្រើនពរជ័យ ទ្រង់បិណ្ឌបាត ទេសនាទូន្មានសាមីកូនប្រុសស្រីអំពីសង្គហធម៌៥យ៉ាង[37] ដែលប្តី ប្រពន្ធត្រូវប្រតិបត្តិធ្វើតបចំពោះគ្នាទៅវិញទៅមក ។

## ២.៤- អាពាហ៍ពិពាហ៍បែបកំព្រាគូ

តាមធម្មតាអាពាហ៍ពិពាហ៍តែងមានគូបុរសស្ត្រី ទើបអាចរៀបចំជាអាពាហ៍-ពិពាហ៍បាន ។ ប៉ុន្តែ តើនៅក្នុងកាលៈទេសៈបែបណាដែលអាពាហ៍ពិពាហ៍ក្លាយជា *កំព្រាគូ* នោះ ? ហេតុអ្វីបានជាមាន អ្នកអវត្តមានក្នុងអាពាហ៍ពិពាហ៍របស់ខ្លួន ?

ហេតុផលរបស់វាស្ថិតនៅលើសាមីខ្លួនខាងកូនប្រុស(ភាគច្រើន)ដែលជាប់រវល់មិនអាចមកបាន ក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍(សង្គ្រាម) ឬក៏រស់នៅឯនាយសមុទ្រ។ អាពាហ៍ពិពាហ៍ប្រភេទនេះជាពិធីធ្វើឡើងដើម្បីបង្គ្រប់កិច្ច ហើយនឹងអាចទទួលការ-រិះគន់ពីអ្នកផង ។ កូនស្រីអាចតូចចិត្ត នឹងវាសនាដ៏អភ័ព្វរបស់ខ្លួន ដែលធ្លាក់ខ្លួនជានារីកំព្រាក្នុងអាពាហ៍ពិពាហ៍ ដែលមានតែម្តងក្នុងមួយជីវិត ។

---

[37] សង្គហធម៌៥យ៉ាងរបស់ប្តី សម្រាប់សង្គ្រោះភរិយា៖

១.សម្មាននាយៈស្រឡាញ់រាប់អានលើកមុខប្រពន្ធ
២.អវិមាននាយៈ មិនត្រូវមើលងាយប្រពន្ធទុកដូចទាសី
៣.អនតិចរិយាៈ មិនត្រូវក្បត់ចិត្តប្រពន្ធ
៤.ឥស្សរិយ វោស្សគ្គេនៈ ត្រូវប្រគល់កិច្ចការក្នុង ផ្ទះគ្រប់យ៉ាងឲ្យប្រពន្ធគ្រប់គ្រងចាត់ចែង
៥. អលង្ការានុប្បទានេនៈ ត្រូវតាក់តែងលម្អប្រពន្ធដោយគ្រឿងអលង្ការ ។

សង្គហធម៌៥យ៉ាងរបស់ភរិយា សម្រាប់សង្គ្រោះស្វាមី៖

១.សុសំវិហិតកម្មន្តាៈ ត្រូវចេះតាក់តែងភោជនាហារឲ្យមានឱជារសឆ្ងាញ់ ពិសាសម្រាប់ប្តី
២.សុសង្គហិត បរិជនាៈ ត្រូវរាប់អានសាច់ញាតិ មិត្តភក្តិ វង្សត្រកូលគ្រួសារខាងប្តីដូចខាងខ្លួន
៣.អនតិចារិនីៈ មិនត្រូវប្រព្រឹត្តក្បត់ចិត្តប្តី ដោយលួចស្នេហ៍ប្រុសដទៃឡើយ
៤.សម្ភតញ្ច អនុរក្ខតិៈ ត្រូវចេះមើលថែរក្សាទ្រព្យ ដែលប្តីរកបានមកឲ្យគង់វង្ស កុំចាយវាយខ្ជះខ្ជាយ
៥. ទក្ខាចហោតិ អនលសា សព្វកិច្ចេសុៈ ត្រូវឈ្លាសវៃក្នុងការគ្រប់គ្រងផ្ទះ មិនខ្ជិលច្រអូសគ្រប់កិច្ចការ ។



www.elibraryofcambodia.org

## ២.៥- អាពាហ៍ពិពាហ៍បែបសែន

អាពាហ៍ពិពាហ៍បែបសែននេះ កើតមានឡើងដោយមូលហេតុច្រើនប្រការដូចខាងក្រោម៖

- ឪពុកម្តាយកូនប្រុសកូនស្រីជាអ្នកក្រកម្សត់ទុគ៌តពុំអាចមានលទ្ធភាពរៀបការធំដុំពេញលេញបាន។
- កម្លោះក្រមុំដែលបានស្រឡាញ់គ្នាលួចលាក់មុនឪពុកម្តាយទុកដាក់ បានពង្រត់គ្នាចាកចេញពីគ្រួសារមួយរយៈ ទើបម៉ែឪទាំងសងខាងហៅមករៀបចំ សែនព្រេនបង្គ្រប់កិច្ច ដើម្បីជម្រាបព្រលឹងជីដូនជីតា មេបាចាស់ទុំឲ្យបានដឹង និងមិនប្រកាន់ តែប៉ុណ្ណោះ ។
- ជាជនពោះម៉ាយ និងមេម៉ាយវ័យចំណាស់ ស្រឡាញ់គ្នាចង់បានគ្នាធ្វើជាប្តីប្រពន្ធ តែមាន ជីវភាពខ្វះខាត ក៏បានត្រឹមតែរៀបការដោយសែនព្រេនតែប៉ុណ្ណោះ ។
- ជាស្ត្រីប្រពន្ធចុង បានលបលួចស្រឡាញ់ប្តីគេ ត្រូវធ្វើពិធីសែនផ្តាច់ខ្មោចដោយស្ងាត់ៗ ដើម្បីកុំឲ្យភ្ញាក់ផ្អើលដល់ប្រពន្ធដើម ឬកុំឲ្យគេដឹងឮច្រើនគ្នា ។

## ២.៦- អាពាហ៍ពិពាហ៍បែបផ្តាច់ការ សមូហភាព

នៅក្នុងសម័យដែលប្រទេសកម្ពុជាធ្លាក់ក្នុងរណ្តៅខ្មៅងងឹតនៃប្រវត្តិសាស្ត្រព្រមជាមួយនឹងវិស័យផ្សេងៗឯទៀតនោះ វិស័យសង្គមវប្បធម៌បានរងនូវការកម្ទេចចោលយ៉ាងសាហាវព្រៃផ្សៃបំផុត ក្នុងនោះមាន សាសនា សិល្បៈ និងវប្បធម៌ប្រពៃណីទំនៀមទម្លាប់ជាដើម ។ ក្នុងពេលនេះ យើងសូមលើកមកនិយាយតែអាពាហ៍ពិពាហ៍ដែលរបបកម្ពុជាប្រជាធិបតេយ្យបានអនុវត្តតែប៉ុណ្ណោះ។ តាមការស្រាវជ្រាវរបស់ឯកសារនានាគួបផ្សំនឹងការបានឆ្លងកាត់របស់យើង អាពាហ៍ពិពាហ៍ក្នុងសម័យនោះមានតែអង្គការ[38]ទេដែលមានសិទ្ធិគិតគូររៀបចំផ្សំផ្គុំយុវជន យុវនារី រីឯ ឪពុកម្តាយ

[38] ប្រធានក្រុម មេភូមិ ប្រធានកង ប្រធានសហករណ៍ គណៈឃុំ គណៈស្រុក គណៈខេត្ត គណៈតំបន់ គណៈមជ្ឈិម...ទាំងអស់នេះរួមមកហៅថា «អង្គការ» ដ៏មហាអស្ចារ្យនោះ ។



www.elibraryofcambodia.org

បង្កើត និងសាមីខ្លួនពុំមានសិទ្ធិអ្វីបន្តិចទាល់តែសោះ។ ប្រសិនអង្គការត្រូវការរៀបចំផ្សំផ្គុំយុវជនណាជាមួយ យុវនារីណានោះ គេពុំបានប្រាប់ឲ្យសាមីជនដឹងខ្លួនមុនទេ ។ ខ្លាំងជាងនេះទៅទៀត ទោះបីសាមីខ្លួនណាមួយមិនពេញចិត្តនឹងគូរបស់ខ្លួនក៏ដោយ ក៏ពួកគេគ្មានសិទ្ធិនឹងប្រកែកដែរ ។ ចង់ឬមិនចង់គេ ត្រូវតែយល់ព្រមតាមផែនការរបស់អង្គការ ប្រសិនបើមានភាគីណាមួយហ៊ានប្រកែកនោះ អង្គការ ឃោរឃៅនឹងដឹងថាត្រូវចាត់ការយ៉ាងណាៗនោះហើយ។

ដំណើរប្រព្រឹត្តទៅនៃអាពាហ៍ពិពាហ៍ផ្តាច់ការសមូហភាពនេះមានភាពសោះក-ក្រោះ ស្ងាត់ជ្រងំ គ្មានភ្លេង គ្មានពិធីជប់លៀង គ្មានអាចារ្យ គ្មានមហា មេបា ដូចដែលយើងធ្លាប់ឃើញនៅក្នុង អាពាហ៍-ពិពាហ៍តាមប្រពៃណីខ្មែរយើងទាល់តែសោះ។



តៀប



ស្លាពាន់ម្លូពាន់



www.elibraryofcambodia.org



ផ្តិលទឹកសំបួរ



ឃ្មោះ



បង់រង



www.elibraryofcambodia.org



ពពិល និង ទៀន



ពពិល ដែលមានរូប



www.elibraryofcambodia.org

៧

# ប្រពៃណីពេលមានមនុស្សស្លាប់

គ្រប់ជនជាតិទាំងអស់លើលោកនេះ តែងតែមានប្រពៃណីរៀងៗខ្លួនដើម្បីរៀបចំពិធីធ្វើបុណ្យ សពឬហៅម្យ៉ាងទៀតថាពិធីជូនដំណើរខ្មោច ។ ដូចគ្នានេះដែរ ចំពោះជនជាតិខ្មែរយើង ពិធីបុណ្យ ខ្មោចជាកាតព្វកិច្ចមួយមិនអាចខ្វះបានចំពោះគ្រួសារនីមួយៗ មិនថានៅជនបទឬនៅទីក្រុងឡើយ។ ទាក់ទងនឹងការស្លាប់របស់មនុស្ស សង្គមខ្មែរយើងបានកំណត់ហៅ៖

- *កាលមរណៈ* សម្រាប់ហៅការស្លាប់ទាំងឡាយណាស្របតាមពេលវេលានៃវ័យវឌ្ឍនាការរបស់មនុស្ស ពោលគឺស្លាប់ដោយជំងឺចាស់ជរា ជំងឺព្យាបាលពុំជា ដូច្នេះហើយ ញាតិមិត្តអាចប្រុងប្រៀបរៀបចំកិច្ច (ការធ្វើបុណ្យជូន ឬ ការឲ្យធម៌) ជាមុនតាមទំនៀមទម្លាប់របស់គេ។
- *អកាលមរណៈ* សម្រាប់ហៅការស្លាប់ដោយចៃដន្យ បន្ទាន់ ដោយញាតិមិត្តពុំអាចរៀបចំកិច្ចតាមទំនៀមទម្លាប់បាន។ ខ្មោចដែលស្លាប់តាមរបៀប អកាលមរណៈនេះ គេនិយមហៅថា «ខ្មោចតៃហោង»។ តាមទំនៀមបុរាណ ខ្មោចរបៀបនេះ គេមិនយកទៅបូជាទេ គឺគេយកទៅកប់សិន ហើយរង់ចាំពេលវេលាល្អ ទើបគេគាស់យកឆ្អឹងមកបូជាវិញ។

ការរំលាយសពមនុស្សក្នុងលោកមាន ៤ យ៉ាងគឺ៖

- បូជាដោយព្រះអគ្គី
- កប់ទុកក្នុងព្រះធរណី
- បណ្តែតចោលក្នុងស្ទឹងសក្តិសិទ្ធិ
- យកទៅចោលក្នុងព្រៃស្មសាន។


www.elibraryofcambodia.org

ក្នុងពេលនេះ យើងសូមលើកយកតែផ្នែក «បូជាដោយព្រះអគ្គី» មករៀបរាប់តែប៉ុណ្ណោះ។ កាលជំនាន់បុរេប្រវត្តិ ខ្មែរពុំបូជាសពឡើយ គឺកប់សពទាំងមូលនៅក្នុងដីដោយមានសំណែនផ្សេងៗ ភ្ជាប់ជាមួយ។[39] អ្នកកាន់ព្រះពុទ្ធសាសនានិយមបូជាសពដោយព្រះអគ្គី ព្រោះព្រះពុទ្ធក៏ព្រះអង្គបូជាព្រះភ្លើងដែរ។ ដោយសារឥទ្ធិពលសាសនានេះហើយ ទើបជនជាតិខ្មែរផ្លាស់ប្តូរមកបូជាវិញ។[40]

យើងនឹងបែងចែកការរៀបចំកិច្ចសម្រាប់ការស្លាប់ជា ៥ ដំណាក់កាលគឺ៖

១- ពេលឈឺធ្ងន់

២- ពេលស្លាប់

៣- ពេលហែសពទៅបូជា

៤- ពេលបូជាសព

៥- ពេលក្រោយបូជាសពរួច

**១- ពេលឈឺធ្ងន់**

នៅសម័យបុរាណក្តី សម័យបច្ចុប្បន្នក្តី កាលបើមានលោកអ្នកដ៏មានគុណណាមួយ មានមាតា បិតាជាដើម កំពុងមានជំងឺធ្ងន់ដោយរោគាពាធណាមួយ គេនាំគ្នាស្វះស្វែងរកគ្រូពេទ្យមកជួយព្យាបាលសព្វបែបយ៉ាង។ កាលបើពិនិត្យទៅឃើញថាអស់លទ្ធភាពហើយ កូនចៅត្រូវដឹកជញ្ជូនគាត់ មកផ្ទះសម្បែង ដើម្បីរៀបចំធ្វើបុណ្យជូនគាត់ (បង្សុកូល បច្ច័យបួន) ជាដើម ។ ក្រុមគ្រួសារអ្នកជំងឺ ត្រូវរកអាចារ្យឲ្យមកប្រចាំការជួយចាត់ចែងត្រៀមធ្វើ *ទៀនកល្ប, ស្លាធ្មៃយ, ទង់ព្រលឹង, ស្រូវគៀសជើងត្បូង, ជណ្តើរកាំបី,* និង *តាំងព្រះបត់* ជាដើម ។ រៀងរាល់រាត្រីក្រុមគ្រួសារតែងនិមន្តព្រះសង្ឃមកឲ្យធម៌ ដល់អ្នកជំងឺ និងសូត្រធម៌សង្វេគដូចជា ព្រះអាការវតាសូត្រ ឬ គិរីមានន្ទសូត្រ ។

**២- ពេលស្លាប់**

ដល់ពេលដាច់ខ្យល់ស្លាប់ អាចារ្យយកទង់ព្រលឹងដាក់ពីខាងលើក្បាលដំណេក

---

[39] អាំង ជូលាន៖ *ដំណើរជីវិតមនុស្សខ្មែរ មើលតាមពិធីឆ្លងវ័យ* ឆ្នាំ២០០៧ ទំព័រ៧៣

[40] ដដែល, ទំព័រ៧៣



www.elibraryofcambodia.org

សព បន្តខ្សែអំបោះពីទង់ព្រលឹងនោះទៅនឹងព្រះពុទ្ធរូបឬបបុឡាមណើរចេតិយ ដុត ទៀនកល្ប ៥ ដើម[41] (ដាក់ក្បែរក្បាលសព១ ទន្ទឹមស្មាសងខាង២ ចុងជើងសងខាង ២) រៀបស្រូវគៀសជើងត្បូងមួយល្អីតូច ដាក់ចុងជើងសព និង រៀបគ្រឿងបន្តុង[42] ជាដើម។ គេដោតទង់ក្រពើមួយឬពីរនៅពីមុខផ្ទះ និង បន្លឺ សម្លេងគង (ដោយមានភ្លេងពិណពាទ្យលេងកំដរពិធីផង) ជាសញ្ញាថាមានមនុស្សស្លាប់។

មុននឹងដាក់សពចូលក្នុងមឈូស កូនចៅលើកសពទៅចំអាសទឹក តែងខ្លួនសិតសក់ លាបម្សៅ លាបទឹកអប់ ស្លៀកពាក់សម្លៀកបំពាក់ណាដែលគាត់ចូលចិត្ត និងយកដៃទាំងពីររបស់សព ផ្គោបផ្គុំលើដើមទ្រូង ដោយដាក់ផ្កា ទៀន និងធូបក្នុងដៃ។ អាចារ្យយោគី យកខ្សែបាសមកចងត្រង់ក របស់សពមួយកន្លែង ក-ដៃមួយកន្លែង និង ក-ជើង មួយកន្លែង រួចយកប្រាក់១កាក់ ឬមាសបង់ក្នុង មាត់ ។ រុំសពនឹងកំណាត់ស ១២ហត្ថ និង ចងខ្សែបាសសាជាថ្មី ទើបយកកំណាត់សមួយចំអាមបូនជ្រុង គ្របមុខ ហើយលើកសពដាក់ចូលក្នុងក្តារមឈូស រួចដាក់តម្កល់ក្នុងទីដ៏សមគួរ ។ ការតម្កល់សពទុកយូរឬឆាប់ អាស្រ័យទៅលើលទ្ធភាពរបស់គ្រួសារនៃសព ។

ក្នុងរយៈពេលតម្កល់សពនេះ ពេលព្រឹក គ្រួសារសពនិមន្តព្រះសង្ឃមកបង្សុកូលសូត្រនូវ ព្រះអភិធម្ម និង ព្រះសហស្សន័យ ព្រមទាំងវេរភត្តហារ។ ពេលរសៀល គេនិមន្តព្រះសង្ឃចម្រើន ព្រះបរិត្ត និងសំដែងធម្មទេសនា ។

**៣- ពេលហែសពទៅបូជា**

ដល់ពេលហែសពទៅកាន់ឈាបនដ្ឋាន គេនិយមរៀបក្បួនយ៉ាងនេះ[43]៖

[41] កាលបើបុគ្គលឈឺធ្ងន់មានកម្លាំងតិចណាស់ហើយ លោកអាចារ្យហៅកូនប្រពន្ធ ឬប្តីនិងក្រុមញាតិនាំគ្នាអុជទៀនកល្បទាំង ៥ គឺព្រះបីតិទាំង៥ ជាចំណាំងស្មើព្រះពុទ្ធ៥ព្រះអង្គក្នុងភទ្ទកប្បនេះ ។ (សូមអាន លី សុវីរៈ *ពិធីបុណ្យខ្មោច សតវត្សទី ១៩ និងដើមសតវត្សទី២០* ការផ្សាយរបស់អ្នកនិពន្ធ, ឆ្នាំ១៩៩៤ ទំព័រ១១ ។)

[42] គ្រឿងបន្តុងគឺជាប្រដាប់ប្រដាដែលគាត់ធ្លាប់ប្រើប្រាស់ និងស្រឡាញ់ មានដូចជាចាន ផ្តាំងស្លាបព្រា កាំបិត អង្ករ ត្រីងៀត ប្រហុក ផ្អក...។



www.elibraryofcambodia.org

- ព្រះសង្ឃ(មានព្រះអភិធម្មនិងព្រះមាតិកា)និមន្តខាងមុខ
- អាចារ្យយោគីកាន់ទង់ព្រលឹង
- វង់ភ្លេងភ្លងខែកឬវង់ភ្លេងពិណពាទ្យ
- អ្នកប្រាយលាជស្លៀកពាក់ស
- អ្នកបួសមុខភ្លើងស្លៀកស ពានាស ចងក្បាលនឹងស្បូវភ្លាំងតភ្ជាប់ទៅនឹងមឈូសសព
- អ្នកទូលទៀនត្បូង
- កូនចៅ ព្រមទាំងញាតិមិត្រ កាន់ផ្កាចងភ្ជាប់ជាមួយធូបនិងទៀន ដើរជាជួរតាមពីខាងក្រោយ។

ក្បួនហែសពប្រព្រឹត្តទៅក្នុងដំណើរយឺតៗនិងមានរបៀបរៀបរយល្អ។ អ្នកដើរដង្ហែមានមុខឱនចុះក្នុងឥរិយាបថកាន់ទុក្ខ ស្រគត់ស្រគំ និងស្ងៀមស្ងាត់ផ្ទៀងស្ដាប់ព្រះសង្ឃសូត្រព្រះអភិធម្មមាតិកា និងព្រះសុត្តន្តមាតិកា។ លុះក្បួនបានដល់កន្លែងបូជាហើយ អ្នកពួកលើកមឈូសសពហែបែបឧត្តរាព័ត៌ជុំវិញឈាបនដ្ឋាន ៣ ជុំ ទើបយកទៅតម្កល់លើជើងថ្ករ ដោយដាក់ក្បាលទៅទិសខាងលិច។ អាចារ្យបើកគម្របមឈូស ស្រាយស្នបរួចលើកកំណាត់គ្របមុខ កាត់ខ្សែបាស រួចអញ្ជើញអ្នកតំណាងគ្រួសារសពឡើងថ្លែងវិយោគកថា រៀបរាប់អំពីជីវប្រវត្តិ និង គុណសម្បត្តិរបស់សពព្រមទាំងនិមន្តព្រះសង្ឃបង្សុកូល។ អាចារ្យប្រកាសថា៖ «នេះជានាទីចុងក្រោយបង្អស់ហើយដែលយើងទាំងអស់គ្នា ជាកូនជាចៅនិងញាតិមិត្តបានឃើញមុខបុគ្គល...» ហើយក៏អញ្ជើញកូនចៅ ព្រមទាំងញាតិមិត្ត ដែលមកជួយគាំទ្រក្នុងពិធីបុណ្យនេះឲ្យចូលទៅមើលមុខ ធ្វើគារវកិច្ចគោរព និងសុំខមាលទោសដែល បានប្រព្រឹត្តផ្ដាំឆ្គងដោយកាយ

---

[43] សព្វថ្ងៃ មានការរៀបចំក្បួនហែប្លែកពីសម័យបុរាណបន្តិចដូចជា៖ ១- អ្នកកាន់កម្រងផ្កា ២-បើមានក្មេងៗ(សិស្ស) ដើរជាក្បួនបន្តក្រោយពីអ្នកកាន់កម្រងផ្កា ៣-លោកអភិធម្ម ៤- អ្នកទូលស្បូវភ្លាំង



www.elibraryofcambodia.org

វាថា ចិត្ត តាំងពីកាលដែលលោកនៅរស់ ដោយយកផ្កានិង ទៀនធូប ដាក់ពីលើសព និងបង្អោនកាយសំពះលា ។

### ៤- ពេលបូជាសព

ពេលបូជាអាចារ្យបង្គាប់ឲ្យកូនចៅឬសាច់សារលោហិតអុជទៀនឬចន្លុះចូល ជើងថ្ករក៏បាន ឲ្យ អ្នកភ្លុកទាំងបួនអុជទៀនឬចន្លុះមួយម្នាក់ដើរប្រទក្សិណ៣ជុំមឈូស រួចចូលជើងថ្ករក៏បាន (បើបញ្ចុះ វិញ អាចារ្យបង្គាប់ឲ្យកូនចៅឬសាច់សារលោហិតបន្ធូរ ខ្សែរ៉តទម្លាក់មឈូសចុះក្នុងរណ្ដៅ) ។ ពេលកំពុងបូជា(ឬបញ្ចុះសព)នោះ អាចារ្យ និមន្តព្រះសង្ឃបំបួសកុលបុត្រម្នាក់ដែលបម្រុងបួស ហៅថា «បួសមុខភ្លើង» ព្រមទាំង មានទេសនាសង្ខេបក្នុងពេលនោះផង ដែលគេហៅថា «ទេសនាមុខភ្លើង» ។ អ្នកបួស មុខភ្លើងនោះអាចនឹងសឹកវិញនៅពេលចប់ពិធីបុណ្យសពឬក៏ស្នាក់នៅវត្តចំនួនពីរ ឬ បីថ្ងៃ ឬ មួយអាទិត្យតាមការចូលចិត្ត ។ កាលណាសពឆេះសុសហើយ អាចារ្យយោគី យកទឹកសំបួរមាសមួយផ្តិល និងអ្នកភ្លុក ៤ នាក់ កាន់ក្អមមានទឹកពេញម្នាក់មួយដើរព័ទ្ធ ៣ ជុំ ទើបស្រោចទឹកលត់ភ្លើង ។ លុះភ្លើងរលត់ហើយ អាចារ្យក៏ចាប់ធ្វើពិធីប្រែរូប ដោយមាន និមន្តព្រះសង្ឃបង្សុកូលផង ។

ក្រុមគ្រួសារនៃសពនាំគ្នារើសឆ្អឹងយកមកដាក់កញ្ច្រែងលាងទឹកម្ទេស ទឹកសំបួរ និង ទឹកដូងខ្ចី ។ ពេលរើសឆ្អឹងនោះ បើកូនចៅណារើសបានប្រាក់កាក់ ឬធ្មេញ គេចាត់ ទុកថាជាអំណោយចុងក្រោយរបស់សព ដែលត្រូវរក្សាទុកធ្វើជាកេរតរៀងទៅ។ គេ និយមយកធ្មេញទៅឆ្លាក់ជាព្រះពុទ្ធរូបស្រោបមាស ធ្វើបន្តោងខ្សែកពាក់។ ធាតុដែល លាងស្អាត គេយកទៅដាក់ក្នុងកោដ្ឋ រួចយកទៅតម្កល់ពីមុខ អាសនៈព្រះពុទ្ធរូប ។

យប់នៃថ្ងៃបូជា ឬបញ្ចុះសពមានប្រារព្ធពិធីសូត្រមន្ត ចម្រើនព្រះបរិត្ត និង សំដែង ធម្មទេសនាផង ។ លុះព្រឹកឡើងប្រគេនយាគូ និងថ្ងៃត្រង់វេរភត្តប្រគេនព្រះសង្ឃ ជាកិច្ច បង្ហើយបុណ្យ ។ ដើម្បីតបស្នងសងគុណដល់បុព្វការីជនកូនចៅរួបរួមគ្នាធ្វើពិធីបុណ្យ ទក្ខិណានុប្បទានតាមទំនៀម ព្រះពុទ្ធសាសនាគម្រប់ ៧ ថ្ងៃ ១០០ ថ្ងៃ និង បុណ្យខួប តាមលទ្ធភាពដែលអាចធ្វើទៅបាន ជាបន្ត បន្ទាប់ទៀត ។



www.elibraryofcambodia.org

## ៥- ទក្ខិណានុប្បទានកម្ម

### ៥.១- បុណ្យ៧ថ្ងៃ

មនុស្សពីសម័យបុរាណ គេតែងនាំគ្នាជឿថា មនុស្សស្លាប់ទៅក្នុងរយៈពេលពី ១ ថ្ងៃ រហូតដល់ ថ្ងៃទី ៦ មិនទាន់បានដឹងខ្លួនថាស្លាប់ទេ ។ ការធ្វើអ្វីៗឲ្យក៏ដោយ ក៏ខ្លួនមិនបានដឹងឡើយ។ លុះដល់ ថ្ងៃទី៧ ទើបដឹងថាខ្លួនស្លាប់។ ម្យ៉ាងទៀតបុណ្យនេះជាបុណ្យធ្វើតាមប្រពៃណីពីបុរាណដែលមាន តាំងពីសម័យពុទ្ធកាលមកម្ល៉េះ។[44]

ក្នុងសម័យពុទ្ធកាល ព្រះបាទបសេនទិកោសលទ្រង់បានបំពេញបុណ្យនេះរួចមកហើយ ដូចមានសេចក្តីដំណាលថា៖ «ព្រះបាទបសេនទិកោសល បរមក្សត្រ ទ្រង់សោយរាជសម្បត្តិនៅកោសលរដ្ឋ។ ព្រះអង្គមានព្រះអគ្គមហេសីព្រះនាមមល្លិកាទេវី ព្រះនាងទ្រង់ជាទីស្រឡាញ់ពេញព្រះទ័យនៃព្រះបាទបសេនទិកោសលយ៉ាងខ្លាំង ។ កាលព្រះនាងមល្លិកាទេវី ទ្រង់ទិវង្គតទៅ ក៏បានទៅកើតសោយទុក្ខនៅក្នុងឋាននរកអស់រយៈពេល ៧ ថ្ងៃ ព្រោះមកពីនាងបានពោលពាក្យកុហកព្រះស្វាមី។ លុះព្រះនាងសោយទុក្ខក្នុងឋាននរកអស់រយៈពេល ៧ ថ្ងៃហើយ ក៏បានទៅកើតសោយសុខឯក្នុងស្ថានសួគ៌វិញ ព្រោះបុញ្ញកម្មដែលព្រះនាងបានកសាងសន្សំមកពីកាលមុន។

ការធ្វើបុណ្យ៧ថ្ងៃនេះ គេមានទិញប្រដាប់ប្រដាឬជាក់វត្ថុដែលមានស្រាប់ធ្វើបន្ទុងម្តងទៀតក៏មានឬធ្វើត្រឹមតែបច្ច័យ៤[45] ប្រគេនព្រះសង្ឃក៏មាន។

### ៥.២- បុណ្យ ១០០ ថ្ងៃ

ពិធីធ្វើបុណ្យ ១០០ ថ្ងៃនេះ មិនមានលក្ខណៈអ្វីប្លែកពីបុណ្យ ៧ ថ្ងៃប៉ុន្មានទេ។ ការប្រារព្ធពិធី បុណ្យនេះបានបង្ហាញពីសទ្ធាជ្រះថ្លាខ្លាំងរបស់កូនចៅ និងឧទ្ទិសជូនវិញ្ញាណក្ខន្ធសព ឲ្យទៅកើតឯ សុគតិភព។ ពិធីធ្វើបុណ្យ១០០ថ្ងៃរបស់ខ្មែរគ្មានថ្ងៃខួបឬ

---

[44] ចឹង ផាន់សុផុន៖ *បុណ្យទំនៀមខ្មែរ*, ផ្សាយចេញពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ, ឆ្នាំ២០០០, ទំព័រ៤៨១

[45] បច្ច័យបួនឬចតុប្បច្ច័យ (គ្រឿងសម្រាប់អាស្រ័យ៤យ៉ាងរបស់ព្រះសង្ឃរួមមាន)៖ ចីវរ បិណ្ឌបាត សេនាសនៈនិង គិលានភេសជ្ជៈ។


www.elibraryofcambodia.org

ថ្ងៃលើសដូចប្រពៃណីចិនឡើយគឺឲ្យតែគ្រប់ ១០០ ថ្ងៃ គេចាប់ធ្វើបុណ្យតែម្តង។

**៥.៣- បុណ្យខួប (គម្រប់បាន១ឆ្នាំ និង ឆ្នាំបន្តបន្ទាប់)**

ពិធីធ្វើបុណ្យខួបនេះ គឺជាពិធីមួយដែលត្រូវកូនចៅប្រជុំគ្នាធ្វើបុណ្យឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធលោកអ្នកដ៏មានគុណផង ជាថ្ងៃប្រជុំរំលឹកប្រាប់គ្នាថា ពេលស្មើនេះ ថ្ងៃនេះ ខែនេះ ឆ្នាំនេះ ដែលម្ដាយឬជីដូនឬឪពុក ជីតារបស់យើងគាត់ស្លាប់ផង។ មិនត្រឹមតែកូនចៅទេ សូម្បីអ្នកដទៃក៏អាចឮ ហើយចាំថ្ងៃខែនិងឆ្នាំដែលគាត់ស្លាប់នោះទៀតផង។ ដូច្នេះ កូនចៅខ្មែរគ្រប់រូប គេតែងនាំគ្នាធ្វើបែប នេះជារៀងរហូត តកូន តចៅជាលំដាប់។

**៦- អត្ថន័យខ្លះៗរបស់កិច្ចក្នុងពិធីបុណ្យសពខ្មែរ**[46]

ប្រពៃណីបុណ្យសពខ្មែរមានការរៀបចំជាច្រើនពិធី ដែលពិធីនីមួយៗសុទ្ធតែបង្កប់នូវខ្លឹមសារ ដ៏ជ្រាលជ្រៅដែលតម្រូវឲ្យយើងសិក្សាយល់ដឹងខ្លះៗដូចជា៖

**៦.១- ពិធីសណ្ដោងស្បូវភ្លាំង**

ពិធីនេះមានន័យសំខាន់ទាក់ទងទៅនឹងព្រះពុទ្ធសាសនា។ មនុស្សម្នាក់ពាក់កម្រងស្បូវភ្លាំងនោះទុកជាប្រតិភូជំនួសមនុស្សសត្វទាំងអស់ ដែលកើតនៅក្នុងវដ្ដសង្សារនេះ។ ឯកម្រងស្បូវភ្លាំងគឺ កិលេសតណ្ហាដែលឲ្យមានជាតិ ជរា ព្យាធិ មរណៈចងទ្វាក់គ្រប់ក្បាលមនុស្សសត្វទាំងអស់។ ពិធី សណ្ដោងស្បូវភ្លាំងនេះក៏ជាកិច្ចសំខាន់មួយសម្រាប់ពិចារណាឲ្យកើតធម៌សង្វេគដែរ។

**៦.២- ពិធីព្រាយលាជ**

លាជដែលគេបាចរាត់រាយ ព្រោងព្រាតទៅលើពសុធាជាភ័ស្តុតាងឲ្យឃើញច្បាស់នឹងភ្នែកថា៖ «សក់ រោម សាច់ ស្បែក ឆ្អឹង»របស់មនុស្សសត្វគ្រប់រូបដែលកើតស្លាប់ៗក្នុងវដ្ដសង្សារនេះ តែងតែបោលរាត់រាយនៅលើផែនដី ដូចជាលាជអញ្ចឹង។

**៦.៣- ពិធីកៀសចិញ្ចៀនត្បូង**

ន័យពិសេសរបស់ពិធីនេះគឺគេចង់ប្រៀបថា «ភ្លើង» ដែលឆេះភ្លឺបភ្លែតៗនោះជា

---

[46] ព្រះគ្រូធម្មាចារ្យ ចក់ កន៖ *នានាធម្មសង្គហៈ* ទំព័រ២២ ២៣ ២៤ និង២៥



www.elibraryofcambodia.org

ជីវិតរស់នៅ។ « ប្រឆេះ» ជារូបកាយ «ប្រេង» ជាអាយុសង្ខារ។ ការប្រៀបប្រដូចបែបនេះសម្រាប់ឲ្យយើងពិចារណា ថា៖ «បើប្រេងអស់ហើយ ភ្លើងត្រូវរលត់ ប្រឆេះក៏ជារបស់ឥតប្រយោជន៍មិនអាចធ្វើភ្លើងឲ្យឆេះវិញ បាន»។ ឯមនុស្សសត្វទាំងឡាយក៏ដូច្នោះដែរ បើអាយុសង្ខារអស់ហើយត្រូវតែស្លាប់ មិនអាចមានជីវិតរស់នៅបាន រូបរាងកាយក៏ជារបស់ឥតប្រយោជន៍ប្រើការមិនកើត។

### ៦.៤- ពិធីបួសមុខភ្លើង

ការបួសនេះអាចពន្យល់បញ្ជាក់ថា មានតែភេទជាអ្នកបួសប៉ុណ្ណោះដែលអាចកាត់ផ្តាច់នូវ ចំណងស្នេហ៍ខ្លាំងដែលជាកិលេសតណ្ហាដែលចងធ្លាក់ភ្ជាប់នឹងក្បាលសត្វលោកគ្រប់រូប។

### ៦.៥- ពិធីប្រែរូប

ពិធីនេះបានបញ្ជាក់ឲ្យដឹងថា រូបកាយយើងទាំងអស់គ្នា ពេលដែលវិញ្ញាណចេញហើយ រូបកាយនោះនឹងពុកផុយរលួយទៅជាធាតុទាំងបួន(ទឹក ដី ភ្លើង ខ្យល់) មិនអាចពូតផ្គុំផ្សំផ្គុំ ឬជបឲ្យកើត រូបដូចដើមវិញបានទេ។ ដូច្នេះអ្នកទាំងឡាយ កុំសោយសោក អាលោះអាល័យនឹងរូបកាយឲ្យ សោះ។

៨

## ប្រពៃណីបុណ្យមាឃបូជា

*មាឃ* គឺជាឈ្មោះខែមួយក្នុងចន្ទគតិ គឺខែមាឃ។ ឯពាក្យ *បូជា* ប្រែថា ការថ្វាយ ការប្រគេន ការជូន ឬ ការប្រតិបត្តិតាម។

រួមពាក្យទាំងពីរពាក្យមក *មាឃបូជា* ប្រែថា *ការបូជាក្នុងខែមាឃ*។ ពុទ្ធសាសនិកក្នុងលោក ជាពិសេស ពុទ្ធសាសនិកខ្មែរ បានធ្វើបុណ្យមាឃបូជានៅថ្ងៃទី ១៥ កើត


www.elibraryofcambodia.org

ក្នុងខែមាឃនេះ ដោយប្រារព្ធ បុព្វហេតុពីរ ប្រការគឺ ១) *ព្រះពុទ្ធសំដែងឱវាទបាតិមោក្ខ* និង *២) ព្រះអង្គដាក់ជន្មាយុសង្ខារ*។

- **បុព្វហេតុទី១៖** ការប្រជុំសម្តែងឱវាទបាតិមោក្ខហៅថាចាតុរង្គសន្និបាត ប្រែថា ការប្រជុំប្រកបដោយអង្គ ៤ គឺ៖

ក- ថ្ងៃនោះជាថ្ងៃ ១៥កើត ខែមាឃ

ខ- ព្រះអរហន្តចំនួន ១២៥០អង្គ និមន្តមកជួបជុំគ្នា នៅវត្តវេឡុវ័នក្រុងរាជគ្រឹះ ដោយឥតបានណាត់គ្នាជាមុនឡើយ។

គ- ព្រះអរហន្តទាំងនោះសុទ្ធតែបានសម្រេចបដិសម្ភិទាញាណ (កន្លែងខ្លះថា បានសេម្រចអភិញ្ញាណ៦)។

*បដិសម្ភិទាញាណ* មាន ៤ គឺ ៖

១- ធម្មប្បដិសម្ភិញាណ ប្រាជ្ញាយល់ធម៌

២- អត្ថាប្បដិសម្ភិទាៈ យល់សេចក្តីរបស់ធម៌

៣- បដិភាណបដិសម្ភិទាៈ ឈ្លាសវៃក្នុងការសំដែងធម៌

៤- និរុត្តិបដិសម្ភិទាៈ ឈ្លាសវៃធម៌ ក្នុងការប្រើភាសា ឬប្រើពាក្យ។

ឃ- ជាភិក្ខុបានបួសក្នុងសំណាក់ព្រះពុទ្ធ។

- **បុព្វហេតុទី ២៖** កាលខែមាឃនោះ ព្រះអង្គដាក់ជន្មាយុសង្ខារថា នៅតែបី ខែទៀតទេ (ខែពិសាខ) ព្រះអង្គនឹងរំលត់ខន្ធចូលបរិនិព្វានហើយ។

បុព្វហេតុទាំងពីរនេះកើតឡើងនៅថ្ងៃ ១៥ កើត ខែ មាឃ ដូចគ្នា។

ពុទ្ធបរិស័ទប្រារព្ធធ្វើបុណ្យមាឃបូជានេះ ដើម្បីរំលឹកដល់ព្រឹត្តិការណ៍ដែលកើតឡើងក្នុងសម័យពុទ្ធកាលទាំងពីរនេះ និង ដើម្បីជាការគោរពគុណព្រះពុទ្ធដែលកើតមានចំពោះសព្វសត្វ។

*បូជា* មានពីរបែបគឺ *សក្ការបូជា* និង *បដិបត្តិបូជា* ។ សក្ការបូជា គឺការបូជាដោយគ្រឿងសក្ការៈ ទាំងឡាយ មានទៀន ផ្កា ជាដើម ។ ការបូជានេះចាត់ថា បានបុណ្យ



www.elibraryofcambodia.org

បានកុសលមួយផ្នែកហើយ ប៉ុន្តែ ព្រះពុទ្ធសម្ដែងថា ការបូជា ឬ ការគោរពចំពោះព្រះពុទ្ធ ដ៏សំខាន់បំផុតគឺ **ការប្រតិបត្តិតាមធម៌** របស់ ព្រះអង្គ។ ព្រះពុទ្ធមានដីការថា៖ *"អ្នកឯណាមួយជា អ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដ៏ត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ ជាប្រក្រតី អ្នកនោះរាប់ថាធ្វើសក្ការៈ ធ្វើសេចក្ដីរាប់អាន បូជាព្រះតថាគតដោយបដិបត្តិបូជា* ***បូជាដ៏ឧត្តម*** *"*

មុនព្រះពុទ្ធចូលបរិនិព្វាន ភិក្ខុទាំងឡាយដែលកំពុងគង់នៅជិតនោះលុះបានជ្រាបថា ព្រះអង្គនឹងបរិនិព្វាន ក៏សម្ដែងនូវការក្រៀមក្រំសោកស្ដាយចំពោះព្រះអង្គ ចំណែកព្រះអរហន្តជាព្រះ ខិណាស្រពកើតក្ដីសង្វេគចំពោះសង្ខាររបស់សព្វសត្វ ដោយគិតថា សូម្បីតែព្រះពុទ្ធជាបុគ្គលឈ្នះមារ ក៏ព្រះអង្គរំលត់ខន្ធចូលព្រះនិព្វានដែរ។ ប្លែកតែភិក្ខុមួយអង្គ គេចខ្លួនពីទីនោះ ពុំគោរពព្រះពុទ្ធជាម្ចាស់ទេ។ ដើម្បីបំបាត់សេចក្ដី-សង្ស័យ ព្រះពុទ្ធបានត្រាស់ឲ្យហៅភិក្ខុនោះមកសាកសួរ ភិក្ខុនោះឆ្លើយថា ខ្ញុំព្រះអង្គគេចទៅចម្រើនព្រះធម៌ឲ្យបានសម្រេចមគ្គផលមុនព្រះអង្គបរិនិព្វាន។ ព្រះពុទ្ធបានប្រទានពរសព្ទសាធុការថា *"ប្រពៃហើយម្នាលភិក្ខុទាំងឡាយ បើជនណាមួយគោរពរាប់អានតថាគត ចូរធ្វើតាមភិក្ខុ អង្គនេះ ដោយប្រតិបត្តិតាមសីល សមាធិ បញ្ញា រហូតសម្រេចមគ្គ ផលនិព្វាន ឈ្មោះថា បូជាតថាគត ដោយបដិបត្តិបូជា បូជាដ៏ឧត្តម ប្រសើរជាងសក្ការបូជាដោយផ្កាភ្ញីទៀន ធូបជាដើម"*

**បាតិមោក្ខមានពីរយ៉ាងគឺ ៖**

**១- អាណាបាតិមោក្ខ៖** បានដល់ព្រះវិន័យរបស់ព្រះភិក្ខុសង្ឃគឺ បាតិមោក្ខសំវរ-សីល ដែលមាន សិក្ខាបទ ២២៧ ដែលព្រះសង្ឃ សូត្ររាល់កន្លះខែម្ដង។

២- បាតិមោក្ខមួយទៀតហៅថា **ឱវាទបាតិមោក្ខ** ដែលព្រះអង្គសម្ដែងក្នុងមហាសន្និបាតព្រះសង្ឃ ១២៥០ អង្គ នៅថ្ងៃ ១៥ កើត ខែ មាឃ មានឱវាទបីយ៉ាងជាដើម។ ឱវាទបីប្រការនោះគឺ ៖

២.១- *សព្វបាបស្ស អករណំ* ប្រែថាការមិនធ្វើអំពើបាបគ្រប់យ៉ាង ពោលគឺហាមមិនឲ្យប្រព្រឹត្តអាក្រក់ មានការបៀតបៀនអ្នកដទៃ ទាក់ទងការរំលោភសិទ្ធិមនុស្សជា



www.elibraryofcambodia.org

ដើម។

**២.២-** *កុសលស្សូបសម្បទា* ប្រែថាការបំពេញកុសល ពោលគឺឲ្យធ្វើសេចក្តីល្អ ដោយកាយ វាចា ចិត្ត ទាក់ទងនឹងចិត្តមេត្តា ករុណា ស្រលាញ់រាប់អានជួយសង្គ្រោះអ្នកដទៃជាដើម។

**២.៣-** *សចិត្តបរិយោទបនំ* ប្រែថាជម្រះចិត្តឲ្យស្អាតបរិសុទ្ធ។ ការសម្អាតចិត្តឲ្យបរិសុទ្ធនេះជាមូលដ្ឋានសំខាន់បំផុត ព្រោះសកម្មភាពល្អកើតមកពីចិត្តបរិសុទ្ធ ហើយការធ្វើតែអំពើល្អ និងធ្វើឲ្យបុគ្គលម្នាក់ៗ គ្រួសារនីមួយៗ និងសង្គមជាតិទាំងមូលបានសុខសន្តិភាព។ បើពុទ្ធសាសនិកខ្មែរ ទាំងអ្នកដឹកនាំ ទាំងប្រជាពលរដ្ឋ ធ្វើតាមព្រះពុទ្ធឱវាទទាំងបីយ៉ាងនេះបានហើយ ឈ្មោះថា *គោរពបុណ្យមាឃបូជាក្នុងថ្ងៃមាឃបូជា* នេះហើយ។

## ៦

## ប្រពៃណីចូលឆ្នាំខ្មែរ

បុណ្យចូលឆ្នាំខ្មែរ តែងធ្វើឡើងនៅថ្ងៃទី ១៣ ខែ មេសា ជារៀងរាល់ឆ្នាំ តែយូរៗម្តង មាននៅ ថ្ងៃទី ១៤ ខែ មេសាដែរ។ ពេលវេលានៃការកំណត់ចូលឆ្នាំនេះគឺកំណត់ទៅតាមក្បួនហោរាសាស្ត្រ ដែលចេញផ្សាយជាផ្លូវការពីព្រះបរមរាជវាំងខ្មែរ។ ទាក់ទងនឹងពេលវេលានៃការចូលឆ្នាំនេះ មានរឿងបុរាណមួយនិទានថា **កបិលមហាព្រហ្ម** ភ្នាល់ចាញ់ធម្មបាលកុមារជាមនុស្សលោក **អំពីសិរី ៣ ប្រការ** គឺ *ពេលព្រឹកយកទឹកលុបមុខ ពេលថ្ងៃត្រង់យកទឹកលាបទ្រូង* និង *ពេលល្ងាចរៀបចូលដំណេក យកទឹកលាងជើង*។



www.elibraryofcambodia.org

នាងទេពធីតាទាំង ៧ នាក់ជាបុត្ររបស់កបិលមហាព្រហ្ម បានផ្លាស់វេនគ្នាក្នុងមួយឆ្នាំម្តង រាល់ ១២ ឆ្នាំយកព្រះសិរសា គឺក្បាលព្រហ្មជាបិតាខ្លួនពីភ្នំកៃលាស ហែប្រទក្សិណភ្នំព្រះសុមេរុ ដោយមានព្រះទេពនិករជួយហែហមផង រួចទើបយកទៅតម្កល់ទុកនៅភ្នំកៃលាសវិញ។ នាងទេពធីតាជា អ្នកនាំផ្លូវហែក្បួននេះ មានអានុភាពសាយភាយចាប់តាំងពីថ្ងៃចូលឆ្នាំទៅ អស់រយៈពេល ១ ឆ្នាំគត់ ហើយ មហាសង្រ្កាន្តក៏ចេញប្រកាសប្រាប់នូវគ្រោះកាច គ្រោះជាក្នុងមួយឆ្នាំនោះ។ សេចក្ដីដំណាលនោះបានប្រកាសប្រាប់ថា ត្រូវឲ្យអស់មនុស្សផងទាំងឡាយខំធ្វើទាន រក្សាសីល ចម្រើនមេត្តាភាវនា ក្នុងឆ្នាំថ្មីនេះ អ្នកទាំងនោះនឹងបានសេចក្ដីសុខក្សេមក្សាន្ត អាយុយឺនយូរ ហើយទេវតានឹងជួយថែរក្សា។ ទោះបីរឿងរ៉ាវនេះមិនមាននៅក្នុងព្រះពុទ្ធសាសនា ប៉ុន្តែពុទ្ធសាសនិកខ្មែរបំពេញបុណ្យកុសល ជាពុទ្ធសាសនា។

ពាក្យថា *សង្រ្កាន្ត* ឬ *សង្រ្កាន្តិ* ប្រែថា ដំណើរឃ្លាតចាកទី ការឈានចូលដល់ដំណើរដែល ព្រះអាទិត្យចូលដល់ទីជួបមួយជុំ នៃរាសីចក្រគឺដំណើរដើម និងចុងនៃរាសីចក្រជួបគ្នាពេញគ្រប់មួយ ឆ្នាំ បានដល់ការដាច់ឆ្នាំចាស់ ផ្លាស់ចូលឆ្នាំថ្មីនេះឯង។

ដូច្នេះ ការកំណត់ចូលឆ្នាំខ្មែរនេះ គឺកំណត់តាមសុរិយគតិ គឺតាមដំណើរព្រះអាទិត្យ។ មានន័យសេចក្ដីថា ក្នុងមួយឆ្នាំ ព្រះអាទិត្យធ្វើដំណើរបានមួយជុំ គឺឃ្លាតចាកពីចំណុច ហើយមកជួបចំណុចដដែលនោះវិញ។ ស្របនឹងវិទ្យាសាស្ត្រថា ផែនដីវិលជុំវិញព្រះអាទិត្យបានមួយជុំក្នុង ១ ឆ្នាំ។ ការចូលឆ្នាំនេះកំណត់បីថ្ងៃ គឺ *ថ្ងៃចូលឆ្នាំ (ថ្ងៃសង្រ្កាន្ត) ថ្ងៃកណ្តាល (ថ្ងៃខ្វាក់ឬវ័នបត)* និង *ថ្ងៃឡើងស័ក/សក្តិ* ។

តាមប្រពៃណី មុនថ្ងៃចូលឆ្នាំចូលមកដល់ ជនជាតិខ្មែរបានរៀបចំប្រដាប់ប្រដាសម្រាប់ធ្វើ បុណ្យ និងសម្រាប់ប្រើប្រាស់ ព្រមទាំងសម្រាប់ទទួលទានទុកជាស្រេច ព្រោះក្នុងអំឡុងពេលបីថ្ងៃនោះ គេផ្អាកការងារទាំងអស់ សូម្បី ឧស ទឹក អង្ករ ក៏គេបម្រុងទុកឲ្យហើយដែរ។

ក្នុងឱកាសចូលឆ្នាំថ្មីនេះ រដ្ឋាភិបាលបានឲ្យមន្ត្រីឈប់ធ្វើការចំនួនបីថ្ងៃ។ ដូច្នេះ ទាំងអ្នករាជការ ទាំងប្រជាពលរដ្ឋ បានកាត់ទៅជួបជុំឪពុកម្ដាយបងប្អូននៅភូមិកំណើត



www.elibraryofcambodia.org

រៀងៗខ្លួន ដោយនាំយកទៅ ជាមួយខ្លួន នូវវត្ថុសម្រាប់ធ្វើបុណ្យ និង សម្លៀកបំពាក់ នំចំណី សម្រាប់ប្រគេនព្រះសង្ឃ និងជូន ឪពុកម្ដាយខ្លួន។ ពេលល្ងាចនៃថ្ងៃបុណ្យនេះ គេនាំគ្នាទៅវត្តស្ដាប់ព្រះសង្ឃចម្រើនព្រះបរិត្ត និងស្ដាប់ ព្រះសង្ឃសម្ដែងធម្មទេសនា ពេលថ្ងៃ គេរាប់បាត្រ វេចង្កាន់ប្រគេនព្រះសង្ឃបង្សុកូល ឧទ្ទិសកុសល ដល់អ្នកដែលបានចែកឋានទៅ។

ក្នុងថ្ងៃចូលឆ្នាំនោះ មានពិធីពូនភ្នំខ្សាច់ធំ មានតំបន់ខ្លះ គេយកស្រូវឬអង្ករពូនជំនួសខ្សាច់។ គេពូនធ្វើជាភ្នំធំមួយនៅចំកណ្ដាល ឯភ្នំតូច ៤ ទៀតនៅសងខាងមានធ្វើរាជវតិព័ទ្ធជុំវិញ នៅជើងភ្នំ មានដោតទង់ក្រដាស់ពណ៌ ទៀន ធូប ផ្កាភ្ញីផ្សេងៗ ។

មតិមួយយល់ថា ភ្នំធំកណ្ដាលជាតំណាងភ្នំព្រះសុមេរុជាស្នូលនៃពិភពលោក ឯភ្នំព័ទ្ធជុំវិញ គ្រប់ទិសជាតំណាងភ្នំសត្តបរិភណ្ឌ ដែលជាបរិវារភ្នំព្រះសុមេរុ ។ បើដូច្នោះ ការធ្វើភ្នំនេះ វាគ្មាន ប្រយោជន៍អ្វីសោះក្នុងការបង្កើតបុណ្យជាកុសល។

ព្រោះហេតុដូច្នេះហើយ អ្នកប្រាជ្ញខ្លះយល់ផ្សេងពីនេះថា ភ្នំធំនៅចំកណ្ដាលជាតំណាង ព្រះចូឡាមណីចេតិយនៅស្ថានត្រៃត្រឹង្សដែលតម្កល់ទុកនូវព្រះកេសា (សក់) នៃ **ព្រះពុទ្ធសមណគោតម** ដែលទ្រង់បានកាត់នៅពេលដែលព្រះអង្គនៅជាព្រះពោធិសត្វ ចេញសាងបព្វជ្ជាវិញទេ។

មានមតិបន្ថែមទៀតថា ភ្នំធំកណ្ដាលជាតំណាងព្រះសាក្យមុនីចេតិយដែលបញ្ចុះព្រះសារីរិកធាតុនៃ**ព្រះពុទ្ធ** ឯភ្នំតូចបួនទៀតជាតំណាងចេតិយដែលបញ្ចុះអដ្ឋិធាតុរបស់ **ព្រះសារីបុត្រ, ព្រះមោគ្គល្លាន, ព្រះអានន្ទ** និង **ព្រះមហាកស្សបៈ** ដែលជាសាវ័កដ៏សំខាន់របស់ព្រះពុទ្ធអង្គ។

យោបល់ខាងក្រោយនេះ មានន័យល្អសម្រាប់បង្កើតបុណ្យជាកុសល គឺការធ្វើភ្នំជានិមិត្តរូបនៃ ចេតិយ ដែលបញ្ចុះសារីរិកធាតុនៃ **ព្រះពុទ្ធ** និងសាវ័ករបស់ព្រះអង្គ ដែលជាព្រះអរហន្ត មានគុណធម៌ ដ៏ខ្ពង់ខ្ពស់កំចាត់អំពើបាបអស់ហើយ។ មួយទៀត ជំនឿរបស់មហាជនខ្មែរថា គ្រាប់ខ្សាច់មួយគ្រាប់ៗ ដែលគាត់ចាក់ពូនភ្នំនោះ អាចផ្ដល់អានិសង្សដល់អ្នកពូន ឲ្យបានរំដោះចាកបាបគ្រោះ ឬកម្មពៀរផ្សេង ទៀតផង។



www.elibraryofcambodia.org

ពុទ្ធសាសនាពន្យល់ថា " បាបគ្រោះបានត្រូវរំដោះដោយសារបុគ្គលឈប់សាង អំពើបាប។ ក្រៅពី វិធីពូនភ្នំខ្សាច់ មានពិធីស្រង់ព្រះ គឺគេយកទឹកទៅស្រោច ឬ រលាស់ ទៅលើព្រះពុទ្ធរូប។ ពិធីនេះក៏ ជាកុសល ព្រោះតាមរយៈការស្រង់ព្រះពុទ្ធរូប ពុទ្ធបរិស័ទ នឹកដល់ **គុណធម៌ព្រះពុទ្ធ** មានព្រះនាមថា **អរហំ** ប្រែថា *ព្រះអង្គឆ្ងាយចាកសឹកសត្រូវ* ពោលគឺកិលេសជាដើម រមែងធ្វើចិត្តឲ្យជ្រះថ្លាស្ងប់ផ្លូវចិត្តមួយខណៈ ដែលជាហេតុនៃ សេចក្ដីសុខ។ មិនត្រឹមតែស្រង់ព្រះពុទ្ធរូបទេ កន្លែងខ្លះ មានការស្រង់ទឹកព្រះសង្ឃ ឬងូតទឹកជូន **មាតាបិតា** និងចាស់ទុំដែលមានគុណធម៌ មានសីលគុណទៀតផង។

បុណ្យចូលឆ្នាំខ្មែរមានខ្លឹមសារពិសេសរបស់ខ្លួន គឺការពិចារណានូវដំណើរជីវិត ដែលប្រព្រឹត្តទៅក្នុងរយៈពេលមួយឆ្នាំ ទុកជាមេរៀនសម្រាប់ឆ្នាំថ្មីក្នុងការរៀបចំផែនការ ជីវិតទៅមុខទៀត ឲ្យបានល្អជាងឆ្នាំចាស់ លះអំពើអាក្រក់ក្នុងឆ្នាំចាស់ កសាងអំពើល្អ ក្នុងឆ្នាំថ្មី។ នៅសម័យពុទ្ធកាល មានរឿង ប្រេតជាញាតិរបស់ **ព្រះបាទពិម្ពិសារ** ដំណាល យ៉ាងសង្ខេបថា នៅពេលដែលព្រះបាទពិម្ពិសារបាននិមន្តព្រះភិក្ខុសង្ឃ មានព្រះពុទ្ធ ជាប្រធាន មកទទួលចង្ហាន់។ ព្រះបាទពិម្ពិសារពុំបានតាំងចិត្តឧទ្ទិស កុសលដល់ពួក ប្រេតដែលជាញាតិរបស់ព្រះអង្គទេ ពួកប្រេតទាំងនោះបានបន្លឺសម្លេងយំស្រែកជុំវិញ ព្រះរាជវាំង ជាសញ្ញាទាមទារបុណ្យកុសល ដើម្បីឲ្យបានជាអាហារបរិភោគ។ ដោយ ទទួលសួរព្រះពុទ្ធជាម្ចាស់ បានជ្រាបរឿងនេះហើយ ទើបព្រះអង្គប្រញាប់ប្រញាល់ ធ្វើបុណ្យជាលើកទីពីរ ហើយតាំងចិត្តឧទ្ទិសកុសលដល់ពួកប្រេតជាញាតិ។ ចាប់ពីពេល នោះមកសម្លេងស្រែកក៏ស្ងាត់ទៅ ជាភ័ស្តុតាង បញ្ជាក់ថា ពួកប្រេតជាញាតិបានទទួល ផលបុណ្យនោះហើយ។ រឿងនេះស្របនឹងរឿង តិរោកុឌ្ឍសូត្រ ដែលបានចែងថា មាន ពួកប្រេតវិស័យខ្លះអត់ឃ្លាន រង់ចាំទទួលបុណ្យដែលញាតិ មិត្តឧទ្ទិសឲ្យដល់ខ្លួន។

**អត្ថន័យសន្ទេបនៃបុណ្យចូលឆ្នាំខ្មែរ**

១- ពិចារណាឲ្យកើតជាធម្មសង្វេកថា ពេលវេលាកន្លងទៅមួយឆ្នាំ អាយុរបស់គេ អស់មួយឆ្នាំដែរ ដូច្នេះពុំគួរប្រមាទក្នុងជីវិត ដែលចេះតែអស់ទៅសូន្យ ទៅនោះឡើយ។



www.elibraryofcambodia.org

២- នាំឲ្យមានស្មារតីពិចារណាថា តើឆ្នាំចាស់កន្លងផុតទៅ ខ្លួនគេបានធ្វើអ្វីខ្លះ ដោយទុកឆ្នាំ ចាស់ជាមេរៀន រៀបចំផែនការជីវិតទៅមុខទៀតឲ្យល្អជាងឆ្នាំចាស់ ។

៣- បើមានការទាស់ទែងខ្វែងគំនិតគ្នាក្នុងឆ្នាំចាស់កន្លងផុតទៅ លុះឆ្នាំថ្មីនេះ គេជានានឹងគ្នា វិញ ឈប់ប្រកួតប្រកាន់គ្នា ហើយស្រលាញ់រាប់អានដូចដើម វិញ។

៤- ក្រៅពីបំពេញបុណ្យកុសលចំពោះព្រះសង្ឃ គេនាំគ្នាទិញសម្លៀកបំពាក់ ម្ហូបចំណីជូន **មាតាបិតា** ដែលជាអ្នកមានគុណ។

៥- គេផ្សាយបុណ្យ ផ្សាយកុសល ជូនដល់ **មាតាបិតា** ញាតិកា មិត្តសំលាញ់ និងសព្វសត្វ ទាំងអស់ដែលបានចែកឋានទៅ។

៦- គេដាក់ទានដល់អ្នកក្រក្រីលំបាកតោកយ៉ាក កំព្រា អនាថាឥតទីពឹង ដោយទឹកចិត្ត អាណិតអាសូរ។

៧- សូម្បីសត្វតិរច្ឆានមានគោ ក្របីជាដើម ដែលតែងតែប្រើវាក៏គេឈប់ប្រើវា ក្នុងរវាងបីថ្ងៃ ហើយពោលសុំខមាលទោសនឹងសត្វទាំងឡាយនោះទៀតផង កុំឲ្យមាន កម្មពៀរទៅអនាគត នៅពេល ដែលខ្លួនប្រើធ្វើបាបវា។

៨- ពុំមែនសូមទោសចំពោះតែសត្វ ដែលមានវិញ្ញាណទេ សូម្បីតែធម្មជាតិ ដែលគ្មានចិត្ត គ្មានវិញ្ញាណ ក៏បុព្វបុរសខ្មែរសម័យដើម សូមខមាលទោស ផងដែរ ដូចជាយកទឹកទៅច្រូចលើដី ហើយពោលសូមខមាលទោសថា សូមកុំឲ្យមានកម្មពៀរ ព្រោះខ្ញុំបាទបន្ទោរបង់មូត្រលាមកពីលើ។

៩- ក្រៅពីកម្មវិធីសាសនា គេមានលេងកំសាន្តដោយល្បែងផ្សេងៗដែលជា ល្បែងឥតទោស ជាល្បែងហាត់ប្រាណ ជាល្បែងដែលនាំគ្នាឲ្យចិត្តរីករាយ បង្កើតចំណង សាមគ្គីភាព ដូចជាល្បែង បោះឈូង ល្បែងទាញព្រ័ត្រជាដើម។



www.elibraryofcambodia.org

## ១០

# ប្រពៃណីបុណ្យពិសាខបូជា

រៀងរាល់ឆ្នាំ ពុទ្ធសាសនិកទូទាំងពិភពលោក ជាពិសេស ពុទ្ធសាសនិកខ្មែរ តែងធ្វើពិធីបុណ្យ មួយនៅខែពិសាខ ហៅថា *បុណ្យពិសាខបូជា* ។ បុណ្យនេះធ្វើឡើង ដើម្បីរំលឹកនូវបុព្វហេតុបីប្រការ ដែលកើតឡើងក្នុងសម័យពុទ្ធកាលគឺ៖

១- ព្រះពោធិសត្វ ព្រះនាមព្រះសិទ្ធត្ថប្រសូត្រ។

២- ព្រះអង្គត្រាស់ជាព្រះពុទ្ធ រកឃើញអរិយសច្ច ៤ គឺ៖ សេចក្ដីទុក្ខ ហេតុនាំឲ្យកើតទុក្ខ ការរំលត់ទុក្ខ និង វិធីប្រតិបត្តិ ដើម្បីរំលត់ទុក្ខ។

៣- ព្រះអង្គរំលត់ខន្ធបរិនិព្វាន។

បុព្វទាំងបីនេះកើតឡើងនៅថ្ងៃទី ១៥ កើត ខែ ពិសាខ ដូចគ្នា។ បុណ្យនេះ គេចាត់ទុកជាបុណ្យសំខាន់ជាងគេ ក្នុងព្រះពុទ្ធសាសនា។

ពាក្យថា *ពិសាខបូជា* កាត់ជាពីរបទគឺ ពិសាខមួយបទ និងបូជាមួយបទ ។ *ពិសាខ* គឺជាឈ្មោះខែមួយក្នុងចន្ទគតិ ចន្លោះខែចែត្រ និង ខែជេស្ឋ។ *បូជា* ប្រែថា ការថ្វាយ ការប្រគេន ការជូនតាមពាក្យខ្ពស់ទាប បើនិយាយពីការប្រគេន ឬ ការថ្វាយវត្ថុផ្សេងៗ។ *បូជា* ម្យ៉ាងទៀតប្រែថា ការប្រតិបត្តិ តាម។ រួមទាំងពីរបទ **ពិសាខបូជា** ប្រែថាការបូជាក្នុងខែពិសាខ គឺជាបុណ្យរំលឹកដល់បុព្វហេតុ ៣ ប្រការ ក្នុងសម័យពុទ្ធកាល ក្នុងខែពិសាខ។

ការបូជាក្នុងខែពិសាខមិនខុសគ្នាពីការបូជាក្នុងខែមាឃទេ ពោលគឺ ក្នុងយប់ថ្ងៃបុណ្យពុទ្ធបរិស័ទខ្មែរនាំគ្នាទៅវត្តនមស្ការព្រះរតនត្រ័យ សមាទានសីល ប្រកាសពិសាខបូជា វេគ្រឿងសក្ការៈ ស្ដាប់ព្រះសង្ឃចម្រើនព្រះបរិត្តនិងទេសនា។ លុះព្រឹកឡើង មានពិធីរាប់បាត្រ និងវេរចង្ហាន់ប្រគេន ព្រះសង្ឃ។ ក្នុងឱកាសបុណ្យពិសាខបូជានេះ រាជរដ្ឋាភិបាលខ្មែរបានអនុញ្ញាតឲ្យមន្ត្រីរាជការឈប់សម្រាកធ្វើការ ដើម្បីបំពេញបុណ្យកុសលនេះ ដែលចាត់ទុកជាបុណ្យជាតិស្របតាមរដ្ឋធម្មនុញ្ញរបស់ ព្រះរាជាណាចក្រកម្ពុជា ដែលចែងថា *ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ* ។



www.elibraryofcambodia.org

# ១១
# ព្រះរាជពិធីច្រត់ព្រះនង្គ័ល

## ១- អត្ថន័យនៃព្រះរាជពិធីច្រត់ព្រះនង្គ័ល

ពិធីច្រត់ព្រះនង្គ័ល ជាព្រះរាជបវេណីមួយរបស់ព្រះមហាក្សត្រ ម្ចាស់ផែនដីខ្មែរ គឺព្រះអង្គ ប្រារព្ធពិធីច្រត់ព្រះនង្គ័លនេះ ដើម្បីបើករដូវធ្វើស្រែចំការឲ្យបណ្តារាស្ត្រ ហើយក៏ចង់ដឹងពី របាយទឹក ភ្លៀង និងភោគផលដំណាំរបស់ប្រជាកសិករដែរ។

នៅក្នុងច្បាប់ក្រមពហុលទេព ព្រះរាជាតែងបញ្ជាចុតហ្មាយ ប្រកាសអស់ប្រជារាស្ត្រដែលនៅក្នុងដែនកម្ពុជាឲ្យបានដឹងគ្រប់ៗគ្នា ពិសេស គឺប្រាប់អ្នកស្រែឲ្យ បោះនង្គ័ល រនាស់ ស្រះរបង ចង គោក្របី។

ក្នុងដើមខែពិសាខ ព្រះអង្គម្ចាស់ឲ្យពួកព្រាហ្មណ៍ធ្វើពិធីបួងសួងដល់ពួកទេវតា និងអារក្ស អ្នកតា សុំឲ្យធ្លាក់ទឹកភ្លៀងបរិបូរណ៍តាមរដូវកាល សុំកុំឲ្យមានជំងឺ។ រវាង ពាក់កណ្តាលខែពិសាខ រាល់ៗឆ្នាំ ឲ្យពួកព្រហ្មណ៍តាំងពិធីព្រត (បួស) បីយប់ បីថ្ងៃ នៅទីព្រះស្រែ លុះដល់ថ្ងៃទី៤ ទ្រង់ឲ្យធ្វើពិធី វប្បមង្គល ច្រត់ព្រះនង្គ័ល។ បើគ្មានភ្លៀង ធ្លាក់តាមរដូវកាល ព្រះអង្គឲ្យគេរៀបចំពិធីពរុណសាស្ត្រ ទៀត។

## ២- កំណើតនៃព្រះរាជពិធីនេះ

តាមសេចក្តីយល់របស់ខ្មែរ ពិធីនេះមានតាំងពីបុរាណកាលមក គឺតាំងពីសម័យ នគរភ្នំ (ហ្វូណន់) ដោយគេយល់ថា កៅណ្ឌិន្យ បាននាំយកអរិយធម៌លទ្ធិសាសនា ទំនៀមទម្លាប់ផ្សេងៗមក ជាមួយ ដូច្នេះ ប្រហែលជា នាំយកពីធីច្រត់ព្រះនង្គ័លនេះមក អនុវត្តនៅក្នុងស្រុកខ្មែរជាប្រាកដ ហើយ ទំនៀមទម្លាប់នេះក៏មាននៅក្នុងប្រទេសឥណ្ឌា ដែរ ដូចមាននៅក្នុងរឿងរាមកេរ្តិ៍ រឿងមហាភារតយុទ្ធ ស្រាប់។

សព្វថ្ងៃនេះ គេឃើញរូបមួយនៅហោព្រះបញ្ចាក្សត្រ ក្នុងព្រះបរមរាជវាំង ជារូប សំរិទ្ធិលីនង្គ័ល ឬចបកាប់ មើលមិនច្បាស់ រូបមួយទៀតធ្វើដោយថ្មភក់ ជារូបលីនង្គ័ល មាននៅសារមន្ទីរភ្នំពេញ។ ដោយហេតុរូបនេះជាស្នាដៃរបស់ខ្មែរសាងនៅក្នុងមណ្ឌល


www.elibraryofcambodia.org

ស្រុកខ្មែរ តាំងពីបុរាណកាលមក ទើបនាំឲ្យគេយល់ថា ទំនៀមច្រត់ព្រះនង្គ័លគង់មានមកពីបុរាណកាល យ៉ាងតិចណាស់ក៏ត្រឹមសម័យមហានគរ ដែរ។

## ៣- ទីកន្លែងប្រារព្ធព្រះរាជពិធីច្រត់ព្រះនង្គ័ល

គេប្រារព្ធពិធីនេះនៅទីព្រះស្រែ ។ ពាក្យ *ព្រះស្រែ* មានន័យពីរយ៉ាងគឺ ៖

- ស្រែដែលព្រះមហាក្សត្រទ្រង់ច្រត់ព្រះនង្គ័លរៀងរាល់ឆ្នាំ
- ស្រែដែលគេថ្វាយជាសម្បត្តិសាសនា (ព្រាហ្មណ៍សាសនាក្តី ពុទ្ធសាសនាក្តី) ។

ព្រោះហេតុនេះ កាលបើលឺគេនិយាយចេញឈ្មោះព្រះស្រែដែលនៅជិតប្រាសាទទេវស្ថាន ឬវត្តបុរាណ គឺគេសម្តៅស្រែជាដង្វាយព្រះ តែបើនៅជិតរាជវាំងបុរាណនោះគឺគេសម្តៅស្រែហ្លួង។

នៅមុនសម័យឧត្តុង្គ ការចាំកន្លែងស្រែហ្លួង គេមិនឃើញមានទេ តែចាប់ពីសម័យឧត្តុង្គមក គេបានចងចាំថា ព្រះស្រែហ្លួងនៅទិសនិរតីនៃព្រះរាជវាំង គឺជិតវត្តឈូកស។ ព្រះស្រែនេះ ពីដើម មានលក្ខណៈជាស្រែមែន ដូចស្រែធម្មតា គឺជាទំនាបល្មមដក់ទឹកបានដូចស្រែធម្មតា។

នៅភ្នំពេញព្រះស្រែហ្លួងធ្វើខាងលិចវត្ត ប្រយុវង្ស។ នៅក្នុងរាជព្រះបាទ **ស៊ីសុវត្ថិ** ព្រះអង្គទ្រង់ ច្រត់ព្រះនង្គ័លនៅវាលព្រះមេរុ ពិតមែន តែទីនោះជាទីរាបធម្មតា មិនមែនពេញលក្ខណៈជាព្រះស្រែទេ លុះច្រត់ព្រះនង្គ័លរួច ទ្រង់ឲ្យគេភ្ជួរដីមួយអន្លើ ប្រមាណប៉ុនស្រែតូចមួយ បើកទឹកម៉ាស៊ីន ដាក់ស្ទូងស្រូវ។

ដូច្នេះ ព្រះមហាក្សត្របុរាណទ្រង់ធ្វើព្រះស្រែឲ្យកើតជាផល មិនមែនគ្រាន់តែជានិមិត្តរូប ដូចសព្វថ្ងៃនេះទេ។

## ៤- ពេលវេលាច្រត់ព្រះនង្គ័ល

ពីដើម ពិធីច្រត់ព្រះនង្គ័ល មានទំនៀមរើសរយកថ្ងៃល្អ ដូចពិធីដទៃទៀតដែរ។ តែក្រោយមក គេកំណត់យកថ្ងៃ ៤ រោច ខែ ពិសាខ ទោះថ្ងៃនោះល្អក្តី មិនល្អក្តី ។

## ៥- គ្រឿងប្រដាប់ក្នុងពិធីច្រត់ព្រះនង្គ័ល

នៅថ្ងៃទី១រោច ២រោច ៣រោច ខែពិសាខ ក្រុមព្រះបុរោហិត ត្រូវធ្វើពិធីបូជា



www.elibraryofcambodia.org

ទេវតានៅក្នុងរោងទាំង ៥ ដែលសង់នៅទីព្រះស្រែនោះ ។ នៅពេលជិតព្រលប់ ថ្ងៃ ១ រោច គេរៀបចំសែនក្រុងពាលី ដើម្បីសុំទឹកដីរៀបចំពិធី ។ នៅពេលជិតព្រលប់ថ្ងៃ ២ រោច និង ៣ រោច ពួកព្រាហ្មណ៍បារគូរៀបចំធ្វើ ពិធីហោមរោង ។ ពាក្យថា *ពិធី* មានន័យថា "ការរៀបចំ" ឬថា "កិច្ចការធ្វើបុណ្យ" ឯពាក្យ ថា *ហោម* បានសេចក្ដីថា ពលិការក្នុងរណ្ដៅភ្លើង ឬការបូជាទេវតា ដោយសាច់ ទឹកដោះថ្លាក្នុងរណ្ដៅភ្លើង បើប្រែឲ្យខ្លីថា "ពិធីបូជាភ្លើង" ព្រោះទំនៀមនេះជាប្រពៃណីនៅប្រទេសឥណ្ឌាដែលធ្លាប់ធ្វើតាំងពីយូរអង្វែង ណាស់មកហើយ។ ប៉ុន្តែ សព្វថ្ងៃនេះ ពួកព្រាហ្មណ៍នៅក្នុងកម្ពុជរដ្ឋយើងសង្ខេបពិធីត្រឹមពលិការ ទេវរូប និងសូត្រប្រកាសដល់ទេវតា នៅរោងមណ្ឌលតែប៉ុណ្ណោះជាការស្រេច ឯក្បួនច្បាប់សម្រាប់ធ្វើ ហោមពិធីមាននៅសល់ដល់សព្វថ្ងៃនេះ។

**៦- ព្រះគោដែលប្រើក្នុងពិធី**

ព្រះមហាក្សត្រទាំងឡាយ ក្នុងដែនដីឥណ្ឌាបុរាណទ្រង់និយមប្រើគោសម្បុរសជារាជពាហនៈ តួយ៉ាងក្នុងរឿងមហាភាតយុទ្ធ មានសេចក្ដីខាងដើមថា ព្រះយុធិ ស្ឋិរៈ ទ្រង់ប្រើព្រះគោសម្បុរ ស ច្រត់ព្រះនង្គ័ល។

ក្នុងរជ្ជកាលព្រះបាទសម្ដេចបរមកោដ្ឋ (ព្រះអង្គឌួង) ទ្រង់ប្រើព្រះគោសម្បុរស។ លុះចាប់ពីរជ្ជកាលសម្ដេចព្រះបាទនរោត្តម រហូតមកដល់រជ្ជកាល **សម្ដេចនរោត្តម សីហនុ** ចំនួន ៤ រជ្ជកាលនេះ ប្រាកដជាប្រើព្រះគោសម្បុរខ្មៅច្រត់ព្រះនង្គ័ល។

លើសពីនេះ ព្រះគោតែងមានស្នែងរាងជ្រពាស់ឈ្មក់ គឺរាងឱបទៅមុខ វាត់ចុងឡើងបន្តិច ទម្រង់ដូចគ្នាទាំងគូ គ្មានកែកលម្អៀងគ្នាសោះ។

**៧- អ្នកតំណាងព្រះមហាក្សត្រពេលច្រត់ព្រះនង្គ័ល**

ពេលធ្វើហោមពិធីគ្រប់បីថ្ងៃហើយ ក្នុងថ្ងៃទី ៤ ពេលព្រឹក ព្រះរាជា ព្រះអង្គឯងចាត់តាំងតំណាងព្រះអង្គឲ្យចេញច្រត់ព្រះនង្គ័ល។

អ្នកត្រូវចាត់តំណាង គឺឧកញ៉ា ពហុលទេពក្សេត្រធិបតី។ បើរវល់ គេត្រូវចាត់ឧកញ៉ាពិធីធសាលីក្សេត្រភោជនហារ។

អ្នកទទួលតំណែងច្រត់ព្រះនង្គ័លពីព្រះអង្គ គេហៅថា **ស្ដេចមាឃ** ហើយ ភរិយា



www.elibraryofcambodia.org

ស្ដេចមាយ ហៅថា **ព្រះមេហ្វ** ដែលមានមុខងារជាអ្នកព្រោះស្រូវ។ (ក្នុងភាសាសៀម ម៉ែយូហ្វ=មេលើត្បូង)។

## ៨- ការតែងខ្លួនសម្រាប់អ្នកតំណាងព្រះរាជា

ការតែងខ្លួនជាមុខងាររបស់អ្នកគ្រូល្ខោនព្រះរាជទ្រព្យ ។ ការតែងខ្លួនមាន៖

- **ស្ដេចមាយ** ស្លៀកសំពត់សារបាប់ពណ៌លឿងទុំសម្លុយ ពាក់អាវសារបាប់ ពណ៌លឿងទុំ និង ពាក់មួកប្រពាតពណ៌លឿងទុំ ។ ក្នុងរាជព្រះបាទ **ស៊ី សុវត្ថិ** និង **សីហនុវង្ស** មានពាក់ស្រោមជើង និង ស្បែកជើងពណ៌ខ្មៅ។

- **មេហ្វ៖** ក្នុងរាជ្ជកាលព្រះបាទ នរោតម ព្រះមេហ្វ ស្លៀកសំពត់សារបាប់សម្លុយ ពាក់អាវព្រៃបំពង់វែងលឿទុំ ពានាក្រមាព្រៃពណ៌បៃតង ប្រដាប់គ្រឿងមាសពេជ្រទំហ្វជៀងខ្លួន ពាក់ ជញ្ជៀន ក្បាលទទេ ឥតពាក់អ្វី។ ក្នុងរជ្ជកាលព្រះបាទ **ស៊ីសុវត្ថិ** ព្រះមេហ្វស្លៀកសំពត់ហូលមានជរ ពានាផាហ៊ុំខាងក្នុង ស្បៃសារបាប់ខាងក្រៅ ។ នាសម័យបច្ចុប្បន្ន ព្រះមេហ្វស្លៀកសំពត់សារបាប់សម្លុយ ពាក់អាវទ្រនាប់រឹតខ្លួន ពណ៌លឿង ពាក់ស្បៃឈៀងបែបតួល្ខោន និងគ្រឿងអលង្ការផ្សេងៗ ។

- មហាតលិកទាំង ៤ របស់ស្ដេចមាយ ស្លៀសំពត់ពណ៌ចងក្បិន ពាក់អាវផ្កាមាស ពាក់មួក ប្រពាតដូចៗគ្នា ក្បាលទទេ។

- ក្បួនហែហមអ្នកតំណាងព្រះអង្គ៖ ពេលម៉ោង ៧:៣០ នាទី ថ្ងៃ ៤ រោច ខែពិសាខ ឧកញ៉ាពលទេ និងភរិយា ពេលតែងខ្លួនពេញយសតាមទំនៀមហើយ ព្រមទាំងបរិវារ ចូលទៅថ្វាយបង្គំព្រះករុណានៅក្នុងព្រះរាជវាំង។ ព្រះមហាក្សត្រទ្រង់ត្រាស់ថា ថ្ងៃនេះជាថ្ងៃធ្វើពិធីវប្បធម៌នង្គ័ល យើងសន្មតអ្នកជាស្ដេចពលទេពឲ្យជាតំណាងយើង និងសន្មតភរិយារបស់អ្នកជាតំណាងព្រះទេវីរបស់យើង* ក្នុងពិធីច្រត់ព្រះនង្គ័ល ហើយទ្រង់យកម្សៅក្រអូបចឹមនៅថ្ងាសឧកញ៉ាពលទេពនិងភរិយា បារគូផ្លុំស័ង្ខរួច ទ្រង់ប្រគល់ដាវឲ្យឧកញ៉ាពលទេព។

អ្នកឧកញ៉ាពលទេព និងភរិយាថ្វាយបង្គំទទួលព្រះរាជឱង្ការ បារគូផ្លុំស័ង្ខ។ ឧកញ៉ាពលទេពទទួលដាវយកមកស្ពាយ ឬកាតចង្កេះ ហើយថ្វាយបង្គំត្រឡប់ចូលក្បួន



www.elibraryofcambodia.org

ដែលគេត្រៀមចាំនៅទី ព្រះលានក្នុងព្រះបរមរាជវាំង ដើម្បីហែទៅកាន់ទីព្រះស្រែ។

ក្បួនហែមានទង់ធំនាំមុខត្រង់កណ្ដាលផ្ទៃទង់ធ្វើជាត្រាឧញ៉ាពលទេព ដើម្បីសម្ដែងថា ឈ្មោះ នោះជាស្ដេចក្នុងពិធីនេះ។ ក្រៅពីនេះមានភ្លេង និងអ្នកហែហម។

## ៩- ក្បួនហែច្រត់ព្រះនង្គ័ល

ពេលហែទៅដល់ទីព្រះស្រែ ស្ដេចមាឃ និង មេហួ ចូលទៅថ្វាយបង្គំព្រះទេវរូបនៅរោងពិធី ទិសនិរតី (ជាទីពឹងព្រះចន្ទ្រទេវរាជ) បារគូផ្លុំស័ង្ខបីបទ រួចស្ដេចមាឃ និង មេហួ ចេញទៅច្រត់ព្រះ នង្គ័ល។ ភ្នាក់ងារកាន់ព្រះនង្គ័លក៏ប្រគល់នង្គ័លឲ្យស្ដេចមាឃ ហើយចេញដើរនាំមុខ។ នង្គ័លស្ដេច មាឃនៅកណ្ដាល មានមនុស្សម្នាក់បាំងក្លស់ ហើយ មហាតលិកទាំង ៤ នាក់ កាន់គ្រឿងដើរ តាមក្រោយ មេហួដើរក្រោយនង្គ័លទី ៣ មានមនុស្សម្នាក់បាំងក្លស់ ឯសាវឡិក[47] ទាំង ៤ នាក់ កាន់គ្រឿង ដើរហែតាមក្រោយ។ ក្បួនច្រត់ព្រះនង្គ័លចេញច្រត់ជាទក្ខិណាព័ត៌បីជុំ។

ពេលកំពុងច្រត់នោះ មេហួចាប់ស្រូវហៅថា *ក្រយាសំពាន់ករញ្ជី* ព្រោចសាចទៅឆ្វេង ទៅស្ដាំ ដរាបដល់ឈប់ច្រត់ក្នុងមួយជុំ បារគូផ្លុំស័ង្ខម្ដង។ ពេលគ្រប់បីជុំ ភ្នាក់ងារអ្នកដើរម្នាក់ ដើរនាំក្បួនព្រះនង្គ័លទៅឈប់នៅក្បែររោងពិធីទិសបូព៌ា រួចដោះគោចេញ។

## ១០- ការផ្សងគោឧសភរាជ

លំដាប់នោះ ព្រហ្មណ៍ព្រះរាជគ្រូសូត្រពាក្យអធិដ្ឋានផ្សងគោឧសភរាជដែលទឹមច្រត់ព្រះនង្គ័លនោះឲ្យស៊ី ផឹក អាហារ ៧ យ៉ាង ដែលភ្នាក់ងាររៀបដាក់ទុកនូវតុប្រាក់ធំៗ តាំងទុកនៅទីមុខព្រះពន្លា គឺគ្រាប់ស្រូវ ១តុ គ្រាប់សណ្ដែកមួយតុ គ្រាប់ពោត១តុ គ្រាប់ល្ង ១តុ ស្មៅស្រស់ ១តុ ទឹក ១តុ ស្រា ១តុ។ សូត្រចប់ព្រាហ្មណ៍ព្រះរាជគ្រូយកទឹកមន្តប្រស់ក្បាលព្រះគោទាំងពីរ រួចហើយ មន្ត្រី១នាក់ ដែលកាន់នង្គ័លស្ដេចមាឃដឹកគោឧសភរាជទាំងពីរទៅឲ្យស៊ីផឹក របស់ទាំង ៧ យ៉ាងស្រេចហើយ តែគោឧសភរាជចូលចិត្តស៊ីផឹកអ្វីក៏ស៊ីផឹកទៅ គេមិនបង្ខំឲ្យស៊ីផឹកចំពោះអាហាយ៉ាងណានីមួយៗទេ។ កាលព្រះគោស៊ីផឹកអ្វីមួយយ៉ាង ឬពីរយ៉ាង ភាយផលប្រផ្នូល ទៅខាងមុខ

---

[47] ស្ត្រីជាភរិយាតូចរបស់ព្រះអង្គម្ចាស់ ។



www.elibraryofcambodia.org

នោះ គឺថាបើព្រះគោស៊ីអ្វីក៏ទាយថា ក្នុងឆ្នាំនោះ របស់នោះសម្បូរប្លែក តែបើស៊ីស្មៅ ទាយថា កើតជំងឺគោ បើផឹក ស្រាទាយថា និងកើតមនុស្សពាល ចោរលួច ប្លន់ជាច្រើន។ លំដាប់នោះ ស្ដេចមាឃ និងមេហ្វ ចូល ទៅថ្វាយបង្គំព្រះទេវរូប នៅក្នុងរោងមណ្ឌល ទិសខាងកើត (ជាទីតាំងព្រះកំប្លាយនទេវរូប) នោះ ពួកបារគូក៏ចូលទៅផ្លុំស័ង្ខ ហើយ ព្រះរាជគ្រូយកមន្តប្រស់ព្រំឲ្យអ្នកទាំងពីរ ព្រមទាំងឲ្យសព្ទសាធុការពរឲ្យបានប្រកប ដោយសិរីសួស្ដីជាការស្រេច ព្រះរាជពិធីច្រត់ព្រះនង្គ័លហើយ។







www.elibraryofcambodia.org

## ១២
# ប្រពៃណីបុណ្យចូលព្រះវស្សា

តាមទំនៀមជាប្រពៃណីនៃព្រះពុទ្ធសាសនា ព្រះសង្ឃទាំងឡាយគ្រប់អារាម ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែនិមន្តចូលកាន់ព្រះវស្សាអស់ថេរវេលា ៣ ខែ ចាប់តពីថ្ងៃ ១រោច ខែអាសាឍតទៅ។

ពាក្យថា "វស្សា" មកពីពាក្យបាលីថា "វស្សា" ប្រែថាភ្លៀង ឬ រដូវភ្លៀងដែលមានកំណត់បួនខែ (ចាប់ពីថ្ងៃ ១រោច ខែអាសាឍ ដល់១៥កើត ខែកត្តិក)។ ព្រះបរមសាស្តាទ្រង់បានបញ្ញត្តឲ្យមានកិច្ចចូលព្រះវស្សានេះ ប៉ុន្តែសព្វថ្ងៃនេះ នៅប្រទេសកម្ពុជា ការចូលព្រះវស្សាមានកំណត់ត្រឹម តែ ៣ ខែ ទេ (ចាប់ពីថ្ងៃ ១រោច ខែអាសាឍ ដល់ ១៥ កើត ខែអស្សុជ)។

ក្នុងរយៈវេលាបីខែនេះ នៅគ្រប់ព្រះវិហារនៃទីវត្តទាំងឡាយ គេតែងតែរក្សាភ្លើងទៀនព្រះវស្សាឲ្យឆេះជាប់ជានិច្ច។ តួទៀនធ្វើអំពីឈើ មានទំហំប្រមាណចាប់ពីកម្ពស់ ២ហត្ថ មានរចនាក្បាច់យ៉ាងល្អ និងរំលេចពណ៌ដ៏ប្រណីតផង។ ខាងក្នុងតួពុម្ពទៀនមានដោតអំបោះទៅជាប្រឆេះ ហើយគេបង្ហូរក្រមួនឃ្មុំចូលទៅក្នុងពុម្ពនោះ ប៉ុន្តែដោយក្រមួនឃ្មុំពុំសូវសម្បូរ គេនិយមប្រើប្រេងជំនួសវិញ ហើយ ចាក់ក្រមួនឲ្យមានកម្រាស់តែ ៥ ធ្នាប់ខាងលើទេ។ លុះឆេះអស់សាច់ក្រមួនហើយ ទើបវាឆេះដល់ ប្រេង។ គេធ្វើដូច្នេះ ដើម្បីឲ្យទៀននោះឆេះជាប់ជាដរាបគ្រប់ ៣ ខែ។

ចំពោះការប្រារព្ធពិធីចូលវស្សាក្នុងព្រះបរមរាជវាំងវិញ កាលដល់ថ្ងៃកំណត់ចូលព្រះវស្សាហើយ ព្រះករុណា ឬ ព្រះរាជវង្សានុវង្សមួយព្រះអង្គ ទ្រង់យាងចេញអុជទៀនវស្សាទាំង ៤ យ៉ាងឧឡារិក ជារាល់ឆ្នាំ។ បណ្តាទៀនវស្សាទាំង ៤ នោះ ទៀន ១ ត្រូវតម្កល់ហោព្រះរូបក្នុងព្រះបរមរាជវាំង ដែលជាកន្លែងតម្កល់ព្រះពុទ្ធរូប។ ទៀន ១ ទៀត តម្កល់នៅក្នុងហោព្រះអដ្ឋិ នៅក្នុងទីនាំងទេវាវិនិច្ឆ័យ ដែលជាទីតម្កល់នូវកោដ្ឋធាតុរបស់ក្រុមព្រះរាជវង្សានុវង្ស។ ទៀនទី ៣ តម្កល់នៅក្នុងហោព្រះខាន់ ទៀនទី ៤ តម្កល់នៅ


www.elibraryofcambodia.org

ក្នុងព្រះវិហារព្រះកែវមរកត។ ម្យ៉ាងទៀត ព្រះករុណាតម្រូវឲ្យធ្វើទៀនតម្កល់នៅទីវត្ត ក្នុងព្រះរាជធានី និងទីវត្តជិតៗ នៅក្នុងទីក្រុងផង ព្រោះហេតុនេះហើយ ទើបទៀនវស្សាព្រះរាជទ្រព្យមានដល់ទៅ **១៩ ដើម** ។

នៅថ្ងៃដែលធ្វើពិធីអុជទៀនវស្សានៅព្រះបរមរាជវាំង ក្រុមបារគូបុរោហិតរៀបធ្វើពិធីអញ្ជើញ ព្រះបញ្ជាក្សត្រឲ្យចូលទៅកាន់ព្រះវស្សាដែរ។ ចាប់ពីថ្ងៃពេញបូណ៌មីខែអាសាឍ គឺមុនថ្ងៃចូល ព្រះវស្សាមួយថ្ងៃ។ គេសង្កេតឃើញភាពអ៊ូអរស្មើរតែគ្រប់វត្តអារាម។ ពីព្រលឹម ព្រះសង្ឃទាំងឡាយនៅក្នុងវត្ត និមន្តចូលទៅក្នុងព្រះវិហារដើម្បីថ្វាយបង្គំព្រះរតនត្រ័យ និងសូត្រធម៌ ដាបេញ្ជូនផលានិសង្សដល់វិញ្ញាណក្ខន្ធអ្នកដែលបានទទួលមរណភាពទៅហើយ។ ដល់ថ្ងៃត្រង់ពួកទាយក ទាយិកា រៀបចង្ហាន់ប្រគេនព្រះសង្ឃឆាន់ពេលល្ងាចព្រះសង្ឃសម្ដែងធម៌ទេសនាជាការស្រេច។

ថ្ងៃបន្ទាប់មកជាថ្ងៃចូលព្រះវស្សា នៅវេលារសៀល គេរៀបធ្វើពិធីហែទៀនព្រះវស្សា និងគ្រឿងបរិក្ខាផ្សេងៗ មានសំពត់វស្សិកសាដកជាដើម ប្រទក្សិណព្រះវិហារបីជុំជាមុន ទើបនាំទៀនចូលទៅ គេវេទៀនរួចទើបអុជទៀននោះជាក្រោយ។

នៅឱកាសនោះ គេនិមន្តព្រះសង្ឃឲ្យគង់តាមលំដាប់ព្រះវស្សាចាស់ខ្ចី។ ព្រះសង្ឃដែលចាស់វស្សាជាងគេប្រកាសប្រាប់ទីប្រជុំជនថា ថ្ងៃនេះជាថ្ងៃចូលព្រះវស្សាដែលមានថេរវេលា ៣ ខែ ហើយ ព្រះសង្ឃឯទៀតថាតាម។

ក្នុងកំណត់ចូលព្រះវស្សា ៣ ខែនេះ ព្រះសង្ឃពុំអាចនិមន្តទៅណាមកណា ដូចពេលនៅក្រៅវស្សាទេ។ បើកាលណាមានកិច្ចពិសេស ព្រះសង្ឃអាចនិមន្តទៅផ្ទះឯកជនបាន បើសិនជាគេនិមន្ត ឬបើមានធុរៈញោមឈឺ ឬក៏ឧបជ្ឈាយ៍ អាចារ្យឈឺ លោកអាចចេញទៅគង់ក្រៅអារាមបាន ប៉ុន្តែ ត្រូវកុំ ឲ្យហួសពី ៧ ថ្ងៃ។ មុននឹងចេញទៅ លោកត្រូវទៅទូលលោកជាគ្រូមេវត្តសិន ដោយសន្យានឹងលោក ថា នឹងវិលមកវិញឲ្យទាន់មុនអរុណរះនៃថ្ងៃទី ៧ ជាមិនខាន។ ដល់ពេលត្រឡប់ចូលទីអារាមវិញភ្លាម ត្រូវទៅបង្ហាញខ្លួនដល់លោកគ្រូមេវត្តជាដំណឹង។


www.elibraryofcambodia.org

ជូនកាល មានព្រះសង្ឃខ្លះពុំបានចូលព្រះវស្សាតាមកំណត់កាលវេលាដោយមានធុរៈអ្វីមួយ ឬដោយមាតាបិតាអាពាធនោះ លោកអាចចូលបច្ឆិមវស្សាបាន គឺ លោកចូលថ្ងៃទី ១ រោច ខែស្រាពណ៍ ហើយត្រូវគិតវស្សាឲ្យគ្រប់បីខែ ដូចលោកដែលចូលមុន គឺត្រូវចេញវិញនៅថ្ងៃ ១រោច ខែកត្តិក។

ម្យ៉ាងទៀត ការចូលព្រះវស្សានេះមានប្រយោជន៍ ជាពិសេសដល់ភិក្ខុ សាមណេរ ក្នុងការសិក្សាពីគ្នាទៅវិញទៅមកនូវធម៌វិន័យ ហើយជួយរិះគន់គ្នាទៅវិញទៅមក ក្នុងការកែតម្រូវនូវទោស កំហុសឆ្គងតាមធម៌វិន័យវិញ។

បើប្រៀបមកផ្លូវអាណាចក្រវិញ គ្រួសារមួយ ឬសង្គមមួយ ដែលអាចរស់នៅជាមួយគ្នាបាន លុះត្រាតែស្ថិតនៅក្រោមអំណាចច្បាប់មួយ ដែលត្រូវគោរពទាំងអស់គ្នា បើមានការខុសឆ្គងបន្តិចបន្តួច គួរមានអធ្យាស្រ័យអត់ឱនឲ្យគ្នា ដល់គ្នាទៅវិញទៅមក ប្រកបដោយមេត្តាធម៌ ជារបៀបសុជីវធម៌។

## ១៣
## ប្រពៃណីបុណ្យកាន់បិណ្ឌ និង ភ្ជុំបិណ្ឌ

បុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះ ពុទ្ធសាសនិកជនខ្មែរតែងធ្វើមុនព្រះសង្ឃចេញព្រះវស្សា ចំនួនមួយខែ រៀងរាល់ឆ្នាំ គឺចាប់កាន់បិណ្ឌតាមវេនពីថ្ងៃទី ១រោច ដល់ ១៤ រោច ខែភទ្របទ។ ថ្ងៃទី ១៥ រោច ជាថ្ងៃភ្ជុំបិណ្ឌ ដែលជាថ្ងៃសំខាន់ ព្រោះគេធ្វើពិធីបុណ្យនេះរួមគ្នា គ្រប់វេនទាំងអស់។

ពាក្យថា **បិណ្ឌ** ចេញមកពីភាសាបាលី *បិណ្ឌ* ប្រែថាដុំបាយ ដូចពាក្យថា *បិណ្ឌបាត្រ* គឺ យកដុំបាយទៅទម្លាក់ក្នុងបាត្រ។ ប៉ុន្តែបាយបិណ្ឌដែលគេធ្វើក្នុងពេល



www.elibraryofcambodia.org

កាន់បិណ្ឌនិងភ្ជុំបិណ្ឌនេះ គឺជា ដុំបាយដំណើប ដែលគេចម្អិនលាយខ្ទិះដូង និងល្ង ឬ លាយជាមួយគ្រឿងផ្សំផ្សេងៗទៀត តាមទម្លាប់ អ្នកស្រុក។ គេរៀបចំបាយបិណ្ឌនៅជុំវិញបាយបត្តបូរ។

*បាយបត្តបូរ* ក៏ធ្វើដូចជាបាយបិណ្ឌដែរ គ្រាន់តែគេពូតជាពំនូតធំ មានកំពូលស្រួច ហើយគ្របដោយសាជីស្លឹកចេក និងមានដោតទៀនផ្កាភ្ញីផង។ អ្នកខ្លះពន្យល់ន័យនៃពាក្យថា *បិណ្ឌ* ម្យ៉ាងទៀតថា គឺចង្ហាន់ដែលពុទ្ធបរិស័ទប្រគេនព្រះសង្ឃក្នុងពិធីបុណ្យឧទ្ទិសផលបញ្ជូនទៅញាតិសន្តាន មានមាតា បិតាជាដើម ដែលចែកឋានទៅកាន់បរលោកហើយ៖ **ធ្វើបុណ្យដាក់បិណ្ឌ ថាបុណ្យភ្ជុំបិណ្ឌ** ។

មុនថ្ងៃភ្ជុំបិណ្ឌមួយថ្ងៃ គ្រួសារខ្មែរនៅគ្រប់ទីកន្លែងនាំគ្នាធ្វើនំអន្សម នំគមជាដើម បម្រុងយក ទៅវត្តប្រគេនព្រះសង្ឃឧទ្ទិសកុសល និងសម្រាប់ចែកញាតិមិត្ត។ នៅឯទីវត្តពុទ្ធបរិស័ទចំណុះជើង វត្តនីមួយៗ បោសសម្អាតទីធ្លាវត្ត សម្អាតចេតិយ និងតាក់តែងសាលាបុណ្យឲ្យបានសមរម្យ។

នៅល្ងាចថ្ងៃ ១៤ រោច មុនភ្ជុំមួយថ្ងៃមានពិធីពិសេស គឺព្រះសង្ឃចម្រើនព្រះបរិត្ត និងទេសនា កន្លែងខ្លះមានធ្វើពិធីអភិសេកព្រះពុទ្ធរូបផង។ រាល់យប់ ក្នុងអំឡុងពេលកាន់បិណ្ឌនិងភ្ជុំបិណ្ឌនោះ ពុទ្ធបរិស័ទនាំគ្នាទៅវត្ត ស្តាប់ព្រះសង្ឃចម្រើនព្រះបរិត្ត និងសម្តែងធម៌ទេសនា។ រាល់ព្រឹក ពុទ្ធបរិស័ទ បានយកចង្ហាន់ទៅប្រគេនព្រះសង្ឃ ដើម្បីបង្សុកូលឧទ្ទិសកុសល។ ពេលប្រលឹមស្រាងៗ គ្រប់វត្ត អារាម គេលឺសូរព្រះសង្ឃសូត្រ **បរាភវសូត្រ** លាយឡំដោយភ្លេងពិណពាទ្យ និងធម៌បទផ្សេងៗកំដរ បុណ្យផង។ មានកន្លែងខ្លះ ពុទ្ធបរិស័ទក្រោកពីប្រលឹមបាចបាយបិណ្ឌនៅតាមខឿនព្រះវិហារ ដោយគេយល់ថា ពួកប្រេតតែងតែមកពេលងងឹតរកចំណីបរិភោគ។ គេធ្វើបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះ ក្នុងខែរនោច ព្រោះគេយល់ថា ពួកប្រេតចេញដើររកចំណីពេលងងឹត។ ប៉ុន្តែកម្ពីរព្រះពុទ្ធសាសនា ផ្នែកព្រះសូត្របញ្ជាក់ថា អ្នកស្លាប់ដែលអាចទទួលផលបានដោយសារក្រុមគ្រួសារញាតិមិត្តធ្វើបុណ្យឧទ្ទិសទៅ គឺពួកមនុស្សសត្វដែលបានទៅកើតជាប្រេត។


www.elibraryofcambodia.org

នៅក្នុងពេលកាន់បិណ្ឌ និងភ្ជុំបិណ្ឌនោះ ព្រះសង្ឃ និងពុទ្ធបរិស័ទតែងតែសូត្រនូវសូត្រមួយ ហៅថា **បរាភវសូត្រ** ។ បានជាយកសូត្រនេះមកសូត្រធ្វើជាបទផង ព្រោះសូត្រនេះមានប្រយោជន៍ ក្នុងការរោរប្រចាំថ្ងៃរបស់មនុស្ស។ វាជាសូត្រមួយដែលពួកទេវតាទូលសួរព្រះពុទ្ធអំពីធម៌ ដែលនាំឲ្យមានសេចក្តីវិនាស ដែលផ្ទុយគ្នាពី **មង្គលសូត្រ** ដែលពោលអំពីធម៌ដែលនាំឲ្យមានសេចក្តីចម្រើន។

បរាភវសូត្រធម៌ ដែលនាំឲ្យសេចក្តីវិនាសមានជាអាទិ៍ថា "អ្នកស្រលាញ់ធម៌នាំឲ្យចម្រើន អ្នកស្អប់ធម៌នាំឲ្យវិនាស អ្នកសេពគប់អសប្បុរស អ្នកដេកច្រើន និយាយច្រើន អ្នកមានព្រទ្យច្រើន មិនចិញ្ចឹមមាតាបិតាដែលចាស់ជរា អ្នកប្រព្រឹត្តល្បែងបីប្រការ គឺល្បែងស្រី ល្បែងស្រា ល្បែងភ្នាល់មាន់ទាំងឡាយជាដើម ទាំងអស់នេះជាប្រធាននៃក្តីវិនាស។

បុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះមានខ្លឹមសារជាពិសេសគឺ ការឧទ្ទិសកុសលជួយរំដោះទុក្ខដល់ញាតិមិត្ត ក្រុមគ្រួសារមានមាតាបិតាជាដើម ដែលចែកឋានទៅ ក្រែងទៅកើតទីណាមួយ មានទុក្ខវេទនា ដោយមានអត្ថបទបុរាណខ្មែរពោលថា ស្តេចយមរាជបានដោះលែងសត្វនរក ឬ ប្រេត ក្នុងឱកាសបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនោះ ឲ្យទៅរកបងប្អូន កូនចៅ ក្រែងធ្វើបុណ្យកុសល ឧទ្ទិសឲ្យខ្លួន។ រហូតមានអត្ថបទខ្លះនិយាយថា បើរកមិនឃើញញាតិមិត្តណាធ្វើបុណ្យឧទ្ទិសឲ្យទេ ប្រេតនឹងយំសោកបោកខ្លួន ដោយសេចក្តីស្រេកឃ្លាន ហើយក៏ប្រទេចផ្តាសាដល់ញាតិមិត្ត បងប្អូន កូនចៅរបស់ខ្លួនដែលមានចិត្តអាក្រក់ ពុំនឹកនាដល់សេចក្តីទុក្ខវេទនារបស់ខ្លួន។

ដូច្នេះ បុណ្យនេះចាត់ទុកជាបុណ្យឧទ្ទិសកុសល ជួយរំលែកទុក្ខ ក្រែងជាតិកំណើតណាមួយ បានធ្វើអំពើបាប ហើយធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិ។

បុណ្យនេះមានអត្ថន័យសំខាន់មួយ គឺការពិចារណានូវសង្សារវដ្ត ពោលគឺមនុស្សកើតមក តែងតែស្លាប់ទៅវិញ បើដូច្នោះ ត្រូវជំរុញទឹកចិត្តឲ្យលះបង់នូវអំពើបាប ហើយសាងតែអំពើល្អ ព្រោះខ្លាចធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិទាំង ៤ មាននរកជាដើម ។


www.elibraryofcambodia.org

តាមការស្រាវជ្រាវ បុណ្យនេះពុំទាន់ដឹងប្រាកដថា កើតក្នុងសម័យណាទេ។ នៅសម័យពុទ្ធកាល គេទំនុកបម្រុងព្រះសង្ឃដោយបច្ច័យ ៤ ក្នុងរយៈកាល ៣ ខែ ពេលដែលព្រះសង្ឃចូល ព្រះវស្សានោះតែម្ដង។ ខ្លះថា បុណ្យនេះយកតាមលំនាំរឿងប្រេតជាញាតិរបស់ព្រះបាទពិម្ពាសារ នៅក្នុងកម្ពីរធម្មបទ ដោយមានសេចក្ដីដំណាលសង្ខេបថា នៅពេលដែលព្រះបាទពិម្ពិសារបាននិមន្ត ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានមកទទួលចង្ហាន់ ព្រះអង្គពុំបានតាំងព្រះទ័យឧទ្ទិសកុសល ដល់ព្រះញាតិរបស់ព្រះអង្គទេ ពួកព្រះញាតិដែលទៅកើតជាប្រេត បានបន្លឺសម្លេងយំស្រែក ជុំវិញ ព្រះរាជវាំង ជាសញ្ញាទាមទារផលបុណ្យ ព្រោះខ្លួនមានទុក្ខវេទនាអត់ឃ្លានជាយូរមកហើយ។ ព្រះបាទពិម្ពិសារទូលសួរព្រះពុទ្ធជាម្ចាស់ថា "តើសម្លេងនោះជាសម្លេងអ្វី?" ព្រះពុទ្ធត្រាស់ថា "សម្លេងនោះ ជាសំម្លេងពួកប្រេតជាញាតិរបស់ព្រះអង្គ ពួកគេយំស្រែកព្រោះមហារាជពុំបានផ្សាយកុសលដល់ ពួកគេ។" ព្រះបាទពិម្ពិសារ បានជ្រាបហេតុការណ៍នេះហើយ ទើបព្រះអង្គប្រញាប់ប្រញាល់ធ្វើបុណ្យដូចគ្នានេះជាលើកទីពីរ ហើយតាំងចិត្តឧទ្ទិសកុសលដល់ពួកប្រេតជាញាតិ។ ចាប់ពីពេលនោះមក សម្លេងស្រែកក៏បាត់ស្ងាត់អស់ទៅ ជាភ័ស្តុតាងបញ្ជាក់ថា ពួកប្រេតញាតិបានទទួលផលបុណ្យនេះហើយ។ បុណ្យនេះពុំមែនឧទ្ទិសចំពោះតែសត្វដែលកើតជាប្រេតនោះឡើយ ព្រោះពាក្យថា *ប្រេត* ជាពាក្យសំស្ក្រឹត (បាលីថា *បេត*) ប្រែសេចក្ដីជាខ្មែរថា អ្នកទៅកាន់បរលោក ឬអ្នកដែលធ្វើមរណកាលទៅកាន់បរលោក។ ពាក្យនេះប្រើជានាម សម្ដៅយកសត្វប្រេតក្នុងអបាយ-ភូមិ។ ប្រើជាគុណនាម សំដៅយកមនុស្សដែលស្លាប់ទៅហើយ។

នៅល្ងាចថ្ងៃទី ១៥ រោច ខែភទ្របទ នៃថ្ងៃភ្ជុំបិណ្ឌានោះ ប្រជាពលរដ្ឋខ្មែររៀបចំសែនជូនតា ដោយពីធីផ្សេងៗ ក្រៅព្រះពុទ្ធសាសនាខ្លះ គឺនៅវេលាល្ងាចនោះ មានរៀបចំកន្ទេលខ្មើយ ក្រាលសំពត់ ពីលើកន្ទេល ដាក់នំចម្កាបមួយថាស បង្អែមមួយថាស មានក្រាស ម្សៅជាដើម ហើយឲ្យកូនចៅ ច្រូចទឹកលើបង្អែមនោះ ប្រតិស្ឋអធិដ្ឋានជូនទៅជូនតា។ លុះព្រឹកឡើងថ្ងៃ ១ កើតខែអស្សុជ មានធ្វើ ទូកស្រទបចេកដាក់នំចំណីអុជទៀនធូប បណ្ដែតលើខ្នងទឹកទន្លេស្ទឹងព្រែក ឬអូរតាមស្ថានភាពនៃ ស្រុកនីមួយៗ


www.elibraryofcambodia.org

បញ្ជូនដូនតាទៅស្រុកវិញ។ ពិធីទាំងអស់នេះ មកដល់បច្ចុប្បន្ននេះ ហាក់ដូចជាបាត់បង់ទៅហើយ ពុំសូវឃើញមានធ្វើដូចពីដើមទេ។ វាអាចមានធ្វើខ្លះនៅតាមជនបទ។ ទោះបីជា វានៅក្រៅពិធីនេះ ក្រៅព្រះពុទ្ធសាសនា ប៉ុន្តែវាមានន័យរំលឹកគុណ ដូចក្នុងព្រះពុទ្ធសាសនាដែរ។

បុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌនេះមានអត្ថន័យសំខាន់ណាស់ ក្នុងប្រពៃណីខ្មែរ ក្នុងចំណងសាមគ្គីភាព ភាតរភាព មេត្រីភាព ទោះបីជាញាតិមិត្តបែកឋានទៅហើយក៏ដោយ ក៏កូនចៅនៅតែ នឹករលឹកតបគុណជួយរំដោះទុក្ខដែរ។

## ១៤
## បុណ្យចេញព្រះវស្សា

កាលបើគង់ចាំព្រះវស្សា ៣ ខែ ហើយ ព្រះសង្ឃត្រូវបវារណាចេញព្រះវស្សា នៅថ្ងៃ ពេញ បូណ៌មី ខែអស្សុជ។

ក្នុងថ្ងៃជាមួយគ្នានោះ នៅក្នុងព្រះបរមរាជវាំង ពួកបារគូធ្វើពិធីអញ្ជើញទេវរូប (ព្រះឥសូរ ព្រះនាងឧមា ព្រះគណេស ព្រះនារាយណ៍ និងពលទេព) ចេញព្រះវស្សាដែរ។

នៅថ្ងៃនោះ នៅគ្រប់ទីវត្ត ព្រះសង្ឃជួបជុំគ្នា ធ្វើកិច្ចបវារណាចេញព្រះវស្សា គឺសុខមាលទោស កំហុសរបស់ខ្លួនគ្រប់ព្រះអង្គ។ ចំណែកទាយក ទាយិកា ក៏ជ្រះថ្លាធ្វើទានប្រគេនព្រះសង្ឃឯវត្ត តាមទំនៀមទម្លាប់ គឺធ្វើចំពោះព្រះសង្ឃដែលខ្លួនបានចាប់ស្លាកកាន់អង្គតាំងពីថ្ងៃភ្ជុំមក។



www.elibraryofcambodia.org

ក្រោយពេលព្រះសង្ឃសូត្របវារណា គេនិមន្តលោកទេសនាមហាជាតក (ព្រះវេស្សន្តរ) គឺជាតិដែលព្រះបរមគ្រូទ្រង់ធ្វើមហាបរិច្ចាគ ព្រោះព្រះអង្គទ្រង់ដាក់ទានទាំងព្រះរាជទេពី និង ព្រះរាជ បុត្រាបុត្រីដល់ជូជក។

នៅយប់ពេញបូរមីណ៍ខែអស្សុជនោះ អ្នកស្រុកនាំគ្នាបណ្តែតប្រទីប ឬ លយប្រទីប ដែលធ្វើអំពីដើមចេកដោតភ្ជាប់គ្នាជាក្បូន។ ក្បូននេះ ជួនកាល មានរាងធំសម្បើម ហើយមានធ្វើរាងជាសាលា ជាព្រះចូឡាមណីចេតិយ មានគោមរាងកន្សោមតាឪនៅត្រង់កំពូលផង។ គេផ្ទុកនំនែកផ្សេងៗ ហើយគេនាំគ្នាសែងក្បូននោះទៅមាត់ទឹក គេនិយាយឧទ្ទិសបូជាប្រទីបនេះចំពោះព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ។ ចំណែកឯជនសាមញ្ញក៏សូត្រនមស្ការស្នាមព្រះពុទ្ធបាទ និងនិយាយសុំខមាទោសព្រះគង្គា និងព្រះធរណី ដោយខ្លួនបានបន្ទោបង់នូវវត្ថុកខ្វក់ផ្សេងៗក្នុងឆ្នាំនោះស្រេចហើយ ទើបនាំគ្នាអូសក្បូនទម្លាក់ទឹកទៅ។

តាមធម្មតា មុននឹងបណ្តែតប្រទីបទៅតាមខ្សែទឹកហូរ គេច្រើនយកទូករចនាដោយភ្លើផ្កា យ៉ាងវិចិត្រ ទៅសណ្តោងប្រទីប ហែរជាក្បូននៅកណ្តាលទន្លេ ហើយមាននិមន្តព្រះសង្ឃគង់ក្នុងទូក ងនោះទៀត។ នៅភូមិខ្លះអ្នកស្រុកមាននាំគ្នាលេងប្រណាំងទូកងទៀត។

ទំនៀមលយប្រទីបនេះ មានប្រភពច្រើនបែបណាស់ ប៉ុន្តែមានប្រភពពីរ ដែលគេដឹងច្រើនជាងគេ។ រឿងទី១ថា គេធ្វើបុណ្យបណ្តែតប្រទីប ដើម្បីបូជាចំពោះព្រះចង្កូមកែវ ដែលប្រតិស្ឋានទុក នៅឯពិភពនាគឯនោះ។ រឿងទី២ថា វាជាបុណ្យរំលឹកថ្ងៃដែលស្តេចកុជង្គនាគសុំឲ្យព្រះពុទ្ធអង្គទ្រង់ប្រតិស្ឋានស្នាមព្រះបាទទុកជាទីគោរពសក្ការៈ នៃពពួកសត្វទាំងឡាយ។

ចំណែកឯបុណ្យអុំទូក ដែលត្រូវធ្វើក្រោយចេញព្រះវស្សាមួយខែទៀតនោះក៏មានសេចក្តីអធិប្បាយអំពីជំនឿដូចគ្នានឹងរឿងលយប្រទីបចេញវស្សានេះដែរ។



www.elibraryofcambodia.org

## ១៥

# ប្រពៃណីបុណ្យកឋិន

ពាក្យថា "កឋិន" ជាពាក្យបាលី សំដៅយកំណាត់ ដែលភិក្ខុសង្ឃសម័យបុរាណប្រើសម្រាប់ ដេរសំពត់ធ្វើជាស្បង់ចីវរ។ សំពត់ដែលបានរៀបតាក់តែងនោះ មានឈ្មោះថា "សំពត់កឋិន"។

បើតាមអដ្ឋកថា ព្រះពុទ្ធទ្រង់បានបញ្ញត្តទុកមកថា កឋិន គឺជាការប្រជុំរួម រូបធម៌ និងនាមធម៌ ដែលប្រព្រឹត្តទៅក្នុងន័យពីរយ៉ាងគឺ៖

ក) រស់បានដោយកម្រ គឺសភាវៈឯណារស់នៅបានដោយកម្រ សភាវៈនោះហៅថា *កឋិន* ។ ព្រោះលោកប្រៀបប្រដូចជាឈើស្ងួត ដែលបុគ្គលគាត់ចាកពីដើម ហើយ យកទៅបោះភ្ជាប់នឹងដី រមែង ដុះលូតលាស់ ឬរស់នៅដោយកម្រយ៉ាងណា ឯកិច្ចដែលនឹងកើតឡើង ឬក៏តាំងឡើងជាកឋិនពេញទី គឺបានដោយកម្រពន់ពេកណាស់ ក៏យ៉ាងនោះដែរ។

ខ) ពោលដោយសរសើរ ព្រោះចីវរទានដែលយើងបានកសាងជាកឋិននោះ ជាទានវិសេស ជាងទានដទៃ ដែលព្រះអរិយទាំងឡាយមានព្រះពុទ្ធជាប្រធានតែងពោលសរសើរថា ជាទានវិសេស អាចរួបរួម ឬសង្គ្រោះនូវអានិសង្ស ៥ យ៉ាងរបស់ភិក្ខុអ្នកក្រាលគ្រង មិនឲ្យទៅគ្រងនៅទីទៃបាន។

**១- ប្រភពនៃកឋិនទាន**

វិន័យបិដកចែងអំពីប្រភពនៃកឋិនទានក្ខន្ធកថា ៖

ក្នុងបឋមពោធិកាល ដែលព្រះបរមសាទ្រង់ឲ្យភិក្ខុប្រើប្រាស់តែបង្សុកូលចីវរ ពុំទាន់ឲ្យប្រើគហបតីចីវរនៅឡើយ សម័យមួយ កាលដែលទ្រង់គង់ចាំព្រះវស្សានៅវត្តជេតពន។ ជិតដល់ថ្ងៃចូលវស្សា ព្រះសង្ឃ ៣០ អង្គ នៅស្រុកបាវា ប្រាថ្នាចង់មកថ្វាយបង្គំព្រះអង្គមុនថ្ងៃចូលវស្សា។ តែមកមិនទាន់ ក៏ចូលវស្សានៅជនបទមួយត្រង់កណ្តាលផ្លូវ។ ដល់បវារណាចេញវស្សាហើយ ទើបព្រះសង្ឃ ទាំងនោះនាំគ្នាមយមកថ្វាយបង្គំ



www.elibraryofcambodia.org

ព្រះអង្គ។ ដោយពេលដែលភិក្ខុមកនោះ ភ្លៀងច្រើនពេក ភក្ខុទាំងនោះមានស្បង់ចីវរទទឹកជោគដោយទឹកភ្លៀង ហើយដោយហេតុតែចង់ឃើញព្រះភក្ត្រព្រះអង្គឆាប់ៗ ក៏នាំគ្នាទៅថ្វាយបង្គំទាំងស្បង់ចីវរទទឹកនោះ។ ព្រះអង្គទតឃើញដូច្នេះ ក៏ទ្រង់អនុញ្ញាតឲ្យភិក្ខុក្នុងព្រះពុទ្ធសាសនាទទួលសំពត់កឋិន ដែលជាគហបតីចីវរបានហើយ ទ្រង់អនុញ្ញាតថា ភិក្ខុដែលបានទទួលក្រាលគ្រងបានទទួលអនុមោទនាកឋិននោះ ត្រូវបាននូវអនិសង្ស ៥ យ៉ាង។ ភិក្ខុក្នុងព្រះពុទ្ធសាសនា ក៏បានទទួលកឋិនចីវរ អំពីគហបតីតាំងពីពេលនោះមក។

## ២- បុគ្គលទទួលផលពីកឋិនទាន

កឋិនទាននេះអាចសម្រេចដល់បុគ្គលទាំងពីរផ្នែកគឺ៖

១- ទាយកទាយិកា ដែលជាអ្នកឲ្យ ត្រូវបានទទួលអានិសង្សច្រើន ក្នុងអនាគតកាល មានការទទួលសម្បត្តិ ក្នុងឋានទេវលោកជាដើម។

២) បដិគាហក ដែលជាភិក្ខុ អ្នកក្រាលគ្រងកឋិន ឬបុគ្គល ឬគណៈ ឬសង្ឃដែលបាន អនុមោទនា ក៏ត្រូវបានសម្រេចអានិសង្ស ៥យ៉ាង ពេញលេញគ្រប់គ្រាន់ដរាបដល់រយៈនៃកឋិនខេត្ត។

ការកុសលដែលធ្វើដោយនាំសំពត់ ចីវរ ទៅប្រគេនព្រះសង្ឃ ដែលបានគង់ចាំវស្សាអស់ ត្រីមាស ក្នុងអាវាសណាមួយ ក្នុងវេលា ២៩ ថ្ងៃ គឺតាំងពី ១ រោច ខែអស្សុជ ទៅទល់នឹង ១៥ កើត ខែកត្តិក ឲ្យលោកក្រាលគ្រង ដើម្បីលោកបាន អានិសង្ស ៥ តាមពុទ្ធានុញ្ញាត ហៅ *បុណ្យកឋិន* ឬ *កឋិនទាន* ។

## ៣- កឋិនទានជាទានពិសេស ប្លែកពីទានទាំងពួង

កឋិនទានជាទានប្លែកពីទានទាំងពួង ដោយហេតុ ៥ យ៉ាងគឺ៖

១- **ប្លែកដោយកាល៖** គឺបុណ្យនេះមិនអាចធ្វើរាល់ខែបានទេ ដោយមានពុទ្ធានុញ្ញាត ជាពិសេសថា ១ ឆ្នាំធ្វើតែរវាង ២៩ ថ្ងៃ គឺតាំងពីថ្ងៃ ១ រោច ខែអស្សុជ ទៅដល់ថ្ងៃពេញបូរមី ខែកត្តិក ប៉ុណ្ណោះ។ ក្នុងរយៈពេល ២៩ ថ្ងៃនេះ ពុទ្ធបរិស័ទធ្វើក្នុងថ្ងៃណាមួយក៏បាន ហើយមួយវត្តធ្វើបានតែ មួយដង ក្នុងមួយវស្សា។


www.elibraryofcambodia.org

**២- ប្លែកដោយវត្ថុ៖** គឺសំពត់ដែលជាកឋិនវត្ថុ បានតែស្បង់ ឬចីវរ ឬក៏សង្ឃាដី ដែលត្រឹមត្រូវ តាមពុទ្ធប្បញ្ញត្តិប៉ុណ្ណោះ ក្រៅពីនេះពុំបាន សូម្បីវត្ថុទាំងបីនេះនឹងធ្វើទាំងបីមុខជាអង្គកឋិន ១ ក៏ពុំបាន គឺបានតែមួយមុខក្នុងកឋិន ១ ទោះបីទាយកទាយិកាវេរចីវរ ១ ត្រៃជាសំពត់កឋិន ក៏លោក អ្នកក្រាលគ្រង លោករើសយកវត្ថុណាមួយប៉ុណ្ណោះធ្វើជាអង្គកឋិន ស្រេចតែលើព្រះទ័យលោក លោក ចង់យកស្បង់ជាអង្គកឋិនក៏បាន ចីវរក៏បាន សង្ឃាដីក៏បាន ឲ្យតែវត្ថុនោះត្រឹមត្រូវតាមវិន័យប្បញ្ញត្តិ។

**៣- ប្លែកដោយអំពើ៖** គឺបុគ្គលអ្នកធ្វើគប្បីធ្វើឲ្យត្រឹមត្រូវតាមវិន័យប្បញ្ញត្តិ ហើយសង្ឃក៏ គប្បីក្រាលគ្រងឲ្យត្រឹមត្រូវតាមវិន័យប្បញ្ញត្តិដែរ ទើបកើតជាកឋិនត្រឹមត្រូវ បានអានិសង្ស។

**៤- ប្លែកដោយអានិសង្ស៖** គឺបុគ្គលអ្នកធ្វើ ក៏បានអានិសង្ស ៥ យ៉ាង[48] ដូចមានចែងក្នុងវិនយបិដកភាគ ៥ ត្រង់កឋិនទានក្ខន្ធកៈនោះសព្វគ្រប់ស្រាប់។

**៥- ប្លែកដោយបដិគាហកៈ** (អ្នកទទួល) គឺបានតែភិក្ខុ ក្រៅពីនេះពុំបានឡើយ ឯ ភិក្ខុទៀត សោត លុះតែបាននៅចាំវស្សាអស់បីខែទើបបាន។

### ៤- កិច្ចធ្វើសំពត់កឋិន

តាមពុទ្ធានុញ្ញាត សំពត់ដែលជាវត្ថុនៃកឋិននោះ ទោះជាសំពត់ថ្មីក៏បាន សំពត់ជំនំដែលបោកស្អាតក៏បាន សំពត់បង្សុកូលក៏បាន សំពត់ធ្លាក់ក្នុងចន្លោះរានផ្សារក៏បាន ដែលអ្នកណាមួយ ជាគ្រហស្ថ ក៏ដោយ ជាសហធម្មិក[49] ក៏ដោយ បានវេរប្រគេនសង្ឃហើយ សុទ្ធតែជាសំពត់គួរក្រាលកឋិនបានទាំងអស់។ ម្យ៉ាងទៀត សំពត់ដែលមានបរិកម្មស្រេចហើយ គឺសំពត់ដែលទាយកបានកាត់ដេរជា ស្បង់ចីវរ ជាសង្ឃាដីជ្រលក់ពណ៌ត្រឹមត្រូវស្រេចហើយ យកមកវេរចំពោះព្រះសង្ឃ ដើម្បីឲ្យសង្ឃ ក្រាលគ្រងស្រេចតែម្តងនោះ សង្ឃអាចក្រាលគ្រងបាន មិនបាច់រុះរើកាត់ដេរជ្រលក់ទៀតទេ ដូចយ៉ាងកុលបុត្រដែលមានសទ្ធាជ្រះថ្លា បើស្បង់ចីពរចូលមកសួរបុព្វជ្ជា ទាំងសក់មិនទាន់

[48] បើចង់ជ្រាបអានិសង្ស ៥ សូមមើលក្នុងវិន័យបិដក ភាគ ៨ ត្រង់កឋិនក្ខន្ធនៈនោះ។

[49] អ្នកប្រព្រឹត្តធម៌ជាមួយគ្នា៖ មាន ៥ ភិក្ខុ សាមណេរ សាមណេរី សិក្ខាមានា ។


www.elibraryofcambodia.org

គោរនោះ ឧបជ្ឈាយ៍ត្រូវតែគោរសក់ចេញ ទើបបំបួសបាន បើគេគោរសក់រួចហើយ ឧបជ្ឈាយ៍ត្រូវតែបំបួសឲ្យតែម្តង មិនចាំបាច់គោរសក់ទៀតទេ ឯសំពត់កឋិនក៏ដូច្នេះដែរ បើទាយកគេធ្វើត្រឹមត្រូវស្រេចហើយ សង្ឃស្រាប់តែទទួលក្រាលគ្រងតែម្តង បានគ្មានកិច្ចត្រូវធ្វើទៀតឡើយ។

អាស្រ័យដោយមានពុទ្ធានុញ្ញាតដូច្នេះ បានជាសម័យបច្ចុប្បន្ននេះ ទាយក អ្នកធ្វើកឋិន តែងតែធ្វើដោយត្រៃចីវរ គឺស្បង់ ចីវរ សង្ឃាដី ដែលជ្រលក់បានពណ៌ត្រឹមត្រូវហើយ គេដង្ហែទៅប្រគេនព្រះសង្ឃ ដែលគង់ចាំវស្សាអស់ ៣ ខែ នៅវត្តណាមួយតាមតែគេត្រូវការ ហើយចំណែកឯព្រះសង្ឃ នោះសោត កាលបានទទួលត្រៃចីវរនោះមក លោកជ្រើសរើសយកតែស្បង់ ឬ ចីវរ ឬក៏ សង្ឃាដី ធ្វើជាអង្គកឋិន ក្រាលគ្រង និងអនុមោទនាទៅតាមពុទ្ធានុប្បញ្ញត្តិ។

### ៥- កិច្ចសុំវត្តធ្វើកឋិន

កាលទាយកជាម្ចាស់កឋិន គេចាត់ចែងធ្វើសំពត់កឋិនបានហើយ ប្រើត្រូវការហែចូលវត្តណា គេទៅទូលសុំវត្តនោះដល់លោកគ្រូចៅអធិការ ឲ្យលោកជ្រាបជាមុនថា ខ្លួននឹងហែកឋិនចូលមកនូវថ្ងៃ ទី ខែ តាមដែលត្រូវការ។ កាលបើលោកគ្រូចៅអធិការយល់ព្រមហើយ គេក៏កំណត់ថា នឹងហែមក តាមកាលបរិច្ឆេទនោះ។

### ៦- កិច្ចផ្សាយដំណឹងបុណ្យកឋិន

នៅសម័យបុរាណកាល គេកំណត់ថា នឹងហែចូលទៅវត្តណាដោយបានទូលដំណឹងដល់លោកវត្តនោះហើយ គេប្រាប់ដោយមាត់ទទេដល់ញាតិមិត្តជិតឆ្ងាយ និងអ្នកចំណុះជើងវត្តជាមួយ ឲ្យជួយអនុមោទនា តែសម័យបច្ចុប្បន្ន គេប្រាប់ដោយបោះពុម្ពកម្មវិធី ( សេចក្តីជូនដំណឹង ) បុណ្យកឋិននោះ។

### ៧- កិច្ចសូត្រមន្តកឋិន

កាលដល់ថ្ងៃសូត្រមន្ត បើគេត្រូវការសូត្រនៅវត្ត គេក៏រៀបចំនៅវត្ត បើគេត្រូវការសូត្រនៅផ្ទះ គេក៏រៀបចំនៅផ្ទះ។ ឯរបៀបរៀបចំនោះ គេរៀបចំទេយ្យទាន ២ ចំណែក គឺ៖


www.elibraryofcambodia.org

១- សម្រាប់អ្នកក្រាលគ្រងកឋិន ១អង្គ មួយចំណែក និង

២- សម្រាប់លោកអ្នកសូត្រញត្តិកឋិន ២ អង្គ ពីរចំណែក។

ចំណែកទី១ រៀបចំចីវរមួយត្រៃ ព្រមទាំងអង្សក វត្ថពន្ធតម្កល់លើតុ ឬតោកមួយ ដោយមាននោបបួស្សីឬបន្ទះក្តារដាជើងទ្រដាក់គងពីលើមាត់តុឬតោកនោះ ហើយមានបន្ទះក្តារ ស្រែះអង្គាំស្រោបពីលើជាអង្គកឋិនសម្រាប់លោកអ្នកក្រាលគ្រង មួយអង្គ។

ចំណែកទី ២ រៀបតុ ឬតោកពីរទៀត មួយតម្កល់ចីវរ ១ លៀង គឺស្បង់ចីវរ ១ ដោយមាននោបបួស្សីឬបន្ទះក្តារជាជើមទ្រនិងមានបន្ទះក្តារស្រែះអង្គាំស្រោបពីលើដូចគ្នា រៀបដាក់បន្ទាប់ពីតុត្រៃអង្គ កឋិននោះ សម្រាប់លោកសូត្រញតិពីរអង្គ។

ក្រៅពីនេះ មានរបៀបគ្រឿងបរិក្ខាជាបរិវារកឋិនទៀត។ គ្រឿងបរិក្ខានោះ គេរៀបជា ៤ ចំណែក៖

១- សម្រាប់លោកអ្នកក្រាលគ្រងមួយចំណែក

២- សម្រាប់លោកអ្នកសូត្រញត្តិ ២ អង្គ ពីរចំណែក

៣- សម្រាប់លោកអ្នកគង់ហត្ថបាសតាមចំនួន

៤- សម្រាប់លោកសាមណេរតាមចំនួនទាំងបួនចំណែក នោះមានរៀបខុសៗគ្នាតាមថ្នាក់គឺ៖

- របៀបទី១៖ សម្រាប់លោកអ្នកក្រាលគ្រង ១អង្គ មានបាត្រ ឆ័ត្រ ផ្តិល កំសៀវទឹក ចានស្រាក់ ចានថ្ម ស្លាបព្រា កន្សែងដៃ មុង កន្ទេល ខ្នើយ គ្រែសឹង គ្រែទេសន៍។ សម័យបុរាណ គេមិន បានបានធ្វើ **ក្រាំងបវានបាតិមោក្ខ** ទេ តែសម័យបច្ចុប្បន្ន គេដាក់សៀវភៅធម៌ផ្សេងៗ សៀវភៅសរសេរ ទឹកខ្មៅ ខ្មៅដៃ ស្លាបប៉ាការ ។ល។

- របៀបទី២៖ សម្រាប់លោកអ្នកសូត្រញត្តិ ២អង្គ មានកន្ទេល ខ្នើយ ឆ័ត្រ ស្បែកជើង ។ល។

- របៀបទី៣៖ សម្រាប់លោកភិក្ខុ បរិស័ទដែលគង់ហត្ថបាស មានស្បង់ ១ និង បរិក្ខារាយរង ១ ប្រដាប់ ១អង្គ តាមចំនួនដែលមានក្នុងវត្តនោះ។



www.elibraryofcambodia.org

- របៀបទី៤៖ សម្រាប់លោកសាមណេរ មានស៊ំពត់សាដក ១ និងបរិក្ខារាយរង ១ ប្រដាប់ ១ អង្គ តាមចំនួនដែលមាននៅក្នុងវត្តនោះ។

ប្រដាប់ ៤ ចំណែកនោះ គេរៀបខ្ចប់ជាកញ្ចប់ៗ ដោយក្រដាសក្លីរលោង មើលឃើញឥវ៉ាន់ ខាងក្នុងគួរឲ្យជ្រះថ្លា។

**៨- កិច្ចសូត្រសុន្ទរកថា**

លុះដល់វត្តដែលត្រូវការនោះហើយ អ្នកដើមបុណ្យជាស្ត្រីទូលត្រៃអង្គកឋិន ឯអ្នកផ្ដើមបុណ្យប្រុសកាន់បាត្រឬបរិក្ខា ពួកញាតិមិត្តខ្លះកាន់បរិក្ខាផ្សេងៗ ខ្លះសែងសង្ឃិកបរិក្ខារ ដើរដង្ហែប្រទក្សិណព្រះវិហារ ៣ ជុំ ទើបទូលត្រៃចូលក្នុងព្រះវិហារ ដាក់ត្រៃអង្គកឋិនចំពោះមុខព្រះសង្ឃក្នុង **ហត្ថបាស** [50] ដាក់គ្រឿងបរិក្ខារផ្សេងៗក្នុងទីជិតៗនោះហើយ គេនាំគ្នាថ្វាយបង្គំព្រះ សមាទានសីលរួច អ្នកដើមបុណ្យ ឬ អ្នកតំណាងក្រោកឈរឡើង សូត្រសុន្ទរកថាពណ៌នាដំណើរបុណ្យ ដែលមានសេចក្ដីជាអាទិ៍ ៖

**សុន្ទរកថាបុណ្យកឋិន**

បរពិត ព្រះករុណាគ្រប់ព្រះអង្គ អស់លោកអ្នកសប្បុរសទាំងឡាយ ខ្ញុំព្រះករុណាខ្ញុំ តាងនាម អ្នកផ្ដើមបុណ្យ (ឬ ជាអ្នកផ្ដើមបុណ្យ បើអ្នកផ្ដើមបុណ្យសូត្រខ្លួនឯង) សូមឱកាសពណ៌នាដោយ សង្ខេបនូវមូលហេតុ នៃបុណ្យកឋិននេះ ប្រគេន និងជូនជាដំណឹងដល់ព្រះករុណាគ្រប់ព្រះអង្គ និងអស់លោកអ្នកសប្បុរសឱ្យបានជ្រាបដូចតទៅ៖

**បុណ្យកឋិននេះកើតឡើងដោយហេតុ ៤ យ៉ាង ៖**

១- ដោយហេតុយើងខ្ញុំស្ដាប់ព្រះធម៌ ព្រះវិន័យព្រះពុទ្ធសាសនា បានដឹងថាកឋិនទាន ជាកាលទានមានផលពិសេសជាងទានទាំងពួង ព្រោះបានដល់ម្ចាស់ទាន និង បានអានិសង្សដល់ភិក្ខុ ក្នុង **បដិគ្គាហកៈ** អ្នកទទួលក្រាលគ្រង និងអ្នកអនុមោទនា

---

[50] តាមព្រះវិន័យហត្ថបាសប្រគេន មានពួក ២ ហត្ថមួយចំអាម គឺត្រូវគិតពីទីបំផុត ខាងក្រៅនៃព្រះសង្ឃ មកជា ១ហត្ថ ទីបំផុតអង្គុយខាងមុខឧបាសក ទៅ ១ហត្ថ១ចំអាម រួមជា ២ ហត្ថ និង១ចំអាម គឺថាគ្រងដាក់ចីវរកឋិនឱ្យនៅត្រង់ចន្លោះទីបំផុត អង្គុយខាងមុខលោកដើមអាសាន៍ត្រឹម ១ហត្ថ ១ចំអាម។



www.elibraryofcambodia.org

ផង។

២- ដោយហេតុយើងខ្ញុំបានឃើញព្រះសង្ឃដែលគង់ចាំព្រះវស្សា ក្នុងវត្តនេះ បានរៀនសូត្រ ធម៌វិន័យបានប្រព្រឹត្តត្រឹមត្រូវតាមច្បាប់ព្រះពុទ្ធសាសនា។

៣- ដោយហេតុយើងខ្ញុំ បានឃើញវត្តនេះកំពុងមានការកសាងទីសេនាសនៈ។

៤- ដោយហេតុយើងខ្ញុំគិតពិចារណាឃើញថា អាយុសង្ខារបស់ខ្លួនមិនទៀងទាត់បិតថេរ។

ទើបបានផ្តើមធ្វើបុណ្យកឋិនទាននេះឡើង ដោយបានជូនដំណឹងដល់អស់លោក/អ្នក ជាញាតិមិត្តជិតឆ្ងាយឲ្យជួយអនុមោទនាផង។ អស់លោកអ្នកសប្បុរសបានជួយឧបត្ថម្ភដោយកម្លាំងធនធានផង និង កម្លាំងកាយវាចាចិត្តផង បានកើតជាកឋិនទានដ៏ឧឡារិកអធិកអធមឡើង ដូចព្រះករុណា គ្រប់ព្រះអង្គ និង អស់លោកសប្បុរសទាំងឡាយបានទស្សនាឃើញជាក់ស្តែងនេះ។

### ៩- កិច្ចវេរសំពត់កឋិន

លុះចប់សន្ទរកថា

ឧបាសកឧបាសិកាទាំងអស់អង្គុយបត់ជើងបែរមុខឆ្ពោះទៅព្រះសង្ឃ លើកដៃប្រណម្យឡើង ហើយអ្នកដើមបុណ្យ អាចារ្យនាំសូត្រនមោ ៣ ដង រួចវេរសំពត់កឋិន ៣ លើក រួចទើបទាយកវេរប្រគេនកឋិនថា "*បពិត្រព្រះតម្លៃងសង្ឃដ៏ចម្រើនអើយ រីកឋិននៃយើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណាបានទទួលកាន់យកហើយ យើងខ្ញុំទាំងឡាយសូមវេនវគ្រឿងបរិក្ខាជាបរិវារ នៃកឋិនទាំងឡាយ ប្រគេនដល់លោកម្ចាស់អង្គនោះ។*"

កាលវេរដោយវាចាហើយ គប្បីតម្កល់សំពត់កឋិននៅចំពោះមុខព្រះសង្ឃក្នុងហត្ថបាស គឺ ប្រវែង ២ហត្ថ និង ១ចំអាម ពីលោកមិនបាច់ប្រគេនដោយដៃទេ ព្រោះវិន័យមានចែងថា គប្បីប្រគេន តែដោយវាចា មិនគប្បីប្រគេនដោយកាយឡើយ។

កាលទាយកវេរសំពត់កឋិន ព្រមទាំងគ្រឿងបរិក្ខារជាបរិវារកឋិនហើយ ព្រះសង្ឃលោកទទួល ដោយតុណ្ហីភាព ហើយលោកសូត្រធម៌អនុមោទនា ដោយគាថាផ្សេងៗ មានគាថាសម្តែងពីកាលទាន ជាដើម។ លុះអនុមោទនាចប់ហើយ ឧបាសកគប្បីចូល


www.elibraryofcambodia.org

ទៅប្រគេនគ្រឿងបរិក្ខារជាបរិវារកឋិន ដល់ ព្រះសង្ឃគ្រប់អង្គ តាមលំដាប់លំដោយ ដរាប ដល់អស់សព្វគ្រប់ ហើយម្ចាស់ដើមបុណ្យ ឬតំណាង គប្បីបវារណាបច្ច័យ ជាលទ្ធផលដល់នៃបុណ្យកឋិនព្រោះព្រះសង្ឃ ។ ឯបច្ច័យជាលទ្ធផលនៃបុណ្យនោះ គប្បីចែកជាពីរចំណែក ១ចំណែក ប្រគេនចំពោះព្រះសង្ឃគ្រប់ព្រះអង្គ ចំណែក ១ ទៀត ចំពោះការកសាងវត្តអារាម។

ចំណែកឯបច្ច័ដែលគេប្រគេនចំពោះព្រះសង្ឃ គប្បីវារណាតាមពាក្យបវារណា ដូចក្នុងពិធីចម្រើនព្រះបរិត្តឯណោះគ្រប់តែចែកជាចំណែកៗ តាមថ្នាក់លោកអ្នកក្រាលគ្រង លោកអ្នកសូត្រញត្តិ លោកបរិស័ទអ្នកគង់ហត្ថបាស លោកសាមណេរតាមចំនួនច្រើនឬតិចប៉ុណ្ណោះ ។

ចំណែកឯបច្ច័យទុកកសាងអ្វីក្នុងអារាមនោះ គប្បីវារណាដូចតទៅ ៖

បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយមានសទ្ធាជ្រះថ្លា បានហែកឋិនមក។ លទ្ធផល នៃកឋិននេះ បានបច្ច័យចំនួន [51] រៀលសូមបវារណាចំពោះព្រះ សង្ឃ ដើម្បីកសាងនូវ[52] ក្នុងអារាម នេះ។ យើងខ្ញុំបានប្រគល់បច្ច័យចំនួន... ។

**១០- កិច្ចឧទ្ទិសផល**

បន្ទាប់ពីបវារណា ពីប្រគល់បច្ច័យដល់ដល់ គណៈកម្មការគប្បីនាំគ្នាសូត្រ យំកិញ្ចាំឧទ្ទិសផល[53] ជាកិចបង្ហើយបុណ្យ។

[51] រៀលនេះ ដល់គណៈកម្មការវត្តសម្រាប់កសាងនូវ...

[52] រៀលនេះ បើព្រះសង្ឃត្រូវការកសាងវេលាណា សូមឲ្យគណៈកម្មការវត្តចាត់ចែងប្រគេន ដរាបដល់អស់បច្ច័យនេះចុះ ដើម្បីសេចក្តីសុខចម្រើន ដល់យើងខ្ញុំទាំងឡាយផង អស់កាលអង្វែងទៅហោង។

[53] ពាក្យ យំកិញ្ចាំឧទ្ទិសផល គប្បីយកតាមពិធីចំម្រើនព្រះបរិត្តឯណ្ណោះ។



www.elibraryofcambodia.org

## ១៦
## ប្រពៃណីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និង សំពះព្រះខែ

### ១- ប្រពៃណីបុណ្យអុំទូក

បុណ្យអុំទូកមានកំណើតតាំងពីបូរមបុរាណដ៏យូរលង់ណាស់មកហើយ ដែលមានចែងក្នុងឯកសាររបស់ប្រវត្តិវិទូបរទេស ក៏ដូចជាសិលាចារឹកនៃប្រាសាទសម័យអង្គរ។ សូមបញ្ជាក់ថា កំណើត និងបំណងបុណ្យអុំទូកនេះមានការបកស្រាយប្លែកៗគ្នាជាច្រើន ហើយពិធីធ្វើក៏មានប្លែកៗគ្នាខ្លះដែរ។

អ្នកខ្លះយល់ថា ពិធីនេះទាក់ទងទៅនឹងការធ្វើចម្បាំងជើងទឹកដោយព្រះបាទជ័យវរ្ម័នទី ៧ នៅសម័យអង្គរ។ គេពន្យល់ថា នៅគ្រិស្តសតវត្សទី១២ កម្ពុជាមានសេចក្តីសុខក្សេមក្សាន្តរុងរឿងណាស់ ដោយសារព្រះបាទជ័យវរ្ម័នទី៧ ដែលបានកសាងយកព្រះទ័យទុកដាក់លើនយោបាយទឹក និង សង្គមកិច្ច ក៏ដូចជាការពារបូរណភាពទឹកដីដោយស្តេចចេញធ្វើសង្គ្រាមជើងទឹក បង្ក្រាបពួកចាម ដោយកងទ័ពទូក រំដោះក្រុងកម្ពុជាឲ្យរួចផុតស្រឡះចេញពីខ្មាំងសត្រូវ (គ.ស. ១១៧៧-១១៨១)។ រឿងចម្បាំងពេលនោះមានឆ្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន និងបន្ទាយឆ្មារ។

អ្នកខ្លះយល់ថា ពិធីនេះជាប់ទាក់ទងទៅនឹង ទាហានជើងទឹកសម័យលង្វែក។ នៅសម័យនោះ ព្រះអង្គចន្ទទី១ ទ្រង់តាំងពញាតាក ងារជាស្និទ្ធភូមិបាល ជាស្តេចត្រាញ់នៅកម្ពុជាក្រោម ស្រុកបាសាក់។ ស្តេចត្រាញ់នេះបានចាត់របៀបរៀបចំការពារស្រុកដោយទាហានជើងជាបីក្រុមគឺ៖

- ក្រុមទី១ ហៅទ័ពស្រួច ហាត់ច្បាំងដោយទូកដែលមានទ្រង់ទ្រាយដូចទូកប្រណាំងយើងសព្វថ្ងៃ។
- ក្រុមទី២ ហៅទ័ពជំនួយ ហាត់ច្បាំងដោយទូកចែវពីរជួរ ដែលមានទ្រង់ទ្រាយដូចទូកយើងប្រណាំងសព្វថ្ងៃ។



www.elibraryofcambodia.org

- ក្រុមទី៣ ហៅទ័ពបាសាក់ គឺទូកធំ មានដំបូល មានថែវមានក្តោង មានទ្រង់ទ្រាយដូចទូកបាសាក់ ហៅទូកប៉ុកចាយ តែរាងស្រួចវែងមានដំបូលតែមួយកាត់ខាងមុខឥតជញ្ជាំង។ ទូកនេះជា ទូកស្បៀងអាហារសម្រាប់ទ័ព។

ឯកសារខ្លះបាននិយាយថា ពិធីបុណ្យអុំទូក គឺជាបុណ្យប្រពៃណីជាតិដ៏ធំមួយនៅប្រទេស កម្ពុជា។ បុណ្យនេះមានរូបភាពប្រហាក់ប្រហែលនឹងបុណ្យប្រចាំរដូវរបស់ជនជាតិអឺរ៉ុប ដែលមានឈ្មោះថា *សាំងហ្សង់* ដែលបច្ចុប្បន្នប្រារព្ធធ្វើនៅអឺរ៉ុបខាងជើង។

មានការបកស្រាយមួយទៀត ដែលអាចយកជាការបានគ្រប់គ្រាន់ដែរ គឺថា ពិធីបុណ្យនេះ គេប្រារព្ធឡើង ក្នុងបំណងសម្តែងការដឹងគុណដល់ព្រះគង្គា និង ព្រះធរណីដែលបានផ្តល់ទឹកដី (ដែលយើងនាំគ្នាធ្វើឱ្យកករល្អក់) ជីវភាពរស់នៅ និងសុខមាលភាពដល់យើង។

ការបកស្រាយនេះជាប់ពាក់ព័ន្ធទៅនឹងជំនឿខាងព្រហ្មញ្ញសាសនា ប៉ុន្តែវាក៏ស្របទៅនឹងស្ថានភាពភូមិសាស្ត្រ និងជីភាពរស់នៅរបស់ប្រជាកសិករយើងដែរ។

ពិធីបុណ្យអុំទូកនេះប្រព្រឹត្តទៅនៅខែកត្តិក គឺស្របពេលដែលរដូវទឹកជំនន់កើតមាននៅក្នុងប្រទេសកម្ពុជា ដែលក្នុងរយៈពេលប៉ុន្មានខែមកហើយ បឹងបួទាំងឡាយក្លាយទៅជាសមុទ្រ ឯស្រូវក្នុងស្រែកំពុងទុំ។ ដំណាំទាំងឡាយ ដែលកសិករខ្មែរធ្វើតាមចង្វាក់នៃទឹកសម្រកបានផ្តល់នូវផលយ៉ាងច្រើន បង្ការគ្រោះទុរ្ភិក្ស និង ផ្តល់សុភមង្គលដល់ប្រជាជន។

ព្រោះហេតុនេះ ទើប នៅរដូវទឹកស្រក បុព្វបុរសខ្មែរយើងក៏កំណត់យកពេលបីថ្ងៃក្នុងខែកត្តិក រៀងរាល់ឆ្នាំ រៀបចំពិធីអុំទូក បណ្តែតប្រទីប សំពះព្រះខែ និង អកអំបុកដើម្បីសម្តែងមនោសញ្ចេតនា ដឹងគុណចំពោះទន្លេមេគង្គ និងទន្លេសាប ដែលបានផ្តល់ជីវជាតិយ៉ាងសំខាន់ បម្រើឲ្យវិស័យកសិកម្ម។

ពិធីបុណ្យនេះ គេតែងតែប្រារព្ធធ្វើអស់ថេរវេលា ៣ ថ្ងៃ គឺថ្ងៃ ១៤ កើត ១៥ កើត និង ថ្ងៃ ១រោច ខែកត្តិក ធ្វើនៅតាមទន្លេសាប នាកំពង់ផែមុខព្រះបរមរាជវាំង។



www.elibraryofcambodia.org

## ២ ប្រពៃណីបុណ្យបណ្ដែតប្រទីប

តាមទំនៀមទម្លាប់ធម្មតា អ្នកស្រុកនៅប្រទេសកម្ពុជាតែងធ្វើបុណ្យបណ្ដែតប្រទីប នៅថ្ងៃបវារណាចេញព្រះវស្សារបស់ព្រះសង្ឃ ប៉ុន្តែ នៅរាជធានី ព្រះមហាក្សត្រតែងប្រារព្ធធ្វើពិធីបុណ្យនេះ រួមជាពិធីបុណ្យអុំទូកសំពះព្រះខែ និងអកអំបុក ដែលរាប់បញ្ចូលក្នុងពិធីទ្វាទសមាស (ពិធីទាំង ១២ ខែ)។ រឿងបុណ្យបណ្ដែតប្រទីប គេពុំឃើញមាននិយាយទេនៅក្នុងគម្ពីរព្រះត្រៃបិដកនៃពុទ្ធសាសនា ប៉ុន្តែមានឃើញក្នុងរឿងព្រេងខ្មែរ ដែលនិទានទាក់ទងនឹងពុទ្ធសាសនាថា នៅខាងដើមនៃភទ្ទកប្ប យើងនេះមានសត្វក្អែកសញ្ជីឈ្មោល បានបញ្ចេញពងបាន ៥ តែពងទាំងនោះបានធ្លាក់ទៅក្នុងទឹកដោយខ្យល់ព្យុះ។ ក្អែកសញ្ជីឈ្មោលបានយំសោកបោកខ្លួនរហូតស្លាប់ ដោយសោកស្ដាយពងរបស់ខ្លួន ហើយក៏ទៅកើតជាព្រះឥន្ទក្នុងស្ថានសួគ៌ទេវលោក។ ចំណែកពងទាំង ៥ នោះបានធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃសត្វទាំង ៥ មាន *មាន់ ស្ដេចនាគ អណ្ដើក គោ* និង *ខ្លា* ។ សត្វទាំងនេះបានរើស យកពងទៅចិញ្ចឹម រហូតកើតមកសុទ្ធតែមនុស្សប្រុសទាំង ៥។ លុះធំពេញវ័យ កូនទាំង ៥ បានលាមាតា បិតាជាសត្វ ទៅសាងកុសលដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធរៀងៗខ្លួន។ សត្វទាំងនោះក៏បានអនុញ្ញាត ប៉ុន្តែបានធ្វើសំណូមពរថា បើកូនចេញទៅកសាងពុទ្ធភូមិ បានត្រាស់ពេលណា សូមធ្វើឈ្មោះរបស់យើងឲ្យទៅជាប់នឹងឈ្មោះរបស់អ្នកផង។ ហេតុនេះ ទើបព្រះនាម ព្រះពុទ្ធទាំង ៥ ព្រះអង្គ ដែលបានត្រាស់ និង ត្រូវត្រាស់ក្នុងភទ្ទកប្បនេះ ជា **កកុសន្ធោ** (ប្រែថា មាន់) **គោនាគមនោ** (ប្រែថា នាគ) **កស្សបោ** (ប្រែថាអណ្ដើក) **គោតមោ** (ប្រែថា គោ) និងព្រះ **សិអារ្យមេត្តេយ្យ** (ប្រែថាខ្លា)។ ថ្ងៃងពីមាណពទាំង ៥ កាលបានជួបគ្នានៅកន្លែងមួយ ដោយមានគោលបំណងដូចគ្នា ក៏សុំគ្នាធ្វើជាបងប្អូន ហើយជជែកគ្នារកមាតាបិតាដើម។ ក្អែសកញ្ជីឈ្មោល ជាមាតាបិតា ដែលបានកើតជាព្រះឥន្ទ និងព្រះទេពីនោះ ក៏ចុះមកដំណាលរឿងនេះប្រាប់ដល់មាណពទាំង ៥ ថា មាតាបិតា ដើមរបស់អ្នកគឺយើងនេះឯង ដែលពីមុនគឺជាសត្វក្អែកសញ្ជីឈ្មោល។ ព្រះឥន្ទ និងអគ្គមហេសីបានផ្ដាំថា បើកូនរាល់គ្នានឹកអាល័យយើង ចង់បូជាអ្វីដល់យើងទាំងពីរនាក់ ចូរកូនគូស



www.elibraryofcambodia.org

ខ្វែងជើងក្អែក នៅគ្រប់វត្ថុដែលជាសំណែននោះ ហើយឧទ្ទិសដល់យើងទៅ។ មាណព ទាំង ៥ បានបួសជាតាបស ហើយបានគូសសញ្ញាជើងក្អែកនៅលើវត្ថុសំណែន សែនរួច ក៏បណ្ដែតតាមខ្សែទឹកហូរទៅ ដើម្បីបូជា ក្អែកសញ្ជីឈ្មោល រហូតជាប់ជាទំនៀមទម្លាប់ បណ្ដែតប្រទីបមកដល់សព្វថ្ងៃនេះ។ ចាស់បុរាណ ពោលថា រឿងនេះដកស្រង់តាមរឿង សាស្ត្រាក្អែកសញ្ជីឈ្មោល ហើយសាស្ត្រានេះមានយូរមកហើយ ដូចគ្នានឹងគម្ពីររតនសង្គ្រោះ និងគម្ពីរពុទ្ធវង្ស។

ចំពោះរឿងបណ្ដែតប្រទីបនេះ អ្នកស្រុកខ្លះអះអាងថា គេធ្វើពិធីបណ្ដែតប្រទីបនេះ ដើម្បីឧទ្ទិសបូជាចំពោះស្នាមព្រះពុទ្ធបាទ និងព្រះចង្កូមកែវ ដែលប្រតិស្ឋាននៅនាពិភពនាគ។ ខ្លះថា ការបណ្ដែតប្រទីបគឺឧទ្ទិសចំពោះព្រះចូឡាមណីចេតិយដែលស្ថិតនៅឋានត្រៃត្រិង្ស ហើយថា រឿងក្អែកសញ្ជីឈ្មោលដែលជាមាតាបិតាដើមរបស់ព្រះពុទ្ធទាំង ៥ ព្រះអង្គ ក្នុងឯកទ្ទកប្ប នាំឲ្យកើតការបណ្ដែតប្រទីប ដើម្បីឧទ្ទិសដល់សត្វក្អែកស នោះ ចាត់ថា ជារឿងមានហេតុអស្ចារ្យ ពុំអាចជឿបាន។

### ៣- ប្រពៃណីបុណ្យអកអំបុក-សំពះព្រះខែ

គេប្រារព្ធពិធីអកអំបុក និង សំពះព្រះខែ នៅយប់ថ្ងៃ ១៥ កើត ពេញបូរមី ខែកត្ដិក។ ប្រពៃណីនេះជាប់ទាក់ទងនឹងព្រះពុទ្ធសាសនា ដោយមានសេចក្ដីដំណាល ថា កាលព្រះពោធិសត្វយោនយកកំណើតជាសត្វទន្សាយ នៅថ្ងៃពេញបូណ៌មី បានក្រឡេកឃើញព្រះចន្ទពេញវង់ ក៏មានចិត្តជ្រះថ្លា ចង់ដាក់ទានជីវិត។ ពេលនោះ ព្រះឥន្ទបាននិម្មិតជាព្រាហ្មណ៍ចាស់ម្នាក់ មកសុំសាច់ទន្សាយពោធិសត្វ។ ដើម្បីបំពេញទានទន្សាយ ពោធិសត្វក៏លោតចូលក្នុងភ្លើង។ រំពេចនោះភ្លើងក៏រលត់អស់។ ឃើញហេតុអស្ចារ្យ ដូចនេះ ឥន្ទព្រាហ្មណ៍ក៏ហោះទៅយកកែវមុណីសិលា ១ ដុំ ទៅគូររូបទន្សាយ ក្នុងវង់ ព្រះចន្ទនោះទៅ។

ព្រោះរឿងនេះ ទើបអ្នកខ្លះពោលថា ឃើញដូចជារូបទន្សាយនៅក្នុងវង់ព្រះចន្ទ។ ការគោរពព្រះចន្ទ ឬសំពះព្រះខែ ក៏មានមករហូតមកដល់សព្វថ្ងៃនេះ ។ ការសំពះព្រះខែ កាលពីដើម គេធ្វើនៅសក្យមុនីចេតិយ គឺគេធ្វើពីថ្ងៃ ១៥ កើត ខែកត្ដិក ជាថ្ងៃ



www.elibraryofcambodia.org

ពេញបូណ៌មី។ គ្រឿងសក្ការៈបូជាសម្រាប់ព្រះខែ និង រូបទន្សាយពោធិសត្វដែលស្ថិតនៅក្នុងវង់ព្រះចន្ទ គឺអំបុក ចេក ដូង ។ ពេលជាមួយគ្នានោះ ក៏មានការអុជទៀនធូបថ្វាយព្រះរតនត្រ័យ និងនឹកដល់ទេវតា។

បុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និង សំពះព្រះខែនេះ ជាពិធីទំនៀមទម្លាប់របស់ខ្មែរសម្រាប់ចងភ្ជាប់ចិត្តគំនិតឲ្យសប្បាយរីករាយជាមួយគ្នា។

ទោះបីជាប្រវត្តិពិធីបុណ្យទាំងបីនេះ មានរឿងទាក់ទងនឹងសាសនាព្រាហ្មណ៍ខ្លះក៏ដោយ ក៏ពិធីបុណ្យទាំងបីនេះក្លាយជាប្រពៃណីដ៏មានប្រជាប្រិយភាព សម្រាប់ប្រជាពលរដ្ឋខ្មែរទៅហើយ។ ពុទ្ធសាសនាគ្រាន់តែឲ្យយោបល់ថា អំពើគ្រប់យ៉ាង ដែលមានប្រយោជន៍ គឺជាអំពើបណ្តុះគុណធម៌ និងសាមគ្គីធម៌។



ចម្លាក់នៅប្រាសាទបាយ័ន៖ ទូកមករ និង ទ័ពជើងទឹកសម័យអង្គរ



www.elibraryofcambodia.org

# គន្ថនិទ្ទេស


ក. ផាន់៖ *ក្បួនរើសរកឈ្មោះ*, បោះពុម្ពឡើងវិញ, ភ្នំពេញ, ឆ្នាំ២០០៤។

កែវ ណារុំ៖ *តន្ត្រីនិងជីវិតខ្មែរ*, បោះពុម្ពលើកទី១, រោងពុម្ពមិត្តភាពកម្ពុជា-ជប៉ុន, ភ្នំពេញ ឆ្នាំ១៩៩៥។

កែប វ៉ាន់ឌី៖ *វប្បធម៌ខ្មែរ-មន*, ភ្នំពេញ, ១៩៧១។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ *ព្រះរាជពិធីទ្វាទសមាស*, ភាគទី៣, ពុទ្ធសាសនបណ្ឌិត្យ, ឆ្នាំ១៩៦០។

ខៀវ ជុំ៖ *សាកលចិន្តា*, បណ្ណាគារត្រៃរតន៍, ភ្នំពេញ, ឆ្នាំ១៩៧២ ។

គង់ អាំ៖ *ពុទ្ធប្បវត្តិអមដោយរូបភាព* ខ្មែរ-អង់គ្លេស (បកប្រែពីស្នាដៃជាភាសាថៃរបស់ ភិក្ខុ គុណប៉យុតា), The Corporate Body of the Buddha Educational Foundation, ២០០១ ។

ឃុន សាម៉េន៖ *មគ្គុទ្ទេសក៍ថ្មី សំរាប់មន្ទីរជាតិ-ភ្នំពេញ*, បោះពុម្ពលើកទី១,រោងពុម្ពវិចិត្រសិល្បៈ, ភ្នំពេញ, ២០០២។

ងួន ញ៉ិល៖ *ព្រលឹងមាតាធិបតេយ្យក្នុងសង្គមខ្មែរ*, បោះពុម្ពដោយក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ឆ្នាំ២០០០។

ចក់ កន៖ *នានាធម្មសង្គហៈ* , រោងពុម្ព?, ឆ្នាំ?

ចាប ពិន និង អ្នកឯទៀត៖ *របាំប្រជាប្រិយខ្មែរ*, បោះពុម្ពលើកដំបូង, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ១៩៦៤។

ធឹង ចាន់សុផុន៖ *បុណ្យទំនៀមខ្មែរ* ភាគ ២, បោះពុម្ពលើកទី ១, ឆ្នាំ២០០០ ។

_____៖ *បុណ្យទំនៀមខ្មែរ* ភាគ ៣, បោះពុម្ពលើក ១, ឆ្នាំ២០០០ ។

ឆេង ផុន និង ពេជ្រទុំក្រវិល៖ *តន្ត្រី របាំ និង ល្ខោនខ្មែរ*, ភ្នំពេញ, ២០០៦ ។

ឈិន យួន៖ *ជំនឿផ្សេងៗនៃជនជាតិខ្មែរ* ភ្នំពេញ, ឆ្នាំ១៩៩៩ ។

ញាណ គឿន និង ម៉ម ឆែ៖ *លំអានទំនៀមខ្មែរបុរាណ (ទម្លាប់អាចារ្យ)* ភ្នំពេញ,




www.elibraryofcambodia.org

ឆ្នាំ២០០៧។
ត្រឹង ងា៖ *អរិយធម៌ខ្មែរសម្រាប់ថ្នាក់ទីបញ្ចប់* , បោះពុម្ពលើកទី៣, ឆ្នាំ១៩៧៥។
ទៀ ថេន៖ *តម្រាដាក់ឈ្មោះឱ្យបុត្រធីតា: នាមគ្គហណមង្គល* ,បោះពុម្ពលើកទី៣, រោងពុម្ពឥន្ទ្រទេវី, ភ្នំពេញ ឆ្នាំ២០០៦។
ពុទ្ធសាសនបណ្ឌិត្យ៖ *វចនានុក្រមខ្មែរ ភាគ១-២* បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៨។
មៀច ប៉ុណ្ណ៖ *កម្រងឯកសារប្រពៃណី និង ទំនៀមទម្លាប់ខ្មែរ* ភាគទី១, បោះពុម្ពលើកទី ២, ភ្នំពេញ, ឆ្នាំ២០០១។
មៀច ប៉ុណ្ណ៖ *ក្រមុំចូលម្លប់* បោះពុម្ពដោយបណ្ណាគារអង្គរ ភ្នំពេញ ឆ្នាំ២០០៧។
លី សុវីរ៖ *អាពាហ៍ពិពាហ៍ខ្មែរប្រៀបធៀប ពីសម័យបុរាណនិងសម័យបច្ចុប្បន្ន* ភាគ ១-២ ភ្នំពេញ, ឆ្នាំ២០០៨។
_____៖ *អាពាហ៍ពិពាហ៍ខ្មែរ* ភាគ១ និង ភាគ២ បោះពុម្ពលើកទី ១ ឆ្នាំ២០០៤ ។
_____៖ *ពិធីបុណ្យខ្មោច សតវត្សទី ១៩ និងដើមសតវត្សទី ២០*, ភ្នំពេញ, ឆ្នាំ១៩៩៤។
ស៊ីសុវត្ថិ ប៊ូរក្នុស៊ី៖ *បរិវារស័ព្ទក្នុងភាសាខ្មែរ* សមាគមសម្តេចជួនណាត ភ្នំពេញ ឆ្នាំ១៩៧២។
សុង ស៊ីវ៖ *ចលនាអារ្យធម៌* , បោះពុម្ពឡើងវិញ, ឆ្នាំ២០០៥ ។
_____៖ *ជំនឿចាស់ មនុស្សថ្មី* បោះពុម្ពលើកទី១ ឆ្នាំ១៩៩៦។
_____៖ *ពុទ្ធសាសនា និង វិទ្យាសាស្ត្រក្នុងវិចារណកិច្ច (ទស្សនវិជ្ជា តក្កវិជ្ជា វិទ្យាសាស្ត្រ)* , បោះពុម្ព លើកទីពីរ, បណ្ណាគារគីម គី, ភ្នំពេញ, ឆ្នាំ១៩៧២ ។
សូ មុយឃៀង, ទិត សៀង និង ជា ឈិន៖ *អរិយធម៌ខ្មែរ*, បោះពុម្ពលើកទី ១, សាកលវិទ្យាល័យ ជាតិគ្រប់គ្រង, ឆ្នាំ២០០៨។
ហង់ ពៅ៖ *ទំនៀមទម្លាប់កោរជុក* (សិក្ខាសាលានៅមជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-ជប៉ុន ឆ្នាំ២០០៨)។
ហួត តាត៖ *ព្រះពុទ្ធសាសនានៅកម្ពុជាសង្ខេប*, ឆ្នាំ១៩៧០ ។



www.elibraryofcambodia.org

ឡុច ផ្លែង៖ *ប្រជុំវប្បធម៌*, បោះពុម្ពសាជាថ្មី, ភ្នំពេញ, ២ មិថុនា ២០០៤។

អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, និង ស៊ុន ចាន់ដឹប៖ *ដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យ* ការផ្សាយរបស់ហនុមានទេសចរណ៍, បោះពុម្ពលើកទី១, ភ្នំពេញ ឆ្នាំ២០០៧ ។

អាំង ជូនលាន, ព្រាប ចាន់ម៉ារ៉ា, និង ស៊ីយ៉ុន សុភារិទ្ធិ៖ *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ* លេខ១ ខែធ្នូ ២០០៥- ខែធ្នូ ២០០៦។

Roony Dawn F.: *Angkor*, fourth edition, Airphoto International Ltd., Hong Kong, 2002.

Keo Chanbo: www.keochanbo.com, 08 December 2012.

Microsoft Encarta 2009. *Encarta Premium DVD*. CD-ROM. Redmond, WA: Microsoft Corporation 2008



www.elibraryofcambodia.org

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ
មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ
ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេនជា eBook ដោយ ម៉ក់ ឈុនលាង
ខែឧសភា ឆ្នាំ២០១៧
បើលោក លោកស្រី ចង់បានសៀវភៅនេះ ឬអានបន្តទៀត
សូមទិញ ឬជាវពីអ្នកនិពន្ធ
ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធ" របស់អ្នកនិពន្ធ។
យើងខ្ញុំ ពុំមានការប្រស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយ
អ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ
ខ្មៅ យុនសំរ៉ង
ប្រធានមូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

www.elibraryofcambodia.org



9 789996 376405

www.elibraryofcambodia.org